កម្រងអត្ថបទជ្រើសរើស

# សិក្សាតំបន់អាស៊ីអាគ្នេយ៍



# អាស៊ីអាគ្នេយ៍សម័យបច្ចុប្បន្ន

*បកប្រែពីភាសាអង់គ្លេសដោយ*

*មួង ណារ៉េត និង ភី សុភាដា*

## CONTEMPORARY SOUTHEAST ASIA

Translated from English by MUONG Nareth and PHI Sopheada

ជំពូកទី ១ ៖ ឧស្សាហូបនីយកម្មនិងការជះឥទ្ធិពល

ជំពូកទី ២ ៖ ឥទ្ធិពលនៃ « អព្ភូតហេតុ » សេដ្ឋកិច្ចទៅលើមនុស្ស

អត្ថបទនេះដកស្រង់ចេញពីសៀវភៅ ៖ **ការកកើតអាស៊ីអាគ្នេយ៍ទំនើប** ។

រក្សាសិទ្ធិ គ.ស. ២០០៥ ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យសិង្ហបុរី ។

បោះពុម្ពលើកទី ១ គ.ស. ២០០៥ នៅសហរដ្ឋអាមេរិក ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យហាវ៉ៃ ។

**Chapter 1: Industrialization and Its Implications**

**Chapter 2: Human Consequences of the Economic "Miracle"**

**Seleted from: The emergence of Modem Southeast Asia,**

**Copyright © 2005 by Singapore University Press.**

**First published in 2005 by University of Hawai'i Press.**

ជំពូកទី ៣ ៖ រាជាធិបតេយ្យអាស្រ័យបណ្ដាញ និងវិបត្តិភាពស្របច្បាប់នៅក្នុងប្រទេសថៃ

អត្ថបទនេះដកស្រង់ចេញពី **ព្រឹត្តិបត្រប៉ាស៊ីហ្វិក**

រក្សាសិទ្ធិ គ.ស. ២០០៥ ដោយក្រុមថៃល័រនិងហ្វ្រង់ស៊ីស ។

**Chapter 3: Network Monarchy and Legitimacy Crises in Thailand**

**Seleted from: *The Pacific Review,* Vol. 18 No.4 December 2005**

**Copyright © 2005 by Taylor & Francis Group.**

ជំពូកទី ៤ ៖ របៀបដែលជនជាតិវៀតណាមសម្លឹងមើលពិភពលោក

អត្ថបទនេះដកស្រង់ចេញពីសៀវភៅ ៖ **ស្វែងយល់ពីវៀតណាម**

រក្សាសិទ្ធិ គ.ស. ១៩៩៣ ដោយ ឌី រីហ្សិនត្ស៍ អហ្វ ឌី យូនីវ៉ឺរស៊ីធ អហ្វ ខាលីហ្វ័រនៀ។

**Chapter 4: How the Vietnamese See the World**

**Seleted from: Understanding Vietnam**

**Copyright © 1993 by The Regents of The University California.**

អត្ថបទស្រាវជ្រាវ

ជំពូកទី ៥ ៖ ទស្សនៈរបស់ខ្មែរចំពោះជនជាតិភាគតិចវៀតណាម

ស្រាវជ្រាវនិងនិពន្ធដោយ ៖ ឈាត ស្រ៊ាង

ជានិស្សិតចូលរួមក្នុងកម្មវិធី **បណ្ដុះបណ្ដាលសមត្ថភាពថ្នាក់ឧត្តមសិក្សា** ជំនាន់ទី ១ ដែលរៀបចំដោយ មជ្ឈមណ្ឌលខេមរសិក្សា ក្រោមការឧបត្ថម្ភរបស់មូលនិធិ រ៉ក្គីហ្វេល្ល័រ ។

រក្សាសិទ្ធិក្នុងការបកប្រែនិងចេញផ្សាយជាភាសាខ្មែរ © គ.ស. ២០០៧ ដោយមជ្ឈមណ្ឌលខេមរសិក្សា ។

**Copyright © 2007 Center for Khmer Studies for the Khmer translation.**

**រូបភាពក្របមុខដោយ** ◢ Cover picture

លោក ធិម វិន្ទ័រ (រក្សាសិទ្ធិ) គ.ស. ២០០៧ Copyright © 2007 Tim WINTER.

ការបកប្រែនិងបោះពុម្ពសៀវភៅនេះ ទទួលបានការឧបត្ថម្ភពីមូលនិធិ រ៉ក្គីហ្វេល្ល័រ នៅញូយ៉ក ។

**The publication of this book was supported by the Rockefeller Foundation (New York).**

លសខអ ១៣ ៖ ៩៧៨-៩៩៩៥០-៥១-០៥-១ ISBN-13: 978-99950-51-05-1

បោះពុម្ពនៅប្រទេសកម្ពុជាដោយរោងពុម្ព ពន្លឺខ្មែរ ។ **Printed in Cambodia by Ponleu Khmer Printing & Publishing House.**

# សារបណ្ណ


*កថាមុខ ៧*

**ជំពូកទី ១ ៖ ឧស្សាហូបនីយកម្មនិងការជះឥទ្ធិពល** ៩

*ការប្រឈមមុខក្នុងការអភិវឌ្ឍនាសម័យក្រោយសង្គ្រាម ១១*

*គំរូរបស់ប្លុកប្រទេសនិងបស្ចិមប្រទេស ១៧*

*ការចូលរួមចំណែករបស់ជនជាតិចិនរស់នៅតំបន់អាស៊ីអាគ្នេយ៍ ២៤*

*តម្លៃនៃការធ្វើបដិវត្តន៍ឧស្សាហកម្ម ២៨*

*វិបត្តិសេដ្ឋកិច្ចឆ្នាំ ១៩៩៧ និងលទ្ធផលរបស់វិបត្តិនេះ ៣០*

*ប្រវត្តិប្រកបដោយជោគជ័យរបស់អាស៊ាន ៣២*

**ជំពូកទី ២ ៖ ឥទ្ធិពលនៃ «អព្ភូតហេតុ» សេដ្ឋកិច្ចទៅលើមនុស្ស** ៣៥

*ឥទ្ធិពលវិជ្ជមាន ៣៧*

*ឥទ្ធិពលអវិជ្ជមាន ៤០*

*ការបំផ្លិចបំផ្លាញបរិស្ថានធម្មជាតិ ៤៦*

*ដំណោះស្រាយជាមួយនឹងភាពទំនើប ៖ ឥរិយាបថនិងការរិភាគ ៤៧*

*ដំណោះស្រាយជាមួយនឹងភាពទំនើប ៖ សកម្មភាព ៥០*

**ជំពូកទី ៣ ៖ រាជាធិបតេយ្យអាស្រ័យបណ្ដាញ និងឧបត្ថភាពស្របច្បាប់នៅក្នុងប្រទេសថៃ** ៥៣

*សេចក្ដីផ្ដើម ៥៥*

*ការកំណត់ន័យលើនយោបាយថៃ ៥៦*

*ដំណើរវិវឌ្ឍរបស់រាជាធិបតេយ្យអាស្រ័យបណ្ដាញ ៦០*

*រាជាធិបតេយ្យអាស្រ័យបណ្ដាញនិងវិបត្តិភាពស្របច្បាប់ចាប់តាំងពីឆ្នាំ ១៩៩២ ៦៩*

*លោក ប្រេម និងវិបត្តិនៃភាពស្របច្បាប់ ឆ្នាំ ១៩៩៧ ៧០*

*លោក ប្រេម និងវិបត្តិតុលាការធម្មនុញ្ញ ឆ្នាំ ២០០១ ៧៣*

*រាជាធិបតេយ្យនិងតំបន់ភាគខាងត្បូង ៧៥*

*សេចក្ដីសន្និដ្ឋាន ៖ ការផ្លាស់ប្ដូរមុខមាត់ថ្មីនៃរាជាធិបតេយ្យអាស្រ័យបណ្ដាញ ៧៨*

**ជំពូកទី ៤ ៖ របៀបដែលជនជាតិវៀតណាមសម្លឹងមើលពិភពលោក** ៨១

*ទឹកដីប្រទេសវៀតណាម ៖ បរិស្ថានធម្មជាតិជាប្រវត្តិសាស្ត្រ ៨៥*

*ប្រជាជននៅប្រទេសវៀតណាម ៨៧*

*ទស្សនៈជាប្រពៃណីរបស់ជនជាតិវៀតណាមចំពោះពិភពលោក ៩២*

*សង្គមវៀតណាមជាប្រព័ន្ធមួយនៃធាតុយិនយ៉ាំង ៩៣*

*គុណតម្លៃ និងទំនៀមទម្លាប់បុរាណរបស់ជនជាតិវៀតណាម ៩៥*

*ភាពសមហេតុផល ៩៧*

*ការគោរពខ្លាចឪពុកម្ដាយ និងការដឹងគុណ ៩៧*

*ទំនាក់ទំនងរវាងបងប្អូនប្រុស ៩៧*

*តួនាទីរបស់ភេទនីមួយៗ ៩៨*

ផ្លូវត្រូវ ៩៩
អារម្មណ៍និងមនោសញ្ចេតនា ១០០
ភាពសុខដុមមិនដាក់លាក់ ហើយនិងភាពសុខដុមពេញលេញ ១០១
អនុបវាទហើយនិងការចូលរួម ១០២
អំណាចនៃក្រឹត្យក្រមធម្មជាតិ ១០៣
គ្រួសារ ៖ ក្រឹត្យក្រមធម្មជាតិនៅក្នុងអតិសុខុមលោក ១០៣
អាពាហ៍ពិពាហ៍ ១០៦
បុណ្យតិត ៖ ពិធីបុណ្យប្រចាំឆ្នាំរបស់គ្រួសារ ១០៨
ភូមិឋានបែបបុរាណរបស់ជនជាតិវៀតណាម ១០៩
ស្ថានភាពនៃឋានានុក្រមក្នុងភូមិ ៖ សាមគ្គីភាព និងការប្រកួតប្រជែង ១១០
ឋានានុក្រម និងសេដ្ឋកិច្ច «កិត្យានុភាព» ១១១
សេដ្ឋកិច្ចល្មមតែបង្គ្រប់ការចិញ្ចឹមជីវិត ១១៣
សេដ្ឋកិច្ចនយោបាយយិនយ៉ាំង ១១៦
ផ្នែកយិននៃសាសនាក្នុងភូមិ ១១៦
ការរួមបញ្ចូលក្នុងប្រទេសជាតិ ១១៧
ជោគជ័យនិងបរាជ័យនៃប្រព័ន្ធបែបបុរាណ ១២០
**ជំពូកទី ៥ ៖ ទស្សនៈរបស់ខ្មែរចំពោះជនជាតិភាគតិចវៀតណាម ១២៣**
មូលន័យសង្ខេប ១២៥
សេចក្ដីផ្ដើម ១២៦
ការមិនជឿទុកចិត្តដែលប្រវត្តិសាស្ត្របានបន្សល់ទុក ១២៧
មេរៀនដែលគេពុំដែលបំភ្លេច ១២៨
«យួន» ជាពាក្យជេរបន្ថោកដល់សត្រូវរបស់ជាតិខ្មែរ ១៣១
ការប្រើប្រាស់វោហារសាស្ត្រប្រឆាំងវៀតណាមដោយអ្នកនយោបាយខ្មែរ ១៣៣
បញ្ហាអន្តោប្រវេសន៍និងបញ្ហាព្រំដែនដែលមិនចេះចប់ ១៣៣
អសមត្ថភាពរបស់រដ្ឋាភិបាលកម្ពុជាក្នុងការដោះស្រាយរាល់បញ្ហាខាងលើ ១៣៥
ការស្វែងរកប្រជាប្រិយភាពនិងអំណាចនយោបាយ ១៣៧
លក្ខណៈសម្គាល់ខ្លះរបស់វៀតណាមនៅកម្ពុជា ១៣៨
ភាសា ១៣៨
ការប្រកបរបរចិញ្ចឹមជីវិត ១៣៩
សម្លៀកបំពាក់និងរូបរាងខាងក្រៅ ១៤១
សេចក្ដីសន្និដ្ឋាន ១៤២
**កំណត់ចំណាំ ១៤៥**

# សេចក្តីថ្លែងអំណរគុណ

គេបាននិយាយអំពីបញ្ហាបន្ទាន់ជាច្រើនដែលចាំបាច់ ដើម្បីកែលំអរនិងពង្រឹងប្រព័ន្ធអប់រំនៅប្រទេសកម្ពុជា ។ បញ្ហាមួយក្នុងចំណោមបញ្ហាដ៏ចម្បងដទៃទៀត ដែលការអប់រំថ្នាក់ខ្ពស់របស់កម្ពុជាសព្វថ្ងៃកំពុងប្រឈមមុខនោះ គឺការខ្វះខាតឯកសារសិក្សាជាភាសាខ្មែរ ។ ការខ្វះខាតនេះ មានសភាពកាន់តែធ្ងន់ធ្ងរ នៅពេលដែលសាកលវិទ្យាល័យជាច្រើន មានទាំងសាកលវិទ្យាល័យរដ្ឋនិងឯកជន បានផ្តល់នូវការអប់រំមិនត្រឹមតែថ្នាក់បរិញ្ញាប័ត្រទេ ថែមទាំងថ្នាក់អនុបណិតនិងថ្នាក់បណិតទៀតផង ។ ហើយសៀវភៅឯកសារស្ទើរតែទាំងអស់ ដែលផ្តល់សម្រាប់ការសិក្សាស្រាវជ្រាវក្នុងលំដាប់ថ្នាក់ទាំងនោះ គឺសុទ្ធសឹងតែសរសេរឡើងជាភាសាអង់គ្លេស ប៉ុន្តែ ផ្ទុយទៅវិញ និសិត្សកម្ពុជាមិនទាន់ចេះភាសាអង់គ្លេសបានល្អស្ទាត់ជំនាញ ដើម្បីស្វែងយល់នៅក្នុងកម្រិតខ្ពស់បែបនោះទេ ។ មកដល់ពេលនេះ ការបកប្រែសៀវភៅជាច្រើនបានផ្តោតលើតែវិស័យបច្ចេកទេសប៉ុណ្ណោះ ។

មជ្ឈមណ្ឌលខេមរសិក្សា បានព្យាយាមអនុវត្តគម្រោង ។ បណ្តុះបណ្តាលការបកប្រែភាសា ដើម្បីបោះពុម្ពផ្សាយឯកសារបកប្រែនៅក្នុងវិស័យសង្គមសាស្ត្រ និងដើម្បីបណ្តុះបណ្តាលអ្នកបកប្រែខ្មែរជំនាន់ក្រោយ ៗ ទៀត ។ ចាប់ផ្តើមពីការធ្វើសិក្ខាសាលារយៈពេលមួយសប្តាហ៍ ស្តីអំពីទ្រឹស្តីបកប្រែ ហើយនិងការអនុវត្ត មជ្ឈមណ្ឌលខេមរសិក្សាបានបង្កើតជាក្រុមស្នូលមួយឡើង សម្រាប់បកប្រែ អត្ថបទ ដែលជ្រើសរើសចេញពីកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់ឧត្តម-សិក្សា ។ សៀវភៅមួយក្បាលនេះ គឺជាលទ្ធផលនៃការងារបកប្រែ ដែលបានមកពីការជជែកពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់ និងពីការខិតខំប្រឹងប្រែងរបស់សមាជិកក្រុមអ្នកបកប្រែ អស់រយៈពេលជាច្រើនខែ ។

សៀវភៅនេះ ពិតជាមិនអាចលេចជារូបរាងឡើងបានទេ ប្រសិនបើគ្មានការឧបត្ថម្ភពីសំណាក់មូលនិធិរ៉ុក្វីហ្វេល្ល័រ វិទ្យាស្ថានសង្គមបើកទូលាយ អ្នកផ្តល់ជំនួយដទៃទៀត ហើយនិងការប្តេជ្ញាចិត្តរបស់អ្នកបកប្រែទាំងនោះ ។

# កថាមុខ

ក្នុងឆ្នាំ២០០៤ មជ្ឈមណ្ឌលខេមរសិក្សាបានចាប់ផ្ដើមដំណើការកម្មវិធីមួយ ឈ្មោះថា «កម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនថ្នាក់ឧត្តមសិក្សា» ដោយផ្ដោតយ៉ាងសំខាន់ទៅលើការបណ្ដុះបណ្ដាលគ្រូបង្រៀនវ័យក្មេងនៅតាមសាកលវិទ្យាល័យនានា ក្នុងគោលបំណងពង្រីកភាពជំនាញរបស់គ្រូខាងការស្រាវជ្រាវនិងការបង្រៀន នៅក្នុងវិស័យសង្គមសាស្ត្រនិងមនុស្សសាស្ត្រ ។ កម្មវិធីនេះបានទទួលការឧបត្ថម្ភពីមូលនិធិរ៉ក្លឺហ្វេល្ល័រ ហើយបានអនុវត្តឡើងជាវគ្គសិក្សា ដែលក្នុង ១ វគ្គ។ មានរយៈពេល ៦ ខែ ។ ក្នុង ១ វគ្គសិក្សា សាស្ត្រាចារ្យដែលទទួលការអញ្ជើញពីកម្មវិធីនេះ ១ រូប ធ្វើជាអ្នកដឹកនាំវគ្គ ។ សកម្មភាពរៀនសូត្រនិងស្រាវជ្រាវក្នុងរាល់វគ្គសិក្សា ផ្ដោតលើប្រធានបទមួយទាក់ទងនឹងប្រទេសកម្ពុជាសម័យទំនើប ។ យើងខ្ញុំបានធ្វើការជាមួយអ្នកតំណាងមកពីសាកលវិទ្យាល័យនៅកម្ពុជា ដើម្បីកំណត់ប្រធានបទសម្រាប់វគ្គនីមួយ។ ក្នុងគោលបំណងទាក់ទាញអ្នកចូលរួមដែលមានជំនាញផ្សេងៗគ្នា ។ ប្រធានបទនីមួយ។ មានបញ្ចូលទាំងទស្សនវិស័យប្រៀបធៀប ដែលក្នុងនោះ មានការសិក្សាអំពីប្រទេសកម្ពុជាជាមួយប្រទេសជិតខាងពោលគឺប្រទេសថៃនិងប្រទេសវៀតណាម ។ នៅរាល់វគ្គសិក្សានីមួយ។ យើងមានសកម្មភាពជាច្រើន ដូចជា សិក្ខាសាលា បាឋកថា ការចុះធ្វើកម្មសិក្សានៅតាមបណ្ដាប្រទេសជិតខាង ការចុះស្រាវជ្រាវរបស់អ្នកចូលរួមម្នាក់។ ហើយនិងសន្និសីទជាលក្ខណៈអន្តរជាតិមួយដែលផ្ដោតលើមូលបទរបស់វគ្គសិក្សានោះ ។ ជាចុងបញ្ចប់នោះ សាស្ត្រាចារ្យដែលទទួលការអញ្ជើញ ជ្រើសរើសអត្ថបទសំខាន់។ មួយចំនួន ដើម្បីឲ្យអ្នកចូលរួម បកប្រែទៅជាភាសាខ្មែរ ។ សកម្មភាពចុងក្រោយនេះ បានបង្កើតឡើងដោយសារតែយើងខ្ញុំមើលឃើញថា មានការខ្វះខាតឯកសារសិក្សាជាភាសាខ្មែរនៅក្នុងវិស័យឧត្តមសិក្សា និងដោយសារយើងខ្ញុំមានគោលបំណងបណ្ដុះបណ្ដាលអ្នកបកប្រែភាសាជំនាន់ក្រោយផង ។

ក្នុងសៀវភៅវគ្គសិក្សាទី ១ នេះ មានអត្ថបទចំនួន ៤ ជ្រើសរើសដោយលោកសាស្ត្រាចារ្យ ដឹងខិន ម៉ាក់ខារហ្គូ (Duncan McCargo) ជាបណ្ឌិតខាងវិទ្យាសាស្ត្រនយោបាយនៃសាកលវិទ្យាល័យលីឌស៍ រាជាណាចក្រអង់គ្លេស ។ អត្ថបទទាំងបួនដែលគ្របដណ្ដប់កម្មវិធីសិក្សានៃវគ្គទី ១ នេះ និយាយអំពី «តំបន់អាស៊ីអាគ្នេយ៍ដ៏គោគនាពេលបច្ចុប្បន្ន» ។ អត្ថបទចំនួនពីរ (មួយនិពន្ធដោយលោក នីល ចេមីហ្សុន (Neil Jamieson) និងមួយទៀត និពន្ធដោយលោក ដឹងខិន ម៉ាក់ខារហ្គូ) បានផ្ដោតលើវប្បធម៌និងនយោបាយរបស់ប្រទេសវៀតណាម និងប្រទេសថៃ ។ អត្ថបទពីរទៀត ផ្ដោតទៅលើនិន្នាការថ្មី។ នៃការអភិវឌ្ឍសេដ្ឋកិច្ចនៅតំបន់អាស៊ីអាគ្នេយ៍ ហើយនិងឥទ្ធិពលនៃការអភិវឌ្ឍនេះទៅលើមនុស្សជាតិ ។ លោក ដឹងខិន ម៉ាក់ខារហ្គូ បានជ្រើសរើសអត្ថបទទាំងនេះក្នុងគោលបំណងពង្រីកការយល់ដឹងទូទៅរបស់អ្នកចូលរួម អំពីប្រទេសជិតខាងចំនួនពីររបស់ប្រទេសខ្មែរ រួមជាមួយគ្នានោះ ក៏មានបំណងចង់ឲ្យអ្នកចូលរួម យល់ឃើញអំពីការប្រែប្រួលថ្មី។ ក្នុងតំបន់ ដែលមានប្រទេសកម្ពុជាជាផ្នែកមួយផងនោះ ។ បន្ថែមពីលើអត្ថបទទាំង ៤ ដែលសុទ្ធតែបានចេញផ្សាយនៅក្នុងសៀវភៅនិងព្រឹត្តិបត្រវិទ្យាសាស្ត្រអន្តរជាតិ និងព្រឹត្តិបត្រដែលមានគណៈកម្មការឯកទេសនានារួចហើយនោះ យើងខ្ញុំបានជ្រើសរើសអត្ថបទមួយទៀត ដែលជាការស្រាវជ្រាវនិងនិពន្ធដោយអ្នកចូលរួមកម្ពុជាម្នាក់ ។ អត្ថបទស្រាវជ្រាវមួយនេះ គឺជាឧទាហរណ៍មួយដែលបញ្ជាក់អំពីលទ្ធផលនៃទ្រឹស្ដីនិងការអនុវត្តការងារស្រាវជ្រាវនិងការវិភាគរបស់កម្មវិធីនេះ ។

ដោយព្យាយាមរក្សានូវគោលបំណងគុណកោសល្យនៃកម្មវិធីបណ្ដុះបណ្ដាលនេះ យើងខ្ញុំសង្ឃឹមយ៉ាងស្មោះស្ម័គ្រថា អត្ថបទបកប្រែទាំងនេះនឹងមានប្រយោជន៍សម្រាប់សាស្ត្រាចារ្យនិងនិសិត្សនៅក្នុងវិស័យប្រវត្តិសាស្ត្រ សង្គមសាស្ត្រ សេដ្ឋកិច្ច នរវិទ្យា វិទ្យាសាស្ត្រនយោបាយ ទំនាក់ទំនងអន្តរជាតិ និងវិស័យដទៃជាច្រើនទៀត ។ យើងខ្ញុំក៏សង្ឃឹមដែរថា អត្ថបទទាំងនេះនឹងជួយជំរុញឲ្យអ្នកអាន ចង់ស្រាវជ្រាវបន្ថែម ហើយវិភាគរិះគិត ដោយប្រើវិធីប្រៀបធៀបនិងវិធីអន្តរវិស័យ ។

ក្នុងនាមជានាយកមជ្ឈមណ្ឌលខេមរសិក្សា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់សាស្ត្រាចារ្យ ដឹងខិន ម៉ាក់ខារហ្គូ ដែលបានជ្រើសរើសអត្ថបទដ៏គួរឲ្យចាប់អារម្មណ៍ និងដល់លោក ម៉ែន ឈានរិទ្ធី ជាអ្នកចាត់ចែងកម្មវិធីបណ្ដុះបណ្ដាល ដែលបានអនុវត្តគម្រោងការណ៍នេះ ប្រកបដោយជោគជ័យពិតប្រាកដ ។ ខ្ញុំសូមអរគុណជាពិសេសដល់ក្រុមការងារបកប្រែវ័យក្មេង ដែលមានលោក ឈាត ស្រ៊ាង លោក ភី សុភាដា និងលោក មួង ណារ៉េត ក្រោមការដឹកនាំដ៏ហ្មត់ចត់របស់អ្នកស្រី តាន់ សូដានី ដែលជាអ្នកចាត់ចែងកម្មវិធីបកប្រែរបស់មជ្ឈមណ្ឌលខេមរសិក្សា ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងពិសេសដល់លោកសាស្ត្រាចារ្យ ឃីង ហុកឌី ដែលបានជួយអានអត្ថបទមួយចំនួនឡើងវិញ និងបណ្ឌិត មីស្ហែល ឫទ្ធី អង់តែល្ម ដែលបានយកចិត្តទុកដាក់ជួយពិនិត្យពិច័យអត្ថបទទាំងអស់ឡើងវិញ ជួយរកឈ្មោះនិងពាក្យថៃនិងវៀតណាមទាំងឡាយ ជួយរកឯកសារជាភាសាសៀមដើម្បីកែលំអសេចក្ដីបកប្រែ ហើយនិងជួយរៀបចំទំព័រមុននឹងចេញបោះពុម្ពផ្សាយដោយចំណាយពេលវេលាឥតគណនា ។ ខ្ញុំសូមអរគុណលោក ចាច់ ដែតដែលបានផ្ដល់យោបល់ដល់លោក ឈាត ស្រ៊ាង អំពីកថាខណ្ឌខ្លះនៃអត្ថបទស្ដីអំពីទស្សនៈរបស់ខ្មែរចំពោះជនជាតិភាគតិចវៀតណាម ។ ជាទីបញ្ចប់ ខ្ញុំសូមសម្ដែងការដឹងគុណចំពោះការជួយជ្រោមជ្រែងរបស់លោក ខេង ពិទូកេត្យា ដែលជាអ្នកសម្របសម្រួលការងារទំនាក់ទំនងនិងបោះពុម្ពផ្សាយ និងដល់អ្នកស្រី ឡេស្លេយ៍ ផឺលមែន (Lesley Perlman) នាយិការងនៃមជ្ឈមណ្ឌលខេមរសិក្សា ។ អ្នកទាំង ២ នាក់នេះបានយកចិត្តទុកដាក់ជាទីបំផុតក្នុងការរៀបរៀង និងបោះពុម្ពសៀវភៅដែលជាស្នាដៃរួមនេះឡើង ។

បណ្ឌិត ហ្វីលីព្ព ប៊ីកាំ នាយកមជ្ឈមណ្ឌលខេមរសិក្សា ។

# PREFACE

In 2004, the Center for Khmer Studies began the Junior Faculty Training Program aimed at expanding the research and teaching skills of young Cambodian university faculty in the humanities and social sciences. Supported by the Rockefeller Foundation, the program recruits participants for a six-month semester, in which a distinguished Visiting Professor leads classes and seminars in academic analysis and research focusing on one topic related to modern Cambodia. Each topic is defined in collaboration with representatives of Cambodian universities to attract participants from different disciplines, and sets forth a comparative perspective, in which Cambodia is studied alongside its regional neighbors, Thailand and Vietnam. Every session includes a combination of lectures and interactive seminars, a study tour to a neighboring country, a supervised individual research project and an international conference on the session's theme. At the end of the program, a selection of the key texts used in each session is chosen by the Visiting Professor for translation into Khmer by Cambodian participants, with the dual aim of addressing the lack of academic materials available in the Khmer language at Cambodian universities and to train the next generation of translators.

This first volume consists of four texts selected by Dr. Duncan McCargo, Professor of Political Science at the University of Leeds, United Kingdom. They address the program's first session topic, "Contemporary Southeast Asia." Two of the texts, by Neil Jamieson and Duncan McCargo, introduce readers to the culture and politics of Vietnam and Thailand. The other two texts focus on current economic development in Southeast Asia and its effect on the region's populations. Prof. McCargo's choice of these texts is intended to expand general knowledge of Cambodia's nearest neighbors, while inviting scholars to reflect critically on some of the recent developments in the region of which Cambodia is a part. In addition to these four texts, all of which have previously appeared in international publications or peer-reviewed journals, we have included a paper written by one of the Cambodian participants as an example of the research and analysis that has grown from this program and its combination of theory and application.

In keeping with the pedagogical objectives of the JFTP, we very much hope that these translated texts will be useful to both professors and students of history, sociology, economics, anthropology, political science, international relations and other fields. We also hope that they will encourage readers to further exploration and critical analysis, using a comparative and interdisciplinary approach.

CKS is grateful to Prof. McCargo for his thoughtful choice of texts and to Dr. Chean Men, the Project Coordinator, who was essential to the program's implementation and success. Special thanks also to the team of young translators, particularly Chheat Sreang, Phy Sopheada, and Moung Nareth, who, under the careful supervision of CKS Translation Supervisor Tan Sodany, undertook this task with energy, excitement and an appetite for challenge. Prof. Khing Hoc Dy generously proofread some of the translated manuscripts and gave insight and clarity to our work. CKS is grateful to Dr. Michel Rethy Antelme for his meticulous final editing of the manuscript, the time spent in finding Thai and Vietnamese words, names and references throughout this book, and the tremendous amount of time he spent on the layout. Thach Deth gave valuable advice to Chheat Sreang on his research paper. I also wish to acknowledge CKS senior staff members Kheng Pytou Kethya, Communications and Publishing Coordinator, and Deputy Director Lesley Perlman for working on the editing and publishing of this truly collective undertaking.

Philippe Peycam, Ph.D., Director
Center for Khmer Studies.

# ជំពូកទី ១

## ឧស្សាហូបនីយកម្មនិងការជះឥទ្ធិពល

*ច្បាប់ដើមនៃអត្ថបទនេះ សរសេរជាភាសាអង់គ្លេស ក្រោមចំណងជើងថា ÷* Industrialization and Its Implications
*អត្ថបទនេះដកស្រង់ចេញពីសៀវភៅ ÷* **ការកកើតអាស៊ីអាគ្នេយ៍ទំនើប**
*រក្សាសិទ្ធិ គ.ស. ២០០៥ ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យសិង្ហបុរី*
*បោះពុម្ពលើកទី ១ គ.ស. ២០០៥ នៅសហរដ្ឋអាមេរិក ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យហាវ៉ៃ ។*

## CHAPTER 1

Industrialization and Its Implications
(*The emergence of Modem Southeast Asia*)

**Copyright © 2005 by Singapore University Press.**

**First published in 2005 by University of Hawaiʻi Press.**

**បកប្រែដោយ ÷ គី សុភាជា**

# ជំពូកទី ១
# ឧស្សាហូបនីយកម្មនិងការជះឥទ្ធិពល

*បន្ទាប់ពីសង្គ្រាមប៉ាស៊ីហ្វិកបានបញ្ចប់ទៅ ទំនើបនីយកម្មសេដ្ឋកិច្ច (ការធ្វើឲ្យសេដ្ឋកិច្ចមានភាពទំនើប) ទំនងជាជំហានបន្ទាប់ដ៏សមស្របមួយសម្រាប់មេដឹកនាំនៃបណ្តាប្រទេសអាស៊ីអាគ្នេយ៍ភាគច្រើន ប្រកាន់យកក្នុងការស្តារនូវអំណាចនិងកិត្តិយសរបស់ពួកគេឡើងវិញ ។ ប្រសិនបើក្រឡេកមើល «វៀតណាមថ្មី» នៅក្នុងឆ្នាំ ១៩០៧ យើងឃើញថា ជនបដិវត្តវៀតណាមឈ្មោះ ផាន បូយចូវ* (Phan Bội Châu) *បានរំពឹងទុកនូវអនាគតដ៏រុងរឿងមួយដែលរថយន្តនិងរថភ្លើង នឹងលែងជារបស់មាននៅតែក្នុងបស្ចិមប្រទេសទៀត ហើយទំនិញពាណិជ្ជកម្មវៀតណាមនឹងក្លាយជាទំនិញដ៏ល្អបំផុតនៅលើពិភពលោក ។ បំណងដូចនេះ បានទទួលលទ្ធផលជាផ្លែផ្កានៅក្រោយឆ្នាំ ១៩៨០ តែប៉ុណ្ណោះពីព្រោះតែនៅពេលនោះបុព្វហេតុនៃការប្រឆាំងនឹងអាណានិគមទទួលបានជោគជ័យ ។ ប៉ុន្តែ នៅក្នុងសម័យដែលសេដ្ឋវិទូទាំងឡាយមានទឹកមាត់ប្រៃ សៀវភៅសេដ្ឋកិច្ចផ្សេងៗ របស់លោកខាងលិច ត្រូវបានគេកែលំអឲ្យមានលក្ខណៈប្រសើរជាងមុន ដោយចុះបន្ថែមនូវលក្ខខណ្ឌចាំបាច់ជាច្រើនដើម្បីឲ្យឧស្សាហូបនីយកម្មទទួលបានជោគជ័យ ។ លក្ខខណ្ឌទាំងនោះមានដូចជា ÷*

- *ប្រព័ន្ធច្បាប់ដែលធានាខុសត្រូវ ចំពោះសិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ៗ និងការពារទ្រព្យសម្បត្តិឯកជនឲ្យបានពេញលេញ ។*
- *កំណើនផលិតភាពកសិកម្ម ដែលជាលទ្ធផលនៃកំណែទម្រង់រចនាសម្ព័ន្ធ មុនសម័យឧស្សាហកម្មនិងក្នុងសម័យអាណានិគម ។*
- *ភាពសម្បូរបែបនៃកម្លាំងពលកម្មជំនាញ ។*
- *សហគ្រិនដែលហ៊ានប្រឈមនឹងភាពប្រថុយប្រថានហើយមានគំនិតច្នៃប្រឌិតថ្មី ។*
- *ទុនគ្រប់គ្រាន់សម្រាប់វិនិយោគវិស័យឧស្សាហកម្ម ។*
- *ទីផ្សារក្នុងស្រុកដែលមានការរៀបចំប្រកបដោយប្រសិទ្ធភាពខ្ពស់និងជំទូលាយ ។*

## ការប្រឈមមុខក្នុងការអភិវឌ្ឍជាសម័យក្រោយសង្គ្រាម

*នៅក្រៅតំបន់អាស៊ីអាគ្នេយ៍ ស្ទើរតែគ្មាននរណាម្នាក់ជឿថា តំបន់នេះអាចសម្រេចបាននូវលក្ខខណ្ឌខាងលើ ។ រហូតដល់ឆ្នាំ ១៩៥៣ លោកសាស្ត្រាចារ្យ ហ្ស៊ុ.អ័ស្ហ.ប៊ូក* (J H Boeke) *ដ៏មានឥទ្ធិពលមួយរូបផ្នែកសេដ្ឋកិច្ចបូព៌ាប្រទេសនៃសាកលវិទ្យាល័យឡីដិន* (Leiden) *បានលើកឡើងថា សង្គមអាស៊ីអាគ្នេយ៍ ដូចជាប្រទេសឥណ្ឌូនេស៊ី ជាដើម មានទម្រង់សេដ្ឋកិច្ចពីរយ៉ាង ដែលមិនអាចផ្តាច់ចេញពីគ្នាបាន ។ ទម្រង់ផ្សេងៗ នៃសកម្មភាពសេដ្ឋកិច្ចដូចជារបបមូលធននិយមរបស់បស្ចិមប្រទេសជាដើម មិនអាចលុបបំបាត់ចោលបានទាំងស្រុង នូវរបៀបរបបសេដ្ឋកិច្ចថ្នាក់ភូមិរបស់ម្ចាស់ស្រុកបានទេ ដោយសារវានៅមានតម្រូវការមួយចំនួនតូច ។ ករណីនេះបានបង្កការលំបាកដល់ផែនការ*

បដិវត្តឧស្សាហកម្ម ។ អ្វីដែលហៅថា ភាពទំនើបរបស់តំបន់អាស៊ីអាគ្នេយ៍ ពិតជាបានឈប់ទ្រឹងនាពេលពីរទសវត្សរ៍ក្រោយពីលោកសាស្ត្រាចារ្យ ប៊ូក និពន្ធសៀវភៅរួច ។ មានការបះបោររបស់កសិករជាទ្រង់ទ្រាយធំនៅតែបន្តក្នុងប្រទេសវៀតណាម ភូមា និងកម្ពុជា ។ មេដឹកនាំចលនាទាំងនោះបានជំទាស់ទៅលើតម្លៃនៃការរស់នៅរបស់ប្រជាជនវណ្ណៈកណ្តាលនៅទីក្រុង ។ ហើយយ៉ាងហោចណាស់ ក៏មានការបះបោរប្រឆាំង ផ្ទុះឡើងនៅតាមមណ្ឌលបោះឆ្នោតដែលបានរៀបចំឡើងនៅតាមជនបទ ដូចក្នុងប្រទេសឥណ្ឌូនេស៊ីមុនឆ្នាំ ១៩៦៥ ជាដើម ។

ការគិតទុកមុនរបស់លោកសាស្ត្រាចារ្យ ប៊ូក នៅពេលនោះ មានលក្ខណៈសមហេតុផលដែរ ។ ហើយគំនិតនេះក៏ដូចទៅនឹងគំនិតរបស់បណ្តាអ្នកប្រាជ្ញបស្ចិមប្រទេសផ្សេងៗ ទៀត ដូចជា ជ័យលាភីរង្វាន់ណូបែលលោក គុណ្ណារ មឺរដល (Gunnar Myrdal) ដែលបានបរិយាយនៅក្នុងសៀវភៅមួយក្រោមចំណងជើងថា **ខនាដកម្មរបស់អាស៊ី ៖ ដំណើរការអង្កេតពីភាពក្រីក្ររបស់ប្រជាជាតិ** (Asian Drama: An Inquiry into the poverty of Nations) (គ.ស. ១៩៦៨) ជាដើម ។ ក្នុងអំឡុងម្ភៃប្រាំឆ្នាំក្រោយសង្គ្រាមលោកលើកទី ២ កំណើនសេដ្ឋកិច្ចពិភពលោកបានកើនឡើងប្រមាណជិត ៥% ក្នុងមួយឆ្នាំ ។ កំណើននេះមានសន្ទុះលឿនឆ្ងាយជាងសព្វថ្ងៃហើយលឿនជាង ៥០% បើប្រៀបធៀបទៅនឹងកំណើននាពេលក្រោយៗ មកទៀត ។ ទោះជាសង្គ្រាមត្រជាក់បន្តបញ្ហាក្តៅគគុកនៅឧបទ្វីបកូរ៉េនិងវៀតណាម ហើយទោះជាមានការបះបោរដើម្បីឯករាជ្យ និងមានសង្គ្រាមស៊ីវិលក្នុងប្រទេសដែលទើបទទួលបានឯករាជ្យថ្មីៗ ក៏ដោយ ក៏គ្មានជម្លោះណាមួយរីកធំរហូតដល់ធ្វើឲ្យប៉ះពាល់ដល់ដំណើរការពាណិជ្ជកម្មពិភពលោកនោះដែរ ។ ទន្ទឹមនឹងនោះ សហរដ្ឋអាមេរិកនិងប្រទេសមហាអំណាចឧស្សាហកម្មផ្សេងៗ ទៀត បានរៀនសូត្រពីជម្លោះពាណិជ្ជកម្មតាមរយៈបទពិសោធន៍ពីមហាវិបត្តិសេដ្ឋកិច្ច (ពីឆ្នាំ ១៩២៩ រហូតដល់សង្គ្រាមលោកលើកទី ២) ទើបធ្វើឲ្យមានកិច្ចខិតខំប្រឹងប្រែងជាសាកលមួយ ដើម្បីកាត់បន្ថយពន្ធលើទំនិញនាំចេញនាំចូលគ្រប់តំបន់តាមរយៈការបង្កើតនូវស្ថាប័ននាំមុខគេមួយ ដែលក្រោយមកបានក្លាយជាអង្គការពាណិជ្ជកម្មពិភពលោក ។

ប្រទេសអាស៊ីអាគ្នេយ៍ភាគច្រើន ដែលទើបងើបផុតពីភាពខ្ទេចខ្ទាំដោយសារសង្គ្រាម បានទាញយកផលចំណេញពីកំណើនពាណិជ្ជកម្មលើផលិតផលសំខាន់ៗ មួយចំនួនដូចជា កៅស៊ូ សំណប៉ាហាំង ប្រេងឆា និងប្រេងកាត ដែលផលិតផលទាំងនេះមានតម្រូវការនិងតម្លៃខ្ពស់ ។ ជាពិសេស ប្រទេសម៉ាឡាយ៉ា (ម៉ាឡាយូ) និងហ្វីលីពីនបានទាញយកផលចំណេញជាច្រើនពីការផ្គត់ផ្គង់សម្ភារៈយុទ្ធសាស្ត្រនានាក្នុងសង្គ្រាមកូរ៉េ ។ ក៏ប៉ុន្តែ ផលចំណេញបែបនេះមិនមានភាពយូរអង្វែងដូចដែលគេបានដឹងតាំងពីសម័យមុនសង្គ្រាមមកម៉្លេះ ។ ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលកំពុងពង្រឹងនយោបាយឯករាជ្យរបស់ខ្លួន ហាក់ដូចជាមិនបានរៀបចំខ្លួនឲ្យល្អក្នុងការប្រែក្លាយខ្លួនពីប្រទេសផលិតនូវផលិតផលវត្ថុធាតុដើម ទៅជាមហាអំណាចឧស្សាហកម្ម ហើយថែមទាំងមិនបានរៀបចំប្តូរមុខមាត់របស់ខ្លួនឲ្យទៅជាប្រទេសនៅក្នុងចំណោមប្រព័ន្ធមូលធននិយមពិភពលោក ដែលត្រួតត្រាដោយសហរដ្ឋអាមេរិកទៀតផង ។

សក្តានុពលសម្រាប់ការអភិវឌ្ឍរបស់ប្រទេសអាស៊ីអាគ្នេយ៍ទាំងនោះ ក៏ហាក់ដូចជារារាំងដោយសារកំណើនប្រជាជនយ៉ាងរហ័ស រួមទាំងបញ្ហាអយុត្តិធម៌និងការអភិវឌ្ឍគ្មានប្រសិទ្ធភាពនៅតាមតំបន់ជនបទ ដែលបានបន្សល់ទុកតាំងពីសម័យអាណានិគម ។ ការថយចុះយ៉ាងខ្លាំងនូវអត្រាមរណៈដោយសារមូលហេតុផ្សេងៗ (ដូចជាការកម្ចាត់សត្វមូសដែលជាភ្នាក់ងារចម្លងជម្ងឺគ្រុនចាញ់ដោយប្រើថ្នាំដេដេតេជាដើម) បាននាំឲ្យមានកំណើនប្រជាជន

កម្រិតខ្ពស់ដែលមិនធ្លាប់មានពីមុនមក ។ កំណើនប្រជាជននេះមានរហូតដល់ ៣,៥% នៅបណ្តាប្រទេសមួយចំនួនដូចជាប្រទេសថៃនិងប្រទេសហ្វីលីពីន ។ យោងតាមអត្រាកំណើននេះ ចំនួនប្រជាជននឹងកើនឡើងទ្វេដងនៅក្នុងរយៈពេលតែ ២០ ឆ្នាំប៉ុណ្ណោះ ហើយនឹងស្រូបយកកំណើនសេដ្ឋកិច្ចស្ទើរតែទាំងអស់ ។

បញ្ហាមួយទៀត គឺប្រជាជនភាគច្រើននៅតែរស់នៅតាមតំបន់ជនបទ ហើយពឹងផ្អែកទៅលើតែការធ្វើស្រែចម្ការ ។ ការពង្រីកទីក្រុងយ៉ាងឆាប់រហ័ស ហាក់ដូចជាមិនស៊ីសង្វាក់ជាមួយនឹងកសិករភាគច្រើន ដែលកំពុងតែមានបញ្ហាជាមួយនឹងការប្រមូលផលមិនទៀងទាត់ បញ្ហាថ្លៃដួលនិងពន្ធដារខ្ពស់ ហើយនិងបញ្ហារំលោភបំពានពីសំណាក់ពួកម្ចាស់ដីធំៗ (ពួកក្តុម្ពី) ដែលបានពង្រីកឥទ្ធិពលចាប់តាំងពីសម័យឯករាជ្យមកម្ល៉េះ ។ ការតវ៉ាឲ្យមានកំណែទម្រង់ដីធ្លី កើតមាននៅគ្រប់កន្លែងទាំងអស់ ។ ការទាមទារបែបនេះអាចថា ជាសកម្មភាពដើម្បីបញ្ចុះថ្លៃដួលនិងរារាំងអំណាចបំពារបំពានរបស់ពួកម្ចាស់ដី ឬជាសកម្មភាពដើម្បីចាប់យកដីមកធ្វើជាកម្មសិទ្ធិស្របច្បាប់របស់ប្រជាកសិករទាំងអស់នោះ ។ ផលិតភាពកសិកម្មក៏ជាកត្តាល់មួយដែរ ខណៈពេលដែលប្រទេសមួយចំនួនដូចជា ប្រទេសម៉ាឡាយ៉ា និងហ្វីលីពីន នៅតែនាំអង្ករចូលសម្រាប់ផ្គត់ផ្គង់ប្រជាពលរដ្ឋរបស់ខ្លួន ។ អ្នកប្រាជ្ញបស្ចិមប្រទេសមួយចំនួនបារម្ភយ៉ាងខ្លាំងថា ពិភពលោកទាំងមូលទំនងជាអាចកើតគ្រោះទុរ្ភិក្ស ប្រសិនបើកំណើនប្រជាជនមិនមានការទប់ស្កាត់នោះ ។

ផលិតកម្មក្នុងអំឡុងពេលនោះភាគច្រើន ត្រូវបានគេកំណត់តែទៅលើឧស្សាហូបនីយកម្មជំនួសការនាំចូលដូចដែលបានណែនាំដោយធនាគារពិភពលោកនិងសេដ្ឋវិទូមួយចំនួន ។ ដោយគេគិតថា «ប្រទេសតតិយលោក» មិនអាចប្រកួតប្រជែងខាងឧស្សាហកម្មជាមួយបស្ចិមប្រទេស (ឬប្រទេសជប៉ុន) បានទេ នោះអ្នកជំនាញជឿជាក់ថា ផលិតកម្មយ៉ាងសាមញ្ញសម្រាប់ទីផ្សារក្នុងស្រុកដូចជា ចក្រយាន ពិល ស្បែកជើងកៅស៊ូ គឺជាផលិតកម្មដែលអាចទទួលផលចំណេញ ជាពិសេសប្រសិនបើមានការរឹតបន្តឹងពន្ធនាំចូល ដូចដែលរដ្ឋាភិបាលឯករាជនាសម័យនោះកំពុងតែបង្កើតប្រព័ន្ធនេះឡើង ។ ឧស្សាហូបនីយកម្ម «ជំនួសការនាំចូល» បានទទួលជោគជ័យគួរសមនាដើមសម័យក្រោយសង្គ្រាម ជាពិសេសនៅក្នុងប្រទេសហ្វីលីពីន ។ នៅចុងទសវត្សរ៍ឆ្នាំ ១៩៦០ ប្រទេសហ្វីលីពីនគឺជាប្រទេសដែលមានឧស្សាហកម្មច្រើនជាងប្រទេសសិង្ហបុរី ហើយមានចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗ ខ្ពស់ជាងតៃវ៉ាន់និងកូរ៉េខាងត្បូងទៅទៀត ។ ប៉ុន្តែ មិនយូរប៉ុន្មាន ឧស្សាហូបនីយកម្មដូចនេះ បានជួបប្រទះនូវបញ្ហាមួយចំនួន ដែលជៀសមិនរួច ជាពិសេស គឺបញ្ហាទីផ្សារចង្អៀតក្នុងស្រុក សូម្បីតែប្រទេសដែលមានប្រជាជនច្រើនដូចជាប្រទេសចិន ប្រទេសឥណ្ឌា និងប្រទេសឥណ្ឌូនេស៊ី ក៏ត្រូវជំនះនូវបញ្ហានេះក្នុងពេលក្រោយដែរ ។ ឧស្សាហូប-នីយកម្មបែបនេះ ទំនងជាគ្មានប្រសិទ្ធភាព ព្រោះជាឧស្សាហកម្មក្មេងខ្ចី ក៏ប៉ុន្តែឥឡូវនេះ វាបានរីកធំធាត់ ហើយបន្តបញ្ចុះបញ្ចូលឲ្យមានការគាត់តែងច្បាប់ ដើម្បីដាក់កំហិតការប្រកួតប្រជែងពីផលិតផលបរទេស ។

គេឃើញមានទាំងការលំបាកនិងទាំងផលចំណេញ ក្នុងការធ្វើជាប្រទេសឧស្សាហកម្មថ្មីៗ ។ ប្រទេសដែលបានទទួលជោគជ័យត្រចេះត្រចង់រួចហើយក្នុងឧស្សាហកម្ម គឺជាប្រទេសដែលមានទឹកដីទូលំទូលាយ (ឧទាហរណ៍សហរដ្ឋអាមេរិក និងសហភាពសូវៀត) ឬក៏ជាប្រទេសដែលធ្លាប់បានដាក់អាណានិគមលើប្រទេសដទៃទៀត (បណ្តាចក្រភពនៅអឺរ៉ុបនិងអាណាចក្រជប៉ុន) ។ ស្ថានភាពបែបនេះបានផ្តល់ផលប្រយោជន៍ដល់ប្រទេសឧស្សាហកម្មទាំងនោះ ក្នុងការជួយអ្នកប្រើប្រាស់កុំឲ្យខាតបង់ការចំណាយផ្សេងៗ លើផលិតផលឧស្សាហកម្ម ដូច

ជាការបោះចោលនូវកាកសំណល់ និងការធ្វើឲ្យបាត់បង់នូវធនធានធម្មជាតិជាដើម ។ ឧស្សាហូបនីយកម្មរបស់តំបន់អាស៊ីអាគ្នេយ៍ ស្ថិតនៅក្រោមឥទ្ធិពលដ៏ច្រើនរបស់លក្ខណៈភូមិសាស្ត្រនិងសង្គមសាស្ត្រ ហើយធនធានធម្មជាតិរបស់អាស៊ីអាគ្នេយ៍មិនមានប្រយោជន៍ដូចដែលវាធ្លាប់មានពីមុនមកទេ ។ ចាប់ពីឆ្នាំ ១៩៥០ មក បដិវត្តន៍បច្ចេកវិទ្យានិងសេដ្ឋកិច្ចពិភពលោក ដែលនាំមុខដោយទំនិញអេឡិចត្រូនិក ម៉ាស៊ីនឡានដ៏ទំនើប និងជីគីមី ហើយក្រោយមក ការរីកចម្រើនផ្សេងៗ ដូចជា គ្រឿងដំណើរការកុំព្យូទ័រ កុំព្យូទ័រ និងពន្ធុវិស្វកម្ម (បច្ចេកវិទ្យាកម្រើកនិងផ្លាស់ពន្ធុ) បានសបញ្ជាក់យ៉ាងច្បាស់ថា វិទ្យាសាស្ត្រហើយនិងបច្ចេកវិទ្យា បានក្លាយជាកម្លាំងដ៏សំខាន់សម្រាប់ជំរុញឲ្យមានការរីកចម្រើន ។ ឈានចូលដល់សតវត្សរ៍ទី ២១ អាស៊ីអាគ្នេយ៍បានកាប់ព្រៃឈើប្រណីតដើម្បីធ្វើក្តារបន្ទះ ហើយច្រោះដីដើម្បីយករ៉ែ ។ ប៉ុន្តែ ផលកម្រៃដែលបានមកពីឧស្សាហកម្មទាំងនេះ បានចំណេញតែទៅលើក្រុមហ៊ុនដែលពាក់ព័ន្ធ (និងមន្ត្រីពុករលួយប៉ុណ្ណោះ) ពោលគឺវាមិនជួយដល់ការផ្លាស់ប្តូរ ឬការថែរក្សាស្ថិរភាពសេដ្ឋកិច្ចជាតិរបស់ប្រទេសនីមួយៗ នោះទេ ។

បញ្ហាអស់ទាំងនេះបានគំរាមកំហែងដល់បណ្តាមេដឹកនាំប្រទេសអាស៊ីអាគ្នេយ៍ ចំពោះវិសមភាពពិភពលោក ដែលសូម្បីតែលោក អូងសាន (Aungsan) ឬលោក ស៊ូការណូ (Sukarno) ក៏ស្ទើរតែមិនអាចនឹកគិតដល់បញ្ហាអស់ទាំងនេះដែរ ។ ចូលរួមក្នុងពិភពលោកមួយ ដែលការប្រមូលនិងប្រើប្រាស់ព័ត៌មាន ការបង្កើតចំណេះដឹង និងការទាញប្រយោជន៍ពីស្វាកសញ្ញា មានសារៈសំខាន់ដើម្បីបង្កើតឲ្យមានភាពសម្បូរសប្បាយនិងអំណាច ហើយរួមទាំងការបែងចែកធនធាននោះ ។ ចំណុចខ្លាំងរបស់អាស៊ីអាគ្នេយ៍នៅក្នុងឆ្នាំ ១៩៦០ ដូចជាកម្លាំងពលកម្មដែលគ្មានជំនាញ និងវត្ថុធាតុដើមផ្សេងៗ បានថយចុះគួរឲ្យកត់សម្គាល់ ។ (នៅចុងសតវត្សរ៍ទី ២០ មានទំព័រអាំងទែរណែត ប្រមាណជាង ៨០% ក្នុងប្រព័ន្ធអាំងទែរណែត បានសរសេរឡើងជាភាសាអង់គ្លេស ហើយក្នុងចំណោមទំព័រអាំងទែរណែតដែលសម្បូរអ្នកទស្សនាច្រើនជាងគេ ចំនួន ១០០ មានទំព័រអាំងទែរណែតចំនួន ៩៤ មានប្រភពមកពីសហរដ្ឋអាមេរិក ។) ភាពឯកោផ្នែកសេដ្ឋកិច្ចដែលជាសុបិនអាក្រក់ថ្មីមួយ កាន់តែធ្វើឲ្យមានអារម្មណ៍ភ័យខ្លាចក្នុងការក្លាយជាប្រទេសពឹងផ្អែកលើអាណានិគមកើតមានឡើង ។

ផ្ទុយទៅនឹងអ្វីដែលហាក់បីដូចជាឧបសគ្គធំៗ បណ្តាប្រទេសអាស៊ីអាគ្នេយ៍ ភាគច្រើនមានការរីកចម្រើនផ្នែកឧស្សាហកម្មគួរឲ្យកត់សម្គាល់ចាប់តាំងពីឆ្នាំ ១៩៦៥ មកម្ល៉េះ ។ ហើយទសវត្សរ៍បន្ទាប់ គឺជាព្រឹត្តិការណ៍នៃការផ្លាស់ប្តូរដ៏សំខាន់មួយនៅក្នុងប្រវត្តិសាស្ត្រសេដ្ឋកិច្ចក្នុងតំបន់ ទោះជាមិនទាន់មានលទ្ធផលមកបញ្ជាក់នៅក្នុងដំណាក់កាលនេះក៏ដោយ ។ ការអភិវឌ្ឍស្របទិសគ្នាជាច្រើនបានបង្កើតឲ្យមាននូវ «ទម្រង់សេដ្ឋកិច្ចអន្តរជាតិថ្មី» មួយ ដែលផ្តល់ឱកាសឲ្យប្រទេសអាស៊ីអាគ្នេយ៍មួយចំនួន ផ្លាស់ប្តូរនូវតួនាទីរបស់ខ្លួនឡើងវិញ ដើម្បីឲ្យស្របទៅតាមប្រព័ន្ធមូលធននិយមពិភពលោក ។ ការរីកចម្រើនមួយក្នុងចំណោមការរីកចម្រើនទាំងនេះ បានកើតឡើងដោយសារការធ្លាក់ចុះរបស់សហរដ្ឋអាមេរិក ពីឋានៈជាអ្នកលេចធ្លោផ្នែកសេដ្ឋកិច្ចគ្មានគូប្រជែង ដែលធ្លាប់សម្រេចបានភ្លាមៗក្រោយសង្គ្រាម ។ មួយផ្នែកនៃការរីកចម្រើននេះ គឺដោយសារតែប្រទេសផ្សេងៗ ទៀត ជាពិសេសប្រទេសជប៉ុននិងអាល្លឺម៉ង់ បានក្លាយទៅជាប្រទេសប្រកួតប្រជែងកាន់តែខ្លាំងឡើងនៅពេលដែលគេបានស្តាបនាប្រទេសទាំងនេះឡើងវិញ បន្ទាប់ពីសង្គ្រាមបានបញ្ចប់ទៅ ។ មួយផ្នែកទៀត គឺមកពីការចំណាយដ៏សន្ធឹកសន្ធាប់របស់សហរដ្ឋអាមេរិកលើសង្គ្រាមវៀតណាម រួមជាមួយនឹងការប្រឹងប្រែងក្នុងពេលជាមួយគ្នាដើម្បីកសាងឲ្យបាននូវ «សង្គមមហា

អស្ចារ្យ» មួយដែលគ្មានការយកពន្ធ ។ មួយផ្នែកផ្សេងទៀត គឺបណ្ដាលមកពី«វិបត្តិប្រេងឥន្ធនៈ» ដែលបានកើតឡើងជាំបូងបង្អស់ក្នុងឆ្នាំ ១៩៧៣ នៅពេលដែលអង្គការនៃបណ្ដាប្រទេសនាំប្រេងកាតចេញ ហៅ «អូប៉ិច (OPEC)» បានបង្កើនថ្លៃប្រេងកាតពិភពលោកទ្វេដងដោយជោគជ័យ ។ ដោយបដិសេធចោលនូវអ្វីដែលអត្ថបទរបស់ទស្សនាវដ្ដី **ថែមម៉ាហ្គាហ្សីន** (*Time Magazine*) បានចុះផ្សាយថា ជា «សតវត្សរ៍របស់សហរដ្ឋអាមេរិក» កំពុងចប់ទៅនោះ សហរដ្ឋអាមេរិកមានភាពយឺតយ៉ាវក្នុងការលះបង់ចោលនូវវិធីសាស្ត្រនៃការគ្រប់គ្រងគ្មានប្រសិទ្ធភាព និងនៅតែប្រើរថយន្តស៊ីសាំងច្រើននៅឡើយ ។ តែ ស.រ.អា. បានដកខ្លួនចេញពីការប្ដេជ្ញាចិត្តចំពោះតំបន់អាស៊ី ក្នុងខណៈដែលប្រទេសនេះបានសម្រេចចិត្តដកខ្លួនថយពីសង្គ្រាមវៀតណាមជាដើម ។ ការនេះបានអនុញ្ញាតឲ្យប្រទេសជប៉ុន ដែលទើបនឹងងើបឡើងនោះ ក្លាយទៅជាដៃគូសេដ្ឋកិច្ចដ៏សំខាន់ និងជាគំរូដល់ប្រទេសអាស៊ីអាគ្នេយ៍ទាំងឡាយ ។

ក្នុងពេលជាមួយគ្នាដែរ ការសិក្សាស្រាវជ្រាវលើវិស័យកសិកម្ម ដែលមួយចំនួនបានធ្វើឡើងតាំងពីសម័យអាណានិគម បានចាប់ផ្ដើមហុចផល ។ ការសិក្សាស្រាវជ្រាវនេះ បានធ្វើឲ្យឧស្សាហកម្មកៅស៊ូនិងដូងប្រេងរបស់ប្រទេសម៉ាឡេស៊ី ចាប់មានដំណើរការឡើងវិញ ។ លទ្ធផលរបស់ឧស្សាហកម្មនេះផ្ដល់ដល់តំបន់ទាំងមូល បានកើនឡើងកាន់តែប្រសើរថែមទៀត ដោយសារការបង្កើតឡើងនូវដំណាំស្រូវដែលផ្ដល់ទិន្នផលខ្ពស់នៅឯវិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ អ៊ី.អែរ.អែរ.អ៊ី. (IRRI) ដែលស្ថិតនៅក្នុងតំបន់ឡូសបាញ៉ូស (Los Baños) ក្បែរទីក្រុងម៉ានីល ។ នេះគឺជាជោគជ័យធំមួយក្នុងចំណោមជោគជ័យនៃការអភិវឌ្ឍនានាជាច្រើនក្នុងរយៈពេល ៥០ ឆ្នាំចុងក្រោយនេះ ។ គោលបំណងរបស់ អ៊ី.អែរ.អែរ.អ៊ី. គឺបង្កើតធនាគារពូជស្រូវដ៏ធំមួយ និងប្រើប្រាស់នូវវិទ្យាសាស្ត្រទំនើបដើម្បីបង្កើនទិន្នផល ។ នៅក្នុងឆ្នាំ ១៩៦៦ អ្នកវិទ្យាសាស្ត្របានបង្កាត់ពូជស្រូវតឿរបស់ចិននិងឥណ្ឌូនេស៊ី ដើម្បីច្នៃបង្កើតជាប្រភេទស្រូវ អ៊ី.អែរ.អែរ.អ៊ី.-៨ ដែលមានដើមខ្លីជាងមុន ហើយងាយស្រួលក្នុងការការពារពីការទោរទន់មែកទៅលើដី នៅពេលដែលគេប្រើប្រាស់ជីថ្មីធ្វើឲ្យវាមានកួរធំជាងមុននោះ ។ នៅក្នុងឆ្នាំ ១៩៨២ គេក៏បានបង្កើតប្រភេទស្រូវ អ៊ី.អែរ.អែរ.អ៊ី.-៣៦ ដែលបង្កាត់ចេញមកពីស្រូវ ១៣ ប្រភេទផ្សេងៗគ្នា ។ ស្រូវប្រភេទនេះមានភាពធន់ខ្លាំងជាងមុនក្នុងការការពារទប់ទល់ទៅនឹងសត្វល្អិតចង្រៃផ្សេងៗ ។ លើសពីនេះ វដ្ដនៃការរីកលូតលាស់របស់ស្រូវប្រភេទនេះ ក៏មានរយៈពេលខ្លីជាងមុន គឺថយចុះពីប្រមាណ ១៨០ ថ្ងៃមក ១១០ ថ្ងៃវិញ ។ គ្រាប់ស្រូវប្រភេទនេះអាចទុំបាន ទោះមិនមានពន្លឺថ្ងៃគ្រប់គ្រាន់ក្ដី ប៉ុន្តែចាំបាច់ត្រូវប្រើប្រាស់ជីបន្ថែម ។ ប្រភេទស្រូវដែលផ្ដល់ទិន្នផលខ្ពស់ អាចផ្ដល់លទ្ធភាពដល់កសិករនៃបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ទាំងឡាយ បង្កើននូវទិន្នផលស្រូវរបស់ពួកគេបានទ្វេដង ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗ នេះ អ្នកវិទ្យាសាស្ត្រនៅឯ អ៊ី.អែរ.អែរ.អ៊ី. បានប្រើនូវបច្ចេកទេសបង្កាត់ពូជស្រូវដោយក្នុងនោះ មាន «ស្រូវមាស» ប្រភេទថ្មីមួយ មានហ្សែនកែប្រែចំនួន ៣ ប្រភេទ ហើយមានសារជាតិវីតាមីន បេតាការ៉ូទែនបន្ថែម ដែលអាចជួយកាត់បន្ថយនូវជម្ងឺពិការភ្នែករបស់កុមារបាន ។ ស្របពេលជាមួយគ្នានោះ ការសិក្សាស្រាវជ្រាវថ្មីៗ ធ្វើឡើង ដើម្បីធ្វើបន្ថែមនូវជាតិដែកក្នុងដើមស្រូវ ក្នុងគោលបំណងប្រយុទ្ធប្រឆាំងទៅនឹងជម្ងឺខ្វះឈាមក្រហម ដែលប្រហែលជាជម្ងឺកង្វះជីវជាតិដ៏សាហាវបំផុតនៅលើពិភពលោកយើងនេះ ។

«បដិវត្តន៍បៃតង» (បដិវត្តន៍កសិកម្ម) នេះក៏ជួបប្រទះនូវបញ្ហាដែរ ដោយមិនអាចដំណើរការទៅបាន បើ

គ្មានទុនសម្រាប់ចំណាយទៅលើដី ដូចជា ដី ថ្នាំសម្លាប់សត្វល្អិត និងប្រព័ន្ធគ្រប់គ្រងទឹកប្រកបដោយប្រសិទ្ធភាពនោះ ។ លក្ខខណ្ឌទាំងនេះ បានធ្វើឲ្យមានផលពិបាកដល់ប្រជាកសិករក្រីក្រ និងប្រទេសក្រីក្រនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៧០ និង ១៩៨០ ។ បដិវត្តន៍បៃតងក៏ដូចជាបច្ចេកវិទ្យាជំនួយកសិកម្មថ្មីៗ ផ្សេងទៀត ដូចជាត្រាក់ទ័រ ម៉ាស៊ីនបូមទឹក និងម៉ាស៊ីនច្រូតកាត់ ជាដើម កាន់តែធ្វើឲ្យគម្លាតទ្រព្យធនរវាងប្រជាពលរដ្ឋនៅតាមតំបន់ជនបទ មានសភាពខុសគ្នាខ្លាំងឡើង ។ ទោះបីជាបដិវត្តន៍បៃតងនេះមិនបានដោះស្រាយ «បញ្ហារបស់កសិករ» នៅអាស៊ីអាគ្នេយ៍ទាំងស្រុងក៏ដោយ ក៏បដិវត្តន៍នេះពិតជាបានជួយទប់ស្កាត់គ្រោះទុរ្ភិក្សនៅក្នុងតំបន់ ។ ក្នុងពេលនោះដែរ កំណើនប្រជាជនក៏បានចាប់ផ្តើមថយចុះ ដោយសារកម្មវិធីគ្រប់គ្រងអត្រាកំណើតដែលឧបត្ថម្ភដោយរដ្ឋាភិបាល (ជាពិសេសនៅប្រទេសសិង្ហបុរី និងក្រោយមកនៅប្រទេសថៃ) បុការរីកចម្រើនព្រមគ្នារវាងទីក្រុងនិងសេដ្ឋកិច្ច ។ គេនៅតែឃើញមាននូវភាពអយុត្តិធម៌ និងការបះបោររបស់ប្រជាជននៅតាមជនបទ ។ ប៉ុន្តែភាពភ័យខ្លាចអំពីគ្រោះទុរ្ភិក្សនៅតំបន់អាស៊ីអាគ្នេយ៍នោះ លែងមានទៀតហើយ ។

ទោះជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍដ៏សំខាន់នៃសេដ្ឋកិច្ចអាស៊ីអាគ្នេយ៍ បានចាប់ផ្តើមចេញពីលទ្ធផលប្រយោលនៃនយោបាយ ដោយឥតគ្រោងទុក ។ ការផ្តាច់ចេញរបស់ប្រទេសសិង្ហបុរីពីប្រទេសម៉ាឡេស៊ីនៅក្នុងឆ្នាំ ១៩៦៥ បានជំរុញឲ្យប្រទេសនេះពិចារណាឡើងវិញយ៉ាងឆាប់រហ័សអំពីយុទ្ធសាស្ត្រឧស្សាហកម្មរបស់ខ្លួន ដែលមកទល់ពេលនោះ ឧស្សាហូបនីយកម្ម «ជំនួសការនាំចូល» បានបាញ់ផ្តោះទៅរកតែទីផ្សារម៉ាឡេស៊ី ។ នាពេលនោះ ទីផ្សារក្នុងស្រុករបស់សិង្ហបុរី មានលក្ខណៈតូចចង្អៀត ដោយសារមានប្រជាជនតែ ២ លាននាក់ ។ ដូច្នេះ ក្តីសង្ឃឹមតែមួយគត់របស់សិង្ហបុរី គឺការសម្រេចឲ្យបាននូវឧស្សាហូបនីយកម្មសម្រាប់ការនាំចេញជំនួសវិញ ដោយការព្យាយាមបង្កើតនូវឧស្សាហកម្មច្រើនប្រភេទ ដែលអាចប្រកួតប្រជែងជាមួយប្រទេសដទៃទៀតនៅលើពិភពលោកបានទាំងគុណភាព និងតម្លៃ ដោយមិនគិតអំពីផលចំណេញនៃពន្ធលើទំនិញនាំចេញនិងនាំចូលឡើយ ។ យុទ្ធសាស្ត្រនេះបានផ្តល់នូវជោគជ័យយ៉ាងធំធេងដល់ប្រទេសសិង្ហបុរី ហើយនិងហុងកុង តៃវ៉ាន់ ព្រមទាំងកូរ៉េខាងត្បូងដែលជា «កូននាគ» ដទៃទៀតផងដែរ ។ ក្នុងរយៈពេលមួយទសវត្សរ៍នេះ ធនាគារពិភពលោកនិងបណ្ឌិតសេដ្ឋវិទូភាគច្រើនបានសន្និដ្ឋានថា ចំពោះយុទ្ធសាស្ត្រនៃការអភិវឌ្ឍឧស្សាហូបនីយកម្មសម្រាប់ការនាំចេញ មានឥទ្ធិពលខ្លាំងជាងឧស្សាហូបនីយកម្មជំនួសការនាំចូល ។ ប៉ុន្តែ ទស្សនៈបែបនេះ មិនអាចលាក់បំបាំងល្បែងដ៏ធំមួយ ដែលប្រទេសសិង្ហបុរីបានលេងទាំងប្រថុយប្រថាននាពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៦០ ឡើយ ។

ដូច្នេះ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ ប្រទេសសិង្ហបុរីដែលហាក់ដូចជាត្រូវពួកកុម្មុយនិស្តលាក់ខ្លួនមួយក្រុមអុកឡុករាល់ពេលនោះ បានធ្វើឲ្យបណ្ឌិតសេដ្ឋវិទូដែលប្រកាន់នូវទស្សនៈចាស់គំរិល និងសកម្មជនសិទ្ធិមនុស្សស្ងើចសរសើរយ៉ាងខ្លាំង ចំពោះអត្រាកំណើនសេដ្ឋកិច្ចដ៏គួរឲ្យកត់សម្គាល់ដល់កម្រិតមួយ ដែលមានអត្រាសន្សំខ្ពស់បំផុតនៅលើពិភពលោក ។ គេបានប្រែក្លាយវាលលិចទឹក ដែលសម្បូរដោយដើមកោងកាង ឲ្យក្លាយជាដីសម្រាប់អភិវឌ្ឍន៍ឧស្សាហកម្ម រីឯផ្លូវវិថីផ្កាកេសរកូល បានក្លាយជាវិថីលក់ទំនិញដ៏មានប្រជាប្រិយភាពនិងទំនើបបំផុត ។ មកទល់នឹងពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ ប្រទេសសិង្ហបុរីបានក្លាយជាប្រទេសចែកចាយគ្រឿងបច្ចេកវិទ្យាដ៏ធំមួយក្នុងពិភពលោក ដោយបានផលិតនូវឌីស (ថាស) ផ្ទុកទិន្នន័យក្នុងម៉ាស៊ីនកុំព្យូទ័រ ប្រហែលជិតពាក់កណ្តាលនៃផលិតផលទូទាំងពិភពលោក ។ មកទល់នឹងចុងទសវត្សរ៍ឆ្នាំ ១៩៨០ ប្រទេសថៃបានស្ថិតក្នុង

ចំណាត់ថ្នាក់លេខ ៤ នៅក្នុងទ្វីបអាស៊ី (បន្ទាប់ពីប្រទេសជប៉ុន តៃវ៉ាន់ និងកូរ៉េខាងត្បូង) ជាប្រទេសនាំចេញនូវផលិតផលតម្បាញ ហើយរកចំណូលបានពីការនាំចេញសម្លៀកបំពាក់ច្រើនជាងការនាំចេញអង្ករពេលមុនៗ ទៅទៀត ។ ប្រទេសថៃក៏បានចាប់ផ្តើមនាំចេញនូវរថយន្តធុនតូចម៉ាកមិតស៊ុយប៊ីស៊ីឡង់ស៊ែរ (Mitsubishi Lancer) ដែលតម្លើងនៅក្នុងប្រទេសផ្ទាល់ ហើយប្តូរឈ្មោះទៅជា ដូដជ៍និងភ្លីមោស ខូលថ៍ (Dodge and Plymouth Colts) វិញ (ដើម្បីជៀសវាងរបាំងពន្ធគយ) ទៅកាន់ប្រទេសកាណាដានៅឆ្នាំ ១៩៨៨ ។ ក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ និង ១៩៨០ ប្រទេសហ្វីលីពីនបានអភិវឌ្ឍនូវសេដ្ឋកិច្ចនាំចេញផ្អែកលើផលិតផលមួយចំនួន ដូចជា សម្លៀកបំពាក់ សៀគ្វីអេឡិចត្រូនិចក្នុងកុំព្យូទ័រ និងគ្រឿងអេឡិចត្រូនិកផ្សេងៗ ទៀត ។ នេះជាហេតុបណ្តាលឲ្យការធ្លាក់ចុះនូវថ្លៃដំណាំកសិកម្មរបស់ខ្លួនមួយចំនួន មិនមែនជាគ្រោះថ្នាក់អាក្រក់ដូចពេលមុនប៉ុន្មានឡើយ ។

នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ប្រទេសម៉ាឡេស៊ីប្រហែលជាប្រទេសដែលមាននូវទស្សនីយភាពឧស្សាហកម្មដែលទាក់ទាញចិត្តបំផុតក្នុងចំណោមប្រទេសទាំងអស់ ដោយមាននូវអគារទើសមេឃដ៏ខ្ពស់បំផុតនៅលើពិភពលោក ។ ទស្សនីយភាពសំណង់ផ្លូវសហព័ន្ធពីកំពង់ផែក្លាងទៅកាន់ទីក្រុងកូឡាឡាំពួរ ស្ថិតនៅភាគខាងលិចនៃឧបទ្វីបម៉ាឡាយូ បានធ្វើឲ្យមន្ត្រីអាណានិគមអង់គ្លេសចំណាស់ៗ ភ្ញាក់ផ្អើលជាខ្លាំង នៅពេលដែលពួកគេត្រឡប់មកទស្សនាម្តងទៀត បន្ទាប់ពីប្រទេសម៉ាឡេស៊ីទទួលបានឯករាជ្យពីរបីទសវត្សរ៍កន្លងទៅ ។ រោងចក្រអេឡិចត្រូលុចដែហាត់ស៊ឺ និងម៉ូតូរ៉ូឡា (រួមជាមួយនឹងរោងចក្រកែច្នៃម្ហូបអាហារ រោងចក្រធ្វើស្រោមសំបុត្រ រោងចក្រធ្វើរថយន្ត និងរោងចក្រធ្វើសម្ភារៈប្រព័ន្ធទឹក) នាពេលបច្ចុប្បន្ននេះ ក្លាយជាមានសារៈសំខាន់ជាងវិហារអ៊ិស្លាម និងចម្ការដូងប្រេងមួយចំនួនដែលនៅសល់របស់ប្រទេសម៉ាឡេស៊ីទៅទៀត ។ មកទល់នឹងចុងសតវត្សរ៍ទី ២០ ប្រទេសម៉ាឡេស៊ីបាននាំចេញគ្រឿងអគ្គិសនីនិងទំនិញអេឡិចត្រូនិក មានចំនួនច្រើនជាងពាក់កណ្តាលនៃទំនិញនាំចេញរបស់ខ្លួន ។ ប្រទេសម៉ាឡេស៊ីក្លាយជាប្រទេសនាំចេញនូវម៉ាស៊ីនត្រជាក់ និងម៉ាស៊ីនចាក់កាសែតវីដេអូដ៏ធំជាងគេនៅលើពិភពលោក ។

ចំណែកឯប្រទេសភូមា វៀតណាម កម្ពុជា និងលាវវិញ បានស្ថិតនៅពីក្រោយនៃរឿងជោគជ័យទាំងអស់នេះ ។ ក្នុងបរិបទតំបន់ បដិវត្តន៍ឧស្សាហកម្មផ្សេងៗ របស់បណ្តាប្រទេសអាស៊ីអាគ្នេយ៍ បានបណ្តាលឲ្យមានភាពខុសគ្នាយ៉ាងច្រើននៃការរីកចម្រើន ដែលមិនធ្លាប់មានពីមុន ក្នុងចំណោមសង្គមអាស៊ីអាគ្នេយ៍ទាំងឡាយ ។ នៅដើមសតវត្សរ៍ទី ២១ តម្លៃសរុបនៃការនាំចេញរបស់ប្រទេសសិង្ហបុរី មានច្រើនជាងតម្លៃសរុបនៃការនាំចេញរបស់ប្រទេសឥណ្ឌូនេស៊ី ចំនួន ២ ដង និងស្មើនឹង ៣ ដង បើប្រៀបធៀបជាមួយប្រទេសហ្វីលីពីន ។ រីឯតម្លៃសរុបនៃការនាំចេញក្នុងមួយឆ្នាំៗ របស់ប្រទេសថៃ ច្រើនជាងតម្លៃសរុបនៃការនាំចេញរបស់ប្រទេសវៀតណាមស្ទើរតែ ៥ ដង ។ បន្ថែមពីលើនេះ អាយុជីវិតជាមធ្យមរបស់ប្រជាជនម៉ាឡេស៊ី គឺ ៧៣ ឆ្នាំ វែងជាងអាយុជីវិតជាមធ្យមរបស់ប្រជាជននៃប្រទេសកម្ពុជាដែលមានត្រឹមតែ ៥៤ ឆ្នាំនោះ ។ នៅក្នុងឆ្នាំ ១៩៧០ ផលិតភាពនិងកម្រិតជីវភាពរបស់បណ្តាប្រទេសអាស៊ីអាគ្នេយ៍ទាំងឡាយ មានភាពស្រដៀងគ្នាច្រើន ។

## គំរូរបស់បូព៌ាប្រទេសនិងបស្ចិមប្រទេស

តើបដិវត្តន៍ឧស្សាហកម្មទាំងអស់នេះបានកើតឡើងយ៉ាងដូចម្តេច ? នៅក្នុងករណីមួយចំនួន ហេតុអ្វីបានជាបដិវត្តន៍

ឧស្សាហកម្ម មិនអាចកើតឡើង ? អស់រយៈពេលជាយូរ ភាពអន្ទះអន្ទែងរបស់បណ្ដាសស្សរជនអាស៊ីអាគ្នេយ៍ ដែលចង់សម្រេចឲ្យបាននូវឧស្សាហកម្មទំនើបដ៏ខ្លាំងមួយ មិនអាចទទួលលទ្ធផលជាក់ស្ដែងដូចដែលពួកគេចង់បាន ។ នៅក្នុងឆ្នាំ ១៩៥៧ សេដ្ឋវិទូឥណ្ឌូនេស៊ី មហាម៉ាត់ សាដ់លី (Mohammad Sadli) បានទាត់ចោលនូវទ្រឹស្ដីសគ្គម ដែលមានប្រព័ន្ធសេដ្ឋកិច្ចពីរយ៉ាងដែលមិនអាចផ្ដាច់ចេញពីគ្នាបាន របស់លោកសាស្ត្រាចារ្យ ប៊ូក ដោយអះអាងថា ទ្រឹស្ដីនោះបានបង្ហាញអំពីនិរន្តរភាពអាណានិគមនិយមរបស់ពួកបស្ចិមប្រទេស ហើយថា គ្មានហេតុផលណាមួយដែលបង្ហាញថា ប្រទេសឥណ្ឌូនេស៊ីមិនអាចក្លាយទៅជាប្រទេសឧស្សាហកម្មបាននោះទេ ។ នៅក្នុងឆ្នាំ ១៩៦៥ មុនពេលដែលលោកប្រធានាធិបតី ស៊ូការណូ ត្រូវគេបណ្ដេញចេញពីតំណែង គាត់បានបកស្រាយបន្ថែមអំពីបញ្ហានេះ ។ គាត់បានថ្លែងប្រាប់ទៅដល់ប្រជាពលរដ្ឋឥណ្ឌូនេស៊ីថា បណ្ដាសៀវភៅសេដ្ឋកិច្ចរបស់បស្ចិមប្រទេសគ្រប់ប្រភេទ មិនមែនជាក្បួនច្បាប់ដ៏ល្អឥតខ្ចោះនោះទេ ហើយចំពោះការធ្វើបដិវត្តន៍ជាតិ ដូចឥណ្ឌូនេស៊ីជាដើម មិនអាចវាស់វែងបានតាមស្ដង់ដារសៀវភៅណាមួយបានទេ «ទោះបីជាសៀវភៅនោះបាននិពន្ធដោយសាស្ត្រាចារ្យក្បាលទំពែកមកពីសាកលវិទ្យាល័យអក្សហ្វ៊ដ (Oxford University) ឬសាកលវិទ្យាល័យខនែល (Cornell University) ក៏ដោយ» ។

ចំពោះបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ទាំងឡាយ ដែលខ្វះការអត់ធ្មត់ក្នុងការអភិវឌ្ឍនាទសវត្សរ៍ឆ្នាំ ១៩៥០ និង ១៩៦០ នោះ សេដ្ឋកិច្ចបែបផែនការប្រមូលផ្ដុំទ្រព្យធំរបស់សហភាពសូវៀត និងប្រទេសចិនកុម្មុយនីស្ដ ហាក់ដូចជាជម្រើសថ្មីមួយដ៏សមហេតុផល ដើម្បីជំនួសសេដ្ឋកិច្ចបែបមូលធនដែលងាយធ្លាក់ចុះដុនដាបរបស់បណ្ដាប្រទេសដែលធ្លាប់បានដាក់អាណានិគមមកលើបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ទាំងនោះ ។ ក្រោយសម័យអាណានិគម សហភាពសូវៀតបានជំរុញបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ឲ្យជឿជាក់ថា សហគ្រាសឯកជន និងទីផ្សារសេរី មិនជាប់ទាក់ទងនឹងសុខុមាលភាពជាតិទេ ហើយជនជាតិចិននិងឥណ្ឌា ដែលជាអ្នកកាន់កាប់នូវពាណិជ្ជកម្មភាគច្រើននៅក្នុងតំបន់អាស៊ីអាគ្នេយ៍នោះ មិនគួររាប់រកទេ ។ ចំណង់ចង់ក្លាយជារដ្ឋសង្គមនិយមគំរូ មានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ។ វណ្ណៈបញ្ញវន្តរបស់ប្រទេសឥណ្ឌូនេស៊ី ដែលកើតឡើងដោយសារអាណានិគមហូឡង់នោះ គឺកូនរបស់អភិបាល ឬក៏កូនរបស់គ្រូសាសនាអ៊ិស្លាម ហើយពួកគេមានទស្សនៈគាំទ្រចំពោះការគ្រប់គ្រងសេដ្ឋកិច្ច និងមើលងាយចំពោះរបបមូលធននិយម ដែលពួកគេគិតថា «មានលក្ខណៈបរទេស» ឬជា «អំពើបាប» នោះ ស្ថិតនៅជាប់ជាមួយនឹងជីវប្រវត្តិគ្រួសាររបស់ពួកគេជានិច្ច ។ ជនជាតិហ្វីលីពីន ដែលស្ថិតក្នុងវណ្ណៈខ្ពស់ៗ ហើយដែលក្រុមគ្រួសាររបស់ពួកគេ មានចំណូលចិត្តធ្វើជំនួញលើវិស័យកសិកម្មនោះ មិនមានចំណាប់អារម្មណ៍ចំពោះទស្សនៈរដ្ឋសង្គមនិយមឡើយ ។

មានតែប្រទេសវៀតណាម ដែលជារដ្ឋកុម្មុយនីស្ដមួយគត់ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ បានអនុវត្តតាមទាំងស្រុងនូវសុបិនសេដ្ឋកិច្ចបែបសូវៀត ។ ដើម្បីអនុវត្តដូចនេះ ប្រទេសវៀតណាមបានធ្វើខ្លួនឲ្យឃ្លាតឆ្ងាយអស់រយៈពេលយ៉ាងយូរពីបដិវត្តន៍ឧស្សាហកម្មដ៏មានជោគជ័យរបស់ប្រទេសឯទៀតនៅតំបន់នេះ ។ ចំពោះមេដឹកនាំកុម្មុយនីស្ដវៀតណាម នៅរវាងឆ្នាំ ១៩៥៤ និងឆ្នាំ ១៩៨៦ ពាក្យថា «សង្គមនិយម» មានន័យថា ឧស្សាហកម្មធុនធ្ងន់ទ្រង់ទ្រាយធំដែលគ្រប់គ្រងដោយរដ្ឋ ។ ទម្រង់នៃគម្រោងឧស្សាហកម្មបែបនេះ មានដូចជា សំណង់អគាររោងចក្រធ្វើដែកនិងដែកថែបថាយង្វៀន (Thái Nguyên) ដែលគេបានសាងសង់ឡើងនៅក្នុងឆ្នាំ ១៩៦០ ជា

*ដើម ។ សាធារណជនវៀតណាមមានការយល់ដឹងតិចតួចណាស់ អំពីគម្រោងនេះ ប៉ុន្តែគម្រោងនេះត្រូវចំណាយដើមទុនស្មើទៅនឹងទិន្នផលស្រូវទាំងអស់ក្នុងរយៈពេលមួយឆ្នាំរបស់ប្រទេសនេះ ដើម្បីកសាងនូវសំណង់រោងចក្រនេះឡើង ។ តាមពិត គម្រោងនេះហួសពីលទ្ធភាពរបស់ប្រទេសវៀតណាមទៅទៀត តែបានប្រទេសរុស្ស៊ីនិងប្រទេសចិន ជួយផ្តល់ជាជំនួយក្នុងការចំណាយទៅលើការសាងសង់ ។ ដោយសារតែការដឹកនាំខុសតាមទស្សនៈ «ពឹងលើខ្លួនឯង» របស់ស្តាលីន និងដោយសារតែការបង្កើនការពឹងពាក់ទៅលើជំនួយពីបណ្តាប្រទេសកុម្មុយនីស្តនោះ អ្នកការិយាល័យាធិបតេយ្យក្រុងហាណូយ បានបង្ហាញចំណាប់អារម្មណ៍តិចតួចលើវិស័យពាណិជ្ជកម្មអន្តរជាតិនិងការពង្រីកនូវការនាំចេញ ទោះបីប្រទេសនេះនៅតែត្រូវការចំណាយយ៉ាងច្រើនទៅលើទំនិញនាំចូលក៏ដោយ ។ ជាមួយគ្នានេះ អ្នកនិពន្ធប្រលោមលោកវៀតណាមជាច្រើន បានបម្រើឲ្យក្តីប្រាថ្នារបស់សហភាពសូវៀតដោយបានបោះពុម្ពនូវប្រលោមលោកទាក់ទងទៅនឹងជីវិតវណ្ណៈអធន មានដូចជាប្រលោមលោក* **ឥម្ពុកទរ័រ** *និពន្ធដោយ វ៉ោ ហ៊ុយតឹម* (Võ Huy Tâm) *ឬប្រលោមលោក* **ស៊ីម៉ងត៍** *និពន្ធដោយ ហ៊ុយ ផឿង* (Huy Phương) *ក្នុងគោលបំណងដើម្បីសម្តែងសេចក្តីអបអរចំពោះ «ប្រជាជនថ្មី» ដែលវៀតណាមចង់បាន ។ នេះគឺជាការខិតខំប្រឹងប្រែងមួយដ៏គួរឲ្យកត់សម្គាល់ ដើម្បីជំរុញតថភាពសេដ្ឋកិច្ចអាស៊ីអាគ្នេយ៍ ឲ្យដូចទៅនឹងតថភាពរបស់ជីវិតកម្មករនៅក្នុងទ្វីបអឺរ៉ុបខាងកើត ។*

*ទោះជាយ៉ាងណាក៏ដោយ ប្រទេសនេះនៅមានបញ្ហាលំបាកសេសសល់មួយចំនួន ។ នៅក្នុងឆ្នាំ ១៩៨០ ប្រទេសវៀតណាមមានប្រាក់ចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗ មិនច្រើនជាងមួយភាគដប់ បើប្រៀបធៀបទៅនឹងប្រាក់ចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗ នៅក្នុងប្រទេសប៊ុលការីនិងរូម៉ានី នាឆ្នាំ ១៩៦០ ផង ។ ទោះបីជាបញ្ហានេះ បណ្តាលមកពីសង្គ្រាមដ៏សាហាវជាមួយនឹងបារាំងនិងសហរដ្ឋអាមេរិកក៏ដោយ ក៏មនោគមវិជ្ជារបស់រដ្ឋវៀតណាមបានធ្វើដំណើរលើផ្លូវមួយ ងាកចេញពីប្រវត្តិសាស្ត្ររបស់ខ្លួននិងពីបណ្តាប្រទេសអាស៊ីអាគ្នេយ៍ដទៃទៀត ។ មកទល់នឹងទសវត្សរ៍ឆ្នាំ ១៩៨០ ប្រទេសវៀតណាមបានខិតខំលក់កម្លាំងពលកម្មដែលគ្មានការងារធ្វើរាប់សែននាក់របស់ខ្លួន ទៅឲ្យបណ្តាប្រទេសនានានៅក្នុងប្លុកសូវៀត ។ ពលករទាំងនោះ ត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅក្នុងអណ្តូងរ៉ែ នាបណ្តាប្រទេសអឺរ៉ុបខាងកើត និងរោងចក្រធ្វើរថយន្តនៅក្នុងសហភាពសូវៀត ។ ក្នុងដំណាក់កាលនោះ មេដឹកនាំវៀតណាមទាំងឡាយបានចាប់ផ្តើមយល់កាន់តែច្បាស់ថា ប្រទេសមហាអំណាចនៅជិតខាងខ្លួនដែលចេញដំណើរមុនជាច្រើនឆ្នាំនោះ មានប្រៀបលើខ្លួនរួចទៅហើយ ។ ក្នុងឆ្នាំ ១៩៥៧ លោក ម៉ៅ សេទុង បានដឹកនាំប្រទេសចិន ដោយអនុវត្តនូវគំរូសេដ្ឋកិច្ចទំនើបកម្មតាមទស្សនៈដ៏ចាស់គំរិលរបស់ស្តាលីន ហើយបានប្តេជ្ញាថា ប្រទេសចិននឹងយកឈ្នះលើផលិតកម្មដែកថែបអង់គ្លេសតែក្នុងរយៈពេល ១៥ ឆ្នាំទៀតប៉ុណ្ណោះ ។ ចំណែកឯប្រទេសជប៉ុនវិញ ក៏បានដាក់ប្រើនូវច្បាប់ពិសេសមួយឲ្យអនុវត្តជាបន្ទាន់ នូវគម្រោងអភិវឌ្ឍន៍ឧស្សាហកម្មអេឡិចត្រូនិកថ្នាក់ជាតិរបស់ខ្លួន ។ ឆ្នាំ ១៩៩១ ជាឆ្នាំដែលសហភាពសូវៀតបានដួលរលំ ។ ក្រុងហាណូយមានការយឺតយ៉ាវក្នុងការរៀបចំខ្លួន ដើម្បីទទួលយកជំបូន្មានរបស់ប្រទេសជប៉ុន ដែលរួមមានគម្រោងមិតស៊ុយប៊ីស៊ីសម្រាប់បង្កើតនូវឧស្សាហកម្មរថយន្តរបស់ប្រទេសវៀតណាមជាដើម ។*

*យើងឃើញថា ជោគជ័យនៃការធ្វើបដិវត្តន៍ឧស្សាហកម្មរបស់បណ្តាប្រទេសអាស៊ីអាគ្នេយ៍ ក្រោយសម័យអាណានិគម ពិតជាមិនអាចលេចចេញជារូបរាងបានទេ ប្រសិនបើគ្មានប្រទេសជប៉ុននោះ ករណីនេះលើកលែង*

ចំពោះប្រទេសវៀតណាម ។ ការឈ្វេងយល់របស់បណ្ដាប្រទេសអាស៊ីអាគ្នេយ៍ថា ឥទ្ធិពលរបស់ប្រទេសជប៉ុន អាចជួយឲ្យពួកគេរឹងមាំបាននោះ បានចាប់ផ្ដើមនៅចុងទសវត្សរ៍ឆ្នាំ ១៨៩០ គឺនៅពេលដែលអ្នកបដិវត្តហ្វីលីពីនជាច្រើនរូប បានស្នើឲ្យជប៉ុនជួយជ្រោមជ្រែងពួកគេក្នុងការតស៊ូប្រឆាំងទៅនឹងប្រទេសអេស្ប៉ាញនិងសហរដ្ឋអាមេរិក ។ ទស្សនវិស័យដូចនេះ ចាប់រីកសាយភាយតាំងពីពេលដែលជប៉ុនយកបានជ័យជម្នះលើប្រទេសរុស្ស៊ីនៅក្នុងឆ្នាំ ១៩០៥ មកម្ល៉េះ ។ ឥរិយាបថឈ្លានពានរបស់ជប៉ុន មកលើទ្វីបអាស៊ីរវាងឆ្នាំ ១៩៣១ និង ១៩៤៥ បានបណ្ដាលឲ្យមានប្រតិកម្មប្រឆាំងតបតពីសំណាក់បណ្ដាប្រជាពលរដ្ឋអាស៊ីអាគ្នេយ៍ទាំងឡាយជាច្រើនដែលភ័យខ្លាច ។ ប៉ុន្តែ ចាប់តាំងពីពេលនោះមក គេនៅឃើញមាននូវភាពឋិតថេររបស់ទ្រឹស្ដីសេដ្ឋកិច្ចមួយរបស់សេដ្ឋវិទូ អាកាម៉ាត់ស៊ុ កាណាម៉ិ (Akamatsu Kaname) ដែលថា ការទាមទាររួមគ្នាមួយរបស់បណ្ដាប្រទេសអាស៊ីទាំងឡាយ ដើម្បីទំនើបកម្មនោះ គឺប្រៀបដូចទៅនឹងការហោះហើររបស់សត្វក្ងាន ១ ហ្វូងអ៊ីចឹង ។ ប្រទេសជប៉ុន ដែលហាក់ដូចជាមេហ្វូងនោះ បានធ្វើឲ្យប្រទេសរបស់ខ្លួន ក្លាយជាប្រទេសឧស្សាហកម្មមុនគេបង្អស់ ហើយទុកឲ្យបណ្ដាប្រទេសអាស៊ីផ្សេងៗ ទៀត ហោះនៅពីក្រោយខ្លួនក្នុងទម្រង់ជារូបភាព ដោយផ្ដល់ឲ្យបណ្ដាប្រទេសអាស៊ីទាំងនោះ នូវបច្ចេកវិទ្យាផ្សេងៗ ដែលខ្លួនធ្លាប់បានទទួលជោគជ័យរួចមក ហើយនិងឧស្សាហកម្មហួសសម័យទាំងឡាយណាដែលគ្មានលក្ខណសម្បត្តិក្នុងការប្រកួតប្រជែងតទៅទៀតបាន ។

នៅទសវត្សរ៍ឆ្នាំ ១៩៦០ បណ្ដាប្រទេសអាស៊ីអាគ្នេយ៍ទាំងឡាយសុទ្ធតែបានយល់ដឹងថា ឥទ្ធិពលទាក់ទាញរបស់ជប៉ុនបានផ្អែកលើគំនិតមួយដែលថា ប្រទេសនេះបានរកឃើញនូវគំរូមួយនៃការអភិវឌ្ឍសេដ្ឋកិច្ច ដើម្បីយកប្រៀបលើសេដ្ឋកិច្ចទីផ្សារសេរីបែបបុគ្គលនិយមរបស់សហរដ្ឋអាមេរិក និងប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចដ៏រឹងត្អឹងនិងគ្មានការឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋនៃសហភាពសូវៀត ។ ក្នុងន័យនយោបាយ គំរូនៃការអភិវឌ្ឍសេដ្ឋកិច្ចបែបនេះ មានលក្ខណៈប្រជាធិបតេយ្យតែរូបរាងខាងក្រៅប៉ុណ្ណោះ តែតាមធាតុពិត គំរូនេះមានលក្ខណៈផ្ដាច់ការទៅវិញ ។ ក្នុងនោះ គេឃើញមានគណបក្សនយោបាយមួយតែប៉ុណ្ណោះ ដែលបានគ្រប់គ្រងប្រទេសជប៉ុនអស់រយៈពេលជាច្រើនទសវត្សរ៍ គឺចាប់តាំងពីឆ្នាំ ១៩៥៥ មក ។ ក្នុងន័យសេដ្ឋកិច្ចវិញ គំរូនេះបានបង្ហាញឲ្យឃើញពីការទទួលយក និងការកែលំអបច្ចេកវិទ្យាទំនើបខ្ពស់របស់បណ្ដាប្រទេសនៅទ្វីបអឺរ៉ុប និងសហរដ្ឋអាមេរិកទៅវិញ ។ គេបានបង្កើតម៉ាស៊ីនកុំព្យូទ័រឡើងដំបូងបង្អស់នៅឯបស្ចិមប្រទេស ប៉ុន្តែវាជាគំនិតរបស់ជនជាតិជប៉ុនឯណោះវិញទេ ដែលស្វែងរកទីផ្សារបានល្អបំផុតសម្រាប់ម៉ាស៊ីនកុំព្យូទ័រទាំងនោះ និងបានបង្កើតឲ្យមានពាក្យមួយហៅថា «សង្គមព័ត៌មាន» ឡើង ។

អស់រយៈពេលដ៏យូរ បណ្ដាប្រទេសអាស៊ីអាគ្នេយ៍ទាំងឡាយ មិនអាចធ្វើឲ្យប្រព័ន្ធសេដ្ឋកិច្ចរបស់ខ្លួនឲ្យដូចទៅនឹងប្រព័ន្ធសេដ្ឋកិច្ចរបស់ប្រទេសជប៉ុន ឬដូចទៅនឹងអ្វីដែលបណ្ដាប្រទេសអស់ទាំងនោះរំពឹងទុកឡើយ ។ ប៉ុន្តែ ពួកគេនៅតែទទួលស្គាល់ជប៉ុនថា ជាប្រទេសដែលទទួលបានជោគជ័យដ៏អស្ចារ្យមួយនៅអាស៊ី ។ នៅក្នុងឆ្នាំ ១៩៧៤ អ្នកជំនាញខាងយុទ្ធសាស្ត្រ ដោដ យូស៊ូហ្វ (Daud Jusuf) បានស្នើឲ្យមានការបង្កើតនូវ «ប្រទេសឥណ្ឌូនេស៊ីបែបក្រុមហ៊ុន» ដោយសង្ឃឹមថា នឹងអាចទទួលបាននូវជោគជ័យសម្រាប់អនាគតនៃសេដ្ឋកិច្ចរបស់ខ្លួន នៅលើមូលដ្ឋាននៃអគ្គភាពពាណិជ្ជកម្មជាតិទ្រង់ទ្រាយធំ ក្រោមកិច្ចសហប្រតិបត្តិការដ៏ស្អិតល្មួតក្នុងចំណោមអ្នកនយោបាយ អ្នកការិយាល័យាធិបតេយ្យ អ្នកបច្ចេកាធិបតេយ្យ និងសហគ្រិនទាំងឡាយ ។ ប្រទេសជប៉ុន ពិត

ជាអ្នកគាំទ្រគំនិតនៅពីក្រោយសំណើនេះ ។ នៅក្នុងឆ្នាំ ១៩៨២ លោកនាយករដ្ឋមន្ត្រី ម៉ាឡេស៊ី មហាធៀរ មហាម៉ាត់ បានបង្កើតនូវកម្មវិធី «ការសម្លឹងឆ្ពោះទៅទិសខាងកើត» ឡើង ដែលធ្វើឲ្យយើងនឹកទៅដល់ «ចលនាទៅទិសខាងកើត» របស់អ្នកជាតិនិយមវៀតណាមទៅសិក្សានៅជប៉ុនក្នុងឆ្នាំ ១៩០៥ ។ នាយករដ្ឋមន្ត្រីម្នាក់នេះបានធ្វើការអះអាងថា គុណតម្លៃរបស់ជនជាតិជប៉ុន មានលក្ខណៈស្រដៀងទៅនឹងក្រមសីលធម៌ដែលជនជាតិម៉ាឡេស៊ីមាន ឬ «បម្រុងនឹងមាន» ។ នៅសម័យក្រោយអាណានិគម បណ្តាប្រទេសអាស៊ីអាគ្នេយ៍ទាំងឡាយបានយកគំរូតាមរូបភាពដ៏ល្អប្រពៃនៃតម្លៃការងារជាសហគមន៍ ជាពិសេស ដូចជា ការសហការដ៏មុតមាំក្នុងការងារជាក្រុម ទំនាក់ទំនងដ៏ស្អិតល្មួត និងភាពស្មោះស្ម័គ្រចំពោះក្រុម ។ នៅក្នុងឆ្នាំ ១៩៩៤ គណៈកម្មការសម្រាប់ទ្វីបអាស៊ីថ្មីមួយដែលមានទីចាត់ការនៅប្រទេសម៉ាឡេស៊ី បានលើកឡើងថា គ្រួសារ និង បងប្អូន ដែលជា «ទីស្នាក់អាស្រ័យដ៏ពិសិដ្ឋ» ត្រូវបានបំផ្លាញដោយទស្សនៈបុគ្គលនិយមរបស់បស្ចិមប្រទេស ។ អគ្គរដ្ឋទូតសិង្ហបុរីម្នាក់ឈ្មោះ លោក ថម្មី កូហ៍ (Tommy Koh) បានបញ្ចេញយោបល់ថា ពេលនេះជាពេលសម្រាប់បស្ចិមប្រទេសរៀនសូត្រពីបូព៌ាប្រទេស នូវការគោរពសិទ្ធិអំណាចនិងកិច្ចព្រមព្រៀងក្នុងការធ្វើសេចក្តីសម្រេចចិត្តហើយ ។

ការសម្តែងឡើងនូវការផ្លាស់ប្តូរលទ្ធភាពប្រកបដោយលក្ខណៈសុទិដ្ឋិនិយមចំពោះគុណតម្លៃរបស់អាស៊ី បានធ្វើឡើងដោយផ្អែកជាមូលដ្ឋានលើបទពិសោធន៍ជាប្រវត្តិសាស្ត្ររបស់ប្រទេសជប៉ុន ដែលមានដូចជាកំណើនប្រជាជនតិច រាជការមានប្រសិទ្ធភាពនិងស្វ័យភាព អត្រាសន្សំក្នុងស្រុកខ្ពស់ និងការការពាររបស់សហរដ្ឋអាមេរិកក្នុងសម័យសង្គ្រាមត្រជាក់ ។ កត្តាទាំងនេះជួយប្រទេសជប៉ុនឲ្យផ្តោតលើការអភិវឌ្ឍសេដ្ឋកិច្ច ជាជាងការចំណាយទៅលើវិស័យយោធា ។ ទោះមុនពេលដែលសេដ្ឋកិច្ចរបស់ប្រទេសជប៉ុន បានរីកចម្រើនដល់កម្រិតកំពូលនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ក៏ដោយ ប្រទេសអាស៊ីអាគ្នេយ៍ខ្លះបានដឹងយ៉ាងច្បាស់ពីដំណើរការរីកចម្រើននេះ ។ នៅក្នុងឆ្នាំ ១៩៨៨ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មឥណ្ឌូនេស៊ី អា.អ៊ែរ. ស៊ូហ៊ូដ (A. R. Soehoed) បានគូសបញ្ជាក់ថា ប្រទេសឥណ្ឌូនេស៊ីមិនអាចតាមទាន់ក្បាននាំមុខជប៉ុននោះបានទេ បើឥណ្ឌូនេស៊ីគ្រាន់តែហើរតាមលំនាំរបស់ជប៉ុននោះ ។ ស្ថានភាពនេះមិនមែនមកពីប្រការដែលថា ប្រទេសឥណ្ឌូនេស៊ីគ្មាននូវបុគ្គលិក ដើម្បីចាត់ចែងកិច្ចការក្រសួងពាណិជ្ជកម្ម ដែលយកលំនាំតាមប្រទេសជប៉ុននោះទេ ប៉ុន្តែ បញ្ហាចម្បង គឺនៅត្រង់ថា ប្រវត្តិសាស្ត្រទាំងមូលរបស់ប្រទេសឥណ្ឌូនេស៊ី ដែលជាប្រទេសមានជាតិសាសន៍ចម្រុះ ព្រមទាំងមាននូវដែនសមុទ្រវែងនោះ ងាយទទួលរងនូវឥទ្ធិពលអរិយធម៌ផ្សេងៗ ដែលបង្កការលំបាកដល់ប្រទេសឥណ្ឌូនេស៊ី ។ ស្ថានភាពនេះខុសពីប្រទេសជប៉ុន ដែលងាយគ្រប់គ្រងទំនាក់ទំនងរបស់ខ្លួនជាមួយនឹងបណ្តាប្រទេសនានា ។ រីឯអ្នកប្រាជ្ញហ្វីលីពីនជាច្រើន មានការព្រួយបារម្ភថា ការគោរពអំណាចថ្នាក់លើខ្លាំងពេក តាមរបៀបជប៉ុន នឹងធ្វើឲ្យការគ្រប់គ្រងបែបផ្តាច់ការដ៏ពុករលួយរបស់ប្រធានាធិបតី ហ្វឺឌីណង់ ម៉ាកូស (Ferdinand Marcos) ក្លាយមកជាត្រឹមត្រូវស្របច្បាប់វិញ ។ នៅពាក់កណ្តាលទសវត្សរ៍ទី ១៩៩០ អ្នកជំនាញវៀតណាម ដែលរស់នៅក្នុងប្រទេសមួយដែលប្រកាន់យកនូវលទ្ធិខុងជឺតាំងពីយូរលង់ណាស់មកហើយនោះ បានសរសេរអំពីភាពរឹងប៉ឹងរបស់ជនជាតិជប៉ុន ដោយឆ្លុះបញ្ចាំងថា លទ្ធិខុងជឺរបស់ជប៉ុន មានលក្ខណៈខុសពីគេ ដោយសង្កត់ធ្ងន់លើនិយមន័យនៃភាពស្មោះស្ម័គ្រខ្លាំងជាងប្រទេសដទៃទៀតដែលអនុវត្តតាមលទ្ធិដូចគ្នានេះ ។

កត្តាដែលមិនអាចធ្វើឲ្យប្រទេសជប៉ុនផ្តាច់ចេញពីដំណើរធ្វើបដិវត្តន៍ឧស្សាហកម្មរបស់អាស៊ីអាគ្នេយ៍ គឺជំនួយអភិវឌ្ឍន៍និងការវិនិយោគ ។ យោងទៅលើការគន់គូរមួយ ជំនួយរបស់ប្រទេសជប៉ុនមានពី ១៥% ទៅ

២០% នៃការចំណាយថវិការបស់ប្រទេសនីមួយៗ ស្ទើរតែទាំងអស់នៅក្នុងអាស៊ីអាគ្នេយ៍ នៅចុងទសវត្សរ៍ឆ្នាំ ១៩៨០ ។ នៅអំឡុងទសវត្សរ៍ឆ្នាំ ១៩៨០ និង ១៩៩០ ប្រទេសជប៉ុនក៏ជាប្រទេសវិនិយោគបរទេសនាំមុខគេដែរនៅក្នុងតំបន់នេះ ។ ការវិនិយោគរបស់ជប៉ុន មានទម្រង់ជាសហគ្រាសសម្ព័ន្ធអាជីវកម្មជាមួយប្រទេសម្ចាស់ស្រុកក្នុងតំបន់ ហើយដៃគូវិនិយោគភាគច្រើន គឺជាសមាជិករបស់ក្រុមវរជនសេដ្ឋកិច្ច ។ បើប៉ាន់ប្រមាណទៅ នៅចុងទសវត្សរ៍ឆ្នាំ ១៩៧០ ដៃគូវិនិយោគជនជាតិហ្វីលីពីនរបស់ប្រទេសជប៉ុននៅក្នុងសហគ្រាសសម្ព័ន្ធអាជីវកម្មជប៉ុន-ហ្វីលីពីន ចំនួន ៧៧ មាន ៤៦ ចេញមកពីគ្រួសារហ្វីលីពីនដែលមានឋានៈខ្ពង់ខ្ពស់ ។ ដៃគូវិនិយោគក្នុងស្រុករបស់ក្រុមហ៊ុនពហុជាតិជប៉ុន គឺអាចជារដ្ឋាភិបាលរបស់បណ្តាប្រទេសអាស៊ីអាគ្នេយ៍ផ្ទាល់តែម្តង ។ ក្រុមហ៊ុនមិតស៊ុយប៊ីស៊ីបានផ្គត់ផ្គង់នូវគ្រឿងរថយន្តនិងក្បួនរចនាម៉ូតជាច្រើនដល់ការផលិតរថយន្តម៉ាកប្រូតុនសាហ្គា (Proton Saga) ក្រោមការជួយឧបត្ថម្ភផលិតដោយរដ្ឋាភិបាលម៉ាឡេស៊ី ។ ដូចដែលជនជាតិជប៉ុនមួយចំនួនបានរិះគន់ខ្លួនឯងផលិតករជប៉ុនបានធ្វើវិនិយោគក្នុងតំបន់អាស៊ីអាគ្នេយ៍ ដោយមានបំណងចង់បង្កើតសេដ្ឋកិច្ចតំបន់មួយ ដែលមានការបែងចែកវណ្ណៈតែប៉ុណ្ណោះ ។ ក្នុងនោះ រចនាសម្ព័ន្ធប្រាក់ឈ្នួលទ្វេភាគបែបប្រពៃណី ធ្លាប់បានអនុវត្តក្នុងប្រទេសជប៉ុន ដែលបានកំណត់ថា កម្មករណាដែលធ្វើការនៅក្នុងរោងចក្រឧស្សាហកម្មធំៗ ហើយមានការរៀបចំចាត់ចែងបានល្អនោះ នឹងអាចទទួលបានប្រាក់ឈ្នួលច្រើន ហើយកម្មករណាធ្វើការនៅក្នុងរោងចក្រម៉ៅបន្តនិងគ្មានការរៀបចំចាត់ចែងបានល្អនោះ នឹងទទួលបានប្រាក់ឈ្នួលតិចនោះ ត្រូវបានសាយភាយមកទិសខាងត្បូងដោយក្នុងនោះ តំបន់អាស៊ីអាគ្នេយ៍មានឋានៈជាអ្នកម៉ៅការបន្តដ៏ថោកទាបបំផុត ។ ប្រសិនបើបណ្តាប្រទេសអាស៊ីអាគ្នេយ៍ទាំងឡាយណា ធ្វើត្រឹមតែជាអ្នកម៉ៅការបន្តរបស់ជប៉ុននោះ ក្វានទាំងឡាយដែលហើរពីក្រោយ ប្រាកដជាត្រូវការចំណាយរយៈពេលយ៉ាងយូរ ដើម្បីតាមឲ្យទាន់មេហ្វូងរបស់វា ។

ទោះជាយ៉ាងណាក៏ដោយ ទំនាក់ទំនងជិតស្និទ្ធរវាងតំបន់អាស៊ីអាគ្នេយ៍ទៅនឹងប្រទេសជប៉ុន នៅតែពិបាកពន្យល់ថា តើហេតុអ្វីបានជាបន្ទាប់ពីទទួលបានឯករាជ្យមក បណ្តាប្រទេសអាស៊ីអាគ្នេយ៍មួយចំនួន អាចមានលទ្ធភាពធ្វើអ្វីមួយបាន ដែលបណ្តាប្រទេសនៅទ្វីបអាហ្វ្រិចនិងមជ្ឈិមបូព៌ា មិនអាចធ្វើបាន ។ ឧទាហរណ៍ដូចជាការរៀនផលិតរថយន្តនិងសៀគ្វីកុំព្យូទ័រ ដើម្បីលក់ចេញទៅកាន់បស្ចិមប្រទេសជាដើម ។ អាណានិគមនិយមបស្ចិមប្រទេសបានបន្សល់ទុកនូវពួកវរជនសំខាន់ៗ មួយចំនួនតូច នៅក្នុងបណ្តាប្រទេសអាស៊ីអាគ្នេយ៍ ដែលពួកទាំងនោះមានគំនិតច្នៃប្រឌិតខ្ពស់ប្រសើរជាង បើប្រៀបធៀបជាមួយនឹងពួកវរជននៅអាហ្វ្រិក អាមេរិកឡាទីន និងមជ្ឈិម-បូព៌ា ។ កត្តាទាំងនេះកំពុងតែត្រូវបានគេស្រាវជ្រាវបន្តទៀត ។ ក្រៅពីសកម្មភាពប្រឆាំងនឹងអាណានិគនិយមវិញបណ្តាប្រទេសអាស៊ីអាគ្នេយ៍ទាំងឡាយ ក៏មានអារម្មណ៍ថា ខ្លួនត្រូវបានគំរាមកំហែងដោយក្រុមបះបោរកុម្មុយនីស្តដែលជាគ្រោះថ្នាក់មួយយ៉ាងធំនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ជាងនៅតំបន់អាហ្វ្រិក ឬនៅអាមេរិកឡាទីនទៅទៀត ។ ពួកគេក៏មានការបារម្ភផងដែរ ចំពោះការប្រឈមមុខទៅនឹងការគំរាមកំហែងរបស់អ្នកនយោបាយនៃបណ្តាប្រទេសអាស៊ីអាគ្នេយ៍មួយចំនួន ដូចជាពួកខ្មែរក្រហមដែលបានបំផ្លាញចោលនូវរាល់ស្ថាប័នទំនើបផ្សេងៗ ដូចជាធនាគារនិងរូបិយវត្ថុជាដើម ។ ពួកវរជនទាំងនោះ គឺជាអ្នកកាន់អំណាចដើម្បីកសាងសេដ្ឋកិច្ចរួមសម្រាប់អនាគត ។ ពួកគេបានប្រថុយប្រថានអនាគតរបស់ខ្លួនដោយអនុវត្តនូវរបបសេដ្ឋកិច្ច ដែលរួមមានការបង្កើននូវការនាំចេញនិងសហគ្រាសឯកជនជាដើម ។ មហាអំណាចសហរដ្ឋអាមេរិកបានរួមចំណែកជាមួយនឹងកង្វល់របស់បណ្តាប្រទេស

អាស៊ីអាគ្នេយ៍ទាំងនោះ មិនបានធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៍របស់ពួកគេឡើយ ព្រោះបណ្តាប្រទេសទាំងនេះក៏ស្វះស្វែងរកមូលធនវិនិយោគនិងទីផ្សារសម្រាប់នាំចេញផលិតផលដែរ ។ មេដឹកនាំបណ្តាប្រទេសទាំងនោះភាគច្រើន ត្រូវបានអ្នកម៉ាក្សនិយមហៅថា «គហបតីក្នុងសម័យអាណានិគម» ។ អ្នកទាំងនោះបានទទួលសេរីភាពនិងអំណាចភ្លាមៗ ក្រោយសម័យអាណានិគម ហើយពួកគេជាតួអង្គនយោបាយដ៏សំខាន់ៗ របស់ប្រទេសទាំងនោះ ។ អ្នកនយោបាយសំខាន់ៗ ទាំងនោះ មានតាំងពីលោក លីក្វាន់យូ (Lee Kuan Yew) នាយករដ្ឋមន្ត្រីប្រទេសសិង្ហបុរី ចាប់ពីឆ្នាំ ១៩៥៩ ដល់ ១៩៩០ និងលោក មហាធៀរ មហាម៉ាត់ នាយករដ្ឋមន្ត្រីប្រទេសម៉ាឡេស៊ី ចាប់ពីឆ្នាំ ១៩៨១ ដល់ ២០០៣ រហូតដល់បណ្តាសេដ្ឋវិទូឥណ្ឌូនេស៊ី ដែលត្រូវបានគេដាក់រហស្សនាមក្នុងន័យចំអកថា «សមាគមជនអន្ធពាលសម្ងាត់ប៊ឺរឃ្លេយ៍ (Berkeley Mafia)» ដោយសារតែពួកគេធ្លាប់រៀននៅឯសាកលវិទ្យាល័យកាលីហ្វ័រនៀ ។

ក្រោយសម័យអាណានិគមបន្តិច គឺក្នុងឆ្នាំ ១៩៥៥ មានការជជែកវែកញែកដ៏ល្បីមួយនៅឯសាកលវិទ្យាល័យនៃប្រទេសឥណ្ឌូនេស៊ី ដើម្បីបង្កើតឲ្យមាននូវពាក្យថា «តស៊ូ» ជាថ្មីឡើង ។ ការជជែកវែកញែកនោះ ចង់សំដៅទៅលើប្រទេសអាស៊ីអាគ្នេយ៍ពីរយ៉ាង ដែលកំពុងតែរកការកកើតឡើង ។ អតីតនាយករដ្ឋមន្ត្រីឥណ្ឌូនេស៊ី លោក វីឡូប៉ូ (Wilopo) បានថ្កោលទោសទស្សនៈសេដ្ឋកិច្ចសេរីនិយមរបស់បស្ចិមប្រទេស ថា វាបណ្តាលឲ្យមាននូវការកេងប្រវ័ញ្ចស្របច្បាប់និងមានគម្លាតខុសគ្នាយ៉ាងធំនៅក្នុងការចែករំលែកធនធាន ។ គាត់បានអះអាងថា លទ្ធផលដ៏អាក្រក់នៃទស្សនៈនេះ បានធ្វើឲ្យខូចប្រយោជន៍ដល់បណ្តាប្រទេសអាស៊ីទាំងឡាយណា ដែលធ្លាប់ទទួលរងនូវអាណានិគម ច្រើនជាងការខូចប្រយោជន៍របស់បស្ចិមប្រទេស ។ លោក វីដយ៉ូយ៉ូ នីតិសាស្ត្រ (Widjojo Nitisastro) ដែលជាកូនប្រុសមួយរូបក្នុងគ្រួសាររបស់គ្រូបង្រៀនជនជាតិជ្វា និងជានិស្សិតដែលបានយកអាវុធប្រឆាំងពួកអង់គ្លេសនិងហូឡង់ មុនពេលដែលប្រទេសឥណ្ឌូនេស៊ីទទួលបានឯករាជ្យនោះ បានបន្ទោសលោក វីឡូប៉ូ ថា មិនបានគិតគូរពីភាពចាំបាច់ក្នុងការបង្កើតនិងការបែងចែកធនធាន ។ លោក វីដយ៉ូយ៉ូ បានរំលឹកលោក វីឡូប៉ូ ថា «សហគ្រាសសេរី» គឺមានរួមទាំងម្ចាស់ដី ដែលជាកសិករតូចតាច និងក្រុមហ៊ុនប្រេងសាំងសែលរ៉ូយាល់ដាច់ធ៍ (Royal Dutch Shell) ។ គាត់លើកឡើងទៀតអំពីលទ្ធភាពនៃការបង្កើតប្រព័ន្ធសេដ្ឋកិច្ចដែល «ប្រឆាំងនឹងប្រព័ន្ធសេដ្ឋកិច្ចសេរី» ដែលក្នុងនោះ យន្តការតម្លៃអាចឆ្លើយតបទៅនឹងការគ្រប់គ្រងរបស់រដ្ឋដែលរវល់នឹងប្រជាសង្គ្រោះ ។

ទម្រង់សេដ្ឋកិច្ចសេរីនិយម ដែលមិនយកលំនាំតាមបស្ចិមប្រទេស នៅក្នុងប្រទេសជប៉ុននិងកូរ៉េខាងត្បូង ហើយនិងភាពរីកវរនិងគ្រោះទុរ្ភិក្ស ដែលបានប៉ះពាល់ដល់ប្រទេសចិននៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ដោយសារតែរបបកុម្មុយនីស្តផ្តាច់ការរបស់លោក ម៉ៅ សេទុង បានធ្វើឲ្យទស្សនៈរបស់លោក វីដយ៉ូយ៉ូ ស្តីពីអាស៊ីអាគ្នេយ៍ បានទទួលការគាំទ្រច្រើន ។ សូម្បីតែអ្នកដាក់ចេញនូវគោលនយោបាយនៃបណ្តាប្រទេសអាស៊ីអាគ្នេយ៍មួយចំនួន ដូចជា អ្នកប្រើអំណាចផ្តាច់ការបែបយោធារបស់ប្រទេសថៃ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៦០ និង ១៩៧០ ក៏បានផ្លាស់ប្តូរនូវគោលនយោបាយរបស់រដ្ឋាភិបាលអាណត្តិមុនៗ ហើយចាប់ផ្តើមទទួលស្វាគមន៍ការវិនិយោគឧស្សាហកម្មពីបរទេសដែរ ។ ពួកគេបានអនុញ្ញាតឲ្យមាននូវកត្តាអាទិភាពមួយចំនួន ដូចជា សិទ្ធិកាន់កាប់ភាគហ៊ុនធំ ការមិនយកពន្ធលើប្រាក់ចំណេញរបស់សាជីវកម្មទាំងឡាយណាដែលទើបបើកដំណើរការដំបូង ការលើកលែងពន្ធចំពោះការនាំចូលនូវរោងចក្រពីបរទេស និងការអនុញ្ញាតឲ្យអ្នកបច្ចេកទេសបរទេសចូលក្នុងប្រទេសដោយសេរីក្នុងកម្រិតល្មម ។

## ការចូលរួមចំណែករបស់ជនជាតិចិនរស់នៅតំបន់អាស៊ីអាគ្នេយ៍

ក្រៅពីក្រុមអ្នកកាន់អំណាចដែលមានសមត្ថភាពគ្រប់គ្រាន់មួយក្រុមតូច យើងសម្គាល់ឃើញថា បណ្តាប្រទេសអាស៊ីអាគ្នេយ៍មួយចំនួន ដែលបានក្លាយទៅជាប្រទេសឧស្សាហកម្មដ៏មានជោគជ័យនៅក្នុងសម័យក្រោយអាណានិគមនោះ មានធនធានមួយផ្សេងទៀត ។ នោះគឺជាក្រុមជនជាតិភាគតិចដែលមានគំនិតច្នៃប្រឌិតផ្នែកសេដ្ឋកិច្ច ។ ប្រវត្តិសាស្ត្របានសបញ្ជាក់ម្តងហើយម្តងទៀត អំពីសារៈសំខាន់របស់ក្រុមមនុស្សភាគតិចពោរពេញដោយគំនិតច្នៃប្រឌិតទាំងនោះ ។ ពួកគេត្រូវបានគេរាំងមិនឲ្យមានប្រៀបលើទង្វើផ្សេងៗ របស់សង្គមដែលពួកគេរស់នៅ ។ ឧទាហរណ៍ដ៏ល្បីមួយ គឺហិរញ្ញាធិការីជនជាតិជ្វីហ្វនៅអឺរ៉ុបនាមជ្ឈិមសម័យ ដែលជាធម្មតាប្រកបមុខរបររកស៊ីចងការប្រាក់នៅក្នុងសង្គមគ្រិស្តសាសនាទាំងឡាយដែលចាត់ទុកការចងការប្រាក់ដូចជាបាបកម្ម ។ ពួកកាន់សាសនាគ្រិស្ត តែងតែដកហូតជនជាតិជ្វីហ្វចេញពីសកម្មភាពនយោបាយឬសកម្មភាពយោធារបស់ក្រុមវរជន ។ ដោយហេតុនេះ ពួកជ្វីហ្វត្រូវតែតាំងចិត្តបង្កើននូវទំនាក់ទំនងផ្អែកលើជំនឿទុកចិត្តគ្នា រវាងជនជាតិជ្វីហ្វដូចគ្នា ដើម្បីជាមធ្យោបាយមួយសម្រាប់ដោះស្រាយបញ្ហាជាមួយនឹងជនជាតិភាគច្រើន ដែលតែងតែប្រើប្រាស់និងកេងប្រវ័ញ្ចលើពួកគេ ។ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ តួនាទីនេះ គឺតម្រូវទៅលើជនជាតិចិន ហើយក្នុងចំណោមពួកនេះ យើងមាននាយទុនក្នុងស្រុកដ៏ល្បីល្បាញជាច្រើន ដែលបានបង្ហាញខ្លួនឡើងនៅក្នុងសម័យក្រោយអាណានិគម ។ ទស្សនាវដ្តី **ហ្វបស៍ម៉ាកាហ្សីន** (*Forbes Magazine*) បានប៉ាន់ប្រមាណនៅក្នុងឆ្នាំ ១៩៩៤ ថា មហាសេដ្ឋីអាស៊ីអាគ្នេយ៍ដែលមានជាប់ខ្សែស្រឡាយចិនមានចំនួន ៨៦% ក្នុងចំណោមមហាសេដ្ឋីអាស៊ីអាគ្នេយ៍ទាំងអស់ ។ តាមពិត នៅមុនឆ្នាំ ១៩៨៦ ប៉ុន្មានឆ្នាំចុងក្រោយនៃរបបសង្គមនិយមបែបស្តាលីននិយម រវាងឆ្នាំ ១៩៧៥ និង ១៩៨០ មូលហេតុមួយភាគនៃគ្រោះមហន្តរាយសេដ្ឋកិច្ច ដែលបានកើតឡើងនៅក្នុងប្រទេសវៀតណាម គឺបណ្តាលមកពីការបណ្តេញអ្នកជំនួញជនជាតិចិនដ៏ច្រើន ។

មានមូលហេតុជាច្រើនដែលនាំឲ្យជាតិសាសន៍ចិន ក្លាយជាអ្នកមានតួនាទីសំខាន់ក្នុងការធ្វើឲ្យមានបម្រែបម្រួលក្នុងសេដ្ឋកិច្ចអាស៊ីអាគ្នេយ៍ ។ ការតាំងចិត្តសម្រេចគោលដៅសមូហភាពដ៏រឹងមាំមួយ គឺជាមូលហេតុមួយក្នុងចំណោមមូលហេតុអស់ទាំងនោះ ។ ជនអន្តោប្រវេសន៍ចិនមកពីខេត្តហុកកៀន និងក្វាងទុង បានធ្វើដំណើរមកស្វែងរកជីវភាពរស់នៅប្រសើរជាងមុន នៅក្នុងតំបន់អាស៊ីអាគ្នេយ៍នាសតវត្សរ៍ទី ១៩ និងដើមសតវត្សរ៍ទី ២០ ។ ពួកគេភាគច្រើន គឺជាកសិករ ហើយអាចជាប្រជាពលរដ្ឋក្រីក្រ ប៉ុន្តែ ដោយសារពួកគេមានចិត្តមោះមុតក្នុងការធ្វើអន្តោប្រវេសន៍ និងមានជំនាញផ្នែកសហគ្រាសផងនោះ បានធ្វើឲ្យពួកគេមានប្រៀបលើអ្នកជិតខាងរបស់ពួកគេដែលមិនចាកចេញពីស្រុកចិន ។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ម្ចាស់ក្រុមហ៊ុនកសិពាណិជ្ជកម្មធំជាងគេមួយនៅក្នុងប្រទេសថៃ លោក ធនិន្ទ្រ ចៀរវនន្ទ្រ (ธนินทร์ เจียรวนนทร์ Dhanin Chiaravanont) ជានាយកនៃសហគ្រាស «ចម្រើនភោគភ័ណ្ឌ» (เจริญโภคภัณฑ์ Charoen Pokphand) មានដើមកំណើតពីឪពុកដែលជាជនអន្តោប្រវេសន៍ចិនតៀជីវ ដែលធ្លាប់ជាម្ចាស់ហាងដ៏តូចមួយខាងអាជីវកម្មនាំចូលនូវគ្រាប់ពូជពីស្រុកចិន និងនាំចេញវិញនូវស៊ុតពីស្រុកថៃ កាលពីទសវត្សរ៍ឆ្នាំ ១៩២០ ។

លទ្ធិខុងជឺ ដែលជាប្រព័ន្ធជំនឿបុរាណមួយ ចែងពីការគ្រប់គ្រងតាមឋានានុក្រមស្របតាមផ្លូវច្បាប់ និង

*សង្កត់ធ្ងន់ទៅលើសារៈសំខាន់ផ្នែកសីលធម៌នៃទំនាក់ទំនងញាតិសន្តាន ក៏ជាជំនួយមួយយ៉ាងប្រត្យក្សក្នុងការជួយជំរុញឲ្យអាជីវកម្មរបស់ជនជាតិចិនទាំងនោះ ទទួលបាននូវផលចំណេញដ៏ច្រើនផងដែរ ។ លទ្ធិខុងជឺនេះបានជួយសម្រួលដល់ការធ្វើជំនួញជាក្រុមមានប្រាក់ខែតិច និងការដឹកនាំតាមបែបគ្រួសារដ៏រឹងមាំ ។ «ញាតិសន្តាន» នៅក្នុងនេះ សំដៅទំនាក់ទំនងមនុស្សដែលមកពីខេត្តដូចគ្នានៅប្រទេសចិន ជាញាតិសន្តានមែនទែនក្តី មិនមែនទែនក្តី ។ នៅក្នុងឆ្នាំ ១៩៨២ សិង្ហបុរីបានអនុវត្តនូវការផ្សព្វផ្សាយរបស់រដ្ឋាភិបាលដើម្បីលើកតម្កើងជំនឿលើទស្សនៈខុងជឺ នៅតាមសាលារៀន ។ ប៉ុន្តែ យុទ្ធនាការនេះបានទទួលការរិះគន់យ៉ាងខ្លាំង ហើយក៏សាបរលាបបន្តិចម្តងៗ ក្នុងអំឡុងពេលតែមួយទសវត្សរ៍ប៉ុណ្ណោះ ។ ប្រការនេះមកពីមូលហេតុថា ជនជាតិសិង្ហបុរី ដែលមិនមែនជាកូនចៅចិន បានចាត់ទុកយុទ្ធនាការនេះជាឧបាយកលមួយបង្ខំឲ្យពួកគេជឿនិងប្រតិបត្តិទៅតាមគោលការណ៍និងជំនឿរបស់ជនជាតិចិន ។ នៅពេលនោះ ជនជាតិសិង្ហបុរីដើមកំណើតចិន ដែលបានទទួលការអប់រំតាមបែបអង់គ្លេស ក៏បានចោទប្រកាន់ទស្សនៈខុងជឺនេះ ថា គ្មានលក្ខណៈប្រជាធិបតេយ្យ និងមានលក្ខណៈបិតាធិបតេយ្យជ្រុលពេក ។*

*តាមការវិភាគចុងក្រោយ ទាំងទស្សនៈខុងជឺ និងទាំងការតាំងចិត្តក្នុងការសម្រេចជោគជ័យរបស់ជនជាតិចិនភាគខាងត្បូង ដ៏ពោរពេញទៅដោយភាពចង់មានចង់បាននោះ ហាក់ដូចជាមិនបានពន្យល់ឲ្យបានច្បាស់អំពីជោគជ័យនៃអាជីវកម្មរបស់ជាតិសាសន៍ចិនរស់នៅក្នុងដែនដីអាស៊ីអាគ្នេយ៍ទេ ។ តាមពិត កត្តាទាំងពីរខាងលើនេះ មានបន្តរហូតមកនៅក្នុងប្រទេសចិនអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ ។ ប៉ុន្តែ ប្រទេសចិនមិនដែលបង្កើតនូវពួកមូលធនល្បីល្បាញ ដូចនៅបណ្តាប្រទេសអាស៊ីអាគ្នេយ៍មួយចំនួននាសម័យក្រោយអាណានិគមទេ ។ បរិស្ថានប្រវត្តិសាស្ត្រតែមួយគត់របស់អាស៊ីអាគ្នេយ៍ ដែលតែងមានការរើសអើងនិងការត្រួតត្រាលើជនជាតិចិនទាំងនោះ បានតម្រូវឲ្យពួកគេខិតខំបញ្ចេញកម្លាំងថាមពលស្ទើរតែទាំងអស់ ចំពោះកិច្ចការពាណិជ្ជកម្ម ។ នេះជាករណីមួយដែលជំរុញឲ្យពួកគេមានការតាំងចិត្តដាក់លាក់មួយសម្រាប់ខ្លួនឯង ។*

*ប្រទេសអាស៊ីអាគ្នេយ៍មួយចំនួននៅសម័យមុនអាណានិគមនិងសម័យអាណានិគម មិនអនុញ្ញាតឲ្យជនជាតិចិនធ្វើជាមេដឹកនាំនយោបាយឬយោធាឡើយ ។ ប្រទេសទាំងនោះបានបង្អាក់ដល់ក្តីសង្ឃឹមរបស់ជនជាតិចិនដែលចង់ផ្លាស់ប្តូរទៅរកឋានៈខ្ពស់ៗ នៅក្នុងសង្គម ។ ទង្វើរើសអើងចំពោះជនជាតិចិន មានសភាពកាន់តែអាក្រក់ឡើងៗ នៅក្នុងដើមសម័យក្រោយអាណានិគម ។ នៅក្នុងប្រទេសថៃពីឆ្នាំ ១៩៣៨ និង ១៩៥៧ រដ្ឋាភិបាលដែលដឹកនាំដោយលោក ប្លែក ភិបូលសង្គ្រាម* (แปลก พิบูลสงคราม Plaek Phibul Songkhram) *បានហាមឃាត់មិនឲ្យមានសាលារៀនភាសាចិន និងបង្ខំឲ្យជនជាតិចិនទាំងនោះយកមន្ត្រីនយោបាយឬយោធាថៃ ជាអ្នកឈរឈ្មោះជួសពួកគេ ។ មិនត្រឹមតែប៉ុណ្ណោះ គេមិនអនុញ្ញាតកូនចៅចិនឲ្យចូលសិក្សានៅសាលាយោធាថៃទេ ។ នៅឯប្រទេសហ្វីលីពីន នាឆ្នាំ ១៩៥៧ វិញ គេបានបង្កើតឡើងនូវច្បាប់ស្តីពីការធ្វើជាតូបនីយកម្មលើអាជីវកម្មលក់រាយមួយក្នុងគោលបំណងបញ្ឈប់លែងឲ្យមានអ្នកលក់រាយជនជាតិចិន ដូចដែលបានធ្វើទៅលើអ្នកជួញអង្ករពីមុនមកអ៊ីចឹង ។ «គោលនយោបាយសេដ្ឋកិច្ចថ្មី» របស់ប្រទេសម៉ាឡេស៊ីនាឆ្នាំ ១៩៧០ ដែលមានគោលបំណងផ្តល់ផលប្រយោជន៍ដល់អ្នកស្រុកដើម (ហៅ «ភូមិបុត្រ») ត្រូវគេមើលឃើញថា ជាយុទ្ធនាការប្រឆាំងនឹងជនជាតិចិន ។ ចំណែកឯនៅក្នុងប្រទេសឥណ្ឌូនេស៊ីក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ វិញ គេមិនត្រឹមតែឃើញនូវការអនុវត្តច្បាប់ប្រឆាំង*

នឹងកូនចៅចិនប៉ុណ្ណោះទេ គេថែមទាំងឃើញមានការសម្លាប់ជនជាតិចិន យ៉ាងរង្គាលជាមួយនឹងអ្នកជាប់សង្ស័យថា ជាជនកុម្មុយនីស្តនៅក្នុងរដ្ឋប្រហារឆ្នាំ ១៩៦៥ ។ ហើយមួយជំនាន់ក្រោយមក ការវាយប្រហារលើខ្លួនប្រាណនិងទ្រព្យសម្បត្តិរបស់ពួកចិន បានកើតឡើងម្តងទៀត (បែបទម្រង់ស្រាល) ក្នុងអំឡុងពេលមានវិបត្តិសេដ្ឋកិច្ចនាចុងទសវត្សរ៍ឆ្នាំ ១៩៩០ ។

ទោះជាយ៉ាងណាក៏ដោយ គេសង្កេតឃើញថា ទង្វើរើសអើងគ្រប់រូបភាព បានស្ថិតនៅជាមួយនឹងប្រពៃណីបុរាណរបស់អាស៊ីអាគ្នេយ៍ ដែលមានតាំងពីសម័យមុនអាណានិគមមកម្ល៉េះ ។ ក្នុងនោះ អ្នកជំនួញជនជាតិចិន បានបម្រើស្តេចទាំងឡាយដែលជាពុទ្ធសាសនិកជនឬអ្នកកាន់សាសនាអ៊ិស្លាមនៅតំបន់អាស៊ីអាគ្នេយ៍ តាមរយៈតែភាពផ្តាច់មុខក្នុងការធ្វើជំនួញ ការជីករុករករ៉ែត្បូងថ្មផ្សេងៗ ឬក៏ការប្រមូលពន្ធជំនួសថ្វាយស្តេចទាំងនោះ ។ ហើយពួកគេចាប់មានទ្រព្យសម្បត្តិពីកិច្ចការទាំងនេះឡើង ។ បណ្តាមេដឹកនាំអាស៊ីអាគ្នេយ៍ នាសម័យក្រោយអាណានិគមបានផ្តល់នូវការអនុគ្រោះផ្នែកសេដ្ឋកិច្ច ជាពិសេស (ដូចជាការនាំចូលផ្តាច់មុខ) ទៅឲ្យគូកនដែលជាអ្នកជំនួញជនជាតិចិន ។ ទង្វើនេះ គឺធ្វើឲ្យកាន់តែទំនើបឡើងនូវទម្រង់ការងារដែលធ្លាប់បានអនុវត្តក្នុងព្រះរាជវាំងអាស៊ីអាគ្នេយ៍ពីសម័យមុន ដូចជាបានប្រើអ្នកជំនួញរាជវង្សចិនមកធ្វើការក្នុងនាមជាកសិករដែលមានសិទ្ធិពិសេសចំពោះពន្ធដារឬក៏ជាអ្នកជំនួញក្រៅប្រទេស ។

នាចុងទសវត្សរ៍ទី ២០ ក្រុមអាជីវកម្មគួក (Kuok Group) ដែលជាអាជីវកម្មចម្រុះជាតិសាសន៍ធំជាងគេបង្អស់គ្រប់គ្រងដោយជនជាតិចិននៅម៉ាឡេស៊ី បានបង្ហាញអំពីវិធីសាស្រ្តក្នុងការច្របាច់បញ្ចូលគ្នារវាងទម្រង់អនុវត្តរបស់រាជវាំងអាស៊ីអាគ្នេយ៍សម័យចាស់និងសម័យថ្មី ដើម្បីបង្កើតបានជាទម្រង់ដ៏មានប្រសិទ្ធភាពពិសេសមួយ ។ លោក រ៉ូបឺត គួក (Robert Kuok) គឺជាកូនប្រុសរបស់ជនក្រីក្រម្នាក់ដែលបានធ្វើអន្តោប្រវេសន៍ពីខេត្តហុកកៀនទៅស្រុកម៉ាឡាយូក្នុងចំណុះអង់គ្លេស (ម៉ាឡាយ៉ាប្រ៊ីតានិក) នាចុងទសវត្សរ៍ឆ្នាំ ១៨០០ ។ គាត់បានសិក្សានៅវិទ្យាល័យអង់គ្លេសនៅចូហូរបារុ (English College of Johor Baru) (មានកូនសិស្សនៅក្នុងវិទ្យាល័យនេះម្នាក់ ជាស្ថាបនិកនៃអង្គការជាតិឯកភាពម៉ាឡយូ) ហើយនិងបានសិក្សានៅសាកលវិទ្យាល័យរ៉ាហ្វហ្វលស៍ (Raffles College) នៅសិង្ហបុរី (លោក មហាធៀរ និងលោក លី ក្វាន់យូ ក៏បានរៀនសូត្រនៅក្នុងសាកលវិទ្យាល័យនេះ) ។ ដោយសារគាត់មាននូវជំនាញផ្សេងៗ ផ្នែកសង្គមនិងមានចំណងទាក់ទងជាមួយអ្នកដទៃតាំងពីមុនមក លោក គួក មានលទ្ធភាពប្រែក្លាយពាណិជ្ជកម្មស្ករទាំងលក់រាយនិងលក់ដុំ ដែលជាមរតកឪពុកគាត់ ឲ្យទៅជាពាណិជ្ជកម្មអន្តរជាតិដ៏ធំមួយ មានទាំងសេវាកម្មធានារ៉ាប់រង ទីផ្សារទំនើបប្រព័ន្ធបណ្តាញទូរទស្សន៍ និងសម្ព័ន្ធអាជីវកម្មសណ្ឋាគារសាំងហ្គ្រីឡា (Shangri-La) ។ ជនជាតិម៉ាឡាយូដ៏មានឥទ្ធិពលមួយចំនួន រួមបញ្ចូលទាំងសមាជិករបស់រាជវង្សានុវង្ស ប៉ឺរលីស (Perlis) និង ចូហូរ (Johore) គឺជាអ្នកជ្រោមជ្រែងនិងជាដៃគូពាណិជ្ជកម្មរបស់លោក គួក តាំងពីដំបូងមកម្ល៉េះ ។ ការរៀបចំឡើងបែបនេះ ត្រូវគេទទួលស្គាល់បែបកំប្លែងថា ជាប្រព័ន្ធ «អាលីបាបា» នៅម៉ាឡេស៊ី តែគេឃើញមានសម្ព័ន្ធនេះនៅតាមបណ្តាប្រទេសផ្សេងៗ ទៀតក្នុងតំបន់អាស៊ីអាគ្នេយ៍ក្រោមទម្រង់និងឈ្មោះផ្សេងៗ គ្នាក៏ដោយ ។ ជាថ្នូរនឹងការអនុញ្ញាតឲ្យពួក «បាបា» (ជាអ្នកជំនួញជាតិចិន) ទទួលបាននូវអាជ្ញាប័ណ្ណរដ្ឋាភិបាល និងជំនួយពីរដ្ឋនោះ ពួក «អាលី» (ដែលជានាយក ឬអ្នកចូលហ៊ុនជាតិម៉ាឡាយូ) ក៏បានទទួលផលចំណេញពីជោគជ័យរបស់ពួកបាបាដែរ ។

ការផ្លាស់ប្តូរសេដ្ឋកិច្ចដែលបានដឹកនាំដោយ «គូកននិយម» របស់វរជនទាំងនោះ មិនបានទទួលនូវការ

កោតសរសើរជាឯកច្ឆន្ទ ទាំងនៅក្នុងនិងក្រៅតំបន់អាស៊ីអាគ្នេយ៍ឡើយ ។ លោក យ៉ូស៊ីហារ៉ា គូនីអុ (Yoshihara Kunio) ជាអ្នករិះគន់ជនជាតិជប៉ុនដ៏ម៉ឺងម៉ាត់មួយរូប បានបរិហារជាសាធារណៈចំពោះការកើតឡើងនូវ «របបមូលធននិយមក្លែងក្លាយ» នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ ចំពោះទស្សនៈរបស់គាត់ របបមូលធននិយមនៅក្នុងតំបន់នេះ គឺជារបបមួយមិនពិត ពីព្រោះរបបនេះនៅតែពឹងលើបច្ចេកទេសរបស់ដៃគូឧស្សាហកម្មបរទេសមកពីប្រទេសជប៉ុននិងប្រទេសផ្សេងៗ ទៀត ហើយពួកនាយទុនចិននៅតំបន់នេះសុទ្ធតែជាអ្នកស្វែងរកការជួល ដោយរស់បានដោយសារតែការស្វែងការឧបត្ថម្ភនិងអាជ្ញាប័ណ្ណផ្ដាច់មុខពីរដ្ឋាភិបាល ។ ការរិះគន់នេះមានភាពយុត្តិធម៌ខ្លះដែរ ព្រោះប្រព័ន្ធអប់រំរបស់បណ្ដាប្រទេសអាស៊ីអាគ្នេយ៍ មិនអាចផលិតអ្នកវិទ្យាសាស្ត្រនិងអ្នកបច្ចេកវិទ្យាផ្នែកឧស្សាហកម្មនៅក្នុងស្រុក សម្រាប់ប្រើប្រាស់បានគ្រប់ចំនួនឡើយ ។ ផ្ទុយមកវិញ ការរិះគន់មួយទៀតទៅលើនាយទុនបស្ចិមប្រទេសនិងនាយទុនជប៉ុន ថា ជាគំរូសេដ្ឋកិច្ចពឹងលើខ្លួនឯងបានហើយនិងមិនចាំបាច់ស្វែងរកនូវការការពារពីរដ្ឋាភិបាល ដើម្បីទប់ទល់នឹងការប្រកួតប្រជែងរបស់បរទេសនោះទេ មិនសូវជាសមហេតុផលឡើយ ។ ពីព្រោះការរិះគន់នេះបានទាត់ចោលនូវប្រវត្តិសាស្ត្រមិនចេះចប់របស់នាយទុននាគ្រប់កន្លែង ដែលទាមទារឲ្យរដ្ឋាភិបាលជួយផ្ដត់ផ្គង់ជាថវិកា ចំពោះសហគ្រាសទាំងឡាយណាដែលទទួលបរាជ័យក្នុងអាជីវកម្មរបស់ខ្លួន ។

តាមពិតទៅ គេឃើញមាននូវរបបមូលធននិយមដែលនិយមបក្សពួកជាច្រើន នៅតំបន់អាស៊ីអាគ្នេយ៍ ។តែមិនសុទ្ធតែជាជនជាតិចិនទេ ។ ឧទាហរណ៍ដ៏លេចធ្លោមួយ គឺជាគម្រោងជាតិផលិតរថយន្តមួយរបស់ឥណ្ឌូនេស៊ី ដែលមានអាយុកាលបានតែប្រហែលជាមួយឆ្នាំ (១៩៩៦-១៩៩៧) ។ លោកប្រធានាធិបតីឥណ្ឌូនេស៊ី បានផ្ដល់នូវសិទ្ធិផលិតរថយន្ត «ថ្នាក់ជាតិ» ដំបូងគេបង្អស់ ឲ្យក្រុមហ៊ុនមួយដែលបានស្ថាបនានិងគ្រប់គ្រងដោយកូនប្រុសរបស់គាត់ គឺលោក ហ៊ុតូម៉ូ (ថម្មី) ស៊ូហារតូ (Hutomo Suharto) ។ ទោះជាគ្មានបទពិសោធន៍ក្នុងការផលិតរថយន្តក៏លោក ថម្មី បានទទួលសិទ្ធិផ្ដាច់មុខដើម្បីសហការជាមួយក្រុមហ៊ុនផលិតឡានគាម៉ូទ័រស៍ (Kia Motors) របស់ប្រទេសកូរ៉េខាងត្បូង ដែលនឹងផលិតតាមគំរូរថយន្តដំបូលជិតរបស់ក្រុមហ៊ុនគា ហៅថា ម៉ាកទីមរស៍ (Timors) នៅសហគ្រាសឧស្សាហកម្មថ្មីមួយ ដែលសាងសង់នៅក្បែរទីក្រុងហ្សាការតា ។ គាត់បានខ្ចីប្រាក់ពីធនាគាររបស់រដ្ឋ តាមការណែនាំពីឪពុករបស់គាត់ ដើម្បីចំណាយទៅលើការសាងសង់នេះ ។ បន្ទាប់ពីរបបគ្រប់គ្រងផ្ដាច់ការរបស់លោក ស៊ូហារតូ ដួលរលំនៅក្នុងឆ្នាំ ១៩៩៨ ប្រជាពលរដ្ឋឥណ្ឌូនេស៊ី ដែលមានរថយន្តម៉ាកនេះ បានប្រញាប់ប្រញាល់ដោះស្លាកម៉ាកនេះចេញពីរថយន្តរបស់ពួកគេ ។

ក៏ប៉ុន្តែ ប្រសិនបើមេដឹកនាំនៃបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ ដែលមិនមែនជាជនជាតិចិន ជាអ្នកបង្កើតឲ្យមាននូវលក្ខខណ្ឌនានា ដើម្បីឲ្យរបបមូលធននិយមចិនកកើតនិងរីកចម្រើនបាននោះ គឺក៏ដោយសារតែដើម្បីឆ្លើយតបទៅនឹងស្ថានការណ៍ប្រលក្ខខណ្ឌអន្តរជាតិជាក់លាក់តែប៉ុណ្ណោះ ។ អ្នករិះគន់បរទេសភាគច្រើនតែងតែមើលរំលងចំពោះស្ថានការណ៍នេះ ។ នៅដើមសម័យក្រោយអាណានិគម ប្រភេទអាជីវកម្មលក្ខណៈគ្រួសារនៅបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ នៅមានទ្រង់ទ្រាយតូច មិនអាចប្រកួតប្រជែងជាមួយនឹងក្រុមសាជីវកម្មពហុជាតិធំៗ ដែលកំពុងមានស្រាប់នោះឡើយ ។ នៅឆ្នាំ ១៩៩៣ ការធ្វើអង្កេតមួយបានបង្ហាញថា មានក្រុមហ៊ុនពាណិជ្ជកម្មធំៗ បំផុតរបស់ជប៉ុននិងកូរ៉េខាងត្បូង ចំនួន ៤៧ ក្នុងចំណោមក្រុមហ៊ុនពាណិជ្ជកម្មធំៗ បំផុតទាំងអស់ចំនួន ៥០ ។ ក្នុងនោះ មានក្រុមហ៊ុនប្រជែងប្រចាំតំបន់អាស៊ីអាគ្នេយ៍ដ៏ធំជាងគេមួយ គឺក្រុមហ៊ុនប្រេង

*របស់រដ្ឋឥណ្ឌូនេស៊ី ឈ្មោះ ប៉ឺរតាមីណា* (Pertamina) *ដែលគេបានចាត់ក្នុងចំណាត់ថ្នាក់ទី ៣៩ ប៉ុណ្ណោះ ។ ដើម្បីប្រឡងប្រណាំងជាមួយនឹងរបបមូលធននិយមពហុជាតិ ជាដំបូង បណ្ដាប្រទេសអាស៊ីអាគ្នេយ៍ទាំងឡាយត្រូវស្វែងរកនូវវិស័យពាណិជ្ជកម្មណា ដែលមានការធានាច្បាស់លាស់ ទោះបីជាពួកគេត្រូវការពឹងផ្អែកទៅលើទំនាក់ទំនងជាមួយបរទេសទាំងផ្នែកបច្ចេកវិទ្យានិងទីផ្សារក៏ដោយ ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ របបមូលធននិយមនៅអាស៊ីអាគ្នេយ៍មិនមានទម្រង់រួមតែមួយរហូតឡើយ ។ មកទល់នឹងទសវត្សរ៍ឆ្នាំ ១៩៩០ ក្រុមហ៊ុនពាណិជ្ជកម្មចិនមួយចំនួន បានវិវឌ្ឍពីក្រុមហ៊ុនដែលមានលក្ខណៈជាគ្រួសារ មកជាសាជីវកម្មទ្រង់ទ្រាយធំបែបបស្ចិមប្រទេសឬក៏បែបជប៉ុន ។ ប៉ុន្តែ ពួកគេត្រូវបាត់បង់នូវអត្តសញ្ញាណនិងវប្បធម៌របស់ចិនយ៉ាងច្រើន ។ ក្រុមហ៊ុនទាំងនោះបានយកលំនាំដែលធ្លាប់អនុវត្តនៅក្នុងប្រទេសហ្វីលីពីននាទសវត្សរ៍ឆ្នាំ ១៨០០ គឺជាដំណើរការមួយដែលកូនចៅចិនទាំងឡាយបានប្រែក្លាយខ្លួនគេ ឲ្យទៅជាក្រុមមនុស្សថ្នាក់កណ្ដាល ហើយលែងគិតថា ពួកគេលែងជាជនជាតិចិន ។*

## តម្លៃនៃការធ្វើបដិវត្តន៍ឧស្សាហកម្ម

*ផ្នែកមិនល្អនៃប្រវត្តិប្រកបដោយជោគជ័យនៃសេដ្ឋកិច្ចនាសម័យក្រោយអាណានិគមរបស់អាស៊ីអាគ្នេយ៍ មិនមានតែបក្សពួកនិយម រោងចក្រដែលជិះជាន់កម្មករ និងការបង្ក្រាបសហជីពឯករាជប៉ុណ្ណោះទេ ។ អាស៊ីអាគ្នេយ៍នៅពេលនោះ បានអនុវត្តគំរូអាក្រក់ៗ ជាច្រើន តាមបដិវត្តន៍ឧស្សាហកម្មរបស់បស្ចិមប្រទេស ទោះជាកម្មករនៅអាស៊ីអាគ្នេយ៍អាចមានក្ដីសង្ឃឹមចំពោះអនាគតកាលខ្ពស់ជាងកម្មករអង់គ្លេសនាសតវត្សរ៍ទី ១៩ ។ នៅក្នុងសុន្ទរកថាមួយទៅកាន់នាយកធនាគារនានា នាឆ្នាំ ១៩៧៤ លោកប្រធានាធិបតីហ្វេរឌីណង់ ម៉ាកូស បានអួតអាងថា តម្លៃពលកម្មនៅហ្វីលីពីន មានកម្រិតទាបបំផុតនៅអាស៊ី ។ តែទោះជាយ៉ាងណា គាត់ប្ដេជ្ញាមិនបណ្ដោយឲ្យមានការតម្លើងប្រាក់ឈ្នួលកម្មករខ្លាំងពេក ដើម្បីកុំឲ្យរាំងស្ទះដល់កម្មវិធីនាំចេញរបស់គាត់ដែរ ។ មេដឹកនាំបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ដទៃទៀត ក៏បានប្រកាន់យកនូវការចង់បានដូចគ្នានេះដែរ ទោះបីជាកម្មករខ្វះលទ្ធភាពក្នុងការទិញផលិតផលផ្សេងៗ ដោយសារតែប្រាក់កម្រៃមិនគ្រប់គ្រាន់ ហើយធ្វើឲ្យទំនិញរបស់ពួកគេពឹងផ្អែកកាន់តែខ្លាំងទៅលើអ្នកទិញបរទេសក៏ដោយ ។*

*នៅក្នុងឆ្នាំ ១៩៤៤ លោក ជេ.អេស. ហ្វឺនីវ៉ល្ល* (J.S. Furnivall) *បានរៀបរាប់នៅក្នុងសៀវភៅ* **ហូឡង់ឥណ្ឌា** (*Netherlands India*) *ថា នៅក្នុងសម័យអាណានិគម អតុល្យភាពដ៏ធំមួយរវាងមូលធននិងកម្លាំងពលកម្មនៅក្នុងបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ដែលស្ថិតនៅក្រោមអាណានិគមបស្ចិមប្រទេស មានច្រើនជាងនៅបណ្ដាបស្ចិមប្រទេសផ្ទាល់ ។ បណ្ដាប្រទេសអាណានិគមទាំងនេះ ត្រូវបានគេរៀបចំឡើង ប្រៀបដូចជារោងចក្រសម្រាប់ផលិតកម្មអ៊ីចឹង គឺមិនដូចជារដ្ឋដែលបង្កើតឡើងដើម្បីឲ្យប្រជាពលរដ្ឋខ្លួនមានជីវភាពប្រសើរឡើយ ។ ការខ្វះនូវ «ឆន្ទៈរួមមួយ» ក្នុងចំណោមប្រជាពលរដ្ឋនៃសង្គមចម្រុះជាតិសាសន៍ ដែលធ្លាប់ទទួលរងនូវអាណានិគម បានបណ្ដាលឲ្យរបបមូលធននិយមហូរចូលតមកតំបន់នេះដោយសេរីឥតមានកំហិត ។*

*សម្រាប់ហេតុផលផ្ទាល់ខ្លួនរបស់ពួកគេ បណ្ដាមេដឹកនាំអាស៊ីអាគ្នេយ៍សម័យក្រោយអាណានិគមទាំងនោះ បានខិតខំប្រែក្លាយសង្គមគេ ឲ្យដូចជារោងចក្រដ៏ទំនើប ដោយមិនចាំបាច់កែទម្រង់សង្គមទាំងនោះប៉ុន្មានឡើយ ។*

ដោយសារតែការជំរុញឲ្យល្បឿននិងចំនួនចរាចរមូលធនប័ណ្ណ ហើយនិងធនធានហិរញ្ញវត្ថុពិភពលោក កើនឡើងយ៉ាងសម្បើមនោះ ការអភិវឌ្ឍផ្នែកប្រព័ន្ធទំនាក់ទំនងនិងប្រព័ន្ធកុំព្យូទ័រ នាសម័យក្រោយសង្គ្រាមលោកលើកទី ២ បានបង្កើនផលចំណេញយ៉ាងច្រើនដល់និយោជកនិងវិនិយោគិនទៅលើកម្មករនៅគ្រប់កន្លែង ។ ទុនវិនិយោគមានភាពចល័តកាន់តែច្រើន តែកម្មករភាគច្រើននៅមួយកន្លែង ។ ទោះបីជាសហជីពកម្មកររបស់បស្ចិមប្រទេសផ្ទាល់ ក៏ត្រូវបាត់បង់នូវឥទ្ធិពលក្នុងការតថ្លៃជាមួយអ្នកចាត់ចែងវិនិយោគ ដែលអាចដើររកទីផ្សារពលកម្មពីកន្លែងមួយទៅកន្លែងមួយទៀត ។ ចំពោះអាស៊ីអាគ្នេយ៍វិញ ឥទ្ធិពលស្ថានភាពនេះមានសភាពកាន់តែអាក្រក់ដូចដែលលោក ហ៊ីនីវ៉ល្វ បានធ្វើការគិតទុកអ៊ីចឹង ។ ការប៉ាន់ប្រមាណមួយធ្វើឡើងនៅឆ្នាំ ១៩៩២ បានបង្ហាញថា ក្រុមហ៊ុនផលិតស្បែកជើងម៉ាកណៃឃី (Nike) ដែលផលិតស្បែកជើងរបស់ខ្លួនច្រើនជាងគេនៅឯប្រទេសឥណ្ឌូនេស៊ី បានចំណាយថវិកាយ៉ាងច្រើនឲ្យកីឡាករដ៏ល្បីល្បាញឈ្មោះ ម៉ៃខឹល ចរដេន (Michael Jordan) ដើម្បីផ្សព្វផ្សាយពាណិជ្ជកម្មរបស់ខ្លួន ។ ប្រាក់ដែលលោក ចរដេន បានទទួល មានចំនួនច្រើនជាងថ្លៃឈ្នួលកម្មកររោងចក្រទាំងអស់ចំនួន ២៥.០០០ នាក់ក្នុងរយៈពេលមួយឆ្នាំទៅទៀត ។

នៅតំបន់អាស៊ី ក្នុងអំឡុងពេលសង្គ្រាមត្រជាក់ ការត្រួតត្រាឬការបង្ក្រាបទៅលើសហជីពកម្មករ មានសភាពខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ។ នៅប្រទេសថៃមុនឆ្នាំ ១៩៧២ សហជីពកម្មករមិនត្រូវបានទទួលស្គាល់ថាស្របច្បាប់ទេ ។ ចាប់ពីឆ្នាំ ១៩៧២ មក សហជីពសហគ្រាសរបស់រដ្ឋ (ប្រមាណមួយភាគបួននៃសហជីពទាំងអស់) ក៏នៅតែត្រូវបានហាមឃាត់មិនឲ្យធ្វើកូដកម្ម ។ សហជីពណាដែលគេអនុញ្ញាតឲ្យធ្វើកូដកម្ម ក៏ត្រូវស្ថិតនៅក្រោមកិច្ចអន្តរាគមន៍របស់កងកម្លាំងនគរបាលថៃ និងអង្គការបរទេសដែលមានទំនោរប្រឆាំងនឹងលទ្ធិកុម្មុយនីស្ត មានដូចជា វិទ្យាស្ថានពលកម្មសេរីអាស៊ី-អាមេរិក ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក ឬសភាពលកម្មអឺរ៉ុប (ដែលជួយឧបត្ថម្ភជាសម្ងាត់ដល់សហជីពថៃនានានៅក្នុងល្បែងមួយដែលហៅថា បំបែកបំបាក់ដើម្បីគ្រប់គ្រង) ជាដើម ។ ចំណែកឯនៅក្នុងប្រទេសសិង្ហបុរីវិញ គណបក្ស «សកម្មភាពប្រជាជន» ដែលជាគណបក្សកាន់អំណាចបានគ្រប់គ្រងលើសភាពាណិជ្ជកម្មជាតិ និងខិតខំលើកតម្កើងនូវទស្សនៈមួយថា និយោជកនិងកម្មករ គួរតែសហការគ្នាទៅវិញទៅមក ដើម្បីរក្សានូវស្ថិរភាពឧស្សាហកម្ម ហើយក្រុមប្រឹក្សាទទួលបន្ទុកប្រាក់ខែជាតិ ក៏បានដាក់ចេញនូវគោលការណ៍មួយចំនួន ដើម្បីកំណត់ប្រាក់ឈ្នួលផ្សេងៗ ។ នៅក្នុងប្រទេសម៉ាឡេស៊ី នាពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៨០ ប្រហែលតិចជាងដប់ភាគរយនៃកម្មករទាំងអស់បានរួបរួមគ្នាបង្កើតជាសហជីពឡើង ។ ហើយកម្មករនៅក្នុងតំបន់ពាណិជ្ជកម្មសេរីទាំងឡាយដែលបង្កើតឡើង ជាពិសេសដើម្បីទាក់ទាញទុនវិនិយោគបរទេសនោះ មិនត្រូវបានគេអនុញ្ញាតឲ្យចូលរួមជាមួយនឹងសហជីពទាំងនេះទេ ។ ស្រដៀងគ្នានេះដែរ សមាជសហជីពដែលឧបត្ថម្ភដោយរដ្ឋាភិបាលរបស់ប្រទេសហ្វីលីពីន បានអនុវត្តតាមបណ្តាប្រទេសដែលបានរៀបរាប់ខាងលើ ដោយប្រឹងប្រែងត្រួតត្រាលើកម្មករ ។ ប៉ុន្តែ កិច្ចប្រឹងប្រែងនេះមិនសូវមានប្រសិទ្ធភាពទេ ។ មកទល់នឹងទសវត្សរ៍ឆ្នាំ ១៩៨០ ប្រទេសហ្វីលីពីនត្រូវប្រឈមមុខនឹងសហជីពកម្មករឯករាជមួយទៀត គឺចលនាដែលមានឈ្មោះថា «ចលនាថ្ងៃមួយឧសភា» (គីលុសាំងម៉ាយ៉ូអ៊ុណូ) ។

ចំណែកឯប្រទេសឥណ្ឌូនេស៊ីដែលដឹកនាំដោយលោក ស៊ូហារតូ វិញ គេមើលឃើញយ៉ាងច្បាស់ថា ប្រសិនបើមានអំពើពុករលួយនៅក្នុងរដ្ឋាភិបាលកាន់តែខ្លាំង ដូចជាតម្រូវការសូកប៉ាន់ពីក្រុមហ៊ុនពាណិជ្ជកម្មនានា ទៅឲ្យ

មន្ត្រីរដ្ឋការនិងនាយទាហានផ្សេងៗ នោះ ផ្ទុយមកវិញ ក្រុមហ៊ុនពាណិជ្ជកម្មកាន់តែឲ្យប្រាក់ឈ្នួលតិចដល់កម្មកររបស់ខ្លួន ។ ចំណុចនេះបានបង្ហាញឲ្យឃើញថា ឧស្សាហកម្មដែលផ្តល់ប្រាក់ឈ្នួលតិចតួចដល់កម្មករ និងរោងចក្រដែលមានលក្ខខណ្ឌអាក្រក់ចំពោះកម្មករនោះ គឺបណ្តាលមកពីកត្តាបក្សពួកនិយមជ្រុល ។ គ្មានកូដកម្មណាមួយ អាចធ្វើឡើងបានដោយស្របច្បាប់ទេ ប្រសិនបើគ្មានការអនុញ្ញាតពីក្រសួងការងារនោះ ។ អង្គការស្របច្បាប់ មានតែក្រុមសូត្រធម៌ថ្វាយព្រះក្នុងសាសនាអ៊ិស្លាមក្នុងរោងចក្រដែលមានតែកម្មការិនីប៉ុណ្ណោះ ។ ប៉ុន្តែ មកទល់នឹងដើមទសវត្សរ៍ឆ្នាំ ១៩៩០ សហជីពឯករាជមួយចំនួន ដែលបានចងសម្ព័ន្ធជាមួយនឹងគណៈសាសនាប្រូតេស្តង់របស់ជាតិបាតាក់ដ៏មានឥទ្ធិពលនោះ អាចរៀបចំបង្កើតក្រុមកម្មកររោងចក្រកាត់ដេររាប់ពាន់នាក់ ដើម្បីធ្វើកូដកម្មខុសច្បាប់ផ្សេងៗ នៅឯទីក្រុងម៉េដាន (Medan) នៃកោះស៊ូម៉ាត្រា ។ រូបភាពច្បាស់នឹងភ្នែកនៃការចាប់ពង្រត់ រំលោភ និងធ្វើឃាតកម្មពីសំណាក់ពួកទាហានឥណ្ឌូនេស៊ីទៅលើរូបនាង ម៉ារស៊ីណះ (Marsinah) ជាសកម្មជនជាតិជ្វាវ័យក្មេងមួយរូប ដោយសារតែនាងបានព្យាយាមរៀបចំនូវក្រុមកម្មករដែលធ្វើការជាមួយនាងនៅឯរោងចក្រនាឡិកាដៃមួយនៅឆ្នាំ ១៩៩៣ នោះ បានសបញ្ជាក់ឲ្យឃើញពីការភ័យខ្លាចរបស់អ្នកដឹកនាំផ្តាច់ការ ។ មតិសាធារណៈបានបង្ខំឲ្យរបបនេះទទួលស្គាល់នូវមរណភាពរបស់នាងថា ជាវីរនារីកម្មករ ។

ការអភិវឌ្ឍបែបនេះមិនមែនជាការរំពឹងទុករបស់បណ្តាមេដឹកនាំអាស៊ីអាគ្នេយ៍ដែលបានគ្រប់គ្រងប្រទេសរបស់ពួកគេតាមបែបមូលធននិយម ដោយផ្តោតទៅលើការនាំចេញតាំងពីដំបូងនោះទេ បន្ទាប់ពីចាប់យកនូវជម្រើសផ្សេងទៀត គឺសេដ្ឋកិច្ចបែបការិយាលយាធិបតេយ្យសង្គមនិយមនៅក្នុងប្រទេសភូមា វៀតណាម កម្ពុជា និង ឡាវ (លាវ) ក៏លែងមានគេចាប់អារម្មណ៍ទៅទៀត ។ ចិត្តគំនិតរបស់ពួកគេមិនដូចទៅនឹងអ្វីដែលសាស្ត្រាចារ្យសេដ្ឋកិច្ចសេរីបស្ចិមប្រទេសបានលើកឡើងថា គឺជាការចង់បាននូវពាណិជ្ជកម្មសេរីនិងកំណើនសេដ្ឋកិច្ច ។ ប៉ុន្តែវាមានលក្ខណៈនយោបាយដែលប្រទេសក្រោយសម័យអាណានិគមទាំងនោះ បានស្តារនូវសេចក្តីថ្លៃថ្នូររបស់ខ្លួនឡើងវិញ ក្នុងនាមជាតួអង្គអន្តរជាតិឯករាជ ។ សង្គ្រាមត្រជាក់បានបង្កើតឲ្យមានភាពស្រពិចស្រពិលពីភាពខុសប្លែកគ្នា រវាងគោលបំណងនៃការអភិវឌ្ឍទាំងនេះ និងគោលបំណងនៃការអភិវឌ្ឍរបស់សេដ្ឋកិច្ចមូលធននិយមបែបក្រុមហ៊ុនចម្រុះជាតិសាសន៍ ។ សំណួរដែលតែងតែលេចឡើងក្នុងប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍នាដើមសតវត្សរ៍ទី ២១ គឺថា តើសាជីវកម្មពាណិជ្ជកម្មបរទេសធំៗ ដែលជាបង្អែកនៃការរីកចម្រើនផ្នែកសេដ្ឋកិច្ចក្នុងតំបន់នោះ ពិតជាចង់ឲ្យរដ្ឋក្រោយអាណានិគមទាំងនេះខ្លាំងឬក៏អត់ ។ ប្រហែលជាពួកគេត្រូវការឲ្យមាននូវរដ្ឋខ្សោយ ដែលមានសមត្ថភាពអាចត្រឹមតែរក្សានូវកងកម្លាំងនគរបាល និងប្រមូលសំរាម ដោយមិនចាំបាច់មានអំណាចដែលអាចរារាំងនិងកំណត់នូវសេរីភាពនៃដំណើរការវិនិយោគរបស់ពួកគេឡើយ ។

## វិបត្តិសេដ្ឋកិច្ចឆ្នាំ ១៩៩៧ និងលទ្ធផលរបស់វិបត្តិនេះ

វិបត្តិសេដ្ឋកិច្ចអាស៊ីអាគ្នេយ៍ឆ្នាំ ១៩៩៧ បានបន្ថយទស្សនៈមួយចំនួនរបស់លោក អាន់វ៉ារ អ៊ីប្រាហ៊ីម (Anwar Ibrahim) ដែលក្រោយមកលោកបានក្លាយជាឧបនាយករដ្ឋមន្ត្រីនៃប្រទេសម៉ាឡេស៊ី ដែលបាននិយាយក្នុងឆ្នាំ ១៩៩៤ ថា ជា «ការចាប់ផ្តើមជាថ្មីរបស់អាស៊ី» នោះ ។ វិបត្តិនេះហាក់ដូចជាត្រូវបានបញ្ជាក់ពីការភ័យខ្លាចរបស់ប្រទេសនៅក្នុងតំបន់ថា សាជីវកម្មឆ្លងដែននិងក្រុមអ្នកគាំទ្រសាជីវកម្មទាំងឡាយនេះ ពិតជាមិនចង់ឲ្យរដ្ឋនៅតំបន់អាស៊ីខ្លាំងក្លានោះ

*ទេ ។ នៅពាក់កណ្ដាលឆ្នាំ ១៩៩៧ ធនាគារកណ្ដាលរបស់ប្រទេសថៃបានបញ្ចេញប្រាក់បាទជាច្រើន ដែលជាហេតុធ្វើឲ្យរូបិយវត្ថុរបស់ថៃ ដែលធ្លាប់មានចំណងទាក់ទងជាមួយនឹងដុល្លារសហរដ្ឋអាមេរិកតាំងពីឆ្នាំ ១៩៨៤ មកនោះធ្លាក់ចុះយ៉ាងខ្លាំង ។ ការណ៍នេះបង្កើតឲ្យមានការចោទសួរមួយថា តើសហគ្រាសពាណិជ្ជកម្មថៃនឹងត្រូវសងបំណុលដ៏ច្រើនរបស់ពួកគេទៅឲ្យបណ្ដាប្រទេសនានា ដែលខ្លួនជំពាក់បានយ៉ាងដូចម្ដេច ប្រសិនបើប្រទេសថៃជួបប្រទះនូវឱនភាពពាណិជ្ជកម្ម និងសល់នូវរូបិយប័ណ្ណបរទេសដែលបម្រុងទុកតិចតួចបំផុតនោះ ។*

*បណ្ដាប្រទេសអាស៊ីអាគ្នេយ៍ដទៃ ៗ ទៀត ក៏បានជួបប្រទះនូវឱនភាពពាណិជ្ជកម្មដូចប្រទេសថៃ ហើយបានទទួលរងគ្រោះវិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់នេះដែរ ។ ទោះបីជាមាននូវការជជែកវែកញែកអំពីសារៈសំខាន់នៃកត្តាពាក់ព័ន្ធមួយចំនួនក៏ដោយ ក៏បរិបទទូទៅបង្ហាញឲ្យឃើញថា ឱនភាពអាស៊ីអាគ្នេយ៍រួមមានដូចជា ៖*

*◉ ការធ្លាក់ចុះដែលកើតយ៉ាងទៀងទាត់ នូវតម្រូវការពិភពលោកចំពោះទំនិញអេឡិចត្រូនិក ដែលសហគ្រាសផលិតក្នុងស្រុកភាគច្រើនបានផ្ដោតលើ ។*

*◉ ការកើនឡើងយ៉ាងឆាប់រហ័សនូវការប្រកួតប្រជែងជាមួយនឹងការនាំចេញរបស់ប្រទេសចិន ព្រោះប្រទេសចិន ក្រោយសម័យគ្រប់គ្រងរបស់លោក ម៉ៅ បានផ្លាស់ប្ដូរយ៉ាងសន្សឹម ៗ ទៅរកគោលនយោបាយអភិវឌ្ឍន៍ផ្អែកលើការនាំចេញជាចម្បង ។*

*◉ ការធ្លាក់ចុះនូវការវិនិយោគ រួមទាំងការបដិសេធរបស់ប្រទេសជប៉ុន (ដែលជាប្រទេសអ្នកមានបំផុតនៅអាស៊ី) ក្នុងការទទួលយកនូវការនាំចូលទំនិញពីអាស៊ីអាគ្នេយ៍បន្តទៀត ។ (យោងទៅលើការប៉ាន់ប្រមាណមួយសហរដ្ឋអាមេរិកបានទិញទំនិញផលិតកម្មនាំចេញរបស់បណ្ដាប្រទេសដែលមិនមែនមកពីប្រទេសលោកខាងលិចទាំងឡាយចំនួន ៧០% នាចុងទសវត្សរ៍ឆ្នាំ ១៩៨០ ចំណែកឯប្រទេសជប៉ុន ដែលមានសេដ្ឋកិច្ចយ៉ាងហោចណាស់ស្មើនឹង ២ ភាគ ៣ នៃសេដ្ឋកិច្ចសហរដ្ឋអាមេរិកនោះ បានទិញទំនិញនាំចេញទាំងនោះតែ ៨% ប៉ុណ្ណោះ ។)*

*ទាក់ទិនទៅនឹងការខ្ចីប្រាក់យ៉ាងស្រពិចស្រពិលនិងពុករលួយរបស់ស្ថាប័នហិរញ្ញវត្ថុកំពូល ៗ ភាគច្រើននៅក្នុងតំបន់ផងនោះ ក៏បានធ្វើឲ្យគ្រោះអាក្រក់មួយនេះកើតមានតែម្ដង ។ ស្ថានការណ៍ដ៏អាក្រក់បំផុត ក៏បានកើតឡើងនៅក្នុងប្រទេសឥណ្ឌូនេស៊ី ដែលរូបិយវត្ថុរបស់ខ្លួនបានធ្លាក់ថ្លៃរហូតដល់ ៣ ភាគ ៤ នៅពាក់កណ្ដាលឆ្នាំ ១៩៩៧ ។ បញ្ហានេះបានបណ្ដាលឲ្យមានការបិទទ្វាររោងចក្រ និងភាពអត់ការងារធ្វើយ៉ាងធ្ងន់ ។ ដោយសារតែថ្លៃទំនិញនាំចូលបានកើនឡើងកាន់តែខ្ពស់ទៅៗ ចំនួនប្រជាជនឥណ្ឌូនេស៊ីជាច្រើននាក់ ដែលកំពុងតែរស់នៅក្នុងភាពក្រីក្រ បានកើនឡើងយ៉ាងខ្លាំង ។ មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលបានបង្កើតឡើងក្រោមកិច្ចដឹកនាំរបស់សហរដ្ឋអាមេរិកនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៤០ ដើម្បីលើកស្ទួយគំនិតសេរីភាវូបនីយកម្មផ្នែកសេដ្ឋកិច្ច បានផ្ដល់ជំនួយដល់ប្រទេសឥណ្ឌូនេស៊ីនៅក្នុងឆ្នាំ ១៩៩៨ ក្នុងលក្ខខណ្ឌបញ្ឈប់លែងឲ្យមានការគ្រប់គ្រងផ្ដាច់មុខ និងការទប់ស្កាត់ការប្រកួតប្រជែងពីបរទេស ក្នុងវិស័យកសិកម្មឥណ្ឌូនេស៊ី ។ ការធ្វើសេរីភាវូបនីយកម្មយ៉ាងឆាប់រហ័សនេះ គ្រាន់តែធ្វើឲ្យសេដ្ឋកិច្ចដួលរលំភ្លាមនោះប៉ុណ្ណោះ ។ នៅពេលលោកប្រធានាធិបតី ស៊ូហារតូ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយនៅខែមេសា ឆ្នាំ ១៩៩៨ (ប៉ុន្មានខែមុនពេលជីវិតនយោបាយរបស់គាត់ត្រូវបានបញ្ចប់) មានគេបានថតរូបនាយកគ្រប់គ្រងមូលនិធិរូបិយវត្ថុអន្តរជាតិ គឺលោក មីសែល កាំដឺស៊ុយស៍* (Michel

Camdessus) កំពុងឈរឱបដៃក្បែរលោក ស៊ូហារតូ ។ គាត់មើលទៅដូចជាអ្នកតំណាងអភិបាលអាណានិគមគ្រប់គ្រងឥណ្ឌូនេស៊ី ដែលទើបរស់ឡើងវិញជាថ្មីអ៊ីចឹង ។

មុននឹងពេលដែលវិបត្តិសេដ្ឋកិច្ចនេះបានកើតឡើង គេឃើញមេដឹកនាំអាស៊ីអាគ្នេយ៍មួយចំនួនធំ នៅតែបន្តការទាញយកប្រយោជន៍ពីកំណើនសេដ្ឋកិច្ចដែលមាន ។ ពួកគេមិនបានគិតទៅដល់ការធ្លាក់ចុះផ្លូនៗ និងសភាពមិននឹងន ដែលធ្លាប់បានកើតឡើងដោយសារតែរបបមូលធននិយម ដែលមានតាំងពីគ្រោះមហន្តរាយក្នុងការវិនិយោគផ្កាទុយលីបរបស់ប្រទេសហូឡង់ នៅទសវត្សរ៍ឆ្នាំ ១៦០០ រហូតដល់ទៅការរង្គោះរង្គើទីផ្សារភាគហ៊ុនរបស់សហរដ្ឋអាមេរិកនៅឆ្នាំ ១៩២៩ ជាដើម ។ នៅក្នុងឆ្នាំ ១៩៩៤ លោកនាយករដ្ឋមន្ត្រីម៉ាឡេស៊ី មហាធៀរ មហាម៉ាត់ បានសហការនិពន្ធសៀវភៅមួយក្បាល ជាមួយនឹងអ្នកជាតិនិយមជប៉ុន ដែលមានចិត្តក្រេវក្រោធមួយរូប មានចំណងជើងថា «អាស៊ីដែលអាចនិយាយបដិសេធចំពោះបស្ចិមប្រទេស» ។ ក្នុងនោះ គាត់បានទស្សន៍ទាយថា ភាពថ្កុំថ្កើងរបស់សហរដ្ឋអាមេរិក គឺជារឿងអតីតកាល ប៉ុន្តែការរីកចម្រើនរបស់អាស៊ីអាគ្នេយ៍ គឺជារឿងបច្ចុប្បន្ន ។ វិបត្តិសេដ្ឋកិច្ចអាស៊ីអាគ្នេយ៍នៅឆ្នាំ ១៩៩៧ ដែលមានទំនាក់ទំនងនឹងវិបត្តិសេដ្ឋកិច្ចជប៉ុន ធ្វើឲ្យមានការភ្ញាក់ផ្អើលដ៏ធំមួយ ដោយមិនចំពោះតែបណ្ដាពលរដ្ឋអាស៊ីនោះទេ ថែមទាំងបណ្ដាជនបរទេសជាច្រើនទៀត (រួមទាំងវិនិយោគិននៅក្នុងទ្វីបអាស៊ី) ផងដែរ ។ បញ្ហាបន្ទាន់នៅតំបន់នេះ គឺថា តើត្រូវធ្វើយ៉ាងណាដើម្បីកសាងរដ្ឋរបស់ខ្លួនឲ្យបានរឹងមាំ មានស្ថាប័នហិរញ្ញវត្ថុដែលដំណើរការយ៉ាងត្រឹមត្រូវ និងមានយុត្តិធម៌ក្នុងការយកពន្ធដារក្នុងស្រុក ដោយមិនផ្ដោតខ្លាំងពេកទៅលើតែការបន្ថែមទុនវិនិយោគកាន់តែច្រើន ពីសំណាក់វិនិយោគិនបរទេសដែលចង់ទទួលបានផលចំណេញខ្ពស់ក្នុងរយៈពេលខ្លីពីជំនួញទិញលក់ដីធ្លីជាជាងពីឧស្សាហកម្មក្នុងស្រុក ។

## ប្រវត្តិប្រកបដោយជោគជ័យរបស់អាស៊ាន

តើបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ដែលមានសេដ្ឋកិច្ចរឹងមាំទាំងអស់ ហើយនិងទម្រង់នៃកិច្ចសហប្រតិបត្តិការអន្តររដ្ឋក្នុងតំបន់ ដែលបានចាប់ផ្ដើមបង្កើតនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ នោះ មានភាពស្របគ្នាទៅនឹងទស្សនៈមូលធន-និយមសេរី ដែលបានរីកចម្រើនដោយគ្មានឧបសគ្គរាំងនៅក្នុងពិភពលោកសម័យក្រោយសង្គ្រាមត្រជាក់នោះដែរឬទេ ? នៅឆ្នាំ ១៩៦៧ មានប្រទេស ៥ នៅតំបន់អាស៊ីអាគ្នេយ៍ មិនប្រកាន់យករបបសង្គមនិយម (ប្រទេសទាំងនោះ គឺ ប្រទេសថៃ ឥណ្ឌូនេស៊ី ហ្វីលីពីន សិង្ហបុរី និងម៉ាឡេស៊ី) បានរួមគ្នាបង្កើតនូវ «សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍» ឡើង (ដែលហៅកាត់តាមភាសាអង់គ្លេសថា «អាស៊ាន») ។ នៅក្នុងទស្សនៈរបស់រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ីនាពេលនោះ គេបានបង្កើតអាស៊ានជាសម្ព័ន្ធក្នុងតំបន់មួយ ដែលអាចទប់ទល់នឹងពួកចក្រពត្តិនិយម គឺ «ពួកស្បែកលឿង» (ជនជាតិចិន) និង «ពួកស្បែកស» (ពួកបស្ចិមប្រទេស) ហើយនិងរារាំងមិនឲ្យមាននូវទស្សនៈជាតិនិយមប្រឆាំងនឹងជនជាតិសាសន៍នានានៅក្នុងតំបន់អាស៊ីអាគ្នេយ៍ តាមរយៈកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់ ឲ្យបានកាន់តែប្រសើរ ។

ការបង្កើតសមាគមអាស៊ាន មានសភាពមិនទៀងទាត់តាំងពីដំបូង ។ សមាគមនេះបានរួមបញ្ចូលជាសមាជិកទាំងប្រទេសតូចៗ មួយចំនួន ដែលមានការរីកចម្រើនជឿនលឿនដូចជា ប្រទេសសិង្ហបុរី (និងប្រទេសប្រ៊ុយណេក្នុងឆ្នាំ ១៩៨៤) ដែលមិនសូវមានការព្រួយបារម្ភចំពោះពាណិជ្ជកម្មសេរីក្នុងតំបន់ រួមនឹងប្រទេសក្រីក្រ ប៉ុន្តែ

មានផ្ទៃដីធំៗ ហើយមិនមានសមត្ថភាពច្បាស់លាស់ក្នុងការបង្រួបបង្រួមផ្នែកនយោបាយនិងសេដ្ឋកិច្ចជាតិរបស់ខ្លួន ដូចជាប្រទេសឥណ្ឌូនេស៊ីជាដើម ។ ប៉ុន្តែ ក្រោយមក អាស៊ានបានទទួលជោគជ័យដ៏ធំធេងជាងបណ្តាប្រទេសនានានៅក្រៅតំបន់អាស៊ីអាគ្នេយ៍បានគិត ។ អាស៊ានមិនត្រឹមតែបានជួយបញ្ចប់នូវ «ការប្រឈមមុខដាក់គ្នា» រវាងប្រទេសម៉ាឡេស៊ីនិងឥណ្ឌូនេស៊ី នាទសវត្សរ៍ឆ្នាំ ១៩៦០ (ដែលជាគោលបំណងមួយក្នុងចំណោមគោលបំណងដើមដំបូងទាំងឡាយរបស់អាស៊ាន) ប៉ុណ្ណោះទេ ថែមទាំងបានជួយផ្សះផ្សាគូសត្រូវដ៏យូរលង់ដូចជាប្រទេសថៃនិងវៀតណាម (ដែលបានចូលជាសមាជិកអាស៊ាន នៅក្នុងឆ្នាំ ១៩៩៥) និងជួយកាត់បន្ថយនូវស្ថានការណ៍ដ៏តឹងតែងរវាងប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងហ្វីលីពីន នៅលើកោះបូរណេអូទៀតផង ។ នៅក្នុងឆ្នាំ ២០០៣ អាស៊ានក៏ហាក់ដូចជាចង់ជួយដោះស្រាយបញ្ហាប្រទូសរ៉ាយផ្នែកសិទ្ធិមនុស្សនៅក្នុងប្រទេសភូមា ដែលបានចូលជាសមាជិកអាស៊ាននៅក្នុងឆ្នាំ ១៩៩៧ ។ មកទល់នឹងការប្រារព្ធឡើងនូវពិធីបុណ្យខួប ៣០ ឆ្នាំ អាស៊ានបានក្លាយជាអង្គការក្នុងតំបន់មួយ ដែលបានទទួលជោគជ័យយ៉ាងធំធេងនៅប្រទេសនានាក្រៅបស្ចិមប្រទេស ។ អាស៊ានមានប្រជាជនប្រហែល ៥០០ លាននាក់ ។ អាស៊ាន គឺជាប្លុកពាណិជ្ជកម្មធំបំផុតទី ៤ លើពិភពលោក ។ ហើយអាស៊ានបានរួមបញ្ចូលប្រទេសទាំងអស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ លើកលែងតែប្រទេសកម្ពុជា ដែលជាចុងក្រោយ ប្រទេសនេះបានក្លាយជាសមាជិកទី ១០ (នៅក្នុងឆ្នាំ ១៩៩៩) ដោយមាននិមិត្តសញ្ញាកួរស្រូវចំនួន ១០ ជាតំណាងរបស់ខ្លួនមុនការចូលជាសមាជិករបស់កម្ពុជា ។

អាស៊ានដែលជាផ្នែកមួយនៃពិភពលោក មិនត្រឹមតែក្រដាសសហភាពអឺរ៉ុបប៉ុណ្ណោះទេ តែថែមទាំងជាតំបន់មួយដែលខ្វះនូវលក្ខណៈរួមខាងវប្បធម៌ សាសនា និងមរតកច្បាប់មួយ ដែលសហភាពអឺរ៉ុបមាន ។ កត្តាទាំងនេះជាហេតុដែលអាស៊ានមិនអាចសម្រេចជោគជ័យបានលឿន ។ បណ្តាប្រទេសអាស៊ីអាគ្នេយ៍ទាំងឡាយមិនសូវយល់ពីតម្លៃនៃការសម្រេចបាននូវជោគជ័យទាំងនេះទេ ។ នៅក្នុងឆ្នាំ ១៩៩៥ ពេលដែលស្រីបម្រើតាមផ្ទះជាតិហ្វីលីពីនម្នាក់ ឈ្មោះ ហ្វឡរ កុនតិមប្លាស្យុន (Flor Contemplacion) ត្រូវបានគេកាត់ទោសសម្លាប់ដោយព្យួរកពីបទមនុស្សឃាតនៅក្នុងប្រទេសសិង្ហបុរី មានបុណ្យសពដ៏ធំមួយសម្រាប់នាង ប្រារព្ធធ្វើឡើងក្នុងប្រទេសហ្វីលីពីន ហើយថែមទាំងមានការចាក់ផ្សាយតាមរយៈបណ្តាញទូរទស្សន៍ជាតិទៀតផង ។ អ្នកចូលរួមបុណ្យសពនេះ បានបង្ហាញឲ្យឃើញពីការអាណិតអាសូរពីមហាជនដល់ជីវិតដ៏លំបាករបស់នាងនិងកម្មករអន្តោប្រវេសន៍ជាតិហ្វីលីពីនដទៃទៀត ។ ករណីនេះដែរ គេអាចប្រៀបធៀបទៅនឹងពិធីបុណ្យសពជាសាធារណៈដ៏គួរឲ្យសោកសង្រេងជូនចំពោះក្រុមកម្មករ ដែលត្រូវបានគេសម្លាប់នៅក្នុងប្រទេសអង់គ្លេស នាដំណាក់កាលដំបូងនៃការធ្វើបដិវត្តន៍ឧស្សាហកម្ម ដោយសារតែពួកគេគ្មានការងារធ្វើ ហើយបះបោរប្រឆាំងទៅនឹងបច្ចេកវិទ្យាទំនើប ដោយបំផ្លាញចោលនូវគ្រឿងម៉ាស៊ីនផ្សេងៗ នៅក្នុងរោងចក្រ ។

ក្នុងចំណោមអ្នកសារព័ត៌មានឆ្នើមៗ ទាំងឡាយ លោក ម៉ុចតារ លូប៊ីស (Mochtar Lubis) ដែលជាអ្នកកាសែតមានដើមកំណើតមកពីកោះស៊ូម៉ាត្រា បានសរសេរសៀវភៅមួយក្បាល ដែលលក់ដាច់បំផុតរបស់គាត់នៅឆ្នាំ ១៩៨៣ ក្រោមចំណងជើងថា «**ភាពចាស់ទ្រុឌទ្រោមរបស់ប្រទេសឥណ្ឌូនេស៊ី**» ។ គាត់បានត្អូញត្អែរថា ទំនើប-នីយកម្ម គឺជាអប្បិយជំនឿថ្មីមួយរបស់ប្រទេសឥណ្ឌូនេស៊ី ពោរពេញទៅដោយមន្តអាគមនិងមន្តគាថាផ្សេងៗ

*ហើយមានតែមនុស្សដែលជា «អ្នកបង្កើតនូវនិមិត្តសញ្ញា មានជំនាញច្បាស់លាស់» ប៉ុណ្ណោះ ទើបអាចបង្កើតវាឡើងបាន ។ ប៉ុន្តែ ភាពខុសគ្នារវាងទស្សនៈនេះ ហើយនិងទស្សនៈរបស់លោកសាស្ត្រាចារ្យប៊ូក ដែលថា ប្រទេសឥណ្ឌូនេស៊ីមិនអាចធ្វើទំនើបកម្មបានឡើយ ពីព្រោះតែវប្បធម៌មិនចង់មាន ហើយដែលចង់រស់នៅតាមបែបប្រពៃណីនោះ គឺជារង្វាស់មួយអាចឲ្យគេដឹងបានពីរបៀបដែលប្រទេសឥណ្ឌូនេស៊ីនិងបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ជាច្រើនទៀត ធ្វើដំណើរបានឆ្ងាយប៉ុណ្ណាចាប់តាំងពីទទួលបានឯករាជ្យមក ៕*

# ជំពូកទី ២

## ឥទ្ធិពលនៃ «អព្ភូតហេតុ» សេដ្ឋកិច្ចទៅលើមនុស្ស

*ច្បាប់ដើមនៃអត្ថបទនេះ សរសេរជាភាសាអង់គ្លេស ក្រោមចំណងជើងថា៖* Human Consequences of the Economic "Miracle"
*អត្ថបទនេះដកស្រង់ចេញពីសៀវភៅ ៖* **ការកកើតអាស៊ីអាគ្នេយ៍ទំនើប**
*រក្សាសិទ្ធិ គ.ស. ២០០៥ ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យសិង្ហបុរី*
*បោះពុម្ពលើកទី ១ គ.ស. ២០០៥ នៅសហរដ្ឋអាមេរិក ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យហាវ៉ៃ ។*

## CHAPTER 2

Human Consequences of the Economic "Miracle"
(*The emergence of Modem Southeast Asia*)

**Copyright © 2005 by Singapore University Press.**

**First published in 2005 by University of Hawai'i Press.**

**បកប្រែដោយ ៖ គី សុភាជា**

# ជំពូកទី ២
# ឥទ្ធិពលនៃ «អព្ភូតហេតុ» សេដ្ឋកិច្ចទៅលើមនុស្ស

*ទោះបីជាបដិវត្តន៍ឧស្សាហកម្មនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ មិនមានលក្ខណៈរលូនទៅមុខ ក៏ការផ្លាស់ប្ដូរបដិវត្តន៍ដ៏យឺតយ៉ាវនេះ ធ្វើឲ្យចំណូលជាមធ្យម មានការកើនឡើងផងដែរ ។ មនុស្សមានអាយុវែងនិងមានកំពស់ខ្ពស់ជាងមុន ។ មានទំនិញកាន់តែច្រើនលក់នៅគ្រប់កន្លែង ហើយរបស់ទាំងអស់នោះមិនមែនសម្រាប់តែនៅក្នុងអគារការិយាល័យដ៏ខ្ពស់ ឬក្នុងភូមិគ្រឹះរបស់ពួកអ្នកមានទ្រព្យនោះទេ ។ ប្រជាពលរដ្ឋអាស៊ីអាគ្នេយ៍រាប់រយលាននាក់ មានអាហារបរិភោគច្រើនជាងមុន ហើយពួកគេមានថវិកាអាចទិញស្បែកជើងតឺនីស មួកកីឡាបេហ្ស៍ប៊ល និងទឹកក្រូចកូកាកូឡាបាន ។ ប្រជាពលរដ្ឋទាំងនោះរាប់កោដិ កំពុងសប្បាយរីករាយជាមួយនឹងការមើលទូរទស្សន៍ និងការប្រើប្រាស់អ៊ាំងទែរណែត ។ ដូច្នេះ ប្រវត្តិសាស្ត្រណាមួយមិនទទួលស្គាល់នូវភាពចម្រុងចម្រើនរបស់អាស៊ីអាគ្នេយ៍ គឺជាកំហុសមូលដ្ឋានមួយ ។ ប៉ុន្តែ ប្រសិនបើមានប្រវត្តិសាស្ត្រណាមួយទទួលស្គាល់ថា មានភាពថ្កុំថ្កើងដូចគ្នានិងស្មើគ្នា នៅក្នុងប្រទេសនៃតំបន់ ឬជនជាតិណាក៏ដោយនោះ វាក៏ជាកំហុសមួយដែរ ។ សរុបទៅ ដើម្បីវាយតម្លៃអំពី «អព្ភូតហេតុ» នៅអាស៊ីអាគ្នេយ៍ យើងត្រូវវិភាគអំពីអព្ភូតហេតុនេះ ។*

## ឥទ្ធិពលវិជ្ជមាន

*ប្រទេសសិង្ហបុរី គឺជាប្រទេសដ៏មានជោគជ័យមួយក្នុងយុគសម័យទំនើប ។ លក្ខខណ្ឌសម្ភារៈជាមួយចំណូលជាមធ្យមក្នុងមនុស្សម្នាក់ៗ របស់ប្រទេសនេះ (ប្រហែល ២៣.០០០ ដុល្លារសហរដ្ឋអាមេរិកនៅក្នុងឆ្នាំ២០០០) មានច្រើនជាងបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ដទៃទៀត ៥ ដង (លើកលែងតែប្រទេសប្រ៊ុយណេ ដែលជាប្រទេសអ្នកមានខាងប្រេងកាត) ហើយមានលទ្ធភាពទិញទំនិញចំនួន ២ ដងកន្លះខ្ពស់ជាងប្រទេសឯទៀត ។ មកត្រឹមសហវសត្សរ៍ថ្មី អាយុកាលមធ្យម គឺប្រហែល ៨០ ឆ្នាំ (ដូចដែលគេប៉ាន់ប្រមាណទូទាំងពិភពលោក ស្ត្រីមានអាយុវែងជាងបុរស ៥ ឆ្នាំ) ហើយមរណប្រមាណរបស់កុមារវិញ មានការថយចុះរហូតដល់ ៣ ភាគពាន់នៃកំណើតទារក ។ តួលេខនេះអាចប្រៀបធៀបទៅនឹងតួលេខដ៏ប្រសើរបំផុតក្នុងពិភពលោកបាន ។ អត្រាមនុស្សពេញវ័យដែលចេះអក្សរមានលើសពី ៩០% ។ លើសពីនេះ កម្មវិធីកសាងជម្រកសាធារណៈ បានបង្កើតឲ្យសំណង់អនាធិបតេយ្យ និងភាពគ្មានទីជម្រក បានបាត់បង់ទៅសឹងតែទាំងអស់ ។ ទីក្រុងមានសភាពស្អាតបាត ពីព្រោះតែការដាក់ចេញនូវបទបញ្ញត្តិផ្សេងៗ ដូចជា ការហាមប្រាមមិនឲ្យស្ដោះកាកស្ករកៅស៊ូផ្ដេសផ្ដាស ។ ចរាចរនៅតាមទីក្រុងមានលក្ខណៈរលូន ដោយសារតែមានការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកដើម្បីយកពន្ធ (មិនលើកទឹកចិត្ត) យានយន្តគ្រប់ប្រភេទដែលធ្វើដំណើរចូលទៅក្នុងតំបន់ពាណិជ្ជកម្មក្នុងទីក្រុង ហើយក៏ដោយសារតែមានសេវារថយន្តក្រុង និងរថភ្លើងក្រោមដី ប្រកបដោយប្រសិទ្ធភាព ។ និស្សិតសិង្ហបុរីភាគច្រើន តែងតែទទួលបានពានរង្វាន់ក្នុងការប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ ។ ដូច្នេះហើយ ប្រទេសសិង្ហបុរីហាក់ដូចជាបានរៀបចំយ៉ាងល្អក្នុងដំណើរឆ្ពោះ*

*ទៅរក «សេដ្ឋកិច្ចផ្អែកលើចំណេះដឹង» នាក្រោយសម័យឧស្សាហកម្ម ។ ចំណែកអ្នករិះគន់វិញ បានលើកឡើងថា ធម្មជាតិនៃការគ្រប់គ្រងផ្តាច់ការក្នុងប្រទេសសិង្ហបុរី គឺជាឧបសគ្គរារាំងចំពោះប្រទេសនេះផ្ទាល់ ។ ហើយអ្នករិះគន់មួយចំនួនបានហៅករណីនេះ ដូចជាឃ្លាដ៏គួរឲ្យចងចាំមួយរបស់លោក វីល្លៀម ហ្គិបសុន* (William Gibson) *ដែលថា ជា «សួនកម្សាន្តឌីស្នីឡែនដ៍ ពោរពេញដោយការដាក់ទោសប្រហារជីវិត» ជាដើម ។ ក៏ប៉ុន្តែ ហាក់បីដូចជាប្រជាពលរដ្ឋសិង្ហបុរីភាគច្រើន បានអត់ឱនចំពោះការគ្រប់គ្រងផ្តាច់ការនេះ ពីព្រោះតែពួកគេបានទទួលនូវផលប្រយោជន៍ជាច្រើនពីរដ្ឋាភិបាលពួកគេ ។*

*សិង្ហបុរី គឺដូចទៅនឹងទីក្រុងដ៏អស្ចារ្យផ្សេងៗទៀតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែរ ។ ទីក្រុងទាំងនេះមានលក្ខណៈដូចគ្នាច្រើន ពុំដូចជនបទរបស់ប្រទេសនីមួយៗ ដែលមានលក្ខណៈរបស់ខ្លួន ។ មាននូវឧទាហរណ៍ជាក់ស្តែងជាច្រើនចំពោះការគិតដូចនេះ ដូចជាគេឲ្យមានរោងចក្រ និងសាកលវិទ្យាល័យ អគារពាណិជ្ជកម្មដ៏ទំនើបដែលមានទាំងហាងលក់រាយ និងអាហារដ្ឋានលក់អាហារទាន់ចិត្ត ប៉ុកអគារការិយាល័យនិងអាប៉ាតឺម៉ង់ខ្ពស់ៗ ការកម្សាន្តផ្សេងៗ ដែលមានតាំងពីល្ខោន និងរបាំបុរាណ រហូតដល់វង្គសាលសម្តែងរបាំស្រាត និងព្រឹត្តិការណ៍ប្រកួតកីឡាដ៏អស្ចារ្យផ្សេងៗ ពន្លឺភ្លើងដ៏ភ្លឺចិញ្ចែងចិញ្ចាច ផ្ទាំងផ្សាយពាណិជ្ជកម្មធំៗ ជាដើម ហើយក្រៅពីនេះទៀត (លើកលែងប្រទេសសិង្ហបុរីចេញ) គេនៅឃើញមានសំណង់អនាធិតេយ្យរបស់អ្នករស់នៅគ្មានច្បាប់អនុញ្ញាតដ៏ស្មោគគ្រោក និងការស្ទះចរាចរ ដែលមានភាពរញ៉េរញ៉ៃផ្សេងៗទៀតផងដែរ ។ ទីក្រុងកូឡាឡាំពួរ ប្រៀបដូចជាទីក្រុងហ្សាការតាដ៏តូចមួយ ដែលស្តែងឡើងតាមរយៈកំពូលអគារភ្លោះដ៏អស្ចារ្យ ។ ចំណែកឯទីក្រុងហូជីមិញ (ព្រៃនគរ) វិញ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ បានយកគំរូតាមទីក្រុងបាងកកនាទសវត្សរ៍ឆ្នាំ ១៩៧០ ។ ប្រជាជនបានផ្លាស់លំនៅយ៉ាងច្រើនមិនត្រឹមដើម្បីស្វែងរកឱកាសសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឲ្យស្វែងរកជីវិតរស់នៅក្នុងទីក្រុងផងដែរ ។ ករណីនេះប្រៀបដូចនឹងបទកំណាព្យរបស់កវីភូមា ១ រូប ដែលថែងថា ÷*

> ...នេះគឺជាភាពរំជើបរំជួលចំពោះជីវិតរស់ក្នុងទីក្រុង តើមានកន្លែងណាទៀតដែលអ្នកអាចដើរកាត់នៅលើផងវិថីដ៏អ៊ូអរមួយបាននោះ ហើយកុំឆ្ពោះទៅរកម្ខាងផ្សេងទៀតអី និងសូម្បីតែនៅភូមិក្នុងព្រៃ ដែលឮសូរស្នូរកាំភ្លើងនៅពេលរាត្រី គឺជីវិតគ្មានតម្លៃអ្វីទាំងអស់ ហេតុនេះហើយខ្ញុំជាអ្នកផ្សងព្រេងវ័យក្មេងមួយរូប ខ្ញុំសប្បាយភ្លើតភ្លើនពេលដែលខ្ញុំកំពុងតែស្ថិតនៅក្នុងទីក្រុងរ៉ង់ហ្គូន ។

*សមាមាត្ររបស់ប្រជាជនអាស៊ីអាគ្នេយ៍ដែលរស់នៅក្នុងទីក្រុង បានកើនឡើងពី ១៥% ទៅ ២៤% ចាប់ពីឆ្នាំ ១៩៥០ដល់ ១៩៨០ ហើយនិងបានបន្តកើនឡើងរហូតដល់ ៣៧,៥% គិតមកទល់នឹងឆ្នាំ ២០០០ ។ មកទល់នឹងទសវត្សរ៍ឆ្នាំ ១៩៩០ កំណើនប្រជាជនក្នុងតំបន់បានថយចុះដល់កំណើនប្រមាណ ១ ភាគរយក្នុងមួយឆ្នាំ ប៉ុន្តែទំហំទីក្រុងទាំងឡាយវិញ បានពង្រីក ៣ ដងច្រើនជាងកំណើនប្រជាជននេះ ។ ទីក្រុងហ្សាការតា ម៉ានីល បាងកក និងហូជីមិញ បានក្លាយជាទីក្រុងធំៗ ដែលមានប្រជាជនច្រើនជាង ៥ លាននាក់បើគិតមកទល់ឆ្នាំ ២០០០ (ចំណែកឯទីក្រុងហ្សាការតាព្រមទាំងជាយក្រុង មានប្រជាជនជិត ១៧ លាននាក់) ។ សូម្បីតែក្រុងរបស់បណ្តាខេត្តមួយចំនួនដែលបានអភិវឌ្ឍឲ្យក្លាយទៅជាចំណុចប្រសព្វអនុតំបន់នោះ ក៏បានទទួលជោគជ័យនិងប្រជាប្រិយយ៉ាងរហ័សផងដែរ ដាឧទាហរណ៍ដូចជាការស្ថាបនាឡើងនូវសួនឧស្សាហកម្មដែលគេបានគ្រោងទុកជាមុន ប៉ុក៏តំបន់ពាណិជ្ជកម្មសម្រាប់ដំណើរការនាំចេញទំនិញជាដើម ។ ចំពោះទីក្រុងឈៀងម៉ៃវិញ គិតមកទល់នឹងឆ្នាំ ១៩៧០*

មានប្រជាជនតិចជាង ១០០.០០០ នាក់ និង ៣៥០.០០០ នាក់ នៅក្នុងឆ្នាំ ១៩៩០ ហើយមកទល់នឹងឆ្នាំ ២០០០ មាន ១,៥ លាននាក់ ។ អគារពាណិជ្ជកម្មនៃទីក្រុងសេប៊ូ (Cebu) ដែលមានទីតាំងស្ថិតនៅចំកណ្ដាលប្រទេសហ្វីលីពីន មានទាំងទឹកផ្កាឈូកនិងទូដាក់អីវ៉ាន់ ដើម្បីផ្ដល់ផាសុកភាពដល់អ្នកធ្វើដំណើរវិលល្ងាចតាមកាណូតឆ្លងកោះល្បឿនលឿន ដែលមកពីតំបន់ឆ្ងាយៗ ដូចជា បូហូល (Bohol) និង ឡីតេ (Leyte) នោះ ។

តាមការពិត សញ្ញាណគំហើញមួយក្នុងចំណោមសញ្ញាណគំហើញជាច្រើន នៃភាពចម្រុងចម្រើននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺការកើនឡើងនូវក្រុមអ្នកមានទ្រព្យសម្បត្តិច្រើនជាងមុន ។ មន្ត្រីរដ្ឋការដែលជាស្នូលនៃវណ្ណៈគហបតីក្នុងស្រុក ឥឡូវនេះបានក្លាយទៅជាសហគ្រិន ជានាយទាហាន ជាអ្នកមានជំនាញច្បាស់លាស់ ជាអ្នកសម្ដែងសិល្បៈ និងជាអ្នកធ្វើការនៅក្នុងការិយាល័យជាដើម ។ ហើយពួកគេភាគច្រើន គឺជាអតិថិជន (ជាជាងអ្នកផលិត) របស់ហាងកាហ្វេស្ដារប៊ីកស៍ (Starbucks) របស់រថយន្តម៉ាកហុងដា (Honda) របស់អាប៉ារតឺម៉ង់ដ៏ល្អប្រណីត ស្បែកជើងម៉ាកអាឌីដាស (Adidas) ភាពយន្តគំនូរជីវចលរបស់ជប៉ុន និងជាអ្នកទេសចរធ្វើដំណើរកម្សាន្តទៅកាន់បរទេសនាពេលវិស្សមកាល ។ ក្នុងចំណោមក្រុមមនុស្សទាំងនេះ ម្នាក់ៗ មានលក្ខណៈខុសប្លែកគ្នាទៅតាមចំនួនទ្រព្យសម្បត្តិជាក់ស្ដែង ។ នៅក្នុងរចនាសម្ព័ន្ធ គេអាចបែងចែកអ្នកទាំងនោះជាពីរចំណាត់ថ្នាក់ គឺ «ក្រុមអ្នកមានថ្មី» មានដូចជាម្ចាស់កម្មសិទ្ធិផ្សេងៗ និងវិនិយោគិន ហើយនិង «ក្រុមមនុស្សថ្នាក់កណ្ដាល» ដែលមានដូចជានិយោជកនិងម្ចាស់ហាងតូចៗ ផ្សេងៗ ។

ពួកគេភាគច្រើន បានទទួលការអប់រំយ៉ាងហោចណាស់ កំត្រឹមមធ្យមសិក្សាដែរ ។ មកទល់នឹងទសវត្សរ៍ឆ្នាំ ១៩៩០ មាននិស្សិតជាច្រើនបានបញ្ចប់ថ្នាក់សាកលវិទ្យាល័យនៅក្នុងតំបន់ ។ ដោយសារមូលហេតុនេះ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៧ របស់ប្រទេសថៃ បានតម្រូវឲ្យសមាជិកថ្មីនៃរដ្ឋសភាជាតិត្រូវមាន «បរិញ្ញាបត្រ ឬសញ្ញាបត្រប្រហាក់ប្រហែល» ។ ប្រទេសសិង្ហបុរីបានអនុវត្តការកំណត់បែបនេះមុនរួចហើយ ។ ការរីកដុះដាលនៃការអប់រំកម្រិតឧត្តមសិក្សា ក៏មានគេរិះគន់ផងដែរ ពីព្រោះតែសាកលវិទ្យាល័យមួយចំនួន មានលក្ខណៈខុសគ្នាឆ្ងាយ បើធៀបទៅនឹងស្ដង់ដារនៃសាកលវិទ្យាល័យល្អបំផុតក្នុងតំបន់ ។ ប៉ុន្តែ ជារឿយៗ ទោះបីជាគេបានមើលឃើញនូវស្ថានការណ៍នេះថា មានភាពខ្វះខាត និងមិនអាចរំពឹងទៅមុខបានក៏ដោយ ក៏យុវជន យុវនារីនៃបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ ជាច្រើនលាននាក់បានសិក្សាពីអ្វីផ្សេងៗ ហើយយ៉ាងហោចណាស់ ក៏បានសិក្សាពីវិធីក្នុងការបង្កើតមេរោគកុំព្យូទ័រដែរ (ឧទាហរណ៍ដូចជាសារអេឡិចត្រូនិច ក្នុងឆ្នាំ ២០០០ ក្រោមចំណងជើងថា «អៃឡូវយូ [ខ្ញុំស្រឡាញ់អ្នក]» ដែលជាមេរោគកុំព្យូទ័រមួយបង្កើតឡើងដោយនិស្សិតនៃសាកលវិទ្យាល័យបច្ចេកទេសម៉ានីលជាដើម) ។ លើសពីនេះ និស្សិតអាស៊ីអាគ្នេយ៍ភាគច្រើនបានសិក្សាយ៉ាងហោចក៏ភាសាបរទេសសំខាន់មួយដែរ ដូចជា ភាសាអង់គ្លេស ភាសាជប៉ុន និងភាសាចិន ដើម្បីភ្ជាប់ជាមួយការងាររបស់ពួកគេ ឬដែលពួកគេបានរៀននៅឯសាលារៀនឬវិទ្យាល័យនោះ ។

លក្ខណៈពិសេសមួយផ្សេងទៀតរបស់ពួកវរជន គឺតួនាទីជាសាធារណៈ ដែលមានលក្ខណៈសកម្មច្រើនជាងមុនរបស់ស្ត្រី ។ តាមលក្ខណៈសេដ្ឋកិច្ច ស្ថានការណ៍របស់ស្ត្រីនៅក្នុងទីក្រុងនិងស្ត្រីធ្វើការនៅក្នុងការិយាល័យ រោងចក្រផ្សេងៗ ភាគច្រើនមានភាពល្អប្រសើរជាងមុន ទោះជាពួកគេនៅតែទទួលបានប្រាក់ចំណូលនិងឋានៈទាបជាងបុរសក៏ដោយ ។ ការពង្រីកឱកាសទទួលបានការអប់រំ មានន័យថា ស្ត្រីភាគច្រើនមានឱកាសទទួលបានការងារធ្វើនៅក្នុងផ្នែកជំនាញវិជ្ជាជីវៈ ដូចជាការបង្រៀនរួមទាំងផ្នែកសេវាកម្មផ្សេងៗ ដែលកំពុងតែរីកចម្រើនឡើង ។ ស្ត្រី

ដែលទទួលបានការអប់រំជ្រៅជ្រះភាគច្រើន នឹងមិនសប្បាយចិត្ត ឬពេញចិត្តចំពោះការរស់នៅរបស់ពួកគេទៀតទេ ប្រសិនបើពួកគេនៅតែមើលថែរក្សាផ្ទះនិងជួយជ្រោមជ្រែងអាជីពការងាររបស់ស្វាមីពួកគេ ដោយគ្រាន់តែធ្វើជាកិរិយារៀបចំអាហារដូចពីមុននោះ ។ តាមលក្ខណៈប្រជាសាស្ត្រ ការពង្រីកការអប់រំក៏មាននូវសារៈសំខាន់ផងដែរ ដូចជាកុមារីនិងស្ត្រីក្មេងៗជាច្រើន អាចទទួលបានការអប់រំកាន់តែខ្ពស់ ទំនងជាមានបំណងចង់បានបុត្រធីតាតិចជាងមុន ។ ករណីនេះបណ្ដាលមកពីកត្តាពីរយ៉ាង ទី ១ ពួកគេបានពន្យារពេលរៀបអាពាហ៍ពិពាហ៍និងទី ២ ពីព្រោះពួកគេយល់កាន់តែច្បាស់ពីរបៀបរស់នៅមួយបែបផ្សេងទៀត និងជម្រើសក្នុងការរៀបចំគ្រួសារ ។ ពីព្រោះតែស្ត្រីបានទទួលសិទ្ធិក្នុងការសម្រេចចិត្តទាំងនៅក្នុងសង្គម ក៏ដូចជានៅក្នុងគ្រួសារ អត្រាកំណើតទារកអាចមានការថយចុះ ដោយសារស្ត្រីបានទទួលនូវការអប់រំការងារ និងសេវាថែរក្សាសុខភាពគ្រប់គ្រាន់ ។

ភាពថ្កុំថ្កើនដូចនេះ ក៏បានបង្កឲ្យមានភាពរីកចម្រើនក្នុងវិស័យសិល្បៈនៃតំបន់អាស៊ីអាគ្នេយ៍ ។ អ្នកសិល្បៈអាចរកថវិកាបានគ្រប់គ្រាន់ ចំពោះការលក់ចេញនូវផ្ទាំងគំនូរ អត្ថបទ កំណាព្យ និងរឿងប្រលោមលោកខ្លីៗរបស់ពួកគេ និងមានពេលសម្រាកគ្រប់គ្រាន់ ដើម្បីតែងនិពន្ធអត្ថបទផ្សេងៗ ដែលមានតាំងពីខូនបែបបុរាណ (ល្ខោនខោលបែបសៀម) រហូតដល់ចម្រៀងសម័យ និងសម្រាប់ការរៀបចំនូវវ៉ាយ៉ាំងគូលីត (ល្ខោនស្បែក) ដើម្បីដាក់សម្ដែង និងច្នៃជារឿងបែបកម្សត់ បែបទំនើបផ្សេងៗ ហើយថែមទាំងសម្រាប់ការផលិតខ្សែភាពយន្តនិងរឿងសម្រាប់ចាក់បញ្ចាំងតាមទូរទស្សន៍ ព្រមទាំងល្ខោននិយាយផ្សព្វផ្សាយតាមវិទ្យុផងដែរ ។ ជាធម្មតា គេឃើញមានមនុស្សមួយចំនួន បានត្អូញត្អែរអំពីការធ្លាក់ចុះស្ដង់ដារ ដោយបានពោលថា តន្ត្រីញាក់សម័យថ្មី (រ៉េប និង រ៉ុក) កំពុងតែលុបបំបាត់ចម្រៀងប្រពៃណីទៅហើយ ។ ហើយគ្មាននរណាម្នាក់ដឹងអំពីវិធីសាស្ត្រក្នុងការតែងនិពន្ធចម្រៀងបែបបុរាណនេះឲ្យបានល្អទៀតទេ ។ តែមានមនុស្សមួយចំនួនទៀត បែរជាមានភាពត្រេកត្រអាលជាមួយនឹងទម្រង់បង្កើតបែបថ្មីនេះទៅវិញ ។ ភាពយន្តថៃ វៀតណាម និង ហ្វីលីពីន ជារឿយៗ បានទទួលពានរង្វាន់អន្តរជាតិ ហើយនៅពេលជាមួយគ្នានោះ អាស៊ាននិងអង្គការពហុជាតិជាច្រើនផ្សេងទៀត បានជួយឧបត្ថម្ភដល់កម្មវិធីផ្លាស់ប្ដូរផ្នែកអក្សរសាស្ត្រនិងតូរ្យតន្ត្រី ដើម្បីណែនាំបង្ហាញដល់ប្រជាពលរដ្ឋអាស៊ីអាគ្នេយ៍ឲ្យបានយល់និងស្គាល់ពីវប្បធម៌របស់ប្រទេសជិតខាងជាលើកដំបូង ។

# ឥទ្ធិពលអវិជ្ជមាន

នៅពីក្រោយភាពថ្កុំថ្កើននេះ គេនៅតែឃើញមានភាពក្រីក្របន្តភ្ជាប់ជាមួយនឹងការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ចកើនឡើង ពាសពេញតំបន់អាស៊ីអាគ្នេយ៍ ។ ស្ទើរតែនៅគ្រប់ប្រទេសទាំងអស់ ក្រោយសម័យសង្គ្រាម គម្លាតនៃប្រាក់ចំណូលរបស់មនុស្សថ្នាក់ខ្ពស់និងទាបបំផុតនៅក្នុងសង្គម មានភាពខុសគ្នាខ្លាំងគួរឲ្យកត់សម្គាល់ ។ វាជាការពិតដែលថា អ្នកមាន កាន់តែមានឡើង ប៉ុន្តែហេតុដែលអ្នកក្រចេះតែក្រឡើង ឬមានគម្លាតកាន់តែឆ្ងាយពីអ្នកមាន គឺនៅតែជាបញ្ហាសម្រាប់ជជែកវែកញែកដដែល ។ ទិន្នន័យអំពីការបែងចែកប្រាក់ចំណូល ដែលផ្ទុយទៅនឹងមធ្យមភាគបង្ហាញនៅក្នុងប្រាក់ចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗ នោះគឺមិនអាចយកជាការបាន ។ ប៉ុន្តែ ទិន្នន័យទាំងនេះបានលើកឡើងថា នៅក្នុងប្រទេសអាស៊ីអាគ្នេយ៍ភាគច្រើន ប្រជាជន ២០% ជារឿយៗ កាន់តែក្រឡើងៗ ទោះបីជាស្ថានភាពរបស់អ្នកដែលមានជីវភាពប្រសើរ កាន់តែប្រសើរឡើងជាងមុនក៏ដោយ ។ នៅស្ទើរតែគ្រប់ប្រទេស

ទាំងអស់ គេឃើញមានសំណង់អនាធិបតេយ្យក្នុងទីក្រុង ពោរពេញទៅដោយភាពរញ៉េរញ៉ៃ ហើយកូនក្មេងភាគច្រើន ដែលរស់នៅតំបន់ជនបទមានកង្វះជីវជាតិ ។ លោក អាប្រូឌីស៊ីយ៉ូ ឡាគីយ៉ាន់ (Aprodicio Laquian) បានបែងចែកដាច់ពីគ្នានូវ «សំណង់អនាធិបតេយ្យដែលពោរពេញដោយក្តីសង្ឃឹម» ពី «សំណង់អនាធិបតេយ្យដែលគ្មានក្តីសង្ឃឹម» ប៉ុន្តែ កន្លងទៅ «សំណង់អនាធិបតេយ្យដែលពោរពេញដោយក្តីសង្ឃឹម» អាចក្លាយទៅជា «សំណង់អនាធិបតេយ្យដែលគ្មានក្តីសង្ឃឹម» ប្រសិនបើក្តីសង្ឃឹមនោះត្រូវបានគេបដិសេធចោលជានិរន្តរ៍នោះ ។

តើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះ «ផ្នែកដែលអន់ថយ» នេះ ? ពួកបរទេស ច្រើនអ្នកដែលទ្រូវទទួលរងនូវការបន្ទោសចំពោះស្ថានការណ៍ដ៏អាក្រក់បំផុតនៃផ្នែកអន់ថយនេះ ។ ក្នុងករណីជាច្រើន ពួកគេជាអ្នកទទួលខុសត្រូវពិតប្រាកដ ។ នៅពេលដែលបានឯករាជ្យថ្មីៗ វាជាការងាយស្រួលណាស់ក្នុងការចោទប្រកាន់ទៅលើគេរដំណែលចក្រពត្តិនិយម ។ នៅពេលដែលរដ្ឋាភិបាលមួយចំនួន ដូចជារដ្ឋាភិបាលនៃប្រទេសហ្វីលីពីន ជាដើម នៅតែរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយនឹងអ្នកដឹកនាំមុនៗ របស់ពួកគេនោះ «អាណានិគមបែបថ្មី» កំពុងតែមានជាបន្ត ហើយជារឿយៗ ត្រូវបានគេចោទប្រកាន់ថា ជាឧបសគ្គបង្អាក់ដល់ការអភិវឌ្ឍ ។ កន្លងទៅ ការលើកឡើងដូចនេះ ទោះជាមានលក្ខណៈសមហេតុផលនៅពេលដំបូងក៏ដោយ ក៏វាបានបាត់បង់នូវលក្ខណៈទាក់ទាញបន្តិចម្តងៗដែរ ។ (បើផ្តោតទៅលើលក្ខខណ្ឌប្រៀបធៀបវិញ សេដ្ឋកិច្ចហ្វីលីពីនមានការរីកចម្រើនយ៉ាងប្រាកដនៅក្នុងរយៈពេលបន្ទាប់ពីបញ្ចប់សង្គ្រាមភ្លាមៗ នៅពេលដែលទំនាក់ទំនងជាមួយនឹងសហរដ្ឋអាមេរិក កាន់តែមានភាពស្អិតល្មួតខុសពីមុន ។ តែនៅទសវត្សរ៍បន្ទាប់ទាំងប៉ុន្មាន នៅពេលដែលចំណងមិនខ្លាំងក្លាដូចសម័យមុន ការអភិវឌ្ឍសេដ្ឋកិច្ចមិនប្រសើរដូចពីមុនទេ ។) នៅទីណាដែលចំណងទាក់ទងជាមួយពួកអាណានិគមពីមុនៗ មក ចុះខ្សោយ គេអាចចោទប្រកាន់ធនាគារពិភពលោកនិងមូលនិធិរូបិយវត្ថុអន្តរជាតិ ថា ជាអ្នកទទួលខុសត្រូវ ដោយសារការផ្តល់ជំនួយមានការដាក់លក្ខខណ្ឌទៅលើកិច្ចព្រមព្រៀងសព្វបែបយ៉ាងដ៏តឹងរ៉ឹងបំផុត ដែលរួមមានទាំងការកម្រិតប្រាក់បៀវត្សរ៍ឲ្យនៅដដែលជាដើម ឬឲ្យថយចុះ ។ ប្រទេសវៀតណាម លាវ និងកម្ពុជា បានទទួលរងការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ពីសំណាក់ការលុកលុយរបស់ប្រទេសឈ្លានពានមួយចំនួន ហើយចំណែកឯប្រទេសភូមា ឥណ្ឌូនេស៊ី និងហ្វីលីពីនវិញ បានទទួលរងនូវឧទ្ទាមកម្មផ្សេងៗ ដែលបង្កឡើងដោយពួកជនជាតិភាគតិចនៅក្នុងប្រទេស ដែលគាំទ្រដោយក្រុមមនុស្សមកពីខាងក្រៅប្រទេស ។

ទោះជាយ៉ាងណាក៏ដោយ មិនយូរមិនឆាប់ ប្រជាជនអាស៊ីអាគ្នេយ៍បានចោទជាសំណួរថា តើមេដឹកនាំហើយនិងគោលនយោបាយរបស់ពួកគេ មានទំនួលខុសត្រូវទៅលើភាពក្រីក្រ ដែលកំពុងតែបន្តមានមិនចេះចប់នេះឬទេ ។ នៅក្នុងឆ្នាំ ១៩៨៩ លោក មហាធៀរ មហាម៉ាត់ បានថ្លែងថា ៖

> ពីព្រោះតែសង្គមដែលមានជាតិសាសន៍ចម្រុះរបស់យើង បានរំដោះខ្លួនឯងចេញផុតពីអំណាចគ្រប់គ្រងរបស់អាណានិគមនិយម យើងមិនអាចនៅតែបន្ទោសពួកគេអំពីបញ្ហារបស់យើងផ្ទាល់បានទៀតទេ ។ យើងគ្រាន់តែអាចបន្ទោសពួកគេ ចំពោះអតុល្យភាពផ្នែកសេដ្ឋកិច្ច នយោបាយ និងសង្គម ដែលពួកគេបានបន្សល់ទុកប៉ុណ្ណោះ ប៉ុន្តែក្រោយរយៈពេល ៣១ ឆ្នាំ បន្ទាប់ពីបានទទួលឯករាជ្យមក ប្រសិនបើយើងមិនបានរៀបចំបញ្ហាទាំងនេះដោយខ្លួនយើងនោះទេ យើងប្រាកដជាគ្មានសិទ្ធិបន្ទោសអ្នកដទៃបានទេ ។

ជាការពិតណាស់ របបភាគច្រើនគឺផ្តោតលើការយកចិត្តទុកដាក់ទៅដល់ការបំពេញចិត្តចំពោះពួកវរជន

នៅក្នុងប្រទេសនីមួយៗ (រួមទាំងវិនិយោគិនបរទេសផងដែរ) ក្នុងការព្យាយាមមិនតម្លើងប្រាក់ខែឲ្យពួកកម្មករ ដោយគាបសង្កត់ទៅលើសហជីពនានា ។ សេដ្ឋវិទូអាស៊ីអាគ្នេយ៍ទាំងឡាយ មានទំនោរយល់ស្របជាមួយនឹងគូភាគីអន្តរជាតិរបស់ពួកគេដែលថា ÷

> ការកសាងឡើងវិញជាបន្ទាន់នូវសេដ្ឋកិច្ចដើម្បីប្រឈមមុខជាមួយនឹងការប្រកួតប្រជែងនាថ្ងៃអនាគត ពេលខ្លះអាចតម្រូវឲ្យមានការអនុវត្តណាមួយប្រកបដោយការឈឺចាប់និងការបង្ខំ ទោះជាយើងមិនសុខចិត្តបានក៏ដោយ ។

ពួកគេបានសន្មតថា ជនក្រីក្រអាចទទួលរងការឈឺចាប់និងការបង្ខំច្រើនជាងអ្នកមាន ។ ស្រដៀងគ្នានេះដែរ រដ្ឋាភិបាលមានការស្ទាក់ស្ទើរក្នុងការយកពន្ធពីប្រជាពលរដ្ឋអ្នកមានរបស់ខ្លួន (ឬវិនិយោគិនបរទេស ដោយយល់ច្បាស់ណាស់ថា ពួកគេនឹងចាកចេញទៅវិញ ប្រសិនបើពួកគេមិនបានទទួលនូវប្រាក់ចំណេញពីការវិនិយោគរបស់ពួកគេទេ) ។ ស្ថានភាពនេះធ្វើឲ្យគម្រោងផ្សេងៗជាច្រើនខ្វះខាតទុនសម្រាប់អនុវត្ត ។

សូម្បីតែនៅពេលរដ្ឋាភិបាលបានសម្រេចចំណាយទៅលើសេវាសុខភាព ឬការអភិវឌ្ឍជនបទ ដើម្បីចែកចាយទៅដល់គោលដៅតាមបណ្ដាខេត្តនីមួយៗក៏ដោយ ក៏ថវិកាទាំងនេះត្រូវការឆ្លងកាត់តាមរយៈបណ្ដាញនយោបាយ ឬក៏មន្ត្រីរដ្ឋការនានា ដែលត្រួតត្រាដោយសមាជិកផ្សេងៗនៃក្រុមវរជនដែលជាបង្អែករបស់រដ្ឋាភិបាល (ដូចជាមេទ័ព ចៅហ្វាយស្រុក អភិបាលគ្រប់គ្រងតាមតំបន់ផ្សេងៗជាដើម) ។ ដូច្នេះ នៅទីបញ្ចប់ថវិកាទាំងនោះត្រូវបង្វែរចូលឯកជនវិញ ។ គេឃើញមានតម្រូវការឲ្យមានកំណែទម្រង់គ្មានទីបញ្ចប់ ។ ប៉ុន្តែនៅពេលដែលក្រុមមនុស្សទុច្ចរិតម្សេងៗមួយចំនួន ត្រូវបានគេបង្ខំឲ្យចុះចេញពីតំណែងដូចជា លោក ថ្នម (Thanom) នៅក្នុងប្រទេសថៃ ម៉ារកូស (Marcos) និងអេស្ត្រាដា (Estrada) នៅក្នុងប្រទេសហ្វីលីពីន ស៊ូហារតូ (Suharto) នៅក្នុងប្រទេសឥណ្ឌូនេស៊ី ជាដើម អ្នកកែទម្រង់ភាគច្រើនដែលឡើងជំនួសតំណែងមេដឹកនាំខាងលើមានជីវប្រវត្តិស្រដៀងៗគ្នា ដូច្នេះហើយបានជាគេឃើញមានការកែប្រែតិចតួចបំផុតចំពោះដំណើរវិវឌ្ឍគោលនយោបាយទាំងមូលរបស់រដ្ឋាភិបាល ។

ទោះបីជាភាពក្រីក្រ ដែលបន្តមានមិនចេះចប់ គឺជាបញ្ហាដ៏ធំបំផុតរបស់បណ្ដាប្រទេសកំពុងអភិវឌ្ឍនៅតំបន់អាស៊ីអាគ្នេយ៍ទាំងឡាយក៏ដោយ ក៏ភាពក្រីក្រនេះមិនមែនជាបញ្ហាដ៏អាក្រក់ក្រៃលែងនោះដែរ ។ តំបន់អាស៊ីអាគ្នេយ៍ក៏រងគ្រោះពីបញ្ហាដូចៗគ្នាជាច្រើន បានប៉ះទង្គិចដល់សង្គមទំនើបផ្សេងៗនៅគ្រប់កន្លែងទាំងអស់ ។ អំពើពុករលួយបានរីកសាយភាយ ជាពិសេសចំពោះទំនាក់ទំនងរវាងពាណិជ្ជកម្មនិងរដ្ឋាភិបាល ។ មនុស្សស្ទើរតែគ្រប់ៗរូបបានបញ្ចេញមតិតវ៉ាប្រឆាំងចំពោះបញ្ហាអំពើពុករលួយនេះ ។ ក្នុងនោះ រាល់ប្រធានាធិបតីហ្វីលីពីន ដែលគេបានជ្រើសតាំងឲ្យឡើងកាន់តំណែងថ្មីគ្រប់ៗរូប នៅរវាងឆ្នាំ ១៩៤៦ និងឆ្នាំ ១៩៨៦ បានសច្ចាថា នឹងលុបបំបាត់នូវអំពើពុករលួយបន្សល់ពីអ្នកកាន់អំណាចមុនៗ ។ ប៉ុន្តែ គេឃើញមានតែប្រទេសសិង្ហបុរីមួយគត់ ដែលអាចកាត់បន្ថយអំពើពុករលួយនេះបាន ។ អំពើពុករលួយក៏ជាដើមហេតុបង្កឲ្យមានអំពីហិង្សាដ៏សាហាវយង់ឃ្នងមួយចំនួន កើតឡើងនៅក្នុងតំបន់ផងដែរ ។ អំពើហិង្សាទាំងនោះមិនត្រូវបានប្រព្រឹត្តឡើងដោយគេរកប្រឆាំងទៅនឹងរដ្ឋាភិបាល ឬដោយក្រុមជនឧក្រិដ្ឋផ្សេងៗ (ទោះបីជាមានក្រុមទាំងពីរនេះក៏ដោយ) ប៉ុន្តែបែរជាត្រូវបានប្រព្រឹត្តឡើងដោយប៉ូលីស ទាហានរដ្ឋាភិបាល ឬកងកម្លាំងសន្តិសុខផ្សេងៗ ដែលមានការគប់គិតជាលក្ខណៈផ្លូវការទៅវិញ ។ នៅក្នុងបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ភាគច្រើន ក្រុមហ៊ុនធ្វើអាជីវកម្មកាប់ឈើលក់ ក្រុមហ៊ុនចម្ការ

អំពៅ និងក្រុមហ៊ុនទិញដីដើម្បីអភិវឌ្ឍន៍ឧស្សាហកម្មជាដើម អាចរកកងកម្លាំងទាហានស្លៀកពាក់ជាឯកសណ្ឋានមកជួយការពារទប់ទល់បំភិតបំភ័យ ឬក៏អាចឈានទៅដល់ការសម្លាប់ផងដែរ ចំពោះនរណាដែលបះបោរប្រឆាំងខ្លួននោះ ។ រដ្ឋាភិបាលបានត្រឹមតែបញ្ឈប់នូវសកម្មភាពបែបនេះមួយរយៈប៉ុណ្ណោះ ហើយបានធ្វើអន្តរាគមន៍តិចតួចបំផុត ឬក៏សឹងតែគ្មានសោះផងក៏មាន ។

អំពើពុករលួយក៏បានជួយការពារ ការប្រព្រឹត្តល្បែងស៊ីសងខុសច្បាប់ ពេស្យាកម្ម និងការធ្វើអាជីវកម្មថ្នាំញៀនផងដែរ ។ កាលពីអតីតកាល ជម្រើសនៃថ្នាំញៀនផ្សេងៗ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ មានលក្ខណៈស្រាលៗ ដូចជា ម្លូស្លា សុរា ថ្នាំជក់ (មានចាប់តាំងពីសតវត្សរ៍ទី ១៦ មកម្ល៉េះ) និងអាភៀន ជាដើម ។ ប៉ុន្តែនៅក្រោយសម័យសង្គ្រាម គេឃើញមាននូវប្រភេទថ្នាំញៀន ដែលមានឥទ្ធិពលកាន់តែខ្លាំងជាងមុន ។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ដោយមានការផ្សព្វគំនិតពីមន្ត្រីក្នុងស្រុកនិងភ្នាក់ងារ សេ.អ៊ី.អា អ្នកជួញដូរធ្វើចរាចរថ្នាំញៀនតំបន់ «ត្រីកោណមាស» (តាមពិតគឺជាតំបន់សម្បូរភ្នំខ្វាត់ខ្វែងក្បែរព្រំដែនទាំងបួនរបស់ប្រទេសចិន ភូមា លាវ និងថៃ) បានចាប់ផ្តើមធ្វើការប្រែក្លាយអាភៀនឲ្យទៅជាហេរ៉ូអ៊ីន ។ ការផលិតនៅតំបន់នេះ មិនត្រឹមតែអាចការពារពីគ្រោះថ្នាក់ និងសន្សំសំចៃចំពោះថ្លៃនៃការដឹកជញ្ជូនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចឲ្យថ្នាំញៀនប្រភេទនេះមានលក់នៅតាមទីផ្សារនានានៃបណ្តាប្រទេសអាស៊ីអាគ្នេយ៍ផងដែរ ។ គេឃើញថា មួយផ្នែកនៃផលិតកម្មកញ្ឆា និងការប្រើប្រាស់របស់វា បានរីកសាយភាយតាមរយៈគំរូរបស់ទាហានអាមេរិកាំង និងអ្នកទេសចរផ្សេងៗ ទៀតដែលបានធ្វើដំណើរមកកាន់តំបន់អាស៊ីអាគ្នេយ៍នេះ ។ អ្នកខ្លះក៏បានណែនាំប្រភេទថ្នាំញៀនមេតំហ្វេតាមីន (ដែលមានឈ្មោះក្នុងស្រុកថា «ទឹកកក» ឬ «ស្ប៊ាប៊ូ») ដែលនាពេលបច្ចុប្បន្ននេះ បានក្លាយជាថ្នាំញៀនដ៏មានឥទ្ធិពលអាក្រក់ខ្លាំងបំផុតក្នុងចំណោមថ្នាំញៀនដ៏មានឥទ្ធិពលអាក្រក់ផ្សេងៗ ទៀតក្នុងតំបន់ ។ ការឆ្លើយតបរបស់រដ្ឋាភិបាលនៃបណ្តាប្រទេសអាស៊ីអាគ្នេយ៍ ក៏ដូចជារដ្ឋាភិបាលនៃប្រទេសផ្សេងទៀត ស្ថិតនៅក្នុងភាពមិនច្បាស់លាស់ ។ រដ្ឋាភិបាលមួយចំនួន ដូចជារដ្ឋាភិបាលប្រទេសសិង្ហបុរីនិងម៉ាឡេស៊ី បានហាមប្រាមចំពោះសកម្មភាពទាំងឡាយណាដែលមានការពាក់ព័ន្ធនឹងថ្នាំញៀន ដោយបង្កើតច្បាប់ដ៏សាហាវតឹងរ៉ឹងបំផុត ដែលក្នុងនោះរួមមានទាំងទោសប្រហារជីវិត ។ ចំណែកខាងរដ្ឋាភិបាលផ្សេងទៀត ដូចជារដ្ឋាភិបាលប្រទេសភូមា ថៃ និងកម្ពុជា ផ្តល់ការអនុញ្ញាតឲ្យជាសម្ងាត់ ចំពោះការធ្វើចរាចរថ្នាំញៀន និងបានទទួលផលចំណេញពីការធ្វើចរាចរថ្នាំញៀននេះអស់រយៈពេលជាច្រើនឆ្នាំមកហើយ ទោះបីជាប្រក្រតី រដ្ឋាភិបាលប្រទេសទាំងនេះបានប្រយុទ្ធប្រឆាំងទៅនឹងចរាចរថ្នាំញៀនក៏ដោយ ។

អាជីវកម្មផ្លូវភេទ ដែលបណ្តាលឲ្យមានជម្ងឺឆ្លង ការប្រើប្រាស់ថ្នាំញៀន និងទាសភាពជាក់ស្តែង ក៏ផ្តល់សារៈប្រយោជន៍ចំពោះសេដ្ឋកិច្ចនៃបណ្តាប្រទេសជាច្រើនផងដែរ ។ ទោះបីជាពេស្យាកម្មមានប្រវត្តិដ៏យូរលង់ណាស់មកហើយនៅក្នុងស្រុកសៀមក៏ដោយ ឧស្សាហកម្មផ្លូវភេទទំនើបរបស់ប្រទេសថៃ ទើបបានចាប់ផ្តើមរីកឡើងនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ គឺនៅពេលដែលទាហានអាមេរិកាំងរាប់ពាន់នាក់បានមកបោះទីតាំងនៅទីនោះ ហើយក៏ធ្វើដំណើរកម្សាន្តក្នុងគោលបំណង «សម្រាកលំហែនិងការកម្សាន្តសប្បាយ» បន្ទាប់ពីបានទៅច្បាំងនៅប្រទេសវៀតណាមរួចមក ។ អស់រយៈពេលយ៉ាងយូរបន្ទាប់ពីសង្គ្រាមបានបញ្ចប់ទៅ បន្ទប់ម៉ាស្សានិងបារទាំងឡាយនៅផាត់ផុង និងផាត់ថាយ៉ា នៅតែសម្បូរទៅដោយបុរសនិងស្ត្រីក្មេងៗ ។ ក្មេងជំទង់ទាំងនេះ ត្រូវគេ

ជ្រើសរើសមកថ្មីថ្មោងពីតាមបណ្តាខេត្តនានា ឬត្រូវបានឪពុកម្តាយរបស់ពួកគេលក់ឲ្យផ្ទះបន ។ ក្មេងទាំងនោះត្រូវគេយកមកសម្រាប់បម្រើដល់ទេសចរមកពីបស្ចិមនិងអាស៊ីប្រទេស រួមទាំងអតិថិជនក្នុងស្រុកដែលកំពុងតែកើនឡើងផងដែរ ។ ទោះបីជារដ្ឋាភិបាលមានការខ្មាសអៀនចំពោះទិដ្ឋភាពជាចំហនៃអាជីវកម្មផ្លូវភេទក្នុងប្រទេសខ្លួនក៏ដោយ ក៏ពួកគេនៅតែគិតថា អាជីវកម្មផ្លូវភេទនេះមានសារៈសំខាន់ចំពោះភាពរីកចម្រើននៃវិស័យទេសចរណ៍ ។ ដូច្នេះហើយ ទើបពួកគេមិនដែលដាក់ចេញនូវវិធានការឲ្យបានម៉ឺងម៉ាត់ដើម្បីរារាំងអាជីវកម្មផ្លូវភេទទាំងនោះ ។ ទោះជាយ៉ាងនេះក្តី ក៏អាជ្ញាធរបានយល់យ៉ាងច្បាស់អំពីគ្រោះថ្នាក់នៃការរីករាលដាលនូវជម្ងឺអេដស៍ ដែលជះឥទ្ធិពលអាក្រក់នៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ ដោយចោទជាបញ្ហាមិនត្រឹមតែចំពោះវិស័យទេសចរណ៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចំពោះសង្គមថៃទាំងមូលផងដែរ ។ អ្នកខ្លះភ័យខ្លាចថា អាចបណ្តាលឲ្យមានការធ្លាក់ចុះនៃចំនួនប្រជាជនយ៉ាងប្រាកដ ។ មកទល់នឹងចុងទសវត្សរ៍ឆ្នាំ ១៩៩០ នៅក្នុងប្រទេសថៃ កម្មវិធីអប់រំផ្លូវភេទ និងការចែកចាយស្រោមអនាម័យ បានទប់ស្កាត់ការឆ្លងរីករាលដាលនៃជម្ងឺអេដស៍ ។ ប៉ុន្តែ សកម្មភាពទាំងនេះមិនសូវបានទទួលជោគជ័យប៉ុន្មានឡើយនៅក្នុងប្រទេសក្រីក្រផ្សេងៗ ដូចជាប្រទេសកម្ពុជា ដែលជាប្រទេសមានតម្លៃពលកម្មថោកជាងគេបង្អស់នៅក្នុងតំបន់ ។

រីឯបញ្ហាការបែងចែករវាងភេទប្រុសនិងស្រី ការរីកដុះដាលនៃឧស្សាហកម្មធុនស្រាលផ្សេងៗ ដូចជាឧស្សាហកម្មវាយនភណ្ឌ និងអេឡិចត្រូនិក ជាដើម បានបង្កើតឲ្យមាននូវតម្រូវការកម្មករស្ត្រីជាច្រើន ។ គេច្រើនជឿថា ស្ត្រីមានអាកប្បកិរិយារហ័សរហួន ប៉ិនប្រសប់ និងស្លូតបូត ហើយថែមទាំងត្រូវការប្រាក់ឈ្នួលថោកជាងបុរសផងដែរ ។ ដូចគ្នាទៅនឹងស្ត្រីនាដើមសម័យបដិវត្តន៍ឧស្សាហកម្មនៅឯបស្ចិមប្រទេសផងដែរ កម្មកររោងចក្រជាស្ត្រីនៅតាមបណ្តាប្រទេសអាស៊ីអាគ្នេយ៍ជាទូទៅ អាចត្រូវបានគេមើលឃើញថា ជាទាសករដោចថ្ងៃក្នុងរបបមូលធននិយម ។ ពួកគេត្រូវបានបង្ខំឲ្យធ្វើការធ្ងន់ «យ៉ាងអមនុស្សធម៌» ក្នុងរយៈពេលយូរនៅក្រោមស្ថានការណ៍ភិតភ័យនិងតឹងតែងលំបាក ។ ពួកគេទាំងនេះអាចទទួលរងនូវការកេងប្រវ័ញ្ចផ្លូវភេទ ពីសំណាក់ថៅកែផង ហើយពួកគេក៏ជាអ្នកផ្តល់ប្រសិទ្ធភាពដល់ដំណើរការអាជីវកម្មដែរ ។ ដោយសារការរីកចម្រើននៃឧស្សាហកម្ម យើងឃើញថា ស្ត្រីដែលទទួលការអប់រំតិចតួច ដូចជាកូនស្រីនៃគ្រួសារកសិករក្រីក្រទាំងឡាយ អាចមានឱកាសធ្វើការងារយកកម្រៃ ។ ទោះបីជាទទួលបានប្រាក់ឈ្នួលបន្តិចបន្តួចក៏ដោយ ក៏ពួកគេអាចមានភាពម្ចាស់ការលើខ្លួនឯងនៅក្នុងសង្គម និងអាចជួយផ្គត់ផ្គង់ជាថវិកានិងសម្ភារៈប្រើប្រាស់ថ្មីៗ ដល់ឪពុកម្តាយក្នុងវង្វង់ភូមិស្រុករបស់ពួកគេដែរ ។ ការសិក្សាស្រាវជ្រាវមួយនៅឆ្នាំ ១៩៨៧ អំពីកម្មការិនីនៅក្នុងប្រទេសម៉ាឡេស៊ីដោយ អៃហ៍វ៉ា អុង (Aihwa Ong) បានបង្ហាញពីកម្មការិនីដែលតទល់ប្រឆាំងទៅនឹងវិន័យតឹងរ៉ឹងរបស់រោងចក្រ ដោយការប្រើនូវកលល្បិចបុរាណមួយចំនួនដូចជារោគខ្យល់គ រោគសរសៃប្រសាទ និងខ្មោចលងជាដើម ។ នៅតាមតំបន់ជនបទដែលសេដ្ឋកិច្ចមានសភាពយ៉ាប់យ៉ឺនខ្លាំង ស្ថានភាពរបស់ស្ត្រីក្រីក្រ មានលក្ខណៈកាន់តែលំបាកឡើងៗ នៅក្នុងកាលៈទេសៈនៃទំនើបនីយកម្មកសិកម្ម ។ ជាឧទាហរណ៍ នៅក្នុងឧបទ្វីបម៉ាឡេស៊ី និងកោះជ្វា នៅពេលដែលគេប្រើប្រាស់ម៉ាស៊ីនដើម្បីជំនួសឲ្យការច្រូតកាត់ដោយដៃ ស្ត្រីក្រីក្រទាំងឡាយដែលធ្លាប់តែប្រកបរបរចិញ្ចឹមជីវិតដោយសារការជួយច្រូតកាត់ឲ្យកសិករដទៃទៀតយកកម្រៃ មិនមានលទ្ធភាពក្នុងការទទួលបាននូវថវិកាពីមុខរបរចិញ្ចឹមជីវិតរបៀបនេះទៀតទេ ។

ចំពោះជនជាតិអាស៊ីអាគ្នេយ៍មួយចំនួន ការគំរាមកំហែងដ៏ខ្លាំងក្លាបំផុតពីយុគសម័យទំនើប មានលក្ខណៈស្មុគ

ស្មាញនិងខ្លាំងជាងអំពើពុករលួយ ថ្នាំញៀន ពេស្យាកម្ម ឬក៏សូម្បីតែភាពក្រីក្រទៅទៀត ។ ការគំរាមកំហែងនេះ គឺជាការបាត់បង់នូវអត្តសញ្ញាណវប្បធម៌ក្រោមលំហូរនៃផលិតកម្មសាកលភាវូបនីយកម្មដែលផ្សាយចេញពីហូលីវូដ ម៉ាឌីសុនអាវ៉ឺនុយ (Madison Avenue) និងប៉ុស្តិ៍ទូរទស្សន៍ ស៊ីអិនអិន (CNN) និង អិមធីវី (MTV) ។ អ្នករិះគន់មួយរូប ដែលធ្លាប់បានរិះគន់អំពីឥទ្ធិពលរបស់សហរដ្ឋអាមេរិកនៅក្នុងទ្វីបអឺរ៉ុប បានហៅករណីនេះថា «អាណានិគមនីយកម្មកូកា (Coca-colonization)» តែការគំរាមកំហែងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍មិនមែនបណ្តាលមកពីឥទ្ធិពលរបស់សហរដ្ឋអាមេរិកតែមួយក៏ដោយ ។ ទម្រង់ក្មេងអង់គ្លេសទំនើបរបស់ស្ប៉ាយស៍ហ្គើលស៍ (Spice Girls) និន្តេណ្ដូហ្គេមបូយ (Nintendo Game Boy) មកពីជប៉ុន និងភាពយន្តគុងហ្វូមកពីទីក្រុងហុងកុង បានជះឥទ្ធិពលប្រហាក់ប្រហែលគ្នាទៅលើទម្រង់សិល្បៈនិងប្រពៃណីក្នុងតំបន់ ។ សូម្បីតែម្ហូបអាហារប្រចាំជាតិសាសន៍ក៏ទំនងជាស្ថិតនៅក្នុងស្ថានការណ៍គ្រោះថ្នាក់ផងដែរ ដោយសារតែមានអាជីវកម្មទិញសិទ្ធិលក់អាហារទាន់ចិត្តមួយចំនួន ដូចជាមាន់ចៀនកិន្តឹគី (Kentucky Fried Chicken) ជាដើម ។ រីឯហេមប៊ឺហ្គើរ (Hamburger) អន្តរជាតិវិញ បានក្លាយជាអាហារក្នុងស្រុករបស់ប្រទេសហ្វីលីពីន ដោយសារហេមប៊ឺហ្គើរម៉ាកចូលីប៊ី (Jollibee) របស់ហ្វីលីពីន មានរសជាតិផ្អែមតែមួយគត់ដែលទទួលការចាប់ចិត្តពីជនជាតិហ្វីលីពីន បានធ្វើឲ្យម៉ាកនេះលក់ដាច់ជាងម៉ាក់ដូណាល់ដ៍ (McDonald) ។ ជួនកាល មានទាំងការគំរាមកំហែងផ្នែកវប្បធម៌ពីប្រទេសជិតខាងខ្លួនបង្កើយ ដូចជាករណីប្រទេសឡាវ ។ ជនជាតិឡាវចាប់អារម្មណ៍ថា ពួកគេបានទទួលរងនូវឥទ្ធិពលពីតន្ត្រី ភាពយន្ត ទំនិញ និងសូម្បីតែភាសារបស់ប្រទេសថៃយ៉ាងសម្បើម ។ ទោះបីជាជម្រើសរបស់អ្នកប្រើប្រាស់ក៏បានឯកភាពចំពោះការរាតត្បាតទាំងនេះ ហើយជនជាតិអាស៊ីអាគ្នេយ៍មួយចំនួនយល់ច្បាស់ថា ខ្លួនបានទទួលនូវឥទ្ធិពលពីបណ្ដាប្រទេសផ្សេងៗ នៅតែស្វាគមន៍នូវការបាក់ធ្លាយនៃរបងជាតិ ។ ប៉ុន្តែ មានមនុស្សជាច្រើនមានការសោកស្ដាយចំពោះការបាត់បង់ដ៏ធំធេងនៃអ្វីដែលមានភាពរួមតែមួយ និងមានតម្លៃមិនអាចកាត់ថ្លៃបាន ដូចជា ភាសា ទំនៀមទម្លាប់ សិល្បៈ ម្ហូបអាហារ ឬគុណតម្លៃគ្រួសារតាមបែបប្រពៃណីផងដែរ ។

ការធ្វើអន្តោប្រវេសន៍ដ៏ធំគួរឲ្យចាប់អារម្មណ៍នៅក្នុងតំបន់ បានធ្វើឲ្យស្ថានការណ៍កាន់តែស្មុគស្មាញឡើង ។ នៅក្នុងសម័យក្រោយសង្គ្រាម ជាពិសេសចាប់ពីទសវត្សរ៍ឆ្នាំ ១៩៧០ មក ប្រជាជនអាស៊ីអាគ្នេយ៍ជាច្រើនបានចាកចេញពីប្រទេសរបស់ខ្លួនក្នុងលក្ខណៈជាជនភៀសខ្លួននយោបាយ ជនអន្តោប្រវេសន៍សេដ្ឋកិច្ច ឬជានិស្សិត ។ អ្នកខ្លះបានចាកចេញតែប៉ុន្មានគីឡូម៉ែត្រផុតពីព្រំដែនប៉ុណ្ណោះ ដូចជាជនជាតិខ្មែរនិងជនជាតិភាគតិចមកពីប្រទេសភូមានិងឡាវ ដែលបានជម្លៀសខ្លួនទៅកាន់ប្រទេសថៃ និងរួមទាំងជនជាតិម៉ាឡេស៊ី និងឥណ្ឌូនេស៊ីដែលធ្វើការនៅក្នុងប្រទេសសិង្ហបុរីជាដើម ។ ប៉ុន្តែ ភាគច្រើនបានចាកចេញពីអាស៊ីអាគ្នេយ៍ទាំងស្រុង ក្នុងលក្ខណៈជាកម្មករដាច់កិច្ចសន្យាបរទេស ទៅកាន់មជ្ឈិមបូព៌ា អឺរ៉ុបខាងកើត និងអាស៊ីខាងកើត ឬក្នុងលក្ខណៈជាជនអន្តោប្រវេសន៍ ឬជានិស្សិត ទៅកាន់អាមេរិកខាងជើង អឺរ៉ុប ឬក៏អូស្ត្រាលី ។ មកទល់នឹងចុងសហសវត្សរ៍ទី ២ ពួកគេភាគច្រើនបានត្រឡប់មកកាន់ប្រទេសកំណើតរបស់ខ្លួនវិញ ឬយ៉ាងហោចណាស់ ក៏បានផ្ញើប្រាក់មកវិញដែរ ។ នៅក្នុងប្រទេសហ្វីលីពីននាទសវត្សរ៍ឆ្នាំ ១៩៩០ ប្រាក់ដែលបានផ្ញើមកពីខាងក្រៅប្រទេស បានក្លាយជាប្រភពដ៏ធំតែមួយគត់នៃរូបិយប័ណ្ណ ដោយបានលើសផលចំណេញនៃឧស្សាហកម្មទាំងទម្រង់ចាស់និងថ្មី ។ ចំពោះប្រទេសផ្សេងៗទៀត ចំនួនទាំងអស់នេះមិនសូវមានលក្ខណៈគួរឲ្យកត់សម្គាល់ប៉ុន្មានទេ ។ ប៉ុន្តែ ទាំងប្រាក់ដែលផ្ញើមកពីបរទេស

និងអ្នកធ្វើមាតុភូមិនិវត្តន៍ មានលក្ខណៈភៀវក្លាគួរឲ្យរំពឹងទុក ។

## ការបំផ្លិចបំផ្លាញបរិស្ថានធម្មជាតិ

ផ្នែកខាងងងឹតពិតប្រាកដនៃឧស្សាហូបនីយកម្មនិងនគរូបនីយកម្មអាស៊ីអាគ្នេយ៍ គឺជាផ្សែងអ័ព្ទថប់ដង្ហើមដែលជារឿយៗ បានបង្ខំឲ្យអ្នករស់នៅក្នុងទីក្រុងបាងកក ទីក្រុងម៉ានីល និងទីក្រុងហ្សាការតា ពាក់ម៉ាស់ការពារផ្ទៃមុខ នៅពេលដែលពួកគេធ្វើដំណើរនៅតាមដងផ្លូវក្នុងទីក្រុង ។ ហើយមានទាំងទឹកបំពុល ដែលអាចសម្លាប់ជីវិតមនុស្សសត្វបាន នៅក្នុងទន្លេបឹងបួនិងបឹងទឹកប្រៃក្បែរមាត់សមុទ្រ ។ ទាំងអស់នេះ គឺជាការសម្តែងឲ្យឃើញយ៉ាងជាក់ច្បាស់នូវគ្រោះមហន្តរាយអេកូឡូស៊ី ដែលរួមមានទាំងការបាត់បង់នូវគម្របព្រៃឈើនិងផ្កាថ្មប៉ប្រះទឹកប្រហែល ៨០% ។ នៅពេលដែលសតវត្សរ៍ទី ២១ បានឈានចូលមកដល់ សញ្ញាណអស់ទាំងនេះមិនសូវមានការធ្លាក់ចុះប៉ុន្មានឡើយ ។ ជាក់ស្តែងជាងនេះទៅទៀត ការបំផ្លិតបំផ្លាញនេះ គឺជាកំណើនសេដ្ឋកិច្ចនិងកំណើនប្រជាជនដែលជាទូទៅកើនឡើងក្នុងពេលជាមួយគ្នា ក្នុងនេះ បានន័យថា មានទ្រព្យធនកាន់តែច្រើន បង្កឲ្យមានការប្រើប្រាស់រថយន្តកាន់តែច្រើន ។ ទាំងនេះ បណ្តាលឲ្យមានផ្សែងអ័ព្ទកាន់តែច្រើន ។ ប្រជាជនកាន់តែច្រើន មានន័យថា មានប្រជាកសិករកាន់តែច្រើន ដែលបណ្តាលឲ្យមានការកាប់បំផ្លាញព្រៃឈើកាន់តែច្រើនផងដែរ ។ បញ្ហាមួយទៀតដូចជា ភ្លើងឆេះព្រៃដ៏ធំដែលបានរាតត្បាតប្រទេសឥណ្ឌូនេស៊ីនិងម៉ាឡេស៊ី នៅក្នុងឆ្នាំ ១៩៩៤ និង ១៩៩៧ បានធ្វើឲ្យពពកផ្សែងផេះ ហោះឆ្ងាយឆ្ពោះទៅកាន់ទីក្រុងហុងកុងស្ថិតនៅភាគខាងជើង ហើយបញ្ហានេះត្រូវបានគេរិះគន់ថា មួយផ្នែកបណ្តាលមកពីបាតុភូតធម្មជាតិ«អេល នីញ៉ូ» (El Niño) ។

ប៉ុន្តែ អ្នកដែលបានលើកនូវទឡ្ហីករណ៍ទាំងនេះឡើង គឺជាអ្នកនិយាយដោះសាចំពោះមហិច្ឆតាមិនចេះចប់ដែលមានទំនួលខុសត្រូវចំពោះបញ្ហាជាច្រើន ។ កំហុសចម្បងបំផុតនៅក្នុងការកាប់បំផ្លាញព្រៃឈើនៅក្នុងតំបន់ គឺមិនមែនមកពីការកាប់ និងដុតបំផ្លាញព្រៃឈើ ដើម្បីយកដីមកធ្វើកសិកម្មនោះទេ ប៉ុន្តែ គឺជាពាណិជ្ជកម្មដ៏លោភលន់ ដែលបានការអនុញ្ញាតដោយស្របច្បាប់ពីរដ្ឋាភិបាល ឬជាការទាញយកផលប្រយោជន៍ដោយខុសច្បាប់របស់មន្ត្រីពុករលួយ ឬមន្ត្រីគប់គិតគ្នាទៅវិញទេ ។ ជាឧទាហរណ៍ ទាហានថៃមិនត្រឹមតែជាប់ពាក់ព័ន្ធជាមួយនឹងការកាប់បំផ្លាញព្រៃធម្មជាតិរបស់ប្រទេសថៃនោះទេ ប៉ុន្តែក៏ជាអ្នកផ្តើមគំនិតនិងអ្នកគាំទ្រដ៏ចម្បងនៅក្នុងការបំផ្លាញព្រៃឈើនៅក្នុងប្រទេសភូមា លាវ និងកម្ពុជា ក្នុងពេលដែលប្រទេសទាំងនេះបានបើកច្រកទ្វារព្រំដែនរបស់ខ្លួន ។ ប្រទេសទាំងនេះបានកាប់ព្រៃឈើរបស់ខ្លួន លឿនជាងប្រទេសថៃផ្ទាល់បានធ្វើទៅទៀត ។ ដូចនៅក្នុងប្រទេសឥណ្ឌូនេស៊ីដែរ ទាហានគឺជាអ្នកឧបត្ថម្ភគាំទ្រដ៏ចម្បងនៅក្នុងការកាប់បំផ្លាញព្រៃឈើ ។ ចំណែកឯក្រុមហ៊ុនផលិតក្តារបន្ទះនៅក្នុងប្រទេសហ្វីលីពីន បែរជាមានទំនោរទៅរកការជួលទាហានជាលក្ខណៈឯកជនវិញ ។ ដើម្បីធ្វើដូច្នេះបាន ប្រទេសទាំងអស់នេះបានលក់ផ្តាច់នូវកេរដំណែលវប្បធម៌របស់ខ្លួន ដើម្បីជាថ្នូរនឹងប្រាក់កម្រៃបន្តិចបន្តួចប៉ុណ្ណោះទេ វាថែមទាំងបានធ្វើឲ្យសេដ្ឋកិច្ចជាតិខ្លួនចុះខ្សោយ ដោយសារថា ការបាត់បង់នូវគម្របព្រៃឈើ គឺជាកត្តាចម្បងដែលបណ្តាលឲ្យមាននូវគ្រោះមហន្តរាយទឹកជំនន់ បំផ្លិចបំផ្លាញនូវផលដំណាំ និងសម្លាប់ជីវិតអស់ជាច្រើនទៀត ។

រដ្ឋាភិបាលនៃបណ្តាប្រទេសអាស៊ីអាគ្នេយ៍ ក៏គ្មានលទ្ធភាព ឬក៏គ្មានឆន្ទៈការពារទប់ទល់ទៅនឹងការបំពុល

ទឹកតាមរយៈសាជីវកម្មរ៉ែ ឬរោងចក្រឧស្សាហកម្មផ្សេងៗ ដោយសារតែមានការភ័យខ្លាចថា សកម្មភាពនេះអាចរារាំងកំណើនសេដ្ឋកិច្ច ឬក៏អាចបង្កើតឲ្យមានសត្រូវផ្នែកនយោបាយទៅវិញ ។ ឧទាហរណ៍ជាក់ស្តែងមួយគឺថា ក្រុមហ៊ុនកាវ៉ាសាគី (Kawasaki) បានផ្ទេររោងចក្រស្ងួរំលាយដែកថែបពីប្រទេសជប៉ុន ទៅកាន់ប្រទេសហ្វីលីពីន ដោយសារតែមានការតវ៉ាយ៉ាងខ្លាំងពីសំណាក់បរិស្ថានវិទូផ្សេងៗ នៅប្រទេសជប៉ុន ។ ករណីនេះបានធ្វើឲ្យក្រុមហ៊ុន កាវ៉ាសាគីបានក្លាយទៅជាអ្នកនាំឲ្យមានការបំពុលនៅក្នុងប្រទេសហ្វីលីពីន ។ ទន្លេបឹងបួនានាក៏ត្រូវបានបំពុលដោយសារការប្រើប្រាស់ជីគីមីហួសកម្រិត ដើម្បីបង្កើនទិន្នផលស្រូវ ។ មហាសមុទ្រនានាបានក្លាយទៅជាវាលរហោដ្ឋានគ្មានត្រី តែពោរពេញទៅដោយនាវាអូសចៃវ៉ាជប៉ុនធំៗ ជាច្រើន សម្រាប់កើបយកនិន្នផលចម្ងាយរាប់គីឡូម៉ែត្រ ។ ចំណែកឯតំបន់ក្បែរឆ្នេរសមុទ្រវិញ គេឃើញអ្នកនេសាទក្រីក្រក្នុងស្រុក បានប្រើប្រាស់នូវរំសេវផ្ទុះ ឬថ្នាំបំពុល ដើម្បីទទួលបាននូវទិន្នផលត្រីដែលកាន់តែតិចចុះ ដោយមិនគិតទៅដល់ឥទ្ធិពលរបស់រំសេវផ្ទុះនិងថ្នាំបំពុលទាំងនោះ ចំពោះជីវិតសត្វរុក្ខជាតិនៅក្នុងសមុទ្រនិងផ្កាថ្មប៉ប្រះទឹកនោះទេ ។ ទំនប់ថាមពលវារីអគ្គិសនីដ៏ធំបានពន្លង់លំនៅនិងវប្បធម៌របស់ជនជាតិដើមភាគតិចផ្សេងៗ រួមទាំងអ្វីៗ ទាំងឡាយនៅក្នុងតំបន់នោះ ។ ជារឿយៗ ទំនប់ទាំងនេះរាំងស្ទះដល់ការពាំនាំមកនូវដីល្បាប់តាមរយៈខ្សែទឹក ហើយធ្វើឲ្យថយចុះនូវទិន្នផលកសិកម្មនៅតំបន់នោះទៅវិញ ។

អង្គការក្រៅរដ្ឋាភិបាលជាច្រើនបានងើបឡើងប្រឆាំងតវ៉ាទៅនឹងការប៉ះពាល់ចំពោះបរិស្ថានទាំងនោះ ការប៉ះពាល់ដល់វប្បធម៌ជនជាតិភាគតិច និងកម្មករ ។ មកទល់នឹងចុងសតវត្សរ៍ទី ២០ រដ្ឋាភិបាលភាគច្រើនបាននិយាយគាំទ្រតែមាត់ចំពោះគោលគំនិតនៃ «ការអភិវឌ្ឍប្រកបដោយចីរភាព» ប៉ុន្តែ មិនបានអនុវត្តសកម្មភាពអ្វីសោះក្នុងការគាំទ្រគោលគំនិតនេះ ។ ប្រហែលជាគេនឹងចងចាំពីសតវត្សរ៍បន្ទាប់ពីទសវត្សរ៍ឆ្នាំ ១៩៥០ ថា ជាសតវត្សរ៍ដែលមនុស្សជាតិបានបំផ្លាញបរិស្ថានធម្មជាតិ ជាជាងសតវត្សរ៍ដែលប្រទេសជាច្រើនទទួលបានឯករាជ្យ និងមាន «អព្ភូតហេតុសេដ្ឋកិច្ច» ។

## ដំណោះស្រាយជាមួយនឹងភាពចំណើប ៖ នវិយាបថនិងការវិភាគ

ប្រជាជនអាស៊ីអាគ្នេយ៍ទាំងឡាយបាននិយាយជាចំហអំពីបញ្ហាផ្សេងៗ ដែលពួកគេបានជួបប្រទះ ទោះជាគេត្រូវប្រយ័ត្ននឹងរបបនយោបាយរបស់ពួកគេ ។ ពួកគេមិនត្រូវការឲ្យមនុស្សខាងក្រៅមកជួយចង្អុលបង្ហាញនូវបាបធម៌នៃគ្រឿងញៀននិងអំពើពុករលួយ ឬក៏គុណធម៌នៃប្រជាធិបតេយ្យ និងការបន្ថយកំណើនប្រជាជន ។ បញ្ហាអស់ទាំងនេះដែលលើកមកវិភាគ បញ្ញវន្តអាស៊ីអាគ្នេយ៍ដែលពោរពេញទៅដោយសេចក្តីអង់អាចនិងវោហារសាស្ត្រល្អៗ បានរៀបរាប់អស់ទៅហើយដែរ ។

តាមរយៈការអប់រំ ការងារ ការធ្វើដំណើរ និងការពង្រីកនូវប្រព័ន្ធទំនាក់ទំនង ប្រជាជនអាស៊ីអាគ្នេយ៍ភាគច្រើន ជាពិសេសពួកវរជនជំនាន់ថ្មី បានយល់កាន់តែប្រសើរជាងមុននូវអ្វីដែលបានកើតឡើងនៅពាសពេញពិភពលោក ហើយខឹងនឹងការប៉ុនប៉ងបំបិទព័ត៌មានផ្សេងៗ ។ ការចាប់ពិរុទ្ធមាននៅគ្រប់កន្លែងទាំងអស់ មានតាំងពីការបដិសេធជាសាមញ្ញរបស់អាជីវករចំពោះការផ្សព្វផ្សាយនៅក្នុងទំព័រសារព័ត៌មានទាំងឡាយដែលប៉ះពាល់ដល់ពួកគេ រហូតដល់បម្រាមផ្សាយរាល់សៀវភៅនិងខ្សែភាពយន្តទាំងឡាយដែលអាចបង្កឲ្យមានបញ្ហា ឬសូម្បី

តែការចាប់អ្នកនិពន្ធទាំងឡាយណាដែលរិះគន់រដ្ឋាភិបាលទៅដាក់ពន្ធនាគារ ។ (គេក៏ឃើញមានរូបភាពតក់ស្លុតផ្សេងៗ នៃអំពើឃាតកម្មទៅលើអ្នកសារព័ត៌មានស៊ើបអង្កេតផងដែរ ។) វរជនជំនាន់ថ្មីបានជឿជាក់ថា មនុស្សមានសិទ្ធិដឹងអំពីអ្វីដែលកំពុងកើតមានឡើង ។ ពួកគេមានលទ្ធភាពកាន់តែប្រសើរឡើង ដោយសារការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ ។ ជាឧទាហរណ៍ ប្រព័ន្ធផ្សព្វផ្សាយបរទេសនានាបានចាក់ផ្សាយអំពីឃាតកម្មបែបនយោបាយទៅលើរូបលោក នីណូយ អាគីណូ (Ninoy Aquino) នៅក្នុងឆ្នាំ ១៩៨២ តាមរយៈខ្សែអាត់វីដេអូបេតាម៉ាក្ស ឲ្យប្រជាជនហ្វីលីពីនរាប់លាននាក់បានឃើញ ។ ឧទាហរណ៍មួយទៀត នៅក្នុងឆ្នាំ ២០០១ ជនជាតិហ្វីលីពីនវណ្ណៈកណ្តាលបានសម្របសម្រួលការផ្សព្វផ្សាយអំពីការធ្វើបដិវត្តន៍ «អំណាចប្រជាជន» តាមរយៈការផ្ញើសារតាមទូរស័ព្ទចល័តរបស់ពួកគេនៅក្នុងទីក្រុងម៉ានីល ។ ជារឿយៗ មនុស្សទូទៅអាចប្រើប្រាស់ប្រព័ន្ធអាំងទែរណែតបាននៅតាមហាងកាហ្វេ ដើម្បីបញ្ជូនចែកចាយនូវរាល់ព័ត៌មានផ្សេងៗជាច្រើន ដែលមិនងាយនឹងទប់ស្កាត់បាន ទោះបីជាមានរបបគ្រប់គ្រងមួយចំនួន ជាពិសេសនៅក្នុងប្រទេសវៀតណាមនិងសិង្ហបុរី ហាមឃាត់មិនឲ្យប្រើប្រាស់ទំព័រអាំងទែរណែតមួយចំនួនក៏ដោយ ។

ប្រជាជនអាស៊ីអាគ្នេយ៍ភាគច្រើន មិនត្រឹមតែមានចំណេះដឹងអំពីពិភពលោកបានទូលំទូលាយជាងមុនប៉ុណ្ណោះទេ ពួកគេថែមទាំងមានអារម្មណ៍ថា គេគួរតែមានសិទ្ធិបញ្ចេញមតិអំពីចំណេះដឹងរបស់ពួកគេទៀតផង ។ ទោះបីជាវណ្ណៈថ្នាក់កណ្តាល គឺជាស្នូលនៃចលនាប្រជាធិបតេយ្យនៅក្នុងប្រទេសហ្វីលីពីន ប្រទេសថៃ និងប្រទេសផ្សេងៗទៀតក៏ដោយ ក៏យើងអាចយល់ខុស បើសិនយើងគិតថា សមាជិកទាំងអស់នៃវណ្ណៈថ្នាក់កណ្តាលនេះធ្វើជាអ្នកប្រជាធិបតេយ្យថ្មីថ្មោង ឬក៏ជាអ្នកបដិវត្តនោះ ។ ពួកវណ្ណៈថ្នាក់កណ្តាលភាគច្រើន បានរស់នៅយ៉ាងសប្បាយជាមួយនឹងបែបបទជីវិតដ៏សុខដុមនៅក្រោមរបបអភិរក្សនិយម ហើយមិនចង់គ្រោះថ្នាក់ឡើយ ។ ជួនកាល ពួកគេក៏អាចគាំទ្រវិធានការគាបសង្កត់ចំពោះពួកវណ្ណៈក្រោមៗ ដែលរុករានសេចក្តីសុខរបស់ពួកគេក៏ដោយ ។ ប៉ុន្តែការគាំទ្ររបស់ពួកវណ្ណៈថ្នាក់កណ្តាលទាំងនេះ ចំពោះមេដឹកនាំពួកគេរៀងៗខ្លួន គឺដោយសារតែមេដឹកនាំនោះរក្សាបាននូវនិរន្តរភាពរុងរឿងនៃសេដ្ឋកិច្ច វាមិនមែនជាការគោរពមេដឹកនាំរបស់ពួកគេយ៉ាងជ្រាលជ្រៅជាងមុននោះទេ ។ ហើយនៅពេលមេដឹកនាំ មិនអាចបំពេញភារកិច្ចដូចនេះបាន ដូចករណីរបស់ប្រទេសហ្វីលីពីនបន្ទាប់ពីឆ្នាំ ១៩៨២ ឬប្រទេសឥណ្ឌូនេស៊ីបន្ទាប់ពីឆ្នាំ ១៩៩៧ ពួកវរជនបានបញ្ជាក់យ៉ាងច្បាស់ថា ពួកគេចង់ឲ្យមានការផ្លាស់ប្តូរ ទោះបីជាតាមរយៈការបោះឆ្នោត វេទិកាសាធារណៈ តាមរយៈសេចក្តីប្រកាសជាសាធារណៈ ឬក៏តាមរយៈការដកចេញនូវការវិនិយោគរបស់ពួកគេក៏ដោយ ។

ជាការពិតណាស់ ការរិះគន់យ៉ាងខ្លាំងចំពោះរបបដឹកនាំនានា គឺមិនមែនជារឿងថ្មីទេនៅក្នុងសម័យបច្ចុប្បន្ននេះ ។ ជារឿយៗ នៅក្នុងប្រទេសឯករាជនានា អ្នករិះគន់ទាំងនេះបានជួបប្រទះនូវការគាបសង្កត់ដ៏ឃោរឃៅប្រៀបដូចជាអ្វីដែលធ្លាប់បានកើតឡើងនៅក្នុងសម័យអាណានិគមដូច្នេះដែរ ។ ជួនកាល អ្នករិះគន់ទាំងនេះត្រូវបានគេចាប់ដាក់ពន្ធនាគារទៀតផង ។ មេដឹកនាំកាន់អំណាចរយៈពេលយូរ ដែលបានគ្រប់គ្រងផ្តាច់មុខនូវរាល់បណ្តាញព័ត៌មានភាគច្រើន មិនត្រឹមតែមានលទ្ធភាពក្នុងការធ្វើទុក្ខបុកម្នេញដល់អ្នករិះគន់ទាំងនោះទេ ប៉ុន្តែថែមទាំងកម្ចាត់ការចងចាំអំពីអ្នកទាំងនោះផងដែរ ។ ជាឧទាហរណ៍ នៅក្នុងប្រទេសថៃ ពួកមូលវិវដ្ត (មនុស្សដែលមានជំនឿដាច់ខាត) ដែលជានិស្សិតនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ បានរុករកឡើងវិញនូវអត្ថបទនិពន្ធដោយអ្នក

ប្រឆាំងសម័យមុនៗ ដែលមានចាប់ពីលោក ទៀនវណ្ណ ព្រះយ៉ាសុរិយានុវ័ត្រ និងនាយ ប្រីឌី ភ្នំយង្គ (Nai Pridi Phanomyong) រហូតដល់លោក ចិត្រ ភូមិសក្តិ (Jit Phumisak) **(ដូចជា «តើមនុស្សប៉ុន្មាននាក់សប្បាយហ៊ឺហា ដោយសារការកេងប្រវ័ញ្ច ពីការខិតខំប្រឹងប្រែងរបស់ពួកយើង ។ យើងជិះក្របី ពួកគេជិះខ្នងយើង»)** ។ សូម្បីតែនៅក្នុងប្រទេសហ្វីលីពីន ដែលប្រព័ន្ធផ្សព្វផ្សាយមានសេរីភាពទូលំទូលាយជាងគេនៅក្នុងតំបន់ក៏ដោយ ក៏លោក អន់ដ្រេស បូនីហ្វាស្យូ (Andres Bonifacio) ទើបតែបានទទួលងារជាមេដឹកនាំនៃការបះបោររបស់មហាជន ៥០ ឆ្នាំបន្ទាប់ពីមរណភាពរបស់គាត់នៅក្នុងឆ្នាំ ១៨៩៦ តែប៉ុណ្ណោះ ។

ទោះជាយ៉ាងនេះក្តី មកទល់នឹងចុងសតវត្សរ៍ទី ២០ ពិតជាមានការលំបាកជាងមុនក្នុងការរារាំងនូវការរិះគន់ចំពោះអ្វីដែលគេបានពុះ ផ្សព្វផ្សាយ និងចងចាំ ។ លើកលែងតែការរិះគន់ទាក់ទងនឹងសាសនានិងរាជាធិបតេយ្យចេញ (ទោះជាមានករណីផ្ទុយមួយចំនួន) ពុំមានប្រធានបទណាមួយដែលអាចផុតពីការរិះគន់ ÷ រដ្ឋាភិបាល សេដ្ឋកិច្ច អេកូឡូស៊ី វប្បធម៌ អំពើពុករលួយ ផ្លូវភេទ ទំនាក់ទំនងជនជាតិភាគតិច ។ល។ សង្គមខ្លះបានអនុញ្ញាតឲ្យមានការបញ្ចេញមតិជាសាធារណៈនិងដោយផ្ទាល់ ។ លោក រ៉េណាតូ កុងស្តង់ទីណូ (Retano Constantino) បានកសាងអាជីពជាអ្នកកាសែតអស់រយៈពេលជាយូរ ដោយបាននិពន្ធនូវអត្ថបទ «ចិត្តជាប់ឃុំរបស់យើង» (១៩៥៧) «ដំណើរអប់រំខុសរបស់ប្រជាជនហ្វីលីពីន» (១៩៦៦) តម្រូវការឲ្យមាន «ជម្រើសរបស់អ្នកជាតិនិយម» (១៩៧៩) និង «វប្បធម៌សំយោគ» (១៩៨៥) ដែលបានបង្កើតឡើងដោយសាកលភាវូបនីយកម្ម ។ ចំពោះប្រទេសផ្សេងទៀត ការរិះគន់ ធ្វើឡើងក្នុងភាពមិនផ្ទាល់ ជាពិសេសនៅក្នុងរដ្ឋផ្តាច់ការ ដូចជាប្រទេសវៀតណាម ជាដើម ។ គេបណ្តោយឲ្យមានសេរីភាពក្នុងរឿងប្រលោមលោកនិងខ្សែភាពយន្តច្រើនជាងក្នុងសុន្ទរកថាទាក់ទងនឹងបញ្ហានយោបាយជាសាធារណៈ ។ ចំណែកឯនៅក្នុងប្រទេសឥណ្ឌូនេស៊ីវិញ យូរៗម្តង ពាក្យរិះគន់ចំអកឡកឡឺយផ្សេងៗ បានលេចចេញមកពីមាត់របស់វ៉ាយ៉ាំង (អាយ៉ង) ក្នុងល្ខោនស្បែកតូច ។ ហើយគេតែងតែឃើញមាននូវពាក្យកំប្លែង ក៏ដូចជា ពាក្យចចាមអារ៉ាមដែលបង្កប់នូវរឿងអាថ៌កំបាំង បង្កើតឡើងដើម្បីប្រដែងជាមួយនឹងរឿងទេវកថាផ្លូវការផ្សេងៗ ។ នៅក្នុងប្រទេសឥណ្ឌូនេស៊ី គេបានហៅលោកស្រី តៀន ភរិយារបស់លោកស៊ូហារតូថា «លោកស្រីតៀនភាគរយ» ដោយសំដៅទៅលើចំណែកប្រាក់ដែលគេនិយាយថា លោកស្រីយកពីគ្រប់អ្នកវិនិយោគបរទេសទាំងអស់ ។ នៅពេលដែលជំនួយសប្បុរសសម្រាប់ជនរងគ្រោះទឹកជំនន់នៅក្នុងប្រទេសថៃ ឬប្រទេសហ្វីលីពីន មិនត្រូវបានចែកចាយដល់ជនរងគ្រោះទាំងអស់នោះ គេសន្មតជាទូទៅថា ជាលទ្ធផលនៃអំពើពុករលួយ ដោយមានតែពាក្យថា «ខ្ញុំឮគេនិយាយថា ...» ។

ក្រុមអ្នកបញ្ចេញមតិនេះ បានផ្តល់នូវដំណោះស្រាយជាច្រើនចំពោះរាល់បញ្ហា ដែលប្រទេសអាស៊ីអាគ្នេយ៍បានជួបប្រទះ ។ ដំណោះស្រាយខ្លះ មានលក្ខណៈជាដំណាក់ៗ និងជាក់លាក់ ដូចជា ត្រូវដកមន្ត្រីពុករលួយនេះត្រូវបញ្ឈប់ការកសាងទំនប់ទឹកនោះ ជាដើម ។ ដំណោះស្រាយខ្លះមានលក្ខណៈនឹកអាឡោះអាល័យនិងមិនសូវច្បាស់ ដូចជាសំណូមពរឲ្យកសាងនូវតម្លៃប្រពៃណី ឬឲ្យមានព្រះរាជាឡើងវិញ ដើម្បីដោះស្រាយបញ្ហារបស់យើងទាំងអស់ ។ (ជារឿយៗ គំនិតលើកឡើងបែបទស្សនវិជ្ជានៃ «តម្លៃអាស៊ី» មានការទាក់ទងជាមួយនឹងអ្នកគាំទ្ររបបផ្តាច់ការនិយមទាំងឡាយណាដែលខ្វះខ្វាចនូវ «លទ្ធិប្រជាធិបតេយ្យសេរី» ជាងអ្វីៗ ទាំងអស់ ។) ហើយដំណោះស្រាយខ្លះទៀត មានការទាក់ទងទៅនឹងលទ្ធិណាមួយ ដូចជាការចូលរួមជាមួយនឹងចលនាបដិវត្ត ដើម្បី

*ដឹកនាំមហាជនទូទៅ ឬពឹងពាក់និងទទួលយកទីផ្សារសេរី ហើយទទួលយកលទ្ធផលទាំងឡាយ ដែលបានផ្តល់ឲ្យ ជាដើម ។ ចំណែកឯដំណោះស្រាយខ្លះផ្សេងទៀត មានលក្ខណៈគ្រាន់តែជាទ្រឹស្តី ប៉ុន្តែមានខ្លះទៀត មានគោលបំណងឆ្ពោះទៅដល់ការអនុវត្តជាក់ស្តែងតែម្តង ។*

## ដំណោះស្រាយជាមួយនឹងភាពជំនើប៖ សកម្មភាព

*ប្រជាជនអាស៊ីអាគ្នេយ៍ទាំងឡាយណា ដែលតែងតែចង់ឲ្យមានការផ្លាស់ប្តូរនយោបាយ ច្រើនតែបានអនុវត្តតាមវិធីសាមញ្ញ ដោយការចូលរួមនៅក្នុងរាជការ គណបក្សកាន់អំណាច ឬដោយការចូលរួមនៅក្នុងកងទ័ព ដូចនៅក្នុងប្រទេសភូមា ឥណ្ឌូនេស៊ី និងថៃ ។ ប៉ុន្តែ ទោះបីជានៅពេលដែលស្ថាប័នទាំងនេះបានជ្រើសរើសសមាជិកយ៉ាងច្រើនក៏ដោយ ក៏ជារឿយៗ គេបានរក្សាទុកតំណែងខ្ពស់ៗ សម្រាប់អ្នកណាដែលមានខ្សែរយៈគ្រួសារ ដូចជាលោកឧបនាយករដ្ឋមន្ត្រីសិង្ហបុរី លី សៀនឡុង* (Lee Hsien Loong) *កូនប្រុសរបស់លោក លី ក្វាន់ យូ* (Lee Kuan Yew) *ឬក៏ប្រធានាធិបតីហ្វីលីពីន គ្លារីយ៉ា ម៉ាកាប៉ាហ្គាល់ អារ៉ូយ៉ូ* (Gloria Macapagal Arroyo) *កូនស្រីរបស់អតីតប្រធានាធិបតី ឌីអូសដាដូ ម៉ាកាប៉ាហ្គាល់* (Diosdado Macapagal) *ជាដើម ។ ចំណុចខ្សោយមួយផ្សេងទៀតចំពោះបញ្ហានេះ គឺថា ទោះបីជាវាអាចនាំឲ្យមានការរីកចម្រើនផ្ទាល់ខ្លួន ឬក៏កំណែទម្រង់បន្តិចបន្តួចក៏ដោយ ក៏វាទំនងជាមិនបង្កើតឲ្យមានការផ្លាស់ប្តូររចនាសម្ព័ន្ធនោះទេ ។*

*«ចលនាប្រជាធិបតេយ្យ» នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (ក៏ដូចជានៅក្នុងប្រទេសចិនដែរ) តំណាងឲ្យមធ្យោបាយមួយផ្សេងទៀត ដែលបានទទួលជោគជ័យយ៉ាងប្រាកដក្នុងការផ្តួលរំលំរបបនយោបាយនៅក្នុងប្រទេសថៃនិងប្រទេសហ្វីលីពីន ហើយក៏បានគំរាមកំហែងដល់របបអស់ទាំងនេះនៅក្នុងប្រទេសភូមា ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី ។ ចំពោះពាក្យថា «ប្រជាធិបតេយ្យ» អ្នកតស៊ូមតិ មិនឲ្យនិយមន័យថា «មនុស្សម្នាក់សំឡេងឆ្នោតមួយសន្លឹក» នោះទេ ប៉ុន្តែគឺជាការប្រមូលផ្តុំនូវទស្សនៈផ្សេងៗ ដូចជា សិទ្ធិមនុស្សដ៏ប្រសើរ (ជាពិសេសគឺសេរីភាពនៃការបញ្ចេញមតិសេរីភាព នៃការប្រជុំ និងសេរីភាពនៃប្រព័ន្ធផ្សព្វផ្សាយ) ការគាំទ្រកាន់តែច្រើនចំពោះមតិសាធារណៈ និងការបញ្ចប់នូវអំពើពុករលួយ ជាដើម ។ ចលនាទាំងនេះបានអនុវត្តនូវទម្រង់ផ្សេងៗគ្នានៅក្នុងប្រទេសនីមួយៗ ប៉ុន្តែទាំងអស់បានព្យាយាមឈ្វេងយល់ថា ប្រជាពលរដ្ឋសាមញ្ញមានសិទ្ធិក្នុងការបញ្ចេញមតិអំពីបញ្ហារបស់រដ្ឋ ហើយអ្នកកាន់អំណាចទាំងអស់ត្រូវតែស្តាប់នូវមតិយោបល់ទាំងអស់នេះ ។*

*មធ្យោបាយទី ៣ គឺរំលងរដ្ឋាភិបាលហើយនិងរៀបចំប្រជាជន ដើម្បីតស៊ូដណ្តើមយុត្តិធម៌ដោយផ្ទាល់ ។ នៅក្នុងដំណាក់កាលទី ៣ ចុងក្រោយនៃសតវត្សរ៍ទី ២០ មានអង្គការក្រៅរដ្ឋាភិបាលរាប់រយនៅក្នុងតំបន់ ក៏ដូចជានៅក្នុងទូទាំងពិភពលោកទាំងមូលផងដែរ ។ ជារឿយៗ អង្គការទាំងនេះបានលើកឡើងនូវបញ្ហាផ្សេងៗ ដែលរដ្ឋាភិបាលមានការខ្វះខាតក្នុងការអនុវត្ត ដូចជា កំណែទម្រង់វិស័យកសិកម្ម សុវត្ថិភាពរបស់កម្មករ សិទ្ធិសេរីភាពរបស់ស្ត្រី សិទ្ធិរបស់ជនជាតិភាគតិច និងបញ្ហាបរិស្ថាន ជាដើម ។ ស្ត្រីជាច្រើនដែលជារឿយៗ ត្រូវបានគេរើសអើងមិនឲ្យចូលរួមក្នុងផ្នែកនយោបាយនោះ បានក្លាយជាបេក្ខនារីតំណាងឲ្យក្រុមមនុស្សដ៏ច្រើន ដែលស្ត្រីខ្លះបានអះអាងថា នឹងដឹកនាំដោយផ្តោតទៅលើប្រជាពលរដ្ឋជាធំ និងដោយលើកដំណោះស្រាយបញ្ហាសង្គមនិងសេដ្ឋកិច្ចជាងអ្វីដែលរដ្ឋាភិបាលបានផ្តល់ឲ្យ ។*

អង្គការក្រៅរដ្ឋាភិបាលបានបង្កើតឡើងក្នុងទម្រង់និងទំហំផ្សេងៗគ្នា ។ អង្គការក្រៅរដ្ឋាភិបាលខ្លះអាចប្រមូលបានអ្នកគាំទ្រចំពោះគោលបំណងរបស់ខ្លួនបានរាប់ម៉ឺននាក់ ដែលផ្ទុយនឹងអង្គការខ្លះ មានតែអ្នកមានទស្សនៈជឿនលឿនប្រូនដប់នាក់រួមនឹងម៉ាស៊ីនអង្គុលីលេខ និងមនោគតិសកម្មមួយចំនួនប៉ុណ្ណោះ ។ អង្គការខ្លះទៀត ដូចជា សាខារបស់អង្គការអុកស៍ហ្វាម (Oxfarm) ហ្គ្រីនភីស (Greenpeace) និង ហ្វ្រែន អហ្វ ឌឹ អឺថ (Friends of the Earth) គឺជាសាខារបស់ចលនាពិភពលោក ដែលផ្ទុយពីអង្គការខ្លះទៀត គឺជាអង្គការក្នុងស្រុកផ្ទាល់ ។ គេបានបង្កើតឡើងនូវវេទិកានៃអង្គការក្រៅរដ្ឋាភិបាលស្តីពីកម្ពុជា (The NGO Forum on Cambodia) នៅឯបរទេសក្នុងឆ្នាំ ១៩៨៦ ប៉ុន្តែបានមកតាំងទីនៅក្នុងទីក្រុងភ្នំពេញនៅឆ្នាំ ១៩៩៤ ហើយមកទល់នឹងឆ្នាំ ២០០២ អង្គការនេះបានកែប្រែ «របៀបវារៈដើម្បីការតស៊ូមតិ» របស់ខ្លួន ពីបញ្ហាអន្តរជាតិមកបញ្ហាជាតិវិញ ដោយផ្តោតទៅលើសង្គមស៊ីវិល ការអភិវឌ្ឍបរិស្ថាន ចម្ការមីន និងស្ត្រី ជាដើម ។ អក្សរតំណាងនានា បានលេចឡើងនៅក្នុងតំបន់ដូចជា ÷ អារ៉េណា (Arena) («ការផ្លាស់ប្តូរក្នុងតំបន់អាស៊ីដើម្បីជម្រើសថ្មី» “Asian Regional Exchange for New Alternatives”) រហូតដល់ ហ្សូតូ (ZOTO) «អង្គការតុនដូតំបន់មួយ» (Zone One Tondo Organization) ។

អង្គការក្រៅរដ្ឋាភិបាលក៏មានយុទ្ធសាស្ត្រខុសគ្នាផងដែរ ។ អង្គការខ្លះមានមុខងារចម្បងជាក្រុមដាក់សម្ពាធផ្នែកនយោបាយ ដោយតវ៉ាបញ្ចុះបញ្ចូលសមាជិករដ្ឋសភាឲ្យធ្វើការផ្លាស់ប្តូរច្បាប់ តវ៉ាដើម្បីសិទ្ធិមនុស្ស និងតវ៉ាប្រឆាំងនឹងអំពើពុករលួយ និងភាពហួសកម្រិតនៃសាកលភាវូបនីយកម្មជាដើម ។ ជាទូទៅ អង្គការទាំងនេះមានទីតាំងនៅក្នុងរដ្ឋធានី ហើយមានទំនោរទៅរកការផ្សារភ្ជាប់ទំនាក់ទំនងយ៉ាងល្អទាំងផ្នែកនយោបាយនិងបច្ចេកវិទ្យាអេឡិចត្រូនិក ដោយតែងតែប្រើប្រាស់ជាប្រយោជន៍សម្រាប់សម្រង់សេចក្តីពីការប្រជុំ ឬក៏ប្រព័ន្ធផ្សព្វផ្សាយនៅតំបន់ក្នុងក្រុង ។ អង្គការផ្សេងៗទៀត មិនបានយកចិត្តទុកដាក់ចំពោះរដ្ឋធានីទេ ដោយផ្តោតទៅលើការផ្លាស់ប្តូរនៅឯថ្នាក់ភូមិ ឬថ្នាក់ខេត្តទៅវិញ ដូចជា ÷

១- ការបង្កើតឲ្យមានសហករណ៍កសិកម្ម ឬសិប្បកម្ម ឬក៏ក្រុមជនជួយខ្លួនឯងដែលមានជំនឿទៅលើសាសនាមួយដូចជា «សហគមន៍គ្រិស្តសាសនាមូលដ្ឋាន» នៃប្រទេសហ្វីលីពីន ។

២- ការងើបឈរទាំងអស់គ្នា ដើម្បីប្រឆាំងទៅនឹងការទន្ទ្រានពីសំណាក់ពួកម្ចាស់ដីធំៗ ម្ចាស់រោងចក្រ ឬអ្នកកសាងទំនប់ទឹក ។

៣- ការបង្ហាត់គ្នាទៅវិញទៅមកឲ្យចេះអានអក្សរ ។

៤- ការផ្តល់ប្រាក់កម្ចីក្នុងបរិមាណតិចតួចៗ ដែលមានប្រយោជន៍ ។

ការបះបោរប្រឆាំងប្រឈមមុខដាក់គ្នា ដោយអាវុធជាមួយនឹងរដ្ឋាភិបាលផ្ទាល់ គឺជាមធ្យោបាយចុងក្រោយសម្រាប់អ្នកដែលស្វះស្វែងឲ្យមានបម្លាស់ប្តូរនៅក្នុងតំបន់អាស៊ីអាគ្នេយ៍សម័យទំនើប ។ មកទល់ដើមសតវត្សរ៍ទី ២១ ការបះបោរប្រឆាំង ត្រូវបានគេលះបង់ចោលស្ទើរតែទាំងស្រុងសម្រាប់អ្នកដែលមានគោលបំណងផ្នែកសេដ្ឋកិច្ចច្បាស់លាស់ លើកលែងតែសម្រាប់បញ្ហាការពារផ្ទាល់ខ្លួន (និងអ្វីដែលនៅសេសសល់របស់គណបក្សកុម្មុយនីស្តនៃប្រទេសហ្វីលីពីន) ។ ឧស្សាហូបនីយកម្មមិនត្រឹមតែពាំនាំនូវភាពចម្រើនរុងរឿងមកឲ្យប្រទេសអាស៊ីអាគ្នេយ៍ជាច្រើននោះទេ ប៉ុន្តែការអភិវឌ្ឍនៅក្នុងប្រទេសចិននិងអតីតសហភាពសូវៀត ធ្វើឲ្យលែងមានការគាំទ្រសម្រាប់ការចលនាបះបោរឆ្វេងនិយម និងបានធ្វើឲ្យលែងមានគោលនយោបាយទាំងនេះក្នុងប្រទេសទាំងពីរទៀតផង ។

ទោះជាយ៉ាងនេះក្តី ឧទ្ទាមកម្មនៅតែជាជម្រើសដ៏រស់រវើកមួយសម្រាប់ពួកផ្តាច់ខ្លួន ។ មូលហេតុនៃក្តីឈឺចាប់ជាច្រើនរបស់ពួកគេ ដែលបានបញ្ជាក់នៅក្នុងពាក្យពេចន៍ទាក់ទងទៅនឹងសាសនា ជាតិពន្ធុ គឺជាអារម្មណ៍មួយដែលយល់ថា ផ្លែផ្កានៃការអភិវឌ្ឍបានផ្តល់ទៅឲ្យមនុស្សភាគច្រើននៅទីប្រជុំជន ជាជាងផ្តល់ឲ្យអ្នកដែលរស់នៅតំបន់ដាច់ស្រយាល ឬឲ្យជនជាតិភាគតិចនានា ។ ប្រជាជនរស់នៅក្នុងតំបន់អាចេះ (Aceh) ម៉ាលូគូ (Maluku) តំបន់ខ្ពង់រាបនៃប្រទេសភូមា និងប្រជុំកោះភាគខាងត្បូងនៃប្រទេសហ្វីលីពីន មានអារម្មណ៍ថា ខ្លួនត្រូវបានគេមើលងាយ ហើយសេដ្ឋកិច្ចសម្រាប់ជីវភាពរស់នៅរបស់គេ ត្រូវបានយកទៅឲ្យអ្នកដែលរស់នៅក្នុងទីក្រុងហ្សាការតា ទីក្រុងរ៉ង់ហ្គូន ឬក៏ទីក្រុងម៉ានីល ។

នៅពេលចាប់ផ្តើមសហស្សវត្សរ៍ទី ៣ ដែលឥឡូវនេះ គេបានទទួលស្គាល់ថា ជាប្រតិទិនពិភពលោកនោះ មធ្យោបាយសម្រាប់បញ្ចប់ភាពមិនចុះសម្រុងគ្នាផ្នែកសង្គមនិងសេដ្ឋកិច្ចផ្សេងៗ នៅមិនទាន់មានសភាពច្បាស់លាស់នៅឡើយ ។ សំណួរថា តើភាពចម្រើនរុងរឿងនៅក្នុងតំបន់អាចនឹងបន្តរីកចម្រើនឡើង និងប្រហែលជាប្រជាជនអាចទទួលបានភាពរីកចម្រើននេះស្មើៗ គ្នា ឬអត់ ឬក៏អ្វីនឹងត្រូវបានបំផ្លាញចោលទាំងស្រុងនោះ ក៏មានសភាពមិនច្បាស់លាស់ដែរ ។ ប៉ុន្តែ អ្វីដែលទំនងជាមានលក្ខណៈជាក់លាក់នោះ គឺថា ពេលនេះ ប្រជាជនអាស៊ីអាគ្នេយ៍ផ្ទាល់ មានលទ្ធភាពនិយាយរៀបរាប់អំពីលទ្ធផលដ៏សន្ធឹកសន្ធាប់ប្រាប់អ្នកដទៃ ច្រើនជាងនៅក្នុងអំឡុងពេលមួយសតវត្សរ៍កន្លះដែលពួកគេត្រូវរងអាណានិគមនិយម អាណានិគមនិយមបែបថ្មី និងសង្គ្រាមដឹកនាំពីចម្ងាយដោយមហាអំណាចផ្សេងៗ នោះ ៕

# ជំពូកទី ៣

## រាជាធិបតេយ្យអាស្រ័យបណ្ដាញ និងវិបត្តិភាពស្របច្បាប់ នៅក្នុងប្រទេសថៃ

*និពន្ធដោយ ៖ ដឹងខិន ម៉ាក់ខារហ្គូ*

*ច្បាប់ដើមនៃអត្ថបទនេះ សរសេរជាភាសាអង់គ្លេស ក្រោមចំណងជើងថា ៖* Network Monarchy and Legitimacy Crises in Thailand
*អត្ថបទនេះដកស្រង់ចេញពីព្រឹត្តិបត្រ* **ប៉ាស៊ីហ្វិក**
*រក្សាសិទ្ធិ គ.ស. ២០០៥ ដោយក្រុមថៃល័រនិងហ្វ្រង់ស៊ីស*

# CHAPTER 3

## Network Monarchy and Legitimacy Crises in Thailand

*( The Pacific Review, Vol. 18 )*

**Copyright © 2005 by Taylor & Francis Group.**

**បកប្រែដោយ ៖ មួង ណារ៉េត និង គី សុភាដា**

# ជំពូកទី ៣
# រាជាធិបតេយ្យអាស្រ័យបណ្តាញ និងវិបត្តិភាពស្របច្បាប់ នៅក្នុងប្រទេសថៃ

**សង្ខេប ៖** *អត្ថបទនេះនឹងពិភាក្សាថា ការប្រើប្រាស់ពាក្យយ៉ាងទូលំទូលាយមួយចំនួន ដូចជា «ទម្រង់រដ្ឋាភិបាល» «ការិយាលយាធិបតេយ្យ» «រាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ» «ប្រជាធិបតេយ្យអន្តរកាល» និង «កំណែទម្រង់នយោបាយ» មិនបានកំណត់ឲ្យត្រូវទៅនឹងចរិតលក្ខណៈនយោបាយ ដែលទើបកើតឡើងថ្មីនៅក្នុងប្រទេសថៃបានទេ ។ ផ្ទុយទៅវិញ គេបានយល់យ៉ាងច្បាស់ថា នយោបាយថៃជាបណ្តាញនយោបាយ ។ បណ្តាញដឹកនាំឈានមុខនាអំឡុងឆ្នាំ ១៩៧៣ ដល់ឆ្នាំ ២០០១ មានមូលដ្ឋាននៅក្នុងព្រះបរមរាជវាំង ដែលនៅក្នុងអត្ថបទនេះ យើងហៅថា «រាជាធិបតេយ្យអាស្រ័យបណ្តាញ» ។ រាជាធិបតេយ្យប្រភេទនេះ មានការពាក់ព័ន្ធទៅនឹងអន្តរាគមន៍យ៉ាងសកម្មរបស់ព្រះមហាក្សត្រថៃ និងអ្នកតំណាងរបស់ព្រះអង្គ ជាពិសេស អតីតនាយករដ្ឋមន្ត្រី ប្រេម តិណសូលានន្ទ*[១] (เปรม ติณสูลานนท์ Prem Tinsulanond) *នៅក្នុងដំណើរការនយោបាយ ។ រាជាធិបតេយ្យអាស្រ័យបណ្តាញបានបង្កើតឥទ្ធិពលគួរឲ្យកត់សម្គាល់ ប៉ុន្តែមិនដែលសម្រេចបាននូវលក្ខខណ្ឌសម្រាប់ក្តោបក្តាប់អំណាចឡើយ ។ ជំនួសមកវិញ រាជវាំងមានកាតព្វកិច្ចសហការជាមួយស្ថាប័ននយោបាយដទៃទៀត ជាពិសេស គឺរដ្ឋសភាដែលបានជាប់ឆ្នោត ។ ទោះជារាជាធិតេយ្យអាស្រ័យបណ្តាញមានលក្ខណៈអភិរក្សបន្តិចក៏ដោយ ក៏រាជាធិតេយ្យបែបនេះបានប្រកាន់យកគោលការណ៍សេរីក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ ។ ចាប់តាំងពីឆ្នាំ ១៩៩២ មក ប្រទេសថៃបានជួបប្រទះវិបត្តិភាពស្របច្បាប់បីដំណាក់កាលសំខាន់ៗ ហើយក្នុងដំណាក់កាលនីមួយៗ លោកប្រេមជាអ្នកដើរតួតំណាងឲ្យព្រះរាជវាំងក្នុងការស្តារតុល្យភាពនយោបាយ ។ ប៉ុន្តែ អន្តរាគមន៍ទាំងនេះបានបង្ហាញនូវការចុះខ្សោយរបស់រាជាធិបតេយ្យ ជាពិសេស បន្ទាប់ពីជោគជ័យដ៏ធំធេងរបស់លោកនាយករដ្ឋមន្ត្រី ទក្សិណ (ថាក់ស៊ិន) ជិនវ័ត្រ*[២] (ทักษิณ ชินวัตร Thaksin Shinawatra) *លើការបោះឆ្នោតនាឆ្នាំ ២០០១ និងឆ្នាំ ២០០៥ ។ លោក ទក្សិណ បានបង្កើតបណ្តាញថ្មីផ្ទាល់ខ្លួនមួយឡើង ដើម្បីជំនួសឲ្យរាជាធិបតេយ្យអាស្រ័យបណ្តាញ ។ អត្ថបទនេះស្នើឲ្យមានការឈ្វេងយល់ឡើងវិញអំពីអំណាចរបស់រាជាធិបតេយ្យនៅក្នុងប្រទេសថៃ ។*

**ពាក្យគន្លឹះក្នុងអត្ថបទនេះ ៖ ប្រទេសថៃ, រាជាធិបតេយ្យ, បណ្តាញ, កំណែទម្រង់, ប្រេម តិណសូលានន្ទ, និង ទក្សិណ ជិនវ័ត្រ ។**

## សេចក្តីផ្តើម

*នាថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០០៥ ការិយាល័យក្រុមប្រឹក្សាព្រះមហាក្សត្ររបស់លោក ប្រេម តិណសូលានន្ទ ប្រធានអគ្គមន្ត្រីរបស់ប្រទេសថៃ បានថ្លែងសុន្ទរកថាជាសាធារណៈដ៏សំខាន់មួយនៅក្នុងទីក្រុងបាងកក អំពីស្ថានការណ៍អសន្តិសុខដែលកាន់តែយ៉ាប់យ៉ឺនទៅៗ នៅក្នុងបណ្តាខេត្តតាមបណ្តោយព្រំដែនភាគខាងត្បូងដែលសម្បូរជនជាតិសាសន៍អ៊ិស្លាមរស់នៅ ។ ក្នុងអំឡុងពេលមួយឆ្នាំចុងក្រោយនេះ មានមនុស្សប្រមាណជាង ៥០០ នាក់ បានស្លាប់នៅក្នុងឧបទ្ទវហេតុហិង្សានៅទីនោះ ។ លោក ប្រេម បានជំរុញឲ្យលោកនាយករដ្ឋមន្ត្រី ទក្សិណ ជិនវ័ត្រ*

ទទួលយកព្រះរាជឱវាទរបស់ព្រះមហាក្សត្រនិងព្រះបរមរាជិនីនាថ ដោយរកដំណោះស្រាយបែបសន្តិវិធី និង ប្រកបដោយការប្រុងប្រយ័ត្ន ចំពោះបញ្ហានៅភាគខាងត្បូង ជាជាងការបញ្ជូនកម្លាំងយោធាប្រញាប់ប្រញាល់ និង គ្មានការយល់ឲ្យបានត្រឹមត្រូវអំពីស្ថានការណ៍ជាមុន ។ លោក ប្រេម បានថ្លែងសុន្ទរកថាដូច្នេះនៅក្នុងអង្គសិក្ខាសាលាមួយ ក្រោមប្រធានបទ «រួបរួមកម្លាំងគ្នា ដើម្បីដំណោះស្រាយបញ្ហានៅតាមបណ្ដាខេត្តភាគខាងត្បូង ផ្អែកលើ ព្រះរាជបន្ទូលរបស់ព្រះមហាក្សត្រ» ។ សេចក្ដីថ្លែងការណ៍របស់លោក ប្រេម យោងផ្ទាល់ទៅលើព្រះរាជបន្ទូល របស់ព្រះមហាក្សត្រនាថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០០៤ ដែលគាំទ្រយោគយល់ (ភាសាសៀមថា เข้าใจ /ខៅចៃ/ មានន័យថា យល់) អាចចូលទៅដល់បាន (ភាសាសៀមថា เข้าถึง /ខៅធឹង/ មានន័យថា ចូលដល់) និងការអភិវឌ្ឍ (ភាសាសៀមថា พัฒนา /ផាត់ថៈណា/) ។ លោក ទក្សិណ មានវត្តមាននៅក្នុងការថ្លែងសុន្ទរកថានេះ ប៉ុន្តែមិន បានអនុវត្តតាមសេចក្ដីថ្លែងសុន្ទរកថានោះទេ ។ លោក ប្រេម បានពន្យល់ថា មនុស្សគ្រប់រូបចាប់តាំងពីមេដឹក នាំសហគមន៍ រហូតដល់មន្ត្រីរដ្ឋាភិបាល សាស្ត្រាចារ្យ និងអង្គការក្រៅរដ្ឋាភិបាល គួរតែឈ្វេងយល់អំពីព្រះរាជ ឱវាទរបស់ព្រះមហាក្សត្រ និងទទួលយកភាសារួមមួយសម្រាប់ប្រើប្រាស់ (របាយការណ៍កាសែតថៃ, ៣ មីនា ២០០៥) ។ ប៉ុន្មានថ្ងៃក្រោយមក រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាសម្រុះសម្រួលជាតិមួយ ដើម្បីដោះស្រាយ ជាមួយចលនាបះបោរនៅភាគខាងត្បូង ។ នេះជាការចេញដំណើរមួយពីគោលនយោបាយសន្តិសុខនិយកម្មមាន ពីមុនមក ។

អន្តរាគមន៍របស់លោក ប្រេម ក្នុងវិបត្តិនៅភាគខាងត្បូង គឺជាឧទាហរណ៍យ៉ាងច្បាស់អំពីទម្រង់គ្រប់គ្រង គួរឲ្យកត់សម្គាល់តូចមួយ អំពីអភិបាលកិច្ចរាជាធិបតេយ្យអាស្រ័យបណ្ដាញ ដែលកំពុងដំណើរការនៅក្នុងប្រទេស ថៃ ។ ពេលខ្លះ គេទទួលស្គាល់ថា ព្រះមហាក្សត្រថៃបានធ្វើអន្តរាគមន៍ផ្ទាល់ក្នុងផ្នែកនយោបាយ ។ ឧទាហរណ៍ ដ៏ល្បីល្បាយបំផុតមួយ គឺការធ្វើអន្តរាគមន៍របស់ព្រះអង្គដែលបណ្ដាលឲ្យមានបាតុកម្មបង្ហូរឈាម នាខែឧសភា ឆ្នាំ ១៩៩២ ។ នៅពេលនោះ ព្រះអង្គបានដាស់តឿនដល់នាយករដ្ឋមន្ត្រីគ្មានប្រជាប្រិយមួយរូប និងមេដឹកនាំប្រឆាំង មួយរូប ហើយបានដាក់ព្រះរាជបញ្ជាដល់ពួកគេឲ្យផ្សះផ្សានូវទស្សនៈផ្ទុយគ្នារបស់គេ ។ ប៉ុន្តែ អន្តរាគមន៍ជា សាធារណៈដ៏កម្រដូចនេះ បានបង្ហាញឲ្យគេដឹងនូវបណ្ដាញដ៏ធំទូលាយមួយរបស់ព្រះរាជវង្សានុវង្ស ដែល ពាក់ព័ន្ធនឹងចលនានយោបាយ ហើយភាគច្រើនត្រូវបានលាក់កំបាំងយ៉ាងជិតពីក្រសែភ្នែកមហាជនទូទៅ ។ តទៅ នេះ យើងនឹងបកស្រាយអំពីបាតុភូតនិងដំណើរវិវឌ្ឍនៃរបបរាជាធិបតេយ្យអាស្រ័យបណ្ដាញ ។

## ការកំណត់ន័យលើនយោបាយថៃ

អស់រយៈពេលដ៏យូរមកហើយ គេមានការពិបាកក្នុងការកំណត់នូវទម្រង់នយោបាយនៅក្នុងប្រទេសថៃ ។ លោក ហ្វ្រេដ រីគ្គស៍ (Fred Riggs) នៅឆ្នាំ ១៩៦៦ បានអះអាងថា ប្រទេសថៃ គឺជាប្រទេស «ការិយាលយាធិបតេយ្យ» ឬថា អ្នកការិយាលយាធិបតេយ្យនិងមន្ត្រីយោធា បានគ្រប់គ្រងប្រទេសថៃ ដើម្បីតែគោលបំណងផ្ទាល់ខ្លួនរបស់ពួក គេ ។ លោក ហេវិសុន (Hewison) បានរិះគន់យ៉ាងត្រឹមត្រូវចំពោះការបកស្រាយជ្រុលនិយមខាងលើ ។ គាត់លើក ឡើងថា វាជាការបកស្រាយងាប់ក្រឡា ហើយមិនបានងាកមើលលើក្រុមប្រឆាំងនឹងក្រុមអ្នកតស៊ូផ្សេងៗ ហើយ ថែមទាំងមិននិយាយអំពីការកកើតចលនាមហាជននៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ ទៀតផង (១៩៩៦: ៧៥)[៣] ។ ក្រោយ

មកទៀត ការពិភាក្សាអំពីនយោបាយថៃជាញឹកញាប់ ត្រូវគេនិយាយតែពីការផ្លាស់ប្ដូរលទ្ធិប្រជាធិបតេយ្យនិងការផ្លាស់ប្ដូរនយោបាយ (ជ័យអនន្ត ១៩៩០) ។ បន្ទាប់ពីរដ្ឋប្រហារយោធានៅក្នុងឆ្នាំ ១៩៩១ បានបដិសេធការសន្និដ្ឋានមិនច្បាស់លាស់ អំពីប្រជាធិបតេយ្យូបនីយកម្មនៅក្នុងប្រទេសថៃមក មានការស្រាវជ្រាវមួយចំនួនធំ បានសង្កត់ធ្ងន់លើការផ្លាស់ប្ដូរសេដ្ឋកិច្ចនយោបាយ និងការកកើតឡើងនូវសង្គមស៊ីវិលដែលនាំមកជាមួយនូវគម្រោងកែប្រែនយោបាយបន្តិចបន្តួច (កុណ្ឌរស័ ១៩៩៩ និង ម៉ាក់ខារហ្គូ ២០០២) ។ អត្ថបទនេះប្រើប្រាស់នូវវិធីសាស្ត្រមួយបែបផ្សេង ហើយនិងលើកឡើងថា ទម្រង់នយោបាយរបស់ប្រទេសថៃ គឺជាទម្រង់មួយមានលក្ខណៈជានយោបាយផ្អែកលើបណ្ដាញ ។ ចាប់ពីឆ្នាំ ១៩៧៣ មក ដល់ឆ្នាំ ២០០១ បណ្ដាញដឹកនាំនយោបាយរបស់ប្រទេសថៃ គឺជាបណ្ដាញរបស់ព្រះមហាក្សត្រសោយរាជ្យ ព្រះបាទសម្ដេចព្រះបរមិន្ទរមហាភូមិពលអតុល្យតេជ ។ ចាប់តាំងពីឆ្នាំ ២០០១ មក ឧត្តមភាពនៃបណ្ដាញរបស់ព្រះរាជវាំង ត្រូវបានប្រជែងជាមួយនឹងការកកើតឡើងគួរឲ្យកត់សម្គាល់របស់លោកនាយករដ្ឋមន្ត្រី ទក្សិណ ជិនវ័ត្រ ដែលជាមហាសេដ្ឋីដ៏មានឥទ្ធិពលផ្នែកប្រព័ន្ធទូរគមនាគមន៍ ។

ចាប់តាំងពីបណ្ដេញលោក ថ្នម កិត្តិខ្ចរ[៤] (ถนอม กิตติขจร Thanom Kittikachorn) និងលោក ប្រភាស ចារុស្ដៀរ[៥] (ประภาส จารุเสถียร Praphas Charusathien) ចេញពីតំណែងនៅក្នុងឆ្នាំ ១៩៧៣ មក ព្រះចៅភូមិពល នៃព្រះរាជអាណាចក្រថៃ បានដើរតួលើសពីអ្វីដែលគេហៅថា ព្រះមហាក្សត្រគ្រងរាជ្យប៉ុន្តែមិនកាន់អំណាច និងហាក់ដូចជាមិនមែនជាព្រះមហាក្សត្រអាស្រ័យលើរដ្ឋធម្មនុញ្ញដូចដែលបានចែងនៅក្នុងច្បាប់ទេ ។ ម្យ៉ាងទៀត មានអ្នកនិពន្ធមួយចំនួន ជាពិសេសលោក ហេវិសុន (១៩៩៧) សាស្ត្រាចារ្យ កបកើ្យ (២០០២-២០០៣) និង លោក កឺរស្ហូវ៍ (Kershaw) (២០០១) បានព្យាយាមវាយតម្លៃចំពោះតួនាទីនយោបាយរបស់ព្រះរាជវង្សានុវង្សថៃ ដោយផ្ដោតជាចម្បងទៅលើតែព្រះមហាក្សត្រប៉ុណ្ណោះ ។ ការពិភាក្សានៅក្នុងអត្ថបទនេះខុសពីគេ ។ ក្នុងនេះ ព្រះមហាក្សត្រ គឺជាតំណាងនៃទម្រង់អភិបាលកិច្ចដ៏ថ្មីសន្ធាងមួយ ដែលអាចយល់បានយ៉ាងច្បាស់ថា ជាបណ្ដាញនយោបាយ ។ «រាជាធិបតេយ្យអាស្រ័យបណ្ដាញ» របស់ប្រទេសថៃ បានប្រមូលផ្ដុំតែទៅលើលោក ប្រេម ប្រធានគណៈអង្គមន្ត្រី (គណៈទីប្រឹក្សានៃព្រះមហាក្សត្រ) តែប៉ុណ្ណោះ ។ រាជាធិបតេយ្យអាស្រ័យបណ្ដាញ គឺជាទម្រង់ដឹកនាំពាក់កណ្ដាលរាជាធិបតេយ្យមួយ ដោយសារតែព្រះមហាក្សត្រថៃនិងសម្ពន្ធមិត្តរបស់ព្រះអង្គ បានប្រឌិតឡើងនូវទម្រង់រាជាធិបតេយ្យបែបទំនើបមួយ ជាស្ថាប័ននយោបាយមិនផ្លូវការ (Para-political institution) ។ លោក អែណ្ឌឺរសុន (Anderson) បានរៀបរាប់យ៉ាងល្អអំពីរបបរាជានិយមរបស់រាជអាណាចក្រថៃ ថា «ជារបបគ្រប់គ្រងដែលចាស់គំរិលហើយប្លែក» (១៩៧៨: ២០៩) ។ ប៉ុន្តែ រាជាធិបតេយ្យអាស្រ័យបណ្ដាញ គឺជាការកកើតឡើងទំនើបជាងទម្រង់ដើម ។ រាជាធិបតេយ្យអាស្រ័យបណ្ដាញនៅពេលបច្ចុប្បន្ន រំលឹកឡើងវិញអំពីរាជានិយមផ្ដាច់ការ (សម្បូណ៌ាញាសិទ្ធិរាជ) មុនសម័យ គ.ស. ១៩៣២ ។ រាជាធិបតេយ្យបច្ចុប្បន្ននេះធ្វើឲ្យមានការទទួលស្គាល់ទាំងស្ទាក់ស្ទើរថា គ្មានព្រះមហាក្សត្រថៃអង្គសម័យទំនើបណាមួយអាចជាអ្នកដឹកនាំផ្ដាច់ការឡើយ ។ ប៉ុន្តែ «អ្នកបង្កើតរឿងព្រះរាជទេវកថា បានផ្សព្វផ្សាយដោយចិត្តប្រាថ្នាខ្ពស់នូវការប្រៀបធៀបរវាងព្រះចៅ ព្រះរាម ទី ៥ ជាមួយព្រះមហាក្សត្រដែលកំពុងសោយរាជ្យ» (ប៉េឡេជ្ជី (Peleggi) ២០០២: ១៦៧) ហើយលោក ភីថឺរ ហ្សាក់សុន (Peter Jackson) បានលើកឡើងថា ការគោរពបូជាដ៏សក្ដិសិទ្ធិចំពោះព្រះចៅ ព្រះរាម ទី ៩ (គឺ ព្រះចៅ ភូមិពល) ត្រូវបានគេដាក់បញ្ចូលក្នុងទេវកថានោះដែរ (ហ្សាក់សុន ១៩៩៩: ៣០១-៤)[៦] ។ លោកនាយករដ្ឋមន្ត្រីថៃ

ទក្សិណ ជិនវ័ត្រ ដែលបានជាប់ឆ្នោតចំនួនពីរដងនៅក្នុងឆ្នាំ ២០០១ និងឆ្នាំ ២០០៥ ដោយសារការគាំទ្រពីប្រជាជន បានស្វះស្វែងដោយប្រុងប្រយ័ត្ន ដើម្បីផ្លាស់ប្តូរបណ្តាញនៃអំណាចព្រះរាជវាំង ដោយដាក់ជំនួសវិញនូវបណ្តាញថ្មីមួយ ។

លក្ខណៈពិសេសនៃរបបរាជាធិបតេយ្យអាស្រ័យបណ្តាញរបស់ប្រទេសថៃ ចាប់ពីឆ្នាំ ១៩៨០ ដល់ឆ្នាំ ២០០១ មានដូចតទៅ÷

១- ព្រះមហាក្សត្រ គឺជាអាជ្ញាកណ្តាលចុងក្រោយ ក្នុងការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងនយោបាយ នៅក្នុងស្ថានការណ៍មានវិបត្តិ ។

២- រាជាធិបតេយ្យ គឺជាប្រភពដ៏សំខាន់នៃភាពស្របច្បាប់របស់ជាតិ ។

៣- ព្រះមហាក្សត្រមានតួនាទីជាអ្នកផ្តល់ព្រះរាជឱវាទ ចំពោះបញ្ហាជាតិ ដោយជួយបង្កើតនូវរបៀបវារៈជាតិ ជាពិសេសតាមរយៈព្រះរាជសុន្ទរកថារបស់ព្រះអង្គក្នុងពេលបុណ្យចម្រើនព្រះជន្មជារៀងរាល់ឆ្នាំ ។

៤- ព្រះមហាក្សត្រមានរាជសិទ្ធិធ្វើអន្តរាគមន៍យ៉ាងសកម្ម នៅក្នុងដំណើរវិវឌ្ឍនយោបាយ ដោយធ្វើការជាមួយអ្នកតំណាងរបស់ព្រះអង្គ ដូចជាសមាជិកក្រុមប្រឹក្សាព្រះមហាក្សត្រ និងមេដឹកនាំយោធាសំខាន់ៗដែលព្រះអង្គទុកព្រះទ័យ ។

៥- អតីតមេបញ្ជាការកងទ័ព និងជានាយករដ្ឋមន្ត្រី ព្រេម តិណសូលានន្ទ តំណាងដ៏ចម្បងបំផុតរបស់ព្រះអង្គ ជាអ្នកជួយកំណត់នូវលក្ខណៈសម្ព័ន្ធរាជរដ្ឋាភិបាលទូទៅ គ្រប់គ្រងដំណើរការយោធា និងការតម្លើងឋានៈផ្សេងៗទៀត ។

ចំណុចសំខាន់នោះ គឺថា អភិបាលកិច្ចអាស្រ័យបណ្តាញប្រភេទនេះ ផ្អែកជាមូលដ្ឋានលើការចេះប្រើមនុស្សឲ្យត្រូវតាមតួនាទីការងារ ។ ការចាត់ចែងនូវមុខតំណែងសំខាន់ៗ គឺជាតួនាទីដ៏ចម្បងរបស់លោក ព្រេម ជាអ្នកតំណាងដ៏សំខាន់បំផុតរបស់ព្រះមហាក្សត្រ ។

របបរាជាធិបតេយ្យអាស្រ័យបណ្តាញមិនមានលក្ខណៈសេរីនិយមទេ ពីព្រោះរបបនេះពឹងផ្អែកទៅលើអ្វីដែលហៅថា «មនុស្សល្អ» និងការកាត់បន្ថយនូវអំណាចរបស់ស្ថាប័ននយោបាយស្របច្បាប់ និងនីតិវិធីផ្លូវការផ្សេងៗ ។ របបនេះផ្តល់អាទិភាពតិចតួចដល់គោលការណ៍ប្រជាធិបតេយ្យ ដូចជា នីតិរដ្ឋនិងអធិបតេយ្យរបស់ប្រជារាស្ត្រ ។ ប៉ុន្តែ ស្នាព្រះហស្តសំខាន់ៗ របស់ព្រះចៅភូមិពល ត្រូវបានគេលើកតម្កើងក្នុងគោលបំណងលើកស្វ័យភាពរបស់ព្រះអង្គរឹតតែខ្ពស់ ក្នុងរបបដឹកនាំពហុបក្សនិយម ដែលកំពុងតែកើនឡើងនៅក្នុងរាជអាណាចក្រថៃ ។ករណីយកិច្ចនេះផ្ទុយទៅនឹងការគ្រប់គ្រងដ៏តឹងរ៉ឹង ដែលបានកំណត់លើរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញដូចមនុស្សទូទៅធ្លាប់បានយល់ ។ ចំពោះមតិរបស់លោក រ៉ូប៊ឺត ដាហ្ល (Robert Dahl) គេអាចស្គាល់រាជាធិបតេយ្យថៃយ៉ាងច្បាស់ថា ជាអង្គការចាត់តាំង ឬ «អនុប្រព័ន្ធ» (ដាហ្ល ១៩៨២: ២៧-៨) គឺមិនមែនជាស្ថាប័នទេ ។ អ្នកនាំមុខដ៏សំខាន់បំផុតរបស់បណ្តាញនេះ គឺគណៈអង្គមន្ត្រី (ក្រុមប្រឹក្សាព្រះមហាក្សត្រ) ដែលជួបប្រជុំគ្នាពីរដងក្នុងមួយសប្តាហ៍ ដើម្បីពិនិត្យឡើងវិញនូវរាល់នីតិវិធីទាំងឡាយ និងផ្តល់ជាអនុសាសន៍ចំពោះបញ្ហាផ្សេងៗ ដល់ព្រះមហាក្សត្រ (ហេវីសុន ១៩៩៧: ៧២) ។ ព្រះរាជាក៏អាចពិគ្រោះយោបល់ជាមួយនឹងមេដឹកនាំនានារបស់គណបក្សនយោបាយបាន ពេលប្រទេសមានវិបត្តិ (១៩៩៧: ៧៣) ។ លោក ហេវីសុន បានលើកឡើងថា ÷

ព្រះមហាក្សត្រនិងទីប្រឹក្សារបស់ព្រះអង្គ មានព្រះរាជតម្រិះនិងយោបល់ថា ព្រះអង្គគួរតែមានរាជសិទ្ធិធ្វើអន្តរាគមន៍ក្នុងដំណើរការនយោបាយ... ព្រះអង្គ ច្រើនហាក់ដូចជាធ្វើព្រះរាជសកម្មភាពហួសពីតួនាទីដែលគេចាត់ថា សមរម្យក្នុងប្រព័ន្ធរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ (១៩៩៧ : ៧២-៣) ។

*ហួសពីអ្វីដែលហៅថា «នៅពីលើនយោបាយ» ព្រះមហាក្សត្រអង្គនេះ តាមពិត បានចូលរួមយ៉ាងពេញទំហឹងក្នុងនយោបាយ ។ ការចូលរួមរបស់ព្រះអង្គ បានន័យថា ព្រះអង្គគឺជា «ព្រះមហាក្សត្រសកម្ម» (១៩៩៧: ៧៤) ។ នៅក្នុងឆ្នាំ ១៩៨៩ ព្រះមហាក្សត្របានរៀបរាប់តួនាទីផ្នែកនយោបាយរបស់ព្រះអង្គយ៉ាងច្បាស់ នៅក្នុងកិច្ចសម្ភាសដ៏កម្រមានមួយជាមួយនឹងសារព័ត៌មាន* **ញូយ៉កថៃមស៍** (New York Times) *ថា ÷*

« ខ្ញុំគិតថា យើងបានរកឃើញវិធីសាស្ត្រដ៏ល្អបំផុតមួយ ។ » ព្រះអង្គទ្រង់បន្ថែមទៀតថា នៅក្នុងតំណែងរបស់ព្រះអង្គ មានកត្តាជ្រុលនិយមពីរ ដែលត្រូវជៀសវាង ទី ១ គឺការចំណុះទាំងស្រុងក្រោមអ្នកនយោបាយ និងទី ២ គឺការមានព្រះរាជហឫទ័យចចេស ។ ព្រះអង្គមានព្រះបន្ទូលទៀតថា « ខ្ញុំអាចសម្រេចចិត្តស្ថិតនៅក្នុងរង្វង់ច្បាប់ ខ្ញុំអាចធ្វើនូវអ្វីដែលច្បាប់បានចែងតែប៉ុណ្ណោះ ។ ប្រសិនបើខ្ញុំនិយាយអ្វីមួយ នាយករដ្ឋមន្ត្រី ឬក៏រដ្ឋមន្ត្រីត្រូវតែចុះហត្ថលេខាអមហើយ ប្រសិនបើគ្មានវត្តមានរបស់ពួកគេក្នុងការចុះហត្ថលេខាអមទេ យើងមិនអាចនិយាយបានទេ ។ នោះជាផ្លូវមួយ គឺមិនបានធ្វើអ្វីទាំងអស់ គ្មានអ្វីកើតឡើងទាំងអស់ ។ វិធីមួយទៀត គឺធ្វើច្រើនពេក ដោយប្រើប្រាស់ឥទ្ធិពលដែលយើងមាននៅក្នុងការធ្វើអ្វីគ្រប់យ៉ាង ។ វិធីនេះក៏មិនបានការដែរ ។ យើងត្រូវតែស្ថិតនៅកណ្ដាល និងធ្វើការគ្រប់ផ្នែកទាំងអស់តាមរបៀបនេះ ។ » (បារបារ៉ា ក្រូហ្សេត្ត (Barbara Crosette) "King Bhumibol's reign" « [រជ្ជកាលព្រះចៅ ភូមិពល] » **ញូយ៉កថៃមស៍** ២១ ឧសភា ១៩៨៩) ។

*ទស្សនៈដែលថា «ត្រូវតែស្ថិតនៅកណ្ដាល និងធ្វើការគ្រប់ផ្នែកទាំងអស់តាមរបៀបនេះ» គឺជាសេចក្ដីសង្ខេបដ៏ច្បាស់លាស់មួយនៃអភិបាលកិច្ចរាជាធិបតេយ្យអាស្រ័យបណ្ដាញ ដូចដែលបានអនុវត្តនៅក្នុងប្រទេសថៃបន្ទាប់ពីឆ្នាំ ១៩៧៣ មកម៉្លេះ ។ សម្រាប់ព្រះរាជវាំង ការចែករំលែកអំណាច គឺជាការឆ្លើយតបដ៏សមហេតុផលមួយនៅក្នុងលំដាប់ថ្នាក់នយោបាយ ។ ការគ្រប់គ្រងរបស់ព្រះមហាក្សត្រមានកម្រិតកំណត់ដោយខានមិនបាន ដូចដែលលោក អុល្សុន* (Olson) *លើកឡើងថា «អ្នកដឹកនាំដែលមិនអាចក្លាយជាអ្នកផ្ដាច់ការតែងតែមានចិត្តចង់សហការជាមួយនឹងអ្នកដទៃផ្សេងទៀត ដើម្បីបង្កើតរាជរដ្ឋាភិបាលមិនផ្ដាច់ការមួយ» (២០០០: ៣៣) ។ លោក អុល្សុន បានវែកញែកថា នៅក្រោមស្ថានការណ៍ដូចនេះ ជាទូទៅ អ្នកដឹកនាំចង់បង្កើតរាជរដ្ឋាភិបាលតំណាងរាស្ត្រមួយ ។ ទោះជាយ៉ាងនេះក្ដី ជម្រើសដ៏ល្អចំពោះរាជាធិបតេយ្យរបស់ប្រទេសថៃ គឺអនុញ្ញាតឲ្យមានការបង្កើតនូវរាជរដ្ឋាភិបាលតំណាងរាស្ត្រឲ្យមានជារូបរាងឡើង ហើយក្នុងពេលជាមួយគ្នានោះដែរ ត្រូវប្រើប្រាស់បណ្ដាញនយោបាយដើម្បីបំផ្លាញនិងផ្ដួលរំលំពួកគេ ។ តែគួរឲ្យអស់សំណើច មានអ្នករាជានិយមដែលមានគំនិតសេរីនិយមផង ដ៏មានឥទ្ធិពលមួយចំនួន បានគាំទ្រមធ្យោបាយបែបនេះ ដូចជា បណ្ឌិត ប្រវេស វ:សី*[៧] (ประเวศ วะสี Prawase Wasi) *និង លោក អានន្ទ ប័ន្យារជុន*[៨] (อานันท์ ปันยารชุน Anand Panyarachun) *។ ពួកគេបានបង្កើតបណ្ដាញការិយាលយាធិបតេយ្យបន្ថែម ដែលក្នុងចំណោមនោះ បុគ្គលម្នាក់ៗ អាចអនុវត្តនូវអំណាចនិងឥទ្ធិពលរបស់គេរៀងៗ ខ្លួន (ពួកគេអាចប្រៀបដូចជាស្ដេចត្រាញ់) ។ ពីព្រោះតែនយោបាយស្របច្បាប់ ត្រូវបានគ្របដណ្ដប់ដោយតួអង្គយកប្រាក់ជាធំនោះ បានជាបណ្ដាញរាជានិយមនិងសេរីនិយមផង បានផ្ដល់នូវមធ្យោបាយមួយទៀត ដើម្បីធ្វើឲ្យរបៀបវារៈ*

នយោបាយមានលក្ខណៈជឿនលឿន ។ សម្រាប់អ្នកសេរីនិយម របបរាជាធិបតេយ្យអាស្រ័យបណ្ដាញ គឺជាទម្រង់អន្តរកម្មមួយនៃការគ្រប់គ្រង ដែលមានមុខនាទីផ្ដល់យោបល់សមស្របក្នុងការបង្កើតនូវទម្រង់នយោបាយសេរីមួយ ។ ស្របពេលជាមួយគ្នានោះដែរ ពុំមែនជាបណ្ដាញរាជានិយមទាំងអស់របស់ដែលមានលក្ខណៈសេរីនិយម ហើយរាជាធិបតេយ្យបានរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងក្រុមអភិរក្សនិយមជ្រុល ដែលមានការទាក់ទងជាមួយនឹងកងទ័ព ក្រសួងមហាផ្ទៃ និងស្ថាប័នមួយចំនួន ដូចជា ក្រុមកាយឫទ្ធិតាមភូមិជាដើម ។ អភិបាលកិច្ចអាស្រ័យបណ្ដាញរបស់ព្រះមហាក្សត្រ មិនមានទំនាក់ទំនងជាមួយទស្សនវិស័យនយោបាយជាក់លាក់ណាមួយនោះទេ ពីព្រោះតែអភិបាលកិច្ចនេះមានភាពបត់បែន អាស្រ័យទៅនឹងហេតុការណ៍ជាក់ស្ដែង ។ បើតាមលោក ដេវីដ ណក (David Knocke) រាជាធិបតេយ្យរបស់ប្រទេសថៃ មានឥទ្ធិពលពេញសន្ធឹក ប៉ុន្តែមិនប្រាកដថា អាចក្ដោបក្ដាប់អំណាចបាននោះទេ ។ ដូច្នេះ របបរាជាធិបតេយ្យអាស្រ័យបណ្ដាញត្រូវតែធ្វើការដោយប្រុងប្រយ័ត្នបំផុត ។ អំណាចក្នុងការធ្វើទំនាក់ទំនងរបស់ខ្លួន ត្រូវតែមានភាពជាក់លាក់ទៅតាមស្ថានការណ៍ (១៩៩៤: ២) ។ គោលបំណងសំខាន់របស់បណ្ដាញនេះ គឺដើម្បីលើកតម្កើងអំណាចនិងកិត្យានុភាពរបស់រាជបល្ល័ង្ក ។ ជាថ្នូរមកវិញ កិត្យានុភាពនេះមានតួនាទីបម្រើអត្តសញ្ញាណជាតិ ហើយធ្វើឲ្យអ្នកដែលបានចូលរួមជាមួយបណ្ដាញនេះ មានគេទទួលស្គាល់ថា ស្របច្បាប់យ៉ាងទូលំទូលាយ ។ ការឈ្វេងយល់ពីរបបរាជាធិបតេយ្យអាស្រ័យបណ្ដាញ ត្រូវជួបប្រទះនូវការលំបាកច្រើន ពីព្រោះតែច្បាប់ស្ដីអំពីការប្រមាថព្រះចេស្ដា ហើយនិងការត្រួតពិនិត្យជុំវិញស្ថាប័នព្រះមហាក្សត្រ មានសភាពតឹងរ៉ឹង (ស្ត្រេកហ្វឹស (Streckfuss) ១៩៩៨) ។ ការឃ្លាំមើលនេះ វាដូចទៅនឹងអ្វីដែលលោក កុណ្ណរស៍ បានលើកឡើងថាជា «បណ្ដុំនៃចំណេះដឹងរបស់អ្នកនៅក្នុងព្រះរាជវាំង» ដែលជាចំណេះដឹងនយោបាយបែបមួយ អនុញ្ញាតឲ្យអ្នកនៅខាងក្នុងដែលមានឯកសិទ្ធិ ទាក់ទងជាមួយអ្នកខាងក្រៅបាន តែគេមិនមានសមត្ថភាពបកស្រាយនូវព្រឹត្តិការណ៍ផ្សេងៗ ឲ្យបានត្រឹមត្រូវច្បាស់លាស់ទេ (២០០៣: ១៣០-១) ។

## ដំណើរវិវឌ្ឍរបស់រាជាធិបតេយ្យអាស្រ័យបណ្ដាញ

រាជាធិបតេយ្យអាស្រ័យបណ្ដាញមិនមែនជាប្រព័ន្ធដែលនៅនឹងថ្កល់នោះទេ ប៉ុន្តែជាវិធីប្រតិបត្តិមួយដែលមានលក្ខណៈទន់ភ្លន់ហើយប្រែប្រួលទៅតាមស្ថានការណ៍នានា ។ ដោយសារតែអ្នកស្រាវជ្រាវ មានការពិបាកក្នុងការយល់ និងការធ្វើបំណែងចែកនូវរបបរាជាធិបតេយ្យអាស្រ័យបណ្ដាញ បានជាគេច្រើនតែមើលរំលង ឬបំភ្លេចចោលនូវរាជាធិបតេយ្យបែបនេះ ។ ក្នុងជំនាន់លោក ស្ញូស្ដិ៍ ធនៈរ័ដ្ឋ៍[៩] (สฤษดิ์ ธนะรัชต์ Sarit Thanarat) (១៩៥៨-៦៣) អំណាចផ្ដាច់ការយោធាបានជួយលើកតម្កើងរាជាធិបតេយ្យដើម្បីជួយឲ្យគេទទួលស្គាល់រដ្ឋថៃ, អំណាចផ្ទាល់ខ្លួនរបស់លោក ស្ញូស្ដិ៍ និងការតស៊ូប្រឆាំងនឹងពួកកុម្មុយនិស្ត ថា ត្រឹមត្រូវមែន (ទ័ក្ស ១៩៧៩: ៣០១-២៥) ។ រាជាធិបតេយ្យដែលបាត់ប្រជាប្រិយភាពនាសម័យមុនៗ បន្ទាប់មក បានលេចធ្លោឡើងវិញ ។ មកទល់នឹងចុងទសវត្សរ៍ឆ្នាំ ១៩៦០ ព្រះមហាក្សត្របានថ្លែងព្រះរាជសុន្ទរកថាសាធារណៈយ៉ាងទៀងទាត់ទាក់ទងនឹងបញ្ហានយោបាយ ។ មកទល់ដើមទសវត្សរ៍ឆ្នាំ ១៩៧០ ព្រះអង្គបានក្លាយជាឥស្សរជនដ៏មានអំណាចបំផុតនៅក្នុងរាជអាណាចក្រថៃ (ម៉ូរ៉េល្វ (Morell) និង ជ័យអនន្ត ១៩៨១: ៦៦-៨) ។ ព្រះអង្គក៏បានបង្ហាញនូវការគាំទ្រចំពោះយុទ្ធនាការដឹកនាំដោយនិស្សិតប្រឆាំងទៅនឹងទំនិញជប៉ុននាឆ្នាំ ១៩៧២ ផងដែរ (ព្រីហ្សៀ (Prizzia) ១៩៨៥:

៥១) ។ ហើយសូម្បីតែនៅមុនព្រឹត្តិការណ៍ឆ្នាំ ១៩៧៣ ប្រជារាស្ត្រថៃមួយចំនួនជឿជាក់ថា ព្រះមហាក្សត្របាន «ស្ថិតនៅក្នុងជំហរតែមួយគត់ក្នុងការជំរុញនូវវិធីផ្សេងៗ ដើម្បីកែទម្រង់សង្គមនិងរដ្ឋាភិបាលជាចាំបាច់និងជាបន្ទាន់» (រ៉ីណុលដ្ស៍ (Reynolds) ១៩៧៨: ១០៨) ។ នៅក្នុងឆ្នាំ ១៩៧៣ ដោយសារព្រះអង្គមិនសព្វព្រះរាជហឫទ័យនឹងការដឹកនាំផ្នែកនយោបាយ ការិយាលយាធិបតេយ្យ និងយោធា ដែលប្រកបដោយគុណវិបត្តិ ព្រះអង្គបានដើរតួយ៉ាងសំខាន់នៅក្នុងការគាំទ្រនូវសកម្មភាពផ្តួលរំលំបុរសខ្លាំង ពោលគឺលោក ថ្នម កិត្តិខ្ចរ និងលោក ប្រភាស ចារុសៀរ ។ នៅពេលនោះ «ព្រះអង្គបានក្លាយជានិមិត្តរូបបង្រួបបង្រួមមួយនៃសេចក្តីប្រាថ្នារបស់ប្រជាពលរដ្ឋ» (បូវី (Bowie) ១៩៩៧: ៩៧) ។ ព្រះមហាក្សត្របានផ្តល់ព្រះរាជឱវាទដល់មេដឹកនាំនិស្សិត មុនព្រឹត្តិការណ៍ខែតុលា ឆ្នាំ ១៩៧៣ កើតឡើង (កុណ្ណូរស៍ ២០០៣: ១៣០) ។

សាស្ត្រាចារ្យ កបកឿ បានប្រមើលមើលថា ការមិនសព្វព្រះទ័យរបស់ព្រះមហាក្សត្រជាមួយនឹងរបបដឹកនាំមួយផ្នែកទំនងមកពីលោក ប្រភាស បានរិះគន់ប្រឆាំងទៅនឹងលោក ស៊ូស្តិ៍ ដែលជាអ្នកផ្តល់ប្រឹក្សានិងជាដៃគូដ៏សំខាន់របស់ព្រះអង្គ (កបកឿ ២០០៣: ១៧៧) ។ បន្ទាប់ពីឆ្នាំ ១៩៧៣ រាជអាណាចក្រថៃមិនអាចត្រឡប់ទៅកាន់បែបរាជានិយមផ្តាច់ការដូចសម័យមុនឆ្នាំ ១៩៣២ បានឡើយ ។ ប៉ុន្តែ អ្នករាជានិយមទាំងឡាយចង់ឲ្យមាននូវទម្រង់ប្រតិបត្តិមួយបែបទៀត ដែលក្នុងនោះ ព្រះរាជវាំងអាចប្រតិបត្តិដើម្បីធ្វើអន្តរាគមន៍ និងតម្រង់ទិសនយោបាយថៃដោយផ្ទាល់និងដោយប្រយោល ។ ជំនួសឲ្យរាជាធិបតេយ្យតាមឋានានុក្រម តើរាជអាណាចក្រថៃអាចបង្កើតនូវទម្រង់គ្រប់គ្រងបែបរបបរាជាធិតេយ្យអាស្រ័យបណ្តាញជំនួសមកវិញបានទេឬ ? នៅក្នុងរាជាធិបតេយ្យតាមឋានានុក្រម ព្រះរាជបល្ល័ង្កអាចទទួលបាននូវគុណបំណាច់និងការសរសើរចំពោះជោគជ័យរបស់ខ្លួន ប៉ុន្តែ ព្រះរាជបល្ល័ង្កត្រូវបានគេបន្ទោសផងដែរ នៅពេលដែលមានបញ្ហាខុសឆ្គងណាមួយបានកើតឡើង ។ នៅក្នុងរាជាធិបតេយ្យអាស្រ័យបណ្តាញវិញ រាជបល្ល័ង្កអាចទទួលបាននូវកិត្តិគុណអំពីជោគជ័យ ប៉ុន្តែការបរាជ័យរបស់ «ប្រព័ន្ធអន់ថយ» ត្រូវបានគេទម្លាក់កំហុសទៅលើអ្នកផ្សេងវិញ ជាពិសេសដូចជាលើអ្នកនយោបាយពុករលួយ និងដែលត្រូវគេចោទប្រកាន់ថា គិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន ជាដើម ។ នៅក្នុងឆ្នាំ ១៩៨១ លោក ម៉ូរ៉េល្វ និង ជ័យអនន្ត បានក្រើនរំលឹកថា «នយោបាយនីយកម្មរបស់ស្ថាប័នព្រះមហាក្សត្រ ដែលកំពុងកើនឡើងនៅក្នុងប៉ុន្មានឆ្នាំថ្មីៗ នេះ ធ្វើឲ្យគេមានការប៉ះទង្គិចដល់សភាវៈរបស់វប្បធម៌បុរាណរបស់សៀម» (១៩៨១: ៣១៣) ។ ដោយធ្វើការតាមរយៈបណ្តាញ យ៉ាងហោចណាស់ ក៏រាជាធិបតេយ្យអាចបង្ហាញទម្រង់ខាងក្រៅរបស់ខ្លួន បែបមិនពាក់ព័ន្ធទៅនឹងនយោបាយ ដើម្បីផ្គាប់ចិត្តសាធារណជនដែរ ។ លោក កុណ្ណូរស៍ បានរិះគន់យ៉ាងត្រឹមត្រូវចំពោះអ្នករាជានិយមគំនិតអភិរក្ស ដែលព្យាយាមពិព័ណ៌នាព្រះចៅ ភូមិពល ថា ជា «អ្នកសម្រុះសម្រួលពួកអ្នកដែលជាសត្រូវនឹងគ្នានៅក្នុងសង្គម» ។ ប៉ុន្តែ រូបភាពនេះ គឺជាការចាប់ផ្តើមនៃរបបរាជាធិបតេយ្យតាមបណ្តាញ (កុណ្ណូរស៍ ២០០៣: ១៣១) ។ បញ្ហាថា តើការបង្កើតរាជាធិបតេយ្យអាស្រ័យបណ្តាញឡើងជាគម្រោងរបស់ពួកឥស្សរជន ឬថា តើរាជាធិបតេយ្យបែបនេះបានវិវត្តដោយចៃដន្យយ៉ាងណានោះ នៅតែជាប្រធានបទសម្រាប់ការពិភាក្សា ។ តែកស្តុតាងអព្យាក្រឹតនាំឲ្យគិតថា មានផែនការនិងការគិតទុកជាមុន ។

សាមសិបឆ្នាំក្រោយមក គេអាចមើលឃើញកិច្ចប្រឹងប្រែងជាបន្តបន្ទាប់ ដើម្បីធ្វើឲ្យរាជាធិបតេយ្យអាស្រ័យបណ្តាញទទួលបានជោគជ័យក្នុងពេលធ្វើការក្នុងក្របខ័ណ្ឌនយោបាយរបស់ជាតិ ។ មានការបង្កើតនូវប្រព័ន្ធមួយ

ដែលទទួលស្គាល់តួនាទីវិជ្ជមាននិងសកម្មរបស់ព្រះមហាក្សត្រ (កបកៀ ២០០២: ៦២-៣) តែការពារមិនឲ្យមានការរិះគន់ ។ លោក គីរស្ទេវ៍ បានលើកឡើងថា រាជាធិបតេយ្យនៅក្នុងតំបន់អាស៊ីអាគ្នេយ៍អាចផ្តល់ «មធ្យោបាយពិសេស» ដើម្បីទំនុកបម្រុងអន្តរកម្មប្រជាធិបតេយ្យ (២០០១: ១៥៩-៦០) ។ ផ្ទុយទៅវិញ អត្ថបទនេះចង់បង្ហាញថា រាជាធិបតេយ្យថៃបានប្រឆាំងទៅនឹងការផ្លាស់ប្តូរប្រជាធិបតេយ្យ អស់ពេលជាយូរលង់មកហើយ ហើយបានយល់ព្រមទទួលស្គាល់ការកែទម្រង់នយោបាយយ៉ាងស្ទាក់ស្ទើរបំផុត និងយ៉ាងយឺតយ៉ាវ ។ ប្រាកដណាស់ យើងអាចពិភាក្សាលំអិតបានថា ដោយសារ «ការជួយសង្គ្រោះប្រទេស» ក្នុងស្ថានការណ៍មានវិបត្តិ រាជាធិបតេយ្យបានគាំទ្ររដ្ឋាភិបាលគ្មានសមត្ថភាពជាច្រើនជំនាន់ និងអាចពន្យារពេលដោះស្រាយបញ្ហានយោបាយរបស់ប្រទេសថៃបាន ។ ចាប់តាំងពីឆ្នាំ ១៩៧៣ មក ដល់ចំណុច ដែលប្រទេសថៃបានចាប់ផ្តើមអនុវត្តនូវរបបពហុបក្សប្រកួតប្រជែង (ដាហ្ល (Dahl) ១៩៧១: ៤០-៧) រាជាធិបតេយ្យបានបញ្ចូលខ្លួនឯងជាថ្មីទៅក្នុងឋានានុក្រមនយោបាយ ដោយធ្វើជាអ្នកដឹកនាំគេ ។ ព្រះរាជវាំងបានស្វះស្វែងបង្កើតនូវលក្ខខណៈរបស់ខ្លួនដោយផ្ទាល់ឬដោយប្រយោលសម្រាប់នយោបាយពហុបក្សនេះ ។ ដូចលោក បិណ្ឌិច (Bendix) បានវិភាគ «ជាការងាយស្រួលបំផ្លាញតេជានុភាពពិសិដ្ឋជាងការកសាងឡើងវិញ» (១៩៧៨: ១៧-១៨) ។ ប៉ុន្តែ អស់រយៈពេល ៣ ទសវត្សរ៍ទៅហើយ រាជាធិបតេយ្យថៃមានសភាពផ្ទុយស្រឡះពីទំនោរនេះ ដោយស្តារឡើងវិញនូវអំណាចរបស់ខ្លួនតាមរយៈការគ្រប់គ្រងប្រកបដោយវិចារណញ្ញាណនូវបណ្តាញទាំងឡាយ ។

ប្រសិនបើក្រឡេកត្រឡប់ទៅក្រោយវិញ ព្រឹត្តិការណ៍ខែតុលា ឆ្នាំ ១៩៧៣ បានបិទបាំងដោយធាតុមិនពិតនៃអន្តរាគមន៍ពោរពេញដោយធម៌ករុណារបស់ព្រះមហាក្សត្រ ដែលនេះជាមធ្យោបាយមួយក្នុងការបង្កឲ្យមានការផ្លាស់ប្តូរផ្នែកនយោបាយ ។ ព្រះមហាក្សត្របានធ្វើអន្តរាគមន៍ផងដែរ នៅក្នុងឆ្នាំ ១៩៧៤ ដោយរារាំងចំពោះការដាក់បញ្ចូលបុព្វសិទ្ធិមួយចំនួនរបស់ព្រះមហាក្សត្រទៅក្នុងសេចក្តីព្រាងច្បាប់រដ្ឋធម្មនុញ្ញ (កុណ្ណូរស៍ ២០០៣: ១៣០; កបកៀ ២០០៣: ៥៩) ។ មកដល់ឆ្នាំ ១៩៧៦ ព្រះរាជវាំងមានទំនោរទៅខាងស្តាំនិយម និងបានផ្តល់ការគាំទ្រដ៏សម្ងាត់ ចំពោះព្រឹត្តិការណ៍បង្ហូរឈាម ថ្ងៃទី ៦ ខែតុលា ។ អតីតមេដឹកនាំផ្តាច់ការ លោក ថ្នម កិត្តិខ្ចរ បានទទួលការអនុញ្ញាតឲ្យចូលមកប្រទេសថៃវិញ និងឲ្យចូលបួសជាសាមណេរនៅក្នុងវត្តបវរនិវេសវិហារ (ជាវត្តក្នុងរាជូបត្ថម្ភ) ហើយព្រះមហាក្សត្រនិងព្រះរាជិនីបានស្តេចយាងទៅសួរសុខទុក្ខ (បូវី ១៩៩៧: ១២៩; កបកៀ ២០០៣: ១៧២) ។ រយៈពេលពីរថ្ងៃបន្ទាប់ពីការសម្លាប់និស្សិតយ៉ាងរង្គាល ព្រះមហាក្សត្របានថ្លែងផ្សព្វផ្សាយតាមវិទ្យុគាំទ្រយ៉ាងពេញទំហឹងដល់ពលប្រហារ ថ្ងៃទី ៦ ខែតុលា ។ សម្តេចព្រះនាងចៅ សិរិកិត្តិ៍ ជាព្រះបរមរាជិនីនាថ និងព្រះរាជបុត្រីទាំងឡាយបានធ្វើព្រះរាជទស្សនកិច្ចនៅឯសាកលវិទ្យាល័យធម្មសាស្ត្រ (ธรรมศาสตร์ Thammasat) ដោយទ្រង់រាជប្រទានម្ហូបអាហារចំពោះក្រុមកាយឫទ្ធិនៅតាមភូមិ (ហៅ ลูกเสือชาวบ้าน «លូកសៀឆាវបាន» ជាភាសាសៀម បកប្រែថា «កូនខ្លាអ្នកស្រុក») ដែលបានបោះជំរំនៅទីវាលនោះ (កបកៀ ២០០៣: ១៧៤) ។ ដូចអ្នកស្រី បូវី បានវែកញែកនេះ គឺជាយុទ្ធសាស្ត្រដ៏គ្រោះថ្នាក់មួយ ដោយព្រះមហាក្សត្រស្ថិតក្នុងទីតាំងដែលមានសុវត្ថិភាព តែនៅពេលដែលព្រះអង្គបានគាំទ្រ «អារម្មណ៍របស់មនុស្សភាគច្រើន» នៅក្នុងឆ្នាំ ១៩៧៣ ។ ប៉ុន្តែ «ព្រះអង្គបានបង្កគ្រោះថ្នាក់ដល់ព្រះរាជតំណែងរបស់ទ្រង់ នៅពេលដែលមានគេគិតថា ព្រះអង្គបានចូលប្រឡូកមួយនឹងក្រុមភាគតិច ដែលមានគេទាស់ទែងខ្វែងគំនិត» (១៩៩៧: ១៤) ។ នៅក្នុងការពិសោធថ្មីមួយ ព្រះមហាក្សត្រ

បានជ្រើសតាំងលោក ធានិន្ទ្រ ក្រ័យវិជៀរ [១០] (ธานินทร์ กรัยวิเชียร Thanin Kraivixian) ជានាយករដ្ឋមន្ត្រី ដោយសង្ឃឹមថា ចៅក្រមតុលាការជាន់ខ្ពស់ដែលពោរពេញដោយគំនិតអភិរក្សនិយម មិនសូវមានប្រជាប្រិយភាព និងជាសំណព្វព្រះរាជហឫទ័យរបស់ព្រះរាជិនីរូបនេះ អាចជាអ្នកតំណាងរបស់ព្រះអង្គបាន ។ ការពិសោធនេះបានទទួលបរាជ័យយ៉ាងអស់សង្ឃឹម ដោយព្រះមហាក្សត្រមិនអាចប្រតិបត្តិតាមរយៈតួអង្គឯកោនិងត្រូវបានគេជំទាស់រូបនេះបានទេ ។ លោក ធានិន្ទ្រ ត្រូវបានបណ្តេញចេញពីតំណែងនៅក្នុងឆ្នាំ ១៩៧៧ តែបានឡើងឋានៈភ្លាមៗ ជាសមាជិកនៃគណៈអង្គមន្ត្រី ។ នេះគឺជាវិធីប្រតិបត្តិធម្មតារបស់រាជវាំង ដើម្បីបញ្ជាក់ពីភាពមិនសព្វព្រះរ័យចំពោះរបៀបដែលគេបានប្រព្រឹត្តទៅលើមនុស្សសំណព្វរបស់ព្រះរាជវង្សានុវង្ស (កបកៀ ២០០៣: ១៧៥) ។

ព្រះរាជវង្សានុវង្សបានបន្តបង្ហាញនូវភាពលំអៀងហួសប្រមាណ ខាងការប្រើប្រាស់កម្លាំងយោធា ជាជាងការផ្សះផ្សានិងឯកភាព ។ ប៉ុន្តែ ជាបណ្តើរៗ ព្រះមហាក្សត្របានព្រះរាជតម្រិះមេរៀនដ៏សំខាន់មួយដែលក្នុងនោះ រាជាធិបតេយ្យអាស្រ័យបណ្តាញចាំបាច់ត្រូវសន្និដ្ឋានពីទម្រង់ខាងក្រៅរបស់ដៃគូជាច្រើន ហើយជ្រើសតាំងនិងសហការជាមួយតួអង្គនយោបាយមួយចំនួនធំទៀត ។ រាជាធិបតេយ្យអាស្រ័យបណ្តាញត្រូវតែពឹងផ្អែកលើការសម្រុះសម្រួល ដោយទទួលស្គាល់ផ្នែកទាំងឡាយនៃសង្គមថៃទាំងមូល ។ ជាងនេះទៅទៀត រាជាធិបតេយ្យអាស្រ័យបណ្តាញ ត្រូវតែជាប់ទាក់ទងទៅនឹងការស្រុះស្រួល ផ្អែកលើស្ថានការណ៍ជាក់ស្តែងជាមួយនឹងអ្នកនយោបាយគួរឲ្យសង្ស័យមន្ទិល ត្រូវតែប្រើប្រាស់ផ្នែកនៃកម្លាំងទ័ពតាមលំដាប់ជាន់ថ្នាក់ និងត្រូវតែជាប់ទាក់ទងទៅនឹងនយោបាយនៃការកសាងសមត្ថភាព ។ ទោះជាយ៉ាងនេះក្តី ការកសាងសមត្ថភាពទាំងនេះ គឺមិនមែនជាតួនាទីរបស់ប្រមុខរដ្ឋដែលជាព្រះមហាក្សត្រនោះទេ ។ ព្រះមហាក្សត្រត្រូវការអ្នកតំណាងម្នាក់ដែលអាចគ្រប់គ្រងបណ្តាញរបស់ព្រះអង្គបាន ។ តាមពិត ព្រះមហាក្សត្រមិនចាំបាច់មានចំណងទាក់ទងដោយផ្ទាល់ច្រើននៅក្នុងការគ្រប់គ្រងប្រទេសនោះទេ ។ រាជាធិបតេយ្យអាស្រ័យបណ្តាញអាចដំណើរការដោយខ្លួនឯង អាស្រ័យដោយមានមេដឹកនាំត្រឹមត្រូវកាន់តំណែង ហើយព្រះមហាក្សត្រត្រូវការធ្វើអន្តរាគមន៍ដោយផ្ទាល់ព្រះអង្គនៅក្នុងស្ថានការណ៍មានវិបត្តិប៉ុកំនៅពេលដែលព្រះអង្គមានព្រះរាជសារពិសេសដើម្បីផ្តល់ជាដំណឹងតែប៉ុណ្ណោះ ។ ធាតុមួយនៃរាជាធិបតេយ្យតាមបណ្តាញ គឺចលនាកាយបុទ្ធិតាមភូមិ ដែលប្រកាន់នយោបាយស្តាំនិយម ។ អ្នកស្រី បូវី បានលើកឡើងថា អ្នកដែលបានចូលរួមក្នុងចលនាកាយបុទ្ធិតាមភូមិមាន «ក្តីសង្ឃឹមស្រពេចស្រពិលថា ប្រសិនបើមានបញ្ហាកាន់តែច្រើនបានកើតឡើង ពួកគេអាចមានឱកាសប្រសើរធ្វើឲ្យព្រះមហាក្សត្រអានលិខិតរបស់ពួកគេ និងទទួលបានការជ្រោមជ្រែងពិសេសពីព្រះអង្គ» (១៩៩៧: ២៥៣) ។ ការចូលរួមជាមួយរាជាធិបតេយ្យអាស្រ័យបណ្តាញ អាចទទួលបាននូវអត្ថប្រយោជន៍គួរឲ្យកត់សម្គាល់តាំងពីការបង្កើនកិត្តិសព្ទ ដើម្បីរំពឹងទុកនូវការតម្លើងឋានៈ និងការបង្កើននូវលទ្ធភាពក្នុងការទទួលបាននូវព័ត៌មាននិងអំណាចផងដែរ ។

លោក ហេវីសុន បានកត់សម្គាល់ថា ព្រះមហាក្សត្របានអះអាងខ្លួនព្រះអង្គជា «ព្រះមហាក្សត្រជ្រើសតាំង» ហើយបានស្នើឡើងថា ប្រជានុរាស្ត្រអាចទម្លាក់ព្រះអង្គចេញពីព្រះរាជបល្ល័ង្កបាន ប្រសិនបើពួកគេមិនពេញចិត្ត (១៩៩៧ : ៦០) ។ រាជាធិបតេយ្យអាស្រ័យបណ្តាញផ្អែកលើភាពស្របច្បាប់ផ្សេងៗជាច្រើន រួមទាំងប្រជាប្រិយភាពដ៏ធំធេងរបស់រាជាធិបតេយ្យ ដែលផ្តល់ឲ្យព្រះរាជវាំងនូវសិទ្ធិពិសេសក្នុងការធ្វើអន្តរាគមន៍បន្ថែមលើរដ្ឋធម្មនុញ្ញក្នុងដំណើរការនយោបាយ ។ ព្រះមហាក្សត្របញ្ជាក់អះអាងអំពី «សិទ្ធិពិសេស» ពីសំណាក់ប្រជានុរាស្ត្រ ដែល

ជាសិទ្ធិមានអានុភាពជាងសិទ្ធិរបស់មេដឹកនាំនយោបាយទទួលបានពីការបោះឆ្នោតទៅទៀត ។ ព្រះអង្គមានការគោរពតិចតួចចំពោះអ្វីដែលលោក ម៉ូរ៉េល្ល និង ជ័យអនន្ត បានហៅថា «ដំណើរការតំណាងសំឡេងនយោបាយ» (ម៉ូរ៉េល និង ជ័យអនន្ត ១៩៨១: ២៧១) ។ ដូចដែលលោក ហេវីសុន បានធ្វើការវែកញែក រាជាធិបតេយ្យ «មិនបានបង្ហាញអំពីការប្តេជ្ញាចិត្តណាមួយក្នុងកំណែទម្រង់ប្រជាធិបតេយ្យនោះទេ» (១៩៩៧: ៦៣) ។ ដំណើរការកែទម្រង់នយោបាយនាទសវត្សរ៍ឆ្នាំ ១៩៩០ មានអានុភាពធ្វើឲ្យអន្តរាយដល់សិទ្ធិពិសេសរបស់ព្រះមហាក្សត្រ ។ នៅពេលណានយោបាយបោះឆ្នោតនៅក្នុងប្រទេសថៃ មានលក្ខណៈពុករលួយ ប្រឡូកប្រឡាក់ និងមិនល្អឥតខ្ចោះ ព្រះមហាក្សត្រមានសិទ្ធិអំណាចបដិសេធភ្លាមៗ ។ ហើយជាទីបញ្ចប់ ព្រះមហាក្សត្របានប្រទាននូវដំណោះស្រាយបញ្ហា ដែលអនុញ្ញាតឲ្យរាជអាណាចក្រថៃអាចរកផ្លូវចេញបាន ពេលមានភាពរឹកវរខាងនយោបាយ ។ ប៉ុន្តែប្រសិនបើប្រទេសថៃបានពង្រឹងប្រព័ន្ធនយោបាយរបស់ខ្លួនដោយជោគជ័យ និងបានបង្កើតយន្តការស្ថាប័នផ្សេងៗទៀត ដើម្បីគ្រប់គ្រងវិបត្តិនិងធានាស្ថិរភាព នោះតួនាទីពិសេសរបស់រាជាធិបតេយ្យនឹងត្រូវបានកាត់បន្ថយជាក់ជាមិនខាន ។ និយាយម្យ៉ាងវិញទៀត ព្រះរាជវាំងមានក្តីរំពឹងថា នឹងបានផលចំណេញមួយផ្នែកពីការរក្សារបៀបរបបនយោបាយ ដែលដំណើរការណ៍មិនច្បាស់លាស់ ដែលគ្រាន់តែអនុញ្ញាតនូវអន្តរាគមន៍មានកម្រិតត្រឹមត្រូវមួយរបស់រាជាធិបតេយ្យ ដើម្បីរក្សានូវកិត្តិសព្ទនៃព្រះមហាក្សត្រតែប៉ុណ្ណោះ ។ ព្រះមហាក្សត្រឯកភាពទៅនឹងទស្សនៈឯកភាពជាតិ ដែលពាក់ព័ន្ធនឹងការសម្រុះសម្រួល (ហេវីសុន ១៩៩៧: ៦៥) ជាជាងដំណោះស្រាយឲ្យដាច់ស្រឡះនូវបញ្ហាវិវាទផ្សេងៗ ។ ករណីនេះបានបង្ហាញតាមរយៈការលើកលែងទោសនៃព្រះមហាក្សត្រ ចំពោះអ្នកជាប់ពាក់ព័ន្ធនឹងបាតុកម្មខែឧសភា ឆ្នាំ ១៩៩២ ដែលធ្វើឲ្យការស៊ើបអង្កេតយ៉ាងត្រឹមត្រូវចំពោះឧក្រិដ្ឋកម្មភាគច្រើន ដែលប្រព្រឹត្តដោយទាហាន ត្រូវអាក់ខាន ។ ដូចដែលមេដឹកនាំប្រឆាំង លោក ចម្លង ស្រីមឿង[១១] (จำลอง ศรีเมือง Chamlong Srimuang) បាននិយាយបន្ទាប់ពីការស្តីឲ្យរបស់ព្រះមហាក្សត្រនាថ្ងៃទី ២០ ខែឧសភា ឆ្នាំ ១៩៩២ មក «នៅពេលដែលព្រះអង្គទ្រង់មានព្រះរាជតម្រាស់ អ្នកត្រូវតែឱនក្បាលនិងអនុវត្តព្រះរាជតម្រាស់នេះ» (មតិជន ២២ ឧសភា ១៩៩២) ។ រាជាធិបតេយ្យអាស្រ័យបណ្តាញមានការពាក់ព័ន្ធជាមួយនឹងនយោបាយប្រកបដោយល្បិចដោះខ្លួននិងមិនច្បាស់លាស់ ហើយបានលើកព្រះរាជសកម្មភាពរបស់ព្រះមហាក្សត្រ ឲ្យស្ថិតនៅពីលើការរិះគន់របស់មហាជនទូទៅ ។ ទិដ្ឋភាពសំខាន់មួយរបស់រាជាធិបតេយ្យអាស្រ័យបណ្តាញ គឺបញ្ហាភាសាដូចដែលបានបង្ហាញនៅក្នុងសុន្ទរកថាខែកុម្ភៈ ឆ្នាំ ២០០៥ របស់លោក ប្រេម ថា ជាសំខាន់ណាស់ដែរ ដែលការពិភាក្សាជាសាធារណៈបានប្រើប្រាស់ភាសាដែលចេញជាបញ្ញត្តិនិងអនុម័តដោយព្រះមហាក្សត្រ ដើម្បីរៀបរាប់និងកំណត់នូវរឿងរ៉ាវនិងបញ្ហាផ្សេងៗ ។ ការត្រួតត្រារបស់ព្រះមហាក្សត្រដោយភាសា គឺជាទម្រង់សំខាន់មួយនៃអំណាចនយោបាយ និងត្រូវបានថ្លែងនៅក្នុងព្រះរាជសុន្ទរកថាជាប្រក្រតី ជាពិសេស គឺព្រះរាជសុន្ទរកថារៀងរាល់ថ្ងៃទី ៤ ខែធ្នូ មួយថ្ងៃមុនថ្ងៃចម្រើនព្រះជន្មព្រះមហាក្សត្រ ។ សុន្ទរកថាដូចនេះ «បានក្លាយជាគោលការណ៍ឯកភាពជានិរន្តរ៍និងជាសេចក្តីត្រូវការមនុស្សល្អសម្រាប់ដឹកនាំប្រទេស» (បេកឺរ (Baker) និង ផាសុក ២០០៥: ២៣៧) ។

ចាប់តាំងពីឆ្នាំ ១៩៨០ មក មេដឹកនាំរាជាធិបតេយ្យអាស្រ័យបណ្តាញរបស់រាជអាណាចក្រថៃ គឺលោក ប្រេម តិណសូលានន្ទ ។ លោក ប្រេម បានជ្រើសតាំងយ៉ាងប្រុងប្រយ័ត្នដោយព្រះមហាក្សត្រ ឲ្យធ្វើជាមេបញ្ជាការកងទ័ព និងក្រោយមកជានាយករដ្ឋមន្ត្រី ។ ការឡើងឋានៈជានាយករដ្ឋមន្ត្រីរបស់លោក ប្រេម ហាក់ដូចជាធ្វើតាម

លក្ខណៈប្រជាធិបតេយ្យ ប៉ុន្តែការពិត គឺជា «រដ្ឋប្រហារដោយព្រះមហាក្សត្រ» វិញ[១២] ។ លោក ប្រេម មិនអាចជំនួសតំណែងរបស់លោក ស្ងួត ជាទីស្រឡាញ់របស់ព្រះអង្គបានទេ ប៉ុន្តែ ព្រះមហាក្សត្របានប្រទានការទុកព្រះរាជហឫទ័យចំពោះលោក ប្រេម យ៉ាងជាច់អហង្ការ ដោយទតឃើញលោក ប្រេម ជាមេដឹកនាំសំខាន់ស្មោះត្រង់មួយរូប ដែលបានចែករំលែកនូវវិធីសាស្ត្រទន់ជ្រាយនិងលាក់លៀមរបស់ទ្រង់ តែក៏ជាអ្នកចេះកសាងនូវសម្ពន្ធភាពដ៏មានជំនាញ និងជាអ្នកចេះគ្រប់គ្រងការប្រព័ន្ធមេកម្លាំង ។ រយៈពេល ២១ ឆ្នាំបន្ទាប់មក លោក ប្រេម បានបម្រើការ អាចទុកដូចជា «ប្រធានគ្រប់គ្រងធនធានមនុស្ស» យ៉ាងមានប្រសិទ្ធភាពរបស់ប្រទេសថៃ ជាអ្នកផ្ដើមគំនិតចំពោះការតែងតាំង ការផ្ទេរ និងការតម្លើងឋានៈ ។ អំណាចរបស់លោក ប្រេម មិនដែលមានលក្ខណៈផ្ដាច់ការទេ ទោះបីជាគាត់មានអំណាចសម្បើមក៏ដោយ ។ លោក ប្រេម កាន់តំណែងជានាយករដ្ឋមន្ត្រីរហូតដល់ឆ្នាំ ១៩៨៨ ហើយបន្ទាប់មក ភ្លាមៗ បានក្លាយជាសមាជិកគណៈអង្គមន្ត្រី (គឺជាគណៈទីប្រឹក្សានៃព្រះរាជា) មានឋានៈជារដ្ឋបុរស ហើយបានទទួលតំណែងជាប្រធាននៃគណៈអង្គមន្ត្រីនៅក្នុងឆ្នាំ ១៩៩៨ ។ នៅខែមេសា ឆ្នាំ ១៩៨១ ព្រះមហាក្សត្រនិងព្រះរាជិនីបានអមដំណើរលោក ប្រេម ទៅខេត្តគោរាជ (នគររាជសីមា) ដើម្បីបង្ហាញនូវការគាំទ្ររបស់ទ្រង់ទាំងពីរព្រះអង្គចំពោះលោក ប្រេម ក្នុងស្ថានការណ៍មានការប៉ុនប៉ងធ្វើរដ្ឋប្រហារ ហើយសូម្បីតែព្រះរាជិនីក៏បានធ្វើព្រះរាជប្រកាសតាមវិទ្យុគាំទ្រលោក ប្រេម ផងដែរ ។ ដូចដែលសាស្ត្រាចារ្យ កបកឿ បានវែកញែក ការគាំទ្ររបស់ព្រះមហាក្សត្រចំពោះលោក ប្រេម នៅក្នុងឆ្នាំ ១៩៨១ បានបង្ហាញដំណាក់កាលថ្មីមួយនៅក្នុងការវិវត្តនៃអភិបាលកិច្ចរាជាធិបតេយ្យ រាប់តាំងពីការចូលរួមនៅក្នុងនយោបាយទាំងអសកម្មនិងសកម្មពីមុនរបស់ព្រះអង្គមក ហើយព្រះមហាក្សត្របានចាប់ផ្ដើមដើរតួជា «អ្នកចូលរួមអនុវត្តជាមុន» (២០០២: ៦៧) ។ តាំងពីពេលនោះមក លោក ប្រេម និងព្រះរាជវាំង បានរក្សាសម្ពន្ធភាពដ៏រឹងមាំ ។ ភាពជាដៃគូនេះ មានគោលបំណងដើម្បីស្ដាបនាទម្រង់រាជរដ្ឋាភិបាល[១៣] ។ លោក ជ័យអនន្ត សមុទ្ទវណិជ្ជ[១៤] (ชัยอนันต์ สมุทวณิช Chai-Anan Samudavanija) បានពិពណ៌នាលោក ប្រេម ថា ជា «បុរសខ្លាំង» (១៩៩៧: ៥៦) ដោយគាត់បានកាន់តំណែងជាអ្នកធ្វើការជំនួសសម្រាប់ព្រះមហាក្សត្រផ្ទាល់ព្រះអង្គ ។

នៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ លោក ប្រេម និងរាជាធិបតេយ្យ គឺជាអ្នកទទួលផលដ៏ចម្បងពីប្រព័ន្ធពហុបក្សដែលពិបាកគ្រប់គ្រង ដែលបានអនុញ្ញាតឲ្យលោក ប្រេម និងរាជាធិបតេយ្យអាចរក្សាទុកនូវភាពមានអំណាចលើសគេ ។ លោក ប្រេម ប្រឹក្សាជាមួយព្រះមហាក្សត្ររៀងរាល់សប្ដាហ៍ បង្កើតជាទម្លាប់សម្រាប់មន្ត្រីថ្នាក់ខ្ពស់និងមេដឹកនាំនយោបាយជំនាន់ក្រោយ ។ នៅពេលដែលលោក ប្រេម បានជួបប្រទះការរិះគន់ជាច្រើន ចំពោះការធ្លាក់ចុះតម្លៃរូបិយវត្ថុបាទនៅក្នុងឆ្នាំ ១៩៨៤ មក ព្រះរដ្ឋទាយាទបានបើកយន្តហោះរបស់លោក ប្រេម ជូនគាត់ទៅកាន់ទីក្រុងបាងកក ហើយបន្ទាប់មក បានបើករាជរថដឹកគាត់ទៅកាន់វិមានរដ្ឋាភិបាល ដែលទាំងនេះ ដើម្បីបង្ហាញឲ្យឃើញអំពីការសព្វព្រះរាជហឫទ័យរបស់ព្រះមហាក្សត្រទៅលើលោក ប្រេម[១៥] ។ ជាការពិបាកពន្យល់ មេដឹកនាំបក្សប្រជាធិបតេយ្យ (គណបក្សប្រជាធិបតេយ្យ) លោក ពិជ័យ រ័ត្តកុល[១៦] (พิชัย รัตตกุล Pichai Ratakul) បានយល់ព្រមឲ្យលោក ប្រេម ស្ថិតនៅក្នុងតំណែងជានាយករដ្ឋមន្ត្រី បន្ទាប់ពីការបោះឆ្នោតឆ្នាំ ១៩៨៦ មក ។ នេះប្រហែលជាមានអន្តរាគមន៍ពីព្រះមហាក្សត្រ[១៧] ។ នៅទីបំផុត លោក ប្រេម បានធ្លាក់ពីអំណាចនៅក្នុងឆ្នាំ ១៩៨៨ បន្ទាប់ពីចំណាយអស់រយៈពេល ៨ ឆ្នាំក្នុងមុខតំណែង «ដោយតស៊ូដើម្បីរក្សានូវអំណាច និងការពាររាជាធិ-

*បតេយ្យ»[១៨] ។ នៅក្នុងដំណាក់កាលសំខាន់នីមួយៗ ដូចជាឆ្នាំ ១៩៨០, ១៩៨៣ និង ១៩៨៦ ការគាំទ្ររបស់ព្រះមហាក្សត្រ គឺជាគន្លឹះដើម្បីរក្សាតំណែងជានាយករដ្ឋមន្ត្រីរបស់គាត់ ។ ក្នុងរយៈពេលនេះ លោក ប្រេម ដើរតួជាឈ្នួញកណ្ដាល ជាអ្នកហេតុការណ៍និយម ដែលមានឆន្ទៈក្នុងការធ្វើដំណោះស្រាយណាមួយដែលអាចតម្កើងផលប្រយោជន៍ រូបភាព និងឥទ្ធិពលរបស់ព្រះរាជវាំង ។ គុណភាពទាំងនេះបានធ្វើឲ្យលោក ប្រេម ក្លាយជាតំណាងព្រះមហាក្សត្រដ៏ល្អវិសេសវិសាល និងជាស្ថាបត្យករនៃរាជាធិបតេយ្យអាស្រ័យបណ្ដាញ ។*

*រយៈពេលពីឆ្នាំ ១៩៨៨ ដល់ ១៩៩២ គឺជារយៈពេលមួយពិបាកដោះស្រាយសម្រាប់ព្រះរាជវាំង ។ មេដឹកនាំគណបក្សជាតិថៃ (ឆាតថៃ) លោក ជាតិជាយ ជុណ្ហៈវ័ណ*[១៩] (ชาติชาย ชุณหะวัณ Chatchai Choonhawan) *ដែលជាអ្នកស្នងតំណែងជានាយករដ្ឋមន្ត្រីបន្ទាប់ពីលោក ប្រេម គឺជាមនុស្សដែលមានគំនិតឯករាជ ។ លោក ជាតិជាយ បានព្យាយាមរុះរើម៉ាស៊ីនដែលព្រះមហាក្សត្រនិងលោក ប្រេម បានបង្កើតឡើង[២០] ។ លោក ហេវីសុន លើកឡើងថា ព្រះមហាក្សត្រចាត់ទុកលោក ជាតិជាយ ថា គ្មានលទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋាភិបាល ។ លោក ហេវីសុន ក៏គិតថា ព្រះរាជវាំងបានគាំទ្ររដ្ឋប្រហារទម្លាក់រដ្ឋាភិបាលនេះ ហើយសូម្បីតែព្រះមហាក្សត្រក៏បានប្រទានការអនុញ្ញាតចំពោះអ្នកបង្កើតរដ្ឋប្រហារជាមុនផងដែរ (១៩៩៧ : ៧០) ។ ជាការពិត ការរិះគន់របស់អ្នកបង្កើតរដ្ឋប្រហារ ដូចជា កម្រិតនៃអំពើពុករលួយ និងការកកើតនូវ «អំណាចផ្ដាច់ការរបស់រដ្ឋសភា» គឺត្រូវរ៉ូវនឹងការឃោសនារបស់ព្រះមហាក្សត្រ ។ ព្រះមហាក្សត្របានគាំទ្រជាសាធារណៈនូវរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩១ ដែលពោរពេញទៅដោយបញ្ហា ។ ការប្រឆាំងតវ៉ាទៅនឹងសេចក្ដីព្រាងច្បាប់រដ្ឋធម្មនុញ្ញថ្មី បានកើតឡើងនៅក្នុងទីក្រុងបាងកកក្នុងអំឡុងខែវិច្ឆិកា ឆ្នាំ ១៩៩១ ពីព្រោះតែរដ្ឋធម្មនុញ្ញនេះបានអនុញ្ញាតឲ្យអ្នកដែលមិនមែនជាតំណាងរាស្ត្រ ឡើងជានាយករដ្ឋមន្ត្រី ។ ប៉ុន្តែ ការរិះគន់របស់មហាជនទូទៅអំពីសេចក្ដីព្រាងច្បាប់នេះ ត្រូវបានបញ្ឈប់នៅពេលដែលព្រះមហាក្សត្របានថ្លែងព្រះរាជសុន្ទរកថាក្នុងពិធីចម្រើនព្រះជន្មនាខែធ្នូ ដោយសុំកុំឲ្យប្រជានុរាស្ត្រមានយោបល់ខ្វែងគ្នាចំពោះរដ្ឋធម្មនុញ្ញ ដែលគេអាចនឹងធ្វើវិសោធនកម្មនាពេលក្រោយ (ម៉ាក់ខារហ្គូ ១៩៩៧: ២៤១) ។ តាមការពិត ព្រះមហាក្សត្រ គឺជាអ្នកទទួលផលចំណេញចម្បងបំផុតពីរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩១ ដែលបង្កើនអំណាចរបស់ព្រះអង្គតាមវិធីផ្សេងៗ ជាច្រើន ។*

*ព្រះរាជវាំងមិនបានស្មានប្រមាណជាមុននូវការតវ៉ាដែលបានកើតឡើងនៅខែឧសភា ឆ្នាំ ១៩៩២ ។ អន្តរាគមន៍យ៉ាងយឺតយ៉ាវ និងធ្វើឡើងដោយស្រពេចស្រពិលរបស់ព្រះមហាក្សត្រ ដែលបានបញ្ចប់ជម្លោះបង្ហូរឈាមគ្នា និងបណ្ដាលឲ្យលោក សុចិន្ដា គ្រាប្រយូរ*[២១] (สุจินดา คราประยูร Suchinda Kraprayoon) *លាលែងពីតំណែងនាយករដ្ឋមន្ត្រី បានប្រែក្លាយទៅជាជ័យជំនះសម្រាប់រាជាធិបតេយ្យ ។ ក៏ប៉ុន្តែ ពុំដែលមានការពន្យល់ឲ្យបានក្បោះក្បាយគួរឲ្យទុកចិត្ត អំពីការពន្យារពេលធ្វើសកម្មភាពរបស់ព្រះមហាក្សត្ររយៈពេល ៣ ថ្ងៃនោះទេ[២២] ។ មូលហេតុសមស្របបំផុត គឺភាពភ័យខ្លាចរបស់ព្រះមហាក្សត្រថា លោក សុចិន្ដា នឹងបដិសេធមិនសុខចិត្តលាលែងពីតំណែង ។ ប្រាកដណាស់ លោក សុចិន្ដា មិនលាលែងពីតំណែងភ្លាមៗ នោះទេ បន្ទាប់ពីត្រូវព្រះមហាក្សត្រស្ដីឲ្យនៅពេលគាត់ឡើងទៅគាល់ព្រះរាជា ហើយដែលគេបានផ្សាយតាមកញ្ចក់ទូរទស្សន៍មក ប៉ុន្តែគាត់បានរង់ចាំអស់រយៈពេល ៤ ថ្ងៃទៀត ។ ដូចដែលសាស្ត្រាចារ្យ កបកឿ បានលើកឡើង នៅពេលដែលព្រះមហាក្សត្រមានព្រះរាជសកម្មភាព ជាការចាំបាច់ណាស់ដែលអន្តរាគមន៍ព្រះអង្គត្រូវតែទទួលបានជោគជ័យ (២០០៣: ១៧៩) ។*

*ថ្មីបើទស្សនៈទូទៅអំពើហិង្សាខែឧសភា ឆ្នាំ ១៩៩២ បានផ្ដល់សញ្ញាណថា ដល់ពេលត្រូវបញ្ឈប់ការពឹងពាក់លើយោធានិងរាជាធិបតេយ្យហើយ ហើយបានគូសបញ្ជាក់នូវតម្រូវការសម្រាប់ដំណើរការកំណែទម្រង់រដ្ឋធម្មនុញ្ញ និងនយោបាយឲ្យបានហ្មត់ចត់ក៏ដោយ ក៏ភស្តុតាងទាំងអស់បង្ហាញថា ព្រះមហាក្សត្រផ្ទាល់ព្រះអង្គមិនបានឈ្វេងយល់ពីបញ្ហានេះទេ*[២៣] ។

*អន្តរាគមន៍លើកទី ២ របស់ព្រះមហាក្សត្រនាឆ្នាំ ១៩៩២ គឺការតែងតាំងលោក អានន្ទ ប័ន្យារជុន ជានាយករដ្ឋមន្ត្រីស្ដីទី នាខែមិថុនា បានបង្ហាញពីកិត្តិសព្ទកើនឡើងរបស់រាជបល្ល័ង្ក ។ ការតែងតាំងនេះ ហាក់បីដូចជាតួយ៉ាងនៃការកើនឡើងអំណាចរបស់រាជាធិបតេយ្យ និងអារម្មណ៍មិនពេញចិត្តពីសំណាក់មហាជនចំពោះគណបក្សនិងស្ថាប័ននយោបាយមួយចំនួន (កបកឿ ២០០២: ៦៥) ។ នៅពេលដែលគណបក្សប្រជាធិបតេយ្យរបស់លោក ឈួន លីកភ័យ*[២៤] (ชวน หลีกภัย Chuan Leekpai) *ដែលអាចទុកចិត្តបាន និងប្រកបដោយការប្រុងប្រយ័ត្ន បានបង្កើតស្នូលនៃរដ្ឋាភិបាលនៅខែកញ្ញា ឆ្នាំ ១៩៩២ (ជាជាងគណបក្សពលំធម្ម (ផៈឡាំងថាំ) របស់លោក ចម្លង ស្រីមឿង ដែលចេះតែបង្កបញ្ហាស្មុគស្មាញ) ជន្ទះនៃព្រះមហាក្សត្រហាក់ដូចជាបានសម្រេច ។ លោក ឈួន លីកភ័យ បានប្រកាសជាសាធារណៈនៅក្នុងសុន្ទរកថានាយុទ្ធនាការខែកញ្ញាឆ្នាំ ១៩៩២ ថា គាត់បានទាក់ទងនឹងលោក ប្រេម នាថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ១៩៩២ ដើម្បីសុំឲ្យគាត់ពឹងព្រះមហាក្សត្រធ្វើអន្តរាគមន៍បញ្ឈប់អំពើហិង្សាពាក់ព័ន្ធនឹងការតវ៉ាប្រឆាំងលោក សុចិន្តា*[២៥] ។ *អត្ថបទរបស់កាសែត* **ខាវភិសេត** *(ข่าวพิเศษ «ដំណឹងពិសេស») ដែលបានបោះពុម្ពបន្ទាប់ពីការបោះឆ្នោត បានវែកញែកថា ក្រុមប្រជាធិបតេយ្យបានទទួលជ័យជំនះ ពីព្រោះពួកគេបានប្រើប្រាស់ដោយជោគជ័យនូវការគាំទ្រនិងហិរញ្ញវត្ថុ ពីក្រុមស្មោះស្ម័គ្រចំពោះលោក អានន្ទ ពីមុន ដែលរួមមានទាំងសមាគមពាណិជ្ជកម្ម មន្ត្រីរដ្ឋាភិបាល និងបញ្ញវន្តផ្សេងៗ (***ខាវភិសេត** *២៥ កញ្ញា–១ តុលា ១៩៩២; សុរិន្ទ្រ ១៩៩២: ៤៣) ។ អត្ថបទនេះបានថ្លែងបញ្ជិតបញ្ជៀងថា ព្រះរាជវាំងបានគាំទ្រពួកប្រជាធិបតេយ្យជាសម្ងាត់ ។ នៅក្នុងយុទ្ធនាការនាតំបន់ភាគខាងត្បូង លោក ឈួន បានប្រៀបធៀបខ្លួនគាត់ទៅនឹងលោក ប្រេម ហើយសូមឲ្យអ្នកបោះឆ្នោតគាំទ្រខ្លួនជារដ្ឋមន្ត្រីលើកទី ២ ដែលកើតនៅភាគខាងត្បូង (លោក ប្រេម ធ្លាប់ជានាយករដ្ឋមន្ត្រីលើកទី ១ ដែលកើតនៅភាគខាងត្បូងដែរ) ។*

*អំពើហិង្សាខែឧសភា ឆ្នាំ ១៩៩២ បានបន្សល់ទុកឲ្យព្រះមហាក្សត្រនូវតំណែងយ៉ាងពិតប្រាកដ ។ ព្រះអង្គបានក្លាយជាព្រះអាជ្ញាកណ្ដាលនយោបាយជាន់ខ្ពស់ បន្ទាប់ពីទទួលបានជោគជ័យប្រផិតប្រផើយក្នុងការដោះស្រាយវិបត្តិ ។ ប៉ុន្តែអន្តរាគមន៍នេះ ក៏បានបង្ហាញនូវកម្រិតដ៏ខ្ពស់នៃអំណាចរបស់ព្រះអង្គ ។ ការគាំទ្រដ៏មុឺងម៉ាត់របស់ព្រះអង្គចំពោះពលទាហាន បានបញ្ជាក់ឲ្យឃើញអំពីការយោគយល់ហួសសម័យនៃលំដាប់ថ្នាក់សង្គមនិងនយោបាយថៃ ។ រយៈកាលមានវិបត្តិឆ្នាំ ១៩៩១–៩២ បានធ្វើឲ្យតួអង្គនយោបាយសំខាន់ៗ មួយចំនួនរាងចាលចិត្ត ។ អ្នកចាញ់មានទាំងអតីតនាយករដ្ឋមន្ត្រី ជាតិជាយ ជុណ្ហៈវ័ណ ទីប្រឹក្សារបស់លោកជាច្រើនដែលដឹកនាំដោយលោក ពាន់សក្ដិ វិញ្ញរ័ត*[២៦] (พันศักดิ์ วิญญูรัตน์ Pansak Vinyarat) *ហើយនិងអតីតអភិបាលក្រុងបាងកកនិងមេដឹកនាំការប្រឆាំងគឺ លោក ចម្លង ស្រីមឿង ផងដែរ ។ មិនមែនជាការគាប់ជួននោះទេ ដែលលោក ពាន់សក្ដិ និង ចម្លង ក្រោយមកបានចូលរួមកម្លាំងជាមួយនឹងលោក ទក្សិណ ជិនវ័ត្រ រួមជាមួយនឹងអតីតសកម្មជននិស្សិត និងសមាជិកគណបក្សកុម្មុយនិស្តពីទសវត្សរ៍ឆ្នាំ ១៩៧០ ។ សម្រាប់ពួកគេទាំងអស់គ្នា រាជាធិបតេយ្យអាស្រ័យបណ្ដាញ គឺជាផ្នែកមួយនៃបញ្ហារបស់នយោបាយថៃ ជាជាងផ្នែកដំណោះស្រាយមួយ ។ បន្ទាប់ពីខែឧសភា ឆ្នាំ ១៩៩២ មក*

ប្រព័ន្ធថ្មីនៃអភិបាលកិច្ចរាជាធិបតេយ្យ ត្រូវបានគេកែលំអឡើងវិញឲ្យទៅជាប្រព័ន្ធមួយមិនសូវផ្តោតលើសកម្មភាពផ្ទាល់ទេ ។ អ្នករាជានិយមមួយចំនួន ដូចជា លោក អានន្ទ័ និងលោក ប្រវេស ធ្វើការយ៉ាងមមាញឹកក្នុងការបង្កើតឡើងវិញនូវរាជាធិបតេយ្យអាស្រ័យបណ្តាញ ឲ្យមានលក្ខណៈសេរីជាងមុន ដោយមិនឲ្យជាប់គាំងដោយទាហាន និងការិយាល័យាធិបតេយ្យហួសសម័យ ដើម្បីឲ្យមានស្ថិរភាពនិងរបៀបរៀបរយ ។ បើប្រៀបធៀបជាមួយនឹងមនុស្សជំនិតជាច្រើនរបស់ព្រះមហាក្សត្រ លោក អានន្ទ័ និងលោក ប្រវេស គឺជាអ្នកសេរីនិយម ប៉ុន្តែបើនិយាយឲ្យប្រាកដ លោកទាំង ២ នាក់ក៏ជាអ្នកអភិរក្សនិយមដ៏ខ្លាំងក្លាដែរ ។ អស់រយៈពេល ៩ ឆ្នាំបន្ទាប់មក ព្រះមហាក្សត្រ និងសម្ពន្ធមិត្តរបស់ព្រះអង្គ បានកែលំអគំរូថ្មីមួយឲ្យមានលក្ខណៈប្រសើរជាងមុន ដោយបន្ថយការទាក់ទងផ្ទាល់របស់ព្រះអង្គ ដោយទ្រង់បានធ្វើការតាមរយៈលោក ប្រេម លោក ឈួន និងអ្នកផ្សេងទៀតជំនួស ដើម្បីរៀបចំគោលដៅរបស់ប្រទេស ។ អត្ថបទនៅក្នុងសារព័ត៌មាន **ណែវណា** (แนวหน้า «ជួរមុខ») ឆ្នាំ ១៩៩៣ បានបង្ហាញយ៉ាងល្អអំពីទំនាក់ទំនងរវាងលោក ប្រេម និងរដ្ឋាភិបាលដំបូងរបស់លោក ឈួន លីកភ័យ នាឆ្នាំ ១៩៩២-៩៥ ៖

> ទោះបីជាគ្មានការបង្ហាញជាផ្លូវការទេ មនុស្សម្នាក់ៗ អាចឃ្លាំមើលឧត្តមសេនីយ៍ ប្រេម តិណសូលានន្ទ បាន ... ពីព្រោះប្រសិនបើយើងក្រឡេកមើលឲ្យកាន់តែច្បាស់ ចាប់តាំងពីពេលដែលរដ្ឋាភិបាល ឈួន ឡើងកាន់តំណែងមក លោក ប្រេម គឺជាមនុស្សសំខាន់ ដែលគណបក្សប្រជាធិបតេយ្យផ្តល់ការគោរពនិងសុំដំបូន្មានជាបន្តបន្ទាប់ ។ គ្មាននរណាអាចបដិសេធថា រាល់ការផ្ទេរនិងតម្លើងឋានន្តរស័ក្តិចំពោះនាយទាហាន ត្រូវតែពិនិត្យដោយលោក ប្រេម មុននឹងប្រកាសជាសាធារណៈ ។ (រ៉ាយង៉ានណែវណា [รายงานแนวหน้า] «របាយការណ៍ណែវណា» គ.ស. ១៩៩៣ ។)

ករណីនេះមិនមែនចង់និយាយថា ព្រះមហាក្សត្រ ឬលោក ប្រេម ចូលចិត្តលោក ឈួន ឬក៏រដ្ឋាភិបាលប្រជាធិបតេយ្យ ដែលពួកគេបានផ្តល់នូវមុខមាត់ថ្មី «ដែលអាក្រក់តិចតួចបំផុត» សម្រាប់សណ្តាប់ធ្នាប់នយោបាយថៃនោះទេ ។ ហើយករណីនេះ ក៏មិនចង់មានន័យថា តួនាទីក្រៅឆាករបស់លោក ប្រេម អាចធានានូវស្ថិរភាពរបស់រដ្ឋាភិបាល ឈួន បានដែរ ។ នាខែធ្នូ ឆ្នាំ ១៩៩៤ រដ្ឋាភិបាលចម្រុះដឹកនាំដោយលោក ឈួន លីកភ័យ ប្រធានគណបក្សប្រជាធិបតេយ្យ បានដួលរលំនៅដោយហេតុថា គណបក្ស «ក្តីសង្ឃឹមថ្មី» (พรรคความหวังใหม่ New Aspiration Party) របស់លោក ជវលិត យ៉ុងចៃយុទ្ធ[២៧] (ชวลิต ยงใจยุทธ Chavalit Yongchaiyudh) ដែលជាដៃគូដ៏ធំបំផុត បានដកខ្លួនចេញដើម្បីប្រឆាំងតវ៉ាអំពីកំណែទម្រង់រដ្ឋាភិបាលក្នុងស្រុក ដែលពោរពេញទៅដោយភាពចម្រូងចម្រាស[២៨] ។ ការរំលាយរដ្ឋសភា ទំនងជាមិនអាចជៀសរួច តែគណបក្សជាតិពត្ថនា (ឆាតផាត់ថៈណា Chart Pattana) របស់លោក ជាតិជ័យ ជុណ្ហៈវ័ណ ដែលធ្លាប់បានបដិសេធមិនជួយធានាចំពោះពួកប្រជាធិបតេយ្យ បានជំនួសតំណែងគណបក្សក្តីសង្ឃឹមថ្មី បានធ្វើឲ្យលោក ឈួន កាន់តំណែងរយៈពេល ៦ ខែទៀត ។ អគ្គលេខាធិការរបស់គណបក្សប្រជាធិបតេយ្យ និងអ្នកកែលំអនយោបាយ លោក ស្ណាន់ ខចរប្រសាសន៍[២៩] (สนั่น ขจรประศาสน์ Sanan Kachornprasat) បានអះអាងថា គាត់បានផ្តួចផ្តើមការទាក់ទងនេះដោយពុំបានជម្រាបលោក ឈួន ហើយបានព្រលយពាក្យថា មានមនុស្សសំខាន់នៅក្នុងសង្គមថៃបានជំរុញគាត់ឲ្យធ្វើដូច្នេះ (គជសីហ៍ ១៩៩៤)[៣០] ។ មនុស្សជាច្រើនជឿជាក់ថា លោក ប្រេម បានគ្រោងរៀបចំនូវការតម្រែតម្រង់រួបរួមគ្នា ដើម្បីផ្គាប់ផ្គុនព្រះមហាក្សត្រ ដោយសារតែមិនជឿជាក់លើលោក ជវលិត ទើបព្រះអង្គបែរទៅសព្វព្រះរាជហឫទ័យនឹងលោក ឈួន វិញ[៣១] ។

នៅពេលលោក ឈួន ត្រូវបង្ខំឲ្យចុះចេញពីតំណែងនៅក្នុងខែឧសភា ឆ្នាំ ១៩៩៥ ដំណាក់កាលលំបាកមួយផ្សេងទៀតបានបន្តកើតឡើង ។ ព្រះមហាក្សត្រទ្រង់មានការព្រួយព្រះហឫទ័យយ៉ាងខ្លាំងចំពោះរដ្ឋាភិបាលរបស់លោក បន្ហារ សិល្បអាជា[៣២] (บรรหาร ศิลปอาชา Banharn Silp-archa) ដែលបានបង្កើតឡើង ស្របពេលជាមួយនឹងការសោយទិវង្គតព្រះវររាជមាតាព្រះអង្គ ។ រដ្ឋាភិបាល បរហារ គឺជាតថភាពផ្នែកនយោបាយដែលត្រូវបានគេពន្យារ គឺជាការឡើងកាន់តំណែងនាយករដ្ឋមន្ត្រីរបស់អ្នកជំនួញចិនថ្នាក់ទាបមកពីខេត្តក្រៅ ។ នៅពេលគេកំណុងគ្រោងទុករៀបចំពិធីបុណ្យព្រះសពរបស់ព្រះវររាជមាតាយ៉ាងអឹកធឹក ព្រះមហាក្សត្របានបង្ហាញព្រះភក្ត្រតាមរយៈកញ្ចក់ទូរទស្សន៍ស្ទើរតែរាល់យប់ក្នុងអំឡុងខែសីហា ឆ្នាំ ១៩៩៥ ហើយបានបរិហារចំពោះអ្នកនយោបាយអំពីការស៊ីសំណូក និងការកេងចំណេញផ្ទាល់ខ្លួន ។ បញ្ហាចរាចរនិងទឹកជំនន់នៅក្នុងទីក្រុងបាងកក គឺបញ្ហារិះគន់ពីរយ៉ាងរបស់ព្រះអង្គ ចំពោះអ្នកនយោបាយពុករលួយ ប៉ុន្តែនៅពីក្រោយការរិះគន់នោះ គឺជាភាពភ័យខ្លាចនិងភាពស្អប់ខ្ពើមមហិច្ឆតាអ្នកទាំងនោះ ។ ការឡើងបុណ្យស័ក្តិរបស់លោក បរហារ បានបញ្ជាក់ឲ្យឃើញថា រាជាធិបតេយ្យខ្វះអំណាច ដើម្បីរារាំងអ្នកនយោបាយបែបនោះ កុំឲ្យក្លាយជានាយករដ្ឋមន្ត្រី ។ តែទោះជាយ៉ាងនេះក្តី រាជាធិបតេយ្យមិនស្ទាក់ស្ទើរក្នុងការទម្លាក់នាយករដ្ឋមន្ត្រីជាប់ឆ្នោត ដែលខ្លួនមិនពេញចិត្តនោះទេ ហើយថែមទាំងបានផ្សំគំនិតបណ្តេញនាយករដ្ឋមន្ត្រីទាំងនោះ ចេញពីតំណែងអស់ប្រហែល ៣ ឬ ៤ នាក់រួចមកហើយ[៣៣] ។

# រាជាធិបតេយ្យអាស្រ័យបណ្ដាញ និងវិបត្តិភាពស្របច្បាប់ចាប់តាំងពីឆ្នាំ ១៩៩២

ប្រទេសថៃបានជួបប្រទះវិបត្តិនយោបាយធំៗ ចំនួន ៣ ចាប់ពីឆ្នាំ ១៩៩២ មក ។ វិបត្តិទាំងបីនេះ គឺជាវិបត្តិភាពស្របច្បាប់ផ្នែកនយោបាយ ។ ដំបូងបំផុត គឺវិបត្តិភាពស្របច្បាប់នៃរដ្ឋាភិបាលលោក ជវលិត បន្ទាប់ពីមានការបន្ទយតម្លៃប្រាក់បាទនៅខែកក្កដារួចមក ។ តើរដ្ឋាភិបាលមួយអាចបន្តការងាររបស់ខ្លួនបានយ៉ាងដូចម្តេច បើនៅពេលដែលខ្លួនឡើងកាន់អំណាច ចំពេលដែលវិបត្តិសេដ្ឋកិច្ចអាស៊ីកើតឡើងយ៉ាងដូច្នេះ ? វិបត្តិទី ២ គឺរឿងក្តីប្រកាសទ្រព្យសម្បត្តិរបស់លោក ទក្សិណ ឆ្នាំ ២០០១ ដែលវិះនឹងធ្វើឲ្យលោកនាយករដ្ឋមន្ត្រីជាប់ឆ្នោតថ្មីៗ រូបនេះ ត្រូវគេហាមឃាត់មិនឲ្យធ្វើនយោបាយរហូតដល់ចំនួនប្រាំឆ្នាំឯណោះ ។ គំនិតនៃភាពស្របច្បាប់ខាងការបោះឆ្នោត បានល្បងកម្លាំងគ្នាទល់នឹងបញ្ញត្តិរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៧ ដែលក្នុងនោះ បុគ្គលមានអំណាចត្រូវតែជាមនុស្សថ្លៃថ្នូរគោរព «ច្បាប់ល្បែងកីឡា» (rules of the game) ។ វិបត្តិទី ៣ គឺជាការដួលរលំនៃភាពស្របច្បាប់របស់រដ្ឋនៅក្នុងខេត្តជាយដែននៅភាគខាងត្បូង នាឆ្នាំ ២០០៤ ។ វិបត្តិទី ៣ នេះ គឺជាពេលដំបូងបង្អស់ក្នុងពេលជាច្រើនទសវត្សរ៍ ដែលក្រុងបាងកកបានបាត់បង់ការត្រួតត្រាលើអាណាខេត្តសំខាន់ៗ របស់ប្រទេស ។ រាល់វិបត្តិនីមួយៗ ទាំងនេះ លោក ប្រេម គឺជាឧបករណ៍សំខាន់មួយរបស់រាជាធិបតេយ្យអាស្រ័យបណ្តាញ ដោយលោកបានចូលប្រឡូកយ៉ាងសកម្មក្នុងការចាត់ចែងសំខាន់ៗ នៅខាងក្រោយឆាក ។ វិបត្តិភាគខាងត្បូងបង្ហាញថា រាជាធិបតេយ្យអាស្រ័យបណ្តាញកំពុងចាប់ផ្តើមទម្រង់ថ្មី ។ ដូចបានជម្រាបជូនខាងលើរួចមកហើយ លោក ប្រេម បានធ្វើសុន្ទរកថាសាធារណៈសំខាន់មួយ ដើម្បីស្តីបន្ទោសរដ្ឋាភិបាល និងបានទំនាស់ទៅនឹងគោលនយោបាយរបស់រដ្ឋាភិបាលថែមទៀតផង ។

## លោក ប្រេម និងវិបត្តិនៃភាពស្របច្បាប់ ឆ្នាំ ១៩៩៧

*នៅពេលលោក បន្ហារ ត្រូវគេបណ្តេញចេញពីអំណាចក្នុងខែតុលា ឆ្នាំ ១៩៩៦ រួចមក របបថ្មីក្រោយក៏មិនមានភាពប្រសើរជាងរបបមុននោះដែរ ព្រោះលោក ជវលិត យ៉ុងចៃយុទ្ធ ដែលជារឿយៗ ល្បីថា មិនសូវមានសន្តានចិត្តចំពោះព្រះមហាក្សត្រ បានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីនៃប្រទេសថៃ ។ នៅក្រោមការឃ្លាំមើលរបស់លោក ជវលិត ជំហរសេដ្ឋកិច្ចរបស់ប្រទេសបានចុះខ្សោយ រហូតដល់ការបន្ថយតម្លៃដ៏អាក្រក់បំផុតនៃប្រាក់បាទថៃនៅក្នុងខែកក្កដា ឆ្នាំ ១៩៩៧ ។ ហាក់បីដូចជាគ្មាននរណាម្នាក់ចេញមុខថ្វាយដំណឹងជាមុនដល់ព្រះរាជវាំងឡើយ ហើយ «ទីចាត់ការទ្រព្យសម្បត្តិព្រះមហាក្សត្រ» ខាតបង់ទ្រព្យសម្បត្តិរបស់ខ្លួនស្ទើរតែទាំងអស់ ÷ ក្រុមហ៊ុន ស៊ិម៉េនត៍ថៃ (ស្យាមស៊ីម៉ងត៍) រងនូវការខាតបង់អស់ទឹកប្រាក់ចំនួន ១៩០ កោដិដុល្លារអាមេរិក (១៩០០ លានដុល្លារ) និងនៅជំពាក់បំណុលចំនួន ៤០០ កោដិដុល្លារថែមទៀត ។ ចំណែកឯធនាគារថៃពាណិជ្យវិញ បានជាប់កុនជាមួយនឹងទឹកប្រាក់កម្ចី ដែលមិនបានផលចំណេញចំនួន ៥ កោដិដុល្លារ (កបកៀ ២០០៣: ២៦១ កំណត់លេខ ៣០) ។*

*នៅមានការវិវត្តដ៏សំខាន់ៗ ជាច្រើនផ្សេងទៀត ។ ការវិវត្តមួយបន្ទាប់ពីវិបត្តិនោះមក គឺគេបាប្រើលោក ប្រេម ឲ្យជួយ កុំឲ្យរដ្ឋាភិបាលលោក ជវលិត ដួលរលំភាពស្របច្បាប់នៅក្នុងក្រសែភ្នែករបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (អាយ.អិម.អេហ្វ.) ដោយផ្អែកលើមូលដ្ឋានមួយ គឺថា ការរស់រានមានជីវិតរបស់ប្រទេសជាតិនិងសេដ្ឋកិច្ច គឺជាចំណុចអាទិភាព ។ ម្តងនេះ មានការជជែកគ្នាជាសាធារណៈ ចង់ឲ្យលោក ប្រេម ធ្វើជានាយករដ្ឋមន្ត្រីស្តីទី (កាសែត* **បាងកកប៉ុស្តិ៍** *១៦ តុលា គ.ស. ១៩៩៧) ។ នៅថ្ងៃទី ៦ ខែតុលា ឆ្នាំ ១៩៩៧ លោក ប្រេម បានកោះហៅនិពន្ធនាយកកាសែតមកកាន់គេហដ្ឋានគាត់ ដើម្បីផ្សព្វផ្សាយនូវគំនិតចង់បង្កើតរដ្ឋាភិបាលបង្រួបបង្រួមជាតិមួយ ។ ប្រសិនបើមានប្រសិទ្ធភាពមែន រាជាធិបតេយ្យអាស្រ័យបណ្តាញអាចនឹងត្រួតត្រាប្រទេសដោយផ្ទាល់ ។ ចុងបញ្ចប់ លោក ប្រេម មិនបានធ្វើជានាយករដ្ឋមន្ត្រីទេ បើទោះជាគាត់បានសុំឲ្យមិត្តភក្តិជំនិតនិងជាទីប្រឹក្សារបស់គាត់ រួមមានដូចជា អតីតរដ្ឋមន្ត្រីហិរញ្ញវត្ថុ លោក វីរពង្ស រាមាក្កូរ*[៣៤] (วีรพงษ์ รามางกูร Virabongsa Ramangkura) *ឲ្យចុះចូលជាមួយលោក ជវលិត និងបន្ថែមភាពជឿទុកចិត្តទៅលើរដ្ឋបាលជវលិត (សូមមើលកាសែត* **ដឹណេឆន់** *១៥ សីហា ១៩៩៧ និង* **បាងកកប៉ុស្តិ៍** *២៤ សីហា ១៩៩៧) ។ ប៉ុន្តែ នៅពេលដែលលោក ជវលិត ចាប់ផ្តើមនិយាយថា ចង់ប្រកាសភាពអាសន្ន ហើយបានកោះហៅមេបញ្ជាការយោធា ដើម្បីពិភាក្សាគ្នាអំពីអ្វីដែលអាចនាំទៅរកការរៀបចំរដ្ឋប្រហារប្រឆាំងនឹងរូបគាត់ ភ្លាមនោះ រាជាធិបតេយ្យអាស្រ័យបណ្តាញបង្កការព្រួយបារម្ភភ្លាមៗ ទៅដល់រដ្ឋបាលរបស់គាត់*[៣៥] *។ យោធាបានបដិសេធទៅនឹងការស្នើនោះ ហើយនៅខែវិច្ឆិកា លោក ជវលិត ត្រូវបានជំនួសភ្លាមៗ ដោយលោក ឈួន លីកភ័យ ។ អំណាចបានផ្លាស់ប្តូរគ្នា កាន់កាប់ដោយសារតែលទ្ធផលពីឥទ្ធិពលនៃការព្រមព្រៀងគ្នាដ៏សាំញ៉ាំនិងប្លែករបស់ឥស្សរជន (ព្រឹទ្ធិសាណ ១៩៩៨: ២៨០-៩) ។ លោក ឈួន ត្រឡប់ទៅកាន់វិមានរដ្ឋាភិបាលវិញ ដោយមិនចាំបាច់មានលទ្ធផលការបោះឆ្នោតអ្វីឡើយ ។ គេជឿថា ការណ៍នេះកើតឡើង ដោយផ្អែកទៅលើការរៀបចំក្រោយឆាក ដែលធ្វើឡើងដោយក្រុមមនុស្សនៅក្នុងបក្សប្រជាករថៃ ដែលមានសំឡេងតិច ហើយដែលមិនសប្បាយចិត្ត និងខូចកិត្យានុភាព ។ ចលនាដែលបង្កើតឡើងស្ទើរតែទាំងស្រុង ដោយអគ្គលេខាធិការពួកប្រជាធិបតេយ្យ ឈ្មោះ លោក ស្នាន់ ខូរប្រសាសន៍*

(កាសែត **ដឺណេរាន់** ៦ វិច្ឆិកា ១៩៩៧ និងកាសែត **បាងកកប៉ុស្តិ៍** ១៧ វិច្ឆិកា ១៩៩៧) នេះមានការលូកដៃចូលរបស់លោក ព្រេម ស្ទើរគ្រប់ចំណុចទាំងអស់ ។ ប៉ុន្តែ ឈុតឆាកទាំងស្រុងនៃសាច់រឿងនោះ ត្រូវបានគេបំភ្លេចចោលយ៉ាងឆាប់រហ័សក្នុងភាពក្រៀមក្រំសៅហ្មងរបស់ប្រទេសជាតិ ដែលកើតឡើងបន្ទាប់ពីវិបត្តិនោះមក ។ លោក ព្រេម បានធ្វើរដ្ឋប្រហារមួយទៀត ដោយស្ងៀមស្ងាត់ និងគ្មានការបង្ហូរឈាម ដើម្បីបណ្តេញរដ្ឋាភិបាលដែលបាត់បង់កេរ្តិ៍ឈ្មោះ ហើយដាក់ជំនួសវិញដោយរដ្ឋបាលមួយដែលព្រះរាជវាំងទទួលយកបាន ។ កាលពីមុនយោធាកម្រជំទាស់នឹងឱកាសធ្វើរដ្ឋប្រហារយ៉ាងណាក៏ដោយ ប៉ុន្តែអ្វីៗ បានប្រែប្រួលបន្ទាប់ពីស្ថានការណ៍នយោបាយក្រោយឆ្នាំ ១៩៩២ កន្លងមក ។ លោក សុរយុទ្ធ ចុល្លានន្ទ[៣៦] (สุรยุทธ์ จุลานนท์ Surayud Chulanont) នៅពេលនោះ គឺជាមេបញ្ជាការយោធាទី ២ (មូលដ្ឋានចាស់នៃអំណាចរបស់លោក ព្រេម) បានបដិសេធនៅក្នុងបទសម្ភាសន៍មួយនៅឆ្នាំ ១៩៩៦ ថា មេយោធាឥឡូវនេះ ត្រូវតែបង្កើតសម្ពន្ធភាពផ្នែកនយោបាយជាមួយអ្នកនយោបាយ ក្នុងពេលដែលខ្លួនកំពុងបង្ហាញខ្លួនឯងថា គ្មានការពាក់ព័ន្ធនឹងនយោបាយ ឬគ្មានលំអៀងនោះ (ជ័យអនន្ត ១៩៩៧: ៥៥)[៣៧] ។

នៅឆ្នាំ ១៩៩៧ គេឃើញមានការអនុម័តរដ្ឋធម្មនុញ្ញថ្មីមួយ ដែលជាលទ្ធផលមកពីសម្ពាធរបស់មនុស្សសំខាន់ៗ ដូចជាអតីតគ្រូពេទ្យរបស់ព្រះមហាក្សត្រ លោកវេជ្ជបណ្ឌិត ប្រវេស វៈសី និងនាយករដ្ឋមន្ត្រីចាស់លោក អានន្ទ ប័ន្យារជុន ។ លោក ប្រវេស បានពិពណ៌នាអំពីវិធីសាស្ត្រមួយ គឺរៀបចំបង្កើតចលនាមួយ ឲ្យមានការកែទម្រង់តាមរយៈដំណើរការ «ការពង្រឹងអំណាចសង្គម» ការស្វះស្វែងរកការយកចិត្តទុកដាក់ពីសាធារណជន និងធ្វើការបញ្ចុះបញ្ចូលគេឯងដោយផ្ទាល់ខ្លួន និងដោយគ្មានការអោម៉ាស់មុខ (២០០២: ២២-៤) ។ នេះរួមបញ្ចូលផងដែរនូវអ្វីដែលគាត់ហៅថា «យុទ្ធសាស្ត្រគ្រួសារនិងភរិយា» ដើម្បីដាក់ការគាបសង្កត់លើលោកនាយករដ្ឋមន្ត្រី ប័ន្ហារ សិល្បអាជា ក្នុងការបន្តការកែទម្រង់នយោបាយ ដោយផ្តោតលើគោលគំនិតនៃគុណតម្លៃគ្រួសាររបស់គាត់ទាំងនេះ ។ លោក ប្រវេស បានកត់សម្គាល់ផងដែរថា រដ្ឋធម្មនុញ្ញថ្មីនេះបានក្លាយជាសមរភូមិដើម្បីកំណត់តួនាទីរបស់ព្រះមហាក្សត្រ ។ ក្រុមអ្នកអភិរក្សនិយមបានអះអាងថា អ្នកកែទម្រង់ចង់ធ្វើឲ្យអន្តរាយដល់ឋានៈមហាក្សត្រ ហើយអ្នកអភិរក្សនិយមបានគំរាមកំហែងកេណ្ឌកម្លាំងកាយបុទ្ធិប្រចាំភូមិ (ពួកលូកសឿធាវបាន) ដើម្បីជំទាស់ទៅនឹងសេចក្តីព្រាងរដ្ឋធម្មនុញ្ញនោះទៀតផង (២០០២: ២៥) ។ មាត់ចាបមាត់ព្រាបថា លោកអតីតនាយករដ្ឋមន្ត្រីលោក អានន្ទ ប័ន្យារជុន បានព្រះមហាក្សត្រសុំឲ្យធ្វើជាប្រធានគណៈកម្មាធិការព្រាងរដ្ឋធម្មនុញ្ញនេះ (កុណ្ណូរស៍ ២០០៣: ១៣០) ។ លោក អានន្ទ និងលោក ប្រវេស ទាំងពីរនាក់នេះ គឺជាមនុស្សសំខាន់ដែលនៅពីក្រោយបណ្តាញសេរីនិយមនៃសកម្មជនខាងកែទម្រង់មួយ ដែលបណ្តាញនេះមានភាពស្របគ្នានិងត្រួតស៊ីគ្នាជាមួយនឹងបណ្តាញរដ្ឋាភិបាលរាជាធិបតេយ្យរបស់លោក ព្រេម ។ បើទោះបីជាលោក ប្រវេស កម្រទទួលកាន់កាប់មុខនាទីអំណាចជាផ្លូវការណាមួយក៏ដោយ ក៏គាត់គឺជាកម្លាំងចលករនៅពីក្រោយគម្រោងនិងយុទ្ធនាការមួយចំនួនធំ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ រួមមានការកែទម្រង់ផ្នែកអប់រំ ការកែទម្រង់ផ្នែកសុខាភិបាល ការគ្រប់គ្រងថ្នាំជក់ និងការកែទម្រង់ការសិក្សាស្រាវជ្រាវ ។ វិធីប្រតិបត្តិរបស់លោក ប្រវេស ដូចគ្នានឹងវិធីប្រតិបត្តិរបស់លោក ព្រេម ដែរ ពោលគឺវាផ្អែកមួយភាគធំលើនយោបាយនៃបណ្តាញបុគ្គល ។ លោក ប្រវេស ជាមនុស្សដែលកម្ររកបានដូចគាត់ ដែលទទួលបានការគោរពពីខាងក្នុងផ្នែកការិយាល័យាធិបតេយ្យ និងក្នុងចំណោមអ្នក

ដឹកនាំអង្គការមិនមែនរដ្ឋាភិបាល និងសកម្មជនសង្គមផងនោះ ។ លោក ប្រេម គឺជាអ្នកជំនាញនៃក្រុមដែលពាក់ព័ន្ធនយោបាយ និងការកសាងក្រុមចម្រុះ ។ ដោយសារតែឋានៈរបស់គាត់ជាគ្រូទេព្យរបស់ព្រះមហាក្សត្រ គេអាចស្មានដឹងបានថា លោក ប្រេម ដើរតួជំនួសឲ្យព្រះរាជបរមរាជវាំង (ម៉ាក់ខារហ្គូ ២០០១: ៩៤-៨) ។ នៅក្នុងសុន្ទរកថាដែលមិនបានរាយការណ៍មួយ លោក ប្រេម បានបញ្ជាក់យ៉ាងច្បាស់ថា ការបង្កើតឲ្យមានសណ្ដាប់ធ្នាប់នយោបាយរបស់ប្រទេសថៃ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ប្រសិនបើប្រទេសជាតិចង់ជៀសឲ្យផុតពីវិបត្តិហិង្សាទៅអនាគត នៅចំពេលដែលមានការស្នងរាជសម្បត្តិមួយកើតឡើងនោះ[៣៨] ។ កង្វល់ស្ដីអំពីបញ្ហាស្នងរាជសម្បត្តិ កើតឡើងកាន់តែខ្លាំងនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ មកពីព្រះសុខភាពទ្រុឌទ្រោមរបស់ព្រះមហាក្សត្រនិងព្រះជន្មរបស់ទ្រង់ ។ ដូចលោក ហេវីសុន លើកឡើងថា «ការបង្កើតប្រព័ន្ធរដ្ឋធម្មនុញ្ញមួយអាចការពារអង្គព្រះមហាក្សត្រដែលទន់ខ្សោយ ឬមិនសូវមានប្រជាប្រិយភាពបាន» (១៩៩៧: ៧៤) ម៉្លោះហើយទើបបណ្ដាលឲ្យមានការចាំបាច់ឲ្យមានការកែទម្រង់នយោបាយទៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ។ ដូចសាស្ត្រាចារ្យ កបកឿ អះអាងថា ប្រទេសថៃមាន «ទម្រង់រាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញបែបបុរាណ ដែលផ្ដោតលើអំណាចក្រៅរដ្ឋធម្មនុញ្ញ និងអំណាចតាមប្រពៃណីរបស់ព្រះរាជបល្ល័ង្ក» ដែលជាទម្រង់មួយពឹងផ្អែកយ៉ាងខ្លាំងលើ «ភាពអស្ចារ្យរបស់បុគ្គលដែលជាអ្នកគ្រងរាជបល្ល័ង្ក» (២០០៣: ២៩) ។ រដ្ឋធម្មនុញ្ញថ្មីនេះ គឺជាវិធានការបង្ការមុនដើម្បីជួយការពាររាជាធិបតេយ្យ ។

គម្រោងកែទម្រង់ផ្នែកនយោបាយបង្ហាញឲ្យឃើញពីយន្តការរបស់រាជាធិបតេយ្យអាស្រ័យបណ្ដាញ ។ មុនដំបូង ព្រះរាជវាំងនិងលោក ប្រេម មិនសូវជាមានការចាប់អារម្មណ៍ប៉ុន្មានទេ ប៉ុន្តែក្រោយមក មានការបង្កើតនូវក្រុមចម្រុះនៃផលប្រយោជន៍មួយនេះ ។ គេក៏អាចបកស្រាយផងដែរថា រដ្ឋធម្មនុញ្ញ «ដើម្បីប្រជាជន» ឆ្នាំ ១៩៩៧ តាមពិតទៅ បែរជា «រដ្ឋធម្មនុញ្ញដើម្បីព្រះរាជវាំង» វិញ គឺជាឯកសារមួយដែលគេព្រាងឡើងដើម្បីជួយធានាភាពគង់វង្សនិងស្ថិរភាពទៅថ្ងៃមុខនៃរាជវង្សចក្រី (ម៉ាក់ខារហ្គូ ២០០១: ៩៧-៩៨) ។ គេក៏អាចនិយាយបានថា លោក ប្រេម បានលក់ការកែទម្រង់ផ្នែកនយោបាយទៅឲ្យព្រះរាជវាំង តាមរយៈការសង្កត់ធ្ងន់លើតម្រូវការចាំបាច់ក្នុងការស្វែងរកមធ្យោបាយដើម្បីលើកកម្ពស់អាយុជីវិតនយោបាយ ជាពិសេសតាមរយៈការអនុញ្ញាតឲ្យមនុស្សល្អៗ (ដូចជា លោក ប្រេម និងលោក អានន្ទ) បានចូលក្នុងឆាកនយោបាយ ។ ទស្សនវិស័យរបស់លោក ប្រេម ខិតខំរៀបចំលក្ខណៈប្រសើរបំផុតនៃរាជាធិបតេយ្យអាស្រ័យបណ្ដាញឲ្យមានសភាពជាផ្លូវការ ដោយបង្កើតឲ្យមានជាឱកាសសម្រាប់មនុស្សដែលមានទេពកោសល្យនិងមានសមត្ថភាព ដើម្បីចូលរួមឆាកនយោបាយដោយមិនឲ្យមានការប្រឡាក់ដៃនៅក្នុងកលល្បិចខាងការប្រើប្រាស់សន្លឹកឆ្នោត និងសកម្មភាពដទៃផ្សេងទៀត ។ ការបង្កើតឲ្យមាននូវប្រព័ន្ធបញ្ជីគណបក្ស គឺជាឧទាហរណ៍ជាក់ស្ដែងមួយនៃគំនិតនេះ រួមទាំងគំនិតឲ្យមានព្រឹទ្ធសភានៃក្រុមចាស់ព្រឹទ្ធាចារ្យប្រកបដោយគតិបណ្ឌិត ដែលមិនមែនជាសមាជិករបស់គណបក្សណាមួយ (សូមមើល ម៉ាក់ខារហ្គូ ២០០២) ។ លោក ប្រេម ជឿថា ប្រទេសថៃសម្បូរទៅដោយមនុស្សមានសមត្ថភាព ដែលជាអ្នកកែទម្រង់ដោយសភាវគតិ ។ ប្រសិនបើគេដាក់មនុស្សទាំងនេះឲ្យត្រូវកន្លែងអំណាច នោះធានាថា នឹងមានស្ថិរភាពនយោបាយ ហើយមានការកែទម្រង់វិវឌ្ឍនិយម ក៏អាចវិវឌ្ឍទៅមុខផងដែរ ។ តាមរយៈការបង្កើតស្ថាប័នថ្មីផ្សេងៗ ដូចជា គណៈកម្មការបោះឆ្នោត និងគណៈកម្មការជាតិខាងសិទ្ធិមនុស្ស អាចនឹងធានាបានថា វត្តមានរបស់

មនុស្សដែលប្រកបដោយគុណធម៌ទាំងនេះ ពិតជាបន្តមាននៅក្នុងដំណើរការនយោបាយ ។ ឬអាចនិយាយបាន ម្យ៉ាងទៀតថា គេអាចរៀបចំរាជាធិបតេយ្យអាស្រ័យបណ្ដាញឡើងវិញឲ្យមានមូលដ្ឋានមាំទាំដាងមុន ដែលលើសពី អនុប្រព័ន្ធក្រៅផ្លូវការដែលបន្តមានរហូតដល់ពេលបច្ចុប្បន្ននេះ ។ កម្មវិធីកែទម្រង់នយោបាយនេះ ឆ្លុះបញ្ចាំងពី ការតទល់គ្នារវាងពួកសេរីនិយមនិងពួកអភិរក្សនិយម ដើម្បីធានានៃរាជាធិបតេយ្យអាស្រ័យបណ្ដាញ ។ នៅចុង ឆ្នាំ ១៩៩៧ ខាងគំនិតសេរីនិយមជាអ្នកឈ្នះ ។ មិនមែនជានយោបាយដែលមិនពាក់ព័ន្ធនឹងប្រាក់កាស តែគឺជា វិបត្តិសេដ្ឋកិច្ចនិងរដ្ឋធម្មនុញ្ញថ្មីវិញ ដែលបានត្រួសត្រាយផ្លូវឲ្យលោក ទក្សិណ ជិនវ័ត្រ រះឡើងបានដែរ ។ នៅ ក្នុងការបោះឆ្នោតសាកលនៅខែមករា ឆ្នាំ ២០០១ គណបក្សដែលទើបតែបង្កើតថ្មី ឈ្មោះថា «ថៃរ៉ាក់ថៃ» (ថៃស្រឡាញ់ ថៃ) ដែលដឹកនាំដោយមហាសេដ្ឋីខាងទូរគមនាគមន៍ដ៏មានអំណាច ឈ្មោះ លោក ទក្សិណ ជិនវ័ត្រ បានឈ្នះឆ្នោតយ៉ាង លើសលប់លើក្រុមប្រជាធិបតេយ្យ ។ ជោគជ័យរបស់លោក ទក្សិណ បានមកដោយងាយ តាមរយៈការស្រោចទឹក ប្រាក់យ៉ាងសន្ធឹកសន្ធាប់ និងមួយផ្នែកទៀត ដោយសារតែមុខមាត់របស់គាត់ជាមេដឹកនាំនាយកប្រតិបត្តិដែល ម៉ឺងម៉ាត់មួយរូប ដែលចូលចិត្តដោះស្រាយបញ្ហាភ្លាមៗ និងមួយចំណែកទៀត បានមកពីល្បិចវោហារសាស្ត្រ ប្រជាភិថុតិដែលមានប្រជាប្រិយរបស់គាត់ និងគោលនយោបាយតាក់តែងឡើងដើម្បីទាក់ទាញប្រជាពលរដ្ឋជា ច្រើននៅតាមទីជនបទ (ម៉ាក់ខារហ្គូ និង ឧក្រឹស្ត ២០០៥) ។ លោក ទក្សិណ តំណាងគំរូមួយនៃកម្លាំងនយោបាយ ថ្មី ដែលផ្អែកលើទឹកប្រាក់ ដែលមិនសប្បាយចិត្តនឹងរាជាធិបតេយ្យអាស្រ័យបណ្ដាញនោះឡើយ ។ នាយករដ្ឋមន្ត្រី ដែលគ្មានការគាំទ្រពីព្រះរាជវាំងមួយចំនួន នាពេលថ្មីៗនោះ ដូចជា លោក ប័ន្ហារ សិល្បអាជា និងលោក ជវលិត យ៉ុងចៃយុទ្ធ អាចចូលកាន់តំណែងបានត្រឹមមួយឆ្នាំ ឬមិនលើសពីហ្នឹងផង តែលោក ទក្សិណ មានភាពរឹងមាំខ្លាំង រហូតដល់មិនអាចបណ្ដេញគាត់ឲ្យចេញបានយ៉ាងងាយ ។ លោក ទក្សិណ បានចាប់ផ្ដើមរៀបចំជាប្រព័ន្ធមួយ ដើម្បី បំបែកបណ្ដាញនយោបាយដែលស្មោះត្រង់នឹងលោក ប្រេម នៅក្នុងផ្នែកជាច្រើន ក្នុងគោលបំណងដាក់ជំនួសអ្នក ទាំងនោះដោយមនុស្សដែលគាំទ្រគាត់ គូកនរបស់គាត់ និងញាតិសន្ដានរបស់គាត់វិញ ។ លោក ទក្សិណ ស្វះស្វែង ផ្ដួលរំលំបណ្ដាញរាជាធិបតេយ្យ ហើយជំនួសបណ្ដាញនេះដោយបណ្ដាញសេដ្ឋកិច្ចនយោបាយមួយដែលលោក ការទេរ៍ប្រេស្សុង (Cartier Bresson) (១៩៩៧) ពិពណ៌នាថា ជាបណ្ដាញមួយដែលមានមូលដ្ឋានលើទំនាក់ទំនង ខាងក្នុង និងអំពើពុករលួយបែបជារចនាសម្ព័ន្ធ ។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ មានការតទល់គ្នាយ៉ាងសំខាន់មួយ រវាងក្រុមអភិរក្សនិយម ដែលមានទំនាក់ទំនងគ្នាជាមួយយោធានិងការិយាល័យាធិបតេយ្យ និងអ្នកកែទម្រង់បែប សេរីនិយមដែលស្វះស្វែងដើម្បីពង្រឹងសង្គមស៊ីវិលនិងស្ថាប័ននយោបាយ ។ ប៉ុន្តែ លោក ទក្សិណ ដែលជា នគរបាលមុននឹងក្លាយជាមហាសេដ្ឋី ក្រោយមក ក្លាយជានាយករដ្ឋមន្ត្រី បានលេងទៅតាមក្បួននិងគំនិតថ្មីទាំង ស្រុងមួយ ពោល គឺក្បួននិងគំនិតដឹកនាំបែបពិសពុលមួយដែលទុកច្រកតិចតួចបំផុត សម្រាប់អ្នកលេងដែលជា គូប្រជែង (លិបម៉ាន-ប៊្លូមែន (Lipman-Blumen) ២០០៥) ។

## លោក ប្រេម និងវិបត្តិតុលាការជម្មនុញ្ញ ឆ្នាំ ២០០១

កាលពីដំបូង លោក ទក្សិណ ទទួលបានការគាំទ្រពីក្រុមអ្នកកែទម្រង់នយោបាយរបស់រាជាធិបតេយ្យអាស្រ័យ បណ្ដាញ ជាពិសេស គឺលោក ប្រវេស វ:សី ផ្ទាល់តែម្ដង ។ វាជាការហួសចិត្តមួយ ដែលលោក ប្រវេស បែរ

*ជាគាំទ្រលោក ទក្សិណ ដែលជាអ្នកតំណាងឲ្យចំណុចប្រសព្វគ្នាមួយនៃទឹកប្រាក់និងនយោបាយកាលពីនៅក្នុងរឿងក្តីតុលាការធម្មនុញ្ញរបស់គាត់នៅឆ្នាំ ២០០១ នោះ ។ នៅខែសីហា ឆ្នាំ ២០០១ លោកនាយករដ្ឋមន្ត្រី ទក្សិណ ជិនវ័ត្រ (ដែលបានជាប់ឆ្នោតភ្លូកទឹកភ្លូកដីនៃរដ្ឋសភានៅក្នុងខែមករាដើមឆ្នាំនោះ) បានប្រឈមមុខនឹងការចោទប្រកាន់អំពីការលាក់បំបាំងទ្រព្យសម្បត្តិ ។ ប្រសិនបើតុលាការធម្មនុញ្ញរកឃើញថា មានទោស គាត់អាចនឹងត្រូវគេហាមមិនឲ្យធ្វើនយោបាយរយៈពេលចំនួនប្រាំឆ្នាំ និងត្រូវបណ្តេញចេញពីវិមានរដ្ឋាភិបាលទៀតផង ។ លោក ទក្សិណ មិនសូវបានប៉ុនប៉ងបដិសេធទៅនឹងបទចោទទាំងនោះប៉ុន្មានទេ ប៉ុន្តែគាត់ទទួលបានប្រជាប្រិយភាពយ៉ាងធំធេង ហើយមានមនុស្សជាច្រើនសម្លឹងមើលឃើញរូបគាត់ថា ជាមេដឹកនាំមួយដ៏សក្តិសមបំផុតសម្រាប់ប្រទេសថៃ នៅក្នុងគ្រាដ៏លំបាកទាំងផ្នែកសេដ្ឋកិច្ចនិងនយោបាយនេះ ។ ចុងបញ្ចប់ លោក ទក្សិណ រួចផុតពីការរកឃើញថាមានទោសយ៉ាងប្រផិតប្រផើយនៅក្នុងកាលៈទេសៈដែលពោរពេញដោយបញ្ហានេះ (សម្រាប់ព័ត៌មានពិស្តារ សូមមើល ណិល្សុន* (Nelson) *២០០២: ៣៨០-៨; ខ្លេន* (Klein) *២០០៣: ៧១-៦; និង សុរជៀរ ២០០៣) ។ សាលក្រមនោះ បង្កើតឲ្យមានជាចម្ងល់យ៉ាងច្រើន ហើយកាសែតបាងកកប៉ុស្តិ៍ចុះផ្សាយនូវប្រែកពមួយដែលនិយាយថា ចៅក្រមពីររូបលើកលែងការចោទប្រកាន់លើលោក ទក្សិណ «ព្រោះមានការស្នើមួយពីមនុស្សម្នាក់ដែលមានទឹកមាត់ប្រៃខ្លាំង» ។ ប្រែកពដដែលបានដកស្រង់សម្តីចៅក្រមម្នាក់ថា «គេបង្ខំខ្ញុំឲ្យលេបឈាមខ្លួនឯងនៅពេលដែលខ្ញុំកំពុងសរសេរដូច្នេះ»* (**បាងកកប៉ុស្តិ៍** *៤ សីហា ២០០១) ។ មនុស្សភាគច្រើនជឿថា ការធ្វើដូច្នេះ គឺដោយសារអន្តរាគមន៍របស់លោក ប្រេម ដើម្បីពន្យាងភាពចម្រូងចម្រាសផ្នែកនយោបាយចំពោះសាល-ក្រមពិរុទ្ធភាពណាមួយ ។ ក្នុងពេលកំពុងជំនុំជម្រះក្តី មានការរៀបចំធ្វើយុទ្ធនាការចែកខិត្តប័ណ្ណមួយ ដែលចោទប្រកាន់លោក ប្រេម ថា បានលូកដៃចូលដោះស្រាយដើម្បីធានាថា លោក ទក្សិណ បានរួចខ្លួនពីការចោទប្រកាន់* (**អា.អែហ្វ.ប៉េ**. (*AFP*) *២ សីហា ២០០១) ។ ទោះបីជាការអះអាងដែលចោទប្រកាន់ថា លោក ប្រេម បានចំណាយប្រាក់ដើម្បីដោះស្រាយរឿងនេះ ទំនងជាការពន្លើសសុទ្ធសាធក៏ដោយ ក៏មានខិត្តប័ណ្ណសមហេតុផលមួយទៀតផងដែរ អះអាងថា លោក ប្រេម បានព្រមព្រៀងបញ្ចុះបញ្ចូលគេដើម្បីការលើកលែងការចោទប្រកាន់លោក ទក្សិណ ជាថ្នូរនឹងការរក្សាទុកលោក សុរយុទ្ធ ចុល្លានន្ទ ដែលជាមនុស្សស្មោះត្រង់នឹងលោក ប្រេម នៅក្នុងមុខតំណែងមេបញ្ជាការយោធានៅឆ្នាំតទៅមុខទៀត* (**បាងកកប៉ុស្តិ៍** *២ សីហា ២០០១) ។ គេដឹងថា លោក ប្រេម និងលោក ទក្សិណ បានជួបទាក់ទងគ្នា ។ នៅពេលដែលលោក ទក្សិណ ទៅលេងលោក ប្រេម នៅថ្ងៃទី ១ ខែមិថុនា លោក ប្រេម បានលើកទឹកចិត្តលោក ទក្សិណ កុំឲ្យរាយមាយដោយសារតែរឿងក្តីតុលាការនោះធ្វើអ្វី* (**បាងកកប៉ុស្តិ៍** *២ មិថុនា ២០០១) ។ គេមិនអាចដឹងប្រាកដថា តើលោក ប្រេម ពិតជាបានប្រើឥទ្ធិពលណាមួយលើករណីទ្រព្យសម្បត្តិនេះឬយ៉ាងណានោះទេ ប៉ុន្តែមានពាក្យចចាមអារ៉ាមជាច្រើនលើកឡើងថា មានអ្នកសង្កេតការណ៍នយោបាយជាច្រើន ជឿថា លោក ប្រេម បានពាក់ព័ន្ធក្នុងរឿងនេះមែន ។ អន្តរាគមន៍ដែលគេបានប្រមើលមើលនេះ បានឆ្លុះបញ្ចាំងនូវគំនិតលទ្ធផលនិយមនិងប្រតិបត្តិនិយមដែលធ្វើឲ្យរាជាធិបតេយ្យអាស្រ័យបណ្តាញមានភាពរស់រវើកបាន ÷ ដោយថាហេតុ លោក ប្រេម ចង់បន្ធូរបន្ថយស្ថានការណ៍តានតឹងនៃវិបត្តិដែលអាចកើតឡើង ដោយការជួយការពារលោក ទក្សិណ បើទោះជាការបណ្តេញលោក ទក្សិណ អាចនឹងធ្វើឲ្យលោក ប្រេម ពេញចិត្តពេញថ្លើមផ្ទាល់ខ្លួនខ្លះយ៉ាងណាក៏ដោយ ។ លោក ប្រេម ច្បាស់ជាបានស្មានទុកថា លោក ទក្សិណ*

នឹងតបស្នងគុណចំពោះការធ្វើអន្តរាគមន៍នេះ ដោយទុកតំណែងឯសិទ្ធិខ្ពស់មួយនៅក្នុងកិច្ចការនយោបាយ ជាពិសេស គឺការត្រួតត្រារបស់គាត់លើការចាត់តាំងមេទ័ពសំខាន់ៗ និងតំណែងមន្ត្រី រួមទាំងតំណែងអភិបាលខេត្តទាំងឡាយនៅតំបន់ភាគខាងត្បូងផងដែរ ។ ប៉ុន្តែ លោក ទក្សិណ គ្មានបំណងធ្វើតាមក្បួនលេងល្បែងកីឡាដែលប្រកបដោយសេចក្តីថ្លៃថ្នូរទាំងនេះទេ ។ នៅពេលដែលរឿងក្តីទ្រព្យសម្បត្តិនេះចប់ទៅ លោក ទក្សិណ បានបន្តដាក់លោក ប្រេម ឲ្យនៅក្រៅរង្វង់នៃការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗដដែល នេះបង្ហាញឲ្យឃើញនូវការសម្រេចចិត្តរបស់គាត់ដើម្បីបង្កើតបណ្តាញអស្ចារ្យថ្មីមួយ ពោលគឺអ្វីៗ ទាំងអស់ត្រូវតែសម្រេចចេញពីរូបគាត់ទាំងស្រុង និងជាបណ្តាញមួយដែលមានរចនាសម្ព័ន្ធឋានានុក្រមខ្លាំង ។ ទោះជាយ៉ាងនេះក្តី ក៏លោក សុរយុទ្ធ បានរក្សាទុកតំណែងជាមេបញ្ជាការយោធាមួយឆ្នាំទៀតមែន ។ ហេតុការណ៍នេះបានបង្ហាញនូវរបៀបដែលពួកយោធា (ដែលអ្នកខ្លះបានជឿថា អាចរំលងពួកគេបាន) ដែលតាមពិតទៅ បានផ្សារភ្ជាប់នៅក្នុងក្រឡានៃបណ្តាញប្រព័ន្ធមេកម្លាំងនិងកូនចៅ ដ៏ឈ្លាសវៃនិងមានប្រសិទ្ធភាពរបស់លោក ប្រេម ដោយមានការជួយជ្រោមជ្រែងពីព្រះរាជវាំងនិងក្រុមប្រជាធិបត្យ (ម៉ាក់ខារហ្គូ និង ឧក្រឹស្ត ២០០៥: ១៥៦-៧) ។

## រាជាធិបតេយ្យនិងតំបន់ភាគខាងត្បូង

ខេត្តជាយដែនភាគខាងត្បូងរបស់ប្រទេសថៃ ដែលមានប្រជាជនមូស្លីមរស់នៅច្រើនជាងគេ បានជួបប្រទះនូវការកើនឡើងនូវអំពើហិង្សានយោបាយចាប់តាំងពីខែមករា ២០០៤ មក ដែលពាក់ព័ន្ធគ្នាទៅនឹងចលនាអ្នកចង់បំបែករដ្ឋ និងការកើនឡើងនូវការមិនអត់ឱនខាងសាសនា ។ នៅស្របពេលជាមួយគ្នានេះដែរ កត្តានយោបាយក្នុងស្រុកក៏ជាបញ្ហាចម្បងផងដែរ (ម៉ាក់ខារហ្គូ ២០០៦) ។ លោក ទក្សិណ បានមើលឃើញថា តំបន់ភាគខាងត្បូង គឺជាដែនដីប្រកបដោយគ្រោះថ្នាក់មួយសម្រាប់គណបក្សថៃរ៉ាក់ថៃរបស់គាត់ ពោលគឺជាភាគមួយនៃប្រទេស ដែលសម្បូរទៅដោយមន្ត្រីដែលស្មោះត្រង់ទៅនឹងលោក ប្រេម ព្រះរាជវាំង និងគណបក្សប្រជាធិបត្យ ។ នៅក្នុងឆ្នាំ ២០០២ លោក ទក្សិណ បានរំលាយចោលរចនាសម្ព័ន្ធសន្តិសុខដែលដឹកនាំដោយយោធា ជាពិសេស «មជ្ឈមណ្ឌលចាត់ចែងការបរិហារខេត្តជាយដែនភាគខាងត្បូង» ដែលបង្កើតឡើងដោយលោក ប្រេម និងសម្ពន្ធមិត្តរបស់គាត់នៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ ។ លោក ទក្សិណ បានអាងលេសថា ការបះបោរដែលមាននោះ គឺគ្រាន់តែក្លាយជាអំពើឆក់ប្លន់ប្រដាប់អាវុធប៉ុណ្ណោះ រួចហើយគាត់បានដាក់នគរបាលឲ្យទទួលខុសត្រូវខាងការរក្សាសណ្តាប់ធ្នាប់ជំនួសវិញ ។ បើទោះបីជាលោក ទក្សិណ មានបំណងចង់ប្រិតប្រៀបកងពលទី ៤ ដែលប្រកាន់ច្បាប់ដោយខ្លួនឯងជាយូរមកហើយនៅតំបន់ភាគខាងត្បូងនោះក៏ដោយ ក៏ទង្វើរបស់គាត់បានធ្វើឲ្យចុះខ្សោយនូវបំណងនៃកិច្ចសន្យាសង្គម ហើយមិនយូរប៉ុន្មានបាននាំឲ្យមានការសម្លាប់ក្រៅតុលាការជាច្រើនបន្ថែមទៀត រួមទាំងការបាត់ខ្លួនផងដែរ ។ នៅក្នុងឧប្បត្តិហេតុហិង្សានានានៅតំបន់ភាគខាងត្បូងរវាងខែមករា ឆ្នាំ ២០០៤ និងពាក់កណ្តាលឆ្នាំ ២០០៥ មានមនុស្សជាង ៤៥០ នាក់បានស្លាប់បាត់បង់ជីវិត (សូមមើលក្រុមវិបត្តិអន្តរជាតិឆ្នាំ ២០០៥) ។ ឧប្បត្តិហេតុធ្ងន់បំផុតកើតឡើងនៅថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០០៤ នៅពេលដែលសកម្មជនដែលពុំសូវមានអាវុធការពារចំនួន ១០៨ នាក់ និងភ្នាក់ងារសន្តិសុខចំនួន ៥ នាក់ បានស្លាប់ក្នុងអំឡុងពេលនិងក្រោយពេលវាយប្រហារផ្ទួនៗ គ្នាទៅលើប៉ុស្តិ៍ឆែកឆេរ ។ ការបង្ហូរឈាមនៅថ្ងៃនោះ បញ្ចប់ទៅដោយការឡោមព័ទ្ធពីសំណាក់យោធាទៅលើវិហារ

*មូស្លិមមួយឈ្មោះ គ្រឺសិ* (กรือเซะ Krue Se) *ដាបុរាណស្ថាននៅក្នុងខេត្តបត្តានី ដែលធ្វើឲ្យបុរសកាន់សាសនាអ៊ិស្លាមចំនួន ៣២ នាក់ ត្រូវបានគេគ្លង់ចុងកាំភ្លើងបាញ់សម្លាប់ ។ ស្ថានការណ៍អាប់អួបានកើតឡើងដល់កំពូលគឺនៅថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០០៤ នៅពេលដែលបាតុករមូស្លិមចំនួន ៨៤ នាក់បានស្លាប់នៅតាកបៃ* (ตากใบ Tak Bai) *។ ពួកគេទាំងនោះភាគច្រើន ស្លាប់ដោយថប់ដង្ហើមបន្ទាប់ពីគេចាប់ដាក់គរលើគ្នានៅក្នុងរថយន្តធំរបស់យោធារួចមក ។*

*ព្រះរាជានិងព្រះរាជិនីទ្រង់មានចំណាប់អារម្មណ៍ជាពិសេសទៅលើតំបន់នេះអស់រយៈពេលយូរយារមក ។ តាមធម្មតា ព្រះរាជិនីចំណាយពេលច្រើនសប្តាហ៍រៀងរាល់ឆ្នាំ នៅឯព្រះរាជដំណាក់ទក្សិណរាជនិវេសន៍នៅក្នុងខេត្តនរាធិវាស ហើយបានតក់ស្លុតជាពន់ពេកចំពោះសភាពគួរឲ្យភ្ញាក់ផ្អើលនៃព្រឹត្តិការណ៍ទាំងនេះ ។ នៅថ្ងៃទី ៣ ខែតុលា មន្ត្រី ២ នាក់ដែលជិះរថយន្តរបស់ព្រះរាជដំណាក់ ត្រូវបានពិឃាតនៅក្នុងខេត្តនរាធិវាស នៅពេលដែលពួកគាត់ទាំងពីរទំនងជាកំពុងទិញផ្លែឈើដើម្បីថ្វាយព្រះរាជិនីនោះឯង (ទីភ្នាក់ងារសារព័ត៌មាន* **ស៊ិនហួ** *១៥ តុលា ២០០៤ និង ១៧ វិច្ឆិកា ២០០៤) ។ ក្នុងការថ្លែងទៅកាន់ប្រជារាស្ត្រជាង ១០០០ នាក់នៅព្រះរាជវាំងចិត្រលតា នៅក្នុងខែវិច្ឆិកា ព្រះរាជិនីបានមានព្រះសវនីយ៍ថា ព្រះអង្គទ្រង់ឈ្វេងយល់ថា ត្រូវតែបង្ខំព្រះហឫទ័យទម្លាយការសម្ងាត់របស់ទ្រង់ បន្ទាប់ពីបានទៅធ្វើទស្សនកិច្ចនៅតំបន់ភាគខាងត្បូងអស់រយៈពេលពីរខែរួចមក ដែលជាទស្សនកិច្ចដ៏យូរមួយ អស់ពេលច្រើនឆ្នាំកន្លងទៅ (***បាងកកប៉ុស្តិ៍*** *១៧ វិច្ឆិកា ២០០៤) ។ ព្រះអង្គបានរិះគន់ពួកសាសន៍មូស្លិមដែល «ព្រះអង្គមិនដែលបានដឹងពីមុនមកសោះ» ថា ជនទាំងនោះជាឃាតករដ៏សាហាវព្រៃផ្សៃ ដែលបានសម្លាប់មន្ត្រីរដ្ឋាភិបាលនិងប្រជារាស្ត្រសាមញ្ញអស់ជាច្រើន ។ ព្រះអង្គបានអំពាវនាវពុទ្ធសាសនិកជនថៃទាំង ៣០ ម៉ឺននាក់នៅក្នុងតំបន់នោះឲ្យមានជំហររឹងប៉ឹង និងមិនត្រូវចាកចេញពីតំបន់នោះឡើយ ។ ព្រះអង្គបានបន្ថែមទៀតថា ប្រជារាស្ត្រថៃអាចរៀនឲ្យចេះបាញ់កាំភ្លើងដើម្បីការពារខ្លួន ដោយព្រះអង្គមានព្រះសវនីយ៍ទៀតថា «កុំថាឡើយព្រះជន្ម ៧២ វស្សាហើយក៏ដោយ ក៏ខ្ញុំនឹងរៀនឲ្យចេះរបៀបបាញ់កាំភ្លើងដោយមិនចាំបាច់ពាក់វ៉ែនតាខ្ញុំផងទេ» ។*

*នៅថ្ងៃបន្ទាប់ ព្រះមហាក្សត្រទ្រង់ព្រះរាជានុញ្ញាតឲ្យមន្ត្រីយោធានិងនគរបាល ដែលទើបទទួលបានឋានន្តរសក្តិថ្មីៗ ចំនួន ៥១០ នាក់ចូលគាល់ធ្វើសវនាការ ។ នៅក្នុងសុន្ទរកថាដែលផ្សាយតាមវិទ្យុផងដែរនោះ ព្រះអង្គអំពាវនាវសូមឲ្យមានឯកភាពនិងកិច្ចសហប្រតិបត្តិការគ្នាដ៏មាំមួនរវាងនគរបាលនិងយោធា ដោយព្រះអង្គប្រកាសថា កិច្ចសហប្រតិបត្តិការគ្នានេះអាចនឹងជៀសវាងបាននូវការរំដើបរំដួលនិងភាពច្របូកច្របល់ «ដែលព្រះរាជិនី សិរិកិត្តិ៍ បានទតឃើញអំឡុងពេលព្រះអង្គគង់នៅតំបន់ភាគខាងត្បូងនោះ» (***អេ.អែហ្វ.ប៉េ***. *១៨ វិច្ឆិកា ២០០៤;* ***អេ.ប៉េ***. *១៨ វិច្ឆិកា ២០០៤) ។ សេចក្តីថ្លែងការណ៍ជាសាធារណៈដ៏កម្រមានរបស់ព្រះមហាក្សត្រនិងព្រះរាជិនីនេះ បង្ហាញឲ្យឃើញអំពីវិសាលភាពនៃស្ថានការណ៍អាប់អួនៅតំបន់ភាគខាងត្បូង ដែលបង្កជាគ្រោះគំរាមកំហែងដល់ភាពស្របច្បាប់របស់រដ្ឋថៃ ។*

*ដោយសារតែមានប្រពៃណីអន្តរាគមន៍ក្រៅរដ្ឋធម្មនុញ្ញដោយរាជាធិតេយ្យថៃ ទើបបានជាសកម្មជនពុទ្ធសាសនានិងសកម្មជនមូស្លិមសំខាន់ៗ មួយចំនួន ចាប់ផ្តើមអំពាវនាវឲ្យមានអន្តរាគមន៍ដូចនេះមួយ ដើម្បីដោះស្រាយបញ្ហានៅភាគខាងត្បូង (គ្រោស់សង់ត៍* (Croissant) *២០០៥: កំណត់ចំណាំលេខ ៦២) ។ មានមនុស្សមួយចំនួន*

សង្ឃឹមថា ព្រះមហាក្សត្រអាចបង្កើតរាជរដ្ឋាភិបាលបណ្ដោះអាសន្នដើម្បីការបង្រួបបង្រួមជាតិមួយ ដូចគ្នានឹងរដ្ឋាភិបាលមួយដែលធ្លាប់មានបន្ទាប់ពីខែឧសភា ឆ្នាំ ១៩៩២ ។ នៅខែតុលា ឆ្នាំ ២០០៤ កាសែតបាងកកប៉ុស្ដិ៍បានចេញផ្សាយលើទំព័រមុខនូវរឿងមួយក្រោមចំណងជើងថា «ជនមូស្លិមសុំឲ្យព្រះមហាក្សត្រផ្លាស់ប្ដូររដ្ឋាភិបាល» (២៩ តុលា ២០០៤) ។ បើតាមសាច់រឿងនោះ គឺមានលោក ដាតូ ណេដេះ វ៉ាបា (Dato Nedeh Waba) ដែលជាប្រធានសមាគមសាលារៀនឯកជនបង្រៀនសាសនាអ៊ិស្លាមនៅក្នុងខេត្តជាយដែនភាគខាងត្បូង និងអនុប្រធានសភាការសាសនាមូស្លិម បានអំពាវនាវទៅព្រះមហាក្សត្រឲ្យបង្កើតរដ្ឋាភិបាលមួយដែលតែងតាំងដោយព្រះមហាក្សត្រ ។ គេបានដកស្រង់សម្ដីរបស់លោកដូច្នេះថា ៖

យើងខ្ញុំគ្មានជម្រើសអ្វីផ្សេង ក្រៅពីអង្វរព្រះមហាក្សត្រជាទីស្រឡាញ់របស់យើងខ្ញុំ ដែលជាព្រះបិតារបស់យើងខ្ញុំ ឲ្យព្រះអង្គទ្រង់ព្រះមេត្តាប្រោសព្រះរាជទានមកដល់ពួកយើងខ្ញុំ នូវរាជរដ្ឋាភិបាលមួយ ដើម្បីដោះស្រាយបញ្ហាដែលមាននៅទីនេះ ... ។ ក្នុងស្ថានការណ៍ដ៏មានគ្រោះថ្នាក់បែបនេះ តើឲ្យពួកយើងខ្ញុំទៅពឹងពាក់នរណាក្រៅពីអង្គព្រះមហាក្សត្រ ដែលជាក្ដីសង្ឃឹមទាំងស្រុងរបស់យើងខ្ញុំ ព្រោះប្រជារាស្ត្រមូស្លិមនៅទីនោះទាំងអស់ ចាត់ទុកព្រះអង្គជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត (**បាងកកប៉ុស្ដិ៍** ២៩ តុលា ២០០៤) ។

ទោះបីជាផែនការអំពាវនាវនានាមិនបានទទួលផលអ្វីសោះនោះ ទាំងសកម្មជនខាងពុទ្ធសាសនានិងខាងមូស្លិម នៅតែបន្តជជែកពិភាក្សាគ្នាជាឯកជនអំពីចំណង់ចង់បានព្រះរាជអន្តរាគមន៍ ។

ព្រះមហាក្សត្របានបង្ហាញឲ្យឃើញពីការមិនយល់ស្របរបស់ព្រះអង្គទៅនឹងគោលនយោបាយរបស់លោក ទក្សិណ តាមរយៈការលើកឡើងអំពីការរិះគន់រដ្ឋាភិបាលទៅកាន់គណៈអង្គមន្ត្រី (ដែលជាក្រុមប្រឹក្សានៃព្រះមហាក្សត្រ) និងតាមរយៈការដាស់តឿនលោកនាយករដ្ឋមន្ត្រីខ្លួនឯងផ្ទាល់យ៉ាងសម្ងាត់ឲ្យអនុវត្តនូវគោលជំហរបង្រួបបង្រួមគ្នាមួយ ។ ផ្ទុយទៅវិញ លោក ទក្សិណ គាំទ្រវិធានការតឹងរ៉ឹងមួយទៅវិញ មានជាអាទិ៍ ការប្រើច្បាប់អាជ្ញាសឹកដែលរឹតតែបន្ថែមសាំងទៅលើភ្លើង ដែលកំពុងតែឆេះស្រាប់ ។ ចុងបញ្ចប់ ក្រោយពីការបោះឆ្នោតខែកុម្ភៈ ឆ្នាំ ២០០៥ មក លោក ប្រេម បានធ្វើអន្តរាគមន៍ជាសាធារណៈដែលគួរឲ្យចាប់អារម្មណ៍មួយ ដូចបានជម្រាបម្ដងរួចមកហើយកាលពីខាងដើមអត្ថបទនេះ ។

លទ្ធផលគឺជាការសម្រេចចិត្តដ៏គួរឲ្យភ្ញាក់ផ្អើលរបស់លោក ទក្សិណ ដោយគាត់បានបង្កើតឲ្យមានគណៈកម្មការសម្រុះសម្រួលជាតិមួយ ហៅ «គណៈកម្មការឯករាជ្យដើម្បីសេចក្ដីសមានចិត្តជាតិ» (គ.ឯ.ស.) (คณะกรรมการอิสระเพื่อความสมานฉันท์แห่งชาติ National Reconciliation Commission) ដើម្បីដោះស្រាយវិបត្តិនៅតំបន់ភាគខាងត្បូង ។ គណៈកម្មការថ្មីមួយនេះ ដឹកនាំដោយលោក អានន្ទ ប័ន្យារជុន និងលោក ប្រវេស វៈសី ធ្វើជាអនុប្រធាន ។ ព្រឹត្តិការណ៍នេះបង្ហាញឲ្យឃើញថា នៅពេលដែលបញ្ហាណាមួយឈានដល់កម្រិតធ្ងន់ធ្ងរ សូម្បីតែនាយករដ្ឋមន្ត្រីដែលមានអំណាចខ្លាំងនិងមានធនធានសម្បើម ដូចជាលោក ទក្សិណ ក៏ដោយ ក៏ត្រូវតែឱនលំទោនចំពោះព្រះរាជឥទ្ធិពលដែរ ។ ដោយប្រជាប្រិយភាពរបស់លោក ទក្សិណ បានធ្លាក់ចុះជាបន្តបន្ទាប់ក្រោយពីការបោះឆ្នោតខែកុម្ភៈ ឆ្នាំ ២០០៥ មក «គណៈកម្មការឯករាជ្យដើម្បីសេចក្ដីសមានចិត្តជាតិ» (គ.ឯ.ស.) ស្ទើរតែក្លាយជានិមិត្តរូបនៃរដ្ឋាភិបាលបម្រុងមួយទៅហើយសម្រាប់ប្រទេសថៃ ដែលក្នុងនោះ មានមនុស្សប្រកបដោយគតិបណ្ឌិត និយមរាជាធិបតេយ្យអាស្រ័យបណ្ដាញ នាំគ្នាធ្វើពលិកម្មដើម្បីបន្តនិរន្តរភាពនៃស្មារតីរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៧ ។ ភាព

ខុសគ្នានេះ ឃើញមានយ៉ាងជាក់ច្បាស់នៅក្នុងកិច្ចពិភាក្សាយ៉ាងសំខាន់មួយ នៅតាមទូរទស្សន៍កាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៥ ស្ដីអំពីប្រធានបទភាគខាងត្បូង រវាងលោក អានន្ទ និងលោក ទក្សិណ ផ្សាយបន្តផ្ទាល់ចេញពីវិមានរដ្ឋាភិបាល÷ នាយករដ្ឋមន្ត្រី ២ រូប (១ រូបជាអតីតនាយករដ្ឋមន្ត្រី និង ១ រូបទៀតជានាយករដ្ឋមន្ត្រីកំពុងកាន់អំណាច) គំនិត ២ ទាក់ទងនឹងភាគខាងត្បូង (សន្តិភាពទល់នឹងសន្តិសុខ) និងទម្រង់នយោបាយផ្សេងគ្នាចំនួន ២ (វិចារណកម្មទល់នឹងការត្រួតត្រា) ។ ប៉ុន្តែ តាមការប្រកាសជាផ្លូវការភ្លាមៗ នូវអំណាចវិសាមញ្ញ (អំណាចក្នុងភាពអាសន្ន) យ៉ាងតឹងរ៉ឹង ដោយក្រឹត្យរបស់គណៈរដ្ឋមន្ត្រីនៅខែកក្កដា ឆ្នាំ ២០០៥ មានការកើនឡើងនូវការសង្ស័យថា លោក ទក្សិណ គ្មានភាពស្មោះត្រង់ក្នុងការស្វែងរកការសម្រុះសម្រួលណាមួយនៅក្នុងតំបន់ភាគខាងត្បូងឡើយ ។ ផ្ទុយទៅវិញ គេគិតថា លោក ទក្សិណ បង្កើត «គណៈកម្មការឯករាជ្យដើម្បីសេចក្ដីសមានច្ឆន្ទជាតិ» (គ.ឯ.ស.) (គណៈកម្មាការសម្រុះសម្រួលជាតិ) នេះឡើង គ្រាន់តែដើម្បីទប់ទល់នឹងការរិះគន់មកលើខ្លួនគាត់ប៉ុណ្ណោះស្របពេលជាមួយគ្នានោះ គាត់ប្រើប្រាស់អំណាចរដ្ឋ ដើម្បីយកឲ្យបានមកវិញនូវអំណាចខ្ពស់មួយលើរាជាធិ-បតេយ្យអាស្រ័យបណ្ដាញដែលកំពុងតែរឹងមាំសាជាថ្មីនេះ ។

## សេចក្ដីសន្និដ្ឋាន ៖ ការផ្លាស់ប្ដូរមុខមាត់ថ្មីនៃរាជាធិបតេយ្យអាស្រ័យបណ្ដាញ

ការជជែកគ្នាអំពីព្រះរាជអន្តរាគមន៍នៅក្នុងប្រទេសថៃ ច្រើនតែផ្ដោតលើសកម្មភាពដោយផ្ទាល់របស់ព្រះរាជាជាពិសេស ព្រឹត្តិការណ៍ខែតុលា ឆ្នាំ ១៩៧៣ ខែមេសា ឆ្នាំ ១៩៨១ និងខែឧសភា ឆ្នាំ ១៩៩២ ។ អត្ថបទនេះ បានលើកយកមកបញ្ជាក់អំពីព្រំដែនកំណត់នៃវិធីសាស្ត្រនេះ និងផ្ដល់ជាយោបល់ថា ដើម្បីអាចយល់ដឹងអំពីព្រះរាជអំណាចនៅក្នុងប្រទេសថៃបាន គេចាំបាច់ត្រូវយល់ថា ព្រះរាជអំណាចជាទម្រង់មួយនៃអភិបាលកិច្ចតាមបែបបណ្ដាញ ។ តាមធម្មតា ព្រះមហាក្សត្រថៃបំពេញកិច្ចការងារនេះតាមរយៈតំណាងនានា ដែលស្វះស្វែងពង្រីកឥទ្ធិពលនយោបាយរបស់ទ្រង់ ប៉ុន្តែ នៅចុងបញ្ចប់ ព្រះអង្គនៅតែមិនអាចសម្រេចបាននូវការត្រួតត្រាបានដែរ ។ ចាប់ពីក្រោយខែឧសភា ឆ្នាំ ១៩៩២ មក បែបបទនៃព្រះរាជអន្តរាគមន៍បានប្រែប្រួល ។ នៅពេលដែលព្រះមហាក្សត្រកាន់តែចម្រើនព្រះជន្មចាស់វស្សាទៅ ព្រះអង្គទំនងជាពុំសូវធ្វើព្រះរាជអន្តរាគមន៍ដោយផ្ទាល់ព្រះអង្គច្រើន ដូចពេលមុនទៀតឡើយ ។ ក្នុងពេលដោះស្រាយវិបត្តិនៃភាពស្របច្បាប់ ច្រើនតែធ្វើឡើងដោយអន្តរាគមន៍ពីលោក ប្រេម និងសមាជិកផ្សេងទៀតនៃគណៈអង្គមន្ត្រី (ក្រុមប្រឹក្សាព្រះមហាក្សត្រ) ។ បណ្ដាញរាជាធិបតេយ្យជួបប្រទះនឹងបញ្ហាចាប់តាំងពីមុនពេលដែលលោក ទក្សិណ ឡើងកាន់អំណាចមកម្ល៉េះ ។ ចាប់ពីក្រោយឆ្នាំ ១៩៩២ មក ភាពញឹកញយនៃព្រះរាជអន្តរាគមន៍ បញ្ជាក់ឲ្យឃើញច្បាស់អំពីផលលំបាកនៃការបន្តនិរន្តរភាពនៃឥទ្ធិពលរបស់ព្រះរាជវាំង ក្នុងអំឡុងយុគសម័យលិចអណ្ដែតនៃសេដ្ឋកិច្ច រួមផ្សំជាមួយនឹងតម្រូវការថ្មីខាងផ្នែកនយោបាយ និងអ្នកនយោបាយនិងមហាសេដ្ឋីថ្មីៗ ដ៏មានអំណាចខ្លាំងក្លា ។ លោក ប្រេម ខ្លួនឯង មានអាយុបងព្រះករុណា ៨ ឆ្នាំ ហើយកាន់តែពឹងពាក់ខ្លាំងទៅលើសហការីចាស់ៗ ដែលលទ្ធភាព ទស្សនវិស័យ និងឥទ្ធិពលរបស់អ្នកទាំងនោះ មានព្រំដែនកំណត់ដោយសារប្រវត្តិយោធាពីមុនមក ។

នៅក្នុងសម័យកាលរដ្ឋាភិបាលលោក ទក្សិណ ការតែងតាំងមន្ត្រីនានាក្នុងគណៈអង្គមន្ត្រី រឹតតែពាក់ព័ន្ធក្នុងរឿងនយោបាយខ្លាំងឡើង ។ មានបីករណី ដែលមនុស្សសំខាន់ក្នុងរដ្ឋាភិបាលមិនចុះសម្រុងជាមួយនឹងលោក

*ទក្សិណ ហើយបានចូលទៅក្នុងគណៈអគ្គមន្ត្រីភ្លាមៗ បន្ទាប់ពីពួកគាត់ចាកចេញពីរដ្ឋាភិបាលរួចមក ។ អ្នកទាំងបីរូបនោះ គឺលោក កេស្រម វឌ្ឍនជ័យ*[៣៩] (เกษม วัฒนชัย Kasem Watanachai) *ជារដ្ឋមន្ត្រីជំប្រឹក្សាផ្នែកអប់រំរបស់លោក ទក្សិណ, លោក ពលាករ សុវណ្ណរដ្ឋ*[៤០] (พลากร สุวรรณรัฐ Palakorn Suwanarat) *ជានាយកមជ្ឈមណ្ឌលចាត់ចែងការបរិហារខេត្តជាយដែនភាគខាងត្បូង, និងលោក សុរយុទ្ធ ចុល្លានន្ទ ជាអតីតមេបញ្ជាការយោធានិងមេបញ្ជាការកំពូល ។ លោក កេស្រម និងលោក សុរយុទ្ធ ត្រូវបានគេប្រើប្រាស់ធ្វើឲ្យគោលនយោបាយនៅក្នុងតំបន់ភាគខាងត្បូងរបស់លោក ទក្សិណ ចុះខ្សោយ ហើយជួយគាំទ្រលោក ប្រេម និងជួយបន្ទរភាសាដូចគ្នាមួយ ជាភាសារៀបចំចេញពីព្រះរាជវាំង ។ នេះគឺជាវិធីសាស្ត្រថ្មីមួយដែលមនុស្សសំខាន់ៗ ក្នុងប្រព័ន្ធរាជាធិ-បតេយ្យអាស្រ័យបណ្ដាញ បានព្រមព្រៀងគ្នារៀបចំឡើង ។ គឺវិធីសាស្ត្រថ្មីមួយនេះហើយ ដែលឆ្លុះបញ្ចាំងឲ្យឃើញពីជំហរនយោបាយដ៏រឹងមាំខ្លាំងរបស់លោក ទក្សិណ ។*

*ដោយប្រឈមមុខនឹងនាយករដ្ឋមន្ត្រីមួយរូប ដែលមានអំណាចនិងមានអាណត្តិគ្មានគូប្រដូច រាជាធិបតេយ្យអាស្រ័យបណ្ដាញ ត្រូវតែជ្រើសរើសយកការវាយបករបស់ខ្លួនយ៉ាងប្រយ័ត្នប្រយែង និងត្រូវត្រៀមកម្លាំងធនធានទាំងអស់ដែលមានដើម្បីអនុវត្តការវាយបកទាំងនោះ ។ ចាប់តាំងពីក្រោយឆ្នាំ ១៩៩២ រួចមក អ្នកសេរីនិយមខាងរាជានិយម ដូចជាលោក ប្រវេស និងលោក អានន្ទ បានស្វះស្វែងដើម្បីរៀបចំរាជាធិបតេយ្យអាស្រ័យបណ្ដាញឡើងវិញ ដោយសង្គ្រោះព្រះរាជវាំងពីក្រញាំក្រុមអភិរក្សនិយមជ្រុល និងប្រើប្រាស់រាជាធិបតេយ្យអាស្រ័យបណ្ដាញនេះធ្វើជាយានដើម្បីលើកស្ទួយការកែទម្រង់នយោបាយ ។ ទោះជាយ៉ាងនេះក្ដី លទ្ធផលដែលគេមិនប្រាថ្នាចង់បានពីចលនាកែទម្រង់នោះ គឺការរះឡើងរបស់នាយករដ្ឋមន្ត្រី ទក្សិណ ជិនវ័ត្រ ដែលមានទ្រព្យសម្បត្តិមហាសាលនិងមានអំណាចខ្លាំងក្លានេះ បានបង្ខំចិត្តឲ្យរាជាធិបតេយ្យអាស្រ័យបណ្ដាញកសាងខ្លួនចេញពីទីតាំងដែលមានភាពចុះខ្សោយខ្លាំងនោះឡើងវិញ ។ បើទោះបីជាព្រះរាជវាំងធ្លាប់មានជោគជ័យជាក់ស្ដែងកន្លងទៅក្នុងការដោះស្រាយបញ្ហាវិបត្តិភាពស្របច្បាប់ជាតិក្នុងឆ្នាំ ១៩៩៧ ឆ្នាំ ២០០១ និងឆ្នាំ ២០០៤ យ៉ាងណាក៏ដោយ ក៏សមិទ្ធិផលទាំងនេះមានភាពមិនច្បាស់លាស់នៅឡើយ ហើយឈ្នះដោយសារតែការប្រើប្រាស់ថាមពលកាន់តែប្រសើរឡើង ។ នៅពេលដែលលោក ទក្សិណ ចាប់ផ្ដើមការងាររបស់គាត់នៅអាណត្តិទីពីរនោះមក ប្រព័ន្ធនយោបាយក្រៅផ្លូវការនៃរាជាធិបតេយ្យអាស្រ័យបណ្ដាញ ដែលមានដំណើរការក្នុងប្រទេសថៃអស់ពេលបីទសវត្សរ៍ទៅហើយនោះ មើលទៅដូចជាខិតជិតទៅរកភាពចុះខ្សោយជាពន់ពេក*[៤១] ៕

# ជំពូកទី ៤

## របៀបដែលជនជាតិវៀតណាមសម្លឹងមើលពិភពលោក

*ច្បាប់ដើមនៃអត្ថបទនេះ សរសេរជាភាសាអង់គ្លេស ក្រោមចំណងជើងថា ÷***How the Vietnamese See the World**
*អត្ថបទនេះដកស្រង់ចេញពីសៀវភៅ ÷* **ឈ្វេងយល់ពីវៀតណាម**
*រក្សាសិទ្ធិ គ.ស. ១៩៩៣ ដោយ ឌី រីហ្សិនត្ស៍ អហ្វ ឌី យូនីវ៉ឺស៊ីធី អហ្វ ខាលីហ្វ័រនៀ*

CHAPTER4

How the Vietnamese See the World

*( Understanding Vietnam)*

**Copyright © 1993 by The Regents of The University California.**

**បកប្រែដោយ ៖ មួង ណារ៉េត**

# ជំពូកទី ៤
# របៀបដែលជនជាតិវៀតណាមសម្លឹងមើលពិភពលោក

> «ពុំមែនជាអំពើទេ ប៉ុន្តែគឺជាយោបល់អំពីអំពើ ដែលរំខានដល់ចិត្តមនុស្ស ។» (តាមប្រសាសន៍របស់លោក អេពិចតែត ជាទស្សនវិទូ ១ រូបក្នុងចក្រភពរ៉ូម កើតប្រមាណ គ.ស. ៥០ អនិច្ចកម្មប្រមាណ គ.ស. ១៣០)

ក្នុងអំឡុងសតវត្សរ៍ទី ២០ ប្រទេសវៀតណាមស្ថិតក្នុងសភាពប្រែប្រួលយ៉ាងខ្លាំង ហើយទទួលរងការបែកបាក់ដោយសារផ្នត់គំនិត ដែលមានសភាពផ្ទុយគ្នាក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ។ អស់រយៈពេលជាងប្រាំមួយទសវត្សរ៍មកទល់ពេលនេះក្តី គេច្រើនមើលតែសភាពផ្លាស់ប្តូរនិងបដិវត្តន៍ ។ ក្នុងទសវត្សរ៍ឆ្នាំ ១៩៣០ ការជជែកពិភាក្សាគ្នាជាច្រើននៅក្នុងប្រទេស បានជជែកដេញដោលអំពី «អ្វីដែលចាស់» និង «អ្វីដែលថ្មី» ។ របៀបទាក់ទងគ្នាក្នុងសង្គម ការចង់បានមុខមាត់ របៀបស្លៀកពាក់ ការរៀបការតាមទំនៀមទម្លាប់ អក្សរសិល្ប៍ ជំនឿសាសនា ការព្យាបាលជម្ងឺ រហូតដល់របៀបរៀបចំសក់ មានភាពប្លែកៗ គ្នា នៅជុំវិញបរិបទនេះ ។ អ្នកវណ្ណៈថ្នាក់កណ្តាលនៅក្នុងទីក្រុង ដែលបានទទួលការអប់រំតាមរបៀបបស្ចិមប្រទេស មានចំនួនកើនឡើង ហើយបានបង្កើតឧស្សាហកម្មផ្នែកបោះពុម្ពផ្សាយថ្មីមួយ ដើម្បីបញ្ចេញមតិយោបល់ និងដើម្បីធ្វើជាវេទិកាសម្រាប់ប្រកួតប្រជែងដណ្តើមយកឥទ្ធិពលនៃការប្រមើលមើលអំពីអនាគតរបស់ពួកគេ ។ អ្នកនិពន្ធវ័យក្មេងជាច្រើនបានអះអាងថា មនោសញ្ចេតនាផ្សារភ្ជាប់យ៉ាងជ្រាលជ្រៅទៅនឹងវប្បធម៌បុរាណ គឺជាមូលហេតុដ៏ចម្បងរាំងស្ទះដល់ដំណើរការវិវឌ្ឍ ។

ក្នុងទសវត្សរ៍ឆ្នាំ ១៩៣០ ពួកកុម្មុយនីស្តដែលមានចំនួនតិចតួចនោះ មានផែនការមួយដែលពួកនោះបានអះអាងថា វាបានធ្វើឲ្យគេមើលឃើញយ៉ាងច្បាស់ពីអនាគត ។ តែមុនសង្គ្រាមលោកលើកទី ២ បញ្ញវន្តវៀតណាមវ័យក្មេងភាគច្រើន មិនពេញចិត្តនូវអ្វីដែលមានពីមុនមកនោះទេ ហើយពួកគេយល់ថា ប្រទេសវៀតណាមត្រូវតែស្វែងរក ឬបង្កើតនូវអត្តសញ្ញាណទំនើបមួយដែលមាននិរន្តរភាព ។ ដូចដែល លោក ញ៉ឹត លិញ (Nhất Linh) និពន្ធនាយកនៃកាសែតភាសាវៀតណាម ដ៏មានប្រជាប្រិយភាពមួយរូប បានបញ្ជាក់នៅឆ្នាំ ១៩៣២ ថា ៖

> នៅពេលដែលយើងយកអារ្យធម៌បុរាណមកបង្ហាញ ហើយអនុវត្តនៅចំពោះមុខយើង យើងមិនពេញចិត្តនឹងលទ្ធផលទាំងនោះឡើយ ។ យើងបានត្រឹមតែសង្ឃឹមតទៅទៀតលើអារ្យធម៌បស្ចិមប្រទេសប៉ុណ្ណោះ ។ ពួកយើងមិនដឹងថា តើអារ្យធម៌បស្ចិមប្រទេសនោះនឹងនាំពួកយើងទៅកន្លែងណាទេ ក៏ប៉ុន្តែវាសនាពួកយើងនឹងធ្វើដំណើរទៅកាន់ពិភពដែលគ្មាននរណាមួយដឹង ដើម្បីបន្តការផ្លាស់ប្តូរនិងវឌ្ឍនភាព ។ (*Phong Hóa* **ផង់ហ្វា** [ទម្លាប់] ២០ តុលា គ.ស. ១៩៣២) ។

ប៉ុន្តែ ថា តើការផ្លាស់ប្តូរនេះទៅជាអ្វី ? ផ្លាស់ប្តូរទៅជាមនុស្សប្រភេទណា ? សង្គមបែបណា ? សំណួរទាំងអស់នេះហើយ ដែលជាដើមហេតុបង្កឲ្យមានការប្រទូសរ៉ាយគ្នាអស់រយៈពេលជាច្រើនទសវត្សរ៍ ។

មនោគមវិជ្ជាផ្សេងៗគ្នា ដែលបានប្រកួតប្រជែងគ្នា មានការពាក់ព័ន្ធទៅនឹងបញ្ហាទំនើបនីយកម្ម ។ មនុស្សម្នាមានការបែងចែកជាពួក ដោយសារមានគំនិតផ្សេងគ្នា សូម្បីតែនៅក្នុងគ្រួសារ ។ អ្វីដែលស្មុគស្មាញជាងនេះទៀតនោះ គឺយើងឃើញមានភាពខុសគ្នាតាមតំបន់នៅក្នុងប្រទេសវៀតណាមតាំងពីពេលមុនមកម៉្លេះ ។

តាមយោបល់ខ្ញុំ ទាំងភាពខុសគ្នាតាមតំបន់និងការជជែកដេញដោលគ្នា រវាងអ្នកតស៊ូមតិនៃការប្រកួតប្រជែងមនោគមវិជ្ជា សុទ្ធតែជាលទ្ធផលដែលបានមកពីវប្បធម៌បុរាណ ឬដែលជាការឆ្លើយតបទៅនឹងវប្បធម៌បុរាណដ៏មានឥទ្ធិពលនោះ ។ រាល់ការផ្លាស់ប្តូរនិងភាពខុសគ្នាសំខាន់ៗ គឺជាការឆ្លើយតបទៅនឹងកាលៈទេសៈមួយ (ដែលអាចជាបញ្ហាបរិស្ថាន នយោបាយ សង្គម) ពោលគឺ ដោយសារតែវប្បធម៌បុរាណគ្មានលក្ខណៈគ្រប់គ្រាន់ដើម្បីទប់ទល់នឹងបញ្ហាទាំងនោះបាន ។ ទោះជាមានភាពខុសគ្នា និងមានការប្រែប្រួលយ៉ាងណាក៏ដោយ ក៏វប្បធម៌វៀតណាមនៅ ស.វ. ទី ១៩ ជាផ្នែកដ៏សំខាន់ក្នុងគំនិតច្នៃប្រឌិតថ្មីៗ នា ស.វ. ទី ២០ ។ ការចងចាំពីអតីតកាលនៅតែជាផ្នែកសំខាន់នៃប្រព័ន្ធសង្គមវប្បធម៌វៀតណាមទាំងឡាយនាសម័យបច្ចុប្បន្ន ពោលគឺចាប់ពីគណៈកម្មាធិការប្រតិបត្តិបក្សកុម្មុយនីស្តក្នុងក្រុងហាណូយដល់សៃហ្គនតូច (Little Saigon) នៅទីក្រុងឡូសអែនជីលែស (Los Angeles) និងរហូតដល់សៃហ្គនសៀរសែន (Saigon-sur-Seine) នៅទីក្រុងប៉ារីស ។

អ្វីដែលនឹងរៀបរាប់ក្នុងទំព័រជាបន្តបន្ទាប់នេះ គឺសំដៅទៅលើទិដ្ឋភាពរួមមួយរបស់ «វៀតណាមបុរាណ» ដែលមាននៅក្នុងផ្នត់គំនិតមនុស្សជំនាន់ថ្មី ។ « វៀតណាមបុរាណ» នេះ ជារូបភាពទូទៅមួយដែលបានប្រមូលពីប្រភពអក្សរសិល្ប៍ល្បីៗ ដែលមានបង្រៀនក្នុងសៀវភៅសិក្សាទូទៅ សំណេរជីវប្រវត្តិ និងសំណេរប្រវត្តិសាស្ត្រល្បីល្បាញ ការសន្ទនាជាមួយនឹងជនជាតិវៀតណាមគ្រប់ស្រទាប់វណ្ណៈ ការសំណេះសំណាលរំពុកពីអតីតកាលក្នុងពេលទទួលទានទឹកតែឬស្រានៅក្នុងផ្ទះអ្នកភូមិ ឬនៅក្នុងរថយន្តហ្ស៊ីប នៅក្នុងវត្តអារាម ព្រះវិហារ ឬ ក្លឹបកម្សាន្តពេលរាត្រីនៅក្រុងព្រៃនគរ នៅក្នុងកន្លែងធ្វើការ ថ្នាក់រៀន និងនៅក្នុងជំរំជនភៀសខ្លួន ។

យើងត្រូវរៀនសូត្រពីអ្វីដែលមនុស្សបានដក់ជាប់ក្នុងចិត្ត នៅពេលពួកគេនិយាយអំពីអ្វីដែល «ចាស់» មុននឹងគេអាចយល់បាននូវការជជែកដេញដោលរបស់ពួកគេ ពាក់ព័ន្ធទៅនឹងអ្វីដែល «ថ្មី» ដែលអាចនឹងជំនួសរបស់ចាស់នោះ ។ ប្រជាជនវៀតណាមបច្ចុប្បន្ន មិនខុសគ្នាពីប្រជាជនវៀតណាមកាលពី ៥០ ឆ្នាំមុនទេ ពោលគឺពួកគេកំពុងផ្សារភ្ជាប់ខ្លួនទៅនឹងអតីតកាល ដើម្បីរៀបចំខ្លួនសម្រាប់អនាគតកាល ។

បទពិសោធន៍របស់មនុស្សម្នាដែលស្គាល់ប្រទេសវៀតណាម ឬធ្លាប់បានរស់នៅក្នុងប្រទេសនេះ ឥឡូវនេះក្លាយជាចំណែកមួយនៃខ្លួនពួកគេ ហើយពួកគេវិញ ក៏ជាចំណែកមួយរបស់ប្រទេសវៀតណាមផងដែរ ។ គេមិនអាចបំភ្លេចប្រទេសវៀតណាមបានទេ ហើយពួកគេក៏មិនអាចដាក់អ្វីៗ ដែលពួកគេដឹងអំពីប្រទេសមួយនេះឲ្យសមស្របទៅនឹងអត្ថន័យរបស់ប្រទេសនេះអស់បានដែរ ។ ភាពតានតឹងនៅតែបន្តកើតមាន ពោលគឺវាកើតឡើងពីភាពមិនស្របគ្នារវាងការចងចាំ និងទស្សនៈរបស់គេថា តើគេជានរណា និងតើគេនៅកន្លែងណាមួយឲ្យពិតប្រាកដនៅក្នុងពិភពលោក ។ គេបានខិតខំរកវិធីដោះស្រាយភាពតានតឹងនេះ ដោយពិនិត្យឡើងវិញនូវទស្សនៈចំពោះខ្លួនឯង ចំពោះសង្គម និងចំពោះពិភពលោកដ៏ធំទូលាយ ឬតាមវិធីនៃការបំភ្លេចចោលនូវការចងចាំទាំងអស់នេះ ឬធ្វើមិនដឹងមិនឮអំពីសារៈសំខាន់របស់ការចងចាំទាំងអស់នេះ ។ ប៉ុន្តែ ការមិនចុះសម្រុងនៅតែមាន ហើយតួនាទីជាបុគ្គលរបស់យើង ក៏ដូចជាតួនាទីរបស់មនុស្សម្នាក់ នៅតែមិនទាន់ល្អគ្រប់គ្រាន់នៅឡើយ ។

បើដាក់នូវគំនិតចាស់ និងមិនទាន់ពេញលេញនោះ ទៅក្នុងបរិបទថ្មីនិងទូលំទូលាយ ជនជាតិអាមេរិកាំងអាចនឹងធ្វើការកែប្រែទស្សនៈនោះបាន ។ ពួកគេអាចសិក្សាឲ្យយល់ដឹងអំពីបែបបទនៃការប្រកួតប្រជែងរបស់ជនជាតិវៀតណាមនោះ ។ ពួកគេគេអាចនឹងឈានទៅរកការជម្រះមន្ទិលនៃការចង់ចេះចង់ដឹងរបស់ពួកគេ ពីរឿងរ៉ាវក្នុងប្រទេសវៀតណាមនេះបាន ហើយប្រហែលជាតាមរយៈដំណើរកែប្រែនេះ វាធ្វើឲ្យពួកគេយល់ដឹងនូវចំណុចវិជ្ជមានបន្ថែមលើបញ្ហានិងចម្ងល់ដែលមានយូរមកហើយនេះ ។ ក្នុងការប្រឹងប្រែងឈ្វេងយល់អំពីប្រជាជនវៀតណាមនោះ ពួកអាមេរិកាំងប្រហែលជាអាចរៀនសូត្រអំពីរឿងរ៉ាវសំខាន់របស់ខ្លួនគេបានដែរ ។

## ទឹកដីប្រទេសវៀតណាម៖ បរិស្ថានធម្មជាតិជាប្រវត្តិសាស្ត្រ

សាធារណរដ្ឋសង្គមនិយមវៀតណាម គឺជាប្រទេសមួយដែលនៅក្នុងចំណោមប្រទេសមានចំនួនប្រជាពលរដ្ឋច្រើនជាងគេ ស្ថិតនៅលំដាប់ទី ១២ នៅក្នុងពិភពលោក[១] ។ ទោះបីប្រទេសវៀតណាមជាប្រទេសដែលមានកម្លាំងយោធាដ៏រឹងមាំច្រើនជាងគេមួយក្នុងពិភពលោកក៏ដោយ ក៏នៅតែជាប្រទេសក្រីក្របំផុតមួយលើពិភពលោកផងដែរ ។ ទឹកដីប្រទេសវៀតណាម មានទំហំតូចជាងរដ្ឋខាលីហ្វ័រនៀបន្តិច ប៉ុន្តែមានប្រជាជន ៧០ លាននាក់[២] ច្រើនជាងមួយភាគបួននៃចំនួនប្រជាពលរដ្ឋនៅសហរដ្ឋអាមេរិកទាំងមូល ។ ប្រទេសវៀតណាមលាតសន្ធឹងតាមបណ្តោយអ័ក្សវែងស្តួចមួយពីជើងទៅត្បូង ដែលអូសកាត់ចេញពីប្រទេសចិនទៅដល់ឈូងសមុទ្រសៀម ។ វៀតណាមជាប្រទេសតូចចង្អៀតមួយ ដែលមានប្រជាជនច្រើន រស់នៅរាយប៉ាយតាមផ្ទៃដីដ៏តូចនេះ ។ បរិស្ថានភូមិសាស្ត្របានបង្ខំប្រជាជនឲ្យប្រមូលផ្តុំគ្នាយ៉ាងណែនណាន់តាន់តាប់ ។ ប្រជាជនភាគច្រើនរស់នៅលើផ្ទៃដីដ៏តូចចង្អៀត ។

មានតែមួយភាគបួននៃទឹកដីវៀតណាមប៉ុណ្ណោះ ដែលជាដីល្អសម្រាប់ធ្វើស្រែចម្ការបាន (ដោយសារដីនោះមានអំណោយផលល្អដល់ដំណាំស្រូវរដូវវស្សា) ហើយនោះគឺជាផ្ទៃដីដែលមានជនជាតិអម្បូរយួន ចំនួន ៨៥% នៃចំនួនប្រជាជនសរុប ផ្តុំរស់នៅ ។ វាលស្រែលិចទឹក ប្រជាជន និងអំណាចនយោបាយ ÷ បញ្ហាទាំងបីនេះមានការផ្សារភ្ជាប់គ្នា ហើយមានការប្រមូលផ្តុំខ្លាំងក្នុងតំបន់តូចៗ ។ សូម្បីតែពេលបច្ចុប្បន្ននេះ វាលស្រែមួយភាគធំ ប្រជាជនភាគច្រើន ភោគទ្រព្យឧស្សាហកម្មភាគច្រើន សកម្មភាពសេដ្ឋកិច្ច នយោបាយ និងវប្បធម៌ភាគច្រើន ឃើញមានតែនៅក្នុងតំបន់គោលសំខាន់មួយក្នុងចំណោមតំបន់សំខាន់ៗ ចំនួនពីរ ។ តំបន់សំខាន់ទី ១ គឺតំបន់ដីសណ្តទន្លេក្រហមនិងទីក្រុងហាណូយនៅភាគខាងជើង ។ ឯតំបន់មួយទៀត គឺតំបន់ដីសណ្តទន្លេមេគង្គ និងទីក្រុងហូជីមិញ (អតីតទីក្រុងសៃហ្គន ឬ ព្រៃនគរ) នៅភាគខាងត្បូង ។ ប្រជាជនដែលប្រមូលផ្តុំនៅក្នុងតំបន់សំខាន់ៗ ទាំងពីរនេះ បានផ្សារភ្ជាប់គ្នាដោយសារជួរវាលទំនាបមាត់សមុទ្រ តាមបណ្តោយឆ្នេរសមុទ្រចិនខាងត្បូង ។ ផ្ទៃដីកណ្តាលភាគច្រើនរបស់ប្រទេសវៀតណាម គឺជាតំបន់ភ្នំដែលមានជនជាតិភាគតិចរស់នៅ តាំងពីយូរលង់មកហើយ ។ ប្រជាជនវៀតណាមទូទៅនាំគ្នាចាត់ទុកថា ពួកកុលសម្ព័ន្ធទាំងនេះជា «ក្រុមមនុស្សមិនទាន់សម័យ» ។

កត្តាបរិស្ថានធម្មជាតិនិងប្រវត្តិសាស្ត្របានត្រូវផ្សំបញ្ចូលគ្នា បង្កើតបានជាតំបន់សំខាន់និងមានលក្ខណៈដោយឡែកពីគ្នា នៅវាលតំបន់ស្នូលទាំងពីរ ដែលគ្របដណ្តប់លើប្រទេសទាំងមូល[៣] ។ ទន្លេក្រហមប្រឈមនឹងការឡើងចុះយ៉ាងរហ័សនៃកម្រិតទឹក ហើយទឹកជំនន់ រួមទាំងភាពរាំងស្ងួត បានផ្តល់ការគំរាមកំហែងជាប្រចាំ ។ ពេល

ពាតត្បាត និងការបីឱយាយពីពីសំណាក់សត្វល្អិតចង្រៃ កើតមានឡើងជាទៀងទាត់ផងដែរ ។ ដីសណ្តទន្លេក្រហម គឺជាកន្លែងដែលមានប្រជាជនរស់នៅច្រើនកុះករ តែដីសណ្តនេះក៏ជាតំបន់ដែលនៅក្នុងចំណោមតំបន់ដែលមានសុវត្ថិភាពតិចជាងបំផុតនៅក្នុងពិភពលោកយើងនេះ ។ នៅក្នុងបរិស្ថានមិននឹងន និងប្រកបដោយគ្រោះថ្នាក់ ភាពអត់ឃ្លាននិងកោលាហលសង្គម គឺជាគ្រោះគំរាមកំហែងឥតឈប់ឈរ ។ នេះជាលទ្ធផលដែលធ្វើឲ្យវប្បធម៌ក្នុងស្រុកផ្តោតជាសំខាន់ទៅលើគោលការណ៍សមូហភាពគ្រួសារ និងសមូហភាពភូមិ-ស្រុក ជាងផ្តោតទៅលើបុគ្គលម្នាក់ៗ ។ ទាំងក្នុងគ្រួសារនិងក្នុងភូមិ-ស្រុក មានសភាពស្និទ្ធស្នាលនឹងគ្នា មានសហករណ៍ មានការពឹងពាក់លើខ្លួនឯង និងមានការទទួលខុសត្រូវចំពោះអំពើរបស់សមាជិកម្នាក់ៗ ។

នៅភាគខាងត្បូង ទឹកទន្លេមេគង្គបានហូរចាក់ចូលទៅបឹងទន្លេសាប ដែលជាបឹងមួយនៅឆ្ងាយពីមាត់សមុទ្រនៅក្នុងប្រទេសកម្ពុជា ហើយអាចស្រូបយកទឹកដែលហូរជន់ ដើម្បីទៅបំពេញបន្គ្រប់ផ្ទៃបឹងទាំងមូល ។ បរិស្ថានទន្លេមេគង្គ អាចស្មានទុកជាមុនបាន ហើយមានគ្រោះថ្នាក់តិចជាងបរិស្ថានទន្លេក្រហម ។ ភាពខុសគ្នាខាងធម្មជាតិរវាងទន្លេក្រហមនិងដីសណ្តមេគង្គ គឺជាកត្តាសំខាន់ខ្លាំងមួយក្នុងការបង្កើតឲ្យមានភាពខុសគ្នានៅក្នុងវប្បធម៌ និងការរៀបចំសង្គម រវាងតំបន់សំខាន់ៗ ទាំងពីរនៃប្រទេសវៀតណាមនេះ ។ ដីសណ្តទន្លេមេគង្គបានក្លាយជាតំបន់ជួរមុខនាពេលបច្ចុប្បន្ននេះ ។ រហូតដល់ ស.វ. ទី ១៧ ទើបប្រជាជនវៀតណាម ចាប់ផ្តើមមករស់នៅតំបន់ដីសណ្តខាងត្បូង ហើយតំបន់ដីសណ្តទន្លេមេគង្គខាងក្រោម មិនទាន់មានមនុស្សរស់នៅឲ្យបានច្រើនកុះករនៅឡើយទេរហូតដល់ ស.វ. ទី ១៩ ។

ជីវភាពរស់នៅ មានភាពងាយស្រួលនិងមានសុវត្ថិភាពនៅក្នុងតំបន់ភាគខាងត្បូងវៀតណាម ដែលស្មើនឹងមួយភាគបីនៃផ្ទៃប្រទេស ។ រីឯស្ថានភាពរស់នៅក្នុងតំបន់ភាគខាងជើង មានវិន័យតឹងរ៉ឹងជាងភាគខាងត្បូង ។ ភូមិឋាននៅភាគខាងត្បូង តែងតែមានលក្ខណៈបើកទូលាយនិងមិនសូវសហការគ្នា ហើយអនុញ្ញាតឲ្យបុគ្គលមានគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន និងការមិនសូវគោរពប្រតិបត្តិលើវប្បធម៌បុរាណ ។ ក្រោយមក នៅក្រោមការគ្រប់គ្រងរបស់បារាំងសែស ដែលចាប់ផ្តើមដាក់នឹមអាណានិគមនៅប្រទេសវៀតណាមក្នុងឆ្នាំ ១៨៥៩ តំបន់ខាងត្បូងដែលហៅថា កូសាំងស៊ីន គឺជាផ្នែកដំបូងដែលត្រូវស្ថិតនៅក្រោមអាណានិគម ហើយតំបន់នេះស្ថិតនៅក្រោមការត្រួតត្រារបស់អាជ្ញាធរបារាំងដោយផ្ទាល់ ។ ដូច្នេះហើយ បានជាតំបន់ភាគខាងត្បូងរងនូវឥទ្ធិពលបស្ចិមប្រទេស និងមានសេរីភាពនយោបាយ ច្រើនជាងតំបន់ផ្សេងៗ ទៀតនៅក្នុងប្រទេស ដែលត្រូវគេដាក់អាណាព្យាបាលនៅលើផ្នែកនោះនៅពេលក្រោយទៀត (អណ្ណាមនៅភាគកណ្តាលនៃប្រទេសវៀតណាម និងតុងកឹងនៅភាគខាងជើង) ។ បារាំងបានដាក់ចូលជាធរមានក្នុងច្បាប់របស់ខ្លួននៅពេលក្រោយមក ហើយបានត្រួតត្រាដោយប្រយោល តាមរយៈភ្នាក់ងាររដ្ឋការវៀតណាមក្នុងស្រុក ។

ដូច្នេះ យើងមានរបៀបសាមញ្ញពីរក្នុងការជជែកពីភូមិសាស្ត្រប្រទេសវៀតណាម ។ យើងគិតដល់ភាគខាងជើង និងភាគខាងត្បូងថា បានចែកដាច់ពីគ្នាដោយខ្សែស្របទី ១៧ ។ ប្រការនេះសមស្របនៅក្នុងលក្ខខណ្ឌនយោបាយនាពេលថ្មីៗ នេះ ។ ប្រការនេះសមហេតុផលទៅតាមប្រវត្តិសាស្ត្រផងដែរ ព្រោះប្រទេសវៀតណាម ចែកដាច់ពីគ្នាជាពីរភាគនៅក្នុង ស.វ. ទី ១៧ និងទី ១៨ ផងដែរ ។ ប៉ុន្តែ ប្រជាជនវៀតណាមនិយាយយ៉ាងសាមញ្ញអំពីការបែងចែកប្រទេសនេះជាបីផ្នែក គឺ ភាគខាងជើង ភាគកណ្តាល និងភាគខាងត្បូង ។ ហើយប្រការនេះសមហេតុផលផងដែរ

ខាងផ្នែកវប្បធម៌ និងភាសាវិទ្យា ទោះបីជាប្រជាជនយួនមានវប្បធម៌រួមមួយ មានបេតិកភណ្ឌប្រវត្តិសាស្ត្ររួម និងនិយាយគ្រាមភាសាចេញពីភាសារួមដែលអាចស្ដាប់គ្នាបាន ។

ចំណុចសំខាន់នៅទីនេះ គឺថា វៀតណាម «បុរាណ» សំដៅមុនដំបូងទៅលើដីសណ្ដទន្លេក្រហមនិងតំបន់វាលទំនាបមាត់សមុទ្រផ្នែកកណ្ដាល ហើយសំដៅទៅលើទំនៀមទម្លាប់ ដែលធ្លាប់មាននៅក្នុងភាគទាំង ២ នេះ នៅក្នុងសតវត្សរ៍ទី ១៩ នោះ ។ ការពិភាក្សានេះមិនសំដៅដោយផ្ទាល់ទៅនឹងភូមិឋានដីសណ្ដទន្លេមេគង្គឡើយ ។ តាមការពិត ពេលដែលបារាំងសែសចូលមកដំបូង តំបន់ដីសណ្ដមេគង្គមានប្រជាជនយួនមួយភាគតូចប៉ុណ្ណោះ ដែលបានតាំងលំនៅនៅទីនោះ ។ បារាំងបានបើកឲ្យមានការតាំងលំនៅនៅដីសណ្ដមេគង្គយ៉ាងច្រើន ដោយសារមានគម្រោងវិស្វកម្មធំៗ ដែលបូមដីភក់ល្បាប់ ដើម្បីធ្វើការដាំដុះ ។

## ប្រជាជនប្រទេសវៀតណាម

រឿងស្ដីពីបណ្ដាជនជាតិទាំងឡាយនៅក្នុងប្រទេសវៀតណាមបច្ចុប្បន្ន ចាប់ផ្ដើមឡើងនៅក្នុងតំបន់ភាគខាងជើង(៤) ។ រាប់ពាន់ឆ្នាំកន្លងទៅ អម្បូរអូស្ត្រូណេស៊ី ដែលជាញាតិសន្ដានឆ្ងាយនៃប្រជាជនដែនកោះអាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក គឺជាផ្នែកមួយដ៏សំខាន់នៃចំនួនប្រជាជនដែលរស់នៅក្នុងតំបន់នេះ ។ ក្រោយមក ប្រហែលជា ៤ ទៅ ៥ ពាន់ឆ្នាំកន្លងទៅ ប្រជាជន ភាសា និងវប្បធម៌មួយចំនួន បានហូរចេញទៅក្រៅពីតំបន់ដែលឥឡូវនេះជាប្រទេសចិនភាគខាងត្បូង មកតាំងលំនៅនៅតំបន់អាស៊ីអាគ្នេយ៍ ហើយបានលាយឡំនឹងអ្នកស្រុកដើម និងភាសារបស់ពួកគេ ។ ប្រជាជន ភាសា និងវប្បធម៌ទាំងឡាយនៅប្រទេសវៀតណាមខាងជើងនិងខាងត្បូងនេះ បានមកពីប្រភពចម្រុះដ៏សម្បូរបែប រួមទាំងឥទ្ធិពលផ្សេងៗ បន្ថែមទៀត ។ ភាសាវៀតណាមជាភាសាស្ថិតនៅក្នុងអម្បូរភាសាមន-ខ្មែរ ដែលមានការជាប់ទាក់ទងគ្នានឹងភាសាខ្មែរ ។ ប៉ុន្តែ ឥទ្ធិពលអម្បូរភាសាតៃ (ដែលបង្កើតភាសាថៃនិងភាសាលាវនាពេលសព្វថ្ងៃនេះ) ធ្វើឲ្យមានស្នៀង (សម្លេងឡើងចុះ) ហើយពាក្យសម្ដីមួយចំនួនធំមកពីបណ្ដាភាសាតៃទាំងនេះ(៥) ។ ប្រជាជនវៀតណាមសម័យដើម មានលក្ខណៈស្រដៀងគ្នាច្រើនជាមួយនឹងប្រជាជនអាស៊ីអាគ្នេយ៍ដែលនៅជិតខាងខ្លួន ។ ឥទ្ធិពលពីចិនមានសារៈសំខាន់យ៉ាងខ្លាំង ប៉ុន្តែទើបតែមាននាពេលក្រោយមក ។ នៅពេលដែលពន្ធុ (ហ្សែន) ភាសា និងវប្បធម៌ ចាប់ផ្ដើមមានទំនាក់ទំនងគ្នានិងច្របល់លាយឡំគ្នាទៅវិញទៅមក និងវិវឌ្ឍទៅយ៉ាងខ្លាំងនៅក្នុងតំបន់ដែលឥឡូវនេះ ជាទឹកដីឥណ្ឌូចិនភាគខាងជើងនោះ ប្រមាណជាប្រាំពាន់ឆ្នាំកន្លងទៅ ទឹកដីមួយផ្នែកធំនៃតំបន់នេះ ដែលឥឡូវជាដីសណ្ដទន្លេក្រហម គឺស្ថិតនៅក្រោមទឹកនៅឡើយ ដោយសារតែកម្រិតកំពស់ទឹកសមុទ្រគ្របដណ្ដប់តំបន់នេះ អស់រយៈកាលជាច្រើនសហស្សវត្សរ៍មកនោះ នៅមិនទាន់ស្រកចុះអស់ទាំងស្រុងនៅឡើយទេ(៦) ។ ចំពោះតំបន់ដែលទឹកសមុទ្របានស្រកទៅអស់នោះ ក៏បានក្លាយជាទំនាបល្បាប់ ។ ប្រហែល ៣ ឬ ៤ ពាន់ឆ្នាំមុននេះ នៅតំបន់ភាគកណ្ដាល តាមជើងភ្នំនិងជុំវិញជ្រលងទន្លេក្រហម មានប្រជាជនរស់នៅដែលមានវប្បធម៌ច្បាស់លាស់មួយ ដែលជាបុព្វបុរសរបស់ជាជនជាតិវៀតណាមបច្ចុប្បន្ន ។ បុរាណវិទូវៀតណាមបានតាមដានរកមើលស្លាកស្នាមដើមកំណើតប្រជាជនទាំងនេះ រហូតដល់តំបន់ទំនាបដែលលេចរូបឡើងនិងនៅក្នុងសម័យកាលប្រវត្តិសាស្ត្រផងដែរ ។

មានពេលមួយនោះ នៅក្នុងអំឡុង ស.វ. ទី ៧ មុនគ្រិស្តសករាជ នៅក្នុងនិងនៅម្ដុំតំបន់ដែលទន្លេក្រហម

ហូរចុះមកពីតំបន់ភ្នំ កាត់តាមវាលទំនាប មានការកកើតបានដានគរមួយឈ្មោះ វ៉ាន់ឡាង (Văn Lang) ដែលត្រួតត្រាដោយរាជវង្ស ហ៊ុង (Hùng)(៧) ។ រាជាណាចក្រតូចមួយដែលមានវត្តមានប្រហែលជាង ២៥០០ ឆ្នាំមកហើយនេះ គឺជាផ្នែកមួយយ៉ាងសំខាន់នៃអតីតកាលដ៏រស់រវើកមួយរបស់ប្រទេសវៀតណាមបច្ចុប្បន្ន ។ បុរាណវិទូវៀតណាមទើបតែប្រទះឃើញនូវបុរាណដ្ឋាន ដែលស្តេចហ៊ុងធ្លាប់គ្រប់គ្រង (បារាំងសែសបានច្រានចោលរាជាណាចក្រវ៉ាន់ឡាង ដោយចាត់ទុកថា នោះគឺជារឿងព្រេងនិទានប៉ុណ្ណោះ) ឥឡូវនេះ គឺជាឧទ្យានជាតិមួយមានស្លាកស្នាមដែលមានអាយុកាលច្រើនជាងពីរពាន់ឆ្នាំ ។

បើតាមរឿងព្រេង ជនជាតិវៀតណាមជាប់ខ្សែលោហិតមកពីសត្វនាគនិងទេពធីតា ។ នៅពេលដែលស្តេចនាគសមុទ្រឡាក (Lạc) បានបុត្រាបុត្រី ១០០ ព្រះអង្គ ជាមួយម្ចាស់ក្សត្រីភ្នំ ដែលមានឈាមជ័រជាទេវតា ព្រះនាមអូវកឺ (Âu Cơ) រួចមក ព្រះអង្គបានយាងត្រឡប់ទៅសមុទ្រវិញ ដោយនាំបុត្រចំនួនពាក់កណ្តាលទៅជាមួយផងចំណែកម្ចាស់ក្សត្រីវិញ បានតាំងលំនៅនៅក្នុងដីតំបន់កណ្តាលនៃទន្លេក្រហមជាមួយបុត្រចំនួនពាក់កណ្តាលទៀត ។ បុត្រមួយព្រះអង្គបានក្លាយជាស្តេចដំបូងរបស់ប្រជាជនវៀតណាម ។ ស្តេចអង្គដំបូងនេះ ក្នុងចំណោមស្តេចរាជវង្សហ៊ុងទាំង ១៨ អង្គ បានដើរតួជាច្រើននៅក្នុងរឿងទេវកថានិងរឿងព្រេង និងជាទីសក្ការៈគោរពបូជាក្នុងភូមិរហូតមកដល់គ្រិស្តសតវត្សរ៍ទី ២០(៨) ។ មានរឿងតំណាលថា ព្រះរាជាហ៊ុងចុងក្រោយ គេ បានធ្វើអត្តឃាតនៅក្នុងឆ្នាំ ២៥៧ មុនគ្រិស្តសករាជ បន្ទាប់ពីចាញ់សង្គ្រាមជាមួយមេកន្ទ្រាញជិតខាងមួយរូបនាភាគខាងជើង ។ មូលហេតុនេះបានឈានឲ្យមានការកកើតព្រះរាជាណាចក្រថ្មីមួយឈ្មោះថា អូវឡាក (Âu Lạc) ដោយព្រះរាជាថ្មី ព្រះនាម អានយឿងវឿង (An Dương Vương) បានស្ថាបនាបន្ទាយល្អវិចិត្រមួយនៅឯតំបន់កូឡូ (Cổ Loa) នៅក្បែរទីក្រុងហាណូយពេលបច្ចុប្បន្ននេះ ដោយមានការជួយជ្រោមជ្រែងពីព្រះអណ្តើកមាសមួយ ។

មេដឹកនាំវៀតណាមសម័យដើម ពូកែទាក់ទងជាមួយពិភពអ្នកតា ។ ពួកលោក គឺជាបព្វជិតជាន់ខ្ពស់ដែលអះអាងថា ខ្លួនមានទំនាក់ទំនងពិសេសជាមួយអារក្សអ្នកតាមួយ ហើយពួកលោកមានមហិទ្ធិឫទ្ធិខ្លាំង អាចបញ្ចុះបញ្ចូលឲ្យអារក្សអ្នកតានោះមកធ្វើជាអ្នកជួយថែរក្សាការពារព្រះនគរបាន ។ ស្តេចនាគសមុទ្រឡាកបានធ្វើជាអ្នកការពារឲ្យព្រះនគររាជវង្សហ៊ុង ហើយព្រះអណ្តើកមាសជាអ្នកមើលការពារព្រះនគរអូវឡាក ។ បន្ទាប់ពីចែកឋានទៅ មេដឹកនាំដ៏មានអំណាច និងវីរបុរសវប្បធម៌សំខាន់ផ្សេងៗ ទៀត បានក្លាយទៅជាអ្នកតាដ៏មានឫទ្ធិអំណាចដែលកូនចៅជំនាន់ក្រោយអាចពឹងពាក់បាន នៅពេលត្រូវការជាចាំបាច់ ។ ការចងចាំជាប្រវត្តិសាស្ត្រអំពីស្តេចរាជវង្សហ៊ុង និង ស្តេច អាន យឿងវឿង បានបន្តពីជំនាន់មួយទៅជំនាន់មួយទៀត ហើយបាននិទានតៗ គ្នា មិនត្រឹមតែក្នុងរឿងទេវកថានិងរឿងព្រេងប៉ុណ្ណោះទេ ប៉ុន្តែតាមរយៈវត្តមានជារូបរាងនៅក្នុងទីសក្ការបូជារាប់រយពាន់របស់អ្នកស្រុកអ្នកភូមិ និងបូជនីយដ្ឋានជាច្រើន ។ នៅពីមុខបដិរូបដែលតំណាងឲ្យគាពរុងរឿងបរមបុរាណទាំងនេះ ពិធីបុណ្យផ្សេងៗ បានផ្សារភ្ជាប់ប្រជាជនវៀតណាមទៅនឹងអតីតកាលរួមមួយរបស់ពួកគេ និងចំពោះខ្លួនពួកគេម្នាក់ៗ ។

នៅឆ្នាំ ២០៨ មុន គ.ស. ព្រះរាជាណាចក្រថ្មីមួយឈ្មោះជាភាសាចិនកុកងឺថា ណានយឿ (Nan Yue) និងឈ្មោះជាភាសាវៀតណាមថា ណាមវៀត (Nam Việt) បានលេចរូបរាងឡើងនៅឆ្នេរសមុទ្រចិនភាគខាងត្បូង ។ មិនយូរប៉ុន្មាន ណាមវៀតច្បាំងដណ្តើមបានអូវឡាក ហើយដីសណ្តទន្លេក្រហមនិងវាលទំនាបតំបន់ឆ្នេរភាគខាង

ជើងរបស់ប្រទេសវៀតណាមសព្វថ្ងៃ ក៏ត្រូវបានគ្រប់គ្រងដោយណាមវៀតដែរ ។ ក្រោយមក រាជវង្សហាន់បានបង្រួបបង្រួមប្រទេសចិន ហើយនៅក្នុងឆ្នាំ ១១១ មុន គ.ស. ណាមវៀតបានស្ថិតក្រោមការគ្រប់គ្រងរបស់ចិន ។ វាលទំនាបភាគខាងជើងនៃវៀតណាម បានក្លាយជាខេត្តអាណានិគមរបស់ចិន តែពេលនោះ ទម្រង់វប្បធម៌ប្រជាជនម្ចាស់ស្រុកស្ថិតនៅដូចដើម ហើយការដឹកនាំក្នុងមូលដ្ឋានទទួលរងការរំខានតិចតួចក៏ដោយ ។

នៅគ្រិស្តសតវត្សរ៍ទី ១ នៅពេលដែលពួករដ្ឋបាលចិនមកពីខាងជើងមានចំនួនកាន់តែច្រើន ហើយកាន់តែមានភាពជឿជាក់លើខ្លួនឯង រចនាសម្ព័ន្ធអាជ្ញាធរម្ចាស់ស្រុកបានប៉ះទង្គិចគ្នាយ៉ាងស្រួចស្រាល់ទៅនឹងការទាមទារឲ្យមានភាពដូចគ្នារបស់ពួកចិន ។ មានស្ត្រីក្មេងដែលមិនចុះញ៉មម្នាក់ឈ្មោះ ទ្រឹង ត្រាក់ (Trưng Trắc) បានពន្យុះឲ្យមានការតវ៉ាប្រឆាំង រួចហើយបះបោរឡើង ។ នាងគឺជាសមាជិកម្នាក់នៃវណ្ណៈវរជនម្ចាស់ស្រុកពីកំណើតនិងតាមរយៈការរៀបអាពាហ៍ពិពាហ៍របស់នាងជាមួយវរជន ។ ឪពុកនិងស្វាមីរបស់នាង គឺ លោកម្ចាស់ឡាកស្លួងតពូង ។ នាង ទ្រឹង ត្រាក់ និងប្អូនស្រីនាងម្នាក់ទៀតឈ្មោះ ទ្រឹង ញី (Trưng Nhị) បានបន់ស្រន់នៅឯទីសក្ការបូជាមួយកន្លែងនៅភ្នំហ៊ុង ជាទីដែលបុព្វបុរសរបស់នាងកាលពីមុនធ្លាប់បានគ្រប់គ្រងប្រទេសតាងនាមនៃស្តេចនាគ ។ ពួកនាងបានអធិដ្ឋានសុំប្រសិទ្ធពរជ័យក្នុងការបះបោរនេះ ។ នៅ គ.ស. ៤០ នាង ទ្រឹង ត្រាក់ បានឡើងឋានៈជាព្រះមហាក្សត្រិយានី ក្រោយពីទ័ពបះបោររបស់ព្រះនាងបានដេញមន្ត្រីចិនឲ្យភៀសចេញទៅកាន់ខេត្តក្វាងទុងបាត់អស់ទៅ ។ ប៉ុន្តែ ដោយសារកម្លាំងវាយបកជាបន្ទាន់មួយរបស់ចិន ពួកគេបានចូលមកដណ្តើមយកដីសណ្តទន្លេក្រហមទៅថ្វាយរាជវង្សហាន់បានវិញក្នុង គ.ស. ៤៣ ។ មានការតំណាលថា បងប្អូនស្រីទ្រឹងបានធ្វើអត្តឃាត ។ គេនៅតែចងចាំជានិច្ចនូវនាងទាំង ២ រូបនេះ នៅក្នុងបទចម្រៀងនិងរឿងនិទានជាច្រើន ហើយសព្វថ្ងៃនេះ នាងទាំងពីរនៅតែជានិមិត្តរូបនៃគុណតម្លៃរបស់វៀតណាមបុរាណ ។

ចំណេរកាលច្រើនទសវត្សរ៍និងសតវត្សរ៍តមក ចំនួនប្រជាជននៅដីសណ្តទន្លេក្រហមនិងវាលទំនាបឆ្នេរខាងជើង បានទទួលឥទ្ធិពលចិនបន្តិចម្តងៗ តាមបែបផ្សេងៗ ។ រីឯជនជាតិចិនដែលរស់នៅក្នុងតំបន់នោះវិញក៏បានទទួលឥទ្ធិពលយ៉ាងខ្លាំងក្លាពីទំនៀមទម្លាប់និងទស្សនវិស័យប្រជាជនក្នុងស្រុកផងដែរ ។ ពន្ធុ (ហ្សែន) និងវប្បធម៌បានចូលលាយឡំគ្នា បង្កើតបានជាវរជនវៀតណាមកាត់ចិនថ្មីៗមួយក្រុម ។ អស់កាល ៧០០ ឆ្នាំ តំបន់នេះក្លាយជាខេត្តយ៉ាវចូវ (Giao Châu) របស់ចិន ។ អត្តសញ្ញាណក្នុងស្រុកដែលប្លែកពីគេមួយ នៅតែអាចរក្សាទុកបានដូចដើម ។ ការបះបោរចេះតែកើតមានជាបន្តបន្ទាប់ បង្កើតបានជាពួកវីរបុរសថ្មីៗ មានបូជនីយដ្ឋានបន្ថែមនិងមានរឿងព្រេងរឿងនិទានកាន់តែច្រើន ។ នៅក្នុងអំឡុង ស.វ. ទី ៩ មានការបះបោរកើតឡើងកាន់តែញឹកញាប់ ហើយវប្បធម៌និងប្រពៃណីក្នុងតំបន់ ក៏ចាប់មានរូបរាងឡើងវិញផងដែរ ។ ដោយប្រទេសចិនកាន់តែចុះអន់ថយ និងកើតកោលាហលក្រោមរាជវង្សថាំង ដែលកំពុងបែកបាក់ស្រាប់ ទើបធ្វើឲ្យប្រជាជនវៀតណាមទទួលបានឯករាជ្យនៅក្នុង គ.ស. ៩៣៩ ។ នៅប៉ុន្មានឆ្នាំដំបូងនៃឯករាជ្យ មិនទាន់មានស្តេចអង្គណាមួយអាចបង្រួបបង្រួមទឹកដីបាននៅឡើយទេ ។ ការដឹកនាំនៅក្នុងប្រទេសវៀតណាមមានភាពមិនច្បាស់លាស់ ដោយចំណុះលើការបែងចែកគោលនយោបាយស្របច្បាប់ពីរ ÷ ប្រពៃណីប្រជាជនម្ចាស់ស្រុក និងប្រព័ន្ធនយោបាយនិងរដ្ឋបាលបែបចិន ដែលធ្លាប់ទទួលរងក្នុងអំឡុងការគ្រប់គ្រងរបស់ចិនអស់មួយពាន់ឆ្នាំមកហើយនោះ ។ ពីមុនមក ស្តេចភាគច្រើនគឺជាយោធា ដែលការដឹកនាំផ្អែកលើភាពអង់អាចក្លាហានរបស់ខ្លួន ។ នៅក្នុងមជ្ឈដ្ឋាន

បែបនេះ ព្រះពុទ្ធសាសនាមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឲ្យសង្គមវៀតណាមមានស្ថិរភាពបាន ។

រហូតមកដល់រាជវង្សលី (Lý) (គ.ស. ១០០៩-១២២៥) ទើបមានការអភិវឌ្ឍចេញជារូបរាងឡើង នូវអ្វីដែលពួកយើងសព្វថ្ងៃនេះគិតថា ជាប្រពៃណីទំនៀមទម្លាប់របស់វៀតណាមមួយនោះ ។ បន្ទាប់ពីបានឡើងសោយរាជ្យមិនយូរប៉ុន្មាន ស្តេចរាជវង្សលីអង្គទីមួយ បានផ្លាស់រាជធានីទៅកាន់តំបន់ដែលសព្វថ្ងៃនេះជាទីក្រុងហាណូយ ដែលពេលនោះព្រះអង្គបានដាក់ឈ្មោះថា «នាគផុស» (ថាំងឡុង Thăng Long) ។ នៅឆ្នាំ ១០៤៨ មានការបង្កើតឡើងនូវវប្បធម៌ពឹងពាក់លើពិធីសែនព្រេនដល់ពពួកទេវតាដែលការពារផលដំណាំមួយ ដោយមានទាំងការស្ថាបនាទីសម្រាប់គោរពបូជាដល់ទេវតាដែលតំណាងឲ្យដីនិងគ្រាប់ធញ្ញជាតិ ហើយនិងមានការបង្កើតតួនាទីរបស់ព្រះរាជាឲ្យធ្វើជាបព្វជិតខ្ពង់ខ្ពស់ថ្នាក់ជាតិខាងវិស័យកសិកម្ម ។ ស្តេចរាជវង្សលីមានសាក់សត្វនាគរាជជាសម្គាល់ ដែលបញ្ជាក់ឲ្យដឹងអំពីការតពូជពីស្តេចនាគដ៏ល្បីល្បាញនៃសមុទ្រឡាក និងស្តេចត្រកូលហ៊ុង ។ តាមការពិត ភាពរុងរឿងនៃរាជវង្សលី មានមូលដ្ឋានធំបិតនៅលើកម្លាំងចិត្តដែលមិនធ្លាប់មានពីមុនមក ដែលបានបង្កើតឡើងដោយការអន្ទងព្រលឹងវីរបុរសពីអតីតកាលដែលបានក្លាយជាអ្នកតាទាំងនេះ ឲ្យចេញមក ដើម្បីជួយគាំទ្រ និងធ្វើឲ្យការត្រួតត្រារបស់គេមានប្រសិទ្ធភាពនិងភាពស្របច្បាប់[៩] ។ ហើយកម្លាំងផ្នែកស្មារតីដូចគ្នានេះ មានឥទ្ធិពលខ្លាំងសម្រាប់ការឡើងកាន់អំណាចរបស់មេដឹកនាំវៀតណាមរហូតមកដល់ពេលបច្ចុប្បន្ននេះ ។

ព្រះពុទ្ធសាសនាបានចម្រើនលូតលាស់ ។ មានស្តេចក្នុងរាជវង្សលីជាច្រើនអង្គ បានចំណាយពេលមួយភាគក្នុងឆាកជីវិតរបស់ព្រះអង្គ រស់នៅក្នុងវត្តអារាម ហើយមានស្តេច ១ ព្រះអង្គទៀតបានធ្វើជាអ្នកដឹកនាំនិកាយសំខាន់មួយទៀតផង ។ ទស្សនៈមនោគមវិជ្ជារបស់ព្រះរាជវាំងលី ដូចឃើញមាននៅក្នុងកំណាព្យនាសម័យកាលនោះ គឺមានអត្ថន័យស៊ីជម្រៅខ្លាំងលើសាសនាព្រះពុទ្ធ ដោយកត់សម្គាល់នូវឥទ្ធិពលពុទ្ធសាសនាឈ្យាននិកាយ (ភាសាវៀតណាមថា «ធៀនតុង» "Thiền tông") ដែលផ្តោតខ្លាំងលើការទ្រង់ញាណ និងការត្រាស់ដឹង ជាជាងលើគម្ពីរឬអំពើល្អ ។ អនុបាទាន (សេចក្តីមិនប្រកាន់ចិត្តគំនិត) វិយោគ (ការប្រាសព្រាត់ពីបុគ្គល ឬអ្វីដែលស្រឡាញ់ពេញចិត្ត) និងរហស្សលទ្ធិ (លទ្ធិអំពីការរួបរួមគ្នាជាមួយអ្វីដែលជាទិព្វ) បែបបរមតិ (Paradoxical mysticism) គឺជាគុណធម៌ដែលបានជ្រួតជ្រាបក្នុងផ្នត់គំនិតជនជាតិវៀតណាម[១០] ។

ប៉ុន្តែ ក៏មានការជួយជំរុញឲ្យមានការសិក្សាខ្លះដែរ ទាក់ទងនឹងលទ្ធិខុងជឺ បន្ទាប់ពីបានឈប់នឹកនាអស់ពេលមួយសតវត្សរ៍មកហើយនោះ ។ នៅក្នុងឆ្នាំ ១០៧០ គេបានស្ថាបនាឡើងនូវវិហារអក្សរសិល្ប៍មួយ ដើម្បីឧទ្ទិសដល់ខុងជឺ នៅនាគផុស (ស្លាកស្នាមរបស់វិហារនេះ នៅមានដល់សព្វថ្ងៃនេះនៅក្នុងទីក្រុងហាណូយ) ។ ក្នុងឆ្នាំ ១០៧៥ មានរៀបចំការប្រឡងថ្នាក់ជាតិ ជាលើកដំបូងនៅក្រោមរដ្ឋអំណាចឯករាជវៀតណាម ហើយនៅក្នុងឆ្នាំ ១០៧៦ មានការបង្កើតឲ្យមានសាកលវិទ្យាល័យជាតិមួយផងដែរ ។ លទ្ធិខុងជឺបានចាប់ផ្តើមរស់រានឡើងវិញនៅក្រោមការគ្រងរបស់ស្តេចរាជវង្សលី ។

រាជវង្សលី ក្រោយមកត្រូវបានស្នងបន្តដោយរាជវង្សធំមួយទៀត គឺរាជវង្សត្រឹន (Trần) (គ.ស. ១២២៥-១៤០០) ។ បន្តិចម្តងៗ ប្រទេសវៀតណាមមានការកើនឡើងនូវចំនួនប្រជាជននិងបានពង្រីកទឹកដីរបស់ខ្លួន ។ កងទ័ព ការិយាលយាធិបតេយ្យ និងប្រព័ន្ធការប្រឡង បានលូតលាស់បន្ថែមទៀត ។ ប៉ុន្តែ ស្តេចរាជវង្សត្រឹនអង្គដំបូងៗ បានចំណាយកម្លាំងរបស់ទ្រង់យ៉ាងច្រើន នៅក្នុងកិច្ចការបរទេសនិងការការពារជាតិ ប្រយុទ្ធទល់នឹង

ការគំរាមកំហែងពីភាគខាងជើង ។ នៅក្នុងឆ្នាំ ១២៨៤ ប្រទេសវៀតណាមទំនងជាធ្លាប់ចូលក្នុងគ្រោះកម្មនៃការដួលរលំដោយកម្លាំងទ័ពចិន ប៉ុន្តែ ដោយសារការដឹកនាំដ៏ឈ្លាសវៃនិងប៉ិនប្រសប់របស់មេទ័ពឈ្មោះ ត្រឹន ហ៊ឹងដាវ (Trần Hưng Đạo) ពួកឈ្លានពានត្រូវបានបណ្តេញចេញពីទឹកដីវិញ ។

ក្នុងអំឡុងរាជវង្សត្រឹន លទ្ធិខុងជឺនៅក្នុងមនោគមវិជ្ជារដ្ឋ នៅតែបន្តវិវឌ្ឍខណៈដែលព្រះពុទ្ធសាសនានៅតែមានសារៈសំខាន់ ។ ក្រោយមក នៅចុងសតវត្សរ៍ទី ១៤ នៅចំពេលដែលកំពុងមានវិបត្តិសេដ្ឋកិច្ចនិងការបះបោររបស់អ្នកស្រែ អាមាត្យដែលមានអំណាចរបស់ព្រះរាជាម្នាក់ បានដណ្តើមរាជបល្ល័ង្ក ។ នៅក្រោមការដឹកនាំថ្មីដែលមិនមានប្រជាប្រិយភាពនេះ ប្រទេសវៀតណាមបានធ្លាក់ចូលក្នុងនឹមត្រួតត្រារបស់ចិនសាជាថ្មីម្តងទៀតនៅឆ្នាំ ១៤០៧ ។ ក្នុងរយៈពេលមួយ មានភ្នាក់ងាររដ្ឋបាលរាជវង្សម៉េង មកពីប្រទេសចិន បានរៀបចំយ៉ាងតឹងរ៉ឹងនូវរដ្ឋបាលភូមិ ពិធីបុណ្យសាសនា របៀបរៀបចំសក់ របៀបស្លៀកពាក់ ការតាក់តែងនិងការផ្សព្វផ្សាយអក្សរសិល្ប៍ និងអ្វីៗដែលសំខាន់ផ្សេងៗទៀត ទាក់ទងនឹងវប្បធម៌ សេដ្ឋកិច្ច ឬនយោបាយ ។ ទាំងរាជវង្សម៉េង និងអ្នកដឹកនាំវៀតណាមដែលបានផ្លាស់ចេញ សុទ្ធតែបានលើកតម្កើងឲ្យមានការផ្សព្វផ្សាយលទ្ធិខុងជឺបែបថ្មី (១១) ។

នៅក្រោមការគ្រប់គ្រងរបស់ព្រះចៅ ឡេ ឡើយ (Lê Lợi) ពួកឈ្លានពានចិនត្រូវបានបណ្តេញចេញ ហើយរាជវង្សឡេ (Lê) បានកើតឡើងក្នុងឆ្នាំ ១៤២៨ ។ លទ្ធិខុងជឺបែបថ្មី (ដែលមានមូលដ្ឋានលើការបកស្រាយរបស់អ្នកប្រាជ្ញចិនម្នាក់ឈ្មោះ ឈូស៊ី (Chu Hsi) នូវអក្សរសិល្ប៍ល្បីរបស់ចិនក្នុង ស.វ. ទី ១១) មានឥទ្ធិពលយ៉ាងសំខាន់លើគំនិតរបស់ជនជាតិវៀតណាម ។ នៅក្នុងអំឡុង ៣៧ ឆ្នាំ (គ.ស. ១៤៦០-១៤៩៧) នៃការគ្រងរាជ្យរបស់ស្តេចឡេ ថាញ់តុង (Lê Thánh Tông) ដ៏មហិមា លទ្ធិខុងជឺបែបថ្មីបានគ្របដណ្តប់មនោគមវិជ្ជាដទៃទៀតរបស់វៀត-ណាម ។ ប៉ុន្តែ រាជវង្សឡេបានធ្លាក់ចុះមកវិញយ៉ាងឆាប់រហ័ស ។ អស់រយៈពេលជិត ៣ សតវត្សរ៍ ជម្លោះផ្ទៃក្នុងបានបំផ្លាញទ្រព្យសម្បត្តិនិងកម្លាំងរបស់ប្រជាជនវៀតណាម ។ មានវីរបុរសចំនួនតិចតួច អក្សរសិល្ប៍ល្អៗ ស្តួចស្តើង និងការបង្កើតថ្មីៗ ផ្នែកវប្បធម៌តែបន្តិចបន្តួចប៉ុណ្ណោះ ដែលលេចរូបរាងឡើងក្នុងពេលនោះ ។ ហេតុការណ៍នេះកើតឡើងរហូតមកដល់ពាក់កណ្តាលទី ២ នៃ ស.វ. ទី ១៨ ទើបមានការប្រែប្រួលខ្លះឡើងវិញ ។ នៅពេលនោះ វប្បធម៌បុរាណត្រូវគេលើកយកមកបញ្ជាក់យ៉ាងរស់រវើកក្នុងអក្សរសិល្ប៍ភាសាវៀតណាម ។ មូលហេតុសំខាន់មួយក្នុងការរស់ឡើងវិញនេះ គឺជាការពង្រីក និងការធ្វើឲ្យមានលក្ខណៈបទដ្ឋាននៃប្រព័ន្ធសរសេរ (ហៅថា «ជឺណូម» "chữ Nôm" គឺ «អក្សរខាងត្បូង») ដែលគេបានប្រើប្រាស់សម្រាប់ចម្លងភាសាវៀតណាម (១២) ។

នៅទសវត្សរ៍ចុងក្រោយនៃ ស.វ. ទី ១៨ ប្រវត្តិសាស្ត្រវៀតណាមពោរពេញទៅដោយការបះបោររបស់ពួកតៃសឺន (ឬ តីសឺន) (Tây Sơn) ដែលបានចាប់ផ្តើមដំបូងជាការរើបម្រះរបស់កសិករ ប្រឆាំងទៅនឹងស្ថានភាពដែលគេមិនពេញចិត្តជាច្រើន ។ នៅឆ្នាំ ១៧៨៦ មេដឹកនាំការបះបោរ បានគ្រប់គ្រងប្រទេសវៀតណាមទាំងមូល ។ យុគសម័យរបស់តៃសឺន មានការជជែកវែកញែកច្រើននិងពិបាកយល់បានណាស់ ។ ចលនាបដិវត្តនេះបញ្ជាក់នូវទោមនស្សយ៉ាងខ្លាំង ដែលកប់ជ្រៅក្នុងស្រទាប់សង្គមជនបទវៀតណាម ប៉ុន្តែក៏មានការពាក់ព័ន្ធគ្នានឹងផលប្រយោជន៍ថ្មីៗ ខាងពាណិជ្ជកម្ម ផែនការសម្ងាត់របស់អាណិកជនចិន ជំនឿប្រឆាំងគ្នាខាងសាសនា និងការរស់រានឡើងវិញនៃប្រពៃណីប្រជាជនម្ចាស់ស្រុក ដែលនាំឲ្យខូចប្រយោជន៍ដល់ធាតុផ្សំបរទេស ជាពិសេសគឺលទ្ធិខុងជឺបែបថ្មី ។ «ជឺណូម» ដែលជាប្រព័ន្ធអក្សររបស់អ្នកស្រុក បានជំនួសអក្សរចិន ជាប្រព័ន្ធសរសេរផ្លូវ

ការ ។ គេបានរំលឹកឡើងវិញនូវបងប្អូនស្រីត្រកូលទ្រឹងថា ជាវីរនារីនៃវប្បធម៌លំដាប់ទីមួយ ។

ប៉ុន្តែ នៅឆ្នាំ ១៨០២ រាជវង្សង្វៀន (Nguyễn) បានគ្រប់គ្រងអំណាច ដោយប្រកាសទុកជាអសារបង់ ឬមោឃៈ នូវរាល់ការកែទម្រង់របស់ពួកតៃសឺន ។ ដោយយល់ឃើញថា ប្រវត្តិសាស្ត្រវៀតណាមនាពេលថ្មីៗនោះ មានភាពធ្លាក់ចុះនិងខ្វះសណ្តាប់ធ្នាប់ ស្តេចរាជវង្សង្វៀនបានខិតខំយ៉ាងខ្លាំងក្លា ដើម្បីធ្វើឲ្យលទ្ធិខុងជឺបែបថ្មី បានចាក់គ្រឹះនៅក្នុងវប្បធម៌ជាតិ ។ នៅក្រោមការគ្រប់គ្រងរបស់រាជវង្សង្វៀន វប្បធម៌ប្រពៃណីវៀតណាមបានឋិតនៅក្នុងទម្រង់ចុងក្រោយ ដែលជាវប្បធម៌មួយអាចស្ថិតនៅបន្តដល់ ស.វ. ទី ២០ បាន ដើម្បីធ្វើអន្តរកម្មជាមួយឥទ្ធិពលបស្ចិមប្រទេស[១៣] ។

## ទស្សនៈជាប្រពៃណីរបស់ជនជាតិវៀតណាមចំពោះពិភពលោក

ជាច្រើនសតវត្សរ៍កន្លងទៅ លទ្ធិតាវ ពុទ្ធសាសនា និងលទ្ធិខុងជឺ បានផ្សារភ្ជាប់គ្នា កែសម្រួលឲ្យស្របទៅតាមរបៀបរបបវៀតណាម ដើម្បីដើរឲ្យបានស្របគ្នាជាមួយស្នាមចាស់នៃជំនឿអរូបី ដែលជាសាសនាឬជាប្រពៃណីមួយយ៉ាងរបស់ជនជាតិវៀតណាម[១៤] ។ នៅចុង ស.វ. ទី ១៥ លទ្ធិខុងជឺបែបថ្មីក្លាយជាសាសនា ដែលមានឥទ្ធិពលគ្របដណ្តប់ ហើយកាន់តែមានសន្ទុះខ្លាំងនៅ ស.វ. ទី ១៩[១៥] ។ លទ្ធិខុងជឺបែបថ្មីនេះ ផ្តោតលើទំនាក់ទំនងសមស្របនៅក្នុងសង្គម ប៉ុន្តែបើយោងលើធម្មជាតិនៃតថភាព គំនិតអំពីទម្រង់ត្រឹមត្រូវនៃទំនាក់ទំនងសង្គមមានមូលដ្ឋានលើគោលគំនិតទូលំទូលាយ ។

ទស្សនៈជាទូទៅរបស់វៀតណាមបុរាណ ផ្តោតជារួមទៅលើគោលការណ៍លោកធាតុដែលផ្អែកលើធាតុ «យិន» (ភាសាវៀតណាមថា âm «អឹម») និងធាតុ «យ៉ាំង» (ភាសាវៀតណាមថា dương «យឿង») ។ ធាតុទាំងពីរនេះ ត្រូវគេយល់ថា ជាកម្លាំងដំបូងពីរដែលបង្កើតឲ្យមានអ្វីៗ ទាំងអស់នៅលើសាកលលោកយើងនេះ ។ ឫសគល់នៃទស្សនៈដែលជាឥទ្ធិពលដ៏ចំណាស់ និងចម្បងរបស់ចិន មានមកលើវៀតណាម បានក្លាយជារបៀបដែលជនជាតិវៀតណាមសម្លឹងមើលពិភពលោក ហើយបានជ្រាបចូលជ្រៅទៅគ្រប់ប្រព័ន្ធទាំងអស់ ពោលគឺពីគ្រួសាររហូតដល់ស្ថាប័នរដ្ឋ ។ បញ្ញត្តិ «យិនយ៉ាំង» នេះបានបកស្រាយពិភពលោកទាំងមូលតាមប្រព័ន្ធមួយ ដែលមានន័យសមហេតុផល ។ អ្វីមួយក៏ដោយ ក៏ជាគំរូ ជារូបតាងឲ្យអ្វីមួយផ្សេងទៀតដែរ[១៦] ។ ដោយផ្អែកលើការសន្មតអំពីបែបបទនិងទម្រង់រួមមួយរបស់លោកធាតុ គំរូមួយនេះបានធ្វើឲ្យជនជាតិវៀតណាមយល់កាន់តែស៊ីជម្រៅ និងដឹងអំពីវិធីទប់ទល់ជាមួយនឹងរចនាសម្ព័ន្ធធម្មជាតិនៃលោកធាតុ ។

នៅក្នុងគ្រប់វិស័យទាំងអស់ នៅពេលណាគេអាចរក្សាឲ្យមានតុល្យភាពសមរម្យមួយរវាងធាតុយិននិងធាតុយ៉ាំង ពេលនោះភាពសុខដុមនឹងកើតឡើង ហើយលទ្ធផលប្រកបដោយគុណសម្បត្តិមួយ ក៏នឹងកើតមានផងដែរ ។ ប្រការនេះពិតដូចគ្នានៅក្នុងរាងកាយរបស់មនុស្សម្នាក់ៗ ក្នុងគ្រួសារនីមួយៗ ក្នុងភូមិស្រុក និងនៅក្នុងប្រទេសជាតិទាំងមូល ។ ឧទាហរណ៍ ការព្យាបាលជម្ងឺ សំខាន់គឺត្រូវធ្វើយ៉ាងណាឲ្យមានតុល្យភាពគ្នារវាងធាតុយិននិងធាតុយ៉ាំង ទាំងក្នុងខ្លួនមនុស្ស និងរវាងមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត និងជាមួយពិភពលោកខាងក្រៅ ។ បើតាមជំនឿរបស់អ្នកស្រុក រាល់ចំណីអាហារទាំងអស់ គេជឿថា មាន «ធម្មជាតិសំខាន់» មួយ ដែលក្តៅខ្លាំង ក្តៅល្មម ត្រជាក់ល្មម ឬត្រជាក់ខ្លាំង ។ អាហារដែល «ក្តៅខ្លាំង» និង «ក្តៅល្មម» គឺជាតុយ៉ាំង ចំណែកអាហារ

ដែល «ត្រជាក់ខ្លាំង» និង «ត្រជាក់ល្មម» គឺជាធាតុយិន ។ ដូច្នេះ របបម្ហូបអាហារអាចធ្វើឲ្យមានតុល្យភាពឬអតុល្យភាពរវាងធាតុយិននិងធាតុយ៉ាំងនៅក្នុងខ្លួនមនុស្សបាន[១៧] ។

បើគេគិតថា ខ្លួនមនុស្សយើងគឺជាអតិសុខុមលោកនៃពិភពធម្មជាតិនោះ គេអាចគិតបានថា គ្រួសារក៏ជាអតិសុខុមលោកនៃសង្គមពិភពលោកផងដែរ ។ តុល្យភាពសមរម្យមួយរវាងធាតុយិននិងធាតុយ៉ាំងនៅក្នុងខ្លួនមនុស្ស និងតុល្យភាពដ៏សមរម្យមួយរវាងខ្លួនមនុស្សនិងបរិស្ថាន អាចបង្កើតឲ្យមានសុខភាពល្អនៅក្នុងខ្លួនមនុស្សបាន ដូច្នេះ ទំនាក់ទំនងល្អរវាងក្រុមមនុស្សខុសៗគ្នា ក៏នឹងអាចបង្កើតបានជាភាពចុះសម្រុងក្នុងសង្គមមួយ ហើយអាចធ្វើឲ្យគ្រួសារ ភូមិស្រុក និងប្រទេសជាតិ មានសុភមង្គលនិងមានភាពរុងរឿងបាន ។ ទាំងប្រព័ន្ធអប់រំជាផ្លូវការ និងការប្រាស្រ័យទាក់ទងក្នុងគ្រួសារ សុទ្ធតែបានផ្តោតទៅលើការបង្រៀនក្មេងៗឲ្យយល់ដឹងអំពីការប្រព្រឹត្តត្រូវនៅក្នុងក្របខណ្ឌនេះ ។ ហើយក្របខណ្ឌនេះ អាចបង្កើតជាមូលដ្ឋាននៃប្រព័ន្ធសង្គមមួយដែលបម្រើសង្គមវៀតណាមបានយ៉ាងល្អរាប់រយឆ្នាំកន្លងមក ។

បែបបទបុរាណនៃធាតុយិនយ៉ាំង គេអាចបកស្រាយថា ជានយ័ធៀបទៅនឹងទ្រឹស្តីនិយន្តសាស្ត្រ (ប្រព័ន្ធគ្រប់គ្រងដោយស្វ័យប្រវត្តិ ឬទ្រឹស្តីស៊ីប៊ែរណេទិក)[១៨] ។ ទ្រឹស្តីប្រព័ន្ធទំនើបមួយនេះ បានផ្តល់ឲ្យយល់កាន់តែច្បាស់អំពីប្រព័ន្ធលំនឹងថាមពលត្រូវតែដំណើរការយ៉ាងដូចម្តេច[១៩] ។ សង្គមមិនមែនជាសព៌ាង្គកាយ ហើយក៏មិនមែនជាគ្រឿងម៉ាស៊ីនដែរ ។ សង្គមគ្រាន់តែជាប្រព័ន្ធមួយ ដូចសព៌ាង្គកាយនិងគ្រឿងម៉ាស៊ីនជាប្រព័ន្ធផងដែរ ។ សង្គមមនុស្សផ្សំឡើងដោយធាតុទាំងឡាយ ដែលក្នុងនោះ ធាតុផ្សំបញ្ចូលគ្នាសរុប វាធំជាង វាសំខាន់ជាង និងវាខុសគ្នាពីធាតុនីមួយៗ ដែលនៅដាច់ពីគ្នា ។ នេះគឺដោយសារតែទំនាក់ទំនងរវាងធាតុនីមួយៗ អាចរក្សាទុកបានដោយយន្តការទំនាក់ទំនង និងការគ្រប់គ្រង ដែលពឹងផ្អែកលើលំហូរនៃព័ត៌មានស្តីអំពី «ប្រតិកម្មតប» ដើម្បីឲ្យដំណើរការមានប្រសិទ្ធភាពទៅបាន ។

ទ្រឹស្តីនិយន្តសាស្ត្រ (ស៊ីប៊ែរណេទិក) ប្រាប់ឲ្យយើងដឹងអំពីការវិភាគសង្គមតាមវិធីច្រើនយ៉ាង ÷ តាមរយៈការផ្តោតលើលក្ខណៈនៃប្រព័ន្ធ ដូចជាការរស់ស្ថិតពីដំណើរមិនប្រក្រតី និងចំនួនលើសសេចក្តីត្រូវការ និងលើគុណតម្លៃដែលបំពេញមុខងារជាគោលការណ៍ប្រតិបត្តិ ដោយផ្តោតលើអត្ថន័យនិងមុខងារនៃប្រព័ន្ធដែលកំណត់ឲ្យដោយបរិបទមួយ ។ល។ លើសពីនេះទៅទៀត ទ្រឹស្តីនេះរំលឹកយើងឲ្យដឹងថា មានតែបរិបទ ពោលគឺទំនាក់ទំនងទាំងមូល មិនមែនធាតុតែឯងណាមួយទេ ដែលធ្វើការវិវឌ្ឍ[២០] ។ ការចាប់អារម្មណ៍របស់ជំពូកនេះ គឺផ្តោតលើបរិបទវិវឌ្ឍន៍នៃគំនិតនៅក្នុងផ្នត់គំនិតជនជាតិវៀតណាមនា ស.វ. ទី ២០ ។

## សង្គមវៀតណាមជាប្រព័ន្ធមួយនៃធាតុយិនយ៉ាំង

ក្នុងវប្បធម៌វៀតណាមបុរាណ យើងអាចរកឃើញគោលការណ៍ ឬគុណតម្លៃប្រតិបត្តិចំនួន ២ ក្នុងគ្រប់វិស័យនៃសង្គម ។ ចំនួនទាំងពីរនេះ គេអាចប្រើធ្វើជាមូលដ្ឋានសម្រាប់ជាគំរូរបស់សង្គមនិងវប្បធម៌ ។ មួយក្នុងចំណោមពីរនោះ គឺធាតុយ៉ាំង ចំណែកឯមួយទៀត គឺធាតុយិន ។ គេបង្ហាញលក្ខណៈរបស់ធាតុយ៉ាំង ដោយសំដៅទៅលើភាពគ្របដណ្តប់របស់បុរស ដែលមានតម្រូវការខ្ពស់ មានដំណើរស្ទូវខុសប្រក្រតី មានឋានានុក្រមសាំញ៉ាំនិងតឹងរ៉ឹង មានការប្រកួតប្រជែងនិងមានការប្រកាន់តាមវិន័យខ្ជាប់ខ្ជួន ដែលផ្តោតលើគោលការណ៍សម្រាប់ការ

ប្រព្រឹត្តផ្អែកលើតួនាទីសង្គមមួយ ។ គេសម្គាល់លក្ខណៈរបស់ធាតុយិន ដោយវាមាននិន្នាការទៅរកភាពស្មើគ្នា ភាពចេះបត់បែន ការចូលរួមពីស្ត្រី ភាពមិនសូវមានការប្រកួតប្រជែង ភាពមិនសូវមានជម្លោះ ផ្ដោតភាគច្រើនទៅលើការយល់ចិត្តនិងសយម្ភូភាព (ភាពដែលកើតឡើងដោយឯង ៗ ដោយគ្មានការព្រាងទុកជាមុន) ។

វប្បធម៌វៀតណាមបុរាណភាគច្រើន អង្គការសង្គម និងនយោបាយរបស់ជនជាតិវៀតណាម បានបង្ហាញថាតុល្យភាពរវាងធាតុយិននិងធាតុយ៉ាំង គឺជាគំនិតចាក់ស្រេះ (រួមមាន គុណតម្លៃ គំនិតអរូបិយប្រភេទផ្សេង ៗ គ្នានិងវិធានការប្រតិបត្តិ ។ល។) ។ បើតាមអរូបីកម្មលំដាប់ខ្ពស់នេះ គេសង្កេតឃើញមានការតស៊ូមួយនៅក្នុងប្រព័ន្ធនោះ បន្ទាប់ពីពេលចេះតែរំកិលទៅមុខ ។ នៅត្រង់កម្រិតនៃបរិបទវប្បធម៌ជាក់លាក់មួយ មានការផ្លាស់ប្ដូរច្រើនបានកើតឡើង ។ តាមរយៈឧទាហរណ៍នៃរឿងនិទានខ្លី ៗ អក្សរសិល្ប៍និងការស្រាវជ្រាវអំពីការរស់នៅរបស់មនុស្ស បានជួយធ្វើឲ្យលក្ខណៈអរូបីកម្មនេះមានន័យគ្រប់គ្រាន់ ។ រួមសេចក្ដីទៅ ធាតុយិននិងធាតុយ៉ាំងកើតមានជាមួយគ្នា ដែលជាធម្មតា ធាតុយ៉ាំងគ្របដណ្ដប់លើធាតុយិន ។ ប៉ុន្តែ នៅពេលដែលធាតុយ៉ាំងកាន់តែគ្របដណ្ដប់ខ្លាំងលើសលប់ពេកនោះ វានឹងមានប្រតិកម្មតបតពីធាតុយិននៅក្នុងប្រព័ន្ធសង្គម ហើយការផ្លាស់ប្ដូរសង្គមក៏កើតមានឡើង ។

ទំនាក់ទំនងគ្នារវាងប្រព័ន្ធសង្គមពិតប្រាកដ និងប្រព័ន្ធគំនិត គឺមានភាពពិតប្រាកដហើយមានសារៈសំខាន់ ។ ប៉ុន្តែ ទំនាក់ទំនងនេះ ក៏មានន័យសំខាន់ជាងនេះផងដែរ ។ ពិភពនៃនយោបាយដែលអាចសង្កេតបាន ហត្ថកម្មនិងពិភពនៃទស្សនៈយល់ឃើញ ដែលបង្កើតដោយវប្បធម៌ឬដោយការស្រមើស្រមៃ បន្តបង្កើតនិងកែទម្រង់គ្នាទៅវិញទៅមក ប៉ុន្តែនៅរក្សាបូរាណភាពសំខាន់នៃទំនាក់ទំនងរបស់វា ល្អឥតខ្ចោះក្ដី មិនគ្រប់លក្ខណ៍ក្ដី ក្នុងអំឡុងពេលនៃដំណើរការផ្លាស់ប្ដូរ ។ នៅស្របពេលដែលពិភពទាំងពីរ ធ្វើចលនាជាមួយគ្នាអស់កាលយូរទៅពិភពនីមួយ ៗ ត្រូវបានស្ដាបនាបញ្ចូលគ្នាទៅវិញទៅមក ។ ដូច្នេះ ទម្រង់ជាក់លាក់ណាមួយនិងធាតុសំខាន់ ៗ នៃប្រភេទពិភពណាមួយ ឬរបស់ពិភពទាំងពីរ អាចប្រែប្រួលគួរឲ្យកត់សម្គាល់ទៅតាមពេលវេលា ប៉ុន្តែ ស្របពេលគ្នានេះដែរ ទំនាក់ទំនងជានិមិត្តរូបនៅតែឋិតនៅតទៅទៀតដើម្បីជាធាតុបង្រួបតាមរយៈភាពផ្ទុយគ្នាសមហេតុសមផល ។

ខ្ញុំជឿថា វាពិតជាមានតម្លៃធំធេងណាស់ក្នុងការសម្លឹងមើលប្រវត្តិសាស្ត្ររបស់វៀតណាមចូលទៅក្នុង ស.វ. ទី ២០ ដូចជាករណីមួយនៃទម្រង់ការប្រែប្រួលនៅជុំវិញតុល្យភាពរវាងធាតុយិននិងធាតុយ៉ាំង ។ អ្នកប្រាជ្ញសម័យបរមបុរាណបានអះអាងរឿងនេះថា ជាធម្មជាតិនៃតថភាព ជាដំណើរសាកលមួយហៅថា «តាវ» ។ យិនយ៉ាំងនៃសង្គមវៀតណាមបុរាណ ដែលមានក្នុងគ្រួសារ ក្នុងអក្សរសិល្ប៍ ក្នុងសាសនា ក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ច រហូតដល់ប្រព័ន្ធនយោបាយ គឺមាននៅក្នុងតួយិននិងតួយ៉ាំងផ្ទាល់ នូវធាតុផ្សំ ដែលផ្ទុយគ្នាយ៉ាងសមហេតុសមផល តែស្របពេលជាមួយគ្នានោះ ក៏មានមុខងារជាធាតុបំពេញបង្រួបគ្នា ដែលមានរចនាសម្ព័ន្ធដោយឡែករបស់ខ្លួន ។ ទាំងនេះអាចគិតបានថា ជាការញែកអនុប្រព័ន្ធពីរដែលកំពុងដំណើរការ នៅក្នុងផ្នែកណាមួយនៃប្រព័ន្ធសង្គមទាំងមូល ។ នៅពេលណាដែលមានអនុប្រព័ន្ធណាមួយរឹងមាំជាច់ពីគេ នោះនឹងបង្កើតឲ្យមានភាពតានតឹង ទុក្ខព្រួយនៅក្នុងសង្គម ហើយពេលនោះ នឹងមានប្រតិកម្មពីបុគ្គលនិងស្ថាប័ន ដើម្បីស្វែងរកបរិយាកាសសង្គមដែលសុខស្រួលជាងនេះ ។ លោក ហ្គ្រេហ្គូរី បីត្សុន (Gregory Bateson) បានប្រៀបធៀបដំណើរការនេះទៅនឹង

ឧបករណ៍វាស់ស្ទង់កម្ដៅ[២១] ។ គាត់បានលើកឡើងថា ចំណុចសំខាន់បំផុតនៅក្នុងប្រវត្តិសាស្ត្រគឺ «ពេលដែលតវិយោបថមានការផ្លាស់ប្ដូរ ។ នេះគឺជាពេលដែលមនុស្សទទួលការឈឺចាប់ដោយសារតែតម្លៃដែលពួកគេមានពីមុន» ។ គាត់បានបន្ថែមទៀតថា អ្វីដែលពិតជាសំខាន់នោះសម្រាប់បុគ្គលនិងសង្គមមនុស្សទាំងមូល គឺការប្រែប្រួលនៅក្នុងភាពលំអៀង ឬ ការដាក់នូវឧបករណ៍វាស់ស្ទង់សម្រាប់កម្រិតតវិយោបថសង្គម[២២] ។

ដោយសារតែមនុស្សប៉ុនប៉ងបង្កើតគុណតម្លៃ ដែលចាំបាច់ត្រូវធ្វើនូវជម្រើសក្នុងលក្ខខណ្ឌមិនច្បាស់លាស់និងលក្ខខណ្ឌប្រក្លួតប្រជែងផងនោះ ការប៉ុនប៉ងទាំងនេះធ្វើឲ្យមានការកើនឡើងនូវជម្លោះនិងភាពតានតឹង មិនមែនតែនៅក្នុងក្រុមទេ ប៉ុន្តែជួនកាលមាននៅក្នុងបុគ្គលខ្លួនឯងផងដែរ ។ នៅក្នុងខ្លួនបុរស ស្ត្រី និងសង្គម មានចំណុចលែងអត់ធ្មត់ចំពោះភាពតានតឹង ហើយពេលដែលឡើងដល់ចំណុចនេះ អាចនាំឲ្យមានសកម្មភាពមួយចំនួនសម្រាប់បង្ការ ។ លទ្ធផលអាចជាការប្រែប្រួលខាងវប្បធម៌ ឬសង្គម រួមទាំងបដិវត្តន៍ផងដែរ ។ ប្រទេសវៀតណាមនា ស.វ. ទី ២០ បានបង្ហាញឲ្យឃើញនូវករណីចម្រូងចម្រាសដ៏ស្រួចស្រាល់មួយក្នុងសង្គម ស្ដីអំពីការដាក់កម្រិតលើសង្គម ។ នៅសម័យនោះ មានប្រជាជនជាច្រើនលាននាក់ទទួលរងការប៉ះទង្គិចយ៉ាងខ្លាំងក្លា ដោយសារតែគុណតម្លៃចាស់របស់គេ នៅពេលដែលមានការកកើតនៅតវិយោបថថ្មីនេះ ។

ការប្រដូចសង្គមពិតប្រាកដទៅនឹងអត្ថន័យសំខាន់របស់លោក បឺត្រុន ស្ដីអំពីការដាក់កម្រិតលើសង្គមនេះ គឺជាបណ្ដុំនៃគុណតម្លៃដែលបុគ្គលនឹងប្រព្រឹត្តតាម ។ បុគ្គលទាំងនោះធ្វើអន្តរកម្មនិងទំនាក់ទំនងជាមួយគ្នា ស្របពេលដែលពួកគេបញ្ចូលនូវលទ្ធផលរបស់សកម្មភាពផ្ទាល់ខ្លួន ចូលទៅជាមួយផងនឹងលទ្ធផលរបស់អ្នកផ្សេង ដើម្បីបង្កើតព័ត៌មានថ្មីមួយ ដែលក្រោយមក ពួកគេអាចកែប្រែតវិយោបថរបស់ខ្លួនគេបាន ។ ជួនកាល ដូចក្នុងប្រទេសវៀតណាម ស.វ. ទី ២០ អ៊ីចឹង ដំណើរការនេះនាំឲ្យមនុស្សស្វែងរកការផ្លាស់ប្ដូរក្រមនៃការប្រព្រឹត្ត ។ ពួកគេនិងអ្នកផ្សេងទៀត ត្រូវគេរំពឹងឲ្យសហការគ្នា និងផ្លាស់ប្ដូរការដាក់កម្រិតរបស់សង្គម តាមរយៈលទ្ធផលនៃការផ្លាស់ប្ដូរទម្រង់ចែកចាយគុណតម្លៃសម្រាប់សង្គមទាំងមូល ។ ចំពោះខ្ញុំ ដំណើរការនេះទំនងជាអាចកែប្រែបានស្របតាមការពិពណ៌នានិងការវិភាគ របស់គោលគំនិតធាតុយិននិងធាតុយ៉ាំង ។

ដើម្បីឲ្យងាយស្រួលយល់ធាតុយិននិងធាតុយ៉ាំង និងគុណតម្លៃរបស់វា ជាញឹកញាប់ យើងហៅវាថា ជា «ប្រព័ន្ធ» ឬ «វិស័យ» នៅក្នុងជំពូកនេះ ។ យើងអាចមើលឃើញការរៀបចំសង្គមរបស់វៀតណាមបុរាណ ដូចជាការដែលរក្សាបានតាមរយៈអន្តរកម្មរវាងប្រព័ន្ធខុសគ្នាទាំងពីរនេះ ។ បន្ថែមពីលើការប្រើប្រាស់ជាធម្មតារបស់ជនជាតិវៀតណាម ខ្ញុំបានពង្រីកការគិតដោយប្រើប្រាស់នូវគោលការណ៍អរូបីមួយចំនួន ដែលជនជាតិវៀតណាមមិនធ្លាប់ធ្វើឬស្រមៃនោះ ។ នៅក្នុងជំពូកនេះ ខ្ញុំប្រើពាក្យយិននិងយ៉ាំងក្នុងន័យធៀបប៉ុណ្ណោះ ។

វគ្គបន្ទាប់ទៀតនេះ នឹងពិពណ៌នាអំពីស្ថានភាពរបស់ប្រព័ន្ធសង្គមវប្បធម៌វៀតណាម ដូចដែលមាននៅពេលដែលឥទ្ធិពលអាណានិគមបារាំងសែសចាប់ផ្ដើមដាក់សម្ពាធលើវៀតណាមក្នុង ស.វ. ទី ១៩ និងដើម ស.វ. ទី ២០ ។ នេះគឺជាចំណុចចាប់ផ្ដើមដ៏សំខាន់នៃប្រវត្តិសាស្ត្រវៀតណាមដែលនឹងត្រូវរៀបរាប់ក្នុងជំពូកនេះ ។

## គុណតម្លៃ និងទំនៀមទម្លាប់បុរាណរបស់ជនជាតិវៀតណាម

វប្បធម៌វៀតណាមបុរាណមានភាពស្មុគស្មាញនិងមានការដឹងឮទូលំទូលាយពីតម្លៃទាំងនេះ ។ នៅក្នុងការស្ទាបស្ទង់

គ្រួសៗ បន្ទាប់នេះ ខ្ញុំចាំបាច់ត្រូវបង្ហាញជូននូវរូបភាពនៃប្រពៃណីវៀតណាម ដែលខ្ញុំបានសម្រិតសម្រាំងយ៉ាងប្រយ័ត្នប្រយែងនិងដែលងាយយល់ ។ វាថែមទាំងធ្វើឲ្យយើងដឹងពីគុណសម្បត្តិ ដែលមានប្រើជាចម្បងនៅតំបន់ភាគខាងជើងនិងភូមិស្រុកនៅតំបន់ទំនាបកណ្ដាលនាសតវត្សរ៍ទី ១៩ និងដើមសតវត្សរ៍ទី ២០ ដែលផ្ដោតខ្លាំងលើវប្បធម៌ច្រើនជាងឥរិយាបថ ។ ខ្ញុំក៏ផ្ដោតផងដែរលើបទដ្ឋាននិងរំលងចោលភាពមិនស្របគ្នាជាច្រើនទៀត ។ ការជជែកអំពីធម្មជាតិពិតប្រាកដនៃសង្គមវៀតណាមបុរាណ នៅមានការចម្រូងចម្រាសគ្នានៅឡើយ ។ ដូច្នេះ និយាយឲ្យងាយស្រួលយល់ គឺថា មានទស្សនៈធំៗ ចំនួនពីរអំពីប្រទេសវៀតណាមបុរាណ ។

ចំពោះអ្នកស្រាវជ្រាវជាច្រើន ជាពិសេស អ្នកប្រាជ្ញបារាំងជំនាន់មុនៗ ដែលបានចាប់ផ្ដើមសិក្សាប្រទេសវៀតណាមបន្ទាប់ពីបានសិក្សាស៊ីជម្រៅអំពីប្រទេសចិននោះ បានយល់ថា អនុប្រព័ន្ធជាតុយ៉ាំង ហើយជាពិសេសលទ្ធិខុងជឺបែបថ្មី គឺជាប្រព័ន្ធវប្បធម៌បុរាណ ។ ហើយគេយល់ថា អនុប្រព័ន្ធជាតុយិន គឺជាធាតុរំខានដែលនាំឲ្យមានភាពតានតឹង ភាពច្របូកច្របល់ និងបន្តឲ្យគាំងដំណើរការនៅក្នុងប្រព័ន្ធទាំងមូល[២៣] ។

ទស្សនៈថ្មីមួយទៀត មើលឃើញព្រះពុទ្ធសាសនានិងស្ថាប័នភូមិស្រុក ដែលមានសមភាពច្រើននោះ គឺជាអនុប្រព័ន្ធជាតុយិន ហើយជាវៀតណាមពិតប្រាកដ និងតំណាងឲ្យវប្បធម៌ពិតប្រាកដរបស់ប្រជាជនភាគច្រើន ។ តាមរយៈទស្សនវិស័យនេះ អនុប្រព័ន្ធជាតុយ៉ាំង ដែលជាធាតុគ្របដណ្ដប់ ជាធាតុដែលពុំមានតាំងពីយូរលង់ក្នុងប្រវត្តិសាស្ត្រ និងមានភាពពាក់កំកែលក្នុងវិស័យវប្បធម៌ ហើយត្រូវគេមើលឃើញថា ជាទស្សនៈរបស់ពួកវរជន ។ មានការជជែកពិភាក្សាគ្នាថា ទម្រង់មួយនេះត្រូវបានពួកវណ្ណៈគ្រប់គ្រងប៉ុនប៉ងប្រើប្រាស់ ដើម្បីជាឧបករណ៍កេងប្រវ័ញ្ចទៅលើប្រជាជន តែមិនបានទទួលជោគជ័យ ។ ទម្រង់នេះត្រូវបានគេដឹងឮសុសសាយថា ជាការសរសេររបស់ពួកវណ្ណៈវរជននិងបញ្ញវន្តបរទេសដែលតំណាងឲ្យវរជនភាគតិចទាំងនោះ ដើម្បីបម្រើឲ្យផលប្រយោជន៍ផ្ទាល់ខ្លួន[២៤] ។

ទស្សនៈផ្ទាល់របស់ខ្ញុំខុសខ្លាំងពីទស្សនៈទាំងពីរនេះ ។ ខ្ញុំជឿថា យិនយ៉ាំង គឺជាតុផ្សំនៃប្រព័ន្ធវប្បធម៌មួយដែលប្រជាជនវៀតណាមទាំងអស់មានចំណែក ។ ធាតុយ៉ាំងនៃអ្នកកាន់លទ្ធិខុងជឺបែបថ្មី និងធាតុយិននៃអ្នកគោរពពុទ្ធសាសនា លទ្ធិតាវ និងជំនឿខាងជីវចល បានវិវឌ្ឍជាមួយគ្នា ដើម្បីបង្កើតប្រព័ន្ធមួយ ដែលយើងស្គាល់ថា ជាសាសនាព្រេងបុរាណរបស់ជនជាតិវៀតណាម ដែលជ្រួតជ្រាបគ្រប់ទិដ្ឋភាពនៃជីវភាពរបស់ជនជាតិវៀតណាម ។ ធាតុយិននិងធាតុយ៉ាំងមានបង្កប់ក្នុងគ្រួសារ ភូមិ សាសនា និងសេដ្ឋកិច្ច[២៥] ។ល។

ទាំងពីរនេះ គ្មានមួយណា «ត្រឹមត្រូវ» ឬ «ស្របច្បាប់» ជាងមួយណាទេ ។ បើគ្មានមួយណាទេនោះ វប្បធម៌វៀតណាមនិងការគ្រប់គ្រងសង្គមវៀតណាម ជួនកាល ខុសគ្នាពីអ្វីដែលធ្លាប់មានមក ។ បុគ្គល គ្រួសារ សង្គមផ្ទាល់ បានប្រែប្រួលក្នុងជំហរនៃមនោគមវិជ្ជាទាំងពីរនេះ ដែលខ្ញុំបានដាក់ឈ្មោះពួកវាថា ធាតុយិននិងធាតុយ៉ាំង ។ នៅក្នុងក្របខ័ណ្ឌបែបនេះ និងនៅក្នុងការឆ្លើយតបទៅនឹងប្រវត្តិសាស្ត្រនិងកាលៈទេសៈនោះ វាមានការវិវឌ្ឍនូវគុណតម្លៃស្នូលមួយ ដែលបង្កើតបានជាបេះដូងនៃវប្បធម៌ជនជាតិវៀតណាមបុរាណ ដែលនោះ គឺជា «បង្គួច» ដែលជនជាតិវៀតណាមមើលឃើញពិភពលោក និងបកស្រាយនូវអ្វីដែលពួកគេបានឆ្លងកាត់ ។ វិធីនៃការគិត និងការធ្វើ ត្រូវបានបណ្ដុះជាគំនិតដល់កូនក្មេង ចាប់តាំងពីពួកគេកើតមកម្ល៉េះ ហើយត្រូវបានរំលឹកបន្ថែមតាមវិធីសាស្ត្រច្រើនបែបយ៉ាងនៅក្នុងឆាកជីវិត និងបានគ្របដណ្ដប់លើជំនឿរបស់ជនជាតិវៀតណាមចំពោះ

ពិភពលោក ថា មានរូបរាងយ៉ាងដូចម្ដេច និងថា តើពួកគេគួរប្រព្រឹត្តខ្លួនយ៉ាងណាឲ្យសមរម្យ ។ រឿងបន្ទាប់ទៀតនេះ គឺរឿង «មានកើតឡើង» នៅពេលដែលវប្បធម៌វៀតណាមនិងវប្បធម៌បស្ចិមប្រទេសជួបគ្នា មានព្រឹត្តិការណ៍ច្រើនណាស់ដែលគ្មានន័យអ្វីទាំងអស់ ប្រសិនមិនបានយោងព្រឹត្តិការណ៍ទាំងនេះ ទៅនឹងគុណតម្លៃទាំងនេះទេ ។ យើងនិងពិព័ណ៌នាអំពីគុណតម្លៃទាំងនេះត្រួសៗ នៅទីនេះ ។

## ភាពសមហេតុផល (ភាសាវៀតណាមហៅថា «លី» "lý")

ពិភពលោកនិងអ្វីទាំងឡាយ ដែលមាននៅក្នុងលោកយើងនេះ សុទ្ធតែមានរចនាសម្ព័ន្ធដោយឡែករបស់វា ។ ដោយផ្អែកលើក្រឹត្យក្រមធម្មជាតិ វិចារណកម្ម ឬ «ភាពសមហេតុផល» («លី») ប្រមូលផ្ដុំដោយការយល់ស្របគ្នានៅក្នុងរចនាសម្ព័ន្ធជាមូលដ្ឋានមួយ ដែលគ្រប់គ្រងពិភពលោកទាំងមូល ។ ពាក្យថា «លី» មានន័យថា «ធម្ម-ជាតិនៃអ្វីមួយ» ។ «លី» ជាគោលការណ៍ដែលក្ដោបរួមមួយ ដោយផ្អែកលើការសង្កេតនិងបទពិសោធន៍ ដែលធ្វើឡើងក្នុងបំណងផ្ដល់នូវភាពរលូនជាមួយគ្នានៅក្នុងប្រព័ន្ធ ដោយកំណត់ទម្រង់ត្រឹមត្រូវនៃទំនាក់ទំនងទាំងអស់ ។ គោលគំនិត «លី» ធ្វើវិចារណកម្ម និងធ្វើឲ្យស្របច្បាប់នូវក្រឹត្យក្រមនៃឋានានុក្រមរបស់សង្គមនិងជាតិ ដោយធ្វើឲ្យឋានានុក្រមនោះឯង ជាផ្នែកមួយនៃរចនាសម្ព័ន្ធសំខាន់របស់ពិភពលោក ដែលជាស្ថានភាពមួយមានលក្ខណៈធម្មជាតិនិងមិនអាចកែប្រែបាន ។

## ការគោរពខ្លាចឪពុកម្ដាយ និងការដឹងគុណ (ភាសាវៀតណាមហៅថា «ហៀវ» "hiếu" និង «អឹន» "ơn")

ទំនាក់ទំនងគ្រួសារ គឺជាបែបបទសម្រាប់ការរៀបចំសង្គមមួយ ។ ទាំងការចិញ្ចឹមបីបាច់ថែរក្សាកូន និងការអប់រំក្នុងប្រព័ន្ធ សុទ្ធតែបានសង្កត់ធ្ងន់លើការអប់រំចរិយាសម្បត្តិ ឲ្យប្រព្រឹត្តសមរម្យចំពោះសមាជិកគ្រួសារឯទៀត ។ ជាដំបូងនិងសំខាន់ជាងគេនេះ គឺគេបង្រៀនកូនក្មេងឲ្យចេះគោរពខ្លាចស្រឡាញ់ឪពុកម្ដាយ ឲ្យចេះស្ដាប់បង្គាប់ និងចេះមានអាកប្បកិរិយាល្អចំពោះឪពុកម្ដាយរបស់ខ្លួន ។ គេប្រៀនប្រដៅក្មេងៗ ឲ្យចេះមានអារម្មណ៍យ៉ាងជ្រាលជ្រៅថា ពួកគេបានជំពាក់គុណចំពោះឪពុកម្ដាយខ្លួន បំណុលនេះធំអនេករហូតដល់មិនអាចសងអស់បាន ។ ក្មេងៗត្រូវខិតខំធ្វើឲ្យឪពុកម្ដាយសប្បាយចិត្តគ្រប់ពេលតាមមធ្យោបាយណាក៏ដោយ ឲ្យតែអាចធ្វើទៅបាន ដើម្បីបង្កើនសុខុមាលភាពរបស់ពួកគាត់ ដើម្បីឲ្យស្របទៅតាមបំណងប្រាថ្នាទាំងអស់របស់ពួកគាត់ ដើម្បីបំពេញសេចក្ដីប្រាថ្នារបស់ពួកគាត់ ដើម្បីសម្រាលបន្ទុកការងារ និងកង្វល់របស់ពួកគាត់ ហើយនិងដើម្បីធ្វើឲ្យស្របតាមបំណងប្រាថ្នារបស់ពួកគាត់គ្រប់រឿងរ៉ាវទាំងអស់ មិនថាធំឬតូច ។ បើយើងសង្កេតមើលជីវភាពប្រចាំថ្ងៃ និងប្រវត្តិសាស្ត្ររាប់ពាន់ឆ្នាំមកហើយ យើងឃើញថា ក្មេងៗ ត្រូវបានរងនូវទម្ងន់នៃគំរូមួយ ដែលខ្លួនត្រូវធ្វើដើម្បីក្លាយជាកូនដែល «ចេះគោរពខ្លាចឪពុកម្ដាយ» ។ ទំនាក់ទំនងរវាងកូននិងឪពុកម្ដាយ បានក្លាយជាស្នូលនៃវប្បធម៌វៀតណាមដែលមានច្រើនលើសលប់លើអ្វីៗ ផ្សេងទៀត ។

## ទំនាក់ទំនងរវាងបងប្អូនប្រុស (ភាសាវៀតណាមហៅថា «ដេ» "đễ")

បែបបទសម្រាប់តួនាទីសង្គមសំខាន់បន្ទាប់មួយទៀតគឺទំនាក់ទំនងរវាងបងប្អូនប្រុស ។ បងប្រុសត្រូវបង្រៀនចិញ្ចឹមបីបាច់ថែរក្សានិងការពារប្អូនប្រុសរបស់ខ្លួន ។ ប្អូនប្រុសវិញត្រូវគោរពធ្វើតាម និងគាំទ្របងប្រុសរបស់ខ្លួន ។ ទំនាក់ទំនងត្រឹមត្រូវរវាងបងប្រុសនិងប្អូនប្រុស ត្រូវបានបកស្រាយបញ្ជាក់តាមរយៈសុភាសិតនិងរឿងព្រេងនិទានជាច្រើន ។ បើតាមរឿងព្រេងទាំងនេះ ចំណងរវាងបងប្អូន ជាញឹកញាប់ មិនដូចគ្នានឹងចំណងប្តីប្រពន្ធទេ ។ បងប្អូនប្រុសមិនគួរឲ្យមាននរណាម្នាក់ ឬអ្វីមួយ ជាពិសេស ស្ត្រី អាចមកជ្រៀតជ្រែកឡើយ ។ មានរឿងប្រជាប្រិយជាច្រើន លើកតម្កើងថែមទៀតនូវប្រការសំខាន់នៃមនោគមវិជ្ជារបស់ចំណងសាច់សាលោហិត ដោយបញ្ជាក់យ៉ាងច្បាស់នូវការធ្វើផ្ទុយនឹងកាតព្វកិច្ចគ្រួសារ គឺផ្ទុយនឹងក្រឹត្យក្រមធម្មជាតិនៅក្នុងលោក ។ ហើយការធ្វើខុសនឹងក្រឹត្យក្រមធម្មជាតិគឺជាការប្រព្រឹត្តឥតខ្លឹមសារ និងនាំឲ្យមានគ្រោះថ្នាក់ ។

ខុសពីកូនក្មេងៗ នៅបស្ចិមប្រទេសភាគច្រើន កូនក្មេងដែលធំដឹងក្តីនៅក្នុងគ្រួសារវៀតណាមបុរាណ បានរៀនសូត្រពីភាពពឹងពាក់លើគ្រួសារ ការមានគេចិញ្ចឹមបីបាច់ មិនមែនរៀនសូត្រអំពីភាពឯករាជម្ចាស់ការទេ។ ពួកគេបានរៀនសូត្រអំពីសារៈសំខាន់នៃឋានានុក្រម មិនមែនរៀនសូត្រអំពីសមភាពទេ ។ ពួកគេបានរៀនសូត្រអំពីវង្វាន់ ដែលបានមកពីការគោរពប្រណិប័តន៍ចំពោះអ្នកដែលមានឋានៈខ្ពស់ជាង មិនមែនរៀនសូត្រអំពីការជឿជាក់លើខ្លួនឯងទេ ។ ឧទាហរណ៍ជាគំរូសម្រាប់ពង្រីកបែបបទគ្រួសារចំពោះសង្គមនេះ គឺជាទំនាក់ទំនងរវាងបងប្អូនប្រុសនេះឯង ។ មនុស្សម្នាក់ត្រូវគោរពអ្នកមានអាយុច្រើនជាង ឬមានឋានៈខ្ពស់ជាង ឲ្យដូចទៅនឹងការគោរពបងប្រុសរបស់ខ្លួន ។

ប្អូនប្រុសត្រូវទុកប្រយោជន៍ខ្លួនមួយអន្លើ និងត្រូវមានចរិយាមារយាទក្នុងទំនាក់ទំនងជាមួយបងប្រុសខ្លួន ។ ទោះបីជាយ៉ាងនេះក្តី បើតាមរឿងព្រេងនិទានវៀតណាម មានប្អូនប្រុសខ្លះដែរ អាចរកស៊ីមានបាន ទោះជាខ្លួនមិនបានគោរពសព្វគ្រប់តាមចរិយាមារយាទដែលបានកំណត់ក៏ដោយ ។ ពួកគេទទួលបានជោគជ័យពិតប្រាកដដោយសារពួកគេបានធ្វើតាមតួនាទីនៃការប្រព្រឹត្តដែលច្បាប់កំណត់ ហើយដែលសមរម្យទៅតាមស្ថានភាពជាក់ស្តែងរបស់គេ ។ ពួកគេត្រូវតែឱនលំទោននិងផ្គាប់ចិត្តតាមបងប្រុស ដូចគ្នាទៅនឹងចំពោះឪពុកម្តាយដែរ ទោះបីជាមានការលើកលែងខ្លះយ៉ាងណាក៏ដោយ ។ ក្នុងការដែលសុខចិត្តព្រមចំណុះទៅតាមការស្នើរបស់បងប្រុសខ្លួន ដែលជួនកាលមិនសមហេតុផលយ៉ាងណាក្តីនោះ ពួកគេនឹងបានសន្សំកុសលច្រើន ។ ប្អូនប្រុសមិនដែលទទួលបានជោគជ័យនោះទេ ប្រសិនបើពួកគេមានភាពក្លាហាន ឬភាពឈ្លាសវៃ ឬក៏ការជឿជាក់លើខ្លួនឯងពេក ។ បែបបទមនោគមវិជ្ជាមួយនេះ ត្រូវបានរៀនសូត្រពីសាលារៀន ពីគ្រួសារ ពីប្រពៃណីនិងពីទំនៀមទម្លាប់អ្នកស្រុក ហើយវាគឺជាការធ្វើដើម្បីផ្គាប់ចិត្តទៅនឹងបំណងប្រាថ្នានៃអ្នកដែលមានឋានៈបុណ្យស័ក្តិខ្ពស់ជាងខ្លួន នៅក្នុងឋានានុក្រមសង្គមៈ កូនចំពោះឪពុកម្តាយ ប្អូនចំពោះបងប្រុស និងប្រពន្ធចំពោះប្តី ។

## តួនាទីរបស់ភេទនីមួយៗ

ស្ត្រីកើតមក នឹងរស់នៅក្នុងគំនិតមួយ ដែលតម្រូវឲ្យគាត់បំពេញតួនាទីជាកូនស្រី ភរិយា និងមាតាយ៉ាងមានរបៀបរៀបរយ ។ តួនាទីរបស់ស្ត្រី គឺជាប្រភពនៃភាពតានតឹងនៅក្នុងសង្គម ។ ជារឿយៗ មានភាពខណ្ឌចែកដាច់គ្នាយ៉ាងខ្លាំងរវាងគោលការណ៍មនោគមវិជ្ជានិងតថភាពសង្គម ។ នៅក្នុងរឿងទេវកថា រឿងព្រេងនិទាន

និងប្រវត្តិសាស្ត្រវៀតណាម មានពោរពេញទៅដោយរឿងនិទានអំពីស្ត្រីដែលខ្លាំង ឈ្លាសវៃ និងម៉ឺងម៉ាត់ ។ នៅក្នុងលំដាប់ខ្ពស់បំផុតនៃសង្គម បុរសនិងស្ត្រីជារឿយៗ ធ្វើការជាមួយគ្នា ។ ស្ត្រីបានបំពេញការងារលំបាកជាច្រើន ដោយប្រើកម្លាំង ហើយអ្នកខ្លះទៀតប្រកបរបរជួញដូរតិចតួច និងធ្វើជាសិប្បករិនីជំនាញ ។

ទោះជាយ៉ាងណាក្តី តាមមនោគមវិជ្ជា បុរសគឺជាធាតុយ៉ាំង ចំណែកឯស្ត្រីគឺធាតុយិន ។ ស្ត្រីចំណុះឱ្យបុរសទៅតាមបែបធម្មជាតិ ។ ដូចកូនក្មេងនិងប្អូនប្រុសដែរ ស្ត្រីត្រូវតែចេះស្តាប់បង្គាប់ ចេះជួយគាំទ្រ និងធ្វើតាមស្វាមីរបស់ខ្លួន ។ ស្វាមីរបស់ពួកគាត់ ត្រូវបង្រៀនិងគ្រប់គ្រងភរិយាខ្លួនឱ្យដូចទៅនឹងការធ្វើចំពោះប្អូនប្រុសនិងកូនរបស់ខ្លួនដូច្នេះដែរ ។

មាននិន្នាការបន្តមួយ ដែលចាក់ឫសគល់នៅក្នុងទស្សនៈបែបឋានានុក្រមនៃធាតុយិននិងធាតុយ៉ាំង ដើម្បីនិយាយបន្ទាបឋានៈរបស់ស្ត្រី និងដាក់អំណាចពួកគាត់ឱ្យនៅក្រោមការគ្រប់គ្រងរបស់បុរស ។ ស្ត្រីត្រូវតែចេះឱនលំទោនចំពោះឪពុករបស់គាត់ ពេលគាត់នៅក្មេង ត្រូវចេះឱនលំទោនចំពោះស្វាមីគាត់ពេលគាត់រៀបការរួច និងត្រូវចេះឱនលំទោនចំពោះកូនប្រុសច្បងរបស់គាត់នៅពេលដែលគាត់ក្លាយជាស្ត្រីមេម៉ាយ ។ គំនិតដែលថាប្រុសមានភាពឧត្តុង្គឧត្តមលើសគេ កាន់តែមានឥទ្ធិពលខ្លាំងឡើង ។ «មានក្មេងប្រុសម្នាក់ ប្រសើរជាងមានក្មេងស្រី ១០ នាក់»[២៦] ។ «ស្រី ១០០ នាក់មិនថ្លៃស្មើនឹងពងស្វាសម្ខាងផង»[២៧] ។ ពួកគេស្រឡាញ់និងចិញ្ចឹមបីបាច់ថែរក្សាកូនស្រី ប៉ុន្តែដាក់ស្នេងពួកគេពេញចិត្តកូនប្រុសជាង ។

ក្មេងប្រុសៗ ទទួលបានការយកចិត្តទុកដាក់ច្រើនជាងក្មេងស្រី ។ ក្មេងប្រុសៗ អាចធ្វើអ្វីមួយទៅតាមទំនើងចិត្តរបស់ពួកគេបាន និងអាចដើរហើរទៅណាមកណាបានសេរីជាងក្មេងស្រី ។ ក្មេងស្រីវិញ គេឱ្យនៅចាំផ្ទះ មានភារកិច្ចជួយធ្វើការងារផ្ទះសម្បែង និងស្ថិតក្រោមការគ្រប់គ្រងតឹងរ៉ឹងជាងក្មេងប្រុសៗ ។ ប្រសិនបើគ្រួសារមានប្រាក់កាសតិចតួច ប្រាក់ទាំងនោះនឹងត្រូវឱ្យទៅកូនប្រុស ដើម្បីរៀនសូត្រ ចំណែកកូនស្រីត្រូវនៅផ្ទះ ។ ប្រសិនបើកូនស្រីហ៊ានជជីកសួរថា «ហេតុអ្វីបងប្អូនប្រុសរបស់នាងអាចធ្វើបាន ប៉ុន្តែនាងធ្វើមិនបានដូចអ៊ីចឹង ?» ចម្លើយយ៉ាងងាយគឺ «ដោយសារតែពួកគេនោះឯងជាប្រុស» ។ ចម្លើយប៉ុណ្ណឹងមិនចាំបាច់មានការបកស្រាយអ្វីបន្ថែមទៀតឡើយ[២៨] ។

ក្រោយពេលរៀបការរួច ភរិយាត្រូវទៅរស់នៅជិត ឬជាមួយគ្រួសារខាងស្វាមី ។ ដូចនេះ ក្រុមគ្រួសារខាងស្រី ត្រូវតែបង្ហាត់បង្រៀនកូនស្រីឱ្យត្រៀមខ្លួនជាស្រេច ដើម្បីចាកចេញទៅរស់នៅជាមួយគ្រួសារខាងប្តីដែលនាងនឹងទៅរស់នៅអស់មួយជីវិតរបស់នាង ។ ជាពិសេស ចំពោះម្តាយរបស់កូនប្រុស ពួកគាត់ត្រូវតែប្រកួតប្រជែងជ្រើសរើសរកអនាគតកូនប្រសាស្រី ដែលមានស្វាមីភក្តិចំពោះកូនប្រុសពួកគាត់ ។

## ផ្លូវត្រូវ (ភាសាវៀតណាមហៅថា «ង៉ៀ» “nghĩa”)

គោលការណ៍ប្រព្រឹត្តដែលផ្តោតលើតួនាទីទាំងនេះរួមជាមួយ «ហៀវ» និង «ដេ» ដែលជាស្នូលនិងចងភ្ជាប់ជាមួយគោលគំនិតរបស់ «អឺន» ផងនោះ បានបណ្តុះនៅក្នុងជនជាតិវៀតណាមនូវក្រមសីលធម៌តឹងរ៉ឹងមួយ និងកាតព្វកិច្ចច្បងដែលមិនត្រូវប្រព្រឹត្តឱ្យមានកំហុស ។ មានគុណតម្លៃផ្សេងទៀតដែរ ដែលមានមុខងារក្នុងការជួយគាំទ្រនូវគុណតម្លៃសំខាន់របស់ធាតុយ៉ាំងទាំងនេះ ។ គតិបណ្ឌិតឬការចេះដឹង ភាសាវៀតណាមហៅថា «ទ្រី» (trí)

*ភាពសមរម្យ ភាសាវៀតណាមហៅថា «លែ» (lễ) និងភាពស្មោះត្រង់ឬសច្ចធម៌ ភាសាវៀតណាមហៅថា «ទិន» (tín) រួមទាំងភាពក្លាហាន ភាសាវៀតណាមហៅថា «យុង» (dũng) និងការតស៊ូ ភាសាវៀតណាមហៅថា «ជី» (chí) ទាំងអស់នេះគឺជាគុណតម្លៃចម្បង ដែលបានជួយគាំទ្រនិងអនុវត្តកាតព្វកិច្ចចម្បងរបស់សង្គមឈរលើមូលដ្ឋាន «ហៀវ» និង «ដេ» ហើយបានជួយបន្ថែមធ្វើជាប្រទីបសម្រាប់សម្ពន្ធភាពរបស់មនុស្សម្នាក់ៗ នៅក្នុងក្រុមផ្សេងៗ ទៀតនៃសង្គម ។ កត្តីភាព ភាសាវៀតណាមហៅថា «ទ្រុង» (trung) ដែលជាការពង្រីកបន្ថែមនៃ «ហៀវ» ចំពោះទំនាក់ទំនងនៃវត្ថុមួយទៅនឹងម្ចាស់របស់វា ។*

*កាតព្វកិច្ចសំខាន់របស់សង្គម ត្រូវបានសង្ខេបដោយគុណតម្លៃរបស់ «ងៀ» ប្រហែលជាប្រែសម្រួលឲ្យស្រួលស្តាប់នោះគឺ «ការធ្វើត្រូវ» ។ «ងៀ» បញ្ជាក់ន័យ ករណីយកិច្ច យុត្តិធម៌ និងកាតព្វកិច្ច ។ «ងៀ» បណ្តុះធន្ធៈឲ្យមនុស្សធ្វើអ្វីដែលខ្លួនត្រូវធ្វើ ដើម្បីបំពេញតាមកាតព្វកិច្ចសង្គមរបស់ខ្លួន ដើម្បីសង «អឺន» ដើម្បីឆ្លើយតបទៅនឹង «ហៀវ» និង «ដេ» ។ «ងៀ» ទាមទារវិចារណញ្ញាណស្ទប់ស្ទាត់នៅក្នុងវចនាសម្ព័ន្ធរបស់ «លី» ដែលជាធម្មជាតិនៃវត្ថុទាំងឡាយ ហើយទាមទារឲ្យមនុស្សម្នាក់រស់នៅក្រោមច្បាប់ទម្លាប់ ដែលមិនអាចជៀសបាន មិនថាកាលៈទេសៈណាឬហេតុផលបុគ្គលយ៉ាងណានោះទេ ។ គោលគំនិត «ងៀ» ផ្អែកទាំងស្រុងលើការប្រព្រឹត្តនៅក្នុងតួនាទីសង្គមសំខាន់ៗ ។ ឧទាហរណ៍ «ងៀ» កំណត់បញ្ជាឲ្យកូនប្រុសគួរប្រព្រឹត្តយ៉ាងដូចម្តេចចំពោះឪពុក ប្អូនប្រុសគួរប្រព្រឹត្តយ៉ាងដូចម្តេចទៅកាន់បងប្រុស ប្រជានុរាស្ត្រគួរប្រព្រឹត្តយ៉ាងដូចម្តេចទៅកាន់ស្តេច ជាដើម ។ល។ «ងៀ» បានភ្លេចចោលទំនាក់ទំនង និងការប្រព្រឹត្តដែលមិនមានទំនាក់ទំនងជាមួយនឹងតួនាទីយុទ្ធសាស្ត្រសង្គម ។*

## អារម្មណ៍និងមនោសញ្ចេតនា *(ភាសាវៀតណាមហៅថា «ទិញ» "tình" និង «ញ៉ឹន» "nhân")*

*នៅត្រង់ស្នូលនៃក្របខ័ណ្ឌដ៏តឹងរ៉ឹងរបស់ធាតុយ៉ាំង គឺជាគោលគំនិតដែលផ្ទុកទៅដោយគុណតម្លៃរបស់ «លី» «ហៀវ» «ដេ» និង «អឺន» ។ ក្របខ័ណ្ឌសង្គមនេះ គឺជាលទ្ធិខុងជឺបែបថ្មីដ៏មុតមាំ ផ្តោតលើបុរសជាធំ ផ្តោតលើតួនាទីជាជាងផ្តោតលើមនុស្ស ផ្តោតលើសុខុមាលភាពរបស់សហករណ៍ (គ្រួសារ ភូមិ ស្រុក ប្រទេសជាតិ) ជាជាងផ្តោតលើអារម្មណ៍ បំណងប្រាថ្នា ឬបញ្ហារបស់បុគ្គល ។ នៅស្របពេលដែល «លី» ទទួលបាននូវតំណែងនៃប្រព័ន្ធដែលគ្របលើគេមួយ ជាពិសេស ក្នុងចំណោមវរជន និងមានឥទ្ធិពលខ្លាំងនៅក្នុងតំបន់ភាគខាងជើង និងផ្នែកភាគកណ្តាលនៃប្រទេសវៀតណាម ។ ភាពខ្លាំងនិងភាពស្អួចស្អើងរបស់ «លី» បានបង្កើតជាការជួយគ្នាខ្លាំងមួយ ទៅនឹងគុណតម្លៃនឹងគោលគំនិតផ្សេងៗ ជាច្រើន ។ ការពិតទៅ យិននិងយ៉ាំង មានភាពប្រឆាំងគ្នាអ៊ីចឹងមែន ប៉ុន្តែវិស័យទាំងពីរនេះមិនអាចខ្វះមួយណាបានទេ ព្រោះជាវិស័យបង្គ្រប់គ្នាទៅវិញទៅមក ។ ក្នុងចំណោមវិស័យទាំងពីរនេះ បើកាលណាមួយណាមានភាពលើសលប់ច្រើនជាងម្ខាងទៀត នោះច្បាស់ជាមានបញ្ហាហើយ ។*

*វិស័យយ៉ាំង គឺជាលក្ខខ័ណ្ឌដែលធ្វើឲ្យមនុស្សម្នាក់ៗ មិនអាចទទួលបាននូវសេចក្តីត្រូវការផ្ទាល់ ។ នេះក៏ដោយសារតែមានគោលការណ៍គោរពតាមទំនៀមទម្លាប់យ៉ាងតឹងរ៉ឹង ដោយរិះគន់មិនត្រឹមត្រូវទៅលើអ្នកមិនគោរពទំនៀមទម្លាប់ ឬក៏ការរិះគន់លើស្ត្រី ហើយក៏ដោយសារតែគោលការណ៍នេះផ្តោតយ៉ាងសំខាន់លើតួនាទី*

អត្តចរិតជាជាងមនុស្ស និងផ្តោតលើក្រុមជាជាងមនុស្សម្នាក់ៗ ។ មានមតិរិះគន់មួយចំនួនហៅគោលការណ៍បែបនេះថា «អាវកុតចង្អៀត» ហើយសន្និដ្ឋានថា គោលការណ៍បែបនេះបានទៅរក «ភាពចូលមិនចុះ»[២៩] ។ ពុទ្ធសាសនា សាសនាតាវ និងប្រពៃណីជនម្ចាស់ស្រុក រួមទាំងធាតុផ្សំនៃគំនិតរបស់លោក ខុងជឺ បានផ្តល់នូវគុណតម្លៃ ទំនៀមទម្លាប់ និងការអនុវត្តយ៉ាងទូលំទូលាយ ដែលបង្កបង្កើតបានជាលំនឹងរបស់ធាតុយិន តទល់នឹងឧបរិវេចនាសម្ព័ន្ធសង្គមដ៏ធំសម្បើមនៃធាតុយ៉ាំង ។ អ្វីដែលជាការផ្ទុយគ្នាយ៉ាងខ្លាំងនៅក្នុងវប្បធម៌វៀតណាម ពោលគឺក្នុងជីវភាពប្រចាំថ្ងៃរបស់ជនជាតិវៀតណាម គឺរវាង «ង៉ៀ» និង «ទិញ» ។ នៅស្របពេលដែល «ង៉ៀ» គឺស្តីពីសីលធម៌ អភិសមាចារ និងករណីយកិច្ច «ទិញ» ឯណោះវិញ គឺស្តីអំពីអារម្មណ៍ ។ «ទិញ» គឺជាអ្វីដែលកើតឡើងដោយខ្លួនឯង មានភាពទោរទន់ទៅតាមការគិតរបស់បុគ្គល ដែលកើតពីសភាវគតិ មិនអាចស្មានទុកមុនបាន និងឆាប់រំជួលចិត្ត ។ គេតែងតែសំដៅ «ទិញ» ទៅនឹង«សេចក្តីស្នេហា» ហើយមិនតែប៉ុណ្ណោះ គេប្រើ «ទិញ» នេះ ដើម្បីបញ្ជាក់ន័យអំពីតណ្ហា មនោសញ្ចេតនា បំណងប្រាថ្នា ឬការរំជួលចិត្ត និយមអ្វីដែលយើងអាចហៅបានថា ជាការបញ្ជារបស់ចិត្ត ។ «ទិញ» ជាធាតុសម្រុះសម្រួលរបស់ «ង៉ៀ» ដែរ ។

គុណតម្លៃដែលស្រដៀងគ្នានឹង «ង៉ៀ» ប៉ុន្តែមានភាពភាពផ្ទុយគ្នាពី «ង៉ៀ» នោះ គឺ «ញ៉ឹន» ។ «ញ៉ឹន» គឺជាគុណតម្លៃនៃមេត្តាធម៌ សប្បុរិសធម៌ គុណធម៌ មនុស្សធម៌ សេចក្តីស្រឡាញ់ចំពោះមនុស្សលោក ។ «ញ៉ឹន» ដូចគ្នានឹង «ទិញ» ដែលមានភាពពាក់ព័ន្ធទៅនិងសភាពធម្មជាតិនិងអារម្មណ៍ ។ «ញ៉ឹន» តម្រូវឲ្យមានការចូលហួសពីបញ្ញត្តិរបស់ចិត្ត ដើម្បីប្រព្រឹត្តអំពើល្អទៅទៀត ព្រោះមនុស្សមានការអធ្យាស្រ័យយល់ចិត្តយល់ថ្លើម និងមេត្តាធម៌នៅក្នុងចិត្តរបស់ខ្លួន ។ ជាក់ស្តែង «ញ៉ឹន» បូកចូលគ្នាជាមួយការទូន្មានប្រដៅរបស់ព្រះពុទ្ធសាសនា ដើម្បីរំលឹកមនុស្សដោយធ្វើឲ្យទៅកាន់គ្នា ឲ្យមានចិត្តមេត្តាធម៌ និងមានចិត្តសប្បុរិសធម៌ ។ «ទិញ» និង «ញ៉ឹន» ផ្តល់នូវតុល្យភាពខាងផ្លូវអារម្មណ៍ទល់នឹងភាពសមហេតុផលនៃភាពត្រឹមត្រូវនៅក្នុង «ង៉ៀ» ។

## ភាពសុខដុមមិនជាក់លាក់ ហើយនិងភាពសុខដុមពេញលេញ *(ភាសាវៀតណាមហៅថា «លី» "lý" និង «ដៀវ» "điều")*

ប្រកពនៃភាពតានតឹងខ្លាំងមួយទៀត រវាងគុណតម្លៃរបស់ធាតុយិននិងធាតុយ៉ាំង គឺការមើលឃើញពីភាពសុខដុមរមនា និងភាពសមហេតុផល តាមរបៀបពីរផ្សេងគ្នា ។ ភាពសុខដុមរមនា គឺជាគោលគំនិតសំខាន់ដែលមានគុណតម្លៃសំខាន់ទាំងក្នុងវិស័យធាតុយិននិងវិស័យធាតុយ៉ាំង ។ ភាពសមហេតុផល គឺជាមូលដ្ឋានចាំបាច់ដើម្បីឈានទៅរកការសុខស្រួលមួយបាន ។ ប៉ុន្តែ ភាពសុខស្រួលនៃធាតុយ៉ាំង ជានិច្ចកាលសំដៅត្រឡប់ទៅរកគោលគំនិត«លី» ពោលគឺគោលគំនិតទូលំទូលាយរបស់ក្រឹត្យក្រមធម្មជាតិ ដែលរួមមានបញ្ចូលទាំងពិភពលោកធម៌ ពិភពសង្គម និងពិភពធម្មជាតិ ។ «លី» គឺជាអ្វីដែលនឹងន ភាពថាវរៈ ដែលបុគ្គលនិងសង្គមត្រូវតែធ្វើតាម ។ ជំនឿខាងលោកធាតុនេះ គាំទ្រគោលគំនិតធាតុយ៉ាំងទាំងស្រុង ។ មានចម្លើយដែលត្រឹមត្រូវតែមួយគត់ មានផ្លូវត្រឹមត្រូវតែមួយដើម្បីនឹងធ្វើអ្វីៗ ហើយភាពសុខដុមរមនា គឺបានមកពីការអនុលោមទៅតាមអ្វីដែល «ត្រូវ» គឺអ្វីដែលស្របគ្នាទៅនឹង «លី» ។

ប៉ុន្តែ មានពាក្យមួយដែលមានន័យបែបម្យ៉ាងផ្សេងទៀតចំពោះពាក្យ «សមហេតុផល» ដែលមាននៅក្នុង

*វិស័យធាតុយិននេះ ។ នៅប្រទេសវៀតណាម នេះគឺជាគុណតម្លៃរបស់ «ដៀវ» ។ ពាក្យនេះ គេប្រើក្នុងសមាសនាមដែលសំដៅទៅលើព័ណ៌ចម្រុះ ការផ្សំសម្លេងឲ្យពីរោះក្នុងតន្ត្រី ការសម្រុះសម្រួលយោបល់ផ្ទុយគ្នា ការធ្វើជាអាជ្ញាកណ្ដាលក្នុងរឿងជម្លោះ ។ «ដៀវ» តែងតែសំដៅទៅលើអន្តរកម្មនិងឆន្ទៈ ដើម្បីទទួលយកឬកែសម្រួលជំហរឬសកម្មភាពណាមួយរបស់ខ្លួន ដើម្បីឲ្យរាស៊ីគ្នាទៅនឹងស្ថានភាពមួយ ពោលគឺដើម្បីឲ្យចូលនឹងគេចុះ ។ ដើម្បីឲ្យងាយយល់ គឺការបន្ទន់ជំហររបស់ខ្លួន ដើម្បីប្រយោជន៍នៃការស្រុះស្រួលគ្នារបស់សង្គម ។ «លី» កំណត់ន័យរបស់បទដ្ឋានបែបដាច់ខាតមួយ ឬជាក្របខ័ណ្ឌយោង រីឯជំនឿលើការប៉ត់បែនទៅតាមកាលៈទេសៈ គឺជាខ្លឹមសារសំខាន់របស់ «ដៀវ» ។ «ដៀវ» ក្នុងនាមជាគុណតម្លៃ មានន័យថា «សមហេតុសមផល» គឺល្មម ចេះជាកណ្ដាល ។ ចំពោះអ្នកដែលមិនយល់ពាក្យថា ល្មម ហើយដែលមានមហិច្ឆតាលោភលន់ខ្លាំងពេក ឬតឹងរ៉ឹងពេក ឬក៏ជឿជាក់លើខ្លួនឯងខ្លាំងពេក អាចនឹងនាំឲ្យមានការវិនាសដល់ខ្លួន ។ ការរិះរកឲ្យមានតុល្យភាពគ្នារវាងធាតុយិននិងធាតុយ៉ាំង រវាងកាតព្វកិច្ចនិងមនោសញ្ចេតនា ជួយកសាងជីវិតឲ្យសមល្មមទាក់ទិននឹងជម្លោះនិងការវិនិច្ឆ័យ ។*

## អត្តបរាធហើយនិងការចូលរួម

*វិសាលភាពធំមួយផ្សេងទៀតនៃភាពតានតឹងនេះ គឺភាពផ្ទុយគ្នារវាងការចូលរួមយ៉ាងសកម្មក្នុងសង្គម និងការមិនចូលរួមធ្វើអ្វីសោះ ឬដកខ្លួនចេញពីសង្គម ។ បើតាមគំនិតនៃពុទ្ធសាសនាចិន «ការចូលរួមក្នុងកិច្ចការលោកិយ» និង «ការមិនចូលរួមក្នុងកិច្ចការលោកិយ» គឺផ្នែកដែលចែកដាច់ពីគ្នានិងដែលមិនអាចផ្សះផ្សាគ្នាបាន ។ ប៉ុន្តែជនជាតិវៀតណាមជាច្រើនបានខិតខំយ៉ាងខ្លាំង ដើម្បីបញ្ចូលគំរូទាំងពីរនេះទៅក្នុងជីវភាពនិងក្នុងសង្គមរបស់ពួកគេ[៣០] ។ លទ្ធិខុងជឺបែបថ្មី និងវិស័យយ៉ាំងទាំងស្រុង លើកទឹកចិត្តឲ្យមានភាពសកម្ម និងបង្កើតឲ្យមានការប្រកួតប្រជែង ។ ការបម្រើដល់ប្រយោជន៍សាធារណៈ គេមើលឃើញថា ជាកិត្តិយសនិងកាតព្វកិច្ច ។ ប៉ុន្តែធាតុផ្សំរបស់ពុទ្ធសាសនានិងសាសនាតាវ លើកតម្កើងការតាំងសមាធិនិងអកម្មភាព ព្រមទាំងមិនបានឲ្យតម្លៃ ឬថែមទាំងចំអកចំពោះការតស៊ូឥតន័យក្នុងការដាក់កំហិតឆន្ទៈរបស់ខ្លួនទៅលើតថភាពមួយ ដែលមិនមានការពាក់ព័ន្ធនឹងឆន្ទៈរបស់មនុស្សម្នានោះ ។*

*បញ្ញត្តិរបស់ «អឺន» ធ្វើឲ្យការបែងចែករវាងការចូលរួម និងការមិនចូលរួមនេះ មានថាមភាពខុសពីធម្មតា ហើយជារឿយៗ ធ្វើឲ្យមានការប៉ះពាល់ដល់ផ្លូវចិត្តយ៉ាងខ្លាំងនៅក្នុងប្រទេសវៀតណាម ។ មនុស្សដែលមានតម្រិះវិជ្ជា ក៏មានបំណងដកខ្លួនចេញពីការបំពុល និងការធ្វើឲ្យរំខាននៃភាពវឹកវររបស់លោកនេះ ។ គាត់ចង់ដកខ្លួនចេញពីការប្រកួតប្រជែងសង្គម ដើម្បីលុះវិមុត្តិ ស្វែងរកភាពស្ងប់ស្ងាត់ និងការអភិវឌ្ឍខ្លួនឯង ។ ប៉ុន្តែ គេគ្មានសិទ្ធិធ្វើអ្វីចឹងបានជានិច្ចកាលនោះទេ ។ បំណុលត្រូវតែមានការទូទាត់សង កាតព្វកិច្ចត្រូវមានការបំពេញនៅពេលករណីយកិច្ចតម្រូវ ។ មនុស្សថ្លៃថ្នូរម្នាក់ ត្រូវតែឆ្លើយតបទៅតាមបទបញ្ជារបស់ «អឿ» ។*

*ម្យ៉ាងទៀត ជួនកាល នៅពេលដែលពិភពលោកផ្ដាច់ការទំនាក់ទំនងគ្នា នៅពេលដែលគេមិនអាចសម្រេចបានភាពត្រឹមត្រូវនិងភាពសមរម្យ នៅក្រោមលក្ខខ័ណ្ឌនាពេលបច្ចុប្បន្ននោះ បុរសឬស្ត្រីថ្លៃថ្នូរត្រូវដកខ្លួនចេញពីលោកនេះ ជាមធ្យោបាយនៃការបញ្ជាក់អំពីគុណតម្លៃដ៏ខ្ពង់ខ្ពស់ ជាជាងចូលរួមក្នុងបរិបទដែលនាំឲ្យគុណតម្លៃ*

*ទាំងនេះត្រូវខូចវិញ ។ មនុស្សជំពូកនេះ គឺអ្នកដែលដកខ្លួនចេញ ដើម្បីរង់ចាំឱកាសមកដល់ ។ ដោយមានទស្សនៈទៅលើពេលវេលាថា ជាកង់វិលជុំ នោះ ពួកគេរង់ចាំការវិលត្រឡប់មួយនៃឋានានុក្រមត្រឹមត្រូវមួយរបស់សង្គម ដែលពួកគេចូលអាចរួមជាមួយដោយសេចក្ដីថ្លៃថ្នូរនិងកិត្តិយស ។*

## អំណាចនៃក្រឹត្យក្រមធម្មជាតិ

*ការវិលត្រឡប់មកវិញនូវលក្ខខណ្ឌ «សមរម្យ» បានធានាដោយដំណើរនៃយុត្តិធម៌ត្រឹមត្រូវ តាមសីលធម៌ដែលមាននៅលើពិភពលោកយើងនេះ ។ ជាការជាក់ស្ដែង ប្រជាជនវៀតណាមទាំងអស់ជឿថា ពេលវេលាគឺវិលជុំ ហើយការធ្វើឲ្យខុសពីក្រឹត្យក្រមធម្មជាតិ អាចនាំឲ្យមានអាយុខ្លី ។ ក្រឹត្យក្រមធម្មជាតិនិងសណ្ដាប់ធ្នាប់សមរម្យ នឹងបង្ហាញខ្លួនវិញមិនខាន ។ ការប្រៀនប្រដៅក្នុងវង្វង់គ្រួសារ ការអប់រំដំបូង រឿងព្រេង សុភាសិត និងអក្សរសិល្ប៍របស់អ្នកស្រុក បានបង្ហាត់បង្រៀនក្មេងៗ នូវការជឿតៗគ្នា អំពីសុពលភាពនៃគោលការណ៍ក្រឹត្យក្រមនេះ ។ ក្មេងៗ បានទទួលទស្សនៈបែបលោកធាតុមួយ ដែលបង្ហាញអំពីទំនាក់ទំនងរវាងការប្រព្រឹត្តនិងលទ្ធផលជាមួយអាកប្បកិរិយានិងសំណាង ។ ប្រជាជននិងសង្គមដែលប្រព្រឹត្តសមស្រមទៅតាមក្រឹត្យក្រមធម្មជាតិ នឹងទទួលរង្វាន់ ហើយចំពោះជនដែលរំលោភបំពានក្រឹត្យក្រមធម្មជាតិនោះ នឹងជួបនូវគ្រោះមហន្តរាយ ។ ជាការពិត ការដែលពួកគេជួបគ្រោះមហន្តរាយនេះ គឺមិនមែនមានចំពោះតែខ្លួនគេប៉ុណ្ណោះទេ គឺមានដល់ក្រុមគ្រួសារ ហើយការដែលធ្វើឲ្យមានបញ្ហាអាក្រក់ដល់ក្រុមគ្រួសារ គឺមានន័យថា ជាបាបកម្មអាក្រក់បំផុត ។*

## គ្រួសារ ៖ ក្រឹត្យក្រមធម្មជាតិនៅក្នុងអតិសុខុមលោក

*គ្រួសារវៀតណាមគឺជាពិភពលោកតូចមួយ ។ អ្វីដែលពួកអ្នកបស្ចិមប្រទេសហៅថា «គ្រួសារវង្វង់តូច» (គ្រួសារដែលមានតែឪពុកម្ដាយនិងកូន) ត្រូវបានបញ្ចូលទៅក្នុង «គ្រួសារវង្វង់ធំ» (ញាតិសន្តាន, បងប្អូន) និងគ្រួសារដែលយកតាមខាងខ្សែឪពុក ។ ការចេះស្រឡាញ់ញាតិសន្តាន មានរួមបញ្ចូលទាំងអ្នកដែលបានទទួលមរណភាព និងអ្នកដែលពុំទាន់កើតនៅឡើយ ដោយដាក់ផ្តុំនៅក្នុងចំណងសាមគ្គី ខាងភាពសុខដុម ខាងស្មារតីនិងសម្ភារៈ*[៣១] *។*

*ជាដំបូងនិងសំខាន់ជាងគេ គេបង្រៀនក្មេងៗ អំពី «ហៀវ» ដែលជាគុណធម៌សំខាន់របស់សង្គម ។ សេចក្ដីខ្វល់ខ្វាយអំពីការចង់តបស្នងនៃ «អឺន» (ការតបស្នងគុណ) ទៅដល់ឪពុកម្ដាយនិងបុព្វបុរស គឺជាកម្លាំងដ៏មានមហិទ្ធិឫទ្ធិខាងគុណធម៌ និងសមិទ្ធផល ។ តាមរយៈការប្រឹងប្រែងនិងពលិកម្ម និងតាមរយៈគុណធម៌របស់ពួកគេ បុព្វបុរសបានប្រមូលកុសល ដែលជាផ្នែកមួយនៃមត៌ករបស់គ្រួសារ ដោយមានការប្រមើលមើលពីសំណាក់ពពួកទេវតា ។*

*មនុស្សណាដែលនៅរស់រានមានជីវិត គឺត្រូវជាប់បំណុលបុព្វបុរសរបស់មនុស្សនោះ មិនចំពោះថា មនុស្សនោះបានបំពេញស្នាដៃធំធេងប៉ុនណាឡើយ និងមិនចំពោះថា មនុស្សនោះរងទុក្ខវេទនាធ្ងន់ប៉ុនណាឡើយ ។ មនុស្សនោះត្រូវតែអរគុណចំពោះបុព្វបុរស ចំពោះម្ហូបអាហារដែលមនុស្សនោះបរិភោគ ចំពោះគេហដ្ឋានដែលមនុស្សនោះរស់នៅ ប្ដីឬប្រពន្ធរបស់មនុស្សនោះ ដីធ្លីរបស់មនុស្សនោះ សមាជិកភាពនៅក្នុងភូមិរបស់មនុស្សនោះ ពិសេសជាងនេះទៅទៀតនោះ គឺចំពោះជីវិតមនុស្សនោះផ្ទាល់ ។ មនុស្សនោះទទួលបានផល ក៏ដោយសារ*

*តែការប្រមូលកុសលផលបុណ្យ ដែលសមាជិកក្រុមគ្រួសារបានខិតខំធ្វើអស់ពេលជាយូរណាស់មកហើយ និងពីកិត្តិសព្ទរបស់គ្រួសារ ។ ជោគជ័យកាន់តែបន្ថែមទម្រង់បំណុល តែមិនអាចសងរួចទាំងអស់ឡើយ ។ គ្រួសារនីមួយៗ ត្រូវខិតខំធ្វើការធ្ងន់ ដើម្បីរក្សាចំណងទាក់ទងជាមួយអ្នកជិតខាង ជាមួយព្រៀងលាន និងជាមួយអ្នកភូមិទាំងអស់ ។ បណ្តាញទាក់ទងនេះ ធ្វើឲ្យមនុស្សគ្រប់រូបទុកសម្រាប់ផលប្រយោជន៍របស់ក្រុមគ្រួសាររៀងៗខ្លួន ។ កាតព្វកិច្ចមានចំពោះអ្នកដែលមិនទាន់កើតនិងអ្នកដែលស្លាប់ទៅហើយផងដែរ ។ កាតព្វកិច្ចចម្បង គឺមានចំពោះគ្រួសារផ្ទាល់ ហើយនេះគឺជាកិច្ចការដែលគ្មានទីបញ្ចប់ឡើយ ។*

*គោលការណ៍វប្បធម៌ គឺផ្តោតទៅលើក្រុមគ្រួសារដែលមានសមាជិកច្រើន ដែលដើរតួតំណាងឲ្យអង្គភាពតែមួយ មានការធ្វើសមាហរណកម្មគ្នាយ៉ាងល្អ និងមានការរៀបចំរចនាសម្ព័ន្ធបែបពីលើចុះក្រោមផង ។ អំណាចទាំងអស់ រួមទាំងកម្មសិទ្ធិទ្រព្យសម្បត្តិផង គឺជារបស់ឪពុកម្តាយ ហើយកូនចៅត្រូវតែស្តាប់តាមអ្វីដែលពួកគាត់ចង់បាន ។ ការរំលោភបំពានទៅលើការគោរពករណីយកិច្ចជាកូន ដែលស្តែងឲ្យឃើញច្បាស់នោះ នឹងខុសច្បាប់ ហើយនឹងត្រូវទទួលទណ្ឌកម្មយ៉ាងដំណំពីអាជ្ញាធរ ប្រសិនបើមាននរណាម្នាក់រាយការណ៍ឲ្យដឹង ។ ធ្ងន់ជាងនេះទៅទៀតនោះ គឺថា នរណាម្នាក់ត្រូវបានគេរកឃើញថា មានកំហុសពាក់ព័ន្ធនឹងចរិយាមារយាទបែបនេះ នៅក្នុងក្រសែភ្នែករបស់សាធារណជន អ្នកនោះឯងនឹងទទួលរងនូវទម្រង់នៃភាពអាម៉ាស់អស់មួយជីវិត ។*

*ការគោរពបុព្វបុរស (ដូនតា) គឺដើម្បីពង្រឹងនិងផ្ទេរគំនិត ដើម្បីបង្កើតបានជាចំណងសាមគ្គីភាពរឹងមាំនៃគ្រួសារមួយ ។ ចរិតលក្ខណៈនៃសង្គមប្រពៃណីវៀតណាម មានឫសគល់មកពីបំណងគ្រួសារនេះឯង ។ ភាពជាសមាជិក និងទីតាំងណាមួយនៅក្នុងគ្រួសាររបស់នរណាម្នាក់ គឺជាធាតុផ្សំសំខាន់នៃអត្តសញ្ញាណបុគ្គលនិងសង្គម ។ ការប្រារព្ធពិធីនៅក្នុងគ្រានគ្រួវៀតណាមបុរាណ គឺមានភាពសម្បូរបែបនិងប្លែកៗគ្នា ប៉ុន្តែពិធីបែបនេះ បើគេធ្វើចំពោះបុព្វបុរសពិសេសណាមួយនោះ គឺចាំបាច់ត្រូវមានការចូលរួមពីមនុស្សច្រើនគ្នា ដើម្បីធ្វើឲ្យពិធីនោះមានភាពអធិកអធមនិងសំខាន់ ។ បុណ្យខួបរំលឹកបុព្វបុរស ដែលបានចែកឋានទៅហើយនោះ ត្រូវគេធ្វើឡើងជារៀងរាល់ឆ្នាំ ហើយក្នុងពិធីនេះ មានការរៀបចំដារបស់របរសម្រាប់សែនជាលក្ខណៈផ្លូវការទៀតផង ។ អ្នកចូលរួមក្នុងពិធីនេះ អាចមានចំនួនជាមធ្យមបុច្រើន គឺអាស្រ័យទៅលើភាពជិតដិត បុក៏ឋានៈរបស់បុព្វបុរសនោះ ហើយក៏អាស្រ័យទៅលើទ្រព្យធនរបស់ជនដែលជាប់ខ្សែខាងឪពុក ។ អ្នកស្រី ឡេ ធីក្វេ (Lê Thị Quê) និយាយថា ÷*

> លោកអ្នកត្រូវតែចូលរួមក្នុងពិធីជួបជុំគ្រួសារណាមួយ ដើម្បីបានយល់ដឹងអំពីអារម្មណ៍ដលជនជាតិវៀតណាមមានចំពោះគ្រួសារពួកគេ ។ នៅក្នុងបរិយាកាសដែលពោរពេញទៅដោយការចងចាំ ប្រពៃណីនិងទំនៀមទម្លាប់នេះ ឋានានុក្រមគ្រួសារ ត្រូវបានគេស៊ើបសួរមើលយ៉ាងយកចិត្តទុកដាក់ ។ សមាជិកម្នាក់មិនចំពោះថា ឋានៈសង្គមគាត់ជាអ្វីនោះទេ ក៏មានកន្លែងរបស់គាត់មួយ នៅចំពីមុខអាសនៈដូនតា (កន្លែងកុងម៉ា) និងនៅតុជប់លៀង ទៅតាមលំដាប់លំដោយនៃជំនាន់មនុស្ស និងតាមអាយុក្នុងចំណោមសមាជិកគ្រួសាររបស់គាត់នោះដែរ ។ នៅក្នុងបរិយាកាសបែបនេះ បុគ្គលម្នាក់បាត់បង់នូវភាពជាខ្លួនឯង និងមានអារម្មណ៍ធូរស្រាលនៅកន្លែងនោះឯង ។ នៅទីនោះហើយ ដែលគាត់ស្វែងរកនូវកម្លាំងជាក្រុម ។ អ្នកនោះឯងនឹងមិនផ្លាស់ប្តូរទីកន្លែងរបស់គាត់នៅក្នុងក្រុមនេះទេ ទោះបីជាទីកន្លែងដទៃទៀតល្អប្រសើរយ៉ាងណាក៏ដោយ(៣២) ។

*ខ្សែស្រឡាយខាងឪពុកដែលមានសមាជិកជាច្រើន និងមានភាពធូរធារ អាចមានការប្រមូលផ្តុំបែបនេះ*

យ៉ាងហោចណាស់ រាប់សិបដងក្នុងមួយឆ្នាំដែរ ចំណែកឯគ្រួសារដទៃទៀត ក៏មានការជួបជុំគ្នាបែបនេះច្រើនដងក្នុងមួយឆ្នាំដែរ ។ ប៉ុន្តែ ចំនួនមនុស្សដែលមកចូលរួម ភាពរៀបចំល្អិតល្អន់នៃពិធី ចំនួនម្ហូបចំណីនិងភេសជ្ជៈដែលយកមកសែននេះ គឺមានភាពខុសៗគ្នាខ្លាំង ។ ដោយឥតខ្វះ គ្រួសារនីមួយៗគប្បីតែមានដីមួយចំណែកដើម្បីប្រារព្ធធ្វើពិធីនេះ ។ ដីនោះគេឲ្យឈ្មោះថា «ដីធូបនិងភ្លើង» ហើយដីដ៏សក្តិសិទ្ធិនេះ ទទួលការការពារដោយច្បាប់និងទំនៀមទម្លាប់ ។ ពិធីបែបនេះ គឺជាផ្នែកមួយនៃទំនាក់ទំនងដ៏រឹងមាំរបស់សង្គមដែលមានចំណងអន្តរអារម្មណ៍និងកិរិយាមារយាទ នៅក្នុងផ្នត់គំនិតអ្នកចូលរួមទាំងអស់ ។ ការដែលគ្រួសារមកជួបជុំគ្នាធ្វើពិធីរំលឹកខួបអ្នកដែលចែកឋានទៅហើយ គឺដើម្បីឲ្យក្រុមគ្រួសារបានដឹងពីបុសគល់នៃសាច់សាលោហិតរបស់ខ្លួននិងរឹតចំណងសាមគ្គីភាពគ្នាក្នុងគ្រួសារ និងបង្កើតចេតនាស្រឡាញ់ចំពោះគ្រួសារ ។ នៅក្នុងគ្រួសារនីមួយៗអ្នកដែលនៅរស់ អ្នកដែលបានទទួលមរណភាព ហើយនិងអ្នកដែលមិនទាន់កើតផងនោះ បានចងភ្ជាប់គ្នាក្នុងចំណងដែលឋិតនៅក្នុងក្រឌីបេះដូងមួយនៃការពឹងពាក់គ្នាទៅវិញទៅមក ។

បុព្វបុរសនៅតែជាអ្នកចូលរួមយ៉ាងសកម្ម នៅក្នុងជីវភាពរបស់គ្រួសារ ពោលគឺចូលរួមចែករំលែកសេចក្តីសុខនិងទុក្ខ ក្រើនរំលឹកកុំឲ្យធ្វើអាក្រក់ និងទូន្មានកុំឲ្យលោភលន់ទ្រព្យសម្បត្តិ ។ ដូនតាទាំងនោះធ្វើការនៅឯឋានក្រោម ដើម្បីជួយគ្រួសារឲ្យមានសុខុមាលភាព ។ ដូនតានៅចាំឃ្លាំមើលនិងចាំជួយកូនចៅ ។ នៅពេលប្រឈមមុខនឹងការសម្រេចចិត្តសំខាន់ណាមួយនោះ មានជនជាតិវៀតណាមមួយចំនួន ជ្រើសរើសការនិយាយជាមួយសមាជិកគ្រួសារដែលស្លាប់ទៅហើយ ដើម្បីជួយការយោបល់ ។ បុព្វបុរសអាចជួយនិងផ្តល់ដំបូន្មាន ហើយមានពេលខ្លះ ដាក់ទណ្ឌកម្មដល់កូនចៅខ្លួនទៀតផង ប៉ុន្តែទាំងអស់នេះគឺសុទ្ធតែដើម្បីគ្រួសារប៉ុណ្ណោះ ។

បើទុកបីជាគ្រួសារនីមួយៗសុទ្ធតែបានប្រឹងប្រែងជួយខ្លួនឯង ដោយមិនចាំបាច់ពឹងពាក់អ្នកដទៃក៏ដោយ ក៏ពួកគេនៅតែគិតពីការប្រកួតប្រជែងក្នុងសង្គម ជាជាងស្វែងរកភាពឯកោ ។ ការប្រកួតប្រជែងរវាងគ្រួសារ កើតមានឡើងនៅក្នុង «ប្រព័ន្ធវណ្ណៈ» មួយ ដែលបើកចំហ ធ្វើឲ្យគ្រួសារមានកិត្យានុភាពតាមឋានានុក្រម ដែលមានតែសាធារណមតិប៉ុណ្ណោះជាអ្នកកាត់សេចក្តី ។ អ្នកភូមិធ្វើការវិនិច្ឆ័យដោយផ្អែកលើសមភាពនៃឋានៈនិងជំហរគ្រួសារទៅតាមអាកប្បកិរិយារបស់សមាជិកគ្រួសារ ។ ទ្រព្យសម្បត្តិ កម្រិតវប្បធម៌ ឋានៈ និងកិត្យានុភាព ក៏ជាកម្មបទនៃការឲ្យតម្លៃលើគ្រួសារដែរ ប៉ុន្តែវាមិនមែនជាកត្តាកំណត់ដែលគេនិយមនោះទេ ។

មនុស្សកត់សម្គាល់អំពីកំហុសនិងគុណវិបត្តិ ហើយពួកគេបានជជែកអំពីរឿងហ្នឹង ។ មនុស្សមានការភ័យខ្លាចចំពោះការសើចចំអកនិងការនិយាយដើម ។ ដូច្នេះ មនុស្សត្រូវបង្ខំចិត្តស្វែងរកឋានៈខ្ពង់ខ្ពស់ តែពួកគេក៏ត្រូវចំណាយច្រើនដែរ ។ ជាពិសេស ទំនាក់ទំនងគ្នាទៅវិញទៅមកពេលមានពិធីបុណ្យ រវាងគ្រួសារនិងសហគមន៍ភូមិ គឺជាឱកាសដែលសប្បុរសជនត្រូវតែបង្អួតបង្អរ ដើម្បីបញ្ជាក់ពីភាពមានឋានៈរបស់ពួកខ្លួន និងធនធានរបស់គ្រួសារ ។

នៅពេលគេកត់ឈ្មោះរបស់ក្មេងប្រុសម្នាក់ក្នុងបញ្ជីរបស់ភូមិ គេត្រូវតែធ្វើពិធីបុណ្យ និងជូនជំនូន ។ ពិធីបុណ្យសពចំណាយអស់ប្រាក់កាសច្រើនជាងនេះទៅទៀត ។ គ្រួសារដែលធូរធារ ចំណាយប្រាក់កាសយ៉ាងច្រើនសន្ធឹកសន្ធាប់ សម្រាប់រៀបចំពិធីកាន់ទុក្ខនិងបុណ្យសព ។ អាពាហ៍ពិពាហ៍មានភាពសាំញ៉ាំច្រើន និងចាយលុយក៏ច្រើនដែរ ។ ពេលគេពិនិត្យឲ្យបានជិតដល់ទៅលើការរៀបអាពាហ៍ពិពាហ៍ គេរកឃើញយ៉ាង

ច្រើនអំពីវប្បធម៌ប្រពៃណីនិងរបៀបប្រព្រឹត្តទៅរបស់សង្គមវៀតណាម ជាពិសេសចំពោះវដននិងអ្នកដែលមានមហិច្ឆតាសង្គម ។

## អាពាហ៍ពិពាហ៍

យើងអាចទុកការរៀបការថា មុនដំបូង ជាការចរចានិងការសម្រុះសម្រួលគ្នារវាងគ្រួសារពីរ ។ ដូច្នេះ ការជ្រើសរើសគូស្រករ គឺមិនមែនធ្វើឡើងដោយបុគ្គលម្នាក់ទេ គឺឪពុកម្ដាយជាអ្នករើសឲ្យ ដោយជារឿយៗ មានចាស់ទុំនៅក្នុងគ្រួសារជួយផងដែរ[៣៣] ។ កូនក្រមុំ ច្រើនតែទៅរស់នៅជាមួយ ឬយ៉ាងហោចណាស់ ក៏រស់នៅក្បែរឪពុកម្ដាយខាងប្ដីរបស់នាង ហើយនាងត្រូវគោរពប្រណិប័តន៍ឪពុកម្ដាយក្មេករបស់ខ្លួន ឲ្យលើសពីឪពុកម្ដាយបង្កើតខ្លួនទៅទៀត ។ ដោយសារនាងទៅរស់នៅក្នុងគ្រួសារខាងប្ដី ក្នុងនាមជាអ្នកក្រៅម្នាក់ ដូច្នេះ នាងត្រូវផ្គាប់ចិត្ត មិនមែនត្រឹមតែប្ដីរបស់នាងតែម្នាក់នោះទេ គឺគ្រួសារទាំងមូល ហើយជាពិសេសនោះ គឺម្ដាយក្មេករបស់នាង ។

ចំពោះគ្រួសារទាំងសងខាង ប្រការសំខាន់ដែលត្រូវជៀសវាង គឺការធ្វើឲ្យគ្រួសារបាក់មុខ ដោយវង្វេងនូវភាពអាម៉ាស់ណាមួយ ដូចជាតាមរយៈការប្រកែកមិនព្រមទទួលយកអាពាហ៍ពិពាហ៍នៅកណ្ដាលហ្វូងមនុស្សម្នាជាច្រើន ដូច្នេះហើយបានជារឿយៗ គេត្រូវប្រើអ្នកចែចូវឲ្យជួយក្នុងរឿងនេះ ។ គេមានការគិតគូរល្អិតល្អន់ណាស់ មុននឹងសម្រេចរើសអនាគតគូស្រករណាម្នាក់ គឺគេត្រូវមើលអំពីធនធាន ចរិត សុជីវធម៌ កេរ្ដិ៍ឈ្មោះ ឥទ្ធិពលអំណាច និងការរំពឹងទុកផ្នែកហិរញ្ញវត្ថុទៅថ្ងៃខាងមុខរបស់គូស្រករូបនេះ និងគ្រួសាររបស់គាត់ ។

ប្រពៃណីរបស់អ្នកស្រុក ច្រើនតែធ្វើការជ្រើសរើសនេះទៅដោយងាយៗ (ដោយកាត់ចោលប្រពៃណីស្មុគស្មាញតាមបែបចិនចោលខ្លះ) តែសង្កត់ធ្ងន់លើពិធីភ្ជាប់ពាក្យ ។ របៀបជ្រើសរើសគូស្រករទាំងនេះ គេយកមកអនុវត្តជាសាធារណៈទៅហើយ និងបានក្លាយជាទំនៀមទម្លាប់របស់ជនជាតិវៀតណាមកាន់តែច្បាស់ និងកាន់តែចំណាយប្រាក់កាសច្រើន ។ គេរៀបចំពិធីភ្ជាប់ពាក្យឡើង ជាលក្ខណៈបង្ហាញឲ្យដឹងជាផ្លូវការ ឲ្យគេទទួលស្គាល់ ហើយមានការលើកជំនូនពីគ្រួសារកូនកម្លោះទៅជូនខាងគ្រួសារកូនក្រមុំ ។

ពិធីអាពាហ៍ពិពាហ៍ គេឲ្យឈ្មោះថា «រឿកយ៉ូវ» (rước dâu) ។ «រឿក» មានន័យថា «ទទួល» «ស្វាគមន៍» «ដង្ហែ» ។ «យ៉ូវ» មានន័យពីរ គឺ «កូនក្រមុំ (ក្នុងពិធីមង្គលការ)» និង «កូនប្រសាស្រី» ។ ជនជាតិវៀតណាមនិយាយថា «យកប្រពន្ធ» ឬ «តាំងគ្រួសារ» ប៉ុន្តែមិនដែលផ្សារភ្ជាប់ជាមួយនឹងពិធីអាពាហ៍ពិពាហ៍ឡើយ ។ ហើយគេមិនដែលពុំគេនិយាយថា ពិធីរៀបអាពាហ៍ពិពាហ៍សំដៅលើ «ការស្វាគមន៍ភរិយាម្នាក់» នោះដែរ ។ ជាទូទៅ គេតែងតែនិយាយថា «ស្វាគមន៍កូនប្រសាស្រី» ។ តួនាទីរបស់កូនក្រមុំក្នុងនាមជាកូនប្រសាដែលកំណត់ដោយសង្គមនិងវប្បធម៌ គឺធំជាងតួនាទីថ្មីរបស់នាងជាភរិយា ។ ប្រការដែលសំខាន់ជាងគេចំពោះតួនាទីរបស់នាង គឺនៅពេលដែលនាងត្រូវទៅរស់នៅជាសមាជិកថ្មីម្នាក់ជាមួយគ្រួសារថ្មីមួយ ។ ការដែលនាងអាចធ្វើសមាហរណកម្មចូលទៅក្នុងគ្រួសារថ្មីរបស់នាងនោះឯងហើយជារឿងសំខាន់ខ្លាំង ។

ពិធីអាពាហ៍ពិពាហ៍មានការពាក់ព័ន្ធនឹងនិមិត្តរូបនិងតថភាពនៃការបញ្ជូនកូនក្រមុំ ពីគេហដ្ឋានរបស់នាងទៅកាន់គេហដ្ឋានរបស់កូនកម្លោះ ។ កូនកម្លោះ ដោយមានមិត្តភក្តិនិងសាច់ញាតិគ្រួសារហែហមកំដរផង ដើរជា

ក្បួនទៅកាន់ផ្ទះកូនក្រមុំ ដើម្បីសុំយករូបនាងនិងជង្ហែនាងទៅកាន់ផ្ទះរបស់ខ្លួន ។ ការណ៍នេះ មានពេលខ្លះអាចធ្វើរហូតដល់ឆ្លងកាត់ពីភូមិមួយទៅភូមិមួយទៀតផង ។ ខាងនារីៗ ចូលចិត្តរៀបការនៅជាមួយញាតិភូមិផងរបងជាមួយ ប៉ុន្តែគូអនាគតដែលសក្តិសមនឹងនាង មិនប្រាកដថា ជានិច្ចកាល អាចរកឃើញនៅក្នុងភូមិនោះឡើយ ។ មានការពាយខ្សែចងស្ទាក់ផ្លូវក្បួនជង្ហែនេះ ដើម្បីសុំឲ្យអ្នកដែលមកទទួលយកកូនក្រមុំ បង់ប្រាក់ជាមុនសិន ទើបអនុញ្ញាតឲ្យទៅ ។ អ្នកដែលចងខ្សែស្ទាក់យកលុយនេះ គឺអ្នកនៅតាមភូមិ ក្រុមមនុស្សតាមភូមិតូចៗ និងក៏មានក្រុមសាច់ញាតិចូលរួមផងដែរ ។ នៅពេលដែលគ្រួសារខាងកូនកម្លោះទៅផ្ទះខាងកូនក្រមុំ ពេលនោះ អាចមានការស្ទាក់បញ្ឈប់ក្បួនជង្ហែនេះម្តងទៀត ដែលធ្វើឡើងដោយខាងបងប្អូនបង្កើតខាងកូនក្រមុំ ដើម្បីសុំលុយ «បើកមាត់ទ្វាររបង» ។ ការ «ស្ទាក់ផ្លូវ» ទាំងនេះ បញ្ជាក់អំពីន័យជ្រាលជ្រៅនៃអត្តសញ្ញាណរួម ដែលសម្គាល់ក្រុមទាំងនេះ ។ នៅឯគេហដ្ឋានកូនក្រមុំ កូនកម្លោះក្រាបថ្វាយបង្គំនៅចំពោះមុខអាសនៈដូនតា (កន្ទេងកុងម៉ា) របស់គ្រួសារកូនក្រមុំ មុនចាកចេញពីផ្ទះនេះទៅ ដោយពិធីនេះដូចគ្នាទៅនឹងអ្វីដែលគាត់បានធ្វើចំពោះដូនតារបស់គាត់អ៊ីចឹងដែរ ។ ចុងបញ្ចប់ មានពិធីពិសាភេសជ្ជៈ ហើយបន្តិចក្រោយមក ក្បួននេះក៏ចេញដំណើរទៅ ។

ការដែលមានបងប្អូន មិត្តភក្តិ និងអ្នកដែលមកជួយផ្សេងៗទៀត នៅព័ទ្ធជុំវិញនាង គឺជានិមិត្តរូបនៃការការពារកូនក្រមុំពីខ្មោចបិសាចនៅតាមផ្លូវ ជាពិសេស នៅពេលដែលពិធីជង្ហែនេះ ធ្វើដំណើរឆ្លងពីភូមិមួយទៅភូមិមួយ ។ គ្រួសារនិងភូមិ គឺជាក្រុមដែលបង្កើតជាលក្ខណៈវប្បធម៌ ដែលជាផ្នែកដ៏សំខាន់នៃសង្គម ។ កូនក្រមុំលែងជាកូនស្រីទៀតហើយ និងនាងក៏មិនទាន់ជាកូនប្រសាឬភរិយានៅឡើយដែរ ។ នៅពេលដែលឆ្លងកាត់ពីគ្រួសារមួយទៅគ្រួសារមួយទៀត ឬពីភូមិមួយទៅភូមិមួយទៀត កូនក្រមុំស្ថិតនៅក្រៅវប្បធម៌ គឺនាងស្ថិតនៅក្នុងពិភពធម្មជាតិមួយ ដែលពោរពេញដោយគ្រោះថ្នាក់ ពោលគឺនាងក្លាយជាមនុស្សម្នាក់ដែលឯកោ គ្មានអំណាចនិងងាយរងគ្រោះ ។

នៅឯគេហដ្ឋានរបស់កូនកម្លោះ នាងត្រូវធ្វើពិធីគោរពដូនតា ដូចអ្វីដែលកូនកម្លោះបានធ្វើនៅផ្ទះរបស់នាង ។ នៅខណៈនោះឯងហើយ ដែលកូនក្រមុំនិងកូនកម្លោះរៀបចំធ្វើពិធីដ៏ខ្លីមួយ ដែលធ្វើឲ្យពួកគេក្លាយជាស្វាមីនិងភរិយា ។ បន្ទាប់មកទៀត មានពិធីពិធីជប់លៀងដ៏ធំមួយទៅតាមមធ្យោបាយរបស់គ្រួសារ ។ បន្ទាប់ពីភ្ញៀវចាកចេញទៅ ប្តីប្រពន្ធថ្មោងថ្មីនឹងចូលទៅក្នុងបន្ទប់ ដែលជាគ្រាដំបូងដែលអ្នកទាំងពីរចាប់ផ្តើមស្គាល់គ្នា ។ កូនក្រមុំថ្មីថ្មោងអាចមានការលំបាកក្នុងការចូលរួមចែករំលែកឲ្យបានពេញលេញ នូវជីវភាពមនោសញ្ចេតនាដ៏សម្បូរបែប ដែលចងភ្ជាប់ប្តី ឪពុកម្តាយក្មេក បងប្អូនថ្លៃ និងជីដូនជីតាខាងប្តី ម្តាយមីងនិងឪពុកមាខាងប្តី ទៅជាសម្ពន្ធភាពជិតស្និទ្ធនៅក្នុងគេហដ្ឋាន ។ នៅក្នុងផ្ទះនោះ អាចមានសមាជិកគ្រួសាររស់នៅជុំគ្នាច្រើន ដែលធ្វើឲ្យនាងនិងប្តីនាងមានភាពជាឯកជនតិចតួច ដើម្បីបង្កើតភាពស្និទ្ធស្នាលជាលក្ខណៈប្តីប្រពន្ធបាន ។

មានតែពេលវេលាប៉ុណ្ណោះ ដែលបន្តិចម្តងៗ អាចធ្វើឲ្យនាងបញ្ចូលខ្លួនខាងផ្លូវសញ្ចេតនា ចូលទៅក្នុងគ្រួសារថ្មីនេះបាន ។ ទាល់តែអស់ចំណេរកាលច្រើនឆ្នាំកន្លងផុតទៅ គឺទាល់តែនាងសម្រាលបុត្រធីតា និងចិញ្ចឹមបីបាច់ពួកវា ជួយមើលថែទាំអ្នកដែលឈឺថ្កាត់ អាចរកប្រាក់បាន ដែលនាងអាចជួយរួមចំណែករកទ្រព្យរួម និងបានបង្ហាញឲ្យឃើញពីពលិកម្មព្រមទាំងភក្តីភាពចំពោះគ្រួសារថ្មីនេះសិន ទើបនាងអាចចាប់ផ្តើមទទួលបានមកវិញនូវទំហំនៃការគាំទ្រខាងផ្នែកស្មារតី ។ ដូចគ្នាទៅនឹងករណីយកិច្ចរបស់កូនចំពោះឪពុកម្តាយ និងប្អូនៗចំពោះ

*បង ៗ ដែរ ប្រពន្ធគឺជាកូនប្រុសាដែលត្រូវចេះជួយយកអាសានិងចេះស្តាប់បង្គាប់ ។*

*រឿងព្រេងប្រជាប្រិយរបស់អ្នកស្រុកវៀតណាម ច្រើនបង្ហាញឲ្យឃើញអំពីគំរូនៃការធ្វើពលិកម្មដ៏ធំធេងរបស់ភរិយាចំពោះស្វាមី ។ ប៉ុន្តែ ប្រសិនបើភរិយាផិតក្បត់ ឬមិនស្តាប់បង្គាប់ស្វាមីនៅក្នុងរឿងព្រេងនោះ នាងតែងតែត្រូវទទួលការដាក់ទោសនិងមានគ្រោះមហន្តរាយកើតឡើង ។ ហើយមានរឿងនិទានជាច្រើន លើកឡើងអំពីស្ត្រីដែលចចេសរឹងរូស ច្រើនតែនាំមកនូវបញ្ហាមិនចេះចប់ ។ ប៉ុន្តែ សាច់រឿងមិនសូវបង្ហាញឲ្យឃើញស្ត្រីគ្មានសមត្ថភាព ស្ត្រីធាប់ជឿសម្តីគេ ឬងាយស្រួលឲ្យគេត្រួតត្រា ។ នៅក្នុងរឿងនិទានខ្លះ គឺមានស្ត្រីមានប្រាជ្ញាឈ្លាសវៃ និងពូកែអត់ធ្មត់ ចេះជួយប្តីដែលប្រព្រឹត្តគ្គាំគ្គង ។*

*ដោយមានករណីយកិច្ចកំណត់ដោយក្រមនៃការប្រព្រឹត្តនិងគុណតម្លៃដែលគេបានរៀនកាលនៅពីតូច បង្ហាញអំពីការលើកមុខលើកមាត់ ភាពមេត្តាករុណាជាសាធារណៈ និងឋានៈការងារខ្ពស់ត្រដែត ដូចដែលមាននៅក្នុងរឿងនិទាន និងនៅក្នុងជីវភាពប្រចាំថ្ងៃរបស់អ្នកស្រុកវៀតណាម ថា បុរសវៀតណាម ហាក់ដូចជាខ្វះជំនាញខាងកិច្ចការសេដ្ឋកិច្ច បើប្រៀបធៀបទៅនឹងស្ត្រីវៀតណាម ។ គ្រួសារនីមួយៗ គឺដូចជាប្រទេសជាតិតូចមួយអ៊ីចឹង ។ ប្តី គឺដូចជាប្រមុខរដ្ឋ និងទទួលខុសត្រូវខាងកិច្ចការទាក់ទងបរទេស ចំណែកឯប្រពន្ធវិញ គឺជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងគ្រប់គ្រងលុយកាក់ ។ មានការបែងចែកការងារជាលក្ខណៈផ្លូវការ ហើយតួនាទីផ្សេងៗ សុទ្ធមានគុណតម្លៃដោយឡែករបស់វា ។*

*ស្ត្រីមួយរូបដែល «ល្អ» គឺជាស្ត្រីដែលចេះធ្វើពលិកម្មខ្លួនឯង ចេះសន្សំសំចៃ ឧស្សាហ៍ នៅបរិសុទ្ធ ហើយដែលចេះធ្វើពលិកម្មខ្ពស់ចំពោះស្វាមីនាង ។ នាងគឺជាស្ត្រី «មិនល្អ» ប្រសិនបើនាងហ៊ានសម្លឹងមើលប្រុសតែម្នាក់ផ្សេងទៀត ។ ជនជាតិវៀតណាមមានភាពលេចធ្លោខ្លាំងលើសគេ ខាងមានស្តង់ដារមិនស្មើភាពគ្នាក្នុងការវិនិច្ឆ័យទៅលើការប្រព្រឹត្តខាងមេថុនកម្មរបស់បុរសនិងស្ត្រី ។ ជំនឿ គុណតម្លៃ ឥរិយាបថ និងបទដ្ឋានដែលពាក់ព័ន្ធនឹងការប្រព្រឹត្តមេថុនទាំងអស់នេះ មានការទាក់ទងគ្នាយ៉ាងជិតដិតទៅនឹងគោលគំនិតដ៏លើសលប់នៃគ្រួសារ ហើយត្រូវពង្រឹងបន្ថែមដោយគុណតម្លៃនៃ «ហៀវ» ។*

*កាតព្វកិច្ចជាចម្បងរបស់ «ហៀវ» គឺផ្តល់កូនចៅប្រុស ជាអ្នកថែរក្សាបន្តការគោរពបូជាដូនតា ។ ការសង្ស័យលើការជាឪពុករបស់កូនក្នុងគ្រានគ្រួ គឺជាការនាំឲ្យមានកង្វល់ឥតឧបមា ហើយភាពជាម្តាយមិនដែលត្រូវបានគេលើកមកនិយាយនោះទេ ។ វិសមភាពភេទកើតឡើងដោយជៀសមិនរួច ពីភាពខុសគ្នានៃរចនាសម្ព័ន្ធរវាងបុរសនិងគ្រួសាររបស់គាត់ ហើយរវាងស្ត្រីនិងគ្រួសារទាំងសងខាងរបស់នាង ដែលមួយ គឺគ្រួសារពីកំណើត និងមួយទៀត ជាគ្រួសារក្រោយពេលរៀបការ ។ តម្រូវការចាំបាច់របស់គ្រួសារ តម្រូវឲ្យទាំងបុរស ទាំងស្ត្រីធ្វើការបម្រើ ប៉ុន្តែតម្រូវការនេះមានភាពខុសគ្នាខ្លាំងរវាងភេទពីរនេះ ។ មានមនុស្សតិចតួចណាស់ បានសួរនាំអំពីមូលដ្ឋាននៃជីវភាពសង្គម ដែលបានដាក់សុខុមាលភាពរបស់គ្រួសារ ធំជាងបំណងប្រាថ្នានិងការចង់បានរបស់បុគ្គលម្នាក់ៗ ។*

## បុណ្យតិត ៖ ពិធីបុណ្យប្រចាំឆ្នាំរបស់គ្រួសារ

*ការចូលមកដល់នៃបុណ្យចូលឆ្នាំ (បុណ្យតិត têt) បង្កើតជានិមិត្តរូបដ៏ច្រើនលើសលប់នៃការធ្វើសមាហរណកម្ម ។*

អ្នកស្រុកនាំគ្នារៀបចំយ៉ាងយូរទុកជាមុនសម្រាប់បុណ្យចូលឆ្នាំដោយបរិយាកាសរំពឹងទុកយ៉ាងរីករាយ ។ នៅពេលថ្ងៃបុណ្យ មានបុព្វបុរសនឹងមកលេង ហើយគ្រួសារទាំងមូលនឹងមកជួបជុំគ្នា ។ ដើម្បីស្វាគមន៍ឆ្នាំថ្មី គ្រួសារមួយជាច់ខាតត្រូវរៀបចំទទួលនៅពីមុខអាសនៈដូនតា ។ នេះគឺការប្រារព្ធពិធីមួយយ៉ាងសំខាន់របស់គ្រួសារដែលនៅរស់ ។ ពលរដ្ឋអាមេរិកាំងមានការលំបាកនឹងយល់អំពីថា តើបុណ្យតិត មានសារៈសំខាន់យ៉ាងណានោះណាស់ ។ បុណ្យតិត ប្រៀបដូចបុណ្យណូអែល បុណ្យប៉ាក ពេលយប់ឈានចូលថ្ងៃបុណ្យចូលឆ្នាំ បុណ្យថ្ងៃងអំណរគុណព្រះ និងថ្ងៃទី ៤ កក្កដា (ថ្ងៃខួបការបានឯករាជ្យ) របស់ជនជាតិអាមេរិកាំង ទាំងអស់នេះគឺមានរួមក្នុងពិធីបុណ្យតែមួយគត់ ។ ការប្រារព្ធពិធីតិតជាមួយក្រុមគ្រួសារ គឺមានសារៈសំខាន់ខ្លាំងណាស់ ព្រោះការប្រារព្ធនេះ គឺជាផ្នែកមួយនៃភាពជាជនជាតិវៀតណាមត្រឡាំង និងជាមនុស្សពេញលក្ខណៈ ។ នៅពេលដែលថ្ងៃចូលឆ្នាំចូលមកដល់ សំឡេងលាន់កងរំពងនៃស្នូរផ្ទុះផាវ និងស្នូរជួង ព្រុស្វរ័ពេញភូមិ ។ ក្នុងប្រទេសទាំងមូល គេឮសូរតែសំឡេងស្រែកហ៊ោរកគ្នានិងទៅកាន់បុព្វបុរសនិងពពួកទេវតា យ៉ាងសប្បាយអឺងកង ដោយសម្លេងឆ្លើយឆ្លងគ្នា នឹងបង្រួបបង្រួមជនជាតិវៀតណាមឲ្យទៅជាប្រជាជនតែមួយ ជុំវិញស្នូលវប្បធម៌របស់ពួកគេ ។

## ភូមិឋានបែបបុរាណរបស់ជនជាតិវៀតណាម

ភូមិឋាននិងប្រទេសជាតិ អាចប្រៀបដូចជាគ្រួសារធំមួយ ហើយគ្រួសារគឺជាប្រទេសជាតិតូចឬភូមិឋានតូចមួយ ។ នៅតំបន់ភាគខាងជើងនិងវៀតណាមកណ្ដាល (ប៉ុន្ដែមិនមែននៅក្នុងតំបន់ខាងត្បូង ដែលមានប្រជាពលរដ្ឋទើបមកតាំងលំនៅ និងមានមនុស្សរស់នៅតិចជាងខាងជើង) ភូមិឋានមានសភាពបិទជិតនិងជាសហគមន៍រួម ដោយមានកម្រិតស្វ័យភាពខ្ពស់[៣៤] ។ ភូមិករទាំងអស់នៅដាច់ពីភូមិផ្សេងៗ ទៀត ខណ្ឌចែកដោយវាលស្រែ ។ ផ្ទះសម្បែងក្នុងភូមិច្រើនតែនៅផ្ដុំគ្នា ដោយមានរបងដើមឫស្សីក្រាស់នៅព័ទ្ធជុំវិញផ្ទះទាំងនោះ ជាលក្ខណៈរូបវន្ត និងជានិមិត្តរូបធ្វើឲ្យសហគមន៍នៅដាច់ចេញពីតំបន់ជនបទដែលនៅក្បែរនោះ និងស្ថិតនៅដាច់ចេញពីសហគមន៍ដទៃទៀតផង ។ នៅក្នុងតំបន់មានអ្នកស្រុករស់នៅ គេអាចចូលទៅបានតែតាមខ្លោងទ្វារដែលមានតុបតែងផ្កាភ្ញី ជាខ្លោងទ្វារដែលរឹងមាំសម្រាប់ការពារ និងខ្លោងទ្វារដែលជានិមិត្តរូប ហើយខ្លោងទ្វារនេះនឹងត្រូវបិទចាក់សោនៅពេលយប់ ។ ខ្លោងទ្វារនេះគឺជាមុខមាត់របស់ភូមិ ដែលបង្ហាញទៅដល់ពិភពលោក ដែលជាសញ្ញាខាងក្រៅមួយនៃអត្តសញ្ញាណ និងបដិរូបនៃការគោរពខ្លួនឯងជាសមូហភាព ។ នៅខាងក្នុង មាន «ឌិញ» (đình) ដែលជាបេះដូងរបស់ភូមិ ។ «ឌិញ» ធ្លាប់ជាមជ្ឈមណ្ឌលរៀបចំពិធី និងជាសាលាភូមិ ។

កន្លែងនេះហើយ គឺជាទីដ៏ប្រត្យក្សនៃការផ្សារបញ្ចូលគ្នានៃនយោបាយនិងសាសនារបស់ជីវភាពអ្នកភូមិ ។ ជីវភាពបែបសាសនានៅឯ «ឌិញ» កើតឡើងនៅជុំវិញសេចក្ដីគោរពនៃអ្នកតាថែរក្សាភូមិ (អ្នកតាចាស់ស្រុក) ដែលចាត់តាំងដោយព្រះរាជា ដើម្បីធ្វើជានិមិត្តរូបបង្ហាញថា សហគមន៍នេះពិតជាទទួលបាននូវឋានៈជាផ្លូវការថាជាភូមិមួយ គឺអង្គភាពរដ្ឋបាលពាក់កណ្ដាលស្វ័យភាព ។ អ្នកតាបានផ្ដល់ឲ្យនូវបង្គោលសម្រាប់អត្តសញ្ញាណភូមិ និងធ្វើតំណាងជានិមិត្តរូបនៃ «ប្រវត្តិសាស្ត្រ ប្រពៃណី គោលការណ៍សីលធម៌ ក្រមនីត្យានុកូល និងសេចក្ដីប្រាថ្នារបស់ភូមិទាំងមូល»[៣៥] ។ «ឌិញ» ក៏ជាកន្លែងសម្រាប់ពិធីបុណ្យជប់លៀង សម្រាប់ការធ្វើសក្ការបូជាជាសាធារណៈនិងឯកជន សម្រាប់ពិធីបុណ្យសាធារណៈទាំងអស់ទាំងខាងអាណាចក្រនិងផ្លូវសាសនា ។

រៀងរាល់ឆ្នាំ អ្នកភូមិរៀបចំពិធីជាច្រើន ដើម្បីថ្វាយនូវគ្រឿងសក្ការបូជាទៅដល់អ្នកតា ដោយពិធីនេះរៀបចំយ៉ាងឱឡារិកក្រៃលែង ។ ពិធីទាំងនេះ សហគមន៍ជាអ្នកធ្វើក្នុងនាមសហគមន៍ និងសម្រាប់សហគមន៍ ដោយបញ្ជាក់នូវគុណតម្លៃ សេចក្ដីត្រូវការ និងកង្វល់របស់ក្រុមរួមទាំងអស់ ។ នេះគឺជានិមិត្តរូបដ៏មានអត្ថន័យ ។ ដោយផ្ដោតខ្លាំងទៅលើអ្នកតាចាស់ស្រុក សកម្មភាពនៃពិធីរបស់អ្នកភូមិនៅឯ «ឌិញ» ធ្វើឡើងដើម្បីជានិមិត្តរូបតំណាងឲ្យភាពពឹងអាស្រ័យគ្នារបស់សមាជិកទាំងអស់របស់ភូមិ ហើយមិនមែនគ្រាន់តែដើម្បីគ្នានឹងគ្នានោះទេ គឺដើម្បីកម្លាំងខាងក្រៅផងដែរ ពោលគឺកម្លាំងធម្មជាតិ កម្លាំងអធិធម្មជាតិ និងសង្គម ដែលរៀបចំនិងត្រួតត្រាបានយ៉ាងពេញលេញដោយក្រុមសមូហភាព មិនមែនដោយសមាជិកបុគ្គលណាម្នាក់ឡើយ ។ ប្រពៃណីគោរពអ្នកតានេះ ឆ្លុះបញ្ចាំងភូមិទាំងមូល ស្ដីអំពីមុខងារដែលសម្ដែងឡើង ដោយទំនៀមទម្លាប់បុព្វបុរសសម្រាប់គ្រួសារវៀតណាម ។

មិនមែនអ្នកដែលរស់នៅក្នុងភូមិទាំងអស់ ដែលជាសមាជិករបស់ភូមិ ដែលតំណាងឲ្យសហករណ៍ស្របច្បាប់ត្រឹមត្រូវ ឬជាសមាជិករបស់ «សហធម្មចារី» ដែលរៀបចំពិធីឡើងអ្នកតានោះទេ ។ ទាំងឯកសិទ្ធិនិងកាតព្វកិច្ច មានការពាក់ព័ន្ធគ្នាទៅនឹងសមាជិកភាពរបស់ភូមិ ហើយសមាជិកភាពនេះ មិនមែនអ្នកគ្រប់គ្នាទទួលបានដោយឥតគិតថ្លៃនោះឡើយ ។ ភាពខុសគ្នាដ៏ធំមួយនៅក្នុងភូមិ គឺមានរវាងអ្នកដែលជាសមាជិក និងអ្នកដែលមិនមែនជាសមាជិក ។ ជាផ្លូវការ សមាជិកភាពមានចំពោះតែបុរស ៗ ប៉ុណ្ណោះ ហើយបុរស ៗ នោះត្រូវតែមានដើមកំណើតនិងធំដឹងក្ដីនៅក្នុងភូមិនោះទៀតផង ។

ក្នុងនាមជាសហករណ៍មួយ ភូមិគឺជាម្ចាស់កម្មសិទ្ធិដី ។ ទោះជាបំណែកនៃដីធ្លីដែលជាកម្មសិទ្ធិរបស់សមូហភាពអាចមានភាពខុស ៗ គ្នាយ៉ាងណាក៏ដោយ ក៏កម្មសិទ្ធិរួមគ្នាបែបនេះគឺជាលក្ខណៈសំខាន់មួយនៃភូមិករសមូហភាពរបស់ប្រជាជនវៀតណាមបុរាណ ។ ដីភូមិត្រូវគេចែកសាជាថ្មីរៀងរាល់បីឆ្នាំម្ដង ដោយផ្ដល់ដីឲ្យគ្រប់គ្រាន់ដល់អ្នកក្រីក្រខ្លាំងនិងសងដំពាក់ទាំងឡាយដែលបានបម្រើដល់ភូមិ ។ ដីធ្លីមួយចំនួនត្រូវបានជួលឲ្យអ្នកភូមិក្នុងតម្លៃគិតគូរមួយ ដើម្បីបង្កើនប្រាក់ចំណូល ។ ប្រព័ន្ធចែកដីនេះ ជួយធ្វើឲ្យមានសាមគ្គីភាពក្នុងភូមិ ។ គ្មាននរណាម្នាក់ដែលនៅក្រៅភូមិមានសិទ្ធិកាន់កាប់ដីធ្លីភូមិ ឬប្រកបការងារលើដីធ្លីរបស់ភូមិបានឡើយ ។ អ្នកស្រុកអាចមានការខ្វែងគំនិតគ្នាក្នុងចំណោមអ្នកស្រុកគ្នាឯងដែរ ប៉ុន្តែពួកគេមានការសាមគ្គីគ្នាស្អិតល្មួត ពេលមានរឿងជាមួយអ្នកខាងក្រៅ ។ ភូមិមានការទទួលខុសត្រូវរួមក្នុងការបង់ពន្ធអាករ ទៅឲ្យអាជ្ញាធរថ្នាក់លើ ផ្ដល់ជាកំណែនយោធានិងពលកម្មដល់រដ្ឋាភិបាល ។ ភូមិស្រុកណាដែលបានបំពេញគ្រប់ទៅតាមកាតព្វកិច្ចទាំងនោះ ភូមិស្រុកនោះនឹងមិនត្រូវគេរំខានទេ ។ អ្នកខាងក្រៅសូម្បីតែរដ្ឋាភិបាលកណ្ដាល ត្រូវដោះស្រាយបញ្ហាអ្វីមួយជាមួយភូមិ ពុំមែនជាមួយសមាជិកដែលជាបុគ្គលម្នាក់ ៗ នោះទេ ។ មានតែតាមរយៈភូមិនេះឯង ដែលមនុស្សម្នាក់អាចមានសិទ្ធិពេញលេញក្នុងការចូលរួមជាសមាជិករបស់សង្គម ។

## ស្ថានភាពនៃឋានានុក្រមក្នុងភូមិ ៖ សាមគ្គីភាព និងការប្រកួតប្រជែង

សមាជិកភូមិមានឋានៈទៅតាមឋានានុក្រមតឹងរ៉ឹងមួយ ដោយឆ្លើយតបទៅតាមឈ្មោះឋានៈសង្គម ។ លំដាប់ខ្ពស់ជាងគេនៃឋានានុក្រមនេះ មានឈ្មោះថា «ក្រុមប្រឹក្សាអ្នកមានមុខមាត់» ។ បើទោះបីជាឋានៈនិងលក្ខណៈវិនិច្ឆ័យ

ក្នុងការផ្ដល់ឋានៈ មានភាពខុសគ្នាយ៉ាងណាក៏ដោយ ក៏គ្រប់ភូមិទាំងអស់សុទ្ធតែមានឋានានុក្រមឋានៈរបស់ខ្លួន ហើយមានក្រុមប្រឹក្សាអ្នកមានមុខមាត់នៅខ្ពស់ពីលើគេ ។ នៅខាងក្រោមក្រុមប្រឹក្សាអ្នកមានមុខមាត់ គឺមានចាស់ព្រឹទ្ធាចារ្យក្នុងភូមិ ហើយនៅក្រោមចាស់ទុំទាំងនេះ មានមនុស្សពេញវ័យនៅក្នុងភូមិ ។ នៅក្នុងផ្នែកដ៏ធំទូលាយនៃលំដាប់ថ្នាក់ មានការបែងចែកខុសៗគ្នាច្បាស់លាស់ជាច្រើនទៀត ។ ឋានៈទាំងនេះ គឺជាតំណែងតាមលំដាប់សក្តិ ហើយរាល់កិច្ចការទាំងអស់នៅ «ឌិញ» ត្រូវពាក់ព័ន្ធនឹងពិធីសារល្អិតល្អន់ ដោយគោរពតាមលំដាប់ឋានៈនេះយ៉ាងទៀងទាត់ និងមានការសម្ដែងជាលក្ខណៈនិមិត្តរូប ។ នៅក្នុងពិធីផ្លូវការ មិនអាចមានមនុស្សពីរនាក់ដែលមានឋានៈស្មើគ្នាបានទេ ។

នៅក្នុងបរិបទជាក់ស្តែងនៃទំនាក់ទំនងជានិមិត្តរូបនៅកន្លែង «ឌិញ» នេះហើយ ដែលសាមគ្គីរបស់ភូមិត្រូវបានគេសម្ដែងឲ្យឃើញយ៉ាងពេញទំហឹង ហើយការប្រកួតប្រជែងចាប់ផ្ដើមមានភាពស្រួចស្រាល់ខ្លាំង ។ ឋានានុក្រមរួមនិងសកម្មភាពផ្លូវការ ដែលពាក់ព័ន្ធគ្នា បានជួយលើកស្ទួយសាមគ្គីភាព និងបានផ្ដល់នូវអត្ថន័យនៃអត្តសញ្ញាណនៅក្នុងភូមិ ក៏ដូចជានៅក្នុងគ្រួសារអ៊ីចឹងដែរ ។ ប៉ុន្តែ ខុសពីនៅក្នុងគ្រួសារ ឋានៈក្នុងភូមិត្រូវបានប្រគល់ឲ្យ មិនមែនទទួលបានពីកំណើតនោះទេ ។

ឋានៈភូមិមិនមែនជាអង្គការរដ្ឋបាលមួយនោះទេ ។ ក្រុមប្រឹក្សាអ្នកមានមុខមាត់ ជាអ្នកគ្រប់គ្រងការងារភូមិ ប៉ុន្តែមិនមែនដើរតួជាអង្គការនីតិប្រតិបត្តិនោះទេ ។ មន្ត្រីភូមិអនុវត្តតាមបំណងរបស់ក្រុមប្រឹក្សា ។ ដើម្បីក្លាយជាមន្ត្រីភូមិបាន ជារឿយៗគឺជាការលំបាកមួយ ហើយមានបន្ទុកទទួលខុសត្រូវច្រើន ប៉ុន្តែមានអំណាចពិតប្រាកដតិចតួចណាស់ និងបានប្រាក់កម្រៃក៏ស្តួចស្តើងដែរ ។ ប៉ុន្តែ តំណែងជាមន្ត្រី អនុញ្ញាតឲ្យមនុស្សណាម្នាក់អាចឡើងឋានៈក្នុងឋានានុក្រម ដែលផ្ដល់ជាច្រកចូលទៅកាន់ក្រុមប្រឹក្សាអ្នកមានមុខមាត់ដែលមានអំណាចនិងកិត្យានុភាពពិតប្រាកដ ។

## ឋានានុក្រម និងសេដ្ឋកិច្ច «កិត្យានុភាព»

សេដ្ឋកិច្ច «កិត្យានុភាព» មានកប់យ៉ាងជ្រៅនៅក្នុងឋានានុក្រម ដែលបានបញ្ជាក់នៅក្នុងការគោរពបូជាចំពោះអ្នកតាចាស់ស្រុក ។ នេះគឺជាផ្នែកមួយនៃរចនាសម្ព័ន្ធ ដែលមានការក្រកួតប្រជែងនិងតឹងរ៉ឹង ។ មុខតំណែងជាក់ស្តែងនៅក្នុងឋានានុក្រមនេះ គឺពិតជាមានសារៈសំខាន់ណាស់ចំពោះអ្នកភូមិ ។ ពួកគេប្រកួតប្រជែងយ៉ាងខ្លាំងក្លាដើម្បី «ហូបខាងលើ» និង «អង្គុយពីមុខ» គ្នានៅឯពិធីជប់លៀងនៅក្នុងឌិញ ។ បន្ទាប់ពីការរៀបធ្វើពិធីបូជាសំខាន់ៗរួចរាល់មក នឹងមានពិធីជប់លៀងដ៏ធំមួយ ដែលគេរៀបចំឡើងនៅឯឌិញ សម្រាប់សមាជិកភូមិទាំងអស់ ។ ពិធីជប់លៀងនេះបានកំណត់ទីតាំងរបស់មនុស្សក្នុងភូមិ ដូចដែលពិធីសែនដូនបានកំណត់ទីតាំងរបស់មនុស្សនៅក្នុងគ្រួសារនិងខ្សែស្រឡាយខាងឪពុកនីមួយៗ ។ ការរៀបចំកន្លែងអង្គុយនៅក្នុងពិធីជប់លៀង និងការចែកម្ហូបម្ហានៅក្នុងពិធី គឺមានរៀបរាប់លំអិតឲ្យស៊ីគ្នាទៅនឹងមុខតំណែងសំខាន់ៗ នៅក្នុងឋានានុក្រមនេះ ។ ឋានៈត្រូវបានគេបង្ហាញឲ្យឃើញ តាមរយៈនរណាអង្គុយនៅតុណា បុរសប៉ុន្មាននាក់ដែលត្រូវហូបអាហារមួយថាសរួមគ្នាបាន នរណាទទួលបានផ្នែកណានៃសាច់ដែលត្រូវចែក ។ ការលំអិតនេះមានភាពខុសៗគ្នា ប៉ុន្តែគ្រប់ភូមិទាំងអស់សុទ្ធតែមានលក្ខណៈពិសេសបែបនេះដែរ ។

*លោក ង្វៀន ខាក់វៀន* (Nguyễn Khắc Viện) *បានប្រាប់ឲ្យដឹងថា នៅក្នុងភូមិរបស់គាត់ ៖*

> បន្ទាប់ពីពិធីគោរពអ្នកតាមចាស់ស្រុកចប់ទៅ ក្បាល ចំពុះ និងទីបំផុតនៃក្បាលរបស់មាន់ឈ្មោល ដែលគេយកមកបូជានោះ គេយកទៅដាក់ទុកសម្រាប់អ្នកដែលមានមុខមាត់ខ្ពស់បំផុត ។ សូមទេវតាជួយអ្នកដែលយកចំណែកមួយនៃសំណែនសម្រាប់ខ្លួនឯង ... ! អ្នកផងក៏ធ្លាប់ឮពីអ្នកមានមុខមាត់ ដែលបានប្រព្រឹត្តបទល្មើស ដើម្បីយកទីបំផុតនៃក្បាលមាន់ឈ្មោលនោះ ។

*មិនមែនដោយសាររឿងឱជារស ដែលបុរសទាំងអស់នោះប្រកួតប្រជែងបែបជ្រុលពេកដូច្នេះនោះទេ ។*

> អ្នកមានមុខមាត់ម្នាក់ៗ ប្រកួតប្រជែងជាមួយអ្នកដទៃ ដើម្បីយកក្បាលមាន់ដែលគេបូជានៅក្នុងពិធីនេះ ទៅផ្ទះឲ្យបាន ព្រោះនៅក្នុងក្រសែភ្នែកភរិយា កូន និងអ្នកជិតខាងរបស់គាត់ ក្បាលមាន់គឺជាភស្តុតាងដែលមិនអាចប្រកែកបានថា គាត់ពិតជាមនុស្សដែលមានកិត្តិយសបំផុតនៅក្នុងភូមិ(៣៦) ។

*ប្រពៃណីនៃជនជាតិវៀតណាម ទទួលស្គាល់គោលការណ៍ឋានានុក្រមសង្គម និងយកចិត្តទុកដាក់យ៉ាងខ្លាំងអំពីមុខមាត់និងឋានៈ ។ ការទាមទារដើម្បីលើកតម្កើងឋានៈណាមួយ ត្រូវអ្នកភូមិដទៃទៀតពិនិត្យអាកប្បកិរិយានិងតាមដានយ៉ាងផ្ទៀងផ្ទាត់ ។ ការរំលោភបំពានធូន់ណាមួយទៅនឹងបែបបទសមរម្យ គឺអាចនឹងបង្ខូចកិត្យានុភាពរបស់គ្រួសារមួយយ៉ាងខ្លាំងបាន ។ ព្រោះថា អ្នកភូមិតម្រូវឲ្យបង់ «ពន្ធ» លើកិត្យានុភាព ដោយពួកគេចេះតែទាមទារការជួយឧបត្ថម្ភផ្នែកសង្គមកិច្ចនិងហិរញ្ញវត្ថុ ។ តម្លៃនៃឋានៈ កិត្យានុភាព និងការគោរពពីសំណាក់អ្នកផង តម្រូវឲ្យបានប្រុងប្រយ័ត្នជានិច្ច ឲ្យអនុលោមទៅតាមបទដ្ឋានរបស់ភូមិ និងឲ្យបង្អួតក្នុងសប្បុរិសធម៌ ។ ប្រសិនបើមនុស្សណាមិនធ្វើឲ្យសមស្របតាមឋានៈដែលខ្លួនចង់បាននោះ មនុស្សនោះក៏ត្រូវបាត់បង់ការគោរពពីអ្នកដទៃ ។*

*គ្រប់ក្រុមគ្រួសារទាំងអស់ សុទ្ធតែត្រូវចំណាយប្រាក់កាសម្តងម្កាល ដូចជា ការចុះឈ្មោះកូននៅក្នុងបញ្ជីផ្លូវការរបស់ភូមិ ពិធីបុណ្យសព អាពាហ៍ពិពាហ៍ ជាដើម ។ គ្រួសារនីមួយៗ អាចរៀបចំពិធីដូច្នេះបានដោយឲ្យអស់ប្រាក់តិចក៏បាន ឬត្រូវចំណាយប្រាក់ច្រើនក៏បាន ប៉ុន្តែរាល់សកម្មភាពសាធារណៈនីមួយៗ គឺជាសេចក្តីថ្លែងការណ៍មួយប្រាប់ឲ្យដឹងអំពីឋានៈនិងកិត្យានុភាពរបស់គ្រួសារខ្លួន ។ ជារួម ការប្រព្រឹត្តបែបនេះ សង្ខេបនូវកិត្យានុភាពរបស់បុគ្គល និងជាពិសេសរបស់ក្រុមគ្រួសារ ។ សម្រាប់អ្នកដែលមានកិត្យានុភាពល្បី និងមានតំណែងក្នុងសង្គមដែលត្រូវការពារ ឬសម្រាប់អ្នកដែលកំពុងព្យាយាម ដើម្បីបានឋានៈនៅក្នុងឋានានុក្រម ពួកគេមានជម្រើសតិចណាស់ ។*

*ទោះបីជាតំណែងទៅតាមឋានៈទាំងនេះត្រូវបានទទួលដោយការខំប្រឹងក៏ដោយ ក៏ទំនៀមទម្លាប់ភូមិនៅតែទាមទារឲ្យមានការទទួលស្គាល់ពីអ្នកផង ។ ការឡើងទៅក្នុងឋានានុក្រមបាន គឺតម្រូវឲ្យឧបត្ថម្ភពិធីជប់លៀងជាច្រើន («ឡេខាវវ៉ង់»* “lễ khao vọng”) *។ បើសមាជិកណាម្នាក់ឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យសម្រាប់ការឡើងឋានៈបាន សមាជិកនោះត្រូវតែរៀបចំនូវការប្រគល់ជូនអ្វីមួយនៅឯឌិញ និងរៀបចំពិធីជប់លៀងមួយបន្ទាប់មក ។ នេះអាចមានន័យថា ត្រូវរៀបចំពិធីជប់លៀងជូនសមាជិកភូមិទាំងមូលដោយខ្លួនគាត់តែម្តង ពោលគឺដោយចាយទ្រព្យសម្បត្តិរបស់ក្រុមគ្រួសារគាត់ ជាអ្នកដែលត្រូវចំណាយលើពិធីនេះ ។ ប្រសិនបើនេះជាឋានៈមួយខ្ពស់នោះ ពិធីនេះកាន់តែត្រូវចំណាយប្រាក់ច្រើនថែមទៀត ។*

*ការខ្វល់ខ្វាយទាក់ទងនឹងមុខមាត់ ឋានៈ និងកិត្យានុភាពនេះ ដែលគេឃើញក្នុងពិធីសែនសំណែន ពិធី*

ធ្នូនវ័យ និងពិធីដទៃទៀតដែលជាទម្លាប់អ្នកស្រុក បានបង្ហាញឲ្យឃើញពីអកិសមាចារជាទូទៅនៅក្នុងភូមិ ដែលតម្រូវមនុស្សក្នុងភូមិ ឲ្យមានចិត្តទូលាយជាសាធារណៈ តែឲ្យមានភាពអត្តខាត់ជាឯកជន ។ ទំនៀមទម្លាប់នៅតាមភូមិជាច្រើន បានបង្ហាញឲ្យឃើញថា មានការប្រតិបត្តិនូវអកិសមាចារបែបនេះ ។ មានការពិស្តារខុសៗគ្នា តែគោលការណ៍មិនខុសគ្នាទេ ។ គឺជាតួនាទីរបស់អ្នកដែលមានធូរធារ និងចង់បានមុខមាត់ខ្ពស់ក្នុងសង្គម ឲ្យចែកចាយច្រើនជាងក្រុមគ្រួសារដទៃទៀត ។ ក្រុមគ្រួសារយកចិត្តទុកដាក់ណាស់ ចំពោះអ្វីដែលអ្នកស្រុកគិតនិងនិយាយអំពីពួកខ្លួន ។ ពួកគេក៏មានជំនឿលើសំណាង ហើយយល់ថា មានចិត្តទូលាយនាំមកនូវសំណាងល្អ ។ ដូច្នេះហើយ នៅក្នុងក្រសែភ្នែកអ្នកភូមិ ពួកគេចំណាយដោយឥតស្តាយ ដោយហេតុតែទំនៀមទម្លាប់តម្រូវឲ្យពួកគេធ្វើអ៊ីចឹង ។

ការខ្វល់ខ្វាយអំពីមុខមាត់និងកិត្តិយសនេះ មិនមែនតម្រូវតែអ្នកដែលមានទ្រព្យហូរហៀរទេ ឲ្យយកមួយផ្នែកធ្វើបុណ្យធ្វើទាន ប៉ុន្តែមានអ្នកផ្សេងមួយចំនួនទៀត ក៏មានការស្ទាក់ស្ទើរក្នុងការបង្ហាញឲ្យគេឯងដឹងអំពីភាពក្រីក្ររបស់ខ្លួនដែរ ។ មនុស្សមិនព្រមទទួលអំណោយមនុស្សធម៌បានយ៉ាងងាយឡើយ ។ ពួកគេខំរស់នៅយ៉ាងសន្សំសំចៃបំផុតបើអាចធ្វើបាន និងខិតខំរក្សាឲ្យបានឲ្យគេឃើញអំពីលក្ខណៈធម្មតាៗ(៣៧) ។ គេគ្រប់គ្នាត្រូវតែពឹងអាស្រ័យលើខ្លួនឯងនិងធ្វើពលិកម្មខ្លួនឯង ។ អ្នកទាំងឡាយណាដែលមិនចេះពឹងពាក់លើខ្លួនឯង ក៏ត្រូវអ្នកជិតខាងរិះគន់ ។ គោលការណ៍ដែលណែនាំការប្រព្រឹត្តរបស់ក្រុមគ្រួសារ ក៏ត្រូវយកអនុវត្តជាមួយភូមិផងដែរ ។ ដូចអត្តភាពសមូហភាពដែលខ្វល់អំពីមុខមាត់របស់ពួកខ្លួន ភូមិទាំងមូលក៏បង្ហាញនូវអាកប្បកិរិយាពឹងអាស្រ័យលើខ្លួនឯងនិងពលិកម្មខ្លួនផងដែរ ។ អ្នកភូមិសុខចិត្តលំបាកវេទនាខ្លាំង តែមិនឲ្យបាក់មុខដោយសារតែការសុំជំនួយពីអ្នកខាងក្រៅឡើយ(៣៨) ។

បញ្ហាសំខាន់នៃមុខមាត់ និងបំណងប្រាថ្នាចង់បានកិត្យានុភាព ហើយនិងការចង់ឲ្យមហាជនទទួលស្គាល់នេះ ដែលមានការជាប់ពាក់ព័ន្ធគ្នានឹងជំនឿដែលថា អំពើល្អនឹងនាំមកនូវសំណាងល្អ ធ្វើឲ្យមានយន្តការប្រើងប្រែងដោយខ្លួនឯងនិងកម្រិតវិន័យខ្លួនឯងនេះឡើង ។ អ្នកភូមិទាំងឡាយណាដែលមានទ្រព្យហូរហៀរ ត្រូវបង្ខំចិត្តឲ្យចែកចាយមួយផ្នែកជាថ្នូរនឹងកិត្យានុភាព រីឯអ្នកទាល់ក្រវិញ មានការពិបាកក្នុងការទទួលយកទាន ហើយសុខចិត្តទទួលតែក្នុងករណីដែលទាល់បំផុតប៉ុណ្ណោះ ។

គោលការណ៍ជាមូលដ្ឋាននៃការចែកធនធានដែលគេបាន អាចសង្ខេបឲ្យខ្លីថា ជា «ការចែករំលែកពីអ្នកដែលចង់បានមុខមាត់ ទៅឲ្យអ្នកដែលសុខចិត្តបាក់មុខ» ។ ទាំងសេចក្តីត្រូវការចាំបាច់ ទាំងលទ្ធភាពក្នុងការចំណាយប្រាក់បាន គឺជាការប៉ាន់ប្រមាណដោយខ្លួនឯង ដែលកម្រិតដោយការជំរុញពីអំណាចផ្លូវចិត្ត ។ ជនជាតិវៀតណាមជាច្រើនងាយនឹងកើតសេចក្តីសៅហ្មងដោយមតិសាធារណៈ ដែលបង្ហាញតាមរយៈការនិយាយខ្សឹបខ្សៀវ ការចំអកមើលងាយ ឬការតិះដៀល ។

## សេដ្ឋកិច្ចល្មមតែបង្គ្រប់ការចិញ្ចឹមជីវិត

នៅក្នុងភូមិ មានអត្តភាពនិងសកម្មភាពជាច្រើន ដែលបង្ហាញនូវទម្លាប់មួយខុសគ្នាពីអ្វីដែលបានរៀបរាប់ខាងលើ ។ ជនជាតិវៀតណាមបុរាណ គឺជាមនុស្សដែលចូលចិត្តមានគ្នីគ្នា ហើយភូមិទាំងអស់សុទ្ធតែមានក្រុមសង្គម

ខុសៗគ្នា ។ ឧទាហរណ៍ មានក្លិបនិងសមាគមសម្រាប់អ្វីៗ គ្រប់យ៉ាង ចាប់ពីការបង្ហោះខ្លែង រហូតដល់ការចិញ្ចឹមសត្វឲ្យចេះច្រៀង ក្លិបសម្រាប់ទាហានចាស់ៗ សម្រាប់មនុស្សដែលកើតឆ្នាំដូចគ្នា សម្រាប់សិស្សដែលមានគ្រូដូចគ្នា[៣៩] ។ បើទោះជាពួកគេមានភាពខុសៗគ្នាយ៉ាងនេះក្តី ហើយការរស់ស្ងួតដំណើរមិនប្រក្រតី នៅក្នុងប្រព័ន្ធជាតុយិន មានខ្ពស់ក្តី ក៏មានក្រុមដែលមានប្រភេទខុសៗគ្នាជាច្រើន មានចរិតលក្ខណៈពិសេសមួយចំនួនដូចគ្នា ដែលធ្វើឲ្យពួកគេមានជាតុយិនពីធម្មជាតិយ៉ាងច្បាស់ ។

ផ្ទុយគ្នានឹងជាតុយ៉ាំង ដែលមានលើសនៅក្នុងពិភពគ្រួសារនិងភូមិ ដែលសម្គាល់ដោយភាពខុសគ្នាខាងក្នុង និងការប្រកួតប្រជែងឋានៈយ៉ាងស្រួចស្រាល់នោះ ក្រុមយិនមានរចនាសម្ព័ន្ធផ្ដេកស្មើៗ ពិសេសស្មើជាមួយនិងមានសមភាព ។ ក្រុមទាំងអស់ គឺជាក្រុមស្ម័គ្រចិត្តនិងមិនផ្លូវការ ក្រុមទាំងអស់សុទ្ធតែបានបញ្ជាក់ពីសហប្រតិបត្តិការនិងសាមគ្គីភាព និងក្រុមទាំងអស់មានយន្តការកាត់បន្ថយការប្រកួតប្រជែង និងមិនលើកទឹកចិត្តឲ្យមានជម្លោះណាមួយ ហើយភាពខុសគ្នាខាងក្នុងមានតិចតួច ។ ភាពជាអ្នកដឹកនាំ ជារឿយៗត្រូវផ្លាស់ប្តូរវេនគ្នា ឬ ត្រូវទៅតាមអ្នកមានបទពិសោធន៍យូរឆ្នាំ ។ ការចំណាយនៃសមាជិកភាពត្រូវមានការដាក់បញ្ញត្តិនិងស្មើគ្នា ។ ក្រុមនេះផងដែរ គឺសម្រាប់ស្ត្រី ។ ជាចុងបញ្ចប់ នៅពេលដែលវិស័យយ៉ាំង គឺជាចំណុចបង្គោលនៃការយកចិត្តទុកដាក់របស់រដ្ឋ រួមទាំងក្រុមនីត្យានុកូលផង ក្រុមយិនទាំងនេះទំនងជាកើតឡើងដោយឯកឯង ហើយរដ្ឋអំណាចមិនអើពើចំពោះសមាគមទាំងនេះ ។ គ្មានសមាគមណាមួយត្រូវបានបង្កាប់ដោយច្បាប់ឬដោយវប្បធម៌ទេ ។

អ្នកភូមិរស់នៅដោយពួកដោយក្រុមយ៉ាងស្ងៀមស្ងាត់នៅក្នុងភូមិ ហើយនៅមាត់ច្រកចូលនៃក្រុមទាំងនេះ ខ្វាងទ្វារមានសម្គាល់នូវព្រំដែនសគ្គមសាស្ត្រ ។ ក្រុមនីមួយៗ សុទ្ធតែមានសមាជិកភាពនៅក្នុងបញ្ជីផ្លូវការ និងមានប្រធានបោះឆ្នោតដោយខ្លួនផ្ទាល់ ដើម្បីបម្រើជាអ្នកសម្របសម្រួល រវាងក្រុមនិងអាជ្ញាធរភូមិ ។ ក្រុមមួយចំនួន មានបូជនីយដ្ឋានរបស់ខ្លួនផ្ទាល់ សាងសង់ដោយប្រើធនធានផ្ទាល់ខ្លួន ដើម្បីគោរពបូជាអ្នកតាមួយរូបឬទេវតាមួយព្រះអង្គ ទៅតាមជំនឿដែលខ្លួនជ្រើសរើស ។ តែក្រុមខ្លះមិនមានឋានៈស្របច្បាប់ណាមួយទេ ហើយសមាជិកភាពមានភាពបើកចំហ ។ នរណាម្នាក់ក៏អាចចូលក្នុងក្រុមអ្នកជិតខាងណាមួយ ដោយមិនចាំបាច់ចូលជាសមាជិកភូមិជាមុនទេ ។ សូម្បីចំណែកផ្លូវដើរនៅក្នុងតំបន់មួយ ជួនកាលត្រូវមានបញ្ជីសមាជិកភាព មានប្រធានរបស់ខ្លួន និងកិច្ចប្រជុំ និងការប្រារព្ធពិធីបុណ្យរបស់ខ្លួន ។ ចំណែកផ្លូវ លើសពីតំបន់អ្នកជិតខាង គឺជាក្រុមតទល់មុខគ្នា ដែលគេម្នាក់ៗ សុទ្ធតែស្គាល់គ្នាទៅវិញទៅមកយ៉ាងច្បាស់ ហើយការជួយគ្នាទៅវិញទៅមក គឺជារឿងសាមញ្ញមួយនិងធ្វើទៅដោយមិនផ្លូវការ ។ ការជួយគ្នាទៅវិញទៅមកក្រៅផ្លូវការនេះ គឺជាចរិតលក្ខណៈនៃសេដ្ឋកិច្ច ដើម្បីបគ្រប់ការចិញ្ចឹមជីវិតដែលស្របគ្នាទៅនឹងសេដ្ឋកិច្ចកិត្យានុភាពដូចបានពោលមកខាងលើ ។

ភូមិស្ទើរតែទាំងអស់ មានកន្លែងដាច់ដោយឡែកមួយធ្វើជាទីផ្សារខាងក្រៅ ជាធម្មតា ស្ថិតនៅខាងក្រៅរបងឫស្សី ដែលកំណត់ភូមិ ។ នេះបង្ហាញឲ្យឃើញពីឋានៈទាបនៃពាណិជ្ជកម្ម ដែលទុកសម្រាប់ស្ត្រីនិងជនបរទេស ។ ទីផ្សារនេះពាក់ព័ន្ធនឹងការលក់ដូរតូចតាច ជាពិសេសគឺការលក់បន្តនូវទំនិញក្នុងស្រុក ។ ស្ត្រីរកប្រាក់ចំណូលបន្ថែមសម្រាប់គ្រួសារ តាមរយៈការទិញប្រេង ឬស្ករក្នុងបរិមាណតិច រួចហើយលក់វាចេញវិញ ដោយតម្លៃខ្ពស់ជាងនេះបន្តិច និងដោយការធ្វើចំណីអាហារសម្រាប់លក់ ឬលក់បន្លែបង្កា និងផ្លែឈើពីសួនច្បារ ហើយតាមធម្មតាបានប្រាក់ចំណេញតិចណាស់ ។

*គ្រួសារស្ទើរតែទាំងអស់ ចូលរួមក្នុងការយកចំណេញពីវាលស្រែដែលនៅព័ទ្ធជុំវិញភូមិ ។ ប្រសិនបើដំណាំស្រូវមិនសូវបានផល អ្នកភូមិនាំគ្នាដាំដំណាំផ្សេងៗទៀត ។ ប្រសិនបើអាចធ្វើបាន អ្នកគ្រប់គ្នា ទាំងជាងដែក ជាងកាត់សក់ សុទ្ធតែខិតខំធ្វើស្រែចម្ការ ។ ស្រមោលអាក្រក់នៃភាពអត់ឃ្លាននៅលងអន្ទោលតាមប្រាណគ្រប់នាទី ។ ស្រូវអង្ករ ទោះមានប៉ុន្មានក៏មិនដែលថាមានច្រើនហួសដែរ ហើយការធ្វើស្រែទោះលំបាកយ៉ាងណា ក៏ត្រូវតែធ្វើដែរ ។ ប៉ុន្តែ មានគ្រួសារជាច្រើនដែលមិនអាចចិញ្ចឹមជីវិតបានពីការធ្វើស្រែ ហើយមានគ្រួសារជាច្រើនខ្វះខាតប្រាក់កាសមិនចេះចប់ ។ ឧស្សាហកម្មក្នុងភូមិផ្តល់នូវមធ្យោបាយមួយឲ្យអ្នកភូមិអាចប្រើពេលវេលាបន្ថែម ដើម្បីរកលុយកាក់បន្ថែម ។ នេះគឺជាសហគ្រាសគ្រួសារ ។ កម្លាំងពលកម្មមិនបាច់បង់លុយ គ្រួសារទាំងមូលធ្វើការយ៉ាងហត់នឿយទាំងអស់គ្នា ប៉ុន្តែផលកម្រៃដែលបានមក គឺមានបន្តិចបន្តួចប៉ុណ្ណោះ ។*

*នៅក្នុងភូមិមានឯកទេសកម្ម ដែលមានកម្រិតខ្ពស់ជាទីបំផុត*[៤០] *។ លើសពីអ្វីៗ ដែលភូមិនីមួយៗ មានដោយផ្ទាល់ខ្លួន ដូចជា ជាងដែកម្នាក់ ជាងឈើម្នាក់ ជាដើមនោះ ភូមិនីមួយៗ ចង់មានឯកទេសពិសេសរបស់ខ្លួនមួយ ។ នៅក្នុងភូមិខ្លះ បុរសពេញកម្លាំងមានជំនាញជាងទង ជាងកាត់សក់ ជាងសំណង់ ជាងដួសដុលគ្រប់មុខ ឬគ្រូថ្នាំបុរាណ ។ ភូមិផ្សេងៗទៀត ផ្តោតលើការផលិតក្រដាស ឆត្រ ឆ្នាំង សំណាញ់ ឬម្ជុល ។ នៅមានជំនាញពិសេសជាងនេះទៀតក្នុងជំនាញដែលបានរៀបរាប់ខាងលើ ។ ការផលិតនូវផលិតផលអ្វីតែមួយ ជារឿយៗ ពាក់ព័ន្ធទៅនឹងការងាររបស់ភូមិជាច្រើន ភូមិនីមួយៗ មានការម៉ៅផ្តាច់លើការផលិតមួយផ្នែក រូបមន្តណាមួយ បច្ចេកទេសអ្វីមួយ ឬវត្ថុធាតុដើមណាមួយ ។ ជាថ្មីម្តងទៀត នេះគឺជាហេតុនិងផលនៃសាមគ្គីភាពរបស់ភូមិ ។ សិប្បករឬជាងដែលចូលរួមក្នុងប្រភេទការងារដូចគ្នានៅក្នុងភូមិ ជារឿយៗ តែងតែរៀបចំក្រុមខ្លួនជាសមាគមអ្នកមានវិជ្ជាជីវៈដូចគ្នាមួយ (សាជីវកម្ម) ។ សាជីវកម្មនេះចែករំលែកចំណេះដឹងនៅក្នុងក្រុម ប៉ុន្តែមិនចែករំលែកវាជាមួយអ្នកខាងក្រៅទេ ។ សាជីវកម្មទាំងនេះក៏មានមុខងារជាសមាគមអញ្ជាមញ្ញាសង្គ្រោះ គឺជួយសមាជិកទៅវិញទៅមកដែរ ។ នៅពេលដែលមានគ្រោះអាសន្នអ្វីមួយកើតឡើង គេនឹងពឹងពាក់ជំនួយរបស់សាជីវកម្ម ។*

*សាជីវកម្ម គឺជាទម្រង់សមាគមជួយគ្នាទៅវិញទៅមកមួយក្នុងចំណោមសមាគមទាំងឡាយ ដែលឃើញមាននៅក្នុងប្រទេសវៀតណាមបុរាណ ។ មានសមាគមសម្រាប់បុណ្យសពនិងកប់សព ឬសមាគមពិសេសដទៃទៀតសម្រាប់ជួយក្នុងគ្រប់កាលៈទេសៈបន្ទាន់ណាមួយ ដែលត្រូវការចេញប្រាក់កាសភ្លាមៗ ។ សូម្បីតែក្រុមសម្រាប់ប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីក៏មានដែរ ។ តាមផ្ទះសម្បែងនីមួយៗ គេបរិច្ចាគប្រាក់កាសបន្តិចបន្តួចរាល់ខែ ហើយនៅរាល់ដំណាច់ឆ្នាំ គេទិញរបស់ឆ្ងាញ់ថ្លៃៗ ចែកទៅឲ្យសមាជិកបន្តិចម្នាក់ ។ ប្រភេទអង្គភាពដែលមានភាពសាមញ្ញមួយក្នុងមុខងារជួយគ្នាទៅវិញទៅមកនេះ គឺឲ្យឈ្មោះថា «យ៉ាប» (giáp)*[៤១] *។ អង្គភាព «យ៉ាប» នេះប្រហែលត្រូវបានរៀបចំឡើង ដោយផ្អែកលើខ្សែស្រឡាយ ឬឈ្មោះត្រកូលរួមមួយ ដោយសមាជិកនៅក្នុងភូមិផងរបងជាមួយគ្នា ឬក្រុមឬភូមិតូចៗ ការគោរពបូជាអ្នកតាណាមួយ ឬចំណងសម្ពន្ធភាពរួមផ្សេងទៀត ។ «យ៉ាប» គឺជាអង្គភាពសាជីវកម្ម ដែលមានទ្រព្យសម្បត្តិផ្ទាល់របស់ខ្លួន មានការប្រារព្ធពិធីបុណ្យរបស់ខ្លួន និងសមាជិកមានឋានៈតាមបែបឋានានុក្រមរបស់ខ្លួន ។ ប៉ុន្តែ លំដាប់លំដោយឋានៈនៅក្នុងអង្គភាព «យ៉ាប» ផ្អែកទាំងស្រុងលើលំដាប់លំដោយរបស់ឈ្មោះ ដូចមានចុះនៅលើបញ្ជីផ្លូវការរបស់ភូមិ ។ «យ៉ាប» មិនគិតអំពីទ្រព្យសម្បត្តិ ឬឋានៈ*

គឺអ្នកដែលបានចូលសមាជិកភាពមុន ដែលអាចអន្ទុយឱច្ឆាសន៍លើគេ និងពិសាអាហារមុនអ្នកទាំងឡាយផ្សេងទៀត ដែលបានចូលជាសមាជិកក្នុងអង្គភាព «យ៉ាប» ក្រោយៗ គាត់ ។ បើទោះជាការចូលរួមជាសមាជិករបស់ «យ៉ាប» បានន័យថា ត្រូវចំណាយប្រាក់ក៏ដោយ ក៏ការចំណាយទាំងនេះជានិច្ចកាលមានការគ្រប់គ្រងនិងចែករំលែកចំនួនស្មើគ្នា ។ គ្មានពាក់ព័ន្ធនឹងការបាត់ ឬទទួលបានកិត្យានុភាពអ្វីទេ ដូច្នេះការប្រកួតប្រជែងគ្នាអស់លុយកាក់ច្រើន គឺគ្មានទេ ។ ក្រុមជួយគ្នាទៅវិញទៅមកផ្សេងៗ ទៀត ក៏អ៊ីចឹងដែរ ។ នេះគឺជាសភាពនៃសេដ្ឋកិច្ចបគ្រ្គប់ជីវភាពទាំងមូល និងជាអ្វីដែលខ្ញុំហៅថា វិស័យយិន នៃជីវភាពអ្នកភូមិ ។

## សេដ្ឋកិច្ចនយោបាយយិនយ៉ាំង

សេដ្ឋកិច្ចកិត្យានុភាព (ដែលមានការពាក់ព័ន្ធគ្នាជាមួយនឹងការគោរពបូជាចំពោះអ្នកតាចាស់ស្រុក) កេណ្ឌ «ពន្ធ» លើឋានៈនិងកិត្យានុភាពនេះ ។ ប្រព័ន្ធនេះត្រូវបានកំណត់ដោយទម្លាប់និងការប្រកួតប្រជែងដ៏ហួសហេតុមួយ ។ ធាតុផ្សំរបស់ប្រព័ន្ធនេះ មានសភាពបិទជិតនិងទំនងជាមានការបែងចែងគ្នាខ្លាំង ។ ការប្រវាស់ដៃគ្នាទៅវិញទៅមក មិនមានតុល្យភាពទេ ។ យន្តការខុសៗ គ្នា និងទំនៀមទម្លាប់ក្នុងស្រុកកេណ្ឌយកចំណេញពីឋានៈនិងកិត្យានុភាពនេះ ។ នេះបង្កបង្កើតបានជាប្រព័ន្ធសុខុមាលភាពភូមិ ដោយចៀសវាងយ៉ាងគ្រាន់បើ មិនឲ្យមានបញ្ហាមនុស្សប្រញើក្អែក ។ ប៉ុន្តែ មិនមានការអួតអាងអំពីភាពក្រីក្ររួម និងចេតនាចង់ទទួលបានភាពស្មើគ្នាឡើយ ។ ភាពស្មើគ្នាពិតប្រាកដ គឺត្រូវគេយល់ថា ធ្វើឲ្យមានអស្ថិរភាព ព្រោះវាផ្ទុយគ្នាទៅនឹងក្រឹត្យក្រមធម្មជាតិរបស់ពិភពលោក ។ ម្យ៉ាងវិញទៀត មុខងារជានារ៉ាប់រងរបស់ភូមិ មានផ្តល់ឲ្យនៅក្នុងបរិបទនៃសេដ្ឋកិច្ចល្មមចិញ្ចឹមជីវិត ដែលស្របគ្នានឹងមុខងារនៃសេដ្ឋកិច្ចកិត្យានុភាព និងបំពេញបគ្រ្គប់សេដ្ឋកិច្ចកិត្យានុភាពនេះ ។ ដូចយើងបានឃើញស្រាប់ហើយ សេដ្ឋកិច្ចល្មមចិញ្ចឹមជីវិត ពាក់ព័ន្ធនឹងស្ថាប័នខុសៗ គ្នាសុទ្ធសាធពីសេដ្ឋកិច្ចកិត្យានុភាព ហើយផ្អែកលើគោលការណ៍ខុសៗ គ្នាជាច្រើនទៀត ។

ដោយធ្វើការបន្តបន្ទាប់គ្នា សេដ្ឋកិច្ចល្មមចិញ្ចឹមជីវិត និងសេដ្ឋកិច្ចកិត្យានុភាព ដូចគ្នាទៅនឹងធាតុយិននិងធាតុយ៉ាំងដែរ ពោលគឺជាផ្នែករួមបញ្ចូលគ្នាក្នុងប្រព័ន្ធស្មុគស្មាញតែមួយ ហើយអាចធ្វើឲ្យភូមិមានជីវិតឋិតថេរបាន ទោះឋិតនៅក្នុងបរិយាកាសមិនទៀង និងប្រកបដោយគ្រោះថ្នាក់ក៏ដោយ ។ តាមពិតទៅ គោលការណ៍ដែលផ្ទុយគ្នា ការប្រកួតប្រជែងនិងការសហការ ឋានានុក្រមនិងភាពស្មើ ជម្លោះនិងសាមគ្គីភាព គឺមានមុខងារជាផ្នែកបំពេញបគ្រ្គប់នៃសេដ្ឋកិច្ចនយោបាយ ។ រចនាសម្ព័ន្ធភ្ជោះនេះ បង្ហាញពីចរិតលក្ខណៈមនោគមវិជ្ជានិងសង្គមរបស់ប្រទេសវៀតណាមបុរាណ ។

## ផ្នែកយិននៃសាសនាក្នុងភូមិ

ការគោរពបូជាចំពោះដូនតានៅក្នុងគ្រួសារ និងការគោរពបូជាចំពោះអ្នកតាចាស់ស្រុកនៅក្នុងភូមិ គឺធាតុយ៉ាំងដែលគ្រប់គ្រងដោយមនុស្សប្រុស ត្រូវបានបញ្ជាដោយវប្បធម៌ មានឋានានុក្រម មានទម្រង់ផ្លូវការ និងច្រើនតែមានការប្រកួតប្រជែងគ្នា ។ វិស័យយិននៃសាសនា ពាក់ព័ន្ធគ្នានឹងសកម្មភាពច្រើនរបស់ស្ត្រី និងមានភាពអាចជ្រើសរើសបាន មានសមភាពច្រើនជាង មានភាពក្រៅផ្លូវការច្រើនជាង មានការសហការគ្នាច្រើនជាង និង

មានការប្រកួតប្រជែងគ្នាតិចជាងវិស័យយ៉ាំង ។

ក្រុមគ្រួសារនីមួយៗ បកស្រាយខ្លឹមសារ និងការប្រារព្ធពិធីបុណ្យរបស់ខ្លួន ទៅតាមការពេញចិត្ត សេចក្តីត្រូវការ និងសមត្ថភាពរបស់ខ្លួន ។ ផ្ទះលំនៅខ្លះមានអាសនៈដូនតា និងអង្គៗច្រើន ឬមានតិច ឬក៏គ្មានសោះ ។ គេអាចឃើញអង្គៗច្រើនប្រភេទខុសៗ គ្នា នៅតាមគេហដ្ឋានរបស់អ្នកស្រុក សម្រាប់គោរពទេវតានិងអ្នកតាក្នុងសាសនាតាវ ពុទ្ធសាសនា ទេវកថាប្រជាប្រិយ ប្រវត្តិសាស្ត្រវៀតណាម និងរឿងព្រេងក្នុងស្រុក ។ អង្គដើម្បីអង្វរសុំជំនួយពីអ្នកតាណាមួយ ច្រើនតែមានដើម្បីគោលបំណងជាក់លាក់មួយ ។ គេជឿថា ព្រលឹងរបស់មេទ័ពដែលចែកឋាន រួចបានក្លាយជាអ្នកតា ខ្លាំងពូកែសម្រាប់ការពារផ្ទះសម្បែងពីខ្មោចព្រាយបិសាច ។ ទេពធីតានៃចិត្តមេត្តា គឺព្រះនាងគង់ស៊ីអឹម (ក្វានអឹម Quan Âm) ជួយស្ត្រីនិងកុមារជាពិសេស ហើយប្រឆាំងនឹងគ្រោះថ្នាក់នៃការឆ្លងទន្លេ ។

មានស្ត្រីមួយចំនួនមានអារម្មណ៍ថា ត្រូវបានគេហៅទៅបម្រើដល់ទេពធីតា ដូចជា ព្រះនាងខ្មៅមកពីឋានសួគ៌ទី ៩ ឬម្ចាស់ក្សត្រីថ្មយក់របស់ពួកអមតជន ។ ជម្ងឺតម្កាត់និងសំណាងអាក្រក់ កើតឡើងចំពោះស្ត្រីដែលមិនឆ្លើយតបទៅនឹងការកោះហៅនេះ ។ ប៉ុន្តែ ប្រសិនបើមានការគោរពបូជាបានដោយស្មោះស្ម័គ្រវិញនោះ ទេពធីតាប្រយាយទៃពនោះ នឹងនាំមកនូវសុខុមាលភាពល្អនឹងសំណាងល្អ ។ ជំនឿលើទេវតាអារក្សអ្នកតា ច្រើនកើតមានឡើងនៅជុំវិញបាតុភូតបែបនេះ ។ ការគោរពបូជាទាំងនោះ អាចបូកបញ្ចូលគ្នាវាងព្រឹត្តិការណ៍សាសនាជាមួយនឹងសកម្មភាពសង្គម ដូចជាពិធីជប់លៀងប្រចាំឆ្នាំ[៤២] ។

ព្រះពុទ្ធសាសនា គឺជាផ្នែកមួយដែលលេចឡើងច្បាស់ នៃសាសនារបស់ជាតុយិន ។ វត្តមាននៅគ្រប់កន្លែងនៅក្នុងប្រទេសវៀតណាមបុរាណ ប៉ុន្តែ គ្មាន «សហធម្មចារី» ពិតប្រាកដទេ គឺពុំមានឧបាសកដើរវត្តពិតប្រាកដ ។ អ្នកដែលចូលរួម គឺធ្វើទៅតាមចិត្តនឹងចង់ ហើយអ្នកមានជំនឿភាគច្រើន មិនមានភាពទៀងទាត់ចំពោះវត្តណាមួយដោយឡែក ។ ព្រះពុទ្ធសាសនាដែលជាប្រព័ន្ធជំនឿនិងគំនិតយ៉ាងជាក់លាក់មួយ មានឥទ្ធិពលយ៉ាងខ្លាំងនិងពីយូរអង្វែងនៅក្នុងប្រទេសវៀតណាម ប៉ុន្តែស្ថាប័នពុទ្ធសាសនា ជាពិសេស តួនាទីនិងឥទ្ធិពលរបស់គណៈសង្ឃ ម្តងរីកចម្រើន ម្តងចុះអន់ថយជាហូរហែ ។ ព្រះសង្ឃក្នុងឋានៈជាព្រះសង្ឃ គ្មានតំណែងអ្វីមួយច្បាស់លាស់នៅក្នុងរចនាសម្ព័ន្ធសង្គមនៃភូមិ និងមានឥទ្ធិពលតិចតួចឬគ្មានផងនៅក្នុងកិច្ចការភូមិ បើទោះបីជាព្រះសង្ឃអង្គណាដែលមានទេពកោសល្យនិងគុណធម៌ អាចមានឥទ្ធិពលខ្លាំងយ៉ាងណាក្តី ។ វត្តអារាមទទួលការចាប់អារម្មណ៍និងទទួលជំនួយឧបត្ថម្ភច្រើនពីស្ត្រីចំណាស់ៗ ជារឿយៗ គឺស្ត្រីមេម៉ាយ ។ សមាគមស្ត្រីពុទ្ធសាសនិកមានស្ទើរតែនៅគ្រប់ភូមិ ដែលមានអ្នកដឹកនាំសមាគមនេះឆ្លាស់គ្នារៀងរាល់ឆ្នាំ ។ ក្រុមជាច្រើនទាំងនេះ រៀបចំពិធីម្តងក្នុងមួយឆ្នាំ ហើយច្រើនតែជាពិធីជប់លៀង[៤៣] ។

## ការរួមបញ្ចូលក្នុងប្រទេសជាតិ

ស្តេចទាំងឡាយក្នុងរាជវង្សង្វៀន ដែលចាប់ផ្តើមឡើងសោយរាជ្យនៅក្នុងឆ្នាំ ១៨០២ មាននិន្នាការខ្លាំងចម្លែកលើជាតុយ៉ាំង ដើម្បីប្រតិកម្មតបទៅនឹងស្ថានភាព ដែលកើតមានឡើងមុនការគ្រប់គ្រងរបស់រាជវង្សនេះ ។ ស្តេចរាជវង្សង្វៀនស្វះស្វែងស្ថាបនាឲ្យមានលំដាប់លំដោយល្អជាងមុន ឲ្យត្រឹមត្រូវតាមច្បាប់ ឲ្យមានការរួបរួមគ្នាជាង

មុន និងឲ្យជាសង្គមដែលមានការរៀបចំតឹងតែងជាងមុន ។ ស្ដេចរាជវង្សង្វៀនបានសម្រេចព្រះទ័យឲ្យប្រើភាសាចិនជាភាសាផ្លូវ ឲ្យអនុម័តប្រើក្រមនីត្យានុកូលតឹងតែងជាងមុន ដែលបានដាក់តំណែងស្ត្រីឲ្យស្ថិតនៅទាបជាងពីពេលណាៗ ទាំងអស់ បានរឹតត្បិតសាសនាព្រះពុទ្ធ បានប្រកាសឲ្យប្រើគម្ពីរលទ្ធិខុងជឺបែបថ្មីទៅតាមរូបភាពជាច្រើន ដែលផ្សារភ្ជាប់ទំនាក់ទំនងរវាងអ្នកភូមិនិងមន្ត្រី ឲ្យត្រឹមត្រូវទៅតាមតួនាទីទំនៀមទម្លាប់តាមគម្ពីរ និងមានសាមគ្គីភាពសង្គមច្រើនជាងមុនដោយអនុលោមទៅតាម «លី» និង «ង្វៀ» ។

ស្ដេចក្នុងសន្តតិវង្សង្វៀន បានស្ថាបនាព្រះរាជវាំងនៅក្នុងតំបន់វ៉េ (Huê) ដែលយកគំរូតាមវាំងចិនក្នុងក្រុងប៉េកាំង ។ គោលការណ៍ឋានៈរបស់សង្គម បានបង្ហាញឲ្យឃើញតាមរយៈរចនាបថនិបរិវេណរបស់ព្រះរាជវាំង ។ ស្ថាបត្យកម្មនិងការរៀបចំទីតាំងសាងសង់ លើកស្ទួយឲ្យមានភាពសុខដុមរមនាជាមួយនឹងក្រឹត្យក្រមធម្មជាតិ ដោយការរៀបចំអន្តរកម្ម និងការរៀបចំរបៀបប្រព្រឹត្តក្នុងពិធីបុណ្យ[៤៤] ។ ព្រះរាជាវៀតណាមជាមេដឹកនាំការគោរពបូជាបួនយ៉ាង ដូចជា ការគោរពបូជាចំពោះទេវតាក្នុងឋានសួគ៌ ការគោរពបូជាចំពោះព្រះបិតរ ការគោរពបូជាចំពោះលោកតាខុងជឺ និងការគោរពបូជាចំពោះកសិកម្ម ។ ព្រះរាជនាទីរបស់ទ្រង់ ផ្ដោតលើការដឹកនាំពិធីសាសនាឲ្យនៅពីលើមុខងារនីតិប្រតិបត្តិនិងនីតិប្បញ្ញត្តិ ។ ព្រះរាជសកម្មភាពសាសនារបស់ទ្រង់ ផ្សារភ្ជាប់និងធ្វើសមាហរណកម្មជាមួយ ព្រះរាជនាទីទ្វេរបស់ទ្រង់ ជាព្រះរាជារបស់អ្នកស្រុក និងជាអធិរាជបែបចិន ។

ក្នុងឆ្នាំ ១៨០៨ គេបានសាងសង់មហាគ្រឹះពិសេសមួយឡើង នៅខាងក្រៅរាជធានីវ៉េ សម្រាប់ឧទ្ទិសបូជាដល់ឋានសួគ៌និងផែនដី ។ ទីតាំងសាងសង់នេះ ក៏យកតាមលំនាំរចនាបថនៅប្រទេសចិនដែរ ដោយមានទីលានរាងវង្វង់មូល (ធាតុយ៉ាំង) សម្រាប់ឧទ្ទិសបូជាដល់ឋានសួគ៌ ចំណែកឯទីលានរាងបួនជ្រុងមួយទៀតដែលតូចជាង (ធាតុយិន) សម្រាប់ឧទ្ទិសបូជាដល់ផែនដី ។ មានតែព្រះរាជា ឬតំណាងផ្លូវការរបស់ទ្រង់ប៉ុណ្ណោះ ដែលអាចប្រារព្ធពិធីឧទ្ទិសបូជាដល់ឋានសួគ៌បាន ពោលគឺផ្ដល់ជានិមិត្តរូបនៃតួនាទីដោយឡែករបស់ទ្រង់នៅក្នុងសង្គម ជាតំណាងតែមួយគត់ដែលអាចទាក់ទងនឹងអព្ភូតហេតុធម្មជាតិនិងអព្ភូតហេតុអភិធម្មជាតិបាន ។

ការគោរពបូជាចំពោះព្រះបិតរក៏មានការប្រារព្ធយ៉ាងហ្មត់ចត់ផងដែរ ក្នុងទីក្រុងរបស់រាជាធិរាជ ។ ព្រះរាជាមានភាពហ្មត់ចត់យ៉ាងចម្លែកក្នុងការប្រណិប័តន៍ចំពោះព្រះបិតរ ដើម្បីចម្រើនតុល្យភាពនៃការបានកុសលផលបុណ្យរបស់ព្រះអង្គឯង និងដើម្បីធ្វើជាគំរូនិងជាគ្រូសម្រាប់ប្រជារាស្ត្ររបស់ទ្រង់ ។ ការគោរពបូជាចំពោះកសិកម្ម ផ្ដោតលើទីគោរពបូជានៅខាងក្រៅ ដែលមានរាងបួនជ្រុងស្មើ (ធាតុយិន) ដែលធ្វើដើម្បីឧទ្ទិសបូជាដល់ព្រះភូមនិងព្រះពៃស្រពណ៍ និងរដូវកាលទាំងបួន ។ ព្រះរាជាផ្ទាល់ព្រះអង្គ ជាអ្នកប្រារព្ធពិធីនៅទីនេះរៀងរាល់និទាឃរដូវ រួចហើយបញ្ជាឲ្យមន្ត្រីថ្នាក់ខ្ពស់ភ្ជួររាស់ដីមួយដួរ ដើម្បីធ្វើជានិមិត្តសញ្ញានៃការចាប់ផ្ដើមរដូវកាលកសិកម្មមួយទៀត ។ ស្របពេលជាមួយគ្នានេះដែរ តំណាងរបស់ព្រះរាជាក៏ធ្វើពិធីនេះនៅតាមខេត្តនីមួយៗ ។

មានវិហារសាសនាខុងជឺនៅក្នុងទីក្រុងផង និងនៅតាមខេត្តផងដែរ ។ គេប្រារព្ធធ្វើពិធីខុងជឺពីរដងក្នុងមួយឆ្នាំ គឺក្នុងនិទាឃរដូវ (រដូវស្លឹកឈើលាស់) និងក្នុងសរទរដូវ (រដូវស្លឹកឈើជ្រុះ) ។ ព្រះរាជាធ្វើជារាជាធិបតីក្នុងពិធីទាំងនេះនៅក្នុងរាជធានី ហើយមន្ត្រីខេត្តធ្វើត្រាប់តាមសកម្មភាពរបស់ទ្រង់នៅទូទាំងប្រទេស ។ មានទីសក្ការបូជាបែបនេះនៅក្នុងឃុំជាច្រើន និងនៅក្នុងភូមិមួយចំនួន ដែលមានអ្នកប្រាជ្ញចម្លងនូវក្បួនទាំងនេះ ។

ប្រទេសជាតិទាំងមូល មានការរៀបចំយ៉ាងល្អិតល្អន់ទៅតាមលំដាប់ថ្នាក់ឋានានុក្រម ទៅតាមការចម្លង តាម

ទម្លាប់ក្បួនដូចគ្នានេះ ហើយទម្លាប់ទាំងនេះ គឺជាការចម្លងពីក្រឹត្យក្រមធម្មជាតិរបស់កពផែនដី ។ សទិសភាពនៃសកម្មភាពជានិមិត្តរូបនិងពិធីសាសនានាំឲ្យមានសាមគ្គីភាព នៅក្នុងសង្គមនិងរវាងវណ្ណៈនានា ។ ស្តេចវៀនទ្រង់ឈ្វេងយល់ដឹងយ៉ាងឈ្លាសវៃថា កូនប្រុសដែលយកចិត្តទុកដាក់នឹងករណីយកិច្ចរបស់ខ្លួន នឹងក្លាយទៅជាមន្ត្រីដ៏ស្មោះត្រង់ក្នុងស្រុក ។ ហេតុដូច្នេះហើយ បានជាច្បាប់របស់រដ្ឋដាក់ទោសប្បញ្ញត្តិលើការរំលោភបំពានទៅលើទំនៀមទម្លាប់កាន់ទុក្ខ ហើយជូនជារង្វាន់ដល់ក្រុមគ្រួសារណា ដែលអាចបង្រួបបង្រួមកូនចៅប្រាំជំនាន់នៅក្រោមដំបូលតែមួយបាន ។ ការិយាលយាធិបតេយ្យបានយកទំនៀមទម្លាប់គ្រួសារមកអនុវត្តតាម យ៉ាងហ្មត់ចត់ ដើម្បីពង្រឹងនិងធ្វើសមាហរណកម្មក្រុមគ្រួសារ ដោយការធ្វើឲ្យប្រសើរឡើងនូវអារម្មណ៍ក្នុងចំណោមសមាជិកខ្លួនឲ្យគិតថា ជាសមាជិករបស់មហាគ្រួសារតែមួយ ។

បណ្តាញស្មុគស្មាញបែបឧបមាឧបមេយ្យនៃទំនាក់ទំនងរវាងឪពុកទៅកូន និងពីបងប្រុសទៅប្អូនប្រុស បង្កើតបានជាប្រទេសជាតិ ហើយធាតុផ្សំទាំងឡាយត្រូវបានចងភ្ជាប់គ្នាក្លាយជាកាតព្វកិច្ចទៅវិញទៅមក ។ គ្រួសារនីមួយៗ ប្រៀបដូចជាជាតិតូចមួយដែរ ។ ភូមិគឺជាក្រុមគ្រួសារធំមួយ ។ ការិយាលយាធិបតេយ្យជាតិ ត្រូវបានរៀបចំក្នុងរង្វង់និមិត្តរូបនៃគ្រួសារនេះឯង ។ រចនាសម្ព័ន្ធនីមួយៗ បង្ហាញឲ្យឃើញអំពីគំរូបុរសគល់នៃធាតុយិននិងធាតុយ៉ាំង ហើយរចនាសម្ព័ន្ធទាំងនេះ មានរូបរាងទៅតាម «លី» ដែលជាគំរូវប្បធម៌នៃក្រឹត្យក្រមធម្មជាតិរបស់លោកធាតុ ។ នៅលើកំពូលនៃរចនាសម្ព័ន្ធទាំងនេះ ព្រះរាជាក្លាយជាបដិរូបកម្មនៃក្រឹត្យក្រមសីលធម៌នៅក្នុងសង្គមវៀតណាម ដោយផ្អែកលើការរំលាយបញ្ចូលគ្នានៃទេវកថាជនម្ចាស់ស្រុក ជាមួយនឹងគំនិតតាវនិងគំនិតខុងជឺបែបថ្មី ។ ការទទួលខុសត្រូវសំខាន់បំផុតរបស់ទ្រង់ គឺការខំប្រឹងប្រែងប្រើភាពជាអ្នកដឹកនាំខាងផ្នែកស្មារតីតាមរយៈពិធីបុណ្យនិងតាមរយៈគំរូផ្ទាល់ព្រះអង្គ ។

បន្ទុកដដែលនៃភាពជាអ្នកដឹកនាំខាងផ្នែកសីលធម៌ ស្ថិតមួយកម្រិតនៅលើនាម៉ឺនជាន់ខ្ពស់ លើវរជនភូមិ និងលើមេគ្រួសារ ។ គេគិតថា ពួកគេគួរតែប្រៀនប្រដៅនិងដឹកនាំដោយបង្ហាញនូវឧទាហរណ៍ប្រកបដោយគុណធម៌ ដូចជាឪពុក ឬបងប្រុស ។ មេអង្គភាពរដ្ឋបាលណាក៏ដោយ ត្រូវតែនាំមកនូវភាពសុខដុមរមនានិងវិបុលភាព ជូនវិស័យរបស់ខ្លួន តាមមធ្យោបាយនៃជីវភាពប្រកបដោយគុណធម៌ និងអភិបាលកិច្ចរបស់ខ្លួន ។ ដូច្នេះ ស្រុកមួយ ខេត្តមួយ ចាត់ទុកដូចជាគ្រួសារមួយ ។

ផុតពីក្បួនអធិកអធម និងពិធីដែលគួរឲ្យទាក់ភ្នែក និងការដាក់របាំងនិមិត្តរូបដែលបិទបាំងមន្ត្រី អ្នកប្រាជ្ញនិងព្រះរាជវាំងពីប្រជានុរាស្ត្រនេះទៅ មានប្រព័ន្ធដំណើរការឥតថ្ងៃឡើយ មួយរវាងព្រះរាជានិងប្រជានុរាស្ត្ររបស់ទ្រង់ ។ រដ្ឋអំណាចវៀតណាមសម្រេចបាននូវប្រតិបត្តិការ ដែលមិនចំណាយច្រើននេះ ដោយការគ្រប់គ្រងតាម «អំណាចពិនិត្យផ្ទៀងផ្ទាត់ និងអំណាចបង្ក្រាបជាយថាហេតុ ប៉ុន្តែមិនមែនអំណាចប្រតិបត្តិទេ»[៤៥] ។ រដ្ឋនេះផ្សព្វផ្សាយឧត្តមគតិ តាមរយៈមធ្យោបាយជាច្រើន ត្រួតពិនិត្យកិរិយាមារយាទ និងដាក់ទណ្ឌកម្មលើការប្រព្រឹត្តខុសគន្លង និងខិតខំរក្សាឲ្យបាននូវភាពសុខដុមរមនា ជាមួយនឹងក្រឹត្យក្រមធម្មជាតិ តាមរយៈសកម្មភាពតាមក្បួនពិធីបុណ្យជាទៀងទាត់ ។ ក្រសួងសំខាន់បំផុតរបស់រដ្ឋាភិបាលនេះ មិនមែនក្រសួងយុត្តិធម៌ ក្រសួងហិរញ្ញវត្ថុ ឬក្រសួងការពារជាតិទេ ។ ក្រសួងនេះ គឺជាក្រសួងរីតិ៍ (ក្រសួងពិធីបុណ្យ)[៤៦] ។

ប្រព័ន្ធដំណើរការបែបសន្សំសំចៃនេះ អាចមានទៅបាន ដោយសារតែរដ្ឋមិនពាក់ព័ន្ធដោយផ្ទាល់ជាមួយ

បុគ្គល គ្រួសារ ខ្សែស្រឡាយ ក្រុមតូចៗ ឬអង្គការក្នុងស្រុកណាមួយទេ ។ មន្ត្រីការិយាធិបតេយ្យរបស់រដ្ឋពាក់ព័ន្ធជាមួយនឹងភូមិ ចំណែកឯភូមិខ្លួនឯងផ្ទាល់ ដឹកនាំ សម្របសម្រួល និងគ្រប់គ្រងការប្រព្រឹត្តរបស់អ្នកភូមិ ។ ហើយភូមិខ្លួនឯងផ្ទាល់ ពាក់ព័ន្ធជាមួយគ្រួសារ មិនមែនជាមួយបុគ្គលទេ ។ ក្រុមគ្រួសារទាំងមូល ត្រូវទទួលខុសត្រូវចំពោះការប្រព្រឹត្តរបស់សមាជិកគ្រួសារខ្លួន[៤៧] ។ បុគ្គលក្នុងគ្រួសារត្រូវបានគ្រប់គ្រងយ៉ាងជិតដល់ មិនមែនត្រឹមតែពីសំណាក់មេគ្រួសារម្នាក់ប៉ុណ្ណោះទេ តែពីសមាជិកគ្រួសារទាំងអស់ផង ជាពិសេសពីសំណាក់អ្នកដែលជារៀមច្បងរបស់បុគ្គលនេះ ។ ការប្រព្រឹត្តខ្ពង់ខ្ពស់របស់បុគ្គលម្នាក់ ធ្វើឲ្យឈឺចាប់ដល់មនុស្សរាល់គ្នា ហើយគេគ្រប់គ្នាយល់ដឹងអំពីរឿងនេះ ដូចគ្នានេះដែរ ពួកគេរាល់រូបសុទ្ធតែដឹងថា ក្រុមគ្រួសារទាំងមូលនឹងទទួលប្រយោជន៍ទាំងអស់គ្នា នៅពេលមានសមាជិកគ្រួសារណាម្នាក់ទទួលបានជោគជ័យអ្វីមួយ ។

ដោយសារតែគ្រួសារគ្រប់គ្រងការប្រព្រឹត្តរបស់សមាជិកខ្លួន ក្រុមគ្រួសារដដែលនេះត្រូវបានគ្រប់គ្រងទាំងពីសំណាក់មេភូមិ និងពីមតិសាធារណជន ប្រយោជន៍បំពេញមុខងារតាមមធ្យោបាយមួយ ដែលបង្កើនភាពអាចសម្រេចផលបាន និងកិត្យានុភាពរបស់ភូមិទាំងមូល ។ ទាំងគ្រួសារ ទាំងភូមិ គឺជាសហគមន៍ដែលដំណើរការដូចសហករណ៍ ដែលក្នុងនោះ ផលប្រយោជន៍បុគ្គលស្ថិតនៅក្រោមផលប្រយោជន៍រួម ។ ក្នុងសង្គមបែបនេះ អ្វីដែលពួកបស្ចិមប្រទេសយល់ថា ជាសេរីភាពផ្ទាល់ខ្លួន ត្រូវបានគេបង្ក្រាបយ៉ាងហ្មត់ចត់ដូចអ្វីដែលលោក ពីយែរ ហ្គួរូ (Pierre Gourou) ហៅថា «ការត្រួតត្រាបែបចៅហ្វាយនាយនៃមតិសាធារណៈ ទៅលើជីវិតឯកជនរបស់បុគ្គលម្នាក់ៗ» ។ ក៏ប៉ុន្តែ លក្ខណៈបែបនេះនៅបានផ្តល់ជាកម្លាំងរុញច្រាននិងបានដាក់វិន័យលើយន្តការស្ថាប័ន ដែលពាក់ព័ន្ធនឹងសុខុមាលភាព និងការចែករំលែកធនធាន ។ ពុំសូវមានការបង្ខិតបង្ខំដើម្បីរក្សាទុកប្រព័ន្ធនេះឲ្យនៅដដែលទេ ។ សង្គមបានតម្រូវឲ្យប្រជាជនប្រព្រឹត្តតាមរបៀបនេះ ហើយជីវភាពនៅក្នុងគ្រួសារនិងក្នុងភូមិ មានអត្តសេពន់ប្រមាណ និងធ្វើឲ្យពេញចិត្តពេញថ្លើមក្រៃលែង ។ ប្រជាជនវៀតណាមក្នុងសង្គមបុរាណ ត្រូវបានសង្គមកំណត់មិនឲ្យតស៊ូ ដើម្បីឯករាជភាពបុគ្គលទេ ។ ពួកគេពិតជាបានរៀនសូត្រ ដើម្បីចេះគ្រប់គ្រងនិងឲ្យតម្លៃលើទំនាក់ទំនង ដែលចារឹកដោយការចិញ្ចឹមបីបាច់ ភាពនៅក្នុងចំណុះគេ និងកាតព្វកិច្ចរួម ។ ហើយពួកគេមានមោទនភាពក្នុងការធ្វើតាមបញ្ជារបស់ «ធៀ» ។

## ជោគជ័យនិងបរាជ័យនៃប្រព័ន្ធបែបបុរាណ

រួមសេចក្តីមក គឺជាទស្សនៈរួមជាទូទៅរបស់ពិភពលោក និងប្រព័ន្ធនៃគុណតម្លៃ ដែលធ្វើឲ្យប្រព័ន្ធបែបប្រពៃណីមួយនេះ ដំណើរការទៅបាន ។ ទំនាក់ទំនងគ្រួសារ ការអប់រំក្នុងប្រព័ន្ធប្រពៃណី ទំនៀមទម្លាប់អ្នកស្រុកអក្សរសាស្ត្រតាមតំបន់ដែលលូតលាស់នៅចុង ស.វ. ទី ១៨ និងនៅ ស.វ. ទី ១៩ ដែលបានផ្សព្វផ្សាយពាសពេញផ្ទៃប្រទេស ពីសំណាក់អ្នកនិទានរឿងដែលដើរត្រាច់ចរ និងសារព័ត៌មាន ដែលធ្វើឲ្យមានតុល្យភាពគ្នាយ៉ាងល្អរវាងចំណូលចិត្តរបស់ប្រជាជន និងបញ្ញត្តិរដ្ឋាភិបាល ។ ទាំងអស់នេះសំដៅទៅរកគោលដៅតែមួយ គឺដើម្បីពង្រឹងលោកធាតុរួមមួយ ដែលរចនាសម្ព័ន្ធសង្គមទាំងមូលពឹងផ្អែកទៅលើទស្សនៈជ្រួតជ្រាបមួយនៃក្រឹត្យក្រមធម្មជាតិ ។

នៅចំកណ្តាលនៃទស្សនៈអំពីសាកលលោកនេះ មានសេចក្តីស្នើសុំបង្រួមសំខាន់មួយដែលចែងថា កម្រិត

ដែលគេអនុលោមទៅតាមក្រឹត្យក្រមធម្មជាតិ ទាំងពាក្យពេចន៍ ទាំងអំពើ ត្រូវតែមានផលវិបាកដ៏ជ្រាលជ្រៅនិងមិនអាចជៀសបាន ។ បើសិនជាមានការប្រាសចាកពីតួនាទីនៃការប្រព្រឹត្តត្រឹមត្រូវណាមួយកើតឡើង ក្រឹត្យក្រមធម្មជាតិត្រូវបានរំលោកបំពាន ដូច្នេះត្រូវមានយន្តការប៉ះប៉ូវរៀបចំឲ្យមានតុល្យភាពឡើងវិញ ដែលអាចទុកថាមានតថភាពដូចទំនាញផែនដី ឬពន្លឺព្រះចន្ទ្រដែរ ។ បងប្រុសដែលគេងប្រវ័ញ្ច ភរិយាដែលមិនស្ដាប់បង្គាប់ អាចារ្យលោភលន់ និងអ្នកប្រព្រឹត្តខុសគន្លងសាសនា នាំមកនូវអកុសលកម្មចំពោះខ្លួនឯង ។ ប៉ុន្តែ ជួនកាល ការប្រព្រឹត្តខុសឆ្គង អាចនាំមកនូវអកុសលដល់សមាជិករួមរបស់ក្រុមទាំងអស់ ដ្បិតអ្វីនៅក្នុងក្រុមនេះ គេត្រូវចែករំលែកគ្នា ទាំងការស្ដីបន្ទោស និងការលើកសរសើរផង ។ ផ្ទុយមកវិញ គ្រួសារដែលមានគុណធម៌ ដោយរក្សាបានតាមក្រឹត្យក្រមធម្មជាតិ តាមរយៈតួនាទីនៃការប្រព្រឹត្តត្រឹមត្រូវ តាមរយៈការធ្វើតាម «ហៀវ» និង «ដេ» តាមរយៈភាពស្មោះស្ម័គ្រ និងភាពសប្បុរស ក៏នឹងចម្រុងចម្រើន និងទទួលបានជោគជ័យល្អព្រមទាំងអំណោយដែលសមនឹងទទួលបានពីទេព្ដាទាំងឡាយ ។

លោកធាតុរួមនេះ ដោយរួមផ្សំគ្នាជាមួយបំណងប្រាថ្នាទូទៅដើម្បីកិត្យានុភាព កង្វល់ចង់បានមុខមាត់ និងភាពធាប់រំញោចទៅនឹងការរិះគន់ បានធ្វើឲ្យរបៀបរស់នៅរបស់ជនជាតិវៀតណាមស្ថិតក្នុងក្របខ័ណ្ឌសីលធម៌ដ៏ខ្លាំងក្លាមួយ ។ មតិសាធារណជន ទោះជាពេលខ្លះហាក់ដូចជាមិនគ្រប់គ្រាន់ឬមិនសមស្របក៏ដោយ ក៏នៅតែបានដាក់កំហិតយ៉ាងប្រត្យក្ស ទៅលើការអនុវត្តអំណាចនយោបាយនិងសេដ្ឋកិច្ច ។ ទោះបីជាមានករណីបុគ្គលដែលមានមហិច្ឆតា កាមតណ្ហា អាត្មានិយម ជាច្រើនយ៉ាងណាក៏ដោយ ក៏សង្គមអាចរក្សាបាននូវសមត្ថភាពដើម្បីកែតម្រូវខ្លួនឯង គឺនៅក្នុងន័យរបស់ប្រព័ន្ធមួយដែលផ្ដោតលើគុណតម្លៃ ការកែតម្រូវខ្លួនឯង និងការគ្រប់គ្រងបញ្ហាខ្លួនឯង ។

នៅទីបំផុត ប្រព័ន្ធនេះបានបរាជ័យ ប្រហែលជាដោយសារតែជាផ្នែកមួយនៃការផ្ដោតខ្លាំងជ្រុលពេកលើធាតុយ៉ាំងនៃរាជវង្សង្វៀន ។ កាលដើមពាក់កណ្ដាលសតវត្សរ៍ទី ១៩ មានកើតឡើងនូវការបះបោររបស់កសិករជាច្រើន ។ អំពើពុករលួយ ភាពក្រីក្រ និងភាពអយុត្តិធម៌ បានបង្ខិនបង្ខោចប្រទេស ។ ហើយពួកបារាំងសែសបានដាក់អាណានិគមលើប្រទេសវៀតណាម ។ ជាយូរទសវត្សរ៍ គេនិយមស្ដីបន្ទោសប្រព័ន្ធវប្បធម៌វៀតណាមបែបបុរាណ ដូចបានពិព័ណ៌នាខាងលើថាជា «ប្រព័ន្ធសក្តិភូមិ» «អបិយជំនឿ» និងឧបករណ៍មួយ ដែលពួកវរជននាំគ្នាយកមកប្រើ ដើម្បីកេងប្រវ័ញ្ចជិះជាន់លើវណ្ណៈតូចទាប ។ យើងមិនគួរឲ្យការបរាជ័យនិងកង្វះខាតដែលឥតសង្ស័យនៃប្រព័ន្ធប្រពៃណីនោះ ធ្វើឲ្យយើងមើលមិនឃើញនូវអំណាចនៃភាពសមហេតុផលរបស់ប្រព័ន្ធនេះ ឬវិសាលភាពដែលប្រព័ន្ធនេះបានជ្រាបចូលនិងបន្តមាននៅក្នុងកម្រិតជ្រៅបំផុតនៃវប្បធម៌វៀតណាមនោះឡើយ ។

សូម្បីតែបច្ចុប្បន្ននេះ គ្មាននរណាម្នាក់អាចយល់ដឹងបានស៊ីជម្រៅអំពីការប្រព្រឹត្តរបស់ប្រជាជនវៀតណាមនាពេលសព្វថ្ងៃបានទេ ប្រសិនបើពួកគេមិនបានខិតខំត្រិះរិះពិចារណាទៅលើវប្បធម៌ប្រជាជនវៀតណាមបែបប្រពៃណីទេនោះ ។ ប្រសិនបើពួកអាមេរិកាំងចង់យល់ដឹងអំពីសោកនាដកម្មដែលកើតមាននៅប្រទេសវៀតណាមពីទសវត្សរ៍ឆ្នាំ ១៩៥០ ដល់ ១៩៧០ ហើយដែលពួកគេបានចូលស្លុងនោះ ពួកគេត្រូវតែចាប់ផ្ដើមយល់ថា ប្រទេសវៀតណាមនាស.វ. ទី ២០នេះ មានការប្រាធាំងគ្នារវាងចាស់និងថ្មី រវាងប្រតិកម្មផ្សេងគ្នាចំពោះបរាជ័យនៃប្រព័ន្ធវប្បធម៌បុរាណ និងការរក្សាបាននូវមរតកវប្បធម៌នេះ នៅក្នុងចិត្តនិងផ្នត់គំនិតរបស់ប្រជាជនវៀតណាម រួមទាំងអ្នកទាំងឡាយដែលអំពាវនាវខ្លាំង ឲ្យបោះបង់ប្រព័ន្ធនេះចោលផងដែរ ៕

# ជំពូកទី ៥

# អត្ថបទស្រាវជ្រាវ

## ទស្សនៈរបស់ខ្មែរចំពោះជនជាតិភាគតិចវៀតណាម

ស្រាវជ្រាវនិងនិពន្ធដោយ ៖ ឈាត ស្រ៊ាង

*ជានិស្សិតចូលរួមក្នុងកម្មវិធី* **បណ្តុះបណ្តាលសម្ភាពថ្នាក់ឧត្តមសិក្សា** *ជំនាន់ទី ១ ដែលរៀបចំដោយ មជ្ឈមណ្ឌលខេមរសិក្សា ក្រោមការជួយឧបត្ថម្ភពីមូលនិធិ ”ក្ហឺហ្វល័រ ។*

# ជំពូកទី ៥
# ទស្សនៈរបស់ខ្មែរចំពោះជនជាតិភាគតិចវៀតណាម

សេចក្តីថ្លែងអំណរគុណ ៖ ការសិក្សានេះពុំអាចធ្វើទៅបាន ប្រសិនបើពុំមានការជួយជ្រោមជ្រែង និងការលើកទឹកចិត្តពីសំណាក់មនុស្សមួយចំនួននោះ ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះមជ្ឈមណ្ឌលខេមរសិក្សា ដែលបានអនុញ្ញាតឲ្យចូលរួមក្នុងកម្មវិធីចំនួនពីរ ដែលត្រូវដាក់ជូននូវអត្ថបទស្រាវជ្រាវនេះ ។ ជាបឋម ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក ហ្វីលីព្ព ប៉ីកាំ (Philippe Peycam) នាយកមជ្ឈមណ្ឌលខេមរសិក្សា ដែលតែងផ្តល់ការលើកទឹកចិត្ត និងការគាំទ្ររហូតមក និងលោក ម៉ែន ឈានរិទ្ធី ប្រធានកម្មវិធីកសាងសមត្ថភាពសម្រាប់ការផ្តល់យោបល់និងលើកទឹកចិត្តឥតដាច់ ។ ទី ២ ខ្ញុំសូមសម្តែងនូវកតញ្ញុតាធម៌ចំពោះលោក ដឹងខិន ម៉ាក់ខារហ្គូ (Duncan McCargo) ដែលបានផ្តល់នូវគតិបញ្ញានិងពេលវេលារបស់លោកក្នុងការជួយរៀបចំការស្រាវជ្រាវនេះ ។ ទី ៣ ខ្ញុំក៏សូមបង្ហាញនូវការដឹងគុណចំពោះអ្នកស្រី ល័ក្ខធីណា អូលីយេ៉រ៍ (Tina Ollier) ប្រធានកម្មវិធីស្រាវជ្រាវសម្រាប់យុវជន, លោក ភីថឺរ ចេ. ហាំម៉ឺរ (Peter J. Hammer) អ្នកស្រាវជ្រាវជាន់ខ្ពស់ និងអ្នកស្រាវជ្រាវជាន់ខ្ពស់ដទៃទៀត នៅមជ្ឈមណ្ឌល ដែលបានផ្តល់នូវការណែនាំ ។ ទី ៤ ខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកស្រី ម៉ែនឌី សាំម៉ឺរស្កែលស៍ (Mandy Summerscales) ទីប្រឹក្សាបណ្ណាល័យ ដែលបានផ្តល់ដំបូន្មានខ្លះ។ លើផ្នែកភាសាអង់គ្លេស, អ្នកស្រី ម៉ម វណ្ណារី បណ្ណារក្ស ដែលបានផ្តល់នូវសេវាកម្មដ៏ប្រពៃ និងព្រមទាំងបុគ្គលិកដទៃទៀត ដែលបានផ្តល់នូវការងាយស្រួលសម្រាប់ការសិក្សានេះ ។ ជាចុងក្រោយ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បណ្ណារក្សបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ដែលបានផ្តល់នូវការអនុញ្ញាតពិសេសក្នុងការប្រើប្រាស់ឯកសារនៅទីនោះ ។

## មូលន័យសង្ខេប

*អត្ថបទនេះមានបំណងស្វែងរកឫសគល់នៃការយល់ឃើញរបស់ប្រជាជនខ្មែរ ចំពោះជនភាគតិចវៀតណាម ដែលរស់នៅក្នុងប្រទេសកម្ពុជា ។ ប្រាកដណាស់ថា ព័ត៌មានដែលថា ជនជាតិវៀតណាមធ្វើអំពើអាក្រក់នៅក្នុងប្រទេសកម្ពុជានិងចំពោះប្រជាជនខ្មែរ មិនមានអ្វីថ្មីនោះទេ ។ សច្ចភាពទោះយ៉ាងណា មានភាពមិនច្បាស់លាស់ ។ ដោយសារមូលហេតុដូច្នេះហើយ ការស្រាវជ្រាវនេះបានប្រើប្រាស់ការសិក្សាលើឯកសារបោះពុម្ព ដែលមានស្រាប់ ទាក់ទងនឹងប្រធានបទ សារព័ត៌មាន និងការសម្ភាសជាមួយនឹងមនុស្សមកពីក្រុមសាសន៍ទាំងពីរ ។ ការសម្ភាសធ្វើឡើងជាមួយនឹងប្រជាជនខ្មែរ ១២ នាក់ និងវៀតណាម ៩នាក់ ភេទប្រុសស្រី ដែលរស់នៅភ្នំពេញនិងសៀមរាប និងមានអាយុព្រមទាំងការងារខុសគ្នា ។ ការសិក្សាអាចធ្វើសេចក្តីសន្និដ្ឋានថា ប្រវត្តិនៃទំនាក់ទំនងមិនស្មើភាពគ្នារវាងសាសន៍ទាំងពីរ ព្រឹត្តិការណ៍ដែលកំពុងកើតមានជាថ្មី ដែលរួមមានការហូរចូលរបស់អន្តោប្រវេសន៍វៀតណាម និងការរំលោភព្រំដែន រួមទាំងបរាជ័យរបស់រដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាទាំងនេះ ពិតជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឲ្យមានភាពល្អក់កករក្នុងអារម្មណ៍ខ្មែរចំពោះជនជាតិវៀតណាម ។ ជាតិវៀតណាមដែលគេស្អប់ជនជាតិខ្មែរចូលចិត្តប្រើពាក្យ «យួន» ហើយពាក្យនេះត្រូវបានជនជាតិទាំងពីរក្រុមយល់ស្របគ្នាថា មានន័យជេរប្រមាថប្រកបដោយអវិភាពនិងមិនពីរោះស្តាប់ឡើយ ។*

## សេចក្តីផ្តើម

*មានពាក្យចចាមអារ៉ាមជារឿយៗ និយាយអំពីជនជាតិវៀតណាមធ្វើអំពើអាក្រក់ក្នុងប្រទេសកម្ពុជា និងចំពោះជនជាតិខ្មែរ ។ ជួនកាលគេចោទថា ជនជាតិវៀតណាមដាក់ថ្នាំបំពុលក្នុងទឹក ឬដុតបំផ្លាញជម្រកអនាធិបតេយ្យនៅទីក្រុងភ្នំពេញជាដើម (***រស្មីកម្ពុជា*** លេខ ២៥៥៨ ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០០១) ។ ជាមួយនេះ គេក៏តែងមានឃោសនាប្រឆាំងនឹងវៀតណាមពីសំណាក់ក្រុមបក្សប្រឆាំងផងដែរ ។ ការប្រើប្រាស់វោហារសាស្ត្រនយោបាយប្រឆាំងនឹងវៀតណាមនេះ ធ្វើឡើងក្នុងបំណងទាក់ទាញអារម្មណ៍ប្រជាជនខ្មែរឲ្យយកចិត្តទុកដាក់លើវត្តមានរបស់ជនជាតិវៀតណាមក្នុងប្រទេស ហើយជួនកាល ក៏បណ្តាលឲ្យមានការពុំជឿទុកចិត្តគ្នា អរិភាព អំពើឃាតកម្មទៀតផង ។ ហេតុដូច្នេះហើយ គេអាចលើកជាសំណួរថា «តើអ្វីជាឫសគល់នៃឧបទ្ទវហេតុសង្គមនេះ?» ដែលជាសំណួរនឹងត្រូវឆ្លើយក្នុងអត្ថបទស្រាវជ្រាវនេះ ។*

*ដើម្បីឆ្លើយនឹងសំណួរនេះ គេចាំបាច់ត្រូវក្រឡេកមើលប្រវត្តិសាស្ត្រថ្មីៗ អំពីទំនាក់ទំនងរវាងប្រទេសទាំងពីរ ។ គេក៏ត្រូវចាប់អារម្មណ៍ផងដែរលើប្រវត្តិនៃការធ្វើអន្តោប្រវេសន៍ និងការឈ្លានពានព្រំដែនខ្មែរពីសំណាក់វៀតណាម ហើយម្យ៉ាងទៀត លើកង្វះសមត្ថភាពរបស់គណបក្សកាន់អំណាចនៅកម្ពុជា ក្នុងការដោះស្រាយបញ្ហារសើបទាំងនេះ ។ ចំណុចទាំងនេះ នឹងត្រូវលើកយកមកពិភាក្សាជាបន្តបន្ទាប់ ។ ផ្នែកទី ១ នៃអត្ថបទនេះ នឹងផ្តោតលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយចំនួន ដែលទាក់ទងទៅនឹងទំនាក់ទំនងរវាងប្រទេសទាំងពីរ ទំនាក់ទំនងដែលតែងបណ្តាលឲ្យប្រជាជនកម្ពុជាជួបប្រទះនូវជីវិតដ៏លំបាកវេទនា និងដែលគេមិនអាចបំភ្លេចបាន ។ ភាពក្រៀមក្រំនិងទុក្ខសោកទាំងនេះ ដែលតែងចម្លងពីមួយជំនាន់ទៅមួយជំនាន់តាមរយៈការនិទានតគ្នា ឬសាលារៀន តែងតែធ្វើឲ្យជនរួមជាតិ រួមប្រវត្តិសាស្ត្រនិងវប្បធម៌ មានកំហឹង*(១) *។*

*មន្ទិលសង្ស័យដែលមានកប់ក្នុងប្រវត្តិសាស្ត្រនិងវប្បធម៌នេះ ត្រូវបានធ្វើឲ្យកាន់តែរីកធំឡើង ដោយសារនយោបាយកម្ពុជា ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការបណ្តាលឲ្យមានអសន្តិសុខខួរក្បាល និងដែលជាប្រធានបទសម្រាប់ការពិភាក្សានៅក្នុងផ្នែកទី ២ ។ បញ្ហាមិនចេះចប់អំពីរឿងព្រំដែន ការហូរចូលនៃអន្តោប្រវេសន៍វៀតណាម និងអសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការរកដំណោះស្រាយសមស្រប ដែលមនុស្សមួយចំនួនភ័យខ្លាចអំពីការបាត់បង់នូវអត្តសញ្ញាណជាតិខ្លួននោះ នឹងត្រូវលើកយកមកពិភាក្សា ។ បរាជ័យរបស់រដ្ឋាភិបាលនេះ បានផ្តល់នូវបរិយាកាសកាន់តែទូលាយដល់គណបក្សប្រឆាំង ក្នុងការប្រើប្រាស់វោហារសាស្ត្រប្រឆាំងនឹងវៀតណាមជាផ្នែកដ៏គួរឲ្យទាក់ទាញមួយក្នុងកម្មវិធីនយោបាយរបស់គេ ។ ក្នុងន័យនេះ ប្រជាជនដែលមានការស្អប់ខ្ពើមជាប់ខ្លួនរហូតមក ត្រូវបានអ្នកនយោបាយដឹកនាំឲ្យឈានទៅរកការធ្វើឲ្យល្អក់កករនូវទំនាក់ទំនងរវាងក្រុមជនជាតិទាំងពីរ ទោះជាអ្នកនោះចង់ឬមិនចង់ក៏ដោយ ។ បន្ថែមលើនេះទៀត ភាពខុសគ្នាផ្នែកវប្បធម៌ ដែលតែងតែធ្វើឲ្យមានការរំខានចំពោះគ្នាទៅវិញទៅមក នឹងត្រូវយកមកសិក្សាក្នុងជំពូកចុងក្រោយ ដើម្បីរកឲ្យឃើញនូវតួនាទីរបស់វាក្នុងបញ្ហានេះ ។*

*អ្នកទាំងឡាយណា ដែលមានខ្សែស្រឡាយជាវៀតណាមរស់នៅក្នុងប្រទេសកម្ពុជា មិនថាអ្នកនោះមានកំណើតក្នុងប្រទេស ឬធ្វើអន្តោប្រវេសន៍មកពីណាមកនោះទេ តែងតែត្រូវបានចាត់ទុកដោយប្រជាជនខ្មែរថា*

ជាជនអន្តោប្រវេសន៍វៀតណាម ។ ការធ្វើចំណាត់ថ្នាក់មិនមានភាពច្បាស់លាស់នោះទេ ។ អ្នកខ្លះបែងចែកជនជាតិវៀតណាមរស់នៅក្នុងប្រទេសកម្ពុជាជាបីក្រុម ដោយផ្អែកជាមូលដ្ឋានលើរយៈពេលដែលគេរស់នៅក្នុងនោះ រួមមាន អ្នករស់នៅទីនេះរាប់ជំនាន់មកហើយនិងដែលអាចនិយាយភាសាខ្មែរបានយ៉ាងល្អ អ្នកដែលមកតាំងលំនៅតាមជនជាតិវៀតណាមដែលវិលមកកម្ពុជាវិញក្រោយឆ្នាំ ១៩៧៩ និងអ្នកចូលមកក្នុងប្រទេសកម្ពុជាក្នុងបំណងធ្វើជំនួញក្នុងរយៈពេលកំណត់មួយ ។ អ្នកខ្លះទៀត គ្រាន់តែបែងចែករវាងអ្នករស់នៅយូរនិងអ្នកទើបមកដល់ថ្មីប៉ុណ្ណោះ (ប៉ែត្រូន៍ជ៍ ១៩៩៦) ។ ពាក្យ «វៀតណាម» និង «អន្តោប្រវេសន៍» មានន័យដូចគ្នាក្នុងអត្ថបទនេះ សំដៅទៅលើអ្នកដែលមានខ្សែស្រឡាយវៀតណាម ព្រោះថាប្រជាជនខ្មែរមិនបានចាប់អារម្មណ៍អំពីឋានៈខុសគ្នានៃជនជាតិវៀតណាមទាំងនោះទេ ។

ដូច្នេះ ជនជាតិវៀតណាមមួយណាក៏ដោយ អាចជាគោលដៅនៃការប្រកាន់ពូជសាសន៍ ។ ចំណុចសំខាន់គឺថា ការពុំជឿទុកចិត្តនិងស្អប់ខ្ពើមជនជាតិភាគតិចវៀតណាមទាំងមូល ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមប្រព័ន្ធផ្សព្វផ្សាយនិងជ្រាបចូលក្នុងបេះដូងប្រជាជនខ្មែរ ។ ដោយសារមូលហេតុនេះហើយ សារព័ត៌មាននិងបទសម្ភាសជាប្រភពចម្បងពីរ សម្រាប់ការសិក្សានេះ ។ បទសម្ភាសត្រូវបានធ្វើឡើងភាគច្រើនជាក្រុមពិភាក្សា ព្រោះថា ការសម្ភាសម្នាក់ទល់ម្នាក់ពុំបានផ្តល់ផ្លែផ្កាល្អសម្រាប់ការសិក្សាប្រភេទនេះឡើយ ។ អ្នកផ្តល់សម្ភាស រួមមានខ្មែរចំនួន ១២ នាក់ដែលមានអាយុចម្រុះនិងទាំងពីរភេទ និងជនជាតិវៀតណាមចំនួន ៩ នាក់ដែលតាំងលំនៅនៅភ្នំពេញនិងសៀមរាប ។ ខ្ញុំក៏សូមសារភាពថា ការសិក្សានេះដែលមានទំហំធំនិងលំបាកសម្រេចឲ្យបានរួចហើយនោះ បានជួបប្រទះនូវការលំបាកមួយចំនួនក្នុងការស្វែងរកចម្លើយអវិជ្ជមាន ដែលវៀតណាមមានចំពោះជនជាតិខ្មែរ ទោះជាជនអន្តោប្រវេសន៍មួយចំនួន ពិតជាមានការយល់ឃើញដូច្នេះក៏ដោយ ។ ផ្ទុយទៅវិញ យើងបានរកឃើញជារឿយៗ នូវការយល់ឃើញអវិជ្ជមានរបស់ប្រជាជនខ្មែរចំពោះជនជាតិវៀតណាម ទាំងក្នុងកិច្ចសម្ភាស ទាំងក្នុងសារព័ត៌មាន ។

## ការមិនជឿទុកចិត្តដែលប្រវត្តិសាស្ត្រចាក់បញ្ឆេះទុក

ជំពូកនេះនឹងបង្ហាញថា តើប្រវត្តិសាស្ត្រទាក់ទងនឹងមតិជាតិនិយមរបស់ខ្មែរ មានឥទ្ធិពលយ៉ាងណាលើការយល់ឃើញរបស់ប្រជាជនចំពោះអ្នកជិតខាងវៀតណាម ។ អតីតកាលបានកន្លងផុតទៅក៏ពិតមែន ប៉ុន្តែស្រមោលអន្ធកាលរបស់អតីតកាលនេះ នៅតែតាមលងប្រជាជនខ្មែរគ្រប់រូប ពិសេសអ្នកដែលបានទទួលការសិក្សាយ៉ាងហោចថ្នាក់មធ្យមសិក្សាកម្រិត ១ និងអ្នកដែលបានឆ្លងកាត់ផ្ទាល់នូវភាពសាហាវយង់ឃ្នង ដែលវៀតណាមបានប្រព្រឹត្ត ។ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទាំងនេះបានកំណត់នូវគំនិតអវិជ្ជមានរបស់អ្នកជាតិនិយមខ្មែរ និងប្រជាជនសាមញ្ញចំពោះជនជាតិវៀតណាម ។ ទស្សនៈរបស់ខ្មែរយល់ឃើញថា ពេលវេលាមិនដើរហួសផុតពីវដ្តរបស់ខ្លួនឡើយ (មេរៀនរបស់លោក គីថឺរ ហាំម៉ឺរ ១៨ កក្កដា ២០០៥) ។ ក្នុងន័យនេះ អតីតកាលមិនគ្រាន់តែកន្លងផុតទៅធម្មតានោះទេ ប៉ុន្តែវាអាចប្រតិស្ឋានជាថ្មីម្តងទៀតគ្រប់កាលទាំងអស់ ។

## មេរៀនដែលគេពុំដែលបំភ្លេច

*អតីតកាលគឺពិតជាមេរៀនដ៏ល្អដែលគួររៀនសូត្រ ។ ប្រជាជនគ្រប់រូបព្យាយាមចងចាំ មិនត្រឹមតែភាពល្បីល្បាញដែលបុព្វបុរសរបស់ខ្លួនបានបន្សល់ទុកនោះទេ ប៉ុន្តែថែមទាំងបទពិសោធន៍ប្រកបដោយទុក្ខវេទនាទាំងឡាយដែលពួកគាត់បានជួបប្រទះក្នុងបំណងចៀសវាងឲ្យផុតទៅថ្ងៃមុខ ។ ល្បែងនយោបាយដែលកម្ពុជាតែងតែចាញ់បានធ្វើឲ្យប៉ះពាល់យ៉ាងមហិមាលើការគិតរបស់ខ្មែរចំពោះភាគីមួយទៀតដែលពាក់ព័ន្ធ ។ អ្នកជាតិនិយមដែលបានចាប់កំណើតឡើងយ៉ាងហោចណាស់នៅទសវត្សរ៍ឆ្នាំ ១៩៣០ និងដែលឈានដល់កំពូលនៅទសវត្សរ៍ឆ្នាំ ១៩៧០ បានចាប់ផ្តើមបង្កើតកំហឹងក្នុងខ្លួនប្រជាជនខ្មែរ ដោយប្រើប្រាស់វោហារសាស្ត្រនយោបាយរបស់គេ ដែលទាក់ទងនឹងទំនាក់ទំនងពីអតីតកាលរវាងប្រជាជាតិទាំងពីរ ។ ការសិក្សាប្រវត្តិសាស្ត្រមិនមានបំណងលើកទឹកចិត្តឲ្យមានការស្អប់ខ្ពើម ឬវិនិច្ឆ័យឲ្យឃើញថា អ្នកណាត្រូវអ្នកណាខុសនោះទេ តែជាការប្រឹងប្រែងដើម្បីយល់ឲ្យកាន់តែច្បាស់អំពីអតីតកាលប៉ុណ្ណោះ ។ តែទោះយ៉ាងណាជាមួយគ្នានេះ វាក៏បានបង្កើតឲ្យមានការយល់ឃើញអវិជ្ជមានលើភាគីម្ខាងទៀត ដែលទទួលជ័យជំនះ និងដែលបានធ្វើឲ្យខូចខាំនូវអត្តសញ្ញាណជាតិនិងសេចក្តីថ្លៃថ្នូររបស់គេ ដូចលោក នួន ឃឿន (១៩៨៩: ក) បានអះអាងថា ÷*

> « គឺអំពើ ឬព្រឹត្តិការណ៍ [ប្រវត្តិសាស្ត្រ] ទាំងនេះហើយ ដែលបង្កើតនូវសម្បជញ្ញៈខ្មែរ ។ ជនជាតិខ្មែរសម័យនេះ ជាលទ្ធផលនៃអតីតកាល ឬជាលទ្ធផលនៃសម្បជញ្ញៈខ្មែរនេះឯង» ។

*នៅពេលជាមួយនោះ ប្រជាជនចាប់ផ្តើមគាស់កកាយទំនាក់ទំនងពីអតីតកាល រវាងប្រទេសទាំងពីរ ពេលសង្គ្រាមត្រជាក់ឡើងដល់កម្រិតកំពូលក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ ដើម្បីធ្វើឲ្យអ្នកស្នេហាជាតិទាំងឡាយប្រុងប្រយ័ត្នចំពោះអ្នកជិតខាងរបស់ខ្លួន ។ ការនិយាយតៗ គ្នាអំពីភាពឃោឃៅរបស់ទាហានវៀតណាម ក្នុងរយៈពេលនៃការពង្រីកអំណាចរបស់គេលើកម្ពុជាក្នុងសតវត្សរ៍ទី ១៧ និង ១៨ កាន់តែមានសភាពតឹងតែងនៅពេលមានការរីកសាយភាយរបស់កងទ័ពវៀតណាមមកក្នុងទឹកដីកម្ពុជាក្នុងសង្គ្រាមវៀតណាម (គ.ស. ១៩៤៥-១៩៧៥) ។ មុននោះ ប្រជាជនធ្លាប់រងគ្រោះពីការបង្ខិតបង្ខំយ៉ាងសាហាវព្រៃផ្សៃ ឲ្យជីកទំនប់ព្រែកវិញតេ (ធាណ្ឌលរ័ ២០០៥: ១២៩) ដោយនៅពេលនោះ ទាហានយួនបានបើកទ្វារទឹកយ៉ាងតក់ក្រហល់ ដោយពុំបានឲ្យដំណឹងដល់កម្មករខ្មែរជាមុន និងបណ្តាលឲ្យមានការបាត់បង់ជីវិតជាច្រើន ។ លើសពីនេះទៀត យួនចោទថា កម្មករខ្មែរខ្ជិលច្រអូស ពួកទាហានយួនបានកប់ខ្មែរទាំងរស់ និងយកក្បាលខ្មែរមកធ្វើជាកំណល់ជើងក្រានដាំតែ ។ ទាំងនេះសុទ្ធតែជាបទពិសោធន៍ដែលមិនអាចបំភ្លេចបាន ហើយដែលប្រជាជនខ្មែរតែងព្យាយាមនិទានតៗ ឲ្យអ្នកជំនាន់ក្រោយស្តាប់ (ហ៊ុិន ស៊ីថាន គ្មានកាលបរិច្ឆេទ ទំព័រទី ១៤៥-៥២) និងដែលតែងធ្វើឲ្យយុវជនមានកំហឹង ។ ពេលសួរថា តើគាត់មានអារម្មណ៍យ៉ាងណាចំពោះវៀតណាម អ្នករត់ម៉ូតូម្នាក់បាននិយាយថា «មិនស្អប់វៀតណាមទេ ប៉ុន្តែស្អប់យួនដែលបង្ខំឲ្យប្រជាជនខ្មែរជីកព្រែក»[២] ។*

*ប្រវត្តិនៃការជីកព្រែកនេះ កើតឡើងក្នុងអំឡុងជាយវៀត (ប្រទេសយួន) ដាក់អាណាព្យាបាលលើប្រទេសកម្ពុជា ជាលើកដំបូងនៅពាក់កណ្តាលទី ១ នៃសតវត្សរ៍ទី ១៩ ។ នៅពេលនោះ ពេលប្រទេសអណ្ណាមមានការរីកចម្រើនខ្លាំង គេក៏បានបន្តការឈ្លានពានប្រទេសខ្មែរពីទិសបូព៌ាមក ។ ក្នុងចន្លោះឆ្នាំ ១៨៣៥-១៨៤០ អុង ឡឿង*

មិញយ៉ាង មេបញ្ជាការយោធាយួន ដែលស្ថិតក្រោមការបញ្ជាផ្ទាល់ពីព្រះចៅយ៉ាឡុង នៅក្រុងហ្វេ បានដឹកនាំទ័ពឈ្លានពានប្រទេសខ្មែរក្នុងបេសកកម្មមួយដែលគេឲ្យឈ្មោះថា «បេសកកម្មបណ្ដុះបណ្ដាលអរិយធម៌» ឬដូចដែលលោក ឆាណ្ឌល័រហៅថា បេសកកម្ម «វៀតណាមភាវូបនីយកម្ម» ។ យួនមិនបានស្ដារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលខូចខ្ទាំដោយសារសង្គ្រាមគេវាយជាមួយសៀមនោះទេ ហើយព្រះពុទ្ធសាសនាដែលជាជំនឿធំរបស់ខ្មែរក៏គេមិនខ្វល់នឹងយកចិត្តទុកដាក់កសាងឡើងវិញដែរ ។ ផ្ទុយទៅវិញ គេបានចាប់ផ្ដើមសាបព្រោះឲ្យមានការប្រតិបត្តិប្រពៃណីវប្បធម៌យួន ។ ជាលទ្ធផល ប្រជាជនខ្មែរជំច្រើនក្រោមការដឹកនាំរបស់អតីតព្រះសង្ឃមួយចំនួន បានក្រោកឡើងវាយប្រឆាំងនឹងសត្រូវយួន (ឆាណ្ឌលរ័ ២០០៥ : ១២៩-៤៥) ។ ការបំផ្លិចបំផ្លាញលើសាសនានិងការគាបសង្កត់អសីលធម៌ទាំងនេះ ត្រូវបានចាស់ៗ ជំនាន់មុននិទានតៗ គ្នា និងចារនៅក្នុងសៀវភៅប្រវត្តិសាស្ត្រទៀតផង (ត្រឹង ងា ១៩៧៤ : ១៥២-១៥៣) ដែលក្មេងជំនាន់ក្រោយអាចរៀនសូត្រនិងចែករំលែកទុក្ខវេទនាទាំងនោះបាន ។

ក្រោយពីបេសកកម្មបណ្ដុះបណ្ដាលអរិយធម៌របស់វៀតណាម ប្រទេសកម្ពុជាបានក្លាយជាកន្លែងមួយដែលអាណានិគមបារាំងសែសមានបំណងសាបព្រោះអរិយធម៌របស់គេម្ដង ។ ដោយសារតែការសម្រេចចិត្តរបស់បារាំងក្នុងការដាក់ប្រទេសកម្ពុជាក្នុងអាណាព្យាបាលរបស់គេ ព្រោះថាប្រសិនបើមិនដូច្នោះទេ ប្រហែលជាពុំមានប្រទេសកម្ពុជាសព្វថ្ងៃលើផែនទីពិភពលោកសម័យទំនើបនេះទេ ។ ប៉ុន្តែទោះយ៉ាងណា ចំណូលចិត្តរបស់បារាំងក្នុងការប្រើប្រាស់កម្លាំងពលកម្មវៀតណាមក្នុងរដ្ឋបាលរបស់គេនៅកម្ពុជា (ថ្យុង ១៩៩៣ : ២៣០-៣៥) និងសេចក្ដីសម្រេចចិត្តក្នុងឆ្នាំ ១៩៤៩ ដើម្បីភ្ជាប់បណ្ដាខេត្តខ្មែរភាគខាងត្បូងទាំងឡាយទៅឲ្យប្រទេសវៀតណាម មិនបានធ្វើឲ្យខ្មែរសប្បាយចិត្តនោះទេ ។ ជនជាតិខ្មែរដែលរស់នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន និងអ្នករស់នៅជាជនជាតិភាគតិចលើទឹកដីរបស់ខ្លួននៅកូសាំងស៊ីន មិនបានយល់ស្របនឹងការសម្រេចដែលមានលក្ខណៈនយោបាយនោះទេ ប៉ុន្តែពួកគេពុំមានជម្រើសអ្វីផ្សេងទៀតឡើយ ។ ផលលំបាកនៃមរតកអាណានិគមទាំងនោះ នៅតែមានជីវិតយ៉ាងប្រត្យក្សរហូតមកដល់សព្វថ្ងៃនេះ ។

ជនជាតិភាគតិចខ្មែរនៅវៀតណាមខាងត្បូង ត្រូវពុះពារគ្រប់បែបយ៉ាងសម្រាប់ការរស់នៅរបស់ពួកគេក្រោមសេរីភាពដ៏តូចចង្អៀតក្នុងការប្រតិបត្តិសិទ្ធិនិងជំនឿសាសនា ។ ពួកគេត្រូវស្ថិតក្រោមការគ្រប់គ្រងដ៏តឹងរ៉ឹងពីសំណាក់មន្ត្រីបក្សថ្នាក់មូលដ្ឋាន ហើយការប្រមូលផ្ដុំផ្សេងៗ ត្រូវមានការអនុញ្ញាតនិងត្រួតពិនិត្យយ៉ាងហ្មត់ចត់ពីសំណាក់មន្ត្រីបក្ស[៣] ។ នេះមិនមែនជារឿងថ្មីនោះទេ ។ នៅសម័យអាណានិគមនិយមបារាំង ខ្មែរក្រោមមិនត្រូវបានអនុញ្ញាតឲ្យប្រតិបត្តិជំនឿដូចខ្មែរកណ្ដាលឡើយ[៤] ។ ជាក់ស្ដែង នៅចុងទសវត្សរ៍ឆ្នាំ ១៩២០ ក្នុងដំណើរទស្សនកិច្ចរបស់ព្រះសង្ឃខ្មែរទៅកូសាំងស៊ីន ព្រះសង្ឃជាម្ចាស់ផ្ទះបានស្នើសេចក្ដីអនុញ្ញាតពីទេសាភិបាលកូសាំងស៊ីនឲ្យខ្មែរប្រតិបត្តិជំនឿជាប្រពៃណីរបស់ខ្លួន ដូចជា ពិធីបុណ្យសព និងសកម្មភាពព្រះពុទ្ធសាសនាផ្សេងៗ ដូចដែលធ្លាប់មានរហូតមក (**កម្ពុជសុរិយា** ១៩២៩) ។ ក្នុងកិច្ចខិតខំប្រឹងប្រែងតវ៉ាដើម្បីសេរីភាព សិទ្ធិមនុស្ស និងសាសនា ព្រះសង្ឃជួនកាលជុតខ្លួនឯង ដែលជាសកម្មភាពនយោបាយល្បីល្បាញដែលមានបន្តរហូតមកដល់ពេលថ្មីៗ នេះ ។ លោក សាំង ម៉ាកសាង (១៩៧៣ : ១-១០០) បានរំលឹកឡើងវិញនូវទុក្ខវេទនាដែលជនជាតិខ្មែរភាគតិចនៅវៀតណាមបានពើបប្រទះ ។ គាត់សង្កត់ធ្ងន់ថា ជនជាតិភាគតិចខ្មែរខុសពីក្រុមជនជាតិភាគតិចដទៃ

*ត្រូវប្រឈមមុខនឹងការប្រកាន់ពូជសាសន៍ ការធ្វើទារុណកម្ម និងចាប់រំលោភពីសំណាក់វៀតណាម និងដុតខ្លួនឯងជាដើម ។ ជារួម គាត់ចង់បង្ហាញប្រាប់ថា យួនដែលជាសត្រូវប្រវត្តិសាស្ត្ររបស់ប្រជាជនខ្មែរ តែងមានការភ័យខ្លាចថា ប្រទេសកម្ពុជាថ្ងៃណាមួយនឹងយកដីរបស់ខ្លួនពីគេមកវិញ ។ «កូសាំងស៊ីនជាដែនដីខ្មែរ ... ត្រូវប្រគល់ឲ្យខ្មែរវិញ» នេះជាអ្វីដែលគាត់ទទូច និងដែលជាចំណងជើងសៀវភៅរបស់គាត់ទៀតផង ។ ស្នាដៃរបស់លោក សាំង ម៉ាកសាង មិនបានផ្តល់នូវលទ្ធផលគួររីករាយនោះទេ ប៉ុន្តែជាការស្អប់ខ្ពើមចំពោះសត្រូវជាជនជាតិវៀតណាម ។*

*ការបាត់បង់ទឹកដីខ្មែរកូសាំងស៊ីន កាលពីថ្ងៃទី ៤ មិថុនា ឆ្នាំ ១៩៤៩ ត្រូវបានគេប្រារព្ធពិធីរំលឹកខួបក្រៀមក្រំជារៀងរាល់ឆ្នាំនៅក្រុងភ្នំពេញ ។ សេចក្តីទុក្ខវេទនារបស់ខ្មែរក្រោមតិច និងការរំលោភសិទ្ធិមនុស្សនិងសាសនាពីសំណាក់វៀតណាមត្រូវបានគេអានដាក់ឧគ្ឃោសនសព្ទឲ្យលាន់ឮរំពងក្នុងចំណោមអ្នកចូលរួមដ៏ច្រើនកុះករ គោរពដែលចង់ចែករំលែកនូវអារម្មណ៍កណ្តោចកណ្តែង ។ អំពើអមនុស្សធម៌ទាំងអស់នេះ ទោះយ៉ាងណា ត្រូវបានរដ្ឋាភិបាលវៀតណាមបដិសេធនិងបែរជានិយាយថា ទាំងអស់សុទ្ធតែជាការអះអាងរបស់អ្នកនយោបាយខ្មែរជ្រុល-និយម ដែលចង់នាំឲ្យមានអសន្តិសុខនិងអរិភាពក្នុងប្រទេសប៉ុណ្ណោះ (**តម្លៃជាដេលី** លេខ ២៤ ចុះថ្ងៃ ១៣ មិថុនា ២០០២) ។*

*ទស្សនៈរបស់ពលរដ្ឋខ្មែរប្រឆាំងនឹងវៀតណាម ឡើងដល់កំពូលក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៧០ ពេលរបបនយោបាយប្រឆាំងរាជានិយមពីរ គឺ សាធារណរដ្ឋខ្មែរ និងកម្ពុជាប្រជាធិបតេយ្យ ឡើងកាន់អំណាចបន្តបន្ទាប់គ្នា ។ អន្តោប្រវេសន៍វៀតណាមនៅពេលនោះ ត្រូវបានរដ្ឋាភិបាលកម្ចាត់យ៉ាងងាយស្រួល ព្រោះថាជនជាតិនេះចូលចិត្តប្រមូលផ្តុំតាំងទីលំនៅក្នុងភូមិបណ្តែតទឹកតាមដងព្រែកបឹងធំៗ និងទន្លេ (ហ្គូត្តស្មែន ២០០៣ : ១៥៥) ។ ប៉ុន្តែ ទោះយ៉ាងណា នយោបាយប្រឆាំងវៀតណាមរបស់រដ្ឋាភិបាលខ្មែរចុងក្រោយនេះ មិនមានអាយុកាលវែងឡើយ ព្រោះការចូលដៃរបស់វៀតណាមជាថ្មីម្តងទៀតនៅក្នុងនយោបាយរបស់ខ្មែរ ។ អ្នកខ្លះនិយាយថា ការពាក់ព័ន្ធរបស់វៀតណាម គឺជាការឈ្លានពាន (ម៉ូរីស ១៩៩៧) ចំណែកអ្នកខ្លះទៀត បែរជាផ្តល់នូវកតញ្ញុតាធម៌ចំពោះវត្តមានរបស់វៀតណាម ។ ទោះយ៉ាងណា ការខ្វែងគំនិតគ្នានេះហួសពីទំហំនៃអត្ថបទនេះ ។ អ្វីដែលទំនងជាមិនអាចប្រកែកបាន គឺថា ពីដើមទីមក មានអំណរគុណចំពោះទាហានវៀតណាម ចំពោះកិច្ចសហប្រតិបត្តិការជាមួយអតីតមន្ត្រីខ្មែរក្រហមមួយក្តាប់តូចក្នុងការផ្តួលរំលំរបប ប៉ុល ពត ។ ដោយហេតុដូច្នេះហើយ ក្នុងរយៈពេលប៉ុន្មានឆ្នាំដំបូងនៃការកសាងប្រទេស ទស្សនៈអវិជ្ជមាន (អរិភាព) ចំពោះវៀតណាម ហាក់ដូចជាពុំមានភាពច្បាស់លាស់ ។*

*ការពាក់ព័ន្ធរបស់វៀតណាមកាន់តែជ្រៅទៅៗ ក្នុងនយោបាយកម្ពុជានាទសវត្សរ៍ឆ្នាំ ១៩៨០ ទោះយ៉ាងណា បានញាំងឲ្យមានការបាត់បង់ជំនឿយ៉ាងហោចណាស់ចំពោះខ្មែរមួយចំនួន ។ បក្សពួកបក្សប្រជាជនបានថ្លែងអំណរគុណយ៉ាងខ្លាំងដល់វៀតណាម ដែលបានទម្លាក់ខ្មែរក្រហមចេញពីអំណាច និងផ្តល់អំណាចដល់ពួកគេ ចំណែកក្រុមផ្សេងទៀតបានរិះគន់រហូតមកនូវការជ្រៀតជ្រែករបស់វៀតណាមក្នុងនយោបាយកម្ពុជា និងរិះគន់បក្សប្រជាជនដែលឱនលំទោនចំពោះវៀតណាម ។ ការពាក់ព័ន្ធរបស់វៀតណាមនេះ បានបណ្តាលឲ្យមានការហូរចូលរបស់ជនជាតិវៀតណាមក្នុងចំនួនច្រើនលើសលប់ ដែលមិនធ្លាប់មានពីមុន ទាំងនោះរួមមាន ទាំងអ្នកចាកចេញក្នុងសម័យ ប៉ុល ពត និងអ្នកចំណូលថ្មីកាន់តែងាយស្រួល (បែរត្រេង់ ១៩៩៦) ។ តថភាពនេះ គឺជាការ*

ព្រួយបារម្ភរបស់ក្រុមអ្នកជាតិនិយមទាំងអស់ ។

ក្រៅពីនេះ ការឈ្លានពានទឹកដីកម្ពុជាក្នុងអំឡុងការគ្រប់គ្រងរបស់គេក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ បន្ថែមលើអ្វីដែលគេធ្លាប់បានធ្វើក្នុងប្រវត្តិសាស្ត្រកន្លងទៅ បាននាំឲ្យមានការកម្រើកឡើងវិញនូវភាពជាសត្រូវ ។ រដ្ឋាភិបាលកុម្មុយនីស្តខ្មែរ ដែលលើកបន្តុបដោយវៀតណាម បានចុះហត្ថលេខាលើសន្ធិសញ្ញាទ្វេភាគីមួយចំនួន ដែលបណ្តាលឲ្យបាត់បង់ទឹកដីយ៉ាងច្រើន (ស៊ាន ប៉េងសែ ២០០២ : ១-១២៤) ។ ថាតើការអះអាងនេះត្រឹមត្រូវដល់កម្រិតណានោះ នៅទាមទារឲ្យមានការសិក្សាបន្ថែមទៀត ។

## « យួន » ជាពាក្យជេរប្រមាថដល់សត្រូវរបស់ជាតិខ្មែរ

អត្ថន័យដើមនិងផ្នែកវេយ្យាករណ៍របស់ពាក្យ «យួន» ដែលខ្មែរតែងប្រើសព្វថ្ងៃ សំដៅលើរបស់គ្រប់សព្វដែលមិនល្អសម្រាប់គេ ត្រូវបានសិក្សាដោយអ្នកស្រាវជ្រាវមួយចំនួន ។ ប្រភពពីឯកសារជាភាសាខ្មែរមួយ បានអះអាងថា ពាក្យ «យួន» ត្រូវបានប្រើពីដំបូងដោយជនជាតិចាម ដែលពីមុនរស់នៅក្នុងដែនដីវៀតណាមកណ្តាលបច្ចុប្បន្ន ដោយសំដៅលើក្រុមកុលសម្ព័ន្ធ «យឿ» រស់នៅក្នុងតំបន់តុងកឹង ភាគខាងត្បូងប្រទេសចិន និងត្រូវជាហាណ្ឌយសព្វថ្ងៃ ប្រជាជនខ្មែរបានប្រើពាក្យនេះតាមចាម ដោយពីដំបូងពុំមានន័យរើសអើងណាមួយឡើយ ប៉ុន្តែការប្រើប្រាស់នោះ ក៏ត្រូវបានទទួលការចាប់អារម្មណ៍ខ្លាំងឡើងពីសំណាក់សកម្មជនសិទ្ធិមនុស្សនិងអ្នកនយោបាយមួយចំនួន មុនពេលមានការបោះឆ្នោតគាំទ្រដោយអង្គការសហប្រជាជាតិ នាឆ្នាំ ១៩៩៣ (កែវ ប៊ុនធឿន ១៩៩៦ : ៥០-៥២) ។ បន្ថែមលើនេះទៀត លោក សែកហ្វ៍ ថ្យុង (១៩៩៣: ២២៥-២៣០) បានយល់ស្របថា ពាក្យ «យួន» នេះ ដែលមានកំណើតនៅឥណ្ឌា និងយកមកប្រើប្រាស់ដោយប្រជាជនមួយចំនួននៅអាស៊ីអាគ្នេយ៍ រាប់បញ្ចូលទាំងខ្មែរផងនោះ មានន័យដើមមិនលំអៀងឡើយដោយសំដៅលើ «ជនបរទេស» ។ អត្ថបទក្នុងទស្សនាវដ្តី **កម្ពុជសុរិយា** ដែលចុះផ្សាយកាលពីឆ្នាំ ១៩៣០ (បោះពុម្ពផ្សាយដោយព្រះរាជបណ្ណាល័យកម្ពុជា) ក៏មានប្រើពាក្យ «យួន» ជាផ្លូវការសម្រាប់សំដៅលើជនជាតិវៀតណាម ដោយពុំមានឡំអៀងអ្វីឡើយ (ហ. តាត ១៩២៨ក, ១៩២៨ខ, ១៩២៩ក, ១៩២៩ខ) ។ លើសពីនេះទៀត **វចនានុក្រមខ្មែរ** បោះពុម្ពលើកទី ៥ កាលពីឆ្នាំ ១៩៦៧-១៩៦៨ (ទំព័រទី ៩៥៥) ដោយពុទ្ធសាសនបណ្ឌិត្យ មានបញ្ចូលតែពាក្យ «យួន» ជាមេពាក្យ ប៉ុន្តែបែរជាពុំមានបញ្ចូលពាក្យ «វៀតណាម» ឬ «យៀកណាម» ជាមេពាក្យទៅវិញ ៖

> **យួន** ន. ជាតិមនុស្សអ្នកដែនតុងកឹង, ដែនអណ្ណាម, ដែនកូសាំងស៊ីន : *យួនតុងកឹង, យួនអណ្ណាម, យួនកូសាំងស៊ីន* ; ពាក្យសាមញ្ញច្រើនហៅយួនតុងកឹងថា *យួនហាណូយ*, ហៅយួនអណ្ណាមថា *យួនហ្វេ*, ហៅយួនកូសាំងស៊ីនថា *យួនព្រៃនគរ* ។

នេះសបញ្ជាក់ឲ្យឃើញថា ពាក្យនេះមានប្រើនៅក្នុងសង្គមខ្មែររហូតមក ដោយពុំទំនងជាមានន័យលំអៀងអ្វីឡើយ[៥] ។ ទោះយ៉ាងណា ការវិវត្តនៃស្ថានភាពនយោបាយក្នុងប៉ុន្មានទសវត្សរ៍នេះ បានធ្វើឲ្យពាក្យនេះមានន័យពុំច្បាស់លាស់ទៅវិញ ។

សព្វថ្ងៃ សម្រាប់ប្រជាជនខ្មែរ ពាក្យ «យួន» និង «វៀតណាម» ជាពាក្យពីរមានន័យផ្សេងគ្នា ដោយ «យួន» សំដៅលើអន្តោប្រវេសន៍វៀតណាមដែលគេមិនចូលចិត្ត រីឯ «វៀតណាម» សំដៅលើអ្នកជិតខាងជាតិ

វៀតណាម ដែលគេមិនមានគំនិតលំអៀងទៅរក ។ ពាក្យ «យួន» ប្រហែលជាមិនមានន័យភាសាសាស្ត្រច្បាស់លាស់ទាំងក្នុងអក្សរសាស្ត្រខ្មែរនិងវៀតណាមនោះទេ ។ ទោះជាយ៉ាងណា ពាក្យនេះបានផ្តល់មកនូវអត្ថន័យអវិជ្ជមានដល់ប្រជាជនខ្មែរនិងវៀតណាមជាច្រើននៅពេលសព្វថ្ងៃនេះ ។ គេតែងប្រុងប្រយ័ត្នពេលជួបជាមួយមិត្តភក្តិវៀតណាម ប្រសិនបើមិនដូច្នោះទេ ពាក្យ «យួន» ដែលមិនមានន័យល្អនោះ អាចនឹងត្រូវហូរចេញពីបបូរមាត់របស់គេដោយចៃដន្យ និងដែលនឹងធ្វើឲ្យភាគីវៀតណាមមិនសប្បាយចិត្តឡើយ ។ អ្នកខ្លះនិយាយថាជនទាំងនេះមិនគួរនឹងហៅថា «វៀតណាម» ទេ ព្រោះថាជនជាតិនេះបាន ឈ្លានពានប្រទេសកម្ពុជាពីអតីតកាលនិងកំពុងត្រួតត្រាកម្ពុជាក្រោមនៅឡើយ(៦) ។

ពាក្យ «យួន» នេះ ប្រជាជនខ្មែរតែងតែយកមកប្រើដើម្បីហៅអន្តោប្រវេសន៍វៀតណាមក្នុងន័យអវិជ្ជមានហើយវាមានន័យផ្ទុយស្រឡះនឹងពាក្យ «វៀតណាម» ។ ស្ត្រីវៀតណាមម្នាក់មានអាយុជិត ២០ ឆ្នាំ និងធ្វើការនៅហាងកាហ្វេវៀតណាមមួយនៅក្នុងក្រុងភ្នំពេញ បានឲ្យដឹងថា នាងមានការក្រេវក្រោធយ៉ាងខ្លាំងពេលភ្ញៀវរបស់នាងម្នាក់បានហៅនាងថា «យួន» ព្រោះថាវាជាពាក្យជេរប្រមាថ(៧) ។ ផ្ទុយទៅវិញ ពាក្យ «វៀតណាម» ដែលមិនមានន័យរើសអើងឬអវិភាពនោះ មិនសូវពេញនិយមក្នុងការប្រើប្រាស់នោះទេ(៨) ។ ប្រជាជនខ្មែរហៅអ្នកទាំងនោះថា «យួន» ព្រោះថាពួកគេមិនពេញចិត្តនឹងអ្វីដែលរដ្ឋាភិបាលវៀតណាមដោះស្រាយបញ្ហាផ្សេង ៗ ជាមួយនឹងរដ្ឋាភិបាលកម្ពុជា តថភាពទាំងនោះ រួមមាន ករណីអន្តោប្រវេសន៍វៀតណាមជាច្រើនរស់នៅខុសច្បាប់នៅលើទឹកដីកម្ពុជា ភាពយឺតយ៉ាវ ឬបរាជ័យរបស់កម្ពុជាក្នុងការដោះស្រាយបញ្ហាការឈ្លានពានព្រំដែនពីសំណាក់វៀតណាម អន្តោប្រវេសន៍ និងការអភិវឌ្ឍយឺតនៅកម្ពុជាធៀបនឹងវៀតណាម ។

ការមិនជឿទុកចិត្ត ប្រៀបដូចជាគំនិតមានពីកំណើតរបស់ខ្មែរចំពោះវៀតណាម ដែលពួកគេយល់ថា មិនដែលធ្វើល្អចំពោះជាតិសាសន៍ខ្មែរសោះឡើយ ។ វត្តមានរបស់ទ័ពវៀតណាមរាប់ម៉ឺននាក់នៅប្រទេសកម្ពុជាក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ បានធ្វើឲ្យមានគេយល់អំពីយុទ្ធសាស្ត្រទ័ពរបស់វៀតណាម ។ ប្រជាជនខ្មែរបានដាក់ឈ្មោះឲ្យស្រមោចក្រហមម្យ៉ាង (ស្រមោចភ្លើង) ដែលអាចទិចឲ្យចុកមួយសន្ទុះថា «ស្រមោចយួន» តាមយុទ្ធវិធីទ័ពវៀតណាមដែលរុលទៅមុខកាន់តែច្រើន ពេលឃើញមិត្តរួមអាវុធគេណាម្នាក់ត្រូវបានសម្លាប់ ។ ប្រជាជនខ្មែរស្អប់សត្វនេះណាស់ ព្រោះថាពេលអ្នកណាដើរជាន់វាមួយឬសំបុករបស់វា ស្រមោចដទៃទៀតមិនបានរត់ចេញនោះទេ ប៉ុន្តែកាន់តែរត់ចូលមកសំដៅខាំគេ(៩) ។ ទោះយ៉ាងណា អ្នកខ្លះអះអាងផ្សេងពីនេះថា ឈ្មោះស្រមោចនេះត្រូវបានគេដាក់ ដោយយោងលើព័ណ៌ក្រហមរបស់វា ព័ណ៌ដែលពេញនិយមនៅប្រទេសកុម្មុយនីស្ត ដូចវៀតណាមនេះ(១០) ។ មិនខ្វល់ថា ឈ្មោះស្រមោចនេះមានប្រភពមកពីណានោះទេ ពុំមានអ្នកណាចូលចិត្តស្រមោចយួននេះឡើយ ។ ប៉ុន្តែ ពេលនិយាយដល់ «សម្ល្ម្ជូរយួន» យើងប្រហែលជាពុំអាចថា ពាក្យនេះមានបង្កប់នូវអត្ថន័យល្អឬអាក្រក់នោះទេ ។

ពុំមានឯកសារណាអះអាងអំពីប្រវត្តិនៃពាក្យ «យួន» និង «វៀតណាម » ឲ្យបានស្បាស់លាស់ទេ ប៉ុន្តែស្ថានភាពសព្វថ្ងៃបានបង្ហាញច្បាស់ថា ពាក្យទាំងពីរនេះពុំមែនជាសទិសន័យនឹងគ្នាឡើយ ។ ពាក្យ «យួន» ទទួលបាននូវប្រជាប្រិយភាពយ៉ាងខ្លាំង ប្រើសម្រាប់ពាល់របស់របរ និងទំនិញមិនល្អមិនធន់ ជាគំនិតដែលមិនប្រាកដថា មានអំណះអំណាងគ្រប់ករណីនោះ ។ ពេលមនុស្សម្នាក់ប្រាប់ទៅមិត្តម្នាក់ទៀតថា «ឈើធ្មេញ» ចម្លើយអាច

*ថា «នោះក៏ព្រោះតែអ្នកនោះមានធ្មេញយួន» ។ បើឈើក្រពះក៏ព្រោះតែក្រពះ នោះជាក្រពះយួនដែរ ។ ផលិតផលខ្លះ ដែលងាយបាក់បែក មិនខ្វល់ថា ផលិតនៅទីណា ប្រាកដឡើយក៏អាចជារបស់យួនដែរ ។ អ្វីដែលមានពាក្យ «យួន» សុទ្ធតែអាក្រក់បុចំអក ។ មនុស្សធម្មតាក៏យល់ដូច្នេះ ឯអ្នកនយោបាយក៏មានការយល់ឃើញស្រដៀងគ្នាដែរ ។*

## ការប្រើប្រាស់វោហារសាស្ត្រប្រឆាំងវៀតណាមដោយអ្នកនយោបាយខ្មែរ

*ជំពូកនេះ នឹងសិក្សាអំពីថា តើវោហារសាស្ត្រប្រឆាំងនឹងវៀតណាមរបស់អ្នកនយោបាយខ្មែរ បានប៉ះពាល់យ៉ាងណាទៅលើប្រជាជនខ្មែរ និងជនជាតិភាគតិចវៀតណាម ដែលត្រូវជាប់ផុងផ្នែកនយោបាយនិងវប្បធម៌ក្នុងលំហដ៏តូចចង្អៀតមួយ ចន្លោះប្រទេសកំណើតរបស់គេនិងប្រទេសដែលគេកំពុងរស់នៅ ។ អ្នកនយោបាយខ្មែរ ជាអ្នកដឹកនាំក្នុងការញុះញង់ឲ្យប្រជាជនដែលមានស្នាមអនុស្សាវរីយ៍ខ្មៅងងឹត ពួកគេបានជួបប្រទះរៀនសូត្រកាន់តែស្អប់ កាន់តែមានគំនិតអវិជ្ជមានចំពោះជនជាតិវៀតណាម ។ បញ្ហាអន្តោប្រវេសន៍ខុសច្បាប់និងការឈ្លានពានព្រំដែនពីសំណាក់វៀតណាម ត្រូវបានទទួលស្គាល់ទាំងបក្សកាន់អំណាចនិងបក្សប្រឆាំង ប៉ុន្តែកង្វះសមត្ថភាពរបស់បក្សដឹកនាំក្នុងការដោះស្រាយបញ្ហាក្តៅគគុកទាំងនេះ បានផ្តល់នូវបរិយាកាសកាន់តែធំទូលាយដល់បក្សប្រឆាំងឲ្យទទួលបាននូវការគាំទ្រពីមហាជន ។ អន្តរទំនាក់ទំនងរវាងបញ្ហាក្តៅក្រហាយទាំងនេះ ដែលនឹងត្រូវលើកយកមកពិភាក្សាលំអិតជាបន្តបន្ទាប់ខាងក្រោម នឹងអាចរួមចំណែក ធ្វើឲ្យមានការយល់ដឹងកាន់តែច្បាស់អំពីបុសគល់ដែលនាំឆ្ពោះទៅរកអាកប្បកិរិយាចំពោះវៀតណាមដែលខ្មែរមានបច្ចុប្បន្ន ។*

## បញ្ហាអន្តោប្រវេសន៍និងបញ្ហាព្រំដែនដែលមិនចេះចប់

*បញ្ហាអន្តោប្រវេសន៍ ត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងកម្មវិធីនយោបាយរបស់គណបក្សធំទាំងបី សម្រាប់ការបោះឆ្នោតតំណាងរាស្ត្រ ។ គណបក្សនីមួយៗ សន្យាថា នឹងដោះស្រាយប្រកបដោយប្រសិទ្ធភាពជាមួយនឹងបញ្ហានេះ ពេលដែលឈ្នះឆ្នោត (**ភ្នំពេញប៉ុស្តិ៍** ១៩៩៨) ។ ការឃោសនានយោបាយនេះបានទាក់ទាញការគាំទ្រពីមហាជនយ៉ាងច្រើន អ្នកទាំងនោះភាគច្រើនដឹងខ្លួនក្រោយមកថា ខ្លួនត្រូវបានគេបោកប្រាស់ ។ ដូច្នេះហើយបញ្ហាដែលមិនទាន់ដោះស្រាយនេះ នៅតែជាការព្រួយបារម្ភរបស់ប្រជាជនខ្មែរជាច្រើន ដែលយល់ឃើញថា វាពុំមែនជាជម្ងឺធម្មតានោះទេ ។*

*ប្រជាជនខ្មែរមិនដែលជឿលើអាកប្បកិរិយារមនារបស់ភាគីវៀតណាមនោះទេ ព្រោះថាគេបានរៀននូវមេរៀនជូរចត់យ៉ាងច្រើនពីប្រវត្តិសាស្ត្រ ។ អន្តោប្រវេសន៍វៀតណាមមករស់នៅទីនេះ ដោយស្ងប់ស្ងាត់តែដំបូងប៉ុណ្ណោះ ដល់យូរទៅគេនឹងក្លាយជាគ្រោះថ្នាក់ដល់អត្តសញ្ញាណខ្មែរ (នួន ឃឿន ១៩៨៩ : ១-២៦) ។ ជាក់ស្តែងនៅសតវត្សរ៍ទី ១៧ ចាប់ពីពេលមានទំនាក់ទំនងល្អជាមួយគ្នាមក វៀតណាមត្រូវបានព្រះរាជាខ្មែរព្រះរាជទានឲ្យតាំងលំនៅក្នុងដីមួយកន្លែងទំហំសមល្មម ដោយដាក់កិច្ចសន្យាថា នឹងប្រគល់ដីមកឲ្យខ្មែរវិញនៅពេលណាដែលក្សត្រដដែលនោះត្រូវការ ។ សំណាងអាក្រក់ វៀតណាមពុំដែលបានប្រគល់ដីនោះត្រឡប់ឲ្យខ្មែរវិញឡើយ ដោយអះអាងថា ពួកគេបានតាំងលំនៅទីនោះយូរយារណាស់មកហើយ ។ ទោះរហូតមកដល់ឥឡូវនេះ អតីតកាល*

*នេះនៅតែប៉ះពាល់យ៉ាងខ្លាំងដល់ការគិតរបស់ខ្មែរមួយចំនួន ។ ពេលសួរថា ហេតុអ្វីបានជាវៀតណាមចូលចិត្តមករស់នៅក្នុងទឹកដីខ្មែរ ជាឧទាហរណ៍ ស្ត្រីអាយុ ២៩ ឆ្នាំម្នាក់មកពីខេត្តកំពង់ចាម បានឆ្លើយថា គេគ្មានចាប់អារម្មណ៍អ្វីក្រៅពីដីរបស់ខ្មែរឡើយ[១១] ។*

*មនុស្សខ្មែរទូទៅចង់ឲ្យមានការដោះស្រាយចំពោះជម្លោះទឹកដីនិងអន្តោប្រវេសន៍ ដែលនោះក៏ជាផ្នែកសំខាន់មួយនៃគោលនយោបាយរបស់គណបក្សនយោបាយដែរ ។ ពាក្យ «យួន» ត្រូវបានគេបន្លឺឡើងជារឿយៗ តាមសុន្ទរកថារបស់អ្នកនយោបាយមកពីគណបក្សប្រឆាំង ក្នុងអំឡុងឃោសនាបោះឆ្នោត ។ ទោះបីវោហារសាស្ត្រប្រឆាំងវៀតណាមនេះ ត្រូវបានក្រុមសិទ្ធិមនុស្សនិងរដ្ឋាភិបាលវៀតណាមរិះគន់ ដោយអះអាងថា វាមិនស្របទៅនឹងគោលការណ៍សិទ្ធិមនុស្សសាកលនិងកិច្ចព្រមព្រៀងទ្វេភាគីរវាងវៀតណាមនិងកម្ពុជា ពាក្យជេរប្រទេចចំពោះអន្តោប្រវេសន៍វៀតណាម នៅតែត្រូវបានគេចែកផ្សាយយ៉ាងទូលាយតាមប្រព័ន្ធផ្សព្វផ្សាយពេលឃោសនា ។ នៅក្នុងភូមិមួយក្រៅក្រុងភ្នំពេញ សម្តេចក្រុមព្រះ ព្រះប្រធានគណបក្ស ហ៊ុនស៊ិនប៉ិច[១២] ថ្លែងតាមឧគ្ឃោសនសព្ទខ្លាំងៗ ទៅកាន់អ្នកគាំទ្ររបស់ព្រះអង្គថា ÷*

> ប្រសិនបើយើងបោះឆ្នោតឲ្យត្រូវគណបក្ស យួននឹងចាកចេញ ប៉ុន្តែប្រសិនបើយើងជ្រើសរើសគណបក្សខុស យួននឹងមានកាន់តែច្រើន (**ភ្នំពេញប៉ុស្តិ៍** ១៧-២៣ កក្កដា ១៩៩៨) ។

*អ្វីដែលសំខាន់ដូចគ្នានេះដែរ គឺបញ្ហាព្រំដែនសព្វថ្ងៃនេះ ។ បញ្ហានេះទំនងជាមិនអាចទៅរួចនោះទេ សម្រាប់ប្រជាជនខ្មែរឲ្យបំភ្លេចចោលនូវការបាត់បង់ទឹកដីជាបន្តបន្ទាប់រាប់សតវត្សរ៍មកហើយនោះ ។ អតីតកាលដ៏យូរលង់ ត្រូវបានរំលឹកឡើងវិញនិងធ្វើឲ្យកាន់តែតានតឹងឡើង ដោយព្រឹត្តិការណ៍ដែលកំពុងកើតមានបច្ចុប្បន្ន ។ ការរំលោភព្រំដែនត្រូវបានរាយការណ៍ជារឿយៗ ដោយក្រុមប្រឆាំង ដែលមនុស្សជាច្រើនគិតថា ជាអ្នកយកចិត្តទុកដាក់អំពីទឹកដីកម្ពុជា ។ មនោសញ្ចេតនានេះមិនប្រាកដថាត្រូវទាំងអស់នោះទេ ព្រោះថាបក្សកាន់អំណាចក៏យកចិត្តទុកដាក់លើបញ្ហាព្រំដែននោះដែរ ដូចដែលមានចែងនៅក្នុងកម្មវិធីនយោបាយរបស់គេ (យោងដូចខាងលើ) ប៉ុន្តែ ត្រង់ថា ការសន្យានោះត្រូវបានគេយកទៅអនុវត្តឬអត់នោះ គឺជារឿងមួយផ្សេងទៀត ។*

*ប្រជាជនខ្មែរតែងជាអ្នកចាញ់ទៅហើយ ។ ពួកគេត្រូវចាកចេញពីដីរបស់ខ្លួនសម្រាប់សន្តិសុខនិងសុវត្ថិភាពផ្ទាល់ខ្លួន ។ ប្រជាជនខ្មែររស់នៅតាមព្រំដែន តែងខកចិត្តនឹងអ្វីដែលរដ្ឋាភិបាលវៀតណាមនិងកម្ពុជាដោះស្រាយអំពីបញ្ហាព្រំដែនសព្វថ្ងៃនេះ ។ ពេលមានជម្លោះដីធ្លីជាមួយវៀតណាមដែលជាអ្នកជិតខាង ឬអ្នកមកពីទីឆ្ងាយក្នុងប្រទេសវៀតណាម ប្រជាជនខ្មែរពុំដឹងថា ធ្វើអ្វីនោះទេ ក្រៅពីចាកចេញពីដីរបស់ខ្លួន ។ បុរសខ្មែរអាយុ ៦៦ ឆ្នាំមួយរូប ដែលតែងដាំដុះលើដីរបស់គាត់ និងធ្លាប់ទាំងបង់ពន្ធដីទៅឲ្យរបបសង្គមរាស្ត្រនិយម (គ.ស. ១៩៥៤–១៩៦៩) ត្រូវបានជនជាតិវៀតណាមបង្ខំឲ្យចាកចេញពីដីនោះ ។ នេះគ្រាន់តែជាករណីមួយ ក្នុងចំណោមករណីយ៉ាងច្រើនសន្ធឹកសន្ធាប់ដែលរដ្ឋាភិបាលខ្មែរមិនមានសមត្ថភាពដោះស្រាយ (យោងដូចខាងលើ) ។*

*ប្រជាជនខ្មែរជាច្រើនទៀត ក៏ចែករំលែកនូវទុក្ខព្រួយក្រៀមក្រំដូចគ្នានេះដែរ ។ គេមិនដែលមានគំនិតចង់ឲ្យមានការបាត់បង់អត្តសញ្ញាណរបស់គេបន្តិចណាឡើយ អារម្មណ៍ទូទៅដែលបក្សប្រឆាំង តែងលើកយកមកសម្តែងនិងគាំទ្រ ។ ប្រជាជនតែងមានបីតិសោមនស្សនឹងសុន្ទរកថានយោបាយជាតិនិយម ។ ពេលសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ប្រកាសថា «បោះឆ្នោតឲ្យហ៊ុនស៊ីនប៉ិច គឺដូចជាបោះឆ្នោតដើម្បីដោះស្រាយបញ្ហាទឹកដី» កសិករ*

អាយុ ២៥ ឆ្នាំម្នាក់ ដែលមានការប្តេជ្ញាចិត្តដូចគ្នានេះ បានបន្ទឹតបរិញថា «ចង់បានដីដែលបាត់បង់មកវិញ» (**ភ្នំពេញប៉ុស្តិ៍** ១៩៩៨ ការបោះឆ្នោត) ។ នៅមានករណីជាច្រើនទៀត ដែលប្រជាជនកម្ពុជាតែងចាញ់គេ ករណីទាំងនេះរដ្ឋាភិបាលប្រទេសទាំងពីរត្រូវទទួលខុសត្រូវ ។

## អសមត្ថភាពរបស់រដ្ឋាភិបាលកម្ពុជាក្នុងការដោះស្រាយរាល់បញ្ហាខាងលើ

រដ្ឋាភិបាលកម្ពុជាមិនដែលមានសមត្ថភាពដោះស្រាយបញ្ហាអន្តោប្រវេសន៍និងជម្លោះព្រំដែនជាមួយវៀតណាមនោះទេ ។ កង្វះគោលនយោបាយរបស់រដ្ឋាភិបាល និងអំពើពុករលួយនៅព្រំដែន បានធ្វើឲ្យចំនួនអន្តោប្រវេសន៍វៀតណាមដែលមិនបានចុះបញ្ជីកើនឡើង (មិងស័នព៌ និង ខោរ ២០០៣: ២៣៣-៣៤) ។ ពេលដែលបញ្ហាកាន់តែធ្វើឲ្យមានសភាពតឹងតែង ដោយការរៀបអាពាហ៍ពិពាហ៍ឆ្លងសាសន៍ និងកង្វះការចាប់អារម្មណ៍ពីរដ្ឋាភិបាល អន្តោប្រវេសន៍គឺពិតជាការព្រួយបារម្ភរបស់អ្នកនយោបាយមួយចំនួន ដែលខ្លាចបាត់បង់អត្តសញ្ញាណជាតិ ។ លោក សុន ឆ័យ អ្នកតំណាងរាស្ត្រមកពីបក្សសមរង្ស៊ី ជាឧទាហរណ៍ បានថ្លែងថា ÷

> ប្រសិនបើគ្មានវិធានការតឹងតែងពីរដ្ឋាភិបាលទេនោះ កម្ពុជាក្នុងពេលឆាប់ៗ ខាងមុខ នឹងឈានទៅរកបញ្ហាមួយកាន់តែធ្ងន់ ។ យើងនឹងក្លាយជាជនជាតិភាគតិចលើទឹកដីផ្ទាល់របស់ខ្លួន (**កម្ពុជាដេលី** ៦-៧ កក្កដា ២០០២) ។

ពិតណាស់ថា គណៈកម្មាធិការជាតិមួយដឹកនាំដោយលោក វ៉ា គឹមហុង សមាជិកគណបក្សប្រជាជនកម្ពុជាត្រូវបានបង្កើតឡើងក្នុងបំណងដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាង ។ ទោះជាយ៉ាងណា ប្រជាជនជាច្រើននិងបក្សប្រឆាំង មិនគ្រេកអរនឹងអ្វីដែលស្ថាប័ននេះបាននិងកំពុងធ្វើនោះទេ ។ និយាយពីផ្នែកនយោបាយ គណៈកម្មាធិការនេះ ជារឿយៗ ប្រឆាំងនឹងសេចក្តីស្នើផ្សេងៗ ពីបក្សប្រឆាំង ចំណែកបក្សប្រឆាំងក៏ពុំទុកចិត្តវិញដែរ ទោះជាមានតថភាពនយោបាយនេះ គណៈកម្មាធិការតែងស្ទាក់ស្ទើរក្នុងការប្តេជ្ញាចិត្តផ្តោះទៅរកផលប្រយោជន៍ជាតិ ។ គេមិនដែលទទួលយកសំណើរបស់បក្សប្រឆាំងទៅពិចារណានោះទេ ជាក់ស្តែង សំណើសុំឲ្យធ្វើនិរាករណ៍នូវសន្ធិសញ្ញានិងអនុសញ្ញាទ្វេភាគីទាំងឡាយ ដែលធ្វើឡើងក្នុងរយៈពេលគ្រប់គ្រងរបស់វៀតណាមក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ (ស៊ាន ប៉េងសែ ២០០២ និង ២០០៣) ដែលបានធ្វើឲ្យបាត់បង់ទឹកដីរបស់ខ្មែរយ៉ាងច្រើននោះ ។

កង្វះសមត្ថភាពរបស់រដ្ឋាភិបាលកម្ពុជា ការបាត់បង់ទឹកដីក្នុងប៉ុន្មានទសវត្សរ៍កន្លងទៅ និងការរំលោភមិនចេះចប់ពីសំណាក់វៀតណាមលើអធិបតេយ្យនិងបូរណភាពកម្ពុជា មិនលើកទឹកចិត្តឲ្យប្រជាជនខ្មែរមានទំនាក់ទំនងដោយមេត្រីភាពជាមួយវៀតណាមឡើយ ។ ឧទាហរណ៍ ក្នុងចន្លោះឆ្នាំ ១៩៩៨ និង ២០០២ និស្សិតមហាវិទ្យាល័យយ៉ាងច្រើនតែងចូលរួមធ្វើបាតុកម្មអហិង្សានិងដុតកង់ឡាននៅមុខសាកលវិទ្យាល័យ ឬកន្លែងដទៃទៀតពេលប្រតិភូវៀតណាមមកភ្នំពេញ ។ ទោះជានិស្សិតទាំងនេះ ត្រូវបានគេស្គាល់ដោយសារចលនាប្រឆាំងវៀតណាម ពួកគេមិនដែលពេញចិត្តនឹងដំណោះស្រាយរបស់រាជរដ្ឋាភិបាលឡើយ ។ ផ្ទុយទៅវិញ ពួកគេត្រូវបានទទួលទណ្ឌកម្មពីមន្ត្រីសាកលវិទ្យាល័យ ជាការឆ្លើយតបនឹងការពាក់ព័ន្ធនឹងនយោបាយរបស់គេ ដែលជាមនុស្សមានបំណងដោះស្រាយភាពខ្សឹកខ្សួលជាតិប៉ុណ្ណោះនោះ ។ ចលនាដូចគ្នានេះ មិនត្រូវបានគេអនុញ្ញាតឲ្យមាននោះទេ ចាប់ពីមានកុបកម្មប្រឆាំងថៃនៅដើមឆ្នាំ ២០០៣ មក[១៣] ។

លើសពីនេះទៀត រដ្ឋាភិបាលកម្ពុជាមិនបានព្រងើយកន្តើយនោះទេ ប៉ុន្តែមិនមានសុច្ឆន្ទៈនិងសមត្ថភាពក្នុង

*ការដោះស្រាយទុក្ខវេទនារបស់ប្រជាជនដែលបាត់បង់ដីទៅខាងវៀតណាម ការហូរចូលអន្តោប្រវេសន៍ខុសច្បាប់វៀតណាម និងភាពកណ្តោចកណ្តែងនៃការបាត់បង់អត្តសញ្ញាណនោះ ។ ទោះជាមានការបង្កើតគណៈកម្មការជាតិទទួលបន្ទុកផ្នែកព្រំដែន ទឹកដីកម្ពុជានៅត្រូវបានប្រទេសជិតខាងរំលោភមិនចេះឈប់ ។ វាហាក់បីដូចជាពួកគេមានសេចក្តីលំអៀង ឬស្ថិតក្រោមឥទ្ធិពលរបស់វៀតណាម ។ បើមិនដូច្នោះទេ ការពង្រឹងច្បាប់មិនត្រូវបានគេបំពេញនៅក្នុងរបបនេះឡើយ ។ ឧទាហរណ៍ អ្នកនេសាទវៀតណាម ៤៣ នាក់ និងទូកនេសាទចំនួន ១៥ គ្រឿង ដែលចូលនេសាទខុសច្បាប់ក្នុងដែនទឹកកម្ពុជា ត្រូវបានដោះលែងទៅវិញ ។ ក្រោយពីការបង្ខាំងទុកមួយរយៈពេលខ្លីមក ពីព្រោះនគរបាលគិតថា ពួកគេទាំងនោះគ្រាន់តែមករកក្តាមខ្យងប៉ុណ្ណោះ (**ភ្នំពេញប៉ុស្តិ៍**... *

*(**ឆម្ពូជាដេលី** ក្បាល ២០ លេខ ៦២ ថ្ងៃពុធទី ៩ ឧសភា ២០០១) ។ ក្នុងបញ្ហានេះ អ្នកនេសាទខ្មែរម្នាក់បាននិយាយដោយតូចចិត្តនឹងរដ្ឋាភិបាលថា ÷*

ធម្មតានាវានិងទូកនេសាទវៀតណាមអាចចូលក្នុងដែនទឹកកម្ពុជាបាន ប៉ុន្តែប្រសិននាវាកម្ពុជាចូលទៅខាងវៀត-ណាមវិញ តែងមានរឿងធំជាដរាប (**ឆម្ពូជាដេលី** ក្បាល ២៤ លេខ ៥៣ ថ្ងៃទី ១៥ សីហា ឆ្នាំ ២០០២) ។

*កង្វះសមត្ថភាពនេះបានធ្វើឲ្យប្រជាជនមានអារម្មណ៍ខកចិតនឹងរដ្ឋាភិបាលរបស់ខ្លួន និងស្អប់អ្នកជិតខាងដែលអាចឆក់ឱកាសនេះមកធ្វើជាប្រយោជន៍បាន ។*

*ក្រៅពីកង្វះសមត្ថភាពនេះ គណបក្សកាន់អំណាច មិនដែលបានបំពេញការសន្យារបស់ខ្លួនធ្វើឡើង រាល់មុនពេលការបោះឆ្នោត ក្នុងរឿងដោះស្រាយបញ្ហាអន្តោប្រវេសន៍ ។ រហូតមក ក្រសួងមហាផ្ទៃបានកោះប្រជុំអភិបាលខេត្ត មកពិភាក្សារឿងជនអន្តោប្រវេសន៍រស់ក្នុងដែនដីកម្ពុជា ប៉ុន្តែកិច្ចប្រជុំលើកទី ៣ នៅដើមខែកក្កដា ២០០២ មិនបានផ្តល់ផ្លែផ្កាឡើយ ។ វាបែរជានាំឲ្យមានការឆេះជុំស្អប់ខ្ពើមទៅវិញ ។ នៅពេលនោះ លោក ស៊ូ ភិរិន្ទ ដែលជាអភិបាលខេត្តកំពង់ឆ្នាំង បានមានប្រសាសន៍ថា ÷*

« ខ្ញុំស្អប់ជនអន្តោប្រវេសន៍ដែលរស់នៅលើផ្ទះបណ្តែតទឹកតាមបឹងទន្លេសាប ព្រោះថា ពួកគេបានបំផ្លាញបរិស្ថាន ដូច្នេះយើងព្យាយាមដោះស្រាយបញ្ហានេះ [គាត់មានប្រសាសន៍សំដៅលើជនជាតិវៀតណាមដែលរស់តាមដងស្ទឹង] ចង់ឲ្យអន្តោប្រវេសន៍បរទេសទាំងអស់ គោរពច្បាប់អន្តោប្រវេសន៍របស់យើង » (**ឆម្ពូជាដេលី** ក្បាល ២៤ លេខ ២៦ ថ្ងៃទី ៩ កក្កដា ២០០២) ។

*សុខុមាលភាពរបស់ប្រជាជនត្រូវតែជាកាតព្វកិច្ចចម្បងរបស់រដ្ឋាភិបាលនីមួយៗ ប៉ុន្តែប្រហែលជាតិចតួចប៉ុណ្ណោះសម្រាប់រដ្ឋាភិបាលកម្ពុជា ។ គម្រោងសង់ទំនប់វារីអគ្គិសនីយ៉ាលីក្នុងឆ្នាំ ១៩៩៣ និងសេសាន ៣ ក្នុងឆ្នាំ ២០០២ ដោយពុំបានសិក្សាជាមុនពីផលប៉ះពាល់អវិជ្ជមាន បានធ្វើឲ្យប្រជាជនកម្ពុជារស់នៅក្រោមខ្សែទឹក ជួបផលលំបាកជាច្រើន ។ ប្រជាជននិងសត្វពាហនៈត្រូវឆ្លងរោគជាច្រើនប្រភេទ ទឹកបឹងត្រូវបំពុល ត្រីស្លាប់ និងទឹកជំនន់ជាដើម ។ ការសិក្សាមួយចំនួនរបស់អង្គការក្រៅរដ្ឋាភិបាលបានបង្ហាញថា ÷*

ទំនប់សេសាន ៣ ស្ថិតនោះបានទទួលការប្រឆាំងយ៉ាងខ្លាំងពីសំណាក់អង្គការក្រៅរដ្ឋាភិបាលនិងអ្នកភូមិនៅខេត្តស្ទឹងត្រែងនិងរតនគិរី ដោយអ្នកទាំងនោះបានអះអាងថា ទំនប់មួយទៀតនៅតាមដងទន្លេសេសានត្រើយខាងវៀត-ណាម បានធ្វើឲ្យមានទឹកជំនន់និងធ្វើឲ្យខូចគុណភាពទឹក (**ឆម្ពូជាដេលី** ក្បាល ២៤ លេខ ២៨ ថ្ងៃទី ១១ កក្កដា ២០០២) ។

ផលលំបាកដែលបានមកពីគម្រោងសាងសង់ទំនប់វារីអគ្គិសនីនេះ ពិតជាអនុផលនៃកិច្ចព្រមព្រៀងទ្វេភាគីនៃរដ្ឋាភិបាលទាំងពីរ ដែលត្រូវទទួលខុសត្រូវចំពោះជនរងគ្រោះកម្ពុជា ។

## ការស្វែងរកប្រជាប្រិយភាពនិងអំណាចនយោបាយ

គណបក្សប្រឆាំងឆ្លាតល្មមនឹងអាចសង្កត់ធ្ងន់លើកង្វះសមត្ថភាពរបស់រដ្ឋាភិបាល និងការគំរាមកំហែងដែលជាលទ្ធផលចំពោះបូរណភាពនិងអធិបតេយ្យជាតិ ។ ប្រជាជនគ្រប់រូបតាមបណ្តាំរបស់ក្រុមប្រឆាំង គួរត្រូវដឹងនិងយកចិត្តទុកដាក់លើទំនាក់ទំនងរបស់ក្រុមបក្សកាន់អំណាចជាមួយវៀតណាម និងវត្តមានរបស់ជនជាតិវៀតណាមលើទឹកដីខ្មែរ ។ ទោះបី ១០ ឆ្នាំក្រោយពីការដកទ័ពវៀតណាមចេញពីកម្ពុជា នាយករដ្ឋមន្ត្រីខ្មែរ លោក ហ៊ុន សែន នៅតែប្រើអក្ខរក្រុវៀតណាមដដែល ។ ការហូរចូលកាន់តែកើនឡើងនៃទាហានវៀតណាម អាចនឹងមានន័យថា សង្គ្រាមនឹងកើតឡើងក្នុងប្រទេសរវាងខ្មែរនិងយួន ដែលនឹងបើកការវាយប្រហារ ដើម្បីលេបយកទឹកដីខ្មែរតាមរយៈ ហ៊ុន សែន (**គំនិតឆ្នូនខ្មែរ** ក្បាល ២ លេខ ៥១ ថ្ងៃទី ៩-១០ មិថុនា ដកស្រង់ក្នុង **ភ្នំពេញប៉ុស្តិ៍** ថ្ងៃទី ៨-១៤ មិថុនា ១៩៩៧) ។ មួយខែក្រោយពីការចុះផ្សាយមក សង្គ្រាមបានកើតឡើង ពិតមែនតែមិនមែនរវាងប្រជាជាតិទាំងពីរនោះទេ គឺរវាងខ្មែរនឹងខ្មែរប៉ុណ្ណោះ ។

មួយឆ្នាំបន្ទាប់ពីជម្លោះប្រដាប់អាវុធ មានការរៀបចំការបោះឆ្នោតសាកលជាលើកទី ២ ដែលគ្រប់គណបក្សនយោបាយទាំងអស់ត្រូវរួចរាល់ដើម្បីឃោសនា ។ ជួនកាល អ្នកនយោបាយគ្រាន់តែចង់ស្តីបន្ទោសឲ្យរដ្ឋាភិបាលក្នុងការបរាជ័យយកច្បាប់អន្តោប្រវេសន៍ទៅអនុវត្ត ប៉ុន្តែ បែរជាបានធ្វើឲ្យមានការកម្រើកពីអ្នកដែលមិនចូលចិត្តស្តាប់ពាក្យ «យួន» ទៅវិញ ។ តាមសកម្មជនសិទ្ធិមនុស្សខ្លះ ការប្រើប្រាស់ពាក្យជេរប្រមាថនេះ អាចបំភិតបំភ័យអ្នកដែលមានស្រឡាយវៀតណាម ។ លោក សម រង្ស៊ី ប្រធានគណបក្សប្រឆាំង បានបដិសេធថា លោកមិនបានបន្ទាចអ្នកមានជាប់ខ្សែស្រឡាយយួនទាំងនោះ ដោយមានប្រសាសន៍ថា ÷

> មានបំណងសំដៅលើតែរដ្ឋាភិបាលបច្ចុប្បន្នប៉ុណ្ណោះ ដែលខកខានមិនការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី ។ មិនមានបំណងសំដៅចំពោះប្រទេសណាឬបុគ្គលណានោះឡើយ (**ភ្នំពេញប៉ុស្តិ៍** ថ្ងៃ ១៧-២៣ កក្កដា ១៩៩៨) ។

សូម្បីក្រោយពីការបោះឆ្នោត ជនជាតិវៀតណាមដែលមិនដឹងអ្វីសោះក្នុងដំណើរការរាប់សន្លឹកឆ្នោតនោះត្រូវទទួលរងគ្រោះ ដោយសារអ្នកនយោបាយនិងក្រុមបាតុករមួយចំនួន ។ បាតុកម្មនេះបានទាក់ទាញមនុស្សជាច្រើនឲ្យចូលរួម ដែលនៅពេលជាមួយនោះ វៀតណាមត្រូវបានគេចោទប្រកាន់ថា បានបំពុលទឹក និងត្រូវបានវាយសម្លាប់ ព្រមទាំងជេរប្រទេចនឹងពាក្យ «យួន» ទៀតផង ។ បាតុករខ្លះហៅលោក ហ៊ុន សែន ថា «អាយ៉ងយួន» ចំណែកអ្នកខ្លះទៀតស្រែកថា «វ៉ៃយួនៗ» ។ ទោះជាវៀតណាមមិនមានអ្វីពាក់ព័ន្ធក្នុងរឿងនេះក៏ដោយគេបានទទួលនូវការជេរប្រមាថយ៉ាងខ្លាំង ។ លើសពីនេះទៀត ស្តូបមិត្តភាពកម្ពុជាវៀតណាម[(១៤)] នៅភ្នំពេញត្រូវបានវាយបំបែកខ្លះ និងដុតក្នុងបំណងសងសឹកនឹងការគ្រប់គ្រងរបស់វៀតណាមពីអតីតកាល ។ បាតុករបានគិតថា លោក ហ៊ុន សែន ជាអ្នកលួចបន្លំក្នុងការបោះឆ្នោត និងត្រូវចុះចេញពីតំណែងនិងព្រមទាំងបានចោទប្រកាន់ថា ÷

ហ៊ុន សែន កំពុងនឹងសងគុណយួន ។ មិនចង់ឲ្យបរទេស [វៀតណាម] រស់នៅក្នុងប្រទេស ដោយគ្មានច្បាប់ឡើយ (យោងដូចខាងលើ) ។

*មិនត្រឹមតែជនជាតិវៀតណាមប៉ុណ្ណោះទេ ដែលត្រូវរងគ្រោះដោយនយោបាយកម្ពុជានោះ ប្រជាជនខ្មែរខ្លួនឯងមួយគរគោក ក៏ត្រូវបានអ្នកនយោបាយប្រើប្រាស់ដើម្បីបង្កឲ្យមានការភ័យខ្លាចនិងកំហឹង ។ កំហឹងដែលមានក្នុងផ្នត់គំនិតប្រជាជនរួចស្រេចទៅហើយ អាចត្រូវបញ្ឆបានយ៉ាងងាយ ដោយវោហារសាស្ត្រនយោបាយដែលអ្នកនយោបាយយល់ឃើញថា សំខាន់ក្នុងបេសកកម្មស្វែងរកប្រជាប្រិយភាពនិងអំណាចរបស់ខ្លួន ។ អំពីបញ្ហានេះ លោក ចូអិល ឆារនី (Joel Charny) អ្នកតាំងលំនៅនៅប្រទេសកម្ពុជាយូរឆ្នាំមកហើយ បានអះអាងថា វប្បធម៌នយោបាយក្នុងប្រទេសនេះ គឺអំពីហិង្សា ហើយអ្នកនយោបាយតែងប្រើប្រាស់ប្រជាជនសម្រាប់សេចក្តីល្មោភអំណាចនយោបាយជ្រុលរបស់ខ្លួន ដោយមានប្រសាសន៍ថា ៖*

ភាពតានតឹងរវាងប្រជាជនកម្ពុជាភាគច្រើននឹងសហគមន៍ជនជាតិភាគតិចនៅពុំទាន់បានដោះស្រាយនៅឡើយ ។ ការចងចាំរបស់ខ្មែរអំពីការត្រួតត្រារបស់វៀតណាម អាចបង្ហាញតាមរយៈការកាប់សម្លាប់ប្រកាន់ពូជសាសន៍ជារឿយៗ ដែលតែងលើកទឹកចិត្តដោយវោហារសាស្ត្ររបស់អ្នកនយោបាយខ្មែរក្នុងការស្វែងរកប្រជាប្រិយភាពនិងអំណាចរបស់ខ្លួន (**ភ្នំពេញប៉ុស្តិ៍** ១៨ កញ្ញា - ១តុលា ១៩៩៨) ។

## លក្ខណៈសម្គាល់ខ្លះរបស់វៀតណាមនៅកម្ពុជា

*ភាពខុសគ្នាផ្នែកវប្បធម៌ គឺជាកត្តាមួយក្នុងចំណោមកត្តាជាច្រើន ដែលបណ្តាលឲ្យមានការយល់ច្រឡំរវាងមនុស្ស ។ ជំពូកនេះសិក្សាលើថា តើភាពខុសបីយ៉ាង ផ្នែកភាសា ការស្លៀកពាក់រូបរាងកាយ និងការរស់នៅដែលគេឃើញច្បាស់រវាងវៀតណាមនិងខ្មែរ ប៉ះពាល់យ៉ាងណាលើអន្តរកម្មប្រចាំថ្ងៃរវាងប្រជាជនខ្មែរជាក្រុមភាគច្រើន និងជនជាតិភាគតិចវៀតណាម ។*

## ភាសា

*ភាសាវៀតណាមដែលមានសំនៀង (សម្លេងឡើងចុះ) មិនបានធ្វើឲ្យត្រចៀកខ្មែរស្រណុកស្រួលនោះទេ ។ វៀតណាមក៏មានអារម្មណ៍ដូចគ្នាដែរ ពេលស្តាប់និងប្រើភាសាខ្មែរ ។ មិនរាប់បញ្ចូលនូវភាពខុសគ្នាផ្នែកវេយ្យាករណ៍និងភាសាសាស្ត្រ ល្បឿននៃភាសានិយាយរវាងភាសាទាំងពីរខុសគ្នាយ៉ាងខ្លាំង ។ ស្ត្រីវៀតណាមម្នាក់មានអាយុប្រមាណជាង ៤០ ឆ្នាំ ដែលជាឈ្មួញខោអាវដផុះឆ្លងដែន អាចនិយាយខ្មែរបានខ្លះ ជាឧទាហរណ៍ បានប្រាប់ឲ្យដឹងថា គាត់នឿយហត់នឹងនិយាយខ្មែរណាស់ ព្រោះថាវយឺតពេកប្រៀបធៀបនឹងភាសាវៀតណាម*[១៥] *។ ដូចគ្នានេះដែរ ប្រជាជនខ្មែរភាគច្រើនមានអារម្មណ៍ដូចគ្នា ពេលស្តាប់វៀតណាមនិយាយភាសារបស់គេ ។ កន្ទុះការអត់ឱនឲ្យគ្នាទៅវិញទៅមក អាចនឹងនាំមកនូវលទ្ធផលអាក្រក់យ៉ាងងាយ ។*

*ការចេះនិយាយភាសាក្នុងស្រុក ប្រហែលជាទុនមួយយ៉ាងប្រសើរសម្រាប់ជនអន្តោប្រវេសន៍ក្នុងការបញ្ចូលខ្លួនទៅក្នុង និងប្រកបរបរចិញ្ចឹមជីវិតក្នុងប្រទេសមួយទៀត ។ ជនជាតិវៀតណាមក្នុងប្រទេសខ្មែរ ក៏មិនជាករណីលើកលែងដែរ ។ អន្តោប្រវេសន៍វៀតណាម ដែលចាកចេញពីប្រទេសកំណើតខ្លួន ក្នុងបំណងស្វែងរក*

*ផលប្រយោជន៍សេដ្ឋកិច្ច គួររៀនភាសាអ្នកស្រុក បើមិនដូច្នោះទេ ពួកគេមិនមានឱកាសច្រើននិងទទួលស្គាល់ពីសំណាក់ក្រុមភាគច្រើននោះទេ (ប៊ែរត្រង់ដ៍ ១៩៩៦) ។ ជួនកាល ប្រសិនបើគេអាចមានលទ្ធភាពផ្គត់ផ្គង់បាន គេអាចយកចំណេញក្នុងការរកស៊ី មិនត្រឹមតែជាមួយសមាជិកទាំងឡាយរបស់ក្រុមភាគតិចរបស់គេប៉ុណ្ណោះទេ ប៉ុន្តែជាមួយប្រជាជនអ្នកស្រុកអាយផងដែរ ។ ជនជាតិវៀតណាមមួយចំនួន ត្រូវជួបឧបសគ្គផ្នែកវប្បធម៌និងភាសាក្នុងការរស់នៅរបស់ខ្លួននៅក្នុងសង្គមមួយថ្មី (**ភ្នំពេញប៉ុស្តិ៍**) ថ្ងៃទី ៦-៧ កក្កដា ២០០២) ។*

*ក្រៅពីបណ្តាលឲ្យមានការខកខានក្នុងការធ្វើសមាហរណកម្មជនជាតិភាគតិចទៅក្នុងសង្គម ភាពខុសគ្នាផ្នែកភាសា កង្វះការអត់ឱន និងគំនិតចង់ខ្ពស់លើសគេ គឺជាកត្តាមួយចំនួនដែលបាននាំឆ្ពោះទៅរកជីវិតមិនមានសុខដុមរមនាក្នុងភាពជាអ្នកជិតខាងនឹងគ្នា ។ មិនមានប្រជាជនខ្មែរច្រើនទេ ដែលចង់តាំងលំនៅជិតសហគមន៍ជនជាតិវៀតណាម ហើយការរស់នៅក្នុងផ្ទះជាមួយគ្នាកាន់តែមិនអាចទៅរួចទៀត ។ ពេលដែលសួរថា តើគាត់អាចរស់នៅជាមួយវៀតណាមក្នុងផ្ទះជាមួយគ្នាបានទេ ស្ត្រីខ្មែរម្នាក់ឆ្លើយថា នោះជារឿងដែលមិនអាចទៅរួចនោះទេ ព្រោះថាភាសាវៀតណាមរញ៉េរញ៉ៃនិងជំបីជំបា*(១៦) *(ពាក្យវៀតណាមដែលមានន័យថា «ឆ្កួត») ។ ដូចគ្នានេះដែរ វៀតណាមក៏មិនប្រាកដជាមានភាពស្រណុកស្រួលជាមួយពាក្យពេចន៍ជាភាសាខ្មែរនោះផងទេ ដូចដែលស្ត្រីវៀតណាមម្នាក់ឲ្យដឹងថា ÷*

> ខ្មែរមិនសប្បាយចិត្តនឹងពួកវៀតណាមនិយាយភាសាវៀតណាម ដែលជាភាសាគេមិនយល់ ។ ពួកគេចង់ដឹងនូវអ្វីៗ ដែលវៀតណាមនិយាយគ្នា និងខ្លាចវៀតណាមនិយាយអាក្រក់ពីខ្លួន ។ ពួកខ្មែរចង់ឲ្យយើងរៀននិងនិយាយខ្មែរ ចុះហេតុអ្វីបានជាខ្មែរមិនរៀនវៀតណាមវិញទៅ ?(១៧) ។

*ពុំមានការលើកទឹកចិត្តណាមួយសម្រាប់ឲ្យអ្នកស្រុករៀនភាសាវៀតណាមនោះទេ ប៉ុន្តែវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា រៀនភាសាខ្មែរជាករណីផ្ទុយស្រឡះពីនោះ ។*

## ការប្រកបរបរចិញ្ចឹមជីវិត

*ខុសពីភាសា ភាពខុសគ្នាក្នុងការប្រកបរបរចិញ្ចឹមជីវិតរវាងជនជាតិវៀតណាមនិងខ្មែរមិនអាចចែកដាច់ពីគ្នាស្រឡះបានទេ ប៉ុន្តែជារឿយៗ គេអាចសម្គាល់បាន ។ ជាជនអន្តោប្រវេសន៍ស្របច្បាប់ ឬមិនស្របច្បាប់ និងជាវៀតណាមកើតនៅកម្ពុជា ពួកគេកម្ររើសអើងការងារណាស់ ។ ការងាររបស់គេសម្រាប់បុរស អាចមានពីការរកស៊ីជំនួញថ្នាក់មធ្យម និងសម្រាប់ស្ត្រី ពីស្ត្រីពេស្យាដល់ទៅការរើសសំរាម សម្រាប់មនុស្សទាំងពីរភេទនេះ មិននិយាយដល់អ្នកជំនួញធំៗ ទាំងឡាយ ដែលមានខ្សែស្រឡាយជាមួយអ្នកនយោបាយខ្មែរជាន់ខ្ពស់ ឬអ្នកបើកសហគ្រាសធំៗឡើយ ។ ហើយនេះក៏មិនមានន័យថា ពុំមានខ្មែរណាម្នាក់ប្រកបរបរដូចពោលមកខាងលើនេះដែរ ។*

*ជំនួញខ្នាតតូចមួយចំនួនក្នុងចំណោមនោះ ត្រូវបានទទួលការមើលរំលងដោយប្រជាជនខ្មែរ ព្រោះគេគិតថា គេពុំអាចរកបានលុយច្រើន ឬអ្នកដទៃអាចមើលងាយគេដោយសារជំនួញនេះ ។ ផ្ទុយទៅវិញ ជនជាតិវៀតណាមប្រកបរបរចិញ្ចឹមជីវិត ពីមុខរបរតូចតាចទាំងនេះ បានប្រសើរជាងអ្នកស្រុក ។ ការងារទាំងនេះ រួមមាន ការរើសអេតចាយ ការដើរលក់ទំនិញបន្តិចបន្តួចតាមផ្លូវ ធ្វើកូនសោតាមតូប ឬដាក់កង់សំអាតស្បែកជើង ធ្វើក្រចកដៃក្រចកជើង និងដេរស្បែកជើងជាដើម ។ វាមិនអាចទៅរួចនោះទេ សម្រាប់ប្រជាជនខ្មែរយ៉ាងច្រើន*

ឲ្យប្រកបរបរគ្រូខ្មាសអៀនទាំងនេះ[១៨] ។

ជំនួញមួយចំនួនទៀត ត្រូវបានដំណើរការភាគច្រើនក្នុងសហគមន៍វៀតណាម តែជួនកាលក៏ក្នុងចំណោមសហគមន៍ខ្មែរផងដែរ ។ សកម្មភាពជំនួញប្រចាំថ្ងៃអាចងាយមើលឃើញនិងសម្គាល់បាន រួមមានដូចជា លក់សម្លៀកបំពាក់ ផ្លែឈើ និងកាហ្វេ ចំណែកខ្លះទៀត ធ្វើជាជាងឈើ កម្មករសំណង់ និងជាងម៉ាស៊ីន ជាដើម ។ ផលិតផលរបស់ពួកគេ ទោះគុណភាពយ៉ាងណាក៏ដោយ មានសភាពក្រៅស្អាតទាក់ភ្នែក ហើយតែងមានតម្លៃថោកជាងទំនិញខ្មែរ ។ សេវាកម្ម គឺពិតជាត្រូវបានអ្នកជិតខាងនិងអតិថិជនខ្មែរសរសើរច្រាកដមែន ហើយជួនកាល ច្រណែននឹងភាពប៉ិនប្រសប់របស់វៀតណាមទាំងនោះផង[១៩] ។ ជនជាតិវៀតណាមនៅទីក្រុងចូលចិត្តប្រកបរបរខាងលើនេះសម្រាប់ចិញ្ចឹមជីវិត ដែលភាគច្រើនខុសពីវៀតណាមដែលរស់នៅតាមជនបទ ។

ប្រកពមួយទៀត ដែលពេញនិយមសម្រាប់ឲ្យអន្តោប្រវេសន៍វៀតណាមនៅជនបទ រកលុយចិញ្ចឹមជីវិត គឺការនេសាទនៅតាមដងបឹងទន្លេសាប ។ ជាតិសាសន៍នេះ ដែលបញ្ចូលខ្លួនជាមួយវប្បធម៌ចាម មានជំនាញធ្វើការនៅក្នុងទឹក ខុសពីប្រជាជនខ្មែរដែលចូលចិត្តការងារលើគោកច្រើនជាង (ការបង្រៀនរបស់លោក ឌីហ្វូឡូថ ខែកក្កដា ២០០៥ នៅមជ្ឈមណ្ឌលខេមរសិក្សា សៀមរាប) ។ អ្នកទាំងនោះរស់នៅតាមភូមិបណ្តែតទឹក ដែលធ្វើឲ្យខូចបរិស្ថាននិងបំពុលទឹកឲ្យកខ្វក់ ។ ការនេះ អាចទាំងផ្តល់ឱកាសល្អឲ្យអាជ្ញាធរមូលដ្ឋានគាបសង្កត់យកលុយពីប្រជាជនបណ្តែតទឹកទាំងនោះផង (**ភ្នំពេញប៉ុស្តិ៍** ៦-៧ កក្កដា ២០០២) ។

ក្នុងករណីនេះ វប្បធម៌ខ្លាចបាក់មុខរបស់ខ្មែរ (មេរៀនរបស់លោក គីថឺរ ហាំម៉ឺរ ១៨ កក្កដា ២០០៥ នៅមជ្ឈមណ្ឌលខេមរសិក្សា សៀមរាប) តាមរយៈការបំពេញការងារនិងប្រកបរបរតូចតាច គួរឲ្យខ្មាសគេទាំងនេះ បានធ្វើឲ្យមានការមើលងាយលើប្រជាជនវៀតណាម ដែលប្រកបរបរចិញ្ចឹមជីវិតដោយមុខជំនួញនេះ ។ តាមពិតទៅ ជនជាតិភាគតិចវៀតណាម គួរត្រូវបានអបអរសាទរនិងជូនរង្វាន់ជាអារម្មណ៍ស្និទ្ធស្នាលចំពោះទេពកោសល្យដែលគេមាន ។ វៀតណាមទាំងនេះ ពិសេសស្ត្រីនិងក្មេងស្រី មិនទាំងលាក់បំបាំងនូវអត្តសញ្ញាណរបស់គេ ដើម្បីបញ្ជៀតខ្លួនកាន់តែស្រួលចូលទៅក្នុងសង្គមថ្មីផង ។ ពួកគេនៅតែបន្តរស់នៅជាជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជា ។

អ្វីដែលកាន់តែគួរឲ្យចាប់អារម្មណ៍ទៀតនោះ គឺថា ប្រជាជនខ្មែរមួយចំនួន ពិតជាបន្ថោកតម្លៃវប្បធម៌របស់វៀតណាម ដោយធ្វើការសន្និដ្ឋានជាទូទៅថា ក្មេងស្រីវៀតណាមដល់អាយុ ១៥ ឆ្នាំ តែងរកស៊ីចិញ្ចឹមជីវិត ឬចិញ្ចឹមគ្រួសារដោយធ្វើជាស្រីពេស្យា[២០] ។ គំនិតនេះ ទោះយ៉ាងណា មិនត្រូវបានគាំទ្រដោយប្រជាជនខ្មែរភាគច្រើននោះទេ ដូចដែលព្រះសង្ឃមួយអង្គពិភាក្សាជាមួយនោះដែរ បានប្រដាំងថា ៖

> ការអះអាងនេះធ្វើឡើងដោយមិនមានភស្តុតាងអ្វីទាំងអស់ ។ មិនមែនក្មេងស្រីវៀតណាមអាយុលើសពី ១៥ ឆ្នាំ ទាំងអស់ចិញ្ចឹមជីវិតដោយធ្វើជាស្រីពេស្យានោះទេ ។ ការពិតគឺថា តែងមានមូលហេតុជាច្រើននៅពីក្រោយ ដែលបានបង្ខំគេឲ្យទៅរកស៊ីនៅបនពេស្យាចារ ដូចជាស្រីខ្មែរមួយចំនួនដែរ[២១] ។

យោបល់នេះ បានបង្ហាញយ៉ាងច្បាស់នូវការយល់ឃើញអវិជ្ជមានចំពោះក្មេងស្រីវៀតណាម ដែលចូលចិត្តស្លៀកសម្លៀកបំពាក់ដេកម្យ៉ាង ដោយសន្និដ្ឋានថា ពួកគេជាស្រីបម្រើផ្លូវភេទ ។ មានខ្មែរមួយចំនួនប្រើពាក្យ

*«ស្រីពេស្យា» ប្រដូចនឹងស្រីវៀតណាម (***កម្ពុជាដេលី*** ថ្ងៃទី ៦-៧ កក្កដា ២០០២) ។*

## សម្លៀកបំពាក់និងរូបរាងខាងក្រៅ

*ក្នុងពិភពលោកដែលមានការផ្លាស់ប្ដូរយ៉ាងលឿននេះ រកភាពខុសគ្នារវាងខ្មែរនិងវៀតណាម ផ្នែកសម្លៀកបំពាក់និងសំបកក្រៅ មិនមែនជាការងាយស្រួលទេ ដោយហេតុថា វប្បធម៌របស់សាសន៍ទាំងពីរនេះបានជះឥទ្ធិពលឲ្យគ្នាទៅវិញទៅមករាប់សតវត្សរ៍មកហើយ ។ អន្តរឥទ្ធិពលផ្នែកវប្បធម៌នេះ ពុំអាចបដិសេធបានឡើយ ព្រោះថាការធ្វើដំណើររបស់វប្បធម៌ឆ្លងកាត់ទ្វីប កើតមានរាប់សតវត្សរ៍មុនទៅទៀត (ការបង្រៀនរបស់អ្នកស្រី ធីណា អូល្វីយេ៉រ៍ នៅមជ្ឈមណ្ឌលខេមរសិក្សា សៀមរាប ២០០៥) ។ ខ្មែរនិងវៀតណាមក៏ធ្លងគ្នាដែរ ។ សម្លៀកបំពាក់ក្នុងករណីនេះ ដែលជាផលិតផលនៃពិភពលោក ដែលមានទំនាក់ទំនងផ្នែកឧស្សាហកម្មកាន់តែខ្លាំង ប្រាកដជាមិនមែនជាសញ្ញាណល្អមួយដើម្បីអះអាងថា អ្នកពាក់វាជាអ្នកណានោះទេ ។ ហើយវាកាន់តែលំបាកលើសនេះទៅទៀត ក្នុងការរកភាពខុសគ្នារវាងក្រុមជាតិសាសន៍ទាំងពីរដោយសំបកក្រៅនោះ ។ លើសពីនេះទៀត វាកាន់តែលំបាកទ្វេឡើងទៀត សម្រាប់ឲ្យមនុស្សម្នាក់ផ្ដាច់ចេញទាំងស្រុងពីបុសគល់របស់ខ្លួន ឬពីអត្តសញ្ញាណផ្ទាល់របស់ខ្លួន ។*

*ស្ត្រីវៀតណាមភាគច្រើន គ្រប់ក្រុមអាយុទាំងអស់ ដែលរស់នៅក្នុងប្រទេសកម្ពុជា ហាក់បីដូចជាមានមោទនភាពនឹងអត្តសញ្ញាណរបស់ខ្លួន ក្នុងការពាក់សម្លៀកបំពាក់ប្រពៃណីរបស់គេ ក្នុងទីសាធារណៈ ដែលអាចធ្វើឲ្យខុសប្លែកពីអ្នកស្រុកទូទៅ ។ ស្ត្រីវៀតណាមម្នាក់ជឿថា ស្រីៗ វៀតណាមចូលចិត្តឈុតគេងនោះ មិនថាផលិតនៅកម្ពុជា ឬនាំចូលមកពីវៀតណាមនោះទេ ព្រោះថាវាជាសម្លៀកបំពាក់ប្រពៃណីវៀតណាម ដែលយកគំរូតាមចិន[២២] ។*

*ទោះជាវៀតណាមមួយចំនួនអាចនិយាយខ្មែរយ៉ាងស្ទាត់ដូចខ្មែរក៏ដោយ ពួកគេជួនកាលនៅតែត្រូវប្រជាជនខ្មែរស្អប់ខ្ពើមដដែល ពេលដែលស្លៀកពាក់សម្លៀកបំពាក់ប្រពៃណីនោះ ។ ស្ត្រីវៀតណាមម្នាក់នៅភ្នំពេញស្លៀកឈុតគេង ត្រូវបានអ្នកលក់ត្រីខ្មែរជេរថា «មេយួន[២៣]» ពេលសួរថ្លៃហើយមិនទិញ ។ ក្រោយពីនោះទៀត គាត់ត្រូវបានអ្នករត់ម៉ូតូឌុបខ្មែរម្នាក់ដឹកទៅដាក់ប៉ុស្ដិ៍នគរបាល ព្រោះអ្នកម៉ូតូឌុបឃើញស្លៀកពាក់ឈុតដេក ស្មានថា ជាវៀតណាមរស់នៅខុសច្បាប់[២៤] ។*

*គំនិតដែលថា កំណត់អត្តសញ្ញាណវៀតណាមដោយសំបកក្រៅងាយស្រួលនោះ មិនប្រាកដថា ត្រូវទាំងអស់នោះទេ ។ ជួនកាល គេអាចស្គាល់វៀតណាមបានតាមរយៈមុខ ត្របកភ្នែក និងសម្បុរ[២៥] ។ ប្រុសវៀតណាមក៏ស្ថិតក្នុងបុគ្គលិកលក្ខណៈដូចគ្នានេះដែរ ព្រមជាមួយសញ្ញាពិសេសមួយចំនួនទៀតនៅលើសក់ ។ គេចូលចិត្តទុកសក់វែងដោយមិនតម្រង់ឬសិតនោះឡើយ ដែលជាម៉ូតមួយដែលប្រហែលជាទុកឲ្យសមនឹងលក្ខខណ្ឌការងាររបស់គេ ។ ហើយប្រសិនបើគេកាត់ខ្លី ជួនកាលមានម៉ូតតម្រឹមជើងបែបវៀតណាម[២៦] ។ សរុបសេចក្ដីមក ទោះយ៉ាងណា គេទទួលស្គាល់ជាសាកលថា បុគ្គលិកលក្ខណៈទាំងនេះ មិនអាចយកទៅប្រើចំពោះគ្រប់បុគ្គលទាំងអស់ជាវៀតណាមនោះទេ ព្រោះថាពួកគេមានខ្សែជីវិតខុសគ្នានិងតាំងនៅក្នុងស្ថានភាពខុសគ្នាទៀតផង ។ ទោះជា*

មានការលំបាកក្នុងការកំណត់អត្តសញ្ញាណ ភាពខុសគ្នាផ្នែកវប្បធម៌ គឺពិតជាប្លុសគល់មួយក្នុងចំណោមប្លុសគល់ជាច្រើនដែលនាំមកនូវអារម្មណ៍មិនចូលចិត្តគ្នា (ថ្យុង ១៩៩៣: ២២៥-២៣៥) ។

ធាតុបីក្នុងចំណោមធាតុជាច្រើន ដែលបង្កើតឲ្យមានភាពខុសគ្នាផ្នែកវប្បធម៌រវាងជនភាគតិចវៀតណាម និងជនភាគច្រើនខ្មែរប៉ុណ្ណោះ ត្រូវលើកយកមកពិភាក្សានៅទីនេះ ។ ភាសាអាចចាត់ទុកជាសញ្ញាសម្គាល់ចម្បងបំផុតសម្រាប់ជនជាតិវៀតណាម ចំណែកធាតុពីរទៀត មានការប្រកបរបរចិញ្ចឹមជីវិត និងសំបកខាងក្រៅមានតួនាទីបន្ទាប់ ។ លើសពីនេះទៀត តួនាទីដែលកត្តាផ្សេងទៀតដូចជា សាសនា និងចម្រៀងភ្លេង ជាដើម អាចមានក្នុងបញ្ហាអរិភាពរវាងគ្នានេះ អាចជាប្រធានបទស្រាវជ្រាវមួយដោយឡែកទៀត ។

# សេចក្តីសន្និដ្ឋាន

អ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះគឺថា អន្តរទំនាក់ទំនងរវាងប្រជាជនខ្មែរនិងវៀតណាមរស់នៅក្នុងប្រទេសកម្ពុជា និងហួសពីនេះ ត្រូវឱនលំទោនទៅតាមការបកស្រាយប្រវត្តិសាស្ត្រនៃទំនាក់ទំនងរវាងក្រុមអំបូរជាតិសាសន៍ទាំងពីរ ។ ក្នុងបញ្ហានេះ ខ្មែរប្រកាន់យ៉ាងខ្ជាប់ថា វៀតណាមត្រូវទទួលខុសត្រូវយ៉ាងហោចណាស់នូវផ្នែកណាមួយសម្រាប់ការធ្លាក់ចុះរបស់អាណាចក្រខ្មែរនាសម័យអង្គរហូតមក (**ទស្សីតម្ពុជា** ២០០១) និងការភ្ជាប់ដែនដីភាគខាងត្បូងនៃអតីតអាណាចក្រនេះ ទៅក្រោមការគ្រប់គ្រងរបស់ខ្លួនរហូតមកដល់សព្វថ្ងៃនេះ ។ អ្វីដែលប្រជាជនខ្មែរបានរៀនសូត្រតាមប្រវត្តិសាស្ត្ររហូតមក មិនងាយនឹងរលុបបាត់ពីបេះដូងទៅវិញនោះទេ លើកលែងតែក្រុមជាតិសាសន៍ទាំងពីរព្រមរួមគ្នាដោះស្រាយអរិភាព ដែលមានរាប់សតវត្សរ៍មកហើយនេះ ។

ទំនាក់ទំនងនិងជម្លោះយូរអង្វែងមកហើយនោះ បានផ្តល់ជាលទ្ធផលដល់វៀតណាមនូវអំណោយមួយដ៏អសោចមានឈ្មោះថា «យួន» ។ ទោះបីជាពាក្យនេះត្រូវបានគេប្រើប្រាស់ពីដំបូង ដោយមានន័យមិនលំអៀងសំដៅត្រឹមលើជនជាតិបរទេស ឬក្រុមមនុស្សព្រៃភ្នំនៅតំបន់តុងកឹងក៏ដោយ ក៏ឥឡូវនេះ ន័យនោះបានប្រាសចាកសភាពដើមរបស់ខ្លួនអស់ទៅហើយ ។ ពេលណាដែលគេប្រើពាក្យយួននេះ គ្រប់គ្នាតែងយល់នូវន័យជេរប្រមាថរបស់វា ហើយបរិយាកាសមិនសប្បាយរីករាយនឹងលេចឡើងយ៉ាងក្រឡែតចំពោះទាំងខ្មែរ ទាំងវៀតណាម ។ ដូច្នេះ ប្រសិនណាបើមានសមាជិកណាម្នាក់ចេញពីក្រុមអំបូរខ្មែរចង់រាប់អានជាមួយក្រុមជនជាតិវៀតណាម គេត្រូវប្រយ័ត្នខ្ជាចក្រែងពាក្យអពមង្គលនេះហូរចេញឯង ៗ ពីបបូរមាត់របស់គេ ដែលនឹងអាចធ្វើឲ្យខូចមិត្តភាពរបស់គេដោយថាហេតុ ។

ទោះយ៉ាងណា មិត្តភាពរវាងគ្នាឆ្លងសាសន៍មិនងាយស្រួលនឹងមាននោះទេ ព្រោះថាវាមិនអាស្រ័យទាំងស្រុងលើកិច្ចខិតខំប្រឹងប្រែងរបស់បុគ្គលប៉ុណ្ណោះទេ ប៉ុន្តែក៏អាស្រ័យលើកត្តាសង្គមនយោបាយផងដែរ ។ ស្ថានភាពកាន់តែមានសភាពធ្ងន់ ដោយបញ្ហាមួយចំនួន កំពុងបន្ត និងដែលមិនបានដោះស្រាយ ក្នុងនោះ រួមមាន អន្តោប្រវេសន៍វៀតណាម ការរំលោភព្រំដែនពីសំណាក់វៀតណាម និងនយោបាយក្នុងស្រុករបស់កម្ពុជា ដែលជាលទ្ធផលនៃបញ្ហាទាំងពីរខាងដើម ។ ដោយហេតុថា បក្សកាន់អំណាចមិនទំនងជាមានការប្តេជ្ញាចិត្តមុតមាំនឹងដោះស្រាយបញ្ហាខ្វែងគំនិតទាំងនេះឆាប់ៗ បក្សប្រឆាំងបន្តទទួលបានបរិយាកាសកាន់តែធំ ដើម្បីបំពងសំឡេងវោហារសាស្ត្រ

ប្រឆាំងនឹងវៀតណាម សម្រាប់បំណងនយោបាយរបស់គេ ។ ជាលទ្ធផល សមាជិកនៃក្រុមអំបូរទាំងពីរនឹងលំបាករកឲ្យឃើញ នូវមធ្យោបាយប្រសើរ ដើម្បីរឹតចងទំនាក់ទំនងរបស់ពួកគេ ដែលជាប្រការមួយត្រូវរដ្ឋាភិបាលទាំងពីរទទួលខុសត្រូវ ។

រដ្ឋាភិបាលជាភ្នាក់ងារតែមួយគត់ ដែលមានមធ្យោបាយគតិយុត្តនិងអាជ្ញាធរគ្រប់គ្រាន់ សម្រាប់កម្ចាត់បង្កនូវបញ្ហាសង្គមទាំងនេះ ។ ច្បាស់ណាស់ថា ការប្រើប្រាស់ប្រវត្តិសាស្ត្រសម្រាប់នយោបាយលំបាកនឹងស្រមៃថាជាមូលហេតុចម្បង ដែលប្រៀបដូចការយកឈើចាក់ដំបៅចាស់នៃភាពមិនជឿជាក់និងការស្អប់ខ្ពើម ដែលប្រ-ជាជនខ្មែរមានជាមរតករហូតមក ប៉ុន្តែនេះជាការពិត ។ ទោះយ៉ាងណា អត្ថបទនេះមិនមានបំណងបន្ទុះបង្អាប់ឲ្យបំភ្លេចប្រវត្តិសាស្ត្រនោះទេ ហើយលើកសរសើរឲ្យមានការប្រើប្រាស់ប្រវត្តិសាស្ត្រអាក្រក់ៗ តាមអំពើចិត្តក្នុងឆាកនយោបាយនោះក៏ទេដែរ ។ រដ្ឋាភិបាលនៅតែជាមគ្គុទ្ទេសក៍ធំបំផុតក្នុងការដោះស្រាយប្រកបដោយប្រសិទ្ធភាពអំពីបញ្ហាព្រំដែននិងអន្តោប្រវេសន៍ខុសច្បាប់ ដែលជាបញ្ហាគ្មានរដ្ឋណាមួយបណ្តោយឲ្យនៅក្រៅច្បាប់នោះទេ ។

ប្រសិនបើបញ្ហាដែលកើតឡើងម្តងហើយម្តងទៀតនេះ ត្រូវបានដោះស្រាយត្រឹមត្រូវ អ្នកនយោបាយប្រាកដជានឹងលែងមានឱកាសបញ្ចូញការឃោសនាជាតិសាសន៍និយម ដើម្បីចោទប្រកាន់រដ្ឋាភិបាលបានទៀតហើយ ។ ប្រវត្តិសាស្ត្របានបង្ហាញនូវភស្តុតាងគ្រប់គ្រាន់ថា អ្នកនយោបាយជាកត្តាចម្បងអុជអាលឲ្យមានអរិភាពដូចដែលលោក ឆាង សុង រដ្ឋមន្ត្រីក្រសួងព័ត៌មានក្នុងរបប លន់ នល់ (គ.ស. ១៩៧០–១៩៧៥) បានមានប្រសាសន៍ថា ៖

> គេត្រូវស្តីបន្ទោសអ្នកនយោបាយឲ្យច្រើនជាងប្រវត្តិសាស្ត្រ ព្រោះថាអ្នកដឹកនាំខ្មែរជាច្រើនបានលើកទឹកចិត្តខ្មែរឲ្យស្អប់អ្នកជិតខាងដ៏ធំរបស់ខ្លួន [វៀតណាម] (**ភ្នំពេញប៉ុស្តិ៍** ថ្ងៃទី ១២-១៧ កញ្ញា ១៩៩៨) ។

និយាយម្យ៉ាងទៀត ដំណោះស្រាយស្របច្បាប់ត្រឹមត្រូវមួយលើបញ្ហាវៀតណាមរស់នៅកម្ពុជានិងព្រំដែនមានន័យថា ជាការផ្តល់យុត្តិធម៌ដល់ទាំងអ្នកក្នុងស្រុក ដល់ទាំងអ្នកចំណូលស្រុកជាវៀតណាមផងដែរ ។

លើសពីនេះទៀត គេក៏ត្រូវយកចិត្តទុកដាក់ដោះស្រាយភាពខុសគ្នាផ្នែកវប្បធម៌ផងដែរ ព្រោះថាវាក៏ពិតជាបានដើរតួនាទីមួយក្នុងការធ្វើឲ្យភាពសុខដុមរមនាត្រូវរង្គោះរង្គើផងដែរ ។ ភាសា សម្លៀកបំពាក់និងសំបកក្រៅ ហើយនិងការចិញ្ចឹមជីវិត ចំណុចបីក្នុងចំណោមភាពខុសគ្នាជាច្រើនដែលគេអាចរកឃើញ ពិតជាបានផ្តល់នូវមេរៀនល្អៗ ឲ្យយល់ពីតួនាទីដែលវប្បធម៌មានក្នុងបញ្ហានេះ ។ ដើម្បីឲ្យចំណងរវាងគ្នានឹងគ្នាមានសុខដុមរមនាពិសេស អ្នករស់នៅក្នុងប្រទេសកម្ពុជាខុសច្បាប់ឬស្របច្បាប់ មិនមែនជាបញ្ហាកាប់សម្លាប់ក្រុមអំបូរសាសន៍ដទៃដូចដែលប្រវត្តិសាស្ត្របានបង្រៀននោះទេ តែជាការខិតខំប្រឹងប្រែងស្វែងរកមធ្យោបាយផ្លូវច្បាប់ ដើម្បីធ្វើសមាហរណកម្មអ្នកមានសិទ្ធិគ្រប់គ្រាន់ ក្នុងការរស់នៅ និងដំណោះស្រាយការទូត សម្រាប់អ្នកដទៃទៀត ៕

## ជំពូកទី ១៖ ឧស្សាហូបនីយកម្មនិងការជះឥទ្ធិពល

## អំណានផ្សេងទៀតដែលទាក់ទងនឹងប្រធានបទនេះ

◉ខឹស្ហមែន, ចេន្នីហ្វឺរ (Cushman, Jennifer) និង វ៉ាំងគុងអ៊ូ (Wang Gungwu) (បណ្ណាធិការ) គ.ស. ១៩៨៨ *Changing Identities of the Southeast Asian Chinese since World War Two* [**បម្រែបម្រួលអត្តសញ្ញាណរបស់ជនជាតិចិននៅអាស៊ីអាគ្នេយ៍ចាប់តាំងពីសម័យសង្គ្រាមលោកលើកទី ២**] ហុងកុង ។

◉ដូណឺរ, រីឆាដ (Doner, Richard) គ.ស. ១៩៩១ "Approaches to the Politics of Economic Growth in Southeast Asia" «[ដំណោះស្រាយចំពោះនយោបាយកំណើនសេដ្ឋកិច្ចនៅក្នុងតំបន់អាស៊ីអាគ្នេយ៍]» *Journal of Asian Studies* [**ព្រឹត្តិបត្រសិក្សាអាស៊ី**] ៥០,៤ (វិច្ឆិកាគ.ស. ១៩៩១) ទ. ៨១៨-៨៤៩ ។

◉បែលឡូ, វ៉ាល់ដេន (Bello, Walden) និង រ៉ូហ្សិនហ្វែលដ៍ ស្តេហ្វានី (Rosenfeld, Stephanie ) គ.ស. ១៩៩០ *Dragons in Distress: Asia's Miracle Economies in Crisis* [**ពួកនាគនៅក្នុងគ្រោះថ្នាក់ ៖ អព្ភូតហេតុសេដ្ឋកិច្ចរបស់អាស៊ីនៅក្នុងភាពមានខបត្តិ**] សាន់ហ្វ្រាន់ស៊ីស្កូ ។

◉បោអឺរ, ចូអេន្ន (Bauer, Joanne) និង ប៊ែល្ល ដេនៀល (Bell, Daniel) (បណ្ណាធិការ) គ.ស. ១៩៩៩ *The East Asian Challenge for Human Rights* [**ការប្រឈមរបស់អាស៊ីបូព៌ាដើម្បីសិទ្ធិមនុស្ស**] ខេមប្រ៊ីដហ្ស៍ (Cambridge) ។

◉ប្រ៊ូក, ទីម៉ូធី (Brook, Timothy) និង លឿង វ៉ាន់ហ៊ី (Luong Van Hy) (បណ្ណាធិការ) គ.ស. ១៩៩៩ *Culture and Capitalism: The Shaping of Capitalism in Eastern Asia* [**វប្បធម៌និងមូលធននិយម ៖ ការកកើតឡើងនូវរបបមូលធននិយមនៅតំបន់អាស៊ីបូព៌ា**] អាន្នអារប័រ (Ann Arbor) ។

◉ម៉ាក់វ៉ី, រូធ (McVey, Ruth) គ.ស. ១៩៩២ *Southeast Asian Capitalists* [**ជនមូលធននិយមអាស៊ីអាគ្នេយ៍**] អ៊ីថាកា ។

◉យ៉ូស៊ីហារ៉ា គុនីអូ (Yoshihara Kunio) គ.ស. ១៩៨៨ *The Rise of Ersatz Capitalism in Southeast Asia* **ការកកើតឡើងនូវរបបមូលធននិយមគុណភាពថោកទាប ក្នុងតំបន់អាស៊ីអាគ្នេយ៍**] សិង្ហបុរី ។

◉ហេល, គ្រីស្តូហ្វឺរ (Hale, Christopher) គ.ស. ២០០១ "Indonesia's National Car Project Revisited: The History of Kia Timor Motors and Its Aftermath" «[ការពិចារណាឡើងវិញអំពីគម្រោងផលិតរថយន្តថ្នាក់ជាតិរបស់ប្រទេសឥណ្ឌូនេស៊ី ៖ ប្រវត្តិ និងផលសម្រេចរបស់ក្រុមហ៊ុនផលិតរថយន្តគៀទីម័រម៉ូតូរស៍]» *Asian Survey* [**ព្រឹត្តិបត្រអង្កេតអាស៊ី**] ៤១.៤ (កក្កដា-សីហាគ.ស. ២០០១) ទ. ៦២៩-៦៤៩ ។

◉ហ្គូដឺម៉ង់ត៍, ហ្វ្រង់ស័រ (Godement, François) គ.ស. ១៩៩៩ *The Downsizing of Asia* [**ការបន្ថយចំនួនបុគ្គលិករបស់អង្គភាពអាជីវកម្មនៃតំបន់អាស៊ី**] ញូយ៉ក ។

◉ហ្គូស្លីង, ភីថឺរ (Gosling, Peter) និង លីម លីណ្ដា (Lim, Linda) (បណ្ណាធិការ) គ.ស. ១៩៨៧ *The Chinese in Southeast Asia* [**ជនជាតិចិននៅអាស៊ីអាគ្នេយ៍**] អាន្នអារប័រ ។

◉ហ្គ្រីដឺរ, វិល្លៀម (Greider, William) គ.ស. ១៩៩៨ *One World, Ready or Not: The Manic Magic of Global Capitalism* [**ពិភពលោកតែមួយត្រៀមរួចជាស្រេចហើយឬនៅ ៖ វេទមន្តដ៏មមាញឹកនៃរបបមូលធននិយមពិភពលោក**] ញូយ៉ក ។

◉អុង, អៃហ៍វ៉ា (Ong, Aihwa) និង ណូនីនី ដូណាល់ដ៍ (Nonini Donald) (បណ្ណាធិការ) គ.ស. ១៩៩៧ *Ungrounded Empires: The Cultural Politics of Modern Chinese Transnationalism* [**ចក្រភពគ្មានតំបន់តាំង ៖ នយោបាយវប្បធម៌នៃអន្តរអន្តោប្រវេសន៍របស់ជនជាតិចិនសម័យទំនើប**] ញូយ៉ក ៕

## ជំពូកទី ២ ៖ ឥទ្ធិពលនៃ «អព្ភូតហេតុ» សេដ្ឋកិច្ចទៅលើមនុស្ស

## អំណានផ្សេងទៀតដែលទាក់ទងនឹងប្រធានបទនេះ


◉ប្រោដ, រ៉ូប៊ីន (Broad, Robin) គ.ស. ១៩៩៣ *Plundering Paradise: The Struggle for the Environment in the Philippines* [ការប្លន់ឋានសួគ៌ ៖ ការតស៊ូដើម្បីបរិស្ថាននៅក្នុងប្រទេសហ្វីលីពីន] ប៊ីរឃ្លេយ៍ ។

◉ពិនឆេស, ម៉ៃខឹល (Pinches, Michael) (បណ្ណាធិការ) គ.ស. ១៩៩៩ *Culture and Privilege in Capitalist Asia* [វប្បធម៌ និងបុព្វសិទ្ធិ នៃបណ្ដាប្រទេសមូលធននិយមអាស៊ី] ឡុងដ្រ៍ ។

◉ រ៉ូដេន, ហ្គែរី (Rodan, Garry), ហេវីសុន ខេវីន (Hewison Kevin) និង រីឆាដ រ៉ូប៊ីនស៊ុន (Robison Richard) (បណ្ណាធិការ) គ.ស. ១៩៩៧ *The Political Economy of South-East Asia: An Introduction* [សេដ្ឋកិច្ចនយោបាយនៃតំបន់អាស៊ីអាគ្នេយ៍ ៖ ការបង្ហាញឱ្យស្គាល់] ម៉ិលប៊ន (Melbourne) ។

◉រ៉ូប៊ិនស៊ុន, រីឆាដ (Robinson, Richard) និង ហ្គុដម៉ែន ដេវីដ អេស. ហ្សេ. (Goodman David S. G.) (បណ្ណាធិការ) គ.ស. ១៩៩៦ *The New Rich in Asia: Mobile Phones, McDonald's and Middle-Class Revolution* [ពួកអ្នកមានថ្មីនៅអាស៊ី ៖ បដិវត្តន៍ទូរស័ព្ទចល័ត ម៉ាក់ដូណាល់ដ៍ និងវណ្ណៈថ្នាក់កណ្ដាល] ឡុងដ្រ៍ ។

◉ វ៉ូលហ្វ៍, ដាយអេន (Wolf, Diane) គ.ស. ១៩៩២ *Factory Daughters: Gender, Household Dynamics, and Rural Industrialization in Java* [កូនស្រីក្នុងរោងចក្រ ៖ យេនឌ័រ ថាមពលថ្នាក់គ្រួសារ និងឧស្សាហូបនីយកម្មនៅតំបន់ជនបទនៅក្នុងកោះជ្វា] ប៊ីរឃ្លេយ៍ ។

◉ស្កុត្ត, ចេមស៍ សេ. (Scott, James C.) គ.ស. ១៩៨៥ *Weapons of the Weak: Everyday Forms of Peasant Resistance* [អាវុធរបស់អ្នកទន់ខ្សោយ ៖ ទម្រង់ប្រឆាំងតបតទៀងទាត់ថ្ងៃរបស់កសិករ] ញូហេវិន (New Haven) ។

◉ស្តិនស៊ុន, ម៉ៃខឹល (Stenson, Michael) គ.ស. ១៩៨០ *Class, Race and Colonialism in West Malaysia* [វណ្ណៈ ពូជសាសន៍ និងអាណានិគមនិយម នៅម៉ាឡេស៊ីខាងលិច] សិនត៍លូសៀ (St. Lucia) ឃ្វីនស៍ឡេនដ៍ (Queensland) ។

◉ហឺសដ៍, ហ្វីលីព (Hurst, Philip) គ.ស. ១៩៩០ *Rainforest Politics: Ecological Destruction in South-East Asia* [គោលនយោបាយព្រៃស្ទួត ៖ ការបំផ្លិចបំផ្លាញប្រព័ន្ធអេកូឡូស៊ីនៅអាស៊ីអាគ្នេយ៍] ឡុងដ្រ៍ ។

◉ ហ្សេន្តុន, ម៉ារៀ គ្រីស្ទីណា ប្លង់ក៍ (Szanton, Maria Cristina Blanc) គ.ស. ១៩៧២ *A Right to Survive: Subsistence Marketing in a Lowland Philippine Town* [សិទ្ធិក្នុងការរស់រានមានជីវិត ៖ ការប្រកបរបររកស៊ីចិញ្ចឹមពោះនៅក្នុងក្រុងដីទំនាបមួយ នៅប្រទេសហ្វីលីពីន] យូនីវ៉ឺស៊ីធីផាក រដ្ឋពែនស៊ីលវ៉ានី ។

◉ អុង, អៃហ៍វ៉ា (Ong, Aihwa) គ.ស. ១៩៨៧ *Spirits of Resistance and Capitalist Discipline: Factory Women in Malaysia* [ស្មារតីនៃការតស៊ូអត់ធ្មត់ និងវិន័យក្នុងរបបមូលធននិយម ៖ កម្មករស្រីរោងចក្រនៅក្នុងប្រទេសម៉ាឡេស៊ី] អាល់បានី ។

◉អ៊ូ យៀនលី (Wu, Yuan-li) និង ឈុន ស៊ីអ៊ូ (Chun-Hsi Wu) គ.ស. ១៩៨០ *Economic Development in Southeast Asia: The Chinese Dimension* [ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ៖ វិសាលភាពរបស់ជនជាតិចិន] ស្តេនហ្វដ ។

◉អូស៊ីម៉ា, ហារីរ តេ. (Oshima, Harry T.) គ.ស. ១៩៨៧ *Economic Growth in Monsoon Asia* [កំណើនសេដ្ឋកិច្ចនៅក្នុងតំបន់អាស៊ីខ្យល់មូសុង] តូក្យូ ៕

## ជំពូកទី ៣ ៖ រាជានិយមតេយ្យអាស្រ័យបណ្តាញនិងវិបត្តិភាពស្របច្បាប់នៅក្នុងប្រទេសថៃ

## កំណត់ចំណាំ

(១) *ប្រេម តិណសូលានន្ទ* (เปรม ติณสูลานนท์ Prem Tinsulanond) *ឬ ប្រេម តិលសូលានន្ទ* (เปรม ติลสูลานนท์) *(អក្ខរាវិរុទ្ធទី ២ នេះ មិនសមស្របតាមអក្ខរាវិរុទ្ធជាផ្លូវការ) តាមភាសាសៀម ថា* /**ប្រេម ទិន-ស៊ូឡាណុន**/ *ឬ* /**ប្រេម ទិន-ឡ:ស៊ូឡាណុន**/ *។*

(២) *ទក្សិណ ជិនវ័ត្រ* (ทักษิณ ชินวัตร Thaksin Shinawatra) *តាមភាសាសៀម ថា* /**ថាក់ស៊ិន ឈិន-ណ:វ៉ាត់**/ *។*

(៣) *នយោបាយថៃបានផ្លាស់ប្តូរទៅរកភាពបើកចំហច្រើនជាងមុន ដោយសារតែមានការបះបោរ ដឹកនាំដោយនិស្សិតប្រឆាំងនឹងរដ្ឋាភិបាលយោធានាថ្ងៃ ១៤ តុលា ឆ្នាំ ១៩៧៣ ។ ការបើកចំហនយោបាយ នៅរយៈពេលនោះ ត្រូវបានបញ្ចប់ដោយសារតែមានការបង្ក្រាបយ៉ាងយង់ឃ្នងទៅលើចលនានិស្សិត នាថ្ងៃទី ៦ តុលា ឆ្នាំ ១៩៧៦ ។ សម្រាប់ព័ត៌មានលំអិត សូមរកមើល ម៉ូរ៉េល្លៃ* (Morell) *និង ជ័យអនន្ត (គ.ស. ១៩៨១) ។*

(៤) *ថ្នម កិត្តិខ្ចរ* (ถนอม กิตติขจร Thanom Kittikachorn) *តាមភាសាសៀម ថា* /**ថ:ណម ឃិត-ទិខ:ចន**/ *។*

(៥) *ប្រភាស ចារុស្ថៀរ (ឬ ចារុស្ថិរ)* (ประภาส จารุเสถียร Praphas Charusathien) *តាមភាសាសៀម ថា* /**ប្រ:ផាត ចារុស:ថៀន**/ *។*

(៦) *ព្រះរាម ទី ៥ គឺជាព្រះចៅ ចុឡាលង្ករណ៍ ដែលបានទទួលព្រះបរមនាមក្នុងរាជ្យ ថា ព្រះបាទសម្តេចព្រះចុល្ចចមក្លៅចៅយូហួ ... ។ ព្រះអង្គបានសោយរាជ្យពី គ.ស. ១៨៦៩ ដល់ គ.ស. ១៩១០ ។ គេទទួលស្គាល់ព្រះអង្គថា ជាស្តេចដ៏អស្ចារ្យបំផុតរបស់ប្រទេសថៃ ហើយក៏ជាគំរូសម្រាប់ព្រះចៅ ភូមិពល (ព្រះរាម ទី ៩) ។*

(៧) *វេជ្ជបណ្ឌិត ប្រវេស វ:សី* (ประเวศ วะสี Prawase Wasi *តាមភាសាសៀម ថា* /**ប្រ:វ៉េត វ៉:ស៊ី**/) *គឺជាមនុស្សដែលគួរឲ្យកត់សម្គាល់ម្នាក់ ។ ឈ្មោះរបស់លោកល្បីខ្ទរខ្ទារនៅក្នុងចំណោមវេជ្ជបុរសទាំងឡាយ ។ លោកជាវេជ្ជបណ្ឌិត និងជាអ្នកស្រាវជ្រាវ ដែលទទួលបានមេដាយ «ម៉ាគសៃសៃ* (Magsaysay)*» ហើយក៏ឋិតនៅលំដាប់ខ្ពស់ក្នុងបណ្តាញស្ថាប័នក្រៅរដ្ឋាភិបាល និងស្ថាប័នការិយាលយាធិបតេយ្យ ។ លោកថែមជាមនុស្សដ៏សំខាន់ជំរុញពីក្រោយនូវការបង្កើតរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៧ ។*

(៨) *អានន្ទ័ បន្យារជុន* (อานันท์ ปันยารชุน Anand Panyarachun *តាមភាសាសៀម ថា* /**អាណាន់ ប៉ាន់យ៉ារ៉:ឈុន**/) *ជាអតីតឯកអគ្គរាជទូតថៃប្រចាំនៅសហរដ្ឋអាមេរិក និងអង្គការសហប្រជាជាតិ ។លោកក្លាយជានាយករដ្ឋមន្ត្រី មិនតាមរយៈការបោះឆ្នោត ចំនួនពីរដងក្នុងអំឡុងពេលមានវិបត្តិ ឆ្នាំ ១៩៩១-១៩៩២ ។ ក្រោយមក លោក អានន្ទ័ ធ្វើជាប្រធានគណៈកម្មការព្រាងរដ្ឋធម្មនុញ្ញនាឆ្នាំ ១៩៩៦-១៩៩៧ ហើយបានធ្វើការនៅក្នុងក្រុមការងារអន្តរជាតិដឹកនាំដោយលោក កូហ្វី អាណាន់ ដើម្បីស្នើសុំឲ្យមានការកែទម្រង់អង្គការសហប្រជាជាតិក្នុងឆ្នាំ ២០០៤ ។*

(៩) *ស្ឫស្តិ៍ ធនៈរ័ជត៌* (สฤษดิ์ ธนะรัชต์ Sarit Thanarat) *តាមភាសាសៀម ថា* / **ស:រិត ថ:ណ:រ៉ាត់**/ *។*

(១០) *ធានិន្ទ្រ ក្រ័យវិជៀរ* (ธานินทร์ กรัยวิเชียร Thanin Kraivixian) *តាមភាសាសៀម ថា* /**ថានិន ក្រៃវិឈៀន**/ *។*

(១១) *ចម្លង ស្រីមឿង* (จำลอง ศรีเมือง Chamlong Srimuang) *តាមភាសាសៀម ថា* /**ចាំឡុង ស៊ីមឿង**/ *។*

(១២) *ចំណុចនេះបានមកពីសៀវភៅជិតចេញផ្សាយរបស់លោក ប៉ូល ហែនដ៍លេយ៍* (Paul Handley) *ស្តីអំពីព្រះមហាក្សត្រថៃ ដែលនឹងបោះពុម្ពដោយរោងពុម្ពសាកលវិទ្យាល័យយ៉េល ។ ខ្ញុំរីករាយណាស់ដោយបានទទួលការអនុញ្ញាតឲ្យយោងទៅសៀវភៅនេះ ។*

**(១៣)** ក្នុងសៀវភៅរបស់លោក ហែនដ៍លេយ៍ ។

**(១៤)** ជ័យអនន្ត សមុទ្ទវណិជ្ជ (ชัยอนันต์ สมุทวณิช Chai-Anan Samudavanija) តាមភាសាសៀម ថា /**ឆៃអ:ណាន់ ស:មុត-វ៉ៈនិត**/ ។

**(១៥)** សាស្ត្រាចារ្យ កបកៀ (២០០៣: ២៥៧) ផ្អែកលើកំណត់ចំណាំដកចេញពីទីភ្នាក់ងារព័ត៌មានបារាំង (អា.អែហ្វ.ប៉េ Agence France Presse) ២៦ វិច្ឆិកា ឆ្នាំ ១៩៨៤ ។

**(១៦)** ពិជ័យ រ័ត្តកុល (พิชัย รัตตกุล Pichai Ratakul) តាមភាសាសៀម ថា /**ភិឆៃ រ៉ាត់ត:គុន**/ ។

**(១៧)** នៅក្នុងសៀវភៅដែលនឹងចេញផ្សាយឆាប់ៗ របស់លោក ហែនដ៍លេយ៍ ។

**(១៨)** ដដែល ។

**(១៩)** ជាតិជាយ ឈុណ្ហៈវ័ណ (ชาติชาย ชุณหะวัณ Chatchai Choonhawan) តាមភាសាសៀម ថា /**ឆាត-ឆាយ ឈុន-ហ:វ៉ាន់**/ ។

**(២០)** នៅក្នុងសៀវភៅដែលនឹងចេញផ្សាយឆាប់ៗ របស់លោក ហែនដ៍លេយ៍ ។

**(២១)** សុចិន្តា គ្រាប្រយូរ (สุจินดา คราประยูร Suchinda Kraprayoon) តាមភាសាសៀម ថា /**ស៊ុជិណ្ដា ខ្រាប្រ:យូន**/ ។

**(២២)** អំពើហិង្សាបានកើតឡើងនៅក្នុងរាត្រីថ្ងៃទី ១៧ ឧសភា ប៉ុន្តែរាជរ៉ាំងមិនបានកោះហៅអ្នកបង្ករឿងរហូតដល់ថ្ងៃទី ២០ ឧសភា ។

**(២៣)** នៅក្នុងសៀវភៅដែលនឹងចេញផ្សាយឆាប់ៗ របស់លោក ហែនដ៍លេយ៍ ។

**(២៤)** ឈួន លីកភ័យ (ชวน หลีกภัย Chuan Leekpai) តាមភាសាសៀម ថា /**ឈួន លីក-ផៃ**/) ។

**(២៥)** ដកស្រង់ចេញពីការកត់ត្រារបស់ខ្ញុំ (អ្នកនិពន្ធ) ពីការផ្សាយសុន្ទរកថាបន្តផ្ទាល់តាមទូរទស្សន៍លេខ ៧ នាថ្ងៃទី ២ កញ្ញា ឆ្នាំ ១៩៩២ ។ មានការសង្ស័យមួយចំនួនចំពោះអំណះអំណាងរបស់លោក ឈួន ដែលថា ការទាក់ទងរបស់គាត់បានបណ្ដាលឲ្យមានការអន្តរាគមន៍ដោយផ្ទាល់ពីរាជវាំងនៅថ្ងៃទី ២០ ឧសភា ។ ពីព្រោះលោក ឈួន មិនមែនជាមនុស្សតែម្នាក់គត់ដែលគាំទ្រអន្តរាគមន៍នោះទេ ។

**(២៦)** ពាន់សក្តិ វិញ្ញរ័តន៍ (พันศักดิ์ วิญญูรัตน์ Pansak Vinyarat) តាមភាសាសៀម ថា /**ផាន់សាក់ វិន-យ៉ៈរ៉ាត់**/ ។

**(២៧)** ជវលិត យ៉ុងចៃយុទ្ធ (ชวลิต ยงใจยุทธ Chavalit Yongchaiyudh) តាមភាសាសៀម ថា /**ឆ:វ៉ៈលិត យ៉ុង-ចៃយុត**/ ។

**(២៨)** គណបក្ស «ក្តីសង្ឃឹមថ្មី» ហាក់ដូចជាសង្ឃឹមបង្កើតឲ្យមានការបោះឆ្នោតជាទូទៅមួយ ដែលក្នុងនោះគណបក្សខ្លួនអាចនឹងឈ្នះ ។

**(២៩)** ស្នាន់ ខ្ជរប្រសាសន៍ (สนั่น ขจรประศาสน์ Sanan Kachornprasat) តាមភាសាសៀម ថា /**ស:ណាន់ ខ:ចន-ប្រ:សាត**/ ។

**(៣០)** សូមអានកាសែត **ណេឆាន់ស៊ុតសប្ដាហ៍** (เนชั่นสุดสัปดาห์ *Nation Weekend* ណេឆាន់ចុងសប្ដាហ៍) អត្ថបទរបស់លោក គជសីហ៍ អំពីការវិភាគ ដែលសំដៅសន្មតថា ជាអន្តរាគមន៍របស់លោក ប្រេម ។ លោក ស្នាន់ បានបញ្ជាក់ជាមួយរូបខ្ញុំថា គាត់មិនដែលបានពិភាក្សាជាមួយនឹងលោក ឈួន អំពីចលនានេះទេ ។

**(៣១)** លោក ជវលិត គឺជាអតីតអ្នកដឹកនាំក្រុមយោធាមួយហៅថា «ទាហានប្រជាធិបតេយ្យ» ។ រាជវាំងបានចាត់ទុកក្រុមនេះថា ជាអ្នកទោរទន់ទៅកាន់របបសាធារណរដ្ឋ ។

**(៣២)** បរ័ន្ហារ សិល្បអាជា (บรรหาร ศิลปอาชา Banharn Silp-archa) តាមភាសាសៀម ថា /**បាន់ហាន ស៊ិន-ឡ:-ប៉:អាឆា**/ ។

